# វិសុទ្ធិមគ្គ

និង

# បរមត្ថមញ្ជូសាមហាដីកា

## សមាធិនិទ្ទេស

## ភាគ ទី ៣



ប្រែរៀបរៀង
ដោយខ្ញុំបាទ អ៊ុម រ៉ៃយ៉ា

ព្រះទេសនារបស់ព្រះសាស្ដាជាហេតុនាំមកនូវការសម្រេច
ព្រះអរិយមគ្គ

បាត់ដំបង , ថ្ងៃ ១៥ កើត ខែ កត្តិក ព.ស ២៥៥២

# វិសុទ្ធិមគ្គ

និង

# បរមត្ថមញ្ជូសាមហាដីកា

## សមាធិនិទ្ទេស

## ភាគ ទី ៣



ប្រែរៀបរៀង

ដោយខ្ញុំបាទ អ៊ឹម រ៉ៃយ៉ា

ព្រះឱវាទរបស់ព្រះសាស្ដាជាហេតុនាំមកនូវការសម្រេច

ព្រះអរិយមគ្គ

បាត់ដំបង , ថ្ងៃ ១៥ កើត ខែ កត្តិក ព.ស ២៥៥២

# និទានវចនៈ

**វិសុទ្ធិមគ្គ** ជាបករណ៍វិសេស ដែលព្រះថេរៈ អ្នកស្រុកជម្ពូទ្វីប មានឈ្មោះ ពោះសំឡេងមួយរូប បានរចនាឡើង កាលព្រះពុទ្ធសាសនា កន្លងទៅបានប្រមាណ **១.០០០** ឆ្នាំ នៅកោះលង្កាទ្វីប ព្រះថេរៈរូបនេះ គឺ ព្រះពុទ្ធឃោសៈ ឯលោកក៏ បានរចនាគម្ពីរទុកជាច្រើន ក្នុងបវរនៃព្រះពុទ្ធសាសនា ជាការងារដ៏ធំ និងជាមរតក រហូតមកដល់សព្វថ្ងៃ ។ ការប្រែគម្ពីរព្រះត្រៃបិដក អដ្ឋកថា ពីភាសាសីហឡៈ មក ជាភាសាមគធៈ ឬ ភាសាបាលី ព្រះពុទ្ធឃោសៈបានប្រមូលធម៌ក្នុងព្រះត្រៃបិដក មកសម្ដែងទុកជាពួក ៗ តាំងពី **សីល សមាធិ** និង **បញ្ញា** តាមលំដាប់ ។

ឯការរៀបរៀងជាការតែងសំណួរ ឬ លំដាប់នៃការឆ្លើយសំណួរធម៌ក្នុង បច្ចុប្បន្ន គឺ អធិប្បាយសេចក្ដីសង្ខេបឲ្យពិស្ដារ បទសំណួររបស់ **វិសុទ្ធិមគ្គ** ពោល ដោយត្រៃសិក្ខា ដែលជាមាតិកាធំក្នុងព្រះពុទ្ធសាសនា បទសំណួរទាំងអស់ គឺជា បេះដូងនៃការបដិបត្តិតែម្យ៉ាង ព្រោះព្រះពុទ្ធឃោសៈ បានអធិប្បាយដោយវិចិត្រ ពិស្ដារ និងមានរបៀបរៀបរយ បានអាងព្រះពុទ្ធវចនៈជាអាគតដ្ឋានទុកក្នុងទីនោះ ៗ ទូទៅ នេះសម្ដែងឲ្យដឹងថា លោកមានការដឹងបែកធ្លាយក្នុងព្រះត្រៃបិដក អាចលើក យកធម៌ ដែលពោលដោយសីល មករួបរួមទុកក្នុងពួកសីល លើកយកធម៌ដែល ទាក់ទងជាមួយសមាធិ មករួបរួមទុកក្នុងពួកសមាធិ លើកយកធម៌ដែលទាក់ទងជា មួយបញ្ញា មករួមទុកជាមួយពួកបញ្ញា ដោយចែកជានិទ្ទេស ៗ រួមទាំងអស់មាន **២៣** និទ្ទេស , រីឯប្រវត្តិនៃការតែងវិសុទ្ធិមគ្គ ក៏បានក្លាយជាការប្រឡងដេញដោល , ព្រោះព្រះថេរៈ ជាអ្នកស្រុកសីហឡៈ បានផ្ដើមបញ្ហាឲ្យលោកតែងជាមុន កាលបើ លោកធ្វើបានជាទីពេញចិត្ត នឹងលើកគម្ពីរអដ្ឋកថាភាសាសីហឡៈ ឲ្យលោកប្រែជា

ភាសាមគធៈតទៅ ព្រះពុទ្ធឃោសាចារ្យបានធ្វើយ៉ាងរហ័ស និងល្អក្រៃលែង ជាទីពេញចិត្តរបស់ព្រះថេរៈអ្នកស្រុកសីហឡៈទាំងពួង , ដូច្នោះ គម្ពីរវិសុទ្ធិមគ្គនេះ ជាវិជ្ជានិពន្ធ ដើម្បីសាកល្បងចំណេះដឹងរបស់ព្រះពុទ្ធឃោសៈនោះ ។

ព្រះពុទ្ធឃោសៈ មានដើមកំណើតនៅប្រទេសឥណ្ឌា នាតំបន់ពុទ្ធគយាបានសិក្សាជំនាញនៅក្នុងព្រះពុទ្ធវចនៈ ទ្រទ្រង់ព្រះត្រៃបិដក មានបញ្ញាដ៏ក្រៃលែង លោកបានធ្វើដំណើរទៅលង្កាទ្វីប ក្នុងរវាងពុទ្ធសករាជ **៩៥០-១០០០** ហើយបានរចនាគម្ពីរវិសុទ្ធិមគ្គនៅទីនោះ និងប្រែ **ព្រះបាលី-អដ្ឋកថា** ពីភាសាសីហឡៈ មកជាភាសាមគធៈ - ភាសាបាលី ។

គម្ពីរវិសុទ្ធិមគ្គនេះបានរចនាដោយ

**ព្រះពុទ្ធឃោសាចារ្យ**

# ព្រះធម្មបាលត្ថេរ

## ព្រះថេរៈជាអ្នករចនា

## ព្រះគម្ពីរបរមត្ថមញ្ជូសាមហាដីកាវិសុទ្ធិមគ្គ

ខ្ញុំម្ចាស់ ( ព្រះធម្មបាលត្ថេរ ) ដែលព្រះទាដ្ឋានាគត្ថេរ ជាអ្នកមានសីល និងអាចារៈដល់ព្រមហើយ មានបញ្ញាជាគ្រឿងទ្រទ្រង់ មានការប្រព្រឹត្តបរិសុទ្ធ មានចិត្តតាំងមាំ អារាធនាហើយ ។ សូមថ្វាយវន្ទា ព្រះពុទ្ធជាម្ចាស់ ប្រៀបដូចជា ព្រះអាទិត្យ ទ្រង់មានព្រះសទ្ធម្មដូចជាកួងរស្មី ទ្រង់កម្ចាត់ងងឹត គឺ មោហៈធំអស់ហើយ ទ្រង់ញ៉ាំងពួកវេនេយ្យសត្វ ដែលប្រៀបដូចជាផ្កាឈូក ឲ្យដឹងវិសេស ទ្រង់មានព្រះបញ្ញាគុណដ៏វិសេស ដូចដួងព្រះអាទិត្យ មានព្រះវិសុទ្ធិគុណ និង ព្រះករុណាគុណ ដូចជាពន្លឺអរុណដែលមិនមានភាពសៅហ្មង រះឡើងក្នុងលោក គួរដល់ការបូជា សូមថ្វាយវន្ទាព្រះធម៌ដែលបំភ្លឺដល់លោក រុងរឿងដោយរស្មី គឺ ព្រះគុណ និងសូមនមស្ការព្រះអរិយសង្ឃដែលដូចជាផ្កាឈូកបរិសុទ្ធហើយ ដោយតេជះនៃបុណ្យ ចំពោះការថ្វាយវន្ទាព្រះរតនត្រ័យដែលកើតឡើងហើយ ដោយប្រការនោះៗ សូមប្រាសចាកអន្តរាយក្នុងទីគ្រប់ស្ថាន ខ្ញុំម្ចាស់នឹងអាស្រ័យបោរាណកថាមគ្គ ដើម្បីពណ៌នាខ្លឹមសារនៃបករណ៍វិសេស ឈ្មោះ **វិសុទ្ធិមគ្គ** ដែលប្រដាប់ដោយន័យដ៏បរិសុទ្ធ មានលំដាប់បទយ៉ាងប្រណីត ដែលព្រះអាចារ្យពុទ្ធឃោសៈបានពោល ដើម្បីជាឧបាយក្នុងការសម្រេចភាពបរិសុទ្ធិ ដែលលោកជា **នាថ** មានព្រះចរិយាបរិសុទ្ធ មានហឫទ័យដែលព្រះករុណាឲ្យឧស្សាហ៍ហើយ លោកបានសម្រេចហើយសម្ដែងទុក មិនឲ្យខុសពីលទ្ធិរបស់ព្រះថេរៈឯសម្នាក់មហាវិហារ ឲ្យបរិសុទ្ធយ៉ាងល្អ មិនរាត់រាយ មានវិនិច្ឆ័យសេចក្ដីដ៏សុខុម ឲ្យបរិសុទ្ធ និង ប្រកបដោយរបៀប

រៀបរយ ។

សូមសាធុជនទាំងឡាយ តាំងចិត្តសិក្សានូវខ្លឹមសារនៃព្រះវិសុទ្ធិមគ្គ នោះឯង របស់ខ្ញុំម្ចាស់ ដែលប្រាថ្នាឲ្យព្រះសទ្ធម្មតាំងនៅអស់កាលយូរដោយប្រការដូច្នេះចុះ។

**ព្រះធម្មបាលត្ថេរ** ជាជនជាតិស្រីលង្កា លោកបានសិក្សានៅក្នុងសំណាក់មហាវិហារ នាក្រុងអនុរាធបុរៈក្នុងលង្កាទ្វីប បានចូលរួមរចនាគម្ពីរអដ្ឋកថា ជាមួយព្រះពុទ្ធឃោសាចារ្យដែរ , លោកបានរចនាអដ្ឋកថា និង មហាដីកា ទើបបានទទួលការលើកសរសើរថាជា **ព្រះអដ្ឋកថាចារ្យ** និង **ព្រះដីកាចារ្យ** នៅកោះលង្កាទ្វីប ក្នុងរវាង ពុទ្ធសករាជ **៩៥០ - ១០០០** ។

គម្ពីរបរមត្ថមញ្ជូសាមហាដីកានេះរចនាដោយ

**ព្រះធម្មបាលត្ថេរ**

# អារម្ភកថា

ការប្រែរៀបរៀងឡើងនូវ **គម្ពីរវិសុទ្ធិមគ្គ** ដែលពន្យល់ដោយគម្ពីរ **បរមត្ថមញ្ជូសាមហាដីកា** យើងខ្ញុំបានរៀបរៀងដោយល្អមកជាខេមរភាសា និងរៀបរៀងទៅតាមលំដាប់នៃមាតិកានីមួយ ៗ យ៉ាងផ្ចិតផ្ចង់បំផុត មិនឲ្យឃ្លៀងឃ្លាតពីច្បាប់ដើម ដើម្បីជាប្រយោជន៍ដល់កុលបុត្តអ្នកជ្រះថ្លាក្នុងព្រះរតនត្រ័យ និង ជាពិសេសដើម្បីជាប្រយោជន៍ដល់ការសិក្សាផងខ្លួន ។

សូមសាធុជនទាំងឡាយ ដែលមានចិត្តភក្តី ចំពោះព្រះរតនត្រៃ អនុមោទនានូវបុណ្យរបស់ខ្ញុំ ដែលសម្រេចហើយដោយប្រការយ៉ាងនេះ ។

សូមធម្មទាននេះ សម្រេចដល់មាតាបិតា ជាព្រះអរហន្តបច្ចុប្បន្ន ព្រមទាំងអតីតកាលរបស់ខ្ញុំផង ពួកញាតិក្នុងសង្សារវដ្តផង និង សព្វសត្វក្នុងលោកទាំង ៣ ផង លោកគ្រូបណ្ឌិតទាំងពីរ គឺ ៖

លោកគ្រូ អគ្គបណ្ឌិតធម្មាចារ្យ **ប៊ុត សាវង្ស** ផង

លោកគ្រូ បណ្ឌិតធម្មាចារ្យ **រស់ សុជាត** ផង

ដែលលោកទាំងពីរជាអាចារ្យរបស់ខ្ញុំ ជាអ្នកមានសីល មានចរិយាបរិសុទ្ធ , យើងខ្ញុំអាស្រ័យបណ្ឌិតទាំងពីររូបនេះ ទើបបានសិក្សានូវព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធ ក្នុងបដិបទាដ៏ត្រង់តែមួយគត់ គឺ **សតិប្បដ្ឋាន ៤** ប្រព្រឹត្តទៅដើម្បីវិសុទ្ធិ គឺ **ព្រះនិព្វាន** ។

បាត់ដំបង ថ្ងៃ ១៥កើត ខែកត្តិក ព.ស ២៥៥២

**ដោយ ហាយ ចំរើន-អ៊ុម រ៉ៃយ៉ា**

# មាតិកាធម៌

**មាតិកា** **លេខទំព័រ**

## អនុស្សតិកម្មដ្ឋាននិទ្ទេស

## ១-អានាបានស្សតិកម្មដ្ឋាន

### -ចតុក្កៈទី ១


- អធិប្បាយព្រះបាលី .................................................. ៤
- បទថា អសេចនកោ .................................................. ១១
- អធិប្បាយ ឥធ ស័ព្ទ .................................................. ១៦
- អរញ្ញគតោ ន័យទី ១-២-៣ ...................................... ១៧
- ពាក្យថា សតោការី.................................................. ២៧
- បទថា អស្សាសបស្សាសៈ ...................................... ២៨
- អានាបានស្សតិជាកាយានុបស្សនាសតិប្បដ្ឋាន............... ៣០
- បទថា សព្វកាយប្បដិសំវេទី ...................................... ៤៣
- បទថា បស្សម្ភយំ កាយសង្ខារំ ................................ ៥៥
- ខ្យល់ដង្ហើមគ្រោតគ្រាត-ល្អិត សមថន័យ..................... ៦០
- ខ្យល់ដង្ហើមគ្រោតគ្រាត-ល្អិត វិបស្សនាន័យ................ ៦៤
- អធិប្បាយ ក្នុងបដិសម្ភិទាមគ្គ ...................................... ៦៥

- វិធីហ្វឹកហាត់ ........................................ ៦៨
- វិធីមនសិការ ........................................ ៦៩
- គណនា - វិធីរាប់ ........................................ ៧០
- អនុពន្ធនា - វិធីជាប់តាមខ្យល់ ........................................ ៧៩
- លក្ខណៈផ្សេងពីកម្មដ្ឋានដទៃ ........................................ ៨៤
- ឧបាយនាំខ្យល់មកវិញ ........................................ ៨៥
- និមិត្តប្រាកដផ្សេងគ្នា ........................................ ៨៩
- **ចតុក្កៈទី ២** ........................................ ១១១
- **ចតុក្កៈទី ៣** ........................................ ១២១
- **ចតុក្កៈទី ៤** ........................................ ១២៨
- អនិច្ចានុបស្សី ........................................ ១២៨
- វិរាគានុបស្សី - បដិនិស្សគ្គានុបស្សី ........................................ ១២៩
- អានិសង្សនៃអានាបានស្សតិ ........................................ ១៣៦

## ២ – ឧបសមានុស្សតិ

- អធិប្បាយ អត្ថព្រះបាលី ........................................ ១៤២
- អានិសង្សនៃឧបសមានុស្សតិ ........................................ ១៥០

## ព្រហ្មវិហារនិទ្ទេស

**៣ – មេត្តាព្រហ្មវិហារ** ........................................ ១៥២

- បុគ្គលដែលជាទោសដល់ភាវនា ៦ ........................ ១៥៣
- ចម្រើនមេត្តាចំពោះខ្លួនឯងមុន ........................ ១៦១
- ចម្រើនមេត្តារួមដែន ........................ ១៦៧
- ការទូន្មានខ្លួនកាលកើតបដិឃៈ ន័យទី១-៨ ........................ ១៧១
- សីមាសម្ភេទ-រួមដែន........................ ១៩០
- មេត្តាឈាន ........................ ២០៩
- អធិប្បាយបាលី អប្បមញ្ញា ........................ ២១០
- អត្ថនៃ វិកុព្វនា ........................ ២១២
- អធិប្បាយអត្ថនៃ សព្វេ សត្តា ........................ ២១៦
- អប្បនា ........................ ២១៨
- អត្ថនៃមេត្តានិសង្ស........................ ២៣៧

## ៤–ករុណាព្រហ្មវិហារ ........................ ២៤៤

## ៥–មុទិតាព្រហ្មវិហារ ........................ ២៥៤

## ៦–ឧបេក្ខាព្រហ្មវិហារ ........................ ២៦០

- បកិណ្ណកកថាអំពីព្រហ្មវិហារនិទ្ទេស ........................ ២៦៩
- វិនិច្ឆ័យអំពីលក្ខណៈជាដើម ........................ ២៧០
- សត្រូវជិត និងឆ្ងាយ ........................ ២៧២
- អប្បមញ្ញាមានអានុភាពផ្សេងគ្នា ........................ ២៨៤
- អប្បមញ្ញាធ្វើកល្យាណធម៌ឲ្យបរិបូរណ៍ ........................ ២៨៦

# អារុប្បនិទ្ទេស

**៧ – អាកាសានញ្ចាយតនៈ** .......................................... ៣២៥

- ការបើកកសិណ ....................................................... ៣២៧
- ឧបចារៈ និង អប្បនា ............................................... ៣២៨
- អធិប្បាយ រូបសញ្ញានំ ............................................... ៣៣០
- អធិប្បាយ សមតិក្កមា ( ឈានកន្ទង ) .................... ៣៣១
- អធិប្បាយ បដិឃសញ្ញានំ អត្ថង្គមា ........................... ៣៣២
- អធិប្បាយ នានត្តសញ្ញានំ អមនសិការា ..................... ៣៣៤

**៨ – វិញ្ញាណញ្ចាយតនៈ** ............................................... ៣៥៥

**៩ – អាកិញ្ចញ្ញាយតនៈ** .................................................. ៣៦៤

**១០ – នេវសញ្ញានាសញ្ញាយតនៈ** ................................... ៣៩៨

- បកិណ្ណកកថា អំពីអារុប្បនិទ្ទេស ................................ ៣៩៨

# អនុស្សតិកម្មដ្ឋាននិទ្ទេស

--------◎--------

## អានាបានស្សតិ

អានាបានស្សតិកម្មដ្ឋាននោះ ដែលព្រះមានព្រះភាគជាម្ចាស់ ទ្រង់សរសើរទុកយ៉ាងនេះថា “ **ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះ បុគ្គលធ្វើឲ្យមាន ធ្វើឲ្យច្រើនហើយ រមែងជាធម៌ស្ងប់ផង ប្រណីតផង ជាធម៌ដែលជាទីអាស្រ័យមិនរើករាផង ជាសុខផង ញុំាំងធម៌ជាបាបអកុសលទាំងឡាយដែលកើតឡើងហើយ ឲ្យវិនាសស្ងប់រម្ងាប់ទៅដោយរហ័សផង** ” ដូច្នេះឯង ហើយទ្រង់ត្រាស់ចែកឲ្យជាកម្មដ្ឋាន មានវត្ថុ ១៦ យ៉ាង យ៉ាងនេះថា “ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ បុគ្គលធ្វើឲ្យមានដូចម្ដេច ធ្វើឲ្យច្រើនដូចម្ដេច ទើបជាធម៌ស្ងប់ផង ប្រណីតផង ជាទីអាស្រ័យដែលមិនរើករាផង និង ជាសុខផង ញុំាំងធម៌ដែលជាបាបអកុសលទាំងឡាយ ដែលកើតឡើងហើយ ឲ្យវិនាស ស្ងប់រម្ងាប់ទៅវិញដោយរហ័សផង ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ទៅកាន់ព្រៃ ឬ គល់ឈើ ឬ ផ្ទះស្ងាត់ក៏ដោយ អង្គុយពត់ភ្នែន តាំងកាយឲ្យត្រង់ មានសតិចំពោះមុខ ជាអ្នកមានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល មានវត្ថុ ១៦ គឺ ៖

### ចតុក្កៈទី ១

១- កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬ កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។

២- កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង ឬ កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។

៣- ភិក្ខុសិក្សាថា យើងនឹងកំណត់ដឹងច្បាស់នូវកាយសង្ខារ ហើយដកដង្ហើមចេញ សិក្សាថា យើងនឹងកំណត់ដឹងច្បាស់នូវកាយសង្ខារ ហើយដកដង្ហើមចូល ។

៤- ភិក្ខុសិក្សាថា យើងនឹងរម្ងាប់កាយសង្ខារ ហើយដកដង្ហើមចេញ សិក្សាថា យើងនឹងរម្ងាប់កាយសង្ខារ ហើយដកដង្ហើមចូល ។

## ចតុក្កៈទី ២

៥- ភិក្ខុសិក្សាថា យើងនឹងជាអ្នកកំណត់ដឹងច្បាស់នូវបីតិ ដកដង្ហើមចេញ សិក្សាថា យើងនឹងជាអ្នកកំណត់ដឹងច្បាស់នូវបីតិដកដង្ហើមចូល ។

៦- ភិក្ខុសិក្សាថា យើងនឹងជាអ្នកកំណត់ដឹងច្បាស់នូវសុខ ដកដង្ហើមចេញ សិក្សាថា យើងនឹងជាអ្នកកំណត់ដឹងច្បាស់នូវសុខ ដកដង្ហើមចូល ។

៧- ភិក្ខុសិក្សាថា យើងនឹងជាអ្នកកំណត់ដឹងច្បាស់នូវចិត្តសង្ខារ ដកដង្ហើមចេញ សិក្សាថា យើងនឹងជាអ្នកកំណត់ដឹងច្បាស់នូវចិត្តសង្ខារ ដកដង្ហើមចូល ។

៨- ភិក្ខុសិក្សាថា យើងនឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចេញ សិក្សាថា យើងនឹងជាអ្នករម្ងាប់នូវចិត្តសង្ខារ ដកដង្ហើមចូល ។

## ចតុក្កៈទី ៣

៩- ភិក្ខុសិក្សាថា យើងនឹងជាអ្នកកំណត់ដឹងច្បាស់នូវចិត្ត ដកដង្ហើមចេញ សិក្សាថា យើងនឹងជាអ្នកកំណត់ដឹងច្បាស់នូវចិត្តដកដង្ហើមចូល ។

១០- ភិក្ខុសិក្សាថា យើងនឹងជាអ្នកញ៉ាំងចិត្តឲ្យរីករាយ ដកដង្ហើមចេញ សិក្សាថា យើងនឹងជាអ្នកញ៉ាំងចិត្តឲ្យរីករាយ ដកដង្ហើមចូល ។

១១- ភិក្ខុសិក្សាថា យើងនឹងតម្កល់ចិត្ត ដកដង្ហើមចេញ សិក្សាថា យើងនឹងតម្កល់ចិត្ត ដកដង្ហើមចូល ។

១២- ភិក្ខុសិក្សាថា អាត្មាអញនឹងរដោះចិត្តចេញ ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងរដោះចិត្តចេញ ដកដង្ហើមចូល ។

## ចតុក្កៈទី ៤

១៣- ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញថា មិនទៀង ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញថា មិនទៀង ដកដង្ហើមចូល ។

១៤- ភិក្ខុសិក្សាថា អាត្មាអញនឹងពិចារណាឃើញនូវការប្រាសចាកតម្រេក ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការប្រាសចាកតម្រេក ដកដង្ហើមចូល ។

១៥- ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការរលត់ ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការរលត់ ដកដង្ហើមចូល ។

១៦- ភិក្ខុសិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការរលាស់ចេញ ដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងជាអ្នកពិចារណាឃើញនូវការរលាស់ចេញ ដកដង្ហើមចូល យ៉ាងនេះ ។

ឥឡូវនេះ និទ្ទេសនៃការចម្រើនអានាបានស្សតិកម្មដ្ឋាននោះ មកដល់ហើយតាមលំដាប់ តែព្រោះនិទ្ទេសនោះ គប្បីពោលទៅតាមគន្លងព្រះបាលីនោះ ទើបបរិបូរណ៍ដោយអាការទាំងពួង ព្រោះហេតុនោះ និទ្ទេសក្នុងអានាបានស្សតិកម្មដ្ឋាននោះ ទើបជានិទ្ទេសយោងព្រះបាលីជាខាងដើម ។

## អធិប្បាយព្រះបាលី

បណ្ឌិតគប្បីជ្រាបនិទ្ទេស នៃព្រះបាលីបុច្ឆាថា " **កថំ ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ បុគ្គលធ្វើឲ្យមានហើយ ដូចម្ដេច ?** " ជាដើមសិន , ពាក្យថា **កថំ** ជាព្រះបុច្ឆាដែលទ្រង់ប្រាថ្នានឹងត្រាស់នូវការចម្រើនអានាបានស្សតិសមាធិ ឲ្យពិស្ដារដោយប្រការផ្សេងៗ ពាក្យតទៅថា **ភាវិតោ ច ភិក្ខវេ អានាបានស្សតិសមាធិ** ជាពាក្យទ្រង់បង្ហាញដល់ធម៌ដែលទ្រង់បានត្រាស់ទុក ព្រោះទ្រង់មានព្រះបំណងត្រាស់ឲ្យពិស្ដារដោយប្រការផ្សេងៗ ។

សូម្បីក្នុងពាក្យថា **កថំ ពហុលីកតោ ។ បេ ។ វូបសមេតិ** " នោះ ក៏មានន័យដូចគ្នា ។

ក្នុងបទទាំងឡាយនោះ បទថា **ភាវិតោ - ធ្វើឲ្យមាន** នោះគឺ ធ្វើឲ្យកើតឡើង ឬ ចម្រើនឡើង ។ បទថា **អានាបានស្សតិសមាធិ** ប្រែថា សមាធិដែលសម្បយុត្តជាមួយសតិ ក្នុងការកំណត់ខ្យល់ដង្ហើមចេញ ខ្យល់ដង្ហើមចូល ( ជាអារម្មណ៍ ) , ន័យម្យ៉ាងទៀត **សមាធិក្នុងអានាបានស្សតិ** ឈ្មោះថា អានាបានស្សតិសមាធិ ។ បទថា **ពហុលីកតោ - ធ្វើឲ្យច្រើន** គឺ ធ្វើរឿយៗ ។

២ បទថា **សន្តោ ចេវ បណីតោ ច** នោះ គប្បីអធិប្បាយថា **សន្តោ ចេវ បណីតោ ច - ស្ងប់ផង ប្រណីតផង** គប្បីជ្រាបថា ការកំណត់សេចក្តីដោយ **ឯវ** សព្ទ មានទាំង ២ បទ , សួរថា ព្រះពុទ្ធាធិប្បាយ មានដូចម្តេច ? ឆ្លើយថា ព្រះពុទ្ធាធិប្បាយមានថា " អានាបានស្សតិសមាធិនេះ ជាធម្មជាតិមិនស្ងប់ មិនប្រណីតដោយបរិយាយណា ដូចអសុភកម្មដ្ឋាន ដែលស្ងប់ ដែលប្រណីតចំពោះក្នុងបដិវេធតែម្យ៉ាង តែមិនស្ងប់មិនប្រណីតក្នុងអារម្មណ៍ឡើយ ព្រោះមានអារម្មណ៍គ្រោតគ្រាត ទាំងមានវត្ថុបដិកូលជាអារម្មណ៍ ដូច្នោះក៏ទេ សេចក្តីពិត ធម៌ដែលឈ្មោះថា ស្ងប់ ហើយរៀបរយ ត្រជាក់ ក៏ព្រោះទាំងស្ងប់ដោយអារម្មណ៍ និងទាំងស្ងប់ដោយអង្គ គឺ ដែលហៅថា បដិវេធ , ឈ្មោះថា **ប្រណីត** គឺ មិនធ្វើឲ្យធុញ ព្រោះទាំងប្រណីតដោយអារម្មណ៍ និងប្រណីតដោយអង្គ " ដូច្នេះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា " **អានាបានស្សតិជាធម៌ស្ងប់ផង ប្រណីតផង** " ។

# មហាដីកា

## អធិប្បាយ អានាបានស្សតិ

ក្អាប់សេចក្តីថា **អានាបានស្សតិកម្មដ្ឋាន** ព្រះមានព្រះភាគត្រាស់សរសើរយ៉ាងនេះហើយ ទ្រង់ត្រាស់សម្តែងអធិប្បាយទុកយ៉ាងនេះ ទុំៈ , ក្នុងពាក្យទាំងឡាយនោះ កាលទឹងបើកផ្ទារអត្ថនៃព្រះបាលី ដែលជាសំណួរ មានពាក្យថា **កថំ ភាវិតោ** ជាដើមហើយ គឺ បានបើកផ្ទារព្រះបាលី អត្ថនៃព្រះបាលី ជាពាក្យសរសើរសុទ្ធសាធ ព្រោះមិនមានសេចក្តីផ្សេងគ្នា , ដូច្នោះ លោកអាចារ្យ ទើប

កន្លងអត្ថនៃព្រះបាលី ដែលជាពាក្យសរសើរនោះចេញ ហើយផ្តើមពាក្យថា **កថំ ភាវិតោ ច** ដូច្នេះជាដើម ។ ក្នុងបណ្តាពាក្យទាំងឡាយនោះ ភាពជាកម្មដ្ឋានដែលទ្រង់ត្រាស់សរសើរ និង ពាក្យថា **អយម្បិ ខោ** ចាត់ជាការផ្សេងគ្នាអំពីកម្មដ្ឋាននេះ ។ ក្នុងបណ្តាសេចក្តីដែលផ្សេងគ្នានោះ លោកអាចារ្យបំណងសម្តែងភាពជាកម្មដ្ឋាន ដែលទ្រង់ត្រាស់សរសើរ ទើបពោលថា " ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរ " ដូច្នេះ ។ ពាក្យត្រាស់សរសើរ មានការធ្វើឲ្យមានឧស្សាហ៍ ( ឲ្យយកចិត្តទុកដាក់ ) ជាប្រយោជន៍ ព្រោះធ្វើឲ្យគាប់ចិត្តកាន់តែខ្លាំងឡើងក្នុងអានាបានស្សតិកម្មដ្ឋាន នុ៎ះ ។ ពិតហើយ ភិក្ខុទាំងឡាយ ស្តាប់ព្រះតម្រាស់សរសើរនោះហើយ ក៏ជាអ្នកមាននូវការពេញចិត្តយ៉ាងក្រៃលែង ដោយគិតថា " ព្រះមានព្រះភាគ ត្រាស់សរសើរសមាធិនេះ ដោយអនេកបរិយាយ , ក្នុងន័យថា សមាធិនេះស្ងប់ផង សមាធិនេះប្រណីតផង រៀបរយផង ជាសុខវិហារផង ញុំាំងធម៌ដែលឃើតយូរទាំងឡាយឲ្យអន្តរធានទៅដោយរហ័សផង " ដូច្នេះ ជាអ្នកមានឧស្សាហ៍ហើយ នឹងសម្គាល់ថា ជាកម្មដ្ឋានដែលគប្បីប្រកបរឿយៗ គប្បីបដិបត្តិដោយយ៉ាងគោរព ។ សម្រាប់បទថា **អយម្បិ ខោ** បណ្ឌិតគប្បីជ្រាបសេចក្តីដោយការសម្ពន្ធជាគន្លងផ្លូវថា ព្រះមានព្រះភាគ កាលទ្រង់ធ្វើសមាធិដែលជាធម្មជាតិដែលទ្រង់ ព្រះអង្គឯង ឃើញប្រចក្សហើយ ឲ្យឋិតនៅក្នុងទីជិត ឃើញបានប្រចក្ស ដល់ភិក្ខុទាំងឡាយនោះ ដោយអានុភាពនៃព្រះធម៌ទេសនា ទើបត្រាស់ទុក ដោយអំណាចការរួបរួម ( ដោយ **បិ** ស័ព្ទ ) យ៉ាងនេះថា សមាធិទាំងឡាយ មាន កសិណឈាន អសុភឈាន ជាដើម ជាកំពង់ចុះទៅកាន់ស្រះធំ គឺ ព្រះនិព្វាន ដែលតថាគតបានសម្តែងទុកយ៉ាងណា តថាគតក៏មិនបានសម្តែង

ទុកចំពោះតែសមាធិទាំងឡាយដទៃនោះ តែម្យ៉ាងប៉ុណ្ណោះទេ អានាបានស្សតិសមាធិនេះ ក៏តថាគតសម្តែងទុកដូចគ្នា ។

ពាក្យថា **មានវត្ថុ ១៦** គឺ មាន ១៦ ឋាន ទាក់ទងនឹងចតុក្កៈពួក ៤ , ៤ ចតុក្កៈ , ក្នុងបណ្តាអនុបស្សនា ៤ ( គឺ ក្នុងកាយានុបស្សនា ១ ចតុក្កៈ , ក្នុងវេទនានុបស្សនា ១ ចតុក្កៈ , ក្នុងចិត្តានុបស្សនា ១ ចតុក្កៈ , ក្នុងធម្មានុបស្សនា ១ ចតុក្កៈ ) ។ ពាក្យថា **បរិបូរណ៍ដោយអាការទាំងពួង** គឺ បរិបូរណ៍ដោយអាការទាំងពួង យ៉ាងនេះគឺ អត្ថនៃបទព្រះកម្មដ្ឋានបាលី អត្ថនៃពាក្យរូម ឧបមា សំណួរ ចម្លើយ ប្រយោជន៍ ដូច្នេះជាដើម ។ ពាក្យថា **និទ្ទេស** បានដល់ ពាក្យអធិប្បាយសេចក្តីនៃកម្មដ្ឋាន ដោយពិសេស ។

បទថា **កថំ - ដូចម្តេច** នេះជាបទបើកផ្ទារអាការដែលសួរ ។ ឯពាក្យសួរក្នុងព្រះបាលីនេះ ប្រព្រឹត្តទៅទាក់ទងជា កថេតុកម្យតាបុច្ឆា ( សួរដើម្បីនឹងឆ្លើយអង្គឯង ) ព្រោះមិនមែនពាក្យសួរក្នុងអាការដទៃ ។ លោកអាចារ្យកាលសម្តែងសេចក្តីនេះថា ពាក្យសួរនោះ ប្រព្រឹត្តទៅដោយអំណាចការលើកយកមកដោយអាការទាំងពួងដែលផ្សេងគ្នា គ្រប់ប្រការ ឲ្យឡើងកាន់ទេសនាដ៏កំពូល ដូច្នេះ ទើបពោលថា **កថេតុ ។ បេ ។ ... កម្យតាបុច្ឆា** ដូច្នេះ ។ សូម្បីក្នុងពាក្យថា **កថំ ពហុលីកតោ - ធ្វើឲ្យច្រើនដូចម្តេច** នេះ គប្បីនាំបទថា **អានាបា-នស្សតិសមាធិ** ចូលមកភ្ជាប់ផង ( ជា **កថំ ពហុលីកតោ អានាបានស្សតិសមាធិ** ) ក្នុងបទទាំងឡាយនោះ បទថា **កថំ** ជាពាក្យសួរដោយព្រះបំណង ដើម្បីទ្រង់អធិប្បាយឲ្យពិស្តារ នូវការចម្រើនអានាបានស្សតិសមាធិ ដោយប្រការផ្សេងៗ ។ ដោយបទថា **ឯសេវ នយោ - មានន័យដូច្នេះ** នេះ ទ្រង់បំណងភ្ជាប់សេចក្តីថា

ពាក្យថា **ពហុលីកតោ អានាបានស្សតិសមាធិ** ជាការសម្តែងធម៌ដែលទ្រង់បានសួរហើយ យ៉ាងនោះ ។ សេចក្តីនោះយ៉ាងណា លោកអាចារ្យបំណាងសម្តែងថា សភាពជាធម្មជាតិដែលស្ងប់ជាដើម នៃអានាបានស្សតិសមាធិនោះ គប្បីកាន់យកបាន ក៏ព្រោះការធ្វើឲ្យកើតឡើង និងការធ្វើឲ្យចម្រើន ដែលជាហេតុឲ្យសម្រេចនោះឯង ដូច្នោះ ទើបពោលថា សូម្បីក្នុងពាក្យថា **កថំ ពហុលីកតោ ។ បេ ។ វូបសមេតិ** នេះ មានន័យដូច្នេះឯង ។

លោកអាចារ្យ កាលសម្តែងអធិប្បាយ ( ពាក្យថា **ភាវិតោ** ) ដោយទាក់ទងក្នុង ២ ន័យ ទុំះថា ហៅថា **ភាវនា** ព្រោះសំដៅយកការធ្វើឲ្យកើតឡើង និងចម្រើន ដូចក្នុងប្រយោគថា “ **ម្នាលឧទាយី សេចក្តីដទៃនៅមានទៀត បដិបទាសម្រាប់សាវកទាំងឡាយ តថាគតបានពោលទុក ក្នុងប្រការដែលសាវកអ្នកបដិបត្តិទាំងឡាយរបស់តថាគត គប្បីធ្វើសតិប្បដ្ឋាន ៤ ឲ្យកើតឡើង** ” ដូច្នេះជាដើម , ទើបពោលថា បទថា **ភាវិតោ** ប្រែថា ធ្វើឲ្យកើតឡើង ឬ ចម្រើន ។ ក្នុងបទទាំងឡាយនោះ **អានាបានស្សតិសមាធិ** ឈ្មោះថា **ភាវិតោ** ព្រោះអត្ថថា ទៅ គឺ ដល់នូវការៈ គឺ មានប្រាកដ បានដល់ ធ្វើឲ្យកើតឡើង មានន័យថា ជាសមាធិដែលគប្បីធ្វើឲ្យបានមក ។ រីឯ សមាធិដែលកើតឡើងហើយ បាននូវការសេពស្និទ្ធហើយ ក៏ឈ្មោះថា **ភាវិតោ** គឺ ធ្វើឲ្យដល់នូវការស្ទាត់ជំនាញបានហើយ មានន័យថា ចម្រើនហើយ ។ ពាក្យថា **( ដែលសម្បយុត្តជាមួយ ) សតិកំណត់នូវខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ** មានន័យថា ( សម្បយុត្តជាមួយ ) សតិដែលជាបច្ច័យ ក្នុងការកំណត់ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ គឺ ប្រព្រឹត្តទៅប្រារព្ធខ្យល់ទាំងនោះ ព្រមទាំងភាពផ្សេងគ្នា មាន វែង និង ខ្លី ជាដើម ។ ក្នុង

អត្ថខាងដើម ( ដែលថា **អានាបានស្សតិសមាធិ** បានដល់ សមាធិសម្បយុត្ត ជាមួយសតិ ដែលកំណត់ខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ ) ទ្រង់ពោល ដល់ការៈដែលសតិជាបច្ច័យ ដោយសហជាតប្បច្ច័យជាដើមដល់សមាធិ ) ដោយ ពាក្យពោលថា **សម្បយុត្ត** , រីឯ ក្នុងអត្ថទី ២ ( ដែលថា **សមាធិ** ក្នុង **អានាបានស្សតិ** ឈ្មោះថា **អានាបានស្សតិសមាធិ** ) ទ្រង់ពោលក្នុងការៈដែល សតិជាបច្ច័យដោយឧបនិស្សយប្បច្ច័យដល់សមាធិ ។ ពិតហើយ សតិដែល សហគតៈដោយឧបចារឈាន រមែងជាឧបនិស្សយប្បច្ច័យដល់អប្បនាសមាធិ ។ បទថា **ពហុលីកតោ - ការធ្វើ ឲ្យច្រើន** គឺ ធ្វើឲ្យប្រព្រឹត្តទៅដោយច្រើន , ដោយបទថា **ពហុលីកតោ** នោះ ទ្រង់ត្រាស់ដល់ការសម្រេចនូវវសី មាន **អាវជ្ជនវសី** ( ជំនាញក្នុងការនឹក ) ជាដើម ។ ពិតហើយ សមាធិណា ព្រះ យោគាវចរធ្វើឲ្យដល់នូវភាពជាវសីបានហើយ សមាធិនោះ ឈ្មោះថា ត្រូវព្រះ យោគាវចរធ្វើឲ្យប្រព្រឹត្តទៅរឿយៗបាន ព្រោះព្រះយោគាវចរគប្បីចូលបានគ្រប់ៗ ខណៈដែលត្រូវការ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា គឺ **ធ្វើ រឿយ ៗ** ដូច្នេះ ។ **ឯវ** ស័ព្ទ ទ្រង់ត្រាស់ទុក ក្នុងបទថា ក្នុងប្រយោគ មាន យ៉ាងនេះថា **សមណៈទី១ មាននៅក្នុងធម្មវិន័យនេះ តែប៉ុណ្ណោះ** និងថា **ស្ងាត់ ចាកកាមទាំងឡាយហើយ** ដូច្នេះជាដើម ក៏ឈ្មោះថា ទ្រង់ត្រាស់ក្នុងបទទី ២ ជាដើមផងដែរ យ៉ាងណា , សូម្បី **ឯវ** ស័ព្ទ ទ្រង់ត្រាស់ទុកក្នុងវគ្គដំបូងថា **សន្តោចេវ - ស្ងប់ផង** នេះក៏ឈ្មោះថា ទ្រង់បានត្រាស់ទុកក្នុងបទ ទី ២ ថា **បណីតោចេវ - ប្រណីតផង** យ៉ាងនោះឯង ព្រោះហេតុនោះ លោកអាចារ្យទើប ពោលថា គប្បីឃើញថា មានការប្រើ **ឯវ** ស័ព្ទ កំណត់ច្បាស់លាស់ក្នុងបទ

ទាំង២ ដូច្នេះឯង ។ លោកបំណងសម្តែងគុណដែលបាន ដោយការប្រើ **ឯវ** ស័ព្ទ កំណត់ច្បាស់លាស់ក្នុងបទទាំង ២ ទើបពោលថា **អយញ្ហិ** ដូច្នេះជាដើម ។

លោកពោលដល់ឈានដែលមានអសុភនិមិត្តជាអារម្មណ៍ថា អសុភកម្មដ្ឋាន ពិតហើយ ឈានដែលមានអសុភនិមិត្តជាអារម្មណ៍ លោកហៅថា អសុភកម្មដ្ឋាន ព្រោះកើតពីការបំពេញសេចក្តីព្យាយាមក្នុងសាកសពអសុភទាំងឡាយ និងព្រោះជាហេតុនៃសេចក្តីសុខវិសេសរបស់ព្រះយោគី ។ ដោយពាក្យថា **កេវលំ - តែម្យ៉ាង** នេះ លោកហាមអារម្មណ៍ ។ ពាក្យថា **ទាក់ទងនឹងបដិវេធធម៌** គឺ ទាក់ទងជាបដិវេធធម៌ បានដល់ ឈាន ។ ពិតហើយ ឈានដែលសម្រេចដោយភាវនាពិសេស រមែងប្រព្រឹត្តទៅដើម្បីចាក់ធ្លុះអារម្មណ៍របស់ខ្លួននោះឯង ហើយព្រះយោគី រមែងចាក់ធ្លុះបាន ដោយសភាវៈតាមសេចក្តីពិត ព្រោះហេតុនោះ ទើបហៅថា **បដិវេធ** ។ ពាក្យថា **ព្រោះមានអារម្មណ៍គ្រោតគ្រាត** គឺ ព្រោះមានអារម្មណ៍ គួរខ្ពើមរអើម ។ ពាក្យថា **ព្រោះមានអារម្មណ៍ជាបដិកូល** គឺ ព្រោះមានអារម្មណ៍គួររង្កៀស ។ ពាក្យថា **ដោយបរិយាយ** គឺ ដោយហេតុ ឬដោយចំណុចដទៃ ។ ពាក្យថា **ព្រោះមានអារម្មណ៍ស្ងប់** លោកពោលសំដៅយកភាវៈ ព្រោះអារម្មណ៍ល្អិតសុខុម តាមលំដាប់ ដល់នូវភាវៈដែលត្រូវសង្កេតពិនិត្យ ។ ធម៌ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ស្ងប់ គឺ នឹងថ្កល់ គឺ រមែងនឹងថ្កល់ដោយខ្លួនឯងតែម្យ៉ាង ។ ព្រោះហេតុនោះ ទើបលោកពោលថា **ជាធម្មជាតិដែលស្ងប់ គឺ រម្ងាប់ រលត់ ត្រជាក់ ដូច្នេះ** មានន័យថា រលត់ភាពក្តៅក្រហាយទាំងពួង ។ ភាវៈដែលស្ងប់នៃធម៌ទាំងឡាយ ដែលមានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ជាអារម្មណ៍ ព្រោះការដែលមានអារម្មណ៍ស្ងប់ បណ្ឌិតគប្បី

សម្តែងដោយបច្ចវេក្ខណញ្ញាណ ដែលមានលោកុត្តរធម៌ជាអារម្មណ៍ ( គឺ បច្ច-វេក្ខណញ្ញាណ ឈ្មោះថា ស្ងប់ ព្រោះមានលោកុត្តរធម៌ដែលស្ងប់ជាអារម្មណ៍ យ៉ាងណា អានាបានស្សតិសមាធិ ឈ្មោះថា ស្ងប់ ព្រោះមានខ្យល់ដង្ហើមដែលស្ងប់ គឺ ល្អិតសុខុមជាអារម្មណ៍ ក៏ដូច្នោះ ) ។

( ចប់ មហាដីកា )

## បទថា អសេចនកោ

រីឯ ក្នុងពាក្យថា **អសេចនកោ ច សុខោ ច វិហារោ** ធម៌ជាគ្រឿងនៅមិនរើករវ និង សុខដុមផង នោះ មានអធិប្បាយថា **សេចន - ភាពស្អិតល្អូត** មិនមានដល់អានាបានស្សតិសមាធិនោះ ព្រោះហេតុនោះ អានាបានស្សតិសមាធិនោះ ទើបឈ្មោះថា **អសេចនកោ - គ្មានភាពស្អិតល្អូត** ( ដូចបាយស្រស់ទឹក ) គឺ មិនស្រួយ មិនស្អិតជាប់គ្នា ដាច់ចេញពីគ្នាជាគ្រាប់ៗ មានន័យថា ភាពស្ងប់ក្នុងអានាបានស្សតិសមាធិនេះ មិនមានដោយបរិកម្ម ឬដោយឧបចារៈក៏ដោយ តែអានាបានស្សតិសមាធិនេះ ជាធម៌ស្ងប់ផង ប្រណីតផង ដោយសភាវៈនៃខ្លួនឯង ចាប់តាំងពី **អាទិសមន្នាហារ** ( ការផ្តើមប្រមូលចិត្តធ្វើកម្មដ្ឋាន ) ទៅ , រីឯអាចារ្យរូបខ្លះពោលថា បទថា **អសេចនកោ** មានន័យថា មិនចាំបាច់ផ្សំជាមួយអ្វី ៗ ដូចវត្ថុដែលមានរសឆ្ងាញ់ដោយសភាពនៃខ្លួនឯង បណ្ឌិតគប្បីជ្រាបថា

អានាបានស្សតិសមាធិនេះ ជា **អសេចនក** ដូច្នេះឯង ទើបជាសុខវិហារផង ព្រោះប្រព្រឹត្តទៅដើម្បីបានកាយិកសុខ និង ចេតសិកសុខ គ្រប់ខណៈដែលដល់នូវអប្បនា ។

ពាក្យថា **ដែលកើតឡើង** មានន័យថា ដែលមិនទាន់បានគ្របសង្កត់ ។ ពាក្យថា **បាប** គឺ អាក្រក់ ។ ពាក្យថា **ធម៌ដែលជាអកុសល** គឺ ធម៌ដែលកើតពីការមិនឆ្លាត ។ ពាក្យថា **ឲ្យវិនាសទៅដោយរហ័ស** មានន័យថា ឲ្យបាត់ទៅ គឺ គ្របសង្កត់បានភ្លាមៗ ។ ពាក្យថា **ឲ្យរម្ងាប់ទៅ** គឺ ឲ្យស្ងប់ទៅដោយល្អ , ន័យម្យ៉ាងទៀត អ្នកដែលដល់នូវការចម្រើននូវអរិយមគ្គតាមលំដាប់ រមែងលះបង់បាន អធិប្បាយថា ឲ្យស្ងប់ស្ងាត់ទៅបាន ព្រោះអានាបានស្សតិសមាធិ ជានិព្វេធភាគិយធម៌ ។

ក្នុងព្រះបាលីមានពាក្យសួរថា មានសេចក្ដីសង្ខេបថា ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិសមាធិ បុគ្គលធ្វើឲ្យមានដោយប្រការដូចម្ដេច ដោយអាការដូចម្ដេច ដោយវិធីណា ចម្រើនដោយប្រការណា ... ទើបជាធម៌ស្ងប់ផង ។ ល ។ ឲ្យរម្ងាប់ទៅដោយរហ័សផង ។

## មហាដីកា

ឈ្មោះថា **អសេចនកោ - វៀបរយ** ព្រោះអត្ថថា មិនមានវត្ថុជាគ្រឿងរឹកវរ ដែលជាហេតុនាំមកនូវធម៌ស្ងប់ និង ប្រណីត ។ ព្រោះមិនមានវត្ថុជាប់ស្អិត ទើបឈ្មោះថា មិនរឹកវរ , ព្រោះមិនរឹកវរនោះឯង ទើបឈ្មោះថា មិនស្អិតល្អិត ដែលមិនប្របូកប្របល់ដោយបរិកម្មជាដើម ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា

ដោយចំពោះម្យ៉ាងទៀត គឺ ម្យ៉ាងទៀតនោះឯង ។ ឈ្មោះថា ជាចំណែកមួយផ្សេង គឺ មិនសាធារណៈ , ពាក្យទាំងអស់នេះ លោកពោលទុកដើម្បីសម្តែងភាវៈដែលស្ងប់ ដោយសភាវៈនៃខ្លួនឯង ។ ន័យម្យ៉ាងទៀត ហេតុនៃសេចក្តីស្ងប់ ឈ្មោះថា **បរិកម្ម** មានន័យថា ចាប់តាំងពីផ្តើមកសិណរហូតដល់និមិត្តកើតជាទីបំផុត ឈ្មោះថា **បរិកម្ម** អធិប្បាយថា ក្នុងអានាបានស្សតិសមាធិនេះ មិនមានបរិកម្មដែលដូច្នោះ , ព្រោះថា ក្នុងពេលនោះ កម្មដ្ឋានមិនស្ងប់ មិនប្រណីត ព្រោះមិនមានសេចក្តីត្រេកអរ ។ ប្រកបសេចក្តីថា ក្នុងអានាបានស្សតិសមាធិនេះ ភាវៈដែលស្ងប់ដោយសារឧបចារៈមិនមាន ។ សមាធិដទៃស្ងប់ទៅបានក៏ព្រោះការទៅប្រាសនៃនីវរណធម៌ និង ការប្រាកដអង្គក្នុងខណៈនៃឧបចារៈ យ៉ាងណា , អានាបានស្សតិសមាធិនេះ នឹងមានសេចក្តីស្ងប់ដូច្នោះ មិនមាន ។ ប្រកបសេចក្តីថា តែថាសមាធិនេះ ស្ងប់ និង ប្រណីត តាមសភាពនៃខ្លួនឯងប៉ុណ្ណោះ ចាប់តាំងពីការផ្តើមប្រមូល ។ ពាក្យថា **អាចារ្យរូបខ្លះ** លោកអាចារ្យពោលសំដៅយកអាចារ្យដែលនៅឯសំណាក់ឧត្តរវិហារ ។ ពាក្យថា **មិនស្អិតល្អូត** ( អាចារ្យពួកខ្លះពោលថា ) បានដល់ មិនស្អិតល្អូតដោយការប្រឡាក់ចូលគ្នា ។ ព្រោះហេតុនោះ ទើបលោកពោលថា **មានឱជា** ដូច្នេះ , មានន័យថា ដូចវត្ថុដែលមានឱជា ។ ពាក្យថា **ឆ្ងាញ់** គឺ គួរប្រាថ្នា , ឈ្មោះថា ការប្រព្រឹត្តទៅព្រមដើម្បីការបានមកនូវសុខផ្លូវចិត្ត បណ្ឌិតគប្បីជ្រាបបានដោយទាក់ទងនឹងឈាន ៣ ឈាន ៤ ឬ ទាក់ទងនឹងឈានទាំងអស់ ( គឺ រួមទាំងឈានទី ៥ ផង ) ព្រោះឧបេក្ខាក៏មានគតិជាសុខ ព្រោះភាពជាធម្មជាតិស្ងប់ ។ រីឯ ការប្រព្រឹត្តទៅព្រមដើម្បីការបានសុខផ្លូវកាយ គប្បីឃើញបានដោយទាក់ទងនឹងរូបកាយត្រូវបណីតរូប ដែល

មានឈានជាសមុដ្ឋានសម្ផស្សហើយ , តែសេចក្តីនោះ នឹងមានបានក្នុងពេលដែលចេញចាកឈានហើយ ។ រីឯ បទថា **អប្បិតប្បិតក្ខណេ** នេះ គប្បីជ្រាបថាជាសត្តមីវិភត្តិ ក្នុងអត្ថថា **ហេតុ** ប្រែថា ព្រោះគ្រប់ខណៈដែលដល់អប្បនា ។ ពាក្យថា **ដែលគ្របសង្កត់មិនទាន់បាន** គឺ ដែលមិនទាន់កម្ចាត់ចេញចាកសន្ដានរបស់ខ្លួនបាន គឺ ដែលលះបង់មិនទាន់បានដោយឈាន ។ ពាក្យថា **ដែលកើតពីការមិនឆ្លាត** មានន័យថា លោកហៅ **អវិជ្ជា** ថា ការមិនឆ្លាត បានដល់ កើតពីអវិជ្ជានោះ ។ ជាការពិតហើយ បាបធម៌ទាំងឡាយ មានអវិជ្ជាជាប្រមុខ ( ជាប្រធាន ) ។ ពាក្យថា **ដោយខណៈមួយ** គឺ ដោយខណៈដែលខ្លួន ( អានា-បានស្សតិសមាធិ ) ប្រព្រឹត្តទៅនោះឯង ។ ក្នុងពាក្យថា **ឲ្យអន្តរធានទៅ** ឈ្មោះថា ការធ្វើឲ្យអន្តរធាន បានដល់ ការធ្វើឲ្យវិនាសទៅ , ពាក្យថា **ឲ្យអន្តរធាន** នោះ ជាការលះបង់បរិយុដ្ឋាន ព្រោះក្នុងទីនេះ បំណងយកការធ្វើឲ្យអន្តរធាន ដែលជាទីតាំង ទីអាស្រ័យនៃឈាន ព្រោះហេតុនោះ ទើបលោកពោលថា គឺ **គ្របសង្កត់បាន** ដូច្នេះ ។ បទថា **វូបសមេតិ - ឲ្យស្ងប់រម្ងាប់** បានដល់ ចូលទៅស្ងប់ដោយវិសេស , ឯការចូលទៅស្ងប់បានដោយវិសេស គឺ ការចូលទៅស្ងប់ដោយល្អនោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ចូលទៅស្ងប់បានដោយល្អ** ដូច្នេះ ។

**សួរថា** សមាធិដទៃ ៗ រមែងធ្វើធម៌ដែលជាបដិបក្ខទាំងឡាយ ឲ្យអន្តរធានទៅ ឲ្យស្ងប់រម្ងាប់ទៅបាន ក្នុងខណៈដែលខ្លួនប្រព្រឹត្តទៅ មិនមែនឬ ? បើដូច្នោះ ព្រោះហេតុអ្វី ទើបទ្រង់ត្រាស់ចំពោះសមាធិនេះ ឲ្យពិសេសយ៉ាងនេះ ?

**ឆ្លើយថា** ទ្រង់ត្រាស់សមាធិនេះឲ្យពិសេសទៅយ៉ាងនេះ ព្រោះមានការស្ងប់

រម្ងាប់វិតក្កៈផ្សេងៗ មកតាំងពីពេលចាប់ផ្ដើម ។ ប្រការនេះ ដូចព្រះតម្រាស់ទ្រង់ត្រាស់ទុកថា “ គប្បីចម្រើនអានាបានស្សតិ ដើម្បីកម្ចាត់វិតក្កៈ ” ។ ម្យ៉ាងទៀត អានាបានស្សតិកម្មដ្ឋាននេះ ចាត់ជាកម្មដ្ឋានសម្រាប់អ្នកមានបញ្ញាខ្លាំងក្លា ក្រៃលែងដោយញាណ , និង ការលះកិលេសរបស់លោកអ្នកដែលខ្ពង់ខ្ពស់ដោយញាណ ប្រសើរជាងការលះកិលេសរបស់បុគ្គលក្រៅពីនេះ , ដូចការលះកិលេសរបស់ព្រះអរិយបុគ្គលដែលជាទិដ្ឋិបត្តៈ ប្រសើរជាងការលះកិលេសរបស់ព្រះអរិយ-បុគ្គលដែលជាសទ្ធាវិមុត្តិ ។ ព្រោះដូច្នោះ ទ្រង់សំដៅយកភាពពិសេសប្រការនោះ ទើបត្រាស់ថា **ឲ្យអន្តរធាន ឲ្យស្ងប់រម្ងាប់ទៅដោយរហ័ស** ។ ម្យ៉ាងវិញទៀត កាលមានការប្រាកដនៃនិមិត្ត សមាធិនេះប៉ុណ្ណោះអាចពោលបានថា “ ធ្វើ ( អ-កុសលធម៌ទាំងឡាយ ដ៏លាមក ដែលកើតឡើងហើយ ) ឲ្យអន្តរធាន ឲ្យស្ងប់រម្ងាប់ទៅដោយរហ័ស ” ដោយការប្រាកដនៃអង្គក្នុងខណៈនោះ , ដូចកាលដែលភ្លៀងធំខុសរដូវកាល មហាមេឃគ្រហឹមហើយ គ្រាប់ភ្លៀងធ្លាក់មកលើផែនដី ក៏បានជាព្រួចទឹក ហើយក៏បែកទៅក្នុងខណៈនោះឯង , ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ទុកថា **ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចភ្លៀងធំខុសរដូវកាល គ្រហឹមឡើង** ដូច្នេះជាដើម ។ ការចម្រើនឈាននៃព្រះយោគាវចរក្នុងព្រះសាសនា ដោយច្រើនជានិព្វេធភាគិយៈប៉ុណ្ណោះ ( មានចំណែកនៃការចាក់ធ្លុះសច្ចៈ ) ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ព្រោះជានិព្វេធភាគិយសមាធិ** ។ រីឯ ការចម្រើនឈាននៃព្រះពុទ្ធជាម្ចាស់ទាំងឡាយ ជានិព្វេធភាគិយសមាធិតែម្យ៉ាង ។ ពិតហើយ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយ ទ្រង់ចម្រើនកម្មដ្ឋាននោះ ហើយទើបទ្រង់សម្រេចនូវព្រះសម្មាសម្ពោធិញ្ញាណ ។ សមាធិនេះ ជាបាទនៃព្រះអរិយមគ្គ

ចម្រើនទៅតាមលំដាប់ហើយ ក៏រមែងចូលដល់ភាពជាព្រះអរិយមគ្គ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា **ដល់នូវការចម្រើននូវព្រះអរិយមគ្គ តាមលំដាប់** ដូច្នេះ ។

សេចក្ដីនេះនឹងប្រើបានល្អ ក៏ដោយទាក់ទងនឹងវិរាគានុបស្សនា និរោធានុ-បស្សនា និង បដិនិស្សគ្គានុបស្សនា ។ លោកអាចារ្យកាលនឹងសម្ដែងដោយសង្ខេប ដើម្បីឲ្យយល់បានងាយនូវខ្លឹមសារដែលបានពោលហើយ ដោយពិស្ដារក្នុងបទក្រោយ ទើបពោលថា **រីឯ សេចក្ដីសង្ខេបក្នុងព្រះបាលី ដែលជាសំណួរនេះ មានដូចតទៅនេះ** , អធិប្បាយថា សេចក្ដីរួម កាន់យកតែខ្លឹមសារ ។

ពាក្យថា **ខ្លឹមសារនោះ** បានដល់ ខ្លឹមសារដែលទ្រង់ត្រាស់ទុកដោយសង្ខេប ដោយទាក់ទងនឹងការសួរក្នុងពាក្យថា **ធ្វើឲ្យកើតឡើងបានដោយប្រការដូចម្ដេច ?** ដូច្នេះជាដើម ។

( ចប់ មហាដីកា )

# អធិប្បាយ ឥធ ស័ព្ទ

ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **ឥធ ភិក្ខវេ ភិក្ខុ** ប្រែថា **ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ** , ព្រោះ **ឥធ** ស័ព្ទ ក្នុងព្រះបាលីនោះ ជាស័ព្ទសម្ដែងដល់សាសនា ដែលជាទីកើតឡើងនៃបុគ្គលអ្នកធ្វើអានាបានស្សតិសមាធិ

គ្រប់ប្រការឲ្យកើតឡើង និង បដិសេធភាពជាយ៉ាងនោះ នៃសាសនាដទៃ ដូច ព្រះពុទ្ធវចនៈត្រាស់ថា ម្នាលភិក្ខុទាំងឡាយ **សមណៈមានតែក្នុងសាសនានេះ ប៉ុណ្ណោះ ។ល។ វាទៈ ( លទ្ធិ ) ដទៃ សូន្យចាកសមណៈគ្រប់ជំពូក** ។ ព្រោះ ហេតុនោះ ខ្ញុំម្ចាស់ទើបអធិប្បាយ " **ឥធ ភិក្ខុ** " ថា **ឥមស្មឹ សាសនេ ភិក្ខុ - ភិក្ខុក្នុងសាសនានេះ** ។

## អរញ្ញគតោ ។ បេ ។

### ( ន័យ ទី ១ )

ពាក្យថា **ទៅកាន់ព្រៃ ឬ គល់ឈើ ឬ ផ្ទះស្ងាត់ក៏ដោយ** នេះជាពាក្យ សម្តែងដល់ការកំណត់យកសេនាសនៈ ដែលសមគួរដល់ការបំពេញអានាបាន-ស្សតិសមាធិនៃព្រះយោគាវចរភិក្ខុនេះ ព្រោះចិត្តរបស់ភិក្ខុនោះ ត្រាច់ទៅកាន់ អារម្មណ៍ផ្សេងៗ មានរូបារម្មណ៍ជាដើមមកយូរហើយ មិនប្រាថ្នានឹងឡើងកាន់ អារម្មណ៍នៃអានាបានស្សតិសមាធិ ធ្លាប់តែលេងនៅខាងក្រៅផ្លូវ ដូចរទេះដែលទឹម ដោយគោកោង ស្ទុះចេញទៅក្រៅផ្លូវដូច្នោះ ព្រោះហេតុនោះ នាយគោបាលប្រាថ្នា ហ្វឹកហាត់កូនគោកោងនោះ ដែលផឹកទឹកដោះមេគោកោង រហូតធំឡើងហើយ ក៏ បំបែកចេញពីមេគោ ដោយបង្គោលស្នឹង ហើយក៏ចងទុកដោយខ្សែ នៅត្រង់ បង្គោលស្នឹងនោះ ពេលនេះ កូនគោមួយក្បាលនោះ ក៏ដើរទៅដើរមក មិនអាច គេចទៅបាន ក៏នៅស្ងៀម ឬ ដេកជិតបង្គោលស្នឹងនោះឯង យ៉ាងណា ភិក្ខុនេះក៏ ដូច្នោះ ដូចគ្នា , ប្រាថ្នានឹងទូន្មានចិត្តកាច ដែលធំហើយដោយការត្រេកអរនៃ អារម្មណ៍ មានរូបារម្មណ៍ជាដើម មកយូរហើយ ក៏បំបែកចេញពីអារម្មណ៍ មាន

រូបជាដើម ចូលទៅកាន់ព្រៃ ឬ គល់ឈើ ឬ ផ្ទះស្ងាត់ក៏ដោយ ហើយចងទុកនៅត្រង់បង្គោលស្ទឹង គឺ ខ្យល់ដង្ហើមចេញ ខ្យល់ដង្ហើមចូល ដោយខ្សែ គឺ សតិ , កាលត្រូវចងទុកយ៉ាងនោះ ចិត្តរបស់លោកនោះ កាលមិនបានអារម្មណ៍តាមទម្លាប់ ក៏ច្រេច្រាទៅមក តែដោយមិនអាចកាត់ខ្សែ គឺ សតិ គេចទៅបាន ក៏នៅស្ងៀមតម្កល់នៅក្នុងអារម្មណ៍ ( កម្មដ្ឋាន ) នោះ ដោយការបានទទួលឧបចារៈ និង អប្បនា ព្រោះហេតុនោះ ព្រះបោរាណាចារ្យទាំងឡាយ ទើបពោលទុកថា ៖

**បុគ្គលហ្វឹកកូនគោ គប្បីចងទុកនឹងបង្គោលស្ទឹង យ៉ាងណា ព្រះយោគាវចរក្នុងព្រះសាសនានេះ គប្បីចងចិត្តរបស់ខ្លួនទុកក្នុងអារម្មណ៍ ( កម្មដ្ឋាន ) ឲ្យមាំដោយសតិ ក៏ដូច្នោះ ។**

សេនាសនៈ ( ដែលពោលមក ) នោះ ជាកន្លែងសមគួរដល់ការភាវនា នៃព្រះយោគាវចរនោះ ដោយប្រការដូច្នោះ ខ្ញុំម្ចាស់ទើបពោលទុកថា ពាក្យនេះជាពាក្យសម្ដែងដល់ការកំណត់កាន់យកសេនាសនៈ ដែលសមគួរដល់ការបំពេញអានាបានស្សតិសមាធិនៃព្រះយោគាវចរភិក្ខុនោះ ។

## អរញ្ញគតោ ។ បេ ។

### ( ន័យទី ២ )

ន័យម្យ៉ាងទៀត ព្រោះហេតុដែលអានាបានស្សតិកម្មដ្ឋាន ជាកំពូលក្នុងប្រភេទកម្មដ្ឋាន ជាបទដ្ឋាននៃការសម្រេចធម្មវិសេស និង ទិដ្ឋធម្មសុខវិហារ នៃព្រះពុទ្ធជាម្ចាស់ ព្រះបច្ចេកពុទ្ធ និង ពុទ្ធសាវកទាំងពួង មិនមែនជាការងាយក្នុងការលះបង់ទីលំនៅដែលអ៊ូអែរទៅដោយសំឡេងផ្សេង ៗ ដូចជាសំឡេងស្ត្រី

សំឡេងបុរស សំឡេងដំរី សំឡេងសេះ ហើយបំពេញបានឡើយ ព្រោះឈានេនះ មានសំឡេងជាសត្រូវ តែក្នុងទីដែលមិនមែនជាទីលំនៅ គឺ ក្នុងព្រៃវាជាការងាយ សម្រាប់ ព្រះយោគាវចរកាន់យកកម្មដ្ឋាននេះ ញ៉ាំងអានាបានចតុត្ថជ្ឈានឲ្យកើតឡើងហើយ ធ្វើឈាននោះឲ្យជាបាទ ពិចារណាគំនរសង្ខារ រហូតបានសម្រេចព្រះអរហត្តដែលជាផលដ៏កំពូល។ ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់សម្តែងសេនាសនៈដែលសមគួរដល់ព្រះយោគាវចរនោះ ទើបត្រាស់ថា **អរញ្ញគតោ វា** ដូច្នេះជាដើម ។

## អរញ្ញគតោ ។ បេ ។

### ( ន័យ ទី ៣ )

ពិតហើយ ព្រះមានព្រះភាគជាម្ចាស់ ដូចវត្ថុវិជ្ជាចារ្យ ( អាចារ្យមានវិជ្ជាភូមិសាស្ត្រ ) វត្ថុវិជ្ជាចារ្យកាលជួបភូមិសាស្ត្រដែលសមគួរដើម្បីសាងនគរ កាលត្រួតមើលសព្វគ្រប់ហើយ ទើបប្រាប់ថា “ អ្នកទាំងឡាយចូរកសាងទីក្រុងនៅក្នុងទីនេះចុះ ” កាលដែលទីក្រុងកសាងបានសម្រេចហើយ ក៏បានទទួលសក្ការៈធំពីរាជត្រកូល យ៉ាងណា ព្រះមានព្រះភាគជាម្ចាស់ក៏ដូច្នោះ ដូចគ្នា ទ្រង់ត្រួតមើលសេនាសនៈដែលសមគួរដល់ព្រះយោគាវចរហើយ ទើបប្រាប់ថា “ កម្មដ្ឋានគួរប្រកបក្នុងស្ថានទីនេះ ” តែប៉ុណ្ណោះ , កាលព្រះអរហត្តផល ដែលព្រះយោគាវចរអ្នកប្រកបកម្មដ្ឋាន នៅត្រង់កន្លែងនោះ បានសម្រេចតាមលំដាប់ហើយ ទ្រង់ក៏បានទទួលនូវសក្ការៈធំ ( សរសើរព្រះគុណថា ) “ ព្រះមានព្រះភាគនោះ ជាព្រះសម្មាសម្ពុទ្ធ ហ្ន៎ ! ដូច្នេះ , រីឯ ភិក្ខុនេះ ទ្រង់ពោលថា ដូចជាសីហៈ គប្បីជ្រាប

អធិប្បាយថា ដូចជាស្ដេចសីហៈ អាស្រ័យនៅក្នុងស្មៅក្រាស់ ឬ ព្រៃល្បោះ ឬ នៃស្រោង ចូលទៅក្នុងព្រៃពួន ទើបចាប់សត្វព្រៃទាំងឡាយ មានក្របីព្រៃ ក្ដាន់ និង ជ្រូកព្រៃជាដើមបាន យ៉ាងណា ភិក្ខុដែលប្រកបកម្មដ្ឋាន នៅក្នុងសេនាសនៈដែលសមគួរទាំងឡាយ មានព្រៃជាដើមនេះ ក៏អាចចាប់យកសោតាបត្តិមគ្គ សកទាគាមិមគ្គ អនាគាមិមគ្គ អរហត្តមគ្គ និង អរិយផលតាមលំដាប់បាន ក៏ដូច្នោះដូចគ្នា ព្រោះហេតុនោះ ព្រះបោរាណាចារ្យទាំងឡាយទើបពោលថា ៖

**ឧបមាដូចសីហៈលាក់ខ្លួន ទើបចាប់សត្វព្រៃបាន យ៉ាងណាក្ដី ព្រះពុទ្ធបុត្តប្រកបសេចក្ដីព្យាយាម បំពេញវិបស្សនា ក៏ដូច្នោះដែរ ចូលព្រៃទើបអាចយកឧត្តមផលបាន ។**

ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់សម្ដែងសេនាសនៈព្រៃដែលជាយោគភូមិ ( ភូមិប្រកបសេចក្ដីព្យាយាម ) នៃអ្នកដែលមានសេចក្ដីព្យាយាម និង ប្រញាប់ប្រញាល់ ( ក្នុងភាវនា ) ដល់យោគាវចរភិក្ខុនោះ ទើបត្រាស់ថា **អរញ្ញគតោ វា** ជាដើម ។

ក្នុងបទទាំងឡាយនោះ បទថា **អរញ្ញគតោ** មានន័យថា ក្នុងបណ្ដាព្រៃមានលក្ខណៈ ដែលទ្រង់ត្រាស់ទុកថា “ ឈ្មោះថា ព្រៃ ” គឺ ស្ថានទីខាងក្រៅបង្គោលធរណីទ្វារទៅ ចាត់ជាព្រៃទាំងអស់ ដូច្នេះក្ដី ថា “ សេនាសនៈដែលមានក្នុងទីប្រមាណ ៥០០ ធ្នូ ( ពីដែនស្រុក ) យ៉ាងជិត ឈ្មោះថា សេនាសនៈព្រៃ ” ដូច្នេះក្ដី ភិក្ខុទៅកាន់ព្រៃយ៉ាងណាមួយ ដែលជាទីស្ងាត់ ជាសុខ ។ បទថា **រុក្ខមូលគតោ** គឺ ទៅកាន់ស្ថានទីជិតគល់ឈើ ។ បទថា **សុញ្ញាគារគតោ** មានន័យថា ទៅកាន់ស្ថានទីល្ហល្ហេវ គឺ ស្ងាត់ , ក្នុងបាលីនេះ

វៀរព្រៃ និង រុក្ខមូលចេញ ទៅកាន់សេនាសនៈដ៏សេសទៀត ៧ យ៉ាង ក៏គួរហៅថា **សុញ្ញាគារគតោ** បាន ។

ព្រះមានព្រះភាគ កាលទ្រង់ប្រាប់សេនាសនៈដែលសមគួរដល់ការបំពេញអានាបានស្សតិ អនុកូលដល់រដូវទាំង ៣ និង អនុកូលដល់ធាតុ និង ចរិយាផង យ៉ាងនេះហើយ កាលទ្រង់ប្រាប់ឥរិយាបថដែលស្ងប់ មិនប្រព្រឹត្តទៅនាំឲ្យរួញរា និង រាយមាយ ដល់ព្រះយោគាវចរភិក្ខុនោះ ទើបត្រាស់ថា “ អង្គុយ ” បន្ទាប់ពីនោះ កាលទ្រង់សម្ដែងដល់ភាពមាំទាំនៃការអង្គុយ ការប្រព្រឹត្តទៅស្រួលនៃខ្យល់ដង្ហើមចេញ-ចូល និង ឧបាយក្នុងការកំណត់ខ្យល់ជាអារម្មណ៍ផង ទើបត្រាស់ថា “ អង្គុយពត់ភ្នែន ” ជាដើម ។

ក្នុងបទទាំងឡាយនោះ បទថា **បល្លង្កំ** បានដល់ អង្គុយបត់ជើងចូលដោយជុំវិញ ។ បទថា **បត់** គឺ ពត់ចូល ។ ពាក្យថា **តាំងកាយឲ្យត្រង់** គឺ តាំងសរីរៈផ្នែកខាងលើឲ្យត្រង់ ឲ្យចុងនិងចុងឆ្អឹងខ្នងទាំង ១៨ ទល់គ្នា ព្រោះកាលព្រះយោគាវចរអង្គុយយ៉ាងនេះ ស្បែក សាច់ និង សរសៃ រមែងមិនអង្គុញ កាលបើដូច្នោះ វេទនាទាំងឡាយណា គប្បីកើតឡើងក្នុងខណៈៗ ព្រោះការអង្គុញនៃស្បែក សាច់ និងសរសៃនោះ ជាបច្ច័យ វេទនាទាំងឡាយនោះ ក៏មិនកើតឡើងដល់លោក កាលវេទនាទាំងឡាយនោះ មិនកើតឡើង ចិត្តនឹងមានអារម្មណ៍តែមួយ កម្មដ្ឋានមិនធ្លាក់ ចូលដល់ការចម្រើនល្អឡើងៗ ។ ពាក្យថា **តាំងសតិទុកចំពោះមុខ** គឺ តាំងសតិឲ្យមានមុខឆ្ពោះកម្មដ្ឋាន ។

ន័យម្យ៉ាងទៀត អត្ថាធិប្បាយក្នុងពាក្យនេះ គប្បីជ្រាបតាមន័យដែលពោលទុកក្នុងបដិសម្ភិទាយ៉ាងនេះថា “ ស័ព្ទថា **បរិ** មាន **បរិគ្គហ** - ការកំណត់យកជា

អត្ថ , ស័ព្ទថា **មុខ** មាន **និយ្យាន** - ការនាំចេញជាអត្ថ , ស័ព្ទថា **សតិ** មាន **ឧបដ្ឋាន** - ការចូលទៅតម្កល់ មិនវង្វេងជាអត្ថ , ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **បរិមុខំ សតិំ** " ដូច្នេះក៏បាន , នេះជាអធិប្បាយសង្ខេបក្នុងពាក្យនោះ គឺ ធ្វើសតិឲ្យមានការចេញ ( ចាកបដិបក្ខធម៌ ) ដែលបានកំណត់ហើយ ។

## មហាដីកា

លោកអាចារ្យកាលសម្តែងថា **ឥធ** ស័ព្ទ ក្នុងប្រយោគថា " ព្រះតថាគតរមែងកើតឡើងក្នុងលោក " ជាដើម ត្រាស់សំដៅយកលោក , **ឥធ** ស័ព្ទ ក្នុងប្រយោគថា " អ្នកឈរនៅត្រង់ទីនោះឯង " ជាដើម ត្រាស់សំដៅយកឱកាស , **ឥធ** ស័ព្ទ ក្នុងប្រយោគថា ម្នាលភិក្ខុទាំងឡាយ តថាគតបរិភោគរួចរាល់ហើយ ហាមភត្តហើយ " ត្រាស់សំដៅយកត្រឹមការធ្វើបទឲ្យពេញ , រីឯ **ឥធ** ស័ព្ទ ក្នុងប្រយោគថា " ភិក្ខុក្នុងព្រះសាសនានេះ រមែងរៀនធម៌ " ជាដើម ត្រាស់សំដៅយកព្រះសាសនា , **ឥធ** ស័ព្ទ ក្នុងប្រយោគថា " ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងព្រះសាសនានេះ " នេះក៏ត្រាស់សំដៅយកសាសនានេះដែរ , ទើបពោលថា " ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងព្រះសាសនានេះ " បំណងសម្តែងខ្លឹមសារនោះឲ្យកាន់តែជាក់ច្បាស់ ទើបពោលថា " **អយំ ហិ** " ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **នៃបុគ្គលអ្នកធ្វើអានាបានស្សតិសមាធិឲ្យកើតឡើងដោយប្រការទាំងពួង** , ស័ព្ទថា ប្រការទាំងពួង លោកពោលសំដៅយកអាការទាំង ១៦ ។ ឯប្រការទាំង ១៦ នោះ មាននៅតែក្នុងព្រះសាសនានេះប៉ុណ្ណោះ ។ ពិតហើយ បុគ្គលក្រៅសាសនា កាលអាចដឹង រមែងដឹងបានត្រឹម ៤ ប្រការ

ខាងដើម ប៉ុណ្ណោះ , ព្រោះហេតុនោះ លោកទើបពោលថា “ បដិសេធភាពជាយ៉ាងនោះ នៃសាសនាដទៃ ” មានន័យថា បដិសេធភាពជាទីអាស្រ័យនៃបុគ្គលតាមដែលពោលហើយ ។ ដោយពាក្យថា ទ្រង់សម្តែងថា “ **ឥធ ភិក្ខវេ** ” នេះជាពាក្យមាន **ឯវ** ស័ព្ទ រួមក្នុងខ្លួន ( កាន់យកស្មើនឹង **ឥធេវ ភិក្ខវេ** ) នោះឯង។ ពិតហើយ ពាក្យពោល សូម្បីមានបទមួយ តែជាពាក្យអវធារណៈ ( ពាក្យកំណត់សេចក្តី ប្រែថា **ប៉ុណ្ណោះ** , **តែយ៉ាងនោះឯង** ។ល។ ) ក៏មានហើយ ដូចពាក្យថា “ **វាយុភក្ខោ** ប្រែថា មានខ្យល់ប៉ុណ្ណោះជាអាហារ ” ។ ព្រោះហេតុនោះ ទើបទ្រង់ពោលថា **ឥធេវ ភិក្ខវេ សមណោ** ដូច្នេះជាដើម ។ ឯបុគ្គលដែលធ្វើអានាបានស្សតិសមាធិឲ្យកើតឡើងបាន ដោយប្រការទាំងពួង ឈ្មោះថាជាអ្នកមានធម៌ដែលធ្វើភាពជាសមណៈឲ្យបរិបូរណ៍ ។ ពាក្យថា **លទ្ធិសាសនាដទៃ** បានដល់ វាទៈមានប្រការផ្សេងៗនៃពួកអន្យតិរ្ថិយទាំងឡាយ ដែលជាសាសនារបស់ពួកអន្យតិរ្ថិយ ។

លោកអាចារ្យបំណងនឹងសម្តែងដល់ស្ថានទី មានព្រៃជាដើមនោះឯង ជាសេនាសនៈដែលសមគួរចំពោះភាវនា ទើបពោលថា **ឥមស្ស ហិ** ដូច្នេះជាដើម ។ គោដែលគេបង្ហឹកបានដោយលំបាក គឺ មិនសម្រេចបាននូវការហ្វឹកហាត់ ហៅថា **គោកោង** ។ មេគោដែលចង់ដោះក្នុងពេលដែលគេរឹត តាមប្រការដែលអាចឲ្យទឹកដោះហូរចេញចាកដោះឲ្យអស់ មិនបាន ហៅថា **មេគោកោង** ។ សេចក្តីត្រេកអរដែលអាស្រ័យអារម្មណ៍ មានរូប ឬ សំឡេងជាដើម កើតឡើង ឈ្មោះថា រសនៃអារម្មណ៍ មានរូបជាដើម ។ ពាក្យថា **អារម្មណ៍ដែលធ្លាប់សេពក្នុងគ្រាមុន** បានដល់ អារម្មណ៍ដែលធ្លាប់សេពក្នុងកាលមិនទាន់បានបព្វជ្ជា ឬ ក្នុង

សង្សារវដ្តដែលមិនមានទីបំផុតខាងដើម ។

បទថា **និពន្ធេយ្យ** ប្រែថា គប្បីចង ។ បទថា **សតិយា** បានដល់ សតិដែលប្រព្រឹត្តទៅទាក់ទងនឹងការកំណត់កម្មដ្ឋានដោយត្រឹមត្រូវនោះឯង ។ បទថា **អារម្មណេ** បានដល់ អារម្មណ៍ គឺ កម្មដ្ឋាន ។ បទថា **ទឡ្ហំ** ប្រែថា មាំទាំ មានន័យថា ធ្វើឲ្យមានកម្លាំង តាមប្រការដែលសមាធិ មានប្រភេទជាឧបចារៈ និង អប្បនា គប្បីសម្រេចដល់ភិក្ខុអ្នកចម្រើនសតិ ។

ពាក្យថា **ជាបទដ្ឋាននៃការសម្រេចគុណវិសេស និង ទិដ្ឋធម្មសុខវិហារ** គឺ ជាបទដ្ឋាន ( ហេតុជិត ) នៃការសម្រេចគុណវិសេសរបស់ព្រះពុទ្ធជាម្ចាស់ គ្រប់ៗព្រះអង្គ របស់ព្រះបច្ចេកពុទ្ធជាម្ចាស់ និង សាវករបស់ព្រះពុទ្ធជាម្ចាស់រូបខ្លះ និង នៃទិដ្ឋធម្មសុខវិហារ ( ការនៅជាសុខក្នុងអត្តភាពនេះ ) របស់អ្នកបានសម្រេចគុណវិសេស ដោយកម្មដ្ឋានដទៃ ។

ព្រះមានព្រះភាគ ឈ្មោះថា ទ្រង់ដូចជាអាចារ្យដែលមានវិជ្ជាមើលភូមិ-សាស្ត្រ ព្រោះទ្រង់បង្ហាញណែនាំស្ថានទី ដែលសមគួរដល់ព្រះយោគាវចរ ។

ភិក្ខុ ឈ្មោះថា ដូចជាសីហៈ ព្រោះញុំាងប្រយោជន៍ដែលខ្លួនប្រាថ្នា ឲ្យសម្រេច ដោយការនៅក្នុងព្រៃម្នាក់ឯង ហើយញុំាញីធម៌ដែលជាបដិបក្ខបាន ។ ដោយបទថា **ផលមុត្តមំ - ផលដ៏ឧត្តម** ទ្រង់ពោលដល់ សាមញ្ញផល ។ ពាក្យថា **ភូមិប្រទេសដែលសមគួរដល់ការប្រកបនូវសេចក្តីព្យាយាម** គឺ ភូមិប្រទេសដែលមានភាពសមគួរដល់ការញុំាងនូវឧស្សាហៈក្នុងភាវនា ។

ពាក្យថា **មានលក្ខណៈដែលលោកពោលទុកយ៉ាងនេះ** គឺ មានលក្ខណៈដែលលោកពោលទុកដោយ “ បរិយាយព្រះអភិធម្ម និង បរិយាយព្រះសូត្រ ។

ពាក្យថា **ស្ថានទីជិតគល់ឈើ** បានដល់ ស្ថានទីជិតដើមឈើ ដែលទ្រង់ត្រាស់ទុកយ៉ាងនេះថា ស្ថានទីត្រឹមទីដែលម្លប់ឈើផ្សាយទៅដោយជុំវិញ ក្នុងពេលថ្ងៃត្រង់ , ត្រឹមស្លឹកឈើធ្លាក់ចុះក្នុងពេលដែលមិនមានខ្យល់ ហៅថា **រុក្ខមូល** ។ ពាក្យថា **សេនាសនៈ ៧ យ៉ាង ដ៏សេស** បានដល់ សេនាសនៈ ៧ យ៉ាង ដែលលោកពោលទុកយ៉ាងនេះថា ភ្នំ ញកភ្នំ គុហាភ្នំ ព្រៃស្មសាន ព្រៃស្រោង ទីវាលគំនរចំបើង ដូច្នេះ ។

ពាក្យថា **ដែលអនុកូលតាមរដូវ ៣ និង អនុកូលចំពោះធាតុ ព្រមទាំងចរិយា** គឺ ដែលអនុកូលដល់រដូវ ៣ មានរដូវក្ដៅជាដើម , ចំពោះធាតុ ៣ មានធាតុស្លេស្មជាដើម និង ចំពោះចរិយា ៣ មានមោហចរិយា ជាដើម ។ ពិតហើយ ព្រៃចាត់ជាសេនាសនៈដែលសមគួរក្នុងរដូវក្ដៅ , គល់ឈើចាត់ជាសេនាសនៈដែលសមគួរក្នុងរដូវរងា , សុញ្ញាគារចាត់ជាសេនាសនៈដែលសមគួរក្នុងរដូវភ្លៀង , ព្រៃចាត់ជាសេនាសនៈដែលសមគួរសម្រាប់បុគ្គលដែលមានធាតុស្លេស្ម គឺ មានស្លេស្មជាប្រក្រតី , គល់ឈើចាត់ជាសេនាសនៈដែលសមគួរសម្រាប់បុគ្គលដែលមានធាតុប្រមាត់ , សុញ្ញាគារចាត់ជាសេនាសនៈដែលសមគួរសម្រាប់បុគ្គលដែលមានធាតុខ្យល់ , ព្រៃចាត់ជាសេនាសនៈដែលសមគួរសម្រាប់បុគ្គលមោហចរិត , គល់ឈើ ចាត់ជាសេនាសនៈដែលសមគួរសម្រាប់បុគ្គលទោសចរិត , សុញ្ញាគារ ចាត់ជាសេនាសនៈដែលសមគួរសម្រាប់បុគ្គលដែលជារាគចរិត ។ ពាក្យថា **ជាបក្ខពួកនៃការមិនរួញរា និង ការមិនរើរវាយ** គឺជាបក្ខពួកនៃការមិនរាថយ និង ការមិនរាយមាយ ។ ពិតហើយ ការដេកជាបក្ខពួកនៃការខ្ជិលច្រអូស ។ ការឈរជាបក្ខពួកនៃការរាយមាយ ការអង្គុយមិនបានជា

ដូច្នោះ ។ ព្រោះហេតុនោះ ការអង្គុយនេះ ទើបមានភាវៈស្ងប់ ។ ឈ្មោះថា ទ្រង់សម្តែងភាវៈដែលមាំទាំនៃការអង្គុយ ដោយការអង្គុយពែនភ្នែន , ឈ្មោះថា ទ្រង់សម្តែងភាពជាផាសុកក្នុងការដកដង្ហើមចូល និង ដកដង្ហើមចេញឲ្យប្រព្រឹត្តទៅ ក៏ដោយការតាំងកាយកំណាត់លើឲ្យត្រង់ , ឈ្មោះថា ទ្រង់សម្តែងឧបាយកំណត់នូវអារម្មណ៍ ដោយការតាំងសតិទុកចំពោះមុខ ។

ពាក្យថា **ការអង្គុយបត់ជើង** គឺ ការអង្គុយបត់ជើងចូលតម្រួតលើគ្នា ។ ការតាំងកាយផ្នែកកណ្តាលឲ្យត្រង់ គប្បីជ្រាបបាន ដោយពាក្យពោលដល់ការអង្គុយនោះឯង ។ ក្នុងពាក្យថា **ឧជុំ កាយំ** នេះ **កាយ** សព្ទ មានព្រំដែនត្រឹមកាយខាងលើ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា តាំងសរីរៈផ្នែកខាងលើឲ្យត្រង់ ។ ម្យ៉ាងទៀត ដើម្បីសម្តែងការតាំងឲ្យត្រង់នោះ ដោយសភាវៈដែលមានប្រាកដ និង ដោយប្រយោជន៍ ទើបលោកពោលថា បានដល់ ធ្វើឆ្អឹងខ្នង ១៨ កំណាត់ ដូច្នេះជាដើម ។ ពាក្យថា **នឹងមិនតឹង** គឺ នឹងមិនឱនចុះ ។ ពាក្យថា **នឹងមិនធ្លាក់ទៅ** គឺ នឹងមិនវិនាសទៅ បានដល់ មិនចេញខុសវិថី , ព្រោះហេតុនោះឯង ទើបចូលដល់ការចម្រើន សេចក្តីរុងរឿង ព្រោះជាហេតុឧប្បត្តិនៃគុណវិសេសតឡើងទៅ ។

សព្ទថា **បរិ** ក្នុងពាក្យ **បរិមុខំ** នេះ មានអត្ថដូចសព្ទថា **អភិ** ព្រោះហេតុនោះ ទើបលោកពោលថា **កម្មដ្ឋានាភិមុខំ** ( បែរមុខត្រង់ឆ្ពោះកម្មដ្ឋាន ) មានន័យថា ហាមចេញចាកអារម្មណ៍ដែលមានសភាវៈជាច្រើនក្នុងខាងក្រៅ ញុំាងកម្មដ្ឋានប៉ុណ្ណោះឲ្យចេញមុខ ។ សព្ទថា **បរិ** មានអត្ថថា កំណត់យក ដូចក្នុងពាក្យថា **បរិណាយិកា** ជាដើម ។ ឈ្មោះថា **មានអត្ថថា នាំចេញ** បានដល់ មានអត្ថថា

នាំចេញចាកធម៌ដែលជាបដិបក្ខ , ព្រោះដូច្នោះ ពាក្យថា **ឲ្យមានការនាំចេញកំណត់យកបានហើយ** ទើបមានន័យថា ញ៉ាំងសតិឲ្យមានការកាន់យកការមិនភ្លេច គឺ ឲ្យលះបង់ការវង្វេងភ្លេចដោយប្រការទាំងពួង បានដល់ ចូលទៅតម្កល់សតិដែលវាងវៃយ៉ាងក្រៃលែងទុក ។

ពាក្យថា **ជាអ្នកមានសតិរលឹកបានមាំទាំ** គឺជាអ្នកប្រកបព្រមដោយសតិនោះឯង រឭកចំពោះខ្យល់ដង្ហើមចូល មានន័យថា សម្រាប់ភិក្ខុរូបនេះ ការប្រព្រឹត្តទៅនៃខ្យល់ដង្ហើមចូល ដែលប្រាសចាកសតិសូម្បីតិចតួច មិនមាន ។ ក្នុងបទថា **សតោ បស្សតិ** នេះ គប្បីនាំយក **ឯវ** ស័ព្ទ ( ដែលប្រែថា នោះឯង ) ចូលមកពោលទុកថា **សតោវ បស្សតិ** ប្រែថា អ្នកមានសតិរឭកនោះឯង ដកដង្ហើមចេញ ។

( ចប់ មហាដីកា )

# ពាក្យថា សតោការី

ពាក្យថា **អ្នកមានសតិដកដង្ហើមចេញជាដើម** មានន័យថា ភិក្ខុនោះអង្គុយយ៉ាងនេះ តាំងសតិទុកឲ្យមាំទាំយ៉ាងនេះហើយ មិនលះបង់នូវសតិនោះ ឈ្មោះថាមានសតិដកដង្ហើមចេញ មានសតិដកដង្ហើមចូល មានពាក្យអធិប្បាយថា ជា **សតោការី** - អ្នកមានសតិ ។

ឥឡូវនេះ ព្រះយោគាវចរជាសតោការីដោយអាការណា ដើម្បីនឹងសម្តែងអាការទាំងឡាយនោះ ទើបត្រាស់ថា **ទីឃំ វា អស្សសន្តោ** ជាដើម ពិតហើយ

ក្នុងបដិសម្ភិទាមគ្គលោកពោលពាក្យនេះ ទុកក្នុងវិភង្គនៃបាឋៈថា **សោ សតោវ អស្សសតិ សតោ បស្សសតិ** នោះថា “ ព្រះយោគាវចរភិក្ខុជាសតោការីដោយអាការ ៣២ គឺ ៖

១- កាលលោកដឹងក្នុងការមានអារម្មណ៍តែមួយ ការមិនរេខ្វរាទៅមកនៃចិត្ត ដោយអំណាចនៃការដកដង្ហើមចេញវែង សតិរមែងតាំងមាំ ( ក្នុងអារម្មណ៍នោះ ) លោកក៏ជា **សតោការី** ដោយសតិនោះ ដោយការដឹងនោះ ។

២- កាលលោកដឹងនូវការមានអារម្មណ៍តែមួយ ការមិនរេខ្វរាទៅមកនៃចិត្ត ដោយអំណាចនៃការដកដង្ហើមចូលវែង សតិរមែងតាំងមាំ ( ក្នុងអារម្មណ៍នោះ ) លោកក៏ជា **សតោការី** ដោយសតិនោះ ដោយការដឹងនោះ ។ បេ ។....................

៣១- កាលលោកដឹងនូវការមានអារម្មណ៍តែមួយ ការមិនរេខ្វរាទៅមកនៃចិត្ត ដោយអំណាចនៃការពិចារណាឃើញនូវការរលាស់ចោល ដកដង្ហើមចេញ.............

៣២- កាលលោកដឹងនូវការមានអារម្មណ៍តែមួយ ការមិនរេខ្វរាទៅមកនៃចិត្ត ដោយអំណាចនៃការពិចារណាឃើញនូវការរលាស់ចេញ ដកដង្ហើមចូល សតិរមែងតាំងមាំ ( ក្នុងអារម្មណ៍នោះ ) លោកក៏ជា **សតោការី** ដោយសតិនោះ ដោយការដឹងនោះ ។

## បទថា អស្សាសបស្សាស

ក្នុងបាឋៈទាំងឡាយនោះ បាឋៈថា **ទីឃំ វា អស្សសន្តោ** គឺ ញុំាងអស្សាសៈវែងឲ្យប្រព្រឹត្តទៅ ឬ ក្នុងអដ្ឋកថាព្រះវិន័យពោលថា ខ្យល់ចេញក្រៅ ឈ្មោះថា **អស្សាស** ខ្យល់ចូលក្នុង ឈ្មោះថា **បស្សាស** តែក្នុងអដ្ឋកថាព្រះសូត្រទាំងឡាយ

ផ្សុយគ្នាជាមួយ ( នឹងពាក្យអដ្ឋកថាព្រះវិន័យ ) ក្នុងខ្យល់ ២ យ៉ាងនោះ ពេលដែលគព្ភសេយ្យកសត្វទាំងពួងចេញចាកផ្ទៃមាតា ខ្យល់ខាងក្នុងចេញមកក្រៅមុន ខ្យល់ខាងក្រៅនាំធូលីដ៏ល្អិតចូលទៅខាងក្នុងក្រោយ ល្មមដល់ពិតានមាត់ ក៏រលត់ គប្បីជ្រាបរឿងខ្យល់អស្សាសៈ និងបស្សាសៈយ៉ាងនេះសិន ។

រីឯ ភាពវែង និងខ្លីនៃខ្យល់ទាំង ២ នោះ ភាពវែង និងខ្លីនោះ គប្បីជ្រាបថា ដោយអំណាចអទ្ធានៈ ( គឺ រយៈចម្ងាយ និង រយៈកាល ) ដូចទឹក ឬ ខ្សាច់ក្តី ដែលហូរទៅអស់អទ្ធា គឺ ចម្ងាយ ( ឆ្ងាយ ឬ ជិត ) គេក៏ហៅថា ( ខ្សែទឹក ) វែង ឬ ( ឆ្នេរ ) ខ្សាច់វែង , ខ្សែទឹកខ្លី ឆ្នេរខ្សាច់ខ្លី យ៉ាងណា ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូល ដែលជាធម្មជាតិល្អិតក្រៃលែង ( តែវាចូលទៅ ) ធ្វើអទ្ធានៈ ( គឺ ចម្ងាយ ) ដែលវែង ក្នុងរាងកាយដំរី និង ក្នុងរាងកាយពស់ ពោលគឺ ដងខ្លួនរបស់វា ឲ្យក្រពេញ ហើយចេញមកយូរ ដូចគ្នា ព្រោះដូច្នោះ គេទើបថា ខ្យល់ដង្ហើមរបស់ដំរី និងពស់វែង , ខ្យល់នោះចូលទៅ ធ្វើអទ្ធានៈ ( គឺ ចម្ងាយ ) ដែលខ្លី ពោលគឺ ដងខ្លួនរបស់សត្វ ( ខ្លួនតូច និង ខ្លី ) មានសុនខ និង ទន្សាយជាដើម ឲ្យធាប់ពេញ ហើយចេញមករហ័សដូចគ្នា ព្រោះដូច្នោះ គេទើបថា ខ្យល់ដង្ហើមរបស់សត្វតូច ៗ ខ្លី , ឯក្នុងពួកមនុស្ស ពោលដោយអទ្ធានៈ គឺ កាល អ្នកខ្លះក៏ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលវែង ដូច ( សត្វខ្លួនធំ និងខ្លួនវែង ) មានដំរីនិងពស់ជាដើម អ្នកខ្លះខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលខ្លី ដូចសត្វ ( ខ្លួនតូច និងខ្លួនខ្លី ) មានសុនខ និង ទន្សាយជាដើម ព្រោះហេតុនោះ ខ្យល់ដង្ហើមរបស់ពួកមនុស្សនោះ កាលចេញក្តី ចូលក្តី ស៊ីរយៈពេលច្រើន គប្បីជ្រាបថា វែង , កាលចេញក្តី ចូលក្តី ស៊ីរយៈពេលតិច គប្បីជ្រាបថា ខ្លី គឺ

ទាក់ទងក្នុង ពេលវេលា ។

## អានាបានស្សតិ
## ជាកាយានុបស្សនាសតិប្បដ្ឋាន

ក្នុងការដកដង្ហើមចេញនិងចូលវែងនោះ ភិក្ខុនេះ កាលដកដង្ហើមចេញក្តី ដកដង្ហើមចូលក្តី វែង រមែងដឹងច្បាស់ថា យើងដកដង្ហើមចេញដកដង្ហើមចូលវែង ដោយអាការ ៩ យ៉ាង ហើយកាលដឹងយ៉ាងនោះ គប្បីជ្រាបថា ជាសតិប្បដ្ឋាន-ភាវនាផ្នែកកាយានុបស្សនា រមែងសម្រេចដោយអាការម្យ៉ាង ដូចលោកពោលទុកក្នុងបដិសម្ភិទាមគ្គថា " សួរថា ព្រះយោគាវចរ ដកដង្ហើមចេញវែង ក៏ដឹងថា ដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងថា យើងដកដង្ហើមចូលវែង ដោយអាការដូចម្តេច " ឆ្លើយថា ភិក្ខុដកដង្ហើមចេញ ជាខ្យល់ដង្ហើមចេញវែង ព្រោះការរាប់ដោយរយៈវែង , ស្រូបខ្យល់ចូល ខ្យល់ដង្ហើមចូលយូរ ព្រោះស៊ីពេលច្រើន ទាំងបញ្ចេញខ្យល់ និងស្រូបខ្យល់ ជាខ្យល់ចេញនិងខ្យល់ចូលវែង ព្រោះស៊ីរយៈពេលច្រើន ។

កាលលោក ទាំងបញ្ចេញខ្យល់ ទាំងស្រូបខ្យល់ ជាខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលវែង ព្រោះស៊ីពេលច្រើន , ឆន្ទៈកើតឡើង ដោយអំណាចឆន្ទៈ លោកដកដង្ហើមចេញ ជាខ្យល់ចេញវែង ព្រោះស៊ីពេលច្រើន ជាខ្យល់ល្អិតជាងមុននោះ , ដោយអំណាចឆន្ទៈ កាលស្រូបខ្យល់ចូល ជាខ្យល់ចូលវែង ព្រោះស៊ីពេលច្រើន កាលខ្យល់ល្អិតជាងមុន , ដោយអំណាចឆន្ទៈ ទាំងបញ្ចេញខ្យល់ ទាំងស្រូបខ្យល់ ជាខ្យល់ដង្ហើមចេញនិងខ្យល់ដង្ហើមចូលវែង ព្រោះស៊ីពេលច្រើន ។

លោក កាលទាំងបញ្ចេញខ្យល់ចេញ ទាំងស្រូបខ្យល់ចូល ជាខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលវែង ព្រោះស៊ីពេលច្រើន ព្រោះខ្យល់ល្អិតជាងមុន ដោយអំណាចឆន្ទៈ បាមោជ្ជក៏កើតឡើង , ដោយអំណាចបាមោជ្ជ លោកបញ្ចេញខ្យល់ចេញ ជាខ្យល់ដង្ហើមចេញវែង ព្រោះស៊ីពេលច្រើន ជាខ្យល់ដង្ហើមល្អិតក្រៃលែងជាងខ្យល់នោះ ៗ , ដោយអំណាចបាមោជ្ជ លោកស្រូបខ្យល់ ជាខ្យល់ចូលវែង ព្រោះស៊ីពេលច្រើន ជាខ្យល់ល្អិតជាងខ្យល់នោះៗ , ដោយអំណាចបាមោជ្ជ លោកបញ្ចេញខ្យល់ចេញ ទាំងស្រូបចូល ជាខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលវែង ព្រោះស៊ីពេលច្រើន ជាខ្យល់ល្អិតជាងខ្យល់នោះៗទៅទៀត ។

កាលទាំងបញ្ចេញខ្យល់ចេញ និងស្រូបចូល ជាខ្យល់ចេញ និងខ្យល់ចូលវែង ព្រោះស៊ីពេលច្រើន ជាខ្យល់ល្អិតក្រៃលែងជាងនោះ ដោយអំណាចបាមោជ្ជ ចិត្តក៏គ្រាកចេញចាកខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលវែង ឧបេក្ខាក៏កើតឡើង ។

ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលវែង ដោយអាការ ៩ នេះ រាប់ជាកាយ វត្ថុដែលធ្វើកាយនោះ ( ឲ្យជាអារម្មណ៍ ) តាំងមាំ ជាសតិ , អនុបស្សនា ( ការតាមកំណត់មើលកាយឲ្យដឹងតាមដែលវាកើត ) ជាញាណ , កាយដែលជាទីចូលទៅតាំងមាំនៃសតិ មិនមែនសតិ សតិជាវត្ថុចូលទៅតម្កល់ និងជាអ្នករលឹកផង ព្រះយោគាវចរតាមកំណត់មើលកាយនោះដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា " ការតាមកំណត់មើលកាយក្នុងកាយ ជាការបំពេញសតិប្បដ្ឋាន " ។

ន័យក្នុង វេស្សៈបទ ( បទថា ខ្យល់ដង្ហើមខ្លី ) ក៏មានន័យដូច្នេះ តែនេះជា

សេចក្តីខុសគ្នា គឺ ពាក្យថា **ទីឃំ អស្សាសំ អទ្ធានសង្ខាតេ** ជាខ្យល់ដង្ហើមចេញវែង ព្រោះស៊ីពេលច្រើន ) , ទ្រង់ពោលទុកក្នុង ទីឃៈបទ ( បទថា ខ្យល់ដង្ហើមវែង ) នោះយ៉ាងណា ក្នុងរស្សៈបទនេះ ពាក្យនោះ ក៏មកថា **រស្សំ អស្សាសំ ឥត្តរសង្ខាតេ អស្សសតិ** ( បញ្ចេញខ្យល់ចេញជាខ្យល់ដង្ហើមខ្លី ) ព្រោះស៊ីពេលតិច ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីប្រកបពាក្យចូលដោយប្រើរស្សៈស័ព្ទ ( ជំនួសទីឃៈ ស័ព្ទ ) ទៅរហូតដល់ពាក្យថា **តេន វុច្ចតិ កាយេ កាយានុបស្សនា សតិប្បដ្ឋានភាវនា** ( ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា ការតាមកំណត់មើលកាយក្នុងកាយ ជាការបំពេញសតិប្បដ្ឋាន ) ដូច្នេះចុះ ។

ព្រះយោគាវចរនេះ កាលដឹងខ្យល់ដង្ហើមចេញ ខ្យល់ដង្ហើមចូលតាមអាការទាំងឡាយនេះ ទាំងដោយរយៈពេលវែង និងរយៈពេលខ្លី យ៉ាងនេះ បណ្ឌិតគប្បីជ្រាបថា លោកបានឈ្មោះថា កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា យើងដកដង្ហើមចេញវែង ឬ កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា ដកដង្ហើមចូលវែង , កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា យើងដកដង្ហើមចេញខ្លី ឬកាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា ដកដង្ហើមចូលខ្លី ( ដូចពោលមកក្នុងព្រះបាលី ) កាលភិក្ខុនោះ ដឹងយ៉ាងនេះ ៖

**ខ្យល់ ៤ យ៉ាង គឺ ខ្យល់ដង្ហើមចេញវែង និង ខ្លី សូម្បីខ្យល់ដង្ហើមចូលក៏យ៉ាងនោះ រមែងប្រព្រឹត្តទៅត្រង់ចុងច្រមុះរបស់ភិក្ខុនោះ ។**

## មហាដីកា

ពាក្យថា **ជាសតោការី** គឺ ជាអ្នករលឹកបាននោះឯង បានដល់ ធ្វើកិច្ចដែល

គប្បីធ្វើដោយសតិ ឬ ជាអ្នកមានប្រក្រតីចម្រើនសតិ ។

**សួរថា** បើជាពាក្យអធិប្បាយដែលទ្រង់ពោលទុក ក្នុងវិភង្គនៃបាឋៈនេះ ថា **សតោវ អស្សសតិ សតោ បស្សសតិ** ដូច្នោះ ព្រោះហេតុអ្វី ទើបទ្រង់មិនពោលថា **អស្សសតិ**-ខ្យល់ដង្ហើមចូល **បស្សសតិ**-ខ្យល់ដង្ហើមចេញ នោះទៅ , បែរជាពោលថា **សតោការី** ទៅវិញ ?

**ឆ្លើយថា** ទ្រង់មិនពោល **អស្សសតិ បស្សសតិ** តែពោលថា **សតោការី** ដូច្នេះ ក៏ព្រោះទ្រង់បំណងនឹងធ្វើព្រះធម៌ទេសនា ឲ្យមានរសតែមួយដូចគ្នា ។

ពិតហើយ ២ បទដំបូង ក្នុងបឋមចតុក្កៈប៉ុណ្ណោះ ដែលមកហើយទាក់ទងនឹងបច្ចុប្បន្នកាល បទក្រៅពីនេះមកហើយទាក់ទងជាអនាគតកាល ព្រោះដូច្នោះ ព្រោះទ្រង់បំណងនឹងធ្វើព្រះធម៌ទេសនា ឲ្យមានរសតែមួយ ទ្រង់ទើបពោលទុកក្នុងបទទាំងពួងថា **សតោការី** ប៉ុណ្ណោះ ។

ប្រការថា **ទីឃំ អស្សាសវសេន** ជាពាក្យសម្ដែងអធិប្បាយដែលមិនលុបវិភត្តិ ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង , ម្យ៉ាងទៀត ប្រែថា ដោយអំណាចនៃខ្យល់ដង្ហើមចូល ដែលព្រះមានព្រះភាគ ត្រាស់ហៅថា **វែង** ។ ពាក្យថា **ដល់នូវការមានអារម្មណ៍តែមួយ** គឺ ការមិនរាយមាយនៃចិត្ត មានន័យថា កាលលោកដឹងច្បាស់នូវការមានអារម្មណ៍តែមួយ ( ឯកគ្គតាវៈ ) នៃចិត្តដែលបានឈ្មោះថា **អវិក្ខេប-ការមិនរាយមាយ** ព្រោះជាបដិបក្ខចំពោះ **វិក្ខេប-ការរាយមាយ** ។ ពាក្យថា **សតិរមែងជាធម្មជាតិចូលទៅតម្កល់ទុកហើយ** គឺ សតិជាធម្មជាតិចូលទៅកាន់អារម្មណ៍ ហើយតាំងនៅ ។ ពាក្យថា **ដោយសតិនោះ ដោយញាណនោះ** គឺដោយសតិតាមដែលពោលហើយ និងដោយញាណតាមដែលពោលហើយ , សេចក្ដីនេះ

មានពាក្យអធិប្បាយថា កាលលោកមានចិត្តមិនរាយមាយ ឬថា មិនវង្វេង ដឹងច្បាស់ នូវខ្យល់ដង្ហើមចូលវែងជាអារម្មណ៍ **សតិ** ក៏ឈ្មោះថា ជាធម្មជាតិចូលទៅតាំងមាំក្នុងអារម្មណ៍នោះហើយ , កាលដឹងច្បាស់ដោយល្អ នូវខ្យល់ដង្ហើមចូលវែងនោះ ទាក់ទងនឹងការធ្វើឲ្យជាអារម្មណ៍ក្តី , ទាក់ទងនឹងការមិនវង្វេងក្តី **សម្បជញ្ញៈ** ក៏ឈ្មោះថា ជាធម្មជាតិចូលទៅតាំងនៅក្នុងអារម្មណ៍នោះហើយដែរ , ព្រះយោគីជាអ្នកដែលព្រមព្រៀងដោយសតិសម្បជញ្ញៈនោះ ឈ្មោះថា **ជាសតោការី** ព្រោះសតិសម្បជញ្ញៈទាក់ទងនឹងខ្យល់ដង្ហើមចូលវែងនោះឯង ។

២ បទថា **បដិនិស្សគ្គានុបស្សី អស្សាសវសេន** ប្រែថា ដោយអំណាចជាអ្នកពិចារណាឃើញរឿយៗ នូវការសញ្ចរទៅនៃខ្យល់ដង្ហើមចូល ឬ ឋានៈជា **បដិនិស្សគ្គានុបស្សីអស្សាសវសេន** ដូច្នេះក៏បាន ។ សេចក្តីថា ខ្យល់ដង្ហើមចូលរបស់ព្រះយោគាវចរដែលពិចារណាឃើញរឿយ ៗ នូវការសញ្ចរទៅ ឈ្មោះថា **បដិនិស្សគ្គានុបស្សីអស្សាសា** បានដល់ ដោយអំណាចនៃបដិនិស្សគ្គានុបស្សីអស្សាសា នោះ ។ តាមន័យនៃព្រះវិន័យ ខ្យល់ដែលតាំងឡើងខាងក្នុង ឈ្មោះថា **អស្សាស** , ខ្យល់ដែលតាំងឡើងខាងក្រៅ ឈ្មោះថា **បស្សាស** , តែដោយន័យព្រះសូត្រ ខ្យល់តាំងឡើងខាងក្រៅ ឈ្មោះថា **អស្សាស** , ខ្យល់ដែលតាំងឡើងខាងក្នុង ឈ្មោះថា **បស្សាស** ព្រោះបញ្ចេញខ្យល់ទៅខាងក្រៅ ។ ឯន័យក្នុងព្រះសូត្រនេះ ស្មើគ្នានឹងព្រះបាលីថា ៖

កាលភិក្ខុញុំាងសតិឲ្យជាប់តាមខ្យល់ខាងដើម ខ្យល់កណ្តាល និង ខ្យល់ខាងចុង នៃខ្យល់អស្សាសៈ កាលបើចិត្តដល់នូវការរាយមាយទៅខាងក្នុង ទាំងកាយ ទាំងចិត្ត ក៏នាំឲ្យរសាប់រសល់ ញាប់ញ័រ និង ក្រហល់ក្រហាយ , កាលភិក្ខុ

ញុាំងសតិឲ្យជាប់តាមខ្យល់ខាងដើម ខ្យល់កណ្តាល ខ្យល់ខាងចុង នៃខ្យល់បស្សាសៈ កាលបើចិត្តរាយមាយទៅខាងក្រៅ ទាំងកាយ ទាំងចិត្ត ក៏នាំឲ្យរសាប់រសល់ ញាប់ញ័រ និង ក្រហល់ក្រហាយ ។

ព្រះអដ្ឋកថាចារ្យពោលថា ខ្យល់ខាងក្នុង រមែងចេញទៅខាងក្រៅមុន ព្រោះដូច្នោះ ដោយលំដាប់នៃការប្រព្រឹត្តទៅ ទើបទ្រង់ត្រាស់ខ្យល់អស្សាសៈមុន ។ ពាក្យថា **ទល់ពិតានមាត់ហើយក៏រលត់ទៅ** គឺ ដល់ពិតានមាត់ហើយ ក៏រលត់ទៅ ។ គប្បីជ្រាបតាមពាក្យរបស់លោកថា ទារកដែលទើបតែកើតភ្លាម រមែងស្ទះខ្យល់ ។ ប្រការថា **ឯវំ តាវ** ជាដើម ជាពាក្យពោលដល់សេចក្តីតាមដែលពោលហើយ ។ អាចារ្យពួកខ្លះពោលថា ក្នុងន័យថា **ឯវំ តាវ** នេះ មានអធិប្បាយថា បណ្ឌិតគប្បីកាន់យកថា ខ្យល់អស្សាសៈ បានដល់ខ្យល់ដង្ហើមចេញទៅខាងក្រៅ តាមលំដាប់នៃការប្រព្រឹត្តទៅ ។

ពាក្យថា **ដោយអំណាចនៃអទ្ធានៈ** បានដល់ ដោយអំណាចនៃអទ្ធានៈ គឺ ពេលវេលា ។ ដោយស័ព្ទថា **អទ្ធាន** នេះ ប្រែថា ពេលវេលា និង ទេសៈ ( ទីកន្លែង ) ។ ក្នុង **អទ្ធានៈ** ទាំង ២ នោះ លោកអាចារ្យបំណងសម្តែងអទ្ធានៈ គឺ ទេសៈ ក្នុងភាពជាឧទាហរណ៍ ហើយបើកផ្សារកាលវែង និង ខ្លី នៃខ្យល់អស្សាសៈ និង បស្សាសៈ ទុកដោយអំណាចនៃអទ្ធានៈ គឺ ពេលវេលា ទើបពោលថា **យថាហិ** ដូច្នេះជាដើម ។ ក្នុងបទទាំងឡាយនោះ បទថា **ឱកាសទ្ធានំ** ប្រែថា អទ្ធានៈដែលជាឱកាស ( ទីតាំង ) ។ បទថា **ផរិត្វា** ប្រែថា ផ្សាយទៅ ។ ឈ្មោះថាសូម្បីល្អិតសុខុម ក៏ព្រោះមានច្រើនក្រុម ។ ពាក្យថា **អទ្ធានៈដែលវែង** គឺប្រទេស ( ចម្ងាយ , បរិវេណ ) ដែលវែង ។ ពាក្យថា **ព្រោះដូច្នោះ** មានន័យថា ព្រោះ

ការបន្តគ្នាយូរ ដោយប្រព្រឹត្តទៅយូរ ៗ ទើបហៅថា **វែង** ដូច្នោះ ។ ក្នុងអធិការនេះ បណ្ឌិតគប្បីជ្រាបថា លោកពោលនូវភាព វែង និង ខ្លី នៃខ្យល់អស្សាសៈ និងបស្សាសៈ ក្នុងរាងកាយដំរីជាដើម និងក្នុងរាងកាយសុនខជាដើម ទុកដោយអំណាចនៃអទ្ធានៈ គឺ ពេលវេលា ជាពិសេសដោយអទ្ធានៈ គឺ ទីតាំងនោះឯង ព្រោះមានពាក្យថា " ឲ្យក្រពេញ និង ចេញមកយូរដូចគ្នា " និងថា " ឲ្យធាប់ពេញ និងចេញមកក៏រហ័សដូចគ្នា " ។ ពាក្យថា **ក្នុងពួកមនុស្ស** គឺ ក្នុងរាងកាយរបស់មនុស្សទាំងឡាយដែលមានខ្នាតប៉ុនគ្នា ។ ពាក្យថា **ខ្យល់ដង្ហើមចូលវែង** មានន័យថា ការបន្តគ្នាទៅនៃខ្យល់ដង្ហើមចូលនោះប្រព្រឹត្តទៅយូរ ។ សូម្បីក្នុងពាក្យថា **ខ្យល់ដង្ហើមចេញ** ក៏មានន័យដូច្នេះដែរ ។ ប្រកបសេចក្តីថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញខ្លី ដូចជាសត្វទាំងឡាយ មានសុនខ ឬ ទន្សាយជាដើម ។ បណ្ឌិតគប្បីឃើញថា ការដកដង្ហើមចូល និង ដកដង្ហើមចេញ វែងនិងខ្លី នេះ ជាសភាពនៃសរីរៈរបស់សត្វទាំងឡាយនោះ ។ បទថា **តេសំ យោគ សត្តានំ** ប្រែថា របស់សត្វទាំងឡាយនោះ ។ បទថា **តេ យោគ អស្សាសបស្សាសា** ប្រែថា ខ្យល់ អស្សាសៈ និង បស្សាសៈ ទាំងឡាយនោះ ។ ពាក្យថា **ស៊ីពេលតិចតួច** គឺ អស់កាលតិច ។

ពាក្យថា **ដោយអាការ ៩** បានដល់ ដោយអាការ ៩ ទាំងឡាយនេះ គឺ ៣ អាការ ដែលលោកពោលទុកក្នុងខាងដើម ទាក់ទងនឹងពេលវេលាសុទ្ធ ៗ នៃព្រះយោគាវចរដែលបំពេញភាវនា មិនទាន់បានគុណវិសេសបន្តគ្នាទៅតាមលំដាប់ , ឯ ៣ អាការ នោះ លោកពោលទុកទាក់ទងនឹងបុគ្គល ៣ ចំពូកទាំងឡាយនេះ គឺ ពួក ១ កំណត់ខ្យល់ដង្ហើមចូលបានល្អ , ពួក ១ កំណត់ខ្យល់ដង្ហើមចេញបានល្អ ,

ពួក ១ កំណត់ខ្យល់ទាំង ២ នោះ បានល្អ ។ តែអាចារ្យពួកខ្លះពោលថា ពាក្យដែលលោកពោលរួមគ្នាទុកថា រមែងទាំងស្រូប និង បញ្ចេញ ដូច្នេះ លោកពោលទុកដើម្បីសម្តែងនូវការប្រព្រឹត្តទៅមិនដាច់ខ្សែនៃភាវនា ។ ៣ អាការ ដូចខាងដើមទាក់ទងនឹងឆន្ទៈ , ៣ អាការទៀត ទាក់ទងនឹងបាមោជ្ជ ។

ម្យ៉ាងទៀត ក្នុងបណ្តាអាការទាំង ៩ នេះ សម្រាប់បុគ្គលម្នាក់រមែងបានត្រឹម ៣ អាការ ប៉ុណ្ណោះ ក៏ពិត , តែដែលលោកពោលទុក ( ក្នុងវិសុទ្ធិមគ្គនោះ ) ថាភិក្ខុនេះ កាលដកដង្ហើមចូល និង ដកដង្ហើមចេញវែង ដោយអាការ ៩ ដូច្នេះ ក៏ព្រោះអាការទាំងពួង ឡើងកាន់ព្រះបាលី ទាក់ទងជាបែបផែន , និង ព្រោះព្រះយោគាវចរ គប្បីធ្វើបរិកម្មបាន ក៏ដោយអំណាចនៃអាការទាំងឡាយនោះ ។ ពាក្យថា **កាលលោកដឹងច្បាស់យ៉ាងនេះ** មានន័យថា កាលលោកដឹងច្បាស់នូវខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ គឺ ធ្វើមនសិការឲ្យប្រព្រឹត្តទៅក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះ ដោយអាការតាមដែលពោលហើយយ៉ាងនេះ ។ ពាក្យថា **ដោយអាការ ១** គឺ ដោយអាការ ១ ក្នុងអាការ ៤ មានខ្យល់ដង្ហើមចូលវែងជាដើម , ដែលជាអាការ ១ ក្នុងបណ្តាអាការ ៩ ឬ ៣ ។ ពិតហើយ លោកពោលថា អាការ ៤ គឺ ខ្យល់ដង្ហើមចូលវែង ១ ខ្លី ១ និង ខ្យល់ដង្ហើមចេញ ក៏ដូច្នោះ ( គឺ វែង ១ ខ្លី ១ ) រមែងប្រព្រឹត្តទៅ ត្រង់ចុងច្រមុះរបស់ភិក្ខុ ។

លោកអាចារ្យធ្វើទុកក្នុងចិត្តថា ភាវនានេះ គឺ ពិចារណាឃើញរឿយ ៗ នូវកាយ គឺ ខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ , ដូច្នេះហើយ ទើបពោលថាសម្រេចកាយានុបស្សនាសតិប្បដ្ឋានភាវនា ។

ឥឡូវនេះ លោកបំណងសម្តែងនូវអាការ ៩ ទាំងនោះ និង ភាវនាវិធីដោយ

អំណាចនៃព្រះបាលីនោះឯង ទើបផ្ដើមពាក្យថា **យថាហ** ដូច្នេះ ជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ដោយពាក្យថា ដូចម្ដេចទៅ ដែលដឹងច្បាស់ថា ខ្យល់ដង្ហើមចេញវែង ដូច្នេះ លោកសួរ ដោយត្រូវការនឹងពោលនូវវិធីដើម្បីឲ្យដឹងច្បាស់ ។ ២ បទថា **ទីឃំ អស្សាសំ** បានដល់ ខ្យល់ដង្ហើមចូលវែង មានលក្ខណៈដូចពោលមកហើយ ។ ពាក្យថា **ក្នុងកាលដែលរាប់ថាវែង-អទ្ធានសង្ខាតេ** គឺ ក្នុងកាលដែលយូរ ដែលដល់នូវការរាប់បានថា ជាអទ្ធានៈ មានន័យថា អស់ពេលយូរ, ន័យម្យ៉ាងទៀត ស័ព្ទថា **សង្ខាត** ជាពាក្យប្រើជំនួសពាក្យថា **កោដ្ឋាស** ( ប្រែថា ចំណែក ) ដូចក្នុងពាក្យថា **ថេយ្យសង្ខាតំ** ប្រែថា ចំណែកនៃការលួចជាដើម , ព្រោះដូច្នោះ ពាក្យថា **អទ្ធានសង្ខាតេ** ទើបមានសេចក្ដីថា **អទ្ធានកោដ្ឋាសេ** គឺ ចំណែកដែលជាស្ថានទី ។ ពាក្យថា **ឆន្ទៈក៏រមែងកើតឡើង** មានន័យថា ព្រោះបានទទួលនូវសេចក្ដីរីករាយក្នុងភាវនា ដែលនាំមកនូវគុណវិសេស បន្ទាប់ទៅតាមលំដាប់ កុសលឆន្ទៈដ៏ប្រសើរ ដែលមានសេចក្ដីប្រាថ្នាក្នុងការបំពេញភាវនានោះ ជាលក្ខណៈ រមែងកើតឡើង ។ ពាក្យថា **ដោយអំណាចនៃឆន្ទៈ** គឺ ដោយអំណាចនៃឆន្ទៈដែលប្រព្រឹត្តទៅយ៉ាងនោះ ក្នុងការញុំាងកម្មដ្ឋានរបស់ព្រះយោគីដែលបំពេញភាវនា ប្រព្រឹត្តទៅជាមួយគុណវិសេស ឲ្យដល់នូវការចម្រើនឧត្ដុង-ឧត្ដម ។ ពាក្យថា **ដែលល្អិតជាងនោះ** គឺ ដែលល្អិតជាងខ្យល់មុនៗ ព្រោះការប្រព្រឹត្តទៅនៃឆន្ទៈតាមដែលពោលហើយ ។ ពិតហើយ ព្រោះស្ងប់រម្ងាប់នូវសេចក្ដីរសាប់រសល់ និង ការក្ដៅក្រហាយកាយបានហើយ ដោយកម្លាំងនៃភាវនា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ទើបប្រព្រឹត្តទៅជាធម្មជាតិល្អិតសុខុម ។ ពាក្យថា **បាមោជ្ជរមែងកើតឡើង** មានន័យថា ព្រោះកម្មដ្ឋានប្រព្រឹត្តទៅក្នុងវិថីបានហើយ

ព្រោះការដែលអារម្មណ៍ស្ងប់ប្រណីតឡើង តាមភាពល្អិតសុខុមឡើងនៃខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ , បាមោជ្ជដែលសហគតៈដោយការនោចិត្ត គឺតរុណបីតិ មានប្រភេទជា ខុទ្ទកាបីតិជាដើម ទើបកើតឡើង ។ ពាក្យថា **ចិត្តរមែងងាកចេញ** អាចារ្យពួកខ្លះពោលថា ក្នុងការដែលខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញមិនប្រាកដ ព្រោះដល់នូវភាពល្អិតសុខុម ក្រៃលែងឡើងតាមលំដាប់ ចិត្តក៏រមែងងាកចាកខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញទាំងឡាយនោះ ដែលដល់នូវអាការត្រូវស្វែងរក ដូច្នេះ ។ កាលបដិភាគនិមិត្តកើតឡើងហើយ ក្នុងខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ដែលមានសភាពល្អិតសុខុមដោយកម្លាំងនៃការនោនោះ ចិត្តរមែងងាកត្រឡប់ចាកខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ តាមប្រក្រតី ។

ពាក្យថា **ឧបេក្ខារមែងប្រាកដឡើង** មានន័យថា កាលសមាធិដែលមានប្រភេទជាឧបចារៈ និងអប្បនា កើតឡើងហើយក្នុងបដិភាគនិមិត្តនោះ ភាពព្រងើយរមែងកើតឡើង ព្រោះមិនមានសេចក្តីព្យាយាម ដើម្បីញុំាងឈានឲ្យកើតឡើងទៀត ។ **ឧបេក្ខា** នេះគប្បីជ្រាបថា បានដល់ តត្រមជ្ឈត្តុបេក្ខា “ ឧបេក្ខា គឺ ភាពជាកណ្តាលក្នុងធម៌នោះៗ ” ។

ពាក្យថា **ដោយអាការ ៩ ទាំងឡាយនេះ** គឺ ប្រព្រឹត្តទៅដោយអាការ ៩ តាមដែលពោលហើយនេះ ។ ពាក្យថា **ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញវែង ចាត់ជាកាយ** មានន័យថា ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញដែលមានអាការវែង និងល្អិតសុខុម ចាត់ជាកាយ ដោយការសម្គាល់ថា ជាគំនរ ។ សូម្បីនិមិត្តដែលអាស្រ័យខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញកើតឡើង ក្នុងទីនេះ លោកក៏ពោលទុក ស្មើគ្នានឹងខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញនោះឯង ។ ពាក្យថា

**ឧបដ្ឋាន ចាត់ជាសតិ** គឺ សតិ ឈ្មោះថា **ឧបដ្ឋាន** ព្រោះអត្ថថា ចូលទៅកាន់អារម្មណ៍នោះ ហើយតាំងមាំ ។ ពាក្យថា **អនុបស្សនា ចាត់ជាញាណ** មានន័យថា ការពិចារណាឃើញរឿយៗ នូវនិមិត្តដោយអំណាចសមថៈ និង ការពិចារណាឃើញរឿយៗ នូវនាមរូប ដោយអំណាចខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ , និងកាយដែលជាទីអាស្រ័យនៃខ្យល់ដង្ហើមទាំងឡាយនោះថា **ជារូប** កំណត់ចិត្ត និងធម៌ទាំងឡាយសម្បយុត្តជាមួយចិត្តនោះថា **ជានាម** ដោយអំណាចវិបស្សនា ចាត់ជាញាណ បានដល់ ការដឹងតាមសេចក្ដីពិតក្នុងធម៌ទាំងឡាយនោះ ។ ពាក្យថា **កាយ ឈ្មោះថា ឧបដ្ឋាន** មានន័យថា កាយនោះ ឈ្មោះថា **ឧបដ្ឋាន** ព្រោះអត្ថថា ជាទីដែលសតិចូលទៅតម្កល់ ទាក់ទងនឹងការធ្វើឲ្យជាអារម្មណ៍ ។ ក្នុងអធិការនេះ ដោយពាក្យថា “ **កាយ ឈ្មោះថា ឧបដ្ឋាន** ” នេះ មានការសង្គ្រោះយកកាយខាងក្រៅផង ( មិនមែនសំដៅយកតែខ្យល់ដង្ហើមចូលចេញប៉ុណ្ណោះទេ ) ព្រោះក្នុងទីនេះ សូម្បីការពិចារណាតាមដែលពោលហើយ លោកក៏យក ។ ពាក្យថា **មិនឈ្មោះថា សតិ** គឺ កាយនោះឈ្មោះថា សតិ មិនបាន ។ **សតិ** ឈ្មោះថា **ឧបដ្ឋាន** ផង ឈ្មោះថា **សតិ** ផង ព្រោះជាសភាវៈដែលគប្បីរលឹក និងជាសភាវៈដែលចូលទៅតម្កល់ ។ ពាក្យថា **ដោយសតិនោះ** គឺ ជាសតិតាមដែលពោលហើយ ។ ពាក្យថា **ដោយញាណនោះ** គឺ ដោយញាណតាមដែលពោលហើយដូចគ្នា ។ ពាក្យថា **កាយនោះ** គឺ នូវកាយ បានដល់ ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះឯង និងរូបកាយដែលជាទីអាស្រ័យនៃខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញនោះ ។ ពាក្យថា **រមែងពិចារណាឃើញរឿយ ៗ** គឺ រមែងពិចារណាឃើញរឿយ ៗ ដោយញាណដែលសម្បយុត្តដោយឈាន និង ដោយវិបស្សនា-

ញាណនោះឯង ។ ពាក្យថា **ព្រោះហេតុនោះ ទើបហៅថា កាយេ កាយានុបស្សនា-សតិប្បដ្ឋានភាវនា** មានន័យថា ព្រោះការពិចារណាឃើញរឿយៗ នោះ ទើបហៅភាវនានេះថា ការចម្រើនសតិប្បដ្ឋាន ដែលសម្បយុត្តជាមួយការពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ តាមដែលពោលហើយ ។

សេចក្ដីនេះ មានការពោលអធិប្បាយទុកថា ការពិចារណាឃើញរឿយៗ នូវកាយនោះឯង ក្នុងកាយ គឺ ខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ តាមដែលពោលហើយ និងក្នុងករជកាយដែលជាទីអាស្រ័យនៃខ្យល់ដង្ហើមនោះ សេចក្ដីនេះយ៉ាងណា មិនមែនជាការពិចារណាឃើញរឿយ ៗ នូវភាពជាធម្មជាតិទៀងជាដើមក្នុងកាយដែលមានសភាវៈមិនទៀងជាដើម ដូចការឃើញទឹកក្នុងថ្ងៃបណ្ដើរកូនដែលជាស្ថានទីមិនមានទឹកដូច្នោះ , តែថា ជាការពិចារណាឃើញរឿយ ៗ នូវភាពជាធម្មជាតិ មិនទៀង ជាទុក្ខ ជាអនត្តា និង មិនស្អាត តាមសមគួរប៉ុណ្ណោះឯង ។ម្យ៉ាងវិញទៀត ព្រោះធម្មជាតិណា ៗ ដែលគប្បីប្រកាន់ថា **យើង** ក្ដី , ថា **របស់យើង** ក្ដី , ថា **ស្ត្រី** ក្ដី , ថា **បុរស** ក្ដី មិនមានក្នុងកាយ , ការមិនពិចារណាឃើញរឿយៗ នូវធម្មជាតិដែលដូច្នោះ តែពិចារណាឃើញរឿយៗ នូវកាយនោះប៉ុណ្ណោះឯង ឈ្មោះថា **កាយានុបស្សនា** , **សតិ** ដែលសម្បយុត្តជាមួយកាយានុបស្សនានោះឯង ជាឧបដ្ឋាន ទើបឈ្មោះថា **សតិប្បដ្ឋាន** , ភាវនា គឺ ការចម្រើនសតិប្បដ្ឋាននោះ ឈ្មោះថា **កាយានុបស្សនាសតិប្បដ្ឋានភាវនា** ដូច្នេះឯង ។

ពាក្យថា **មានន័យដូច្នេះ** លោកសំដៅវិធីដែលបានពោលហើយ ដោយពាក្យថា **នវហិ អាការេហិ** ជាដើម ទុកក្នុងវេស្សបទ ( បទដែលកំណត់ទុកដោយខ្យល់ដង្ហើមវែង ) ។ បទថា **ឯត្ថ** ( ក្នុងន័យព្រះបាលីមកហើយ ទាក់ទងនឹងបទកំណត់ទុក

ដោយខ្យល់ដង្ហើមវែង ) គឺ ក្នុងន័យព្រះបាលីដែលមកហើយ ដោយបទថា **កថំ ទីឃំ អស្សសន្តោ** ជាដើម តាមដែលព្រះសារីបុត្តត្ថេរបានសម្តែងទុក ។ បទថា **ឥធ** ប្រែថា ក្នុងន័យព្រះបាលីដែលមកហើយ ដោយទាក់ទងនឹងបទដែលកំណត់ទុកដោយខ្យល់ដង្ហើមខ្លីនេះ ។

បទថា **អយំ យោគ យោគាវចរោ** ប្រែថា ព្រះយោគាវចរ ។ បទថា **អទ្ធានវសេន** ប្រែថា ទាក់ទងនឹងពេលវេលាដែលយូរ ។ បទថា **ឥត្តរវសេន** ប្រែថា ទាក់ទងនឹងពេលវេលាដែលតិច ។ ពាក្យថា **ដោយអាការទាំងឡាយនេះ** គឺ ដោយអាការទាំង ៩ នេះ ។

ពាក្យថា ( **សូម្បីខ្យល់ដង្ហើមចេញ** ) **ក៏ដូច្នោះ** គឺ ចម្ងាយឆ្ងាយ ១ និង ជិត ១ ។ ២បទថា **ចត្តារោ វណ្ណា** ប្រែថា អាការ ៤ , ឯអាការ ៤ ទាំងឡាយនោះ បានដល់ អាការដែលវែងជាដើមនោះឯង ។ ២ បទថា **នាសិកគ្គេ វ ភិក្ខុនោ** មានន័យថា លោកពោលធ្វើឲ្យជារស្សៈ ( សំឡេងខ្លី ) ថា **នាសិកគ្គេវ** ជំនួស **នាសិកគ្គេ វា** ដើម្បីងាយស្រួលដល់ការប្រព័ន្ធគាថា , **វា** សព្ទ មានអត្ថថា កំណត់ពិតប្រាកដ , ដោយ **វា** សព្ទ នោះ លោកសង្គ្រោះយកបរិវេណរឹមបបូរមាត់លើផង ។

( ចប់ មហាដីកា )

# បទថា សព្វកាយប្បដិសំវេទី

*ប្រការថា* ***លោកសិក្សាថា*** *យើងនឹងជាអ្នកដឹងទូទៅនូវកាយទាំងអស់ ហើយដកដង្ហើមចេញ .... ដកដង្ហើមចូល នោះ លោកកំណត់ទុកក្នុងចិត្តថា យើងនឹងធ្វើខាងដើម កណ្តាល ខាងចុង នៃកាយគឺ ខ្យល់ដង្ហើមទាំងអស់ ឲ្យជាវត្ថុដែលយើងដឹង គឺ ធ្វើ ( ខ្យល់ដង្ហើមនោះ ) ឲ្យជាវត្ថុឃើញប្រាកដ ដកដង្ហើមចេញ ដាក់ចិត្តថា នឹងធ្វើខាងដើម កណ្តាល ខាងចុង នៃកាយ គឺ ខ្យល់ដង្ហើមទាំងអស់ ឲ្យជាវត្ថុដែលខ្លួនដឹង គឺ ធ្វើ ( ខ្យល់ដង្ហើមនោះ ) ឲ្យជាវត្ថុដែលឃើញប្រាកដ ដកដង្ហើមចូល កាលធ្វើ ( ខ្យល់ដង្ហើម ) ឲ្យជាវត្ថុដែលខ្លួនដឹង គឺ ធ្វើឲ្យជាវត្ថុដែលឃើញប្រាកដយ៉ាងនោះ ឈ្មោះថា លោកដកដង្ហើមចេញ និង ដកដង្ហើមចូល ដោយចិត្តប្រកបដោយញាណ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា “* ***ភិក្ខុសិក្សាថា យើងនឹង ... ដកដង្ហើមចេញ ... ដង្ហើមចូល*** *” ដូច្នេះ ។*

*ពិតហើយ សម្រាប់ភិក្ខុរូបខ្លះ ខ្យល់ដើម ក្នុងគំនរខ្យល់ដង្ហើមចេញក្តី ក្នុងគំនរខ្យល់ដង្ហើមចូលក្តី ដែលដក ( ចេញចូល ) មានយ៉ាងល្អិតនោះ ប្រាកដច្បាស់ ខ្យល់កណ្តាល និងខ្យល់ចុងមិនប្រាកដច្បាស់ លោកក៏កំណត់យកបានតែខ្យល់ដើម វិវក់នៅក្នុងខ្យល់កណ្តាល និង ខ្យល់ចុង , សម្រាប់រូបខ្លះ ខ្យល់កណ្តាលប្រាកដច្បាស់ ដើម និង ចុងមិនច្បាស់ ( លោកអាចកំណត់បានតែកណ្តាល , ដើម និងចុងលំបាក ) , សម្រាប់រូបខ្លះ ខ្យល់ចុងប្រាកដច្បាស់ ដើម និង កណ្តាលមិនប្រាកដច្បាស់ លោកអាចកំណត់បានតែខ្យល់ចុង ដើម និង កណ្តាលលំបាក , សម្រាប់ភិក្ខុរូបខ្លះប្រាកដច្បាស់គ្រប់ស្ថាន លោកអាចកំណត់បានទាំងអស់ មិនលំបាកឡើយ ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់សម្តែងថា ព្រះ*

យោគាវចរគប្បីដូច ភិក្ខុរូបទី ៤ នោះ ទើបត្រាស់ប្រការនេះថា **ភិក្ខុសិក្សាថា យើងនឹងជាអ្នកកំណត់ដឹងកាយទូទៅ ដកដង្ហើមចេញ ... ដកដង្ហើមចូល** ។

ក្នុងបទទាំងឡាយនោះ បទថា **សិក្សា** គឺ ដើម្បីព្យាយាម ( ញុំាងមនសិការដើម្បីដឹង ) យ៉ាងនោះ , ន័យម្យ៉ាងទៀត អត្ថាធិប្បាយក្នុងបទនេះ បណ្ឌិតគប្បីជ្រាបយ៉ាងនេះថា ការសង្រួមនៃភិក្ខុនុ៎ះ ៗ ( គឺជាអ្នកចម្រើនអានាបានស្សតិ ) យ៉ាងណា ការសង្រួមនេះចាត់ជាអធិសីលសិក្ខាក្នុងទីនេះ ការតាំងចិត្តមាំនៃភិក្ខុបែបនុ៎ះ ការតាំងចិត្តនុ៎ះ ចាត់ជាអធិចិត្តសិក្ខាក្នុងទីនេះ ការដឹងទូទៅរបស់ភិក្ខុបែបនេះ ការដឹងនុ៎ះ ចាត់ជាអធិប្បញ្ញាសិក្ខាក្នុងទីនេះ ភិក្ខុសិក្សា គឺ សេព ចម្រើន ធ្វើឲ្យច្រើននូវសិក្ខា ៣ តាមដែលពោលមកនេះ ក្នុងអារម្មណ៍នោះ ដោយសតិនោះ ដោយមនសិការនោះ ដូច្នោះ ។

ក្នុងចតុក្កៈទី ១ នោះ ព្រោះហេតុក្នុងន័យដំបូង ព្រះយោគាវចរ គប្បីដកដង្ហើមចេញដកដង្ហើមចូលម្យ៉ាងប៉ុណ្ណោះ មិនគប្បីធ្វើកិច្ចអ្វីៗដទៃ តែថា បន្ទាប់ពីនេះទៅគួរធ្វើសេចក្តីព្យាយាមក្នុងអាការទាំងពួង មានការញុំាងញាណឲ្យកើតឡើង ជាដើម ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះបាលី ជាវត្តមានកាលថា **...អស្សសាមីតិ បជានាតិ ...បស្សសាមីតិ បជានាតិ** ( ...ដឹងថាយើងដកដង្ហើមចេញ ...ដឹងថាយើងដកដង្ហើមចូល ) ដូច្នេះក្នុងន័យដំបូងនោះហើយ ទើបទ្រង់ចែកព្រះបាលីជាពាក្យសម្តែងក្នុងអនាគតកាល ដោយន័យថា **សព្វកាយ-ប្បដិសំវេទី អស្សសិស្សាមីតិ** ( ...យើងនឹងជាអ្នកដឹងទូទៅក្នុងកាយទាំងអស់ ដកដង្ហើមចេញ ) ដូច្នេះជាដើម ដើម្បីទ្រង់សម្តែងអាការ មានការធ្វើញាណឲ្យកើតឡើង ដែលគប្បីធ្វើតាំងពីន័យដំបូងនេះទៅ ។

# មហាដីកា

បទថា **សព្វកាយប្បដិសំវេទី** មានវិគ្រោះថា អ្នកមានប្រក្រតីដឹង គឺ មានប្រក្រតីដឹងដោយប្រពៃនូវគំនរខ្យល់ទាំងពួង ជាចំណែកៗ គឺ ជាម្យ៉ាងៗ មានន័យថា អ្នកមានការដឹងដោយប្រពៃនូវគំនរខ្យល់ទាំងពួងនោះជាផ្នែកៗ ឬ ដឹងដោយប្រពៃនូវគំនរខ្យល់ទាំងពួងនោះ ជាចំណែកៗ ។ ក្នុងបណ្តាបទទាំងឡាយនោះ លោកអាចារ្យកាលនឹងសម្តែងន័យនេះថា ក្នុងបទថា **សព្វកាយប្បដិសំវេទី** ( **សព្វ -កាយ-បដិ-សំ-វេទី** ) នោះ សូម្បីមានការកាន់យកមិនសេសសល់នូវកាយ មានខ្យល់ដង្ហើមចូលជាដើម សម្រេចហើយដោយសព្ទថា **សព្វ** ( ប្រែថា ទាំងពួង ) ក៏នៅកាន់យកសព្ទថា **បដិ** ( ប្រែថា ចំណែកៗ ) កាលសម្តែងការកំណត់ដឹងនូវកាយ គឺ ខ្យល់ដង្ហើមចូលជាដើមនោះ គ្រប់ស្ថាន ព្រោះការប្រជុំគ្នាច្រើនសំណុំ ។ ទ្រង់កាន់យកសព្ទថា **សំ** ( ប្រែថា ដោយប្រពៃ ) ដើម្បីសម្តែងដល់ភាពជាអ្នកធ្វើដោយសេចក្តីគោរពក្នុងការដឹងនោះ ដូច្នេះទើបពោលថា " **សកលស្ស** " ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ លោកអាចារ្យធ្វើទេសនាចែកជាម្យ៉ាងៗ ក៏ដើម្បីសម្តែងថា វិធីបដិបត្តិក្នុងខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ តាមដែលប្រាកដចំពោះព្រះយោគី ព្រះយោគាវចរគប្បីបដិបត្តិតែមួយវិធីដោយគោរពចុះ , សូម្បីថា មានន័យដូចគ្នា គប្បីជ្រាបថា លោកធ្វើការពណ៌នាអត្ថនៃបទទាំង ២ ឲ្យបែកគ្នាម្យ៉ាងៗ ដោយបទថា " **សកលស្ស** " ជាដើម ដើម្បីសម្តែងន័យតាមប្រការដែលពោលហើយនោះឯង ។ ពាក្យថា **ធ្វើឲ្យប្រាកដច្បាស់** គឺ ធ្វើឲ្យជាក់ច្បាស់ , មានន័យថា ធ្វើឲ្យជាក់ច្បាស់ដោយប្រការទាំងពួង ។ លោកអាចារ្យកាលនឹងសម្តែងការធ្វើឲ្យប្រាកដច្បាស់ គឺ ការធ្វើឲ្យជាក់ច្បាស់ ជាការមិនវង្វេងក្នុងខ្យល់

ដង្ហើមចូល និងខ្យល់ដង្ហើមចេញទាំងឡាយនោះ គប្បីមានបានដោយការធ្វើខ្យល់ដង្ហើមទាំងឡាយនោះ ឲ្យប្រព្រឹត្តទៅដោយញាណនោះឯង ទើបពោលថា **យើងនឹងធ្វើឲ្យបានដឹងច្បាស់យ៉ាងនេះ** ជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **ព្រោះដូច្នោះ** ប្រកបសេចក្ដីថា ព្រោះហេតុដែលព្រះយោគាវចរធ្វើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឲ្យប្រព្រឹត្តទៅជាមួយចិត្តដែលសម្បយុត្តដោយញាណនោះឯង មិនបានធ្វើឲ្យប្រព្រឹត្តទៅជាមួយចិត្តដែលវិប្បយុត្តចាកញាណនោះទេ , ព្រោះដូច្នោះ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម ទើបត្រាស់ហៅភិក្ខុយ៉ាងនេះថា រមែងសិក្សាថា យើងជាអ្នកធ្វើគំនរខ្យល់ទាំងពួង ឲ្យប្រាកដច្បាស់ ដកដង្ហើមចូល ដកដង្ហើមចេញ ដូច្នេះ ។ ពាក្យថា ( **គំនរខ្យល់** ) **ដែលផ្សាយទៅល្អិត** គឺ ដែលផ្សាយទៅដោយភាពជាធម្មជាតិល្អិតសុខុម ព្រោះជាគំនរខ្យល់ច្រើនសំណុំ ។ ឈ្មោះថា ខ្យល់ដើមប្រាកដច្បាស់ ព្រោះបុញ្ញាភិសង្ខារប្រព្រឹត្តទៅយ៉ាងនោះ ដោយអំណាចនៃសតិ និង ញាណ ។ ២ បទថា **តាទិសេន ភវិតព្វំ** គឺ គប្បីដូចជាបុគ្គលទី ៤ អធិប្បាយថា គឺ គប្បីធ្វើសតិនិងញាណឲ្យប្រាកដឡើងជាមុន ហើយធ្វើចិត្តដែលសម្បយុត្តដោយញាណនោះ ឲ្យប្រព្រឹត្តទៅក្នុងឋានៈទាំង ៣ ( ខ្យល់ដើម ខ្យល់កណ្ដាល ខ្យល់ចុង ) ។

ពាក្យថា **ឯវំ - យ៉ាងនេះ** បានដល់ ដោយប្រការដូចពោលហើយ គឺ ទាក់ទងនឹងការធ្វើគំនរខ្យល់ទាំងពួងឲ្យបានដឹងច្បាស់នោះឯង ។ ពាក្យថា **ឃដតីតិ** គឺ រមែងឧស្សាហ៍ ។ ពាក្យថា **រមែងព្យាយាម** គឺ រមែងធ្វើការព្យាយាម មានន័យថា ធ្វើមនសិការឲ្យប្រព្រឹត្តទៅ ។ ពាក្យថា **របស់ភិក្ខុបែបនោះ** គឺ របស់ភិក្ខុដែលចម្រើនអានាបានស្សតិ ។ ពាក្យថា **ការសង្រួម** បានដល់ សតិ ឬ សូម្បី

វិរិយៈ ។ ពាក្យថា **ដោយសតិនោះ** គឺ ដោយសតិដែលប្រព្រឹត្តទៅប្រារព្ធខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ ។ ពាក្យថា **ដោយមនសិការនោះ** គឺ ជាមួយនឹងការធ្វើទុកក្នុងចិត្តនូវភាវនា ដែលមានសតិជាប្រធាន ក្នុងខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញនោះ ។ ពាក្យថា **រមែងសេព** គឺ រមែងសេពនូវអធិកុសលធម៌ទាំងឡាយដែលហៅថា សិក្ខា ៣ , ឯការសេពនូវអធិកុសលធម៌នោះ លោកបំណងពោលថា ជាការសិក្សាក្នុងទីនេះ ។

ពាក្យថា **ក្នុងន័យដំបូង** គឺ ក្នុងន័យភាវនាដំបូង អធិប្បាយថា ក្នុងវត្ថុ ២ ប្រការដំបូង ( ខ្យល់ចូលវែង ... ខ្យល់ចេញវែង ក៏ដឹងច្បាស់ថា យើងដកដង្ហើមចេញវែង ដូច្នេះ ១ , កាលដកដង្ហើមចូលខ្លី ... ដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា យើងដកដង្ហើមចេញខ្លី ដូច្នេះ ១ ) ។ លោកអាចារ្យបំណងសម្ដែងសេចក្ដីនេះថា សូម្បីក្នុងប្រការដំបូងនោះ រមែងធ្វើញាណឲ្យកើតឡើងដូចគ្នា ព្រោះមានការដឹងភាវៈដែលវែង និង ខ្លី នៃខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ តាមសេចក្ដីពិត ក៏ពិត សូម្បីដូច្នោះ ការញ៉ាំងញាណឲ្យកើតឡើងនោះ មិនមែនកិច្ចដែលធ្វើបានដោយលំបាកទេ ព្រោះមានត្រឹមតែការកំណត់ខ្យល់ដង្ហើមដែលប្រព្រឹត្តទៅទាំងឡាយនោះ ព្រោះហេតុនោះ ក្នុងន័យដំបូងនោះ ព្រះមានព្រះភាគទើបទ្រង់ធ្វើការប្រកបពាក្យពោលទុកជាមួយនឹងបច្ចុប្បន្នកាល ( គឺ ពាក្យថា **អស្សសាមិ** - ខ្យល់ដង្ហើមចូល , **បស្សសាមិ** - ខ្យល់ដង្ហើមចេញ ) ។ ទ្រង់បំណងសម្ដែងថា ការធ្វើញាណឲ្យកើតឡើង ក្នុងន័យទី ២ នេះ ជាកិច្ចដែលធ្វើបានដោយលំបាក ដូចបុរសដែលដើរទៅជិតមុតកាំបិតកោរ , ព្រោះដូច្នោះ ត្រូវជាអ្នកមានបុញ្ញាភិសង្ខារ ក្នុងរឿងនេះយ៉ាងប្រពៃ ដូច្នេះ ទើបទ្រង់ធ្វើការប្រកបពាក្យពោលទុកក្នុង

អនាគតកាល ទើបពោលថា " ក្នុងចតុក្កៈដំបូងនោះ ព្រោះហេតុដែល " ដូច្នេះ ជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **ក្នុងកិច្ច មានការធ្វើញាណឲ្យកើតឡើងជាដើម** ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) ទ្រង់រួមយកការធ្វើកាយ-សង្ខារឲ្យស្ងប់រម្ងាប់ ( ដែលជាប្រការទី ៤ ) ការធ្វើបីតិឲ្យជាការដឹងច្បាស់ ( ជាប្រការទី ៥ ) ជាដើម ។ តែថា ក្នុងពាក្យថា ក្នុងកិច្ច មានការធ្វើញាណឲ្យកើតឡើងជាដើមនេះ អាចារ្យពួកខ្លះពោលថា " មានការរួមយកការសង្រួម និង ការសមាទានផង " ។

ពាក្យថា **កាយសង្ខារ** បានដល់ ខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ ។ កាយសង្ខារនោះ សូម្បីថាជាវត្ថុដែលមានចិត្តជាសមុដ្ឋាន ទ្រង់ក៏ហៅថា កាយ-សង្ខារ ព្រោះអត្ថថា ត្រូវកាយនោះតាក់តែង ព្រោះមានការប្រព្រឹត្តទៅទាក់ទងនឹងករជកាយ ។ រីឯកាយសង្ខារណាដែលមកហើយ យ៉ាងនេះថា " **កាយសង្ខារោ វចីសង្ខារោ** " ដូច្នេះ ដែលមានលក្ខណៈជាចេតនា សូម្បីមានការកើតឡើងក្នុងទ្វារដទៃបាន ទ្រង់ក៏កំណត់ទុកដោយកាយទ្វារ ( ទើបឈ្មោះថា កាយសង្ខារ ) ព្រោះមានការប្រព្រឹត្តទៅដោយច្រើន ( ក្នុងកាយទ្វារនោះ ) , និង ដោយមានការប្រព្រឹត្តទៅច្រើនក្នុងកាយទ្វារនោះ កាយសង្ខារដែលមានលក្ខណៈជាចេតនានោះ ក៏មិនបានបំណងយកក្នុងទីនេះទេ ។ ក្នុងបទថា **បស្សម្ភេន្តោ** ( ឲ្យស្ងប់រម្ងាប់ ) **ជាដើម** មានន័យថា បទក្រោយ ៗ ( មានបទថា **បដិសម្ភេន្តោ** - ឲ្យស្ងប់រម្ងាប់ជាដើម ) ជាពាក្យអធិប្បាយអត្ថនៃបទមុន ៗ , ព្រោះដូច្នោះ គប្បីឃើញថា ការធ្វើឲ្យស្ងប់រម្ងាប់ បានដល់ បាននូវសេចក្តីស្ងប់ និង ការធ្វើឲ្យសម្រេចនូវសេចក្តីស្ងប់នោះ បានដល់ ការធ្វើនូវកាយសង្ខារដែលគ្រោតគ្រាត ដែលគប្បីកើតឡើងក្នុង

ពេលដែលមិនមានសេចក្ដីព្យាយាមយ៉ាងនោះ មិនឲ្យកើតឡើង ព្រោះការដល់ព្រម នៃសេចក្ដីព្យាយាម ។ ពាក្យថា **ក្នុងពាក្យនោះ** គឺ ក្នុងពាក្យថា " យើងនឹងធ្វើកាយសង្ខារដែលគ្រោតគ្រាតឲ្យស្ងប់រម្ងាប់ " ។ ពាក្យថា **ក្នុងពេលដែលមិនទាន់បានកំណត់** គឺ ក្នុងពេលដែលមិនទាន់ប្រារព្ធកម្មដ្ឋាន , ព្រោះហេតុនោះឯង ទើបជាពេលដែលមិនទាន់បានកំណត់កាយនិងចិត្ត ។ ពិតហើយ ដោយពាក្យថា " **អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់** " នេះ ទ្រង់ត្រាស់ដល់ការកំណត់កាយ , ដោយពាក្យថា **តាំងសតិចំពោះមុខ** នេះ ទ្រង់ត្រាស់ដល់ការកំណត់ចិត្ត ។ ព្រោះហេតុនោះឯង លោកអាចារ្យទើបពោលថា ទាំងកាយទាំងចិត្ត គឺ គប្បីកំណត់ ។ ពាក្យថា **កាយ** បានដល់ ករជកាយ ។ ពាក្យថា **មានការរសាប់រសល់** គឺ មានការក្ដៅរោលរាល , មានការរសាប់រសល់នៃកាយនិងចិត្តទាំងឡាយនោះ នោះមានប្រក្រតីមិនប្រាសចាកនូវភាពគ្រោតគ្រាត ដូចការមានប្រក្រតីមិនវៀរចាកនូវរបស់ធ្ងន់ ព្រោះហេតុនោះ លោកទើបពោលថា " ទើបឈ្មោះថា គ្រោតគ្រាត " ។ ពាក្យថា **មានកម្លាំងខ្លាំង** គឺ មានកម្លាំងច្រើន ។ ពាក្យថា **ជាធម្មជាតិដែលស្ងប់** មានន័យថា ជាដំបូងចិត្តជាធម្មជាតិមានអារម្មណ៍តែមួយ ព្រោះមិនមានការរាយមាយទៅខាងក្រៅ ពេលកំណត់កម្មដ្ឋានប្រព្រឹត្តទៅ ក៏ជាធម្មជាតិស្ងប់ ស្ងប់វិសេស , ព្រោះហេតុនោះ ក៏រមែងទុករូបធម៌ទាំងឡាយដែលមានចិត្តនោះជាសមុដ្ឋាន ឲ្យដល់នូវភាពជារបស់ស្រាល និង គួរដល់ការងារ ដោយការសមគួរដល់ចិត្តនោះ ជាសន្តតិរូប ៣ ដ៏សេស , កាលចិត្ត និង កាយប្រព្រឹត្តទៅស្ងប់វិសេសយ៉ាងនេះ ដោយប្រការដូច្នេះ ខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ ដែលអាស្រ័យចិត្ត និង កាយនោះ ក៏ប្រព្រឹត្តទៅជាធម្មជាតិដែលមានសភាវៈស្ងប់សុខុម ក្រៃលែងឡើង ៗ

ដាលំដាប់ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា " **រីឯ ក្នុងពេលណា កាយ** " ដូច្នេះជាដើម ។

ការពិចារណាដល់ ឈ្មោះថា **អាភោគ** បានដល់ ការពិចារណាជាដំបូងថា " យើងនឹងធ្វើឲ្យស្ងប់រម្ងាប់ " ។ ការបង្អោនមករឿយៗ ដោយប្រពៃ ឈ្មោះថា **សមន្នាហារ - ការប្រមូលចិត្ត** បានដល់ ការនឹកប្រព្រឹត្តទៅជាបន្ត ក្នុងសភាវៈនោះឯង ។ ការធ្វើសភាវៈនោះទុកក្នុងចិត្ត គឺ តាំងទុកក្នុងចិត្ត ឈ្មោះថា **មនសិការ**។ ការពិចារណា ឈ្មោះថា **បច្ចវេក្ខណា** ។

( ក្នុងគាថា ) បទថា **សារទ្ធេ** ប្រែថា មានការសោប់សេល់ គឺ មានការក្តៅរោលរាល ។ បទថា **អធិមត្តំ** - មានប្រមាណក្រៃលែង គឺ មានកម្លាំងជារបស់គ្រោតគ្រាត ។ ទ្រង់ពោលទុកដោយជា លិង្គវិបល្លាស ( គឺ ការពិតជា **អធិមត្តោ** ) ។ ព្រោះថា លោកបំណងយកថា **កាយសង្ខារោ** ( ជា បុំលិង្គ ) ។ ម្យ៉ាងវិញទៀត ពាក្យថា **អធិមត្តំ** នេះ ជាកិរិយាវិសេសនៈ យ៉ាងនេះថា **អធិមត្តំ ហុត្វា បវត្តតិ** - ប្រព្រឹត្តទៅប្រមាណក្រៃលែង ។ សូម្បីក្នុងបទថា **សុខុមំ** ក៏មានន័យដូច្នេះដែរ ។ ក្នុងបទថា **កាយម្ហិ** នេះ គប្បីនាំបទថា **ចិត្តេ ច** មកភ្ជាប់ផង ។

លោកអាចារ្យធ្វើទុកក្នុងចិត្តថា បរិកម្មដែលមានអាវជ្ជនៈផ្សេងៗ នៃទុតិយជ្ឈាន ( ដែលជាឧបចារៈនៃទុតិយជ្ឈានក្នុងទីនេះ ) ដែលព្រះយោគីចេញចាកបឋមជ្ឈាន ហើយធ្វើ ក៏មានការរុញច្រានធម៌ដែលជាបដិបក្ខ ឲ្យនៅក្នុងទីឆ្ងាយបានដោយល្អ ដូចបឋមជ្ឈាន ដូច្នេះហើយ ទើបពោលដល់កាយសង្ខារ ដែលមានបឋមជ្ឈាន និងឧបចារៈនៃទុតិយជ្ឈាននោះជាសមុដ្ឋាន ថាជា កាយសង្ខារដែលដូចគ្នា យ៉ាងនេះថា ក្នុងបឋមជ្ឈាន និង ក្នុងឧបចារៈនៃទុតិយជ្ឈាន ចាត់ថានៅគ្រោត

គ្រាត ដូច្នេះ ។ សូម្បីក្នុងឧបចារៈទាំង ២ ដ៏សេស ក៏មានន័យដូច្នេះ ។ ន័យមួយទៀត កាលព្រះយោគាវចរបដិបត្តិដើម្បីសម្រេចទុតិយជ្ឈានជាដើម លំបាក ដោយទាក់ទងជាទុក្ខាបដិបទាជាដើម គប្បីជ្រាបដល់សេចក្តីដែលកាយសង្ខារក្នុងឧបចារៈនៃឈានទាំងឡាយ មានទុតិយជ្ឈានជាដើម ជារបស់គ្រោតគ្រាត ទាក់ទងនឹងការលំបាកនៃកាយ ( នាមកាយ ) និង ការរួញរានៃចិត្ត និងព្រោះការប្រព្រឹត្តទៅនៃចិត្ត មានសភាពក្តៅក្រហាយ ដោយអង្គដែលហៅថា វិតក្កជាដើម ។ ពាក្យថា **ល្អិតសុខុម** មានន័យថា កាយសង្ខារដែលមានក្នុងឈានដទៃ ៗ ក្នុងចតុត្ថជ្ឈានឈ្មោះថា ល្អិតក្រៃលែង ។ សូម្បីការៈដែលកាយសង្ខារនេះ ក្នុងចតុត្ថជ្ឈាននោះល្អិត ក៏មិនទាន់មាន , ការៈដែលគ្រោតគ្រាតនឹងមានដូចម្តេចបាន ព្រោះប្រព្រឹត្តទៅមិនបាន ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ដល់នូវការមិនប្រព្រឹត្តទៅ** ដូច្នេះ ។

អាចារ្យអ្នកពោលគម្ពីរមជ្ឈិមនិកាយ ឈ្មោះថា ត្រូវការកាយសង្ខារសូម្បីក្នុងឧបចារៈនៃឈានជាន់លើ ៗ ឡើងទៅថា ល្អិតជាងឈានជាន់ទាប ៗ ដោយសំដៅយកវេលានៃព្រះយោគាវចរ ដែលជាឈានលាភី ចូលសមាបត្តិតាមលំដាប់ ឬ សំដៅយកការបានឈានទាំងពួង ក្នុងអាសនៈមួយប៉ុណ្ណោះ ( ដោយការអង្គុយតែ១ដង ) ។ ពិតហើយ ឈានទាំងឡាយព្រមទាំងឧបចារៈ គប្បីមានភាពពិសេសក្រៃលែងឡើងទៅ និងមានភាពស្ងប់បានក្នុងពេលនោះ , ន័យមួយទៀត លោកពោលទុកយ៉ាងនេះ ព្រោះសំដៅយកឧបចារៈដែលមានអាវជ្ជនៈជាមួយគ្នា ( គឺឧបចារៈមាននៅក្នុងវិថីតែមួយ ជាមួយនឹងឈាន ) ។ ពិតហើយ វាទៈនេះ ( វាទៈរបស់អាចារ្យអ្នកពោលគម្ពីរមជ្ឈិមនិកាយ ) និង មានការសម្រេចការមិនខុសគ្នា

ជាមួយវាទៈដែលពោលហើយ ក្នុងបទដើម ( គឺ វាទៈរបស់លោកអាចារ្យអ្នកពោលគម្ពីរទីឃនិកាយ និង វាទៈរបស់អាចារ្យដែលពោលគម្ពីរសំយុត្តនិកាយ ) ព្រោះមានវិស័យផ្សេងគ្នា តាមប្រការដូចដែលពោលហើយ ។ ពាក្យថា **របស់អាចារ្យគ្រប់ផ្នែក** គឺ របស់អាចារ្យទាំង ២ ផ្នែក ។ ព្រោះហេតុដែលលោកទាំងនោះ សូម្បីគ្រប់អដ្ឋកថាទៃ ក៏ប្រាថ្នានូវភាពស្ងប់ ( នៃកាយសង្ខារ ) តាមវិធីដែលកំពុងពោលដល់នោះឯង ។ លោកពោលពាក្យថា កាយសង្ខារដែលប្រព្រឹត្តទៅក្នុងពេលដែលមិនទាន់បានកំណត់ រមែងស្ងប់រម្ងាប់ទៅក្នុងពេលដែលបានកំណត់ហើយដូច្នេះនេះ ព្រោះមានការបន្តគ្នាជានិច្ច ។ ពិតហើយ ខ្យល់ដង្ហើមចូលជាដើម ដែលគ្រោតគ្រាតទាំងឡាយនោះ នឹងក្លាយជាខ្យល់ដែលល្អិតបាន ក៏ទេ ។ អាការដែលស្ងប់នៃខ្យល់ដង្ហើមចូលទាំងនោះ លោកអាចារ្យក៏ពោលទុកក្នុងបទដើមហើយ ។

ពាក្យថា **ដែលប្រព្រឹត្តទៅក្នុងពេលកំណត់មហាភូតរូប ចាត់ថាល្អិត** លោកពោលសំដៅយកការកំណត់អារម្មណ៍នៃវិបស្សនា ដោយធាតុ ៤ ជាសំខាន់ ។ ឈ្មោះថា ប្រព្រឹត្តទៅក្នុងពេលកំណត់រូបទាំងអស់ ចាត់ថាល្អិត ព្រោះភាវនាមានការប្រណីតក្រៃលែងឡើង ។ ព្រោះហេតុនោះឯង លោកទើបពោលថា ដែលប្រព្រឹត្តទៅក្នុងពេលកំណត់ទាំងរូបទាំងនាម ចាត់ថាល្អិត ។ ពាក្យថា **វិបស្សនាដែលមានលក្ខណៈជាអារម្មណ៍** លោកពោលដល់ការពិចារណាជាកលាបៈ ។ ឈ្មោះថា **វិបស្សនាមានកម្លាំង** គឺ រាប់តាំងពីនិព្វិទានុបស្សនាទៅ ។ ទាបជាងនិព្វិទានុបស្សនាញាណនោះ ឈ្មោះថា វិបស្សនាកម្លាំងខ្សោយ ។ ពាក្យថា **តាមន័យដែលខ្ញុំម្ចាស់បានពោលហើយក្នុងបទដើម** គឺ តាមន័យដែលលោកអាចារ្យបានពោលទុកក្នុងសមថៈ ដោយពាក្យថា **អបរិគ្គហិតកាលេ** ជាដើម ។ មានការ

ពោលអធិប្បាយបានថា គប្បីប្រកបសេចក្តីស្ងប់រម្ងាប់ សូម្បីក្នុងន័យវិបស្សនា ដោយពាក្យថា កាយសង្ខារដែលប្រព្រឹត្តទៅក្នុងពេលដែលមិនទាន់បានកំណត់ រមែងស្ងប់រម្ងាប់ទៅក្នុងពេលដែលបានកំណត់មហាភូតរូប ដូច្នេះជាដើម ។

ពាក្យថា **នៃបទនេះ** គឺ នៃបទថា **បស្សម្ភយំ កាយសង្ខារំ** នេះ ។ ពាក្យថា ព្រមទាំងពាក្យសួរ និងពាក្យឆ្លើយ គឺព្រមទាំងសំណួរ និង ចម្លើយ ។ ពាក្យថា **យ៉ាងនេះ** គឺ ដោយអាការដែលកំពុងពោលដល់ក្នុងពេលនេះ ។

ពាក្យថា **យ៉ាងដូចម្តេច** គឺ ពាក្យដែលពោលថា រមែងសិក្សាថា យើងនឹងធ្វើកាយសង្ខារឲ្យស្ងប់រម្ងាប់ ។ ល ។ ពាក្យនោះឯង តើដូចម្តេច ព្រះសារីបុត្តត្ថេរ កាលសួរដោយភាពជាអ្នកប្រាថ្នា ដើម្បីឆ្លើយដោយអង្គឯងថា ការស្ងប់រម្ងាប់នៃកាយសង្ខារ និង ការសិក្សារបស់ព្រះយោគាវចរ សម្រេចបានដោយប្រការដូចម្តេច ដូច្នេះហើយ បំណងនឹងសម្តែងកាយសង្ខារទាំងឡាយ តាមសភាវៈដែលប្រាកដ ព្រោះជាកាយសង្ខារដែលគ្រោតគ្រាត និងល្អិត ដោយអាការដែលស្ងប់ និងដោយពាក្យសួរព្រមទាំងពាក្យឆ្លើយ ទើបផ្តើមពាក្យថា **កាយសង្ខារតើដូចម្តេច** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **មានក្នុងកាយ** គឺ មានក្នុងរូបកាយ ។ ពាក្យថា **ទាក់ទងដោយកាយ** គឺ អាស្រ័យកាយ , អធិប្បាយថា មានកាយទើបសម្រេចបាន , កាលកាយមិនមាន ក៏សម្រេចមិនបាន ។ ព្រោះហេតុនោះឯង ទើបហៅ ខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ ទាំងឡាយនោះថា **កាយសង្ខារ** ព្រោះអត្ថថា សូម្បីមិនមានកាយជាសមុដ្ឋាន តែក៏ត្រូវកាយ ( រូបកាយ ) តាក់តែងឡើង ។ ពាក្យថា **ធ្វើឲ្យស្ងប់រម្ងាប់** គឺ ធ្វើកាយសង្ខារដែលគ្រោតគ្រាត ឲ្យស្ងប់រម្ងាប់ ។ ២ បទដ៏សេស ( ឲ្យរលត់ , ឲ្យស្ងប់ ) ជាពាក្យវេវចនៈនៃពាក្យ

ថា ឲ្យស្ងប់រម្ងាប់នោះឯង ។ ពិតហើយ កាលធ្វើកាយសង្ខារដែលគ្រោតគ្រាត ដែលមានសភាវៈមិនស្ងប់ ឲ្យស្ងប់ស្ងៀម ក៏ហៅថា ធ្វើឲ្យស្ងប់រម្ងាប់ កាលធ្វើឲ្យដល់នូវការរលត់ គឺ ការមិនកើតឡើង ក៏ហៅថា ធ្វើឲ្យរលត់ កាលនាំចូលទៅកាន់សភាវៈដែលស្ងប់ដោយល្អ ក៏ហៅថា **ធ្វើឲ្យស្ងប់** ដូច្នេះ ។ ពាក្យថា **បែបណា** គឺ ដែលជាយ៉ាងណា ។ ពាក្យថា **ព្រោះកាយសង្ខារ** គឺ ព្រោះកាយសង្ខារដែលគ្រោតគ្រាត ។ បទថា **អានមនា - ការនាំកាយ** គឺ ការនាំកាយទៅខាងមុខ ។ បទថា **វិនមនា - ផាកកាយ** គឺ ការនាំកាយទៅម្ខាង តែមួយខាង ។ បទថា **សន្នមនា - ការពត់កាយ** គឺ ការពត់កាយទៅគ្រប់ទិស ឬ ការឱនកាយទៅដោយល្អ ។ បទថា **បណាមនា - ការឱនកាយ** គឺ ការឱនកាយទៅខាងមុខ ។ បទថា **ឥញ្ជនា - ការបត់កាយ** គឺជាពាក្យវេវចនៈនឹងពាក្យ **អានមនា** ជាដើម ,ម្យ៉ាងទៀត ការកម្រើកកាយជាដើម ខាងមុខច្រើន ឈ្មោះថា **អានមនា** ជាដើម , ការកម្រើកកាយជាដើម តិចតួច ឈ្មោះថា **ឥញ្ជនា** ជាដើម ។ ពាក្យថា **យើងនឹងធ្វើកាយសង្ខារឲ្យស្ងប់រម្ងាប់** មានន័យថា យើងនឹងធ្វើកាយសង្ខារយ៉ាងនោះ គឺ កាយសង្ខារដែលគ្រោតគ្រាត ជាហេតុនៃការយោកកាយជាដើម ឲ្យស្ងប់រម្ងាប់ ។ ពិតហើយ កាលកាយសង្ខារនោះស្ងប់រម្ងាប់ហើយ សូម្បីការយោកកាយជាដើម ក៏ស្ងប់រម្ងាប់ដូចគ្នា ។ ពាក្យថា **ដែលស្ងប់ សុខុម** មានន័យថា ការយោកកាយជាដើម រមែងមិនមាន ព្រោះកាយសង្ខារដែលជាហេតុនៃការមិនកម្រើកកាយបែបណា កាយសង្ខារបែបនោះ ឈ្មោះថា **ស្ងប់** ព្រោះមិនមានការរសាប់រសល់ , ឈ្មោះថា **សុខុម** ព្រោះភាវៈដែលមិនគ្រោតគ្រាត ។

( ចប់ មហាដីកា )

## បទថា បស្សម្ភយំ កាយសង្ខារំ

សេចក្ដីថា **លោកសិក្សាថា** យើងនឹងជាអ្នករម្ងាប់កាយសង្ខារ ដកដង្ហើមចេញ - ដកដង្ហើមចូល នោះគឺ លោកដាក់ចិត្តថា យើងនឹងជាអ្នករម្ងាប់ គឺ ធ្វើកាយសង្ខារដែលគ្រោតគ្រាត ឲ្យស្ងប់រម្ងាប់សន្សឹមៗ ឲ្យរលត់ទៅ ឲ្យស្ងប់ខ្យល់ដង្ហើមចូលខ្យល់ដង្ហើមចេញ ។

ភាពគ្រោតគ្រាត និង សុខុមក្តី ការរម្ងាប់ក្នុងសេចក្តីនោះ គប្បីជ្រាបដូច្នេះ ៖ កាយ និង ចិត្ត របស់ភិក្ខុនេះ ក្នុងកាលដែលមិនទាន់បានកំណត់ ( អានាបានស្សតិកម្មដ្ឋាននោះ ) ជាកាយ - ចិត្ត ដែលនៅមានសភាពសោប់សល់ គ្រោតគ្រាត កាលបើសភាពគ្រោតគ្រាតនៃកាយចិត្តនៅមិនទាន់ស្ងប់ សូម្បីខ្យល់ដង្ហើមចេញ ខ្យល់ដង្ហើមចូល ក៏ជាខ្យល់គ្រោតគ្រាត គឺ ប្រព្រឹត្តទៅខ្លាំងក្លា ប្រមុះមិនល្មម ក៏ឈរដេកដង្ហើមទាំងចេញ ទាំងចូលតាមមាត់ តែពេលណា ទាំងកាយទាំងចិត្ត របស់លោក ត្រូវកំណត់ ( ជាទីតាំងនៃកម្មដ្ឋាន ) ហើយ ពេលនោះវាក៏ល្ហិត ស្ងប់ទៅ កាលកាយនិងចិត្តស្ងប់ហើយ ខ្យល់ដង្ហើមចេញ ខ្យល់ដង្ហើមចូលក៏ល្ហិតទៅដែរ រហូតដល់នូវអាការដែលត្រូវវិច័យថា មាន ឬ មិនមានហ្ន៎ ! ឧបមាដូចជា ខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូល របស់បុគ្គលដែលរត់ចុះពីលើភ្នំ ឬដាក់របស់ធ្ងន់ចុះពីលើសីសៈ ហើយឈរ រមែងជាខ្យល់គ្រោតគ្រាត ប្រមុះមិនល្មម ឈរដេកដង្ហើមទាំងចេញទាំងចូលតាមមាត់ តែកាលគេបន្ទោបង់ការហត់នឿយនោះហើយ បានងូតទឹក និង ផឹកទឹកហើយ យកសំពត់សើមគ្របត្រង់ដើមទ្រូង ដេកសម្រាក នៅក្រោមម្លប់ដ៏ត្រជាក់ ពេលនេះខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូលរបស់គេនោះ ក៏ស្ងប់ចុះ រហូតដល់នូវអាការជាទីតាំងនៃការវិច័យថា មាន ឬមិនមានហ្ន៎ !

យ៉ាងណាក្តី កាយនិងចិត្តរបស់ភិក្ខុនេះ ក្នុងកាលដែលមិនទាន់បានកំណត់ ( អានា-បានស្សតិកម្មដ្ឋាននោះ ) ។ ល ។ ដល់នូវអាការ គឺ ត្រូវវិច័យថា មាន ឬ មិនមានហ្ន៎ ! ដូច្នោះដូចគ្នា , សួរថា សេចក្តីនោះ ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះជាការពិតថា ក្នុងកាលដែលមិនទាន់បានកំណត់ ( ព្រះកម្មដ្ឋាននោះ ) ការពិចារណា ការរួមចិត្ត ការដាក់ចិត្ត ការថ្លឹងថ្លែងថា យើងនឹងរម្ងាប់កាយសង្ខារដែលគ្រោតគ្រាត មិនមានដល់លោក តែក្នុងកាយដែលកំណត់ ( ព្រះកម្មដ្ឋាន ) ទើបមាន ព្រោះហេតុនោះ កាយសង្ខាររបស់លោកក្នុងកាលដែលកំណត់ ( ព្រះកម្មដ្ឋាន ) ហើយ ទើបល្អិតជាង ( កាយសង្ខារ ) ក្នុងកាលដែលមិនទាន់បានកំណត់ ( ព្រះកម្មដ្ឋាន ) ព្រោះដូច្នោះ ព្រះបោរាណាចារ្យទាំងឡាយ ទើបពោលទុកថា ៖

***ពេលកាយនិងចិត្តសោប់សេល់ កាយសង្ខាររមែងគ្រោតគ្រាត ពេលកាយនិងចិត្តមិនសោប់សេល់ កាយសង្ខាររមែងល្អិតសុខុម ។***

## មហាដីកា

លោកពោលធ្វើឲ្យជាបទតែមួយ ព្រោះស្មើគ្នា ( ដោយភាពជាកាយសង្ខារ ) ថា **បស្សម្ភយំ កាយសង្ខារំ** ។ ន័យមួយទៀត ព្រះយោគាវចរអ្នកធ្វើកាយសង្ខារដែលគ្រោតគ្រាត ឲ្យស្ងប់រម្ងាប់ទៅក្នុងខាងដើម ធ្វើកាយសង្ខារដែលល្អិតជាងនោះដែលជាហេតុនៃការមិនកម្រើកកាយ ឲ្យកើតឡើងបាន តាមលំដាប់ ធ្វើកាយសង្ខារនោះឲ្យស្ងប់រម្ងាប់ទៅ ហើយធ្វើកាយសង្ខារឲ្យដល់កំពូល ព្រោះជាកាយសង្ខារដែលស្ងប់រម្ងាប់ក្រៃលែង យ៉ាងណា ឲ្យរម្ងាប់ទៅ តាមលំដាប់ , ពាក្យថា **យើង**

**នឹងធ្វើកាយសង្ខារដែលស្ងប់ ដែលសុខុម ឲ្យរម្ងាប់** ដូច្នេះ លោកពោលយកកាយសង្ខារដែលដល់នូវភាពជាកំពូល ។

សព្ទថា **ឥតិ** ជាដើម ជាពាក្យសួរក្នុងពាក្យទាំងឡាយនោះ សព្ទថា **ឥតិ** ជានិបាតក្នុងសេចក្ដីថា **ប្រការ** ។ សព្ទថា **កិរ** ក្នុងន័យថា **អរុចិសូចន** ( ប្រាប់ការមិនពេញចិត្ត គឺ មិនឃើញ ) ន័យស្មើនឹង **ឯវំ ចេ** ( ប្រែថា ប្រសិនបើដូច្នេះ ) , ក្នុងសេចក្ដីថា **ឥតិ កិរ** នេះ មានពាក្យអធិប្បាយដូចតទៅនេះថា ៖

ប្រសិនបើថា ធ្វើកាយសង្ខារដ៏ល្អិតក្រៃលែង ឲ្យរម្ងាប់ទៅ តាមប្រការដូចដែលពោលហើយសោត ដូច្នេះ ។ ពាក្យថា **ឯវំ សន្តេ** ប្រែថា កាលបើដូច្នេះ គឺកាលដែលអាការដែលលោកពោលដល់ មានហើយ ។ បទថា **វាតូបលទ្ធិយា** គឺការដឹងនូវខ្យល់ ។ **ច** សព្ទ មានអត្ថថា រួបរួម ។ ការធ្វើចិត្តដែលមានខ្យល់ដង្ហើមចូលជាដើមឲ្យជាអារម្មណ៍ កើតឡើង គឺ ឲ្យឧប្បត្តិ ឲ្យប្រព្រឹត្តទៅ ក៏មានមិនបាន អធិប្បាយថា ព្រោះខ្យល់ទាំងនោះ ត្រូវព្រះយោគាវចរនោះធ្វើឲ្យរម្ងាប់ទៅ ។ ពាក្យថា **ការធ្វើខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ឲ្យកើតឡើង ( ក៏មានមិនបាន )** មានន័យថា ការធ្វើខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ ដែលគ្រោតគ្រាត ឲ្យរម្ងាប់ទៅដោយការនា ហើយធ្វើខ្យល់ដង្ហើមទាំងនោះ ដែលល្អិតឲ្យកើតក៏មិនបាន ព្រោះខ្យល់ទាំង ២ យ៉ាងនោះ ត្រូវព្រះយោគាវចរនោះ ធ្វើឲ្យរម្ងាប់ហើយ ។ ពាក្យថា **ធ្វើអានាបានស្សតិ ( ឲ្យកើតក៏មិនបាន )** គឺ ធ្វើសតិដែលមានខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ ជាអារម្មណ៍ ឲ្យប្រព្រឹត្តទៅ មិនបាន ព្រោះមិនមានខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ ។ ព្រោះហេតុនោះឯង ការធ្វើអានាបានស្សតិសមាធិ ដែលសម្បយុត្តជាមួយអានាបានស្សតិនោះ ឲ្យកើតឡើង គឺ

សូម្បីធ្វើឲ្យឧប្បត្តិ ក៏មានមិនបាន ។ ព្រោះថា ក្នុងកាលណាក៏ដោយ ធម៌ដែលមានអារម្មណ៍ នឹងកើតឡើងមិនបានឡើយ បើវៀរអារម្មណ៍ចេញ ។ ក្នុងពាក្យថា **ន ច នំ តំ** នេះ , បទថា **នំ** ត្រឹមតែជានិបាត ។ ប្រកបសេចក្ដីថា និង បណ្ឌិតអ្នកមានបញ្ញា ចូលសមាបត្តិមានវិធីការដូចពោលហើយនោះ ក៏មិនបាន ទាំងចេញចាកសមាបត្តិនោះ ក៏មិនបាន ។ តាមប្រការដែលពោលហើយ លោកអាចារ្យអ្នកសួរ គង់សួរក្នុងន័យថា ធ្វើឲ្យរម្ងាប់ ជាការនាំចូលទៅកាន់ការមិនមាន អស់ហើយដោយប្រការទាំងពួង ។

សេចក្ដីថា **ឥតិ កិរ** ជាដើម , ពាក្យមួយទៀត ជាពាក្យឆ្លើយសំណួរតាមដែលពោលហើយ ។ ក្នុងពាក្យនោះ ស័ព្ទថា **កិរ** ជានិបាត ក្នុងសេចក្ដីថា **យទិ** ( ប្រសិនបើថា ) នេះ មានន័យថា **ឥតិ កិរ សិក្ខតិ** គឺ ប្រសិនបើភិក្ខុសិក្សាតាមអាការដែលខ្ញុំម្ចាស់បានពោលទុក ។ ពាក្យថា **កាលបើដូច្នេះ** គឺ កាលមានការធ្វើឲ្យរម្ងាប់ដូច្នេះ ។ ពាក្យថា **ការធ្វើ ( អានាបានស្សតិ , អានាបានស្សតិ-សមាធិ ) ឲ្យកើតឡើង ក៏សម្រេចបាន** អធិប្បាយថា កាយសង្ខារដែលគ្រោត-គ្រាត រមែងរម្ងាប់ទៅក៏ពិត , តែថា កាយសង្ខារដែលល្អិត នៅមានប្រាកដ ព្រោះដូច្នោះ ការធ្វើអានាបានស្សតិ និង អានាបានស្សតិសមាធិឲ្យកើតឡើង រមែងសម្រេចបានយ៉ាងប្រាកដ ព្រោះមាននិមិត្តកើតឡើង ដោយអំណាចនៃខ្យល់ដង្ហើមដែលដល់នូវភាពល្អិតសុខុម តាមលំដាប់ ។

ពាក្យថា **មានឧបមាប្រៀបបានដូចអ្វី** មានន័យថា វិធីការតាមដែលពោលហើយនោះ មានឧបមាប្រៀបដូចអ្វី ទើបគប្បីយល់បាន , អធិប្បាយថា ឧបមាប្រភេទណា ទើបដើម្បីឲ្យអាចទទួលយកខ្លឹមសារនោះបាន មានដែរឬ ។ ឥឡូវនេះ

ព្រះសារីបុត្តត្ថេរ បំណាងសម្ដែងឧបមា ទើបពោលថា **សេយ្យថាបិ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **សូម្បីយ៉ាងណា** ជាពាក្យនិបាត ក្នុងសេចក្ដីថា ជាឧបមា ។ បទថា **កំសេ** បានដល់ ភាជនៈសម្រិត ។ បទថា **និមិត្តំ** កែជា **និមិត្តស្ស** មានន័យថា ការប្រព្រឹត្តទៅនៃសំឡេងទាំងនោះ ។ បទថា **និមិត្តំ** នេះជា ទុតិយាវិភត្តិ ក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។ បទថា **សុគ្គហិតត្តា** ប្រែថា ព្រោះ ( និមិត្តនៃ សំឡេងគ្រោតគ្រាត ) បុគ្គលកាន់យកបានល្អហើយ ។ ពាក្យថា **ព្រោះធ្វើទុកក្នុងចិត្តបានល្អហើយ** គឺ ព្រោះតម្កល់ទុកក្នុងចិត្តបានដោយល្អ ។ ពាក្យថា **ព្រោះចងចាំទុកក្នុងចិត្តបានល្អហើយ** បានដល់ ព្រោះទ្រទ្រង់ចាំទុកបាន គឺ ព្រោះកំណត់ទុកបានដោយប្រពៃហើយនោះឯង ។ លោកពោលដល់សំឡេងជួមថា **សុខុមកា សទ្ទា - សំឡេងល្អិត** បានដល់ សំឡេងស្រាល , ព្រោះ “ **ក** ” ស័ព្ទ ( ក្នុងពាក្យថា **សុខុមកា** ) នេះ មានអត្ថថា **ល្អិត** គឺ ស្រាល ។ ពាក្យថា **ព្រោះភាវៈដែលនិមិត្តនៃសំឡេងសុខុម ជាអារម្មណ៍** មានន័យថា សំឡេងដែលសុខុមនោះឯង ជានិមិត្ត ទើបហៅថា **សុខុមសទ្ទនិមិត្តំ** បានដល់ ព្រោះភាវៈដែលមាននិមិត្ត គឺ សំឡេងល្អិតនោះជាអារម្មណ៍ ។ មានអធិប្បាយដូចម្ដេច ? មានអធិប្បាយថា ក្នុងពេលនោះ សំឡេងដែលល្អិតនោះ រលត់ទៅហើយ ក៏ពិត តែព្រោះនិមិត្តនៃសំឡេង បុគ្គលកាន់យកបានល្អហើយ ចិត្តក៏នៅប្រព្រឹត្តទៅបាន ដោយភាវៈមាននិមិត្តនៃសំឡេងដ៏ល្អិតជាង ជាអារម្មណ៍ ។ ពិតហើយ កាលបុគ្គលមានចិត្តមិនរាយមាយ ចងចាំនិមិត្តនៃសំឡេងដែលរលត់ទៅហើយនោះ តាំងពីដើម ចិត្តក៏នៅប្រព្រឹត្តទៅ ធ្វើនិមិត្តនៃសំឡេងដែលកាន់តែល្អិតនោះ ឲ្យជាអារម្មណ៍បាន ក្នុងទីបំផុតតាមលំដាប់ ។ ឈ្មោះថា ចិត្តមិនដល់នូវភាពរាយមាយ ព្រោះមានការតាំង

មាំក្នុងនិមិត្ត តាមដែលប្រាកដហើយនោះ ។

ពាក្យថា **កាលបើដូច្នេះជាដើម** លោកពោលទុក ទាក់ទងនឹងពាក្យបញ្ចាក់ដល់សេចក្តីដែលបានពោលហើយនោះឯង ។ ក្នុងពាក្យទាំងឡាយនោះ លោកពោលដល់ អត្ថ ពាក្យសួរ និង ពាក្យឆ្លើយ នៃបទព្រះសូត្រណាទុក , ដើម្បីនឹងលើកបទព្រះសូត្រនោះឡើង សម្តែងនូវកាយានុបស្សនាសតិប្បដ្ឋាន ដោយការចែកទើបពោលថា “ កាយសង្ខារដែលភិក្ខុធ្វើឲ្យរម្ងាប់ ” ដូច្នេះជាដើម , ពាក្យនោះទាំងអស់ ងាយហើយ ព្រោះមានន័យតាមដែលពោលហើយនោះឯង ។

( ចប់ មហាដីកា )

## ខ្យល់ដង្ហើមគ្រោតគ្រាត - ល្អិត

## សមថន័យ

សូម្បីក្នុងថ្នាក់នៃការកំណត់ ក៏នៅរាប់ថា គ្រោតគ្រាត , ក្នុងថ្នាក់ឧបចារៈនៃបឋមជ្ឈាន ទើបល្អិត , ក្នុងថ្នាក់ឧបចារៈនៃបឋមជ្ឈាននោះ ក៏នៅគ្រោតគ្រាតក្នុងតួបឋមជ្ឈាន ទើបល្អិត , ក្នុងបឋមជ្ឈាន និង ឧបចារៈនៃទុតិយជ្ឈាននៅគ្រោតគ្រាត ក្នុងទុតិយជ្ឈានទើបល្អិត , ក្នុងទុតិយជ្ឈាន និង ឧបចារៈនៃតតិយជ្ឈាននៅគ្រោតគ្រាត ក្នុងតតិយជ្ឈានទើបល្អិត , ក្នុងតតិយជ្ឈាន និង ឧបចារៈនៃចតុត្ថជ្ឈាននៅគ្រោតគ្រាត ក្នុងចតុត្ថជ្ឈានទើបល្អិត រហូតដល់នូវការមិនប្រព្រឹត្តទៅតែម្តង , ពាក្យដែលពោលមកនេះ ជាមតិរបស់ព្រះទីឃភាណកៈ

( អ្នកពោល គម្ពីរទីឃនិកាយ ) និង ព្រះសំយុត្តភាណកៈ ( អ្នកពោលគម្ពីរសំយុត្តនិកាយ ) រឺឯ ព្រះមជ្ឈិមភាណកៈ ( អ្នកពោលគម្ពីរមជ្ឈិមនិកាយ ) ទាំងឡាយ បំណងយកថា សូម្បីឧបចារៈនៃឈានជាន់លើៗ ក៏ល្អិតជាងឈានជាន់ក្រោមៗ ( តាមលំដាប់ ) ដូចជា “ ក្នុងបឋមជ្ឈាននៅគ្រោតគ្រាត ក្នុងឧបចារៈនៃទុតិយជ្ឈានទើបល្អិត ” ដូច្នេះ ជាឧទាហរណ៍ , តែថា តាមមតិរបស់អាចារ្យទាំងអស់នោះ គង់បានសេចក្តីថា កាយសង្ខារដែលប្រព្រឹត្តទៅក្នុងកាលដែលមិនទាន់បានកំណត់យក ( ព្រះកម្មដ្ឋាន ) និង កាយសង្ខារដែលប្រព្រឹត្តទៅក្នុងពេលដែលបានកំណត់យក ( ព្រះកម្មដ្ឋាន ) រមែងស្ងប់រម្ងាប់ក្នុងឧបចារៈនៃបឋមជ្ឈាន ។ ល ។ កាយសង្ខារដែលប្រព្រឹត្តទៅក្នុងឧបចារៈនៃចតុត្ថជ្ឈាន ក៏ស្ងប់រម្ងាប់ទៅក្នុងចតុត្ថជ្ឈាន ដូច្នេះឯង នេះជាន័យក្នុងផ្លូវសមថៈជាបទដំបូង ។

## មហាដីកា

ពាក្យថា **ទាក់ទងជាកម្មដ្ឋានរបស់ព្រះយោគាវចរជាអាទិកម្មិកៈ** លោកពោលសំដៅយកសមថកម្មដ្ឋាន រឺឯ វិបស្សនាកម្មដ្ឋាន មាននៅក្នុងចតុក្កៈដទៃ ។ បទថា **ឯត្ថ យោគ បឋមចតុក្កេ** ប្រែថា ក្នុងចតុក្កៈដំបូងនេះ ។ ពាក្យថា **ដែលមានសន្ធិ ៥** គឺ មាន ៥ ប្រការ មានន័យថា មាន ៥ ចំណែក ។ ពាក្យថា **ការរៀនយកនូវកម្មដ្ឋាន** គឺ ការរៀនគម្ពីរដែលពោលអំពីកម្មដ្ឋាន ។ ការសាកសួរនូវខ្លឹមសារក្នុងគម្ពីរ ដែលពោលអំពីកម្មដ្ឋាននោះ ឈ្មោះថា **ការសាកសួរនូវកម្មដ្ឋាន** ។ ន័យមួយទៀត ការរៀនកម្មដ្ឋានដោយគម្ពីរ និង ដោយសការៈ ឈ្មោះថា **ឧគ្គហ** ។ ការសាកសួរ ព្រោះការសង្ស័យក្នុងកម្មដ្ឋាននោះ ឈ្មោះថា **បរិបុច្ឆា** ។ ពាក្យថា

**ការប្រាកដនៃកម្មដ្ឋាន** បានដល់ ការប្រាកដនៃនិមិត្ត គឺ ការចងចាំទុកថា កាលយើងបំពេញការនាទៅយ៉ាងនេះ និមិត្តរមែងប្រាកដក្នុងកម្មដ្ឋាននេះ ដូច្នេះ ។ ដែលឈ្មោះថា អប្បនានៃកម្មដ្ឋានក៏យ៉ាងនោះដូចគ្នា បានដល់ ការចងចាំទុកថា កាលយើងបំពេញការនាទៅយ៉ាងនេះ " ឈានរមែងដល់អប្បនាបានយ៉ាងនេះ " ។ ពាក្យថា **ការកំណត់កម្មដ្ឋាន** បានដល់ ការកំណត់ទុកដោយល្អ នូវសភាវៈនៃកម្មដ្ឋានថា ព្រោះធ្វើការនាឲ្យឈានទៅមុខដោយអំណាចនៃ **គណនា** ( ការរាប់ ) , **អនុពន្ធនា** ( ការជាប់តាមខ្យល់ ) និង **ផុសនា** ( ឋានដែលប៉ះខ្ទប់ ) ទើបមានការសម្រេច **ឋបនា** ( ការតាំងមាំ គឺ អប្បនា ) ឬ សូម្បីក្រៅពីនោះ គឺ មានការដល់នូវកំពូលទាក់ទងនឹងការសម្រេច **សល្លក្ខណា** ( វិបស្សនាដែលកំណត់ត្រៃលក្ខណ៍ ) ជាដើម ដូច្នេះ ។ ព្រោះហេតុនោះឯង លោកទើបពោលថា មានអធិប្បាយថា **ការចងចាំសភាវៈនៃកម្មដ្ឋាន** ដូច្នេះ ។

ពាក្យថា **រមែងមិនលំបាកដោយខ្លួនឯង** ព្រោះរៀនយកកម្មដ្ឋានបានដោយល្អហើយ ព្រោះហេតុនោះឯង ទើបឈ្មោះថា រមែងមិនធ្វើឲ្យអាចារ្យក្តៅក្រហាយ ឬ ព្រោះការញ៉ាំងធម៌ឲ្យសម្រេចដល់កំពូលនៃការនាបាន ។ ពាក្យថា **ព្រោះដូច្នោះ** គឺ ព្រោះហេតុនោះ បានដល់ ព្រោះហេតុដែលមិនធ្វើខ្លួនឲ្យលំបាក មិនធ្វើអាចារ្យឲ្យក្តៅក្រហាយ ។ បទថា **ថោកំ** កែជា **ថោកំ ថោកំ** ( តិចតួច )។ វិធីការនៃកម្មដ្ឋានទាំងអស់ ឈ្មោះថា **ឧគ្គហ** ក្នុងបទថា **អាចរិយុគ្គហោ** ព្រោះត្រូវរៀន មិនមែនតែជាឧគ្គហៈ ( ការរៀន ) ដែលបានពោលក្នុងសន្ធិប្រការដើមនោះទេ ។ វិធីការដែលរៀនពីអាចារ្យ ឈ្មោះថា **អាចរិយុគ្គហោ** បានដល់ រៀនពីអាចារ្យនោះ ។ ពាក្យថា **សូម្បីមួយបទ** គឺ សូម្បីត្រឹមតែផ្នែកមួយ ។

បទថា **អនុវហនា - ការជាប់តាម** គឺ ញ៉ាំងសតិឲ្យប្រព្រឹត្តទៅរឿយៗ មិនដាច់ ដោយអំណាចការជាប់តាមខ្យល់ដង្ហើមចូល និង ខ្យល់ដង្ហើមចេញ ។ បទថា **ផុសនា** បានដល់ ប៉ះខ្ទប់គ្នា រវាងខ្យល់ទាំងនោះជាមួយបរិវេណចុងច្រមុះ នៃព្រះយោគាវចរដែលរាប់ខ្យល់ដង្ហើមចូល និងខ្យល់ដង្ហើមចេញ កាលមានការរាប់ហើយ ក៏ញ៉ាំងសតិជាប់តាមខ្យល់ទាំងនោះ ហើយតម្កល់ចិត្តទុក ក្នុងប្រការដែលអប្បនាគប្បីកើតឡើងបាន ។ តែព្រោះហេតុថា មនសិការទាក់ទងនឹងកម្មដ្ឋាន ដែលខ្យល់ប៉ះខ្ទប់ត្រង់ផ្នែកមួយដទៃទៀត ដូចជាមនសិការដែលទាក់ទងនឹងការរាប់ជាដើម មិនមាន , លោកអាចារ្យកាលនឹងសម្តែងថា ឋានដែលខ្យល់ប៉ះខ្ទប់ ជាទីត្រូវរាប់ខ្យល់ក្នុងទីនេះ ទើបពោលថា បទថា **ផុសនា** បានដល់ ឋានដែលខ្យល់ប៉ះខ្ទប់ ដូច្នេះ កាលសម្តែងថា គួរធ្វើការរាប់ខ្យល់ជាដើម ត្រង់ដែលខ្យល់ប៉ះខ្ទប់ហើយ ប៉ះខ្ទប់ទៀតនោះឯង ។ បទថា **ឋបនា** បានដល់ ការតាំងមាំដោយប្រពៃ( សមាធិ )។ ពិតហើយ ការតាំងមាំដោយប្រពៃនោះ ជាការតាំងមាំ គឺ ការតម្កល់ចិត្តទុកក្នុងអារម្មណ៍ ដោយប្រពៃនោះឯង ។ ពិតហើយ ទ្រង់សម្តែងអធិប្បាយសមាធិទុកថា “ ការតាំងមាំ ការតម្កល់មាំដោយប្រពៃនៃចិត្ត ” ។ អប្បនា មានសមាធិជាប្រធាន ព្រោះហេតុនោះ លោកទើបពោលថា បទថា **ឋបនា** បានដល់ អប្បនា ។

( ចប់ មហាដីកា )

# ខ្យល់ដង្ហើមគ្រោតគ្រាត – ល្អិត
# វិបស្សនានយ័

រីឯ ក្នុងន័យវិបស្សនា កាយសង្ខារដែលប្រព្រឹត្តទៅក្នុងខាងដើម ដែលមិនទាន់បានកំណត់ ក៏នៅគ្រោតគ្រាត ក្នុងពេលដែលកំណត់មហាភូតរូប ទើបល្អិតសូម្បីកាយសង្ខារក្នុងពេលដែលកំណត់មហាភូតរូបនោះ ក៏នៅគ្រោតគ្រាត តែពេលកំណត់ឧបាទាយរូប ទើបល្អិត កាយសង្ខារក្នុងពេលកំណត់ឧបាទាយរូបនោះ ក៏នៅគ្រោតគ្រាត ដល់ពេលកំណត់សកលរូប ទើបល្អិត កាយសង្ខារក្នុងពេលកំណត់សកលរូបនោះ នៅគ្រោតគ្រាត តែពេលកំណត់អរូប ទើបល្អិត កាយសង្ខារក្នុងពេលកំណត់អរូបនោះ នៅគ្រោតគ្រាត តែពេលកំណត់ទាំងរូបទាំងអរូប ទើបល្អិតសូម្បីកាយសង្ខារក្នុងពេលកំណត់ទាំងរូបទាំងអរូបនោះ ក៏នៅគ្រោតគ្រាត តែពេលកំណត់បច្ច័យ ( របស់នាមរូប ) ទើបល្អិត កាយសង្ខារក្នុងពេលកំណត់បច្ច័យនោះ ក៏នៅគ្រោតគ្រាត តែពេលដែលឃើញនាមរូបព្រមទាំងបច្ច័យ ទើបល្អិតកាយសង្ខារពេលឃើញនាមរូបព្រមទាំងបច្ច័យនោះ ក៏នៅគ្រោតគ្រាត តែពេលមានវិបស្សនាដែលមានត្រៃលក្ខណ៍ជាអារម្មណ៍ ទើបល្អិត ក្នុងទុព្វលវិបស្សនា នៅគ្រោតគ្រាត ក្នុងពលវវិបស្សនា ទើបល្អិត ។

ក្នុងវិបស្សនានោះ ការរម្ងាប់នៃកាយសង្ខារ ប្រព្រឹត្តទៅក្នុងពេលដំបូង និងក្នុងពេលក្រោយ បណ្ឌិតគប្បីជ្រាបតាមន័យដែលបានពោលមកហើយខាងដើមនោះចុះ ( ដូចក្នុងសមថន័យ កាយសង្ខារដែលមិនទាន់បានកំណត់ និងបានកំណត់ ) ។

ភាពគ្រោតគ្រាត និង ល្អិតក្តី ការរម្ងាប់ក្តី ( កាយសង្ខារ ) ក្នុងប្រការ

**បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមិ ... បស្សសិស្សាមិ** នេះ បណ្ឌិតគប្បី ជ្រាបតាមន័យដូចពោលមកដូច្នេះចុះ ។

# អធិប្បាយ ក្នុងបដិសម្ភិទាមគ្គ

រីឯ ក្នុងបដិសម្ភិទាមគ្គ លោកពោលសេចក្តីត្រង់នេះ ព្រមទាំងពាក្យសួរ និង ពាក្យឆ្លើយថា “ សួរថា ភិក្ខុសិក្សាថា យើងនឹងជាអ្នករម្ងាប់កាយសង្ខារ ដកដង្ហើមចេញ ដកដង្ហើមចូល ដូចម្តេច អ្វីជាកាយសង្ខារ , ឆ្លើយថា ធម៌ទាំងឡាយដែលមាននៅក្នុងកាយ គឺ ខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលវែង ដែលជាធម៌ទាក់ទងក្នុងកាយ នេះឈ្មោះថា កាយសង្ខារ ភិក្ខុធ្វើកាយសង្ខារនោះឲ្យរម្ងាប់ គឺឲ្យស្ងប់ចុះ សិក្សាទៅ ។ ល ។ សិក្សាថា យើងនឹងរម្ងាប់កាយសង្ខារ ( គ្រោតគ្រាត ) ដែលជាហេតុធ្វើឲ្យកាយឃ្លេងឃ្លោង យោលយោក ញាប់ញ័រទៅមកហើយ ដកដង្ហើមចេញ សិក្សាថា យើងនឹងរម្ងាប់កាយសង្ខារ ( គ្រោតគ្រាត ) ... ដកដង្ហើមចូល , សិក្សាថា យើងនឹងរម្ងាប់កាយសង្ខារដែលស្ងប់ល្អិត ដែលជាហេតុឲ្យកាយមិនយោក មិនឃ្លោង មិនឱន មិនអែន មិនវិល មិនញ័រ ដកដង្ហើមចេញ ... ដកដង្ហើមចូល ” ។

មានពាក្យសួរថា បើដូច្នោះ ឈ្មោះថា **បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ** កាលបើយ៉ាងនោះ ( គឺ សូម្បីកាយសង្ខារដែលល្អិត ក៏ត្រូវរម្ងាប់ទៀត មែនឬ ? ការធ្វើ **វាតុបលទ្ធិ** ( ការកំណត់ដឹងខ្យល់ ) ឲ្យកើតទៅ មិនមាន ការញុំាងខ្យល់ដង្ហើមចេញ និង ខ្យល់ដង្ហើមចូលឲ្យប្រព្រឹត្តទៅ ក៏មិនមាន ( ព្រោះទាំង គ្រោតគ្រាត

ទាំងល្អិតរម្ងាប់ហើយ ) ការចម្រើនអានាបានស្សតិតទៅ ក៏មិនមានការបំពេញអានាបានស្សតិសមាធិក៏មិនមែន ( ព្រោះមិនមានខ្យល់ជាអារម្មណ៍ ) ដូច្នោះ បណ្ឌិតទាំងឡាយក៏មិនបានចូលសមាបត្តិនោះ ទាំងមិនបានចេញពីសមាបត្តិនោះផងដែរ ?

មានពាក្យឆ្លើយថា សូម្បីដូច្នោះ ឈ្មោះថា **បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ** កាលបើដូច្នោះ ( គឺ ពេលកាយសង្ខារស្ងប់ទៅយ៉ាងនោះ ) ការធ្វើ **វាត្ថុបលទ្ធិ** ឲ្យកើតតទៅ ក៏នៅសម្រេចបាន ការញាំងខ្យល់ដង្ហើមចេញ និងខ្យល់ដង្ហើមចូលក៏ប្រព្រឹត្តទៅបាន ការចម្រើនអានាបានស្សតិ ក៏សម្រេចបាន ការបំពេញអានាបានស្សតិសមាធិ ក៏សម្រេចបាន ហើយបណ្ឌិតទាំងឡាយចូលសមាបត្តិក៏បាន ចេញចាកសមាបត្តិក៏បាន តាមដែលពោលមកនេះ មានឧបមាដូចម្តេច ? មានឧបមាដូចការគោះភាជន៍ដែលធ្វើពីលោហៈ សំឡេងគ្រោតគ្រាត រមែងប្រព្រឹត្តទៅមុន ចិត្ត ( ដែលដឹងរបស់មនុស្ស ) ក៏ប្រព្រឹត្តទៅ ព្រោះកាន់យកនិមិត្តនៃសំឡេងគ្រោតគ្រាតបានដោយងាយ ព្រោះធ្វើនិមិត្តនៃសំឡេងគ្រោតគ្រាត ទុកក្នុងចិត្តបានដោយងាយ ព្រោះចងចាំនិមិត្តនៃសំឡេងគ្រោតគ្រាតបានដោយងាយ សូម្បីសំឡេងគ្រោតគ្រាតរលត់ទៅហើយ បន្ទាប់ពីនោះទៅ សំឡេងល្អិតក៏នៅប្រព្រឹត្តទៅ ចិត្តក៏នៅប្រព្រឹត្តទៅ ព្រោះនៅកាន់យកនិមិត្តនៃសំឡេងល្អិតនោះបានល្អ ព្រោះធ្វើនិមិត្តនៃសំឡេងល្អិតនោះទុកក្នុងចិត្តបានល្អ ព្រោះនៅចងចាំនិមិត្តនៃសំឡេងល្អិតនោះ បានល្អ កាលសំឡេងល្អិតនោះរលត់ទៅហើយ បន្ទាប់ពីនោះទៅ ក៏នៅមាននិមិត្តនៃសំឡេងល្អិតនោះជាអារម្មណ៍ យ៉ាងណា ឧបមេយ្យក៏ដូច្នោះ ខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូលដែលគ្រោតគ្រាតរមែងប្រព្រឹត្តទៅមុន ចិត្តក៏មិនដាច់ខ្សែ ព្រោះកាន់

យកនិមិត្តខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូល ដែលគ្រោតគ្រាតបានដោយងាយ ព្រោះធ្វើនិមិត្តនៃខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូល ដែលគ្រោតគ្រាតទុកក្នុងចិត្តបានដោយងាយ ព្រោះសង្កេតនិមិត្តនៃខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូល ដែលគ្រោតគ្រាតបានដោយងាយ សូម្បីកាលខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូល ដែលគ្រោតគ្រាតរលត់ហើយ បន្ទាប់ពីនោះ ខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូលដែលល្អិតក៏នៅប្រព្រឹត្តទៅបាន ចិត្តក៏មិនដាច់ខ្សែ ព្រោះនៅកាន់យកនិមិត្តនៃខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូលដែលល្អិតបានដោយល្អ នៅធ្វើនិមិត្តខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូលដែលល្អិតទុកក្នុងចិត្តបានដោយល្អ នៅសង្កេតនិមិត្តនៃខ្យល់ដង្ហើមចេញ ខ្យល់ដង្ហើមចូលដែលល្អិតបានដោយល្អ កាលខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូលដែលល្អិតរលត់ទៅហើយ បន្ទាប់ពីនោះ ចិត្តក៏មិនទាន់ដាច់ខ្សែ ព្រោះនៅញ៉ាំងនិមិត្តនៃខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូលដែលល្អិតឲ្យជាអារម្មណ៍ កាលបើដូច្នេះ ទើបពោលថា ការធ្វើវាតុបលទ្ធិឲ្យកើតតទៅក៏នៅសម្រេចបាន ការញ៉ាំងខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូល ឲ្យប្រព្រឹត្តទៅក៏នៅមាន ការចម្រើនអានាបានស្សតិតទៅ ក៏សម្រេច ការបំពេញអានាបានស្សតិសមាធិតទៅ ក៏សម្រេចបាន បណ្ឌិតទាំងឡាយចូលសមាបត្តិនោះក៏បាន ចេញចាកសមាបត្តិក៏បាន ។

កងខ្យល់ដែលរម្ងាប់កាយសង្ខារ ខ្យល់ដង្ហើមចេញខ្យល់ដង្ហើមចូលរាប់ជាកាយ , វត្ថុដែលចូលទៅ ( ធ្វើកាយនោះជាអារម្មណ៍ )តាំងនៅ ជាសតិ , អនុបស្សនា ( ការតាមកំណត់កាយឲ្យដឹងតាមដែលវាប្រាកដ ) ជាញាណ , កាយដែលជាទីតាំងនៃសតិ មិនមែនសតិ សតិជាទីតាំងផង ជាគួរលឹកផង ព្រះយោគាវចរ កំណត់កាយនោះដោយសតិនោះ ដោយញាណនោះ ព្រោះហេតុនោះ ទ្រង់

ទើបត្រាស់ថា **ការតាមកំណត់កាយក្នុងកាយ** ជាការបំពេញសតិប្បដ្ឋាន ។

នេះជាពាក្យពណ៌នាបទតាមលំដាប់នៃចតុក្កៈទី ១ ដែលទ្រង់ត្រាស់ជា កាយានុបស្សនា ក្នុងអានាបានស្សតិនេះ ជាលំដាប់ដំបូង ។

## វិធីហ្វឹកហាត់

ព្រោះថា ក្នុងចតុក្កៈទាំង ៤ នោះ ចតុក្កៈនេះប៉ុណ្ណោះដែលទ្រង់ត្រាស់ទុកជាកម្មដ្ឋានសម្រាប់អាទិកម្មិកៈ ( អ្នកផ្ដើមបដិបត្តិ ) , រីឯ ចតុក្កៈ ៣ ក្រៅពីនេះ ត្រាស់ដោយវេទនានុបស្សនា ចិត្តានុបស្សនា និង ធម្មានុបស្សនា សម្រាប់អ្នកបានឈានក្នុងចតុក្កៈដំបូងនេះហើយ ព្រោះហេតុនោះហើយ អាទិកម្មិកកុលបុត្ត ដែលប្រាថ្នានឹងចម្រើនកម្មដ្ឋាននេះ ដើម្បីសម្រេចអរហត្ត ព្រមទាំងបដិសម្ភិទា ដោយវិបស្សនាដែលមានអានាបានចតុត្ថជ្ឈានជាបទដ្ឋាន គប្បីញុំាងកិច្ចទាំងពួង មានការធ្វើសីលឲ្យបរិសុទ្ធជាអាទិ៍ តាមន័យដូចពោលមកខាងដើមនោះ ហើយគប្បីរៀនយកកម្មដ្ឋានដែលមានសន្ធិ ៥ ក្នុងសម្នាក់របស់អាចារ្យតាមដែលពោលហើយនោះចុះ ។

## បញ្ចសន្ធិ

សន្ធិ ៥ ក្នុងពាក្យនោះ **ឧគ្គហៈ បរិបុច្ឆា ឧបដ្ឋាន អប្បនា លក្ខណៈ** ក្នុងសន្ធិ ៥ នោះ ការរៀន ( បែបផែន ) កម្មដ្ឋាន ឈ្មោះថា **ឧគ្គហៈ** , ការសាកសួរ ( ខ្លឹមសារ ) កម្មដ្ឋាន ឈ្មោះថា **បរិបុច្ឆា** , ការប្រាកដនៃ ( និមិត្ត ) កម្មដ្ឋាន ឈ្មោះថា **ឧបដ្ឋាន** , ការតម្កល់មាំនៃកម្មដ្ឋាន ឈ្មោះថា **អប្បនា** , ការកំណត់កម្មដ្ឋានទុក មានអធិប្បាយថា ចងចាំសភាពនៃកម្មដ្ឋានទុកថា កម្មដ្ឋាននេះ មាន

លក្ខណៈយ៉ាងនេះ ឈ្មោះថា **លក្ខណៈ** ។

ព្រះយោគាវចរ កាលរៀនយកកម្មដ្ឋានមានសន្ធិ ៥ ដូច្នេះ ខ្លួនឯងក៏មិនលំបាក ទាំងមិនបៀតបៀនអាចារ្យផង ព្រោះដូច្នោះ អានាបានស្សតិកម្មដ្ឋាននេះ ព្រះយោគាវចរ គប្បីឲ្យអាចារ្យសម្ដែងតែបន្តិចបន្តួច ប្រើពេលស្វាធ្យាយឲ្យយូរ រៀនយកកម្មដ្ឋានឲ្យបានសន្ធិ ៥ យ៉ាង នោះហើយ នៅក្នុងសម្នាក់អាចារ្យក៏បាន ក្នុងសេនាសនៈដទៃមានប្រការដូចពោលមកហើយ ក៏បាន កាត់បលិពោធតូចតាចចេញ ធ្វើកត្តកិច្ច បន្ទាប់ការស្រេីងអាហារ ហើយអង្គុយឲ្យសប្បាយ ញុំាងចិត្តឲ្យត្រេកអរ ដោយរលឹកដល់គុណព្រះរតនត្រៃ មិនភ្លេចសូម្បីតែមួយបទ ពីកន្លែងដែលរៀនពីអាចារ្យ មនសិការទៅចុះ ។

## វិធីមនសិការ

នេះជាវិធីមនសិការក្នុងអានាបានស្សតិកម្មដ្ឋាននោះ គឺ ៖

| | | |
|---|---|---|
| ១- **គណនា** | រាប់ | ( ខ្យល់ ) |
| ២- **អនុពន្ធនា** | ជាប់តាម | ( ខ្យល់ ) |
| ៣- **ផុសនា** | កន្លែងប៉ះ | ( ខ្យល់ ) |
| ៤- **ឋបនា** | តម្កល់ | ( ចិត្ត ) |
| ៥- **សល្លក្ខណា** | កំណត់ដឹងច្បាស់ | |
| ៦- **វិវដ្ដនា** | បញ្ឈប់ | |
| ៧- **បារិសុទ្ធិ** | បរិសុទ្ធ | |
| ៨- **តេសំ បដិបស្សនា** | មើលឡើងវិញនូវ វិវដ្ដនា និង បារិសុទ្ធិនោះ ។ | |

ក្នុងបទទាំងឡាយនោះ បទថា **គណនា** គឺ រាប់ ( ខ្យល់ ) នោះឯង ។ បទថា **អនុពន្ធនា** គឺ តាម ( ខ្យល់ ) ។ បទថា **ផុសនា** សំដៅដល់ស្ថានទីដែលខ្យល់ប៉ះខ្ទប់ ។ បទថា **ឋបនា** សំដៅយកអប្បនា ។ បទថា **សល្លក្ខណា** បានដល់ វិបស្សនា ។ បទថា **វិវដ្តនា** បានដល់ មគ្គ ។ បទថា **បារិសុទ្ធិ** បានដល់ផល ។ បទថា **តេសំ បដិបស្សនា** គឺ បច្ចវេក្ខណៈ ។

## គណនា-វិធីរាប់

ក្នុងវិធីទាំងឡាយនោះ អាទិកម្មិកកុលបុត្ត គប្បីមនសិការកម្មដ្ឋាននេះ ដោយវិធីរាប់ជាមុន ឯកាលរាប់ មិនគប្បីឈប់ក្រោម ៥ មិនគប្បីរាប់លើសពី ១០ មិនគប្បីសម្តែងការរាប់ឲ្យដាច់ជាចន្លោះៗ ព្រោះកាលបើឈប់ក្រោម ៥ ចិត្តុប្បាទនឹងរសាប់រសល់ក្នុងឱកាសចង្អៀត ដូចហ្វូងគោត្រូវឃាំងទុកក្នុងក្រោលតូចៗ បម្រះចេញដូច្នោះ កាលរាប់លើសពី ១០ ចិត្តុប្បាទនឹងកង្វល់នៅក្នុងការរាប់នោះ ( មិនវល់នឹងកម្មដ្ឋាន ) កាលសម្តែងការរាប់ដាច់ជាចន្លោះ ចិត្តនឹងកង្វល់ ( ដោយគិតទាក់ទើ ) ថា កម្មដ្ឋានរបស់យើងនឹងដល់ទីបំផុតឬទេហ្ន៎ ! ព្រោះដូច្នោះហើយគប្បីរាប់ដោយការវៀរចាកទោសទាំងនោះចេញ ។

## រាប់យឺត

អាទិកម្មិកៈដែលត្រូវរាប់ គួររាប់ដោយវិធីរាប់យឺត គឺ រាប់របៀបមនុស្សវាល់អង្ករសិន , ពិតហើយ មនុស្សវាល់អង្ករ កើបពេញនាឡិហើយ ប្រាប់ថា ១ ហើយចាក់ចូលទៅ កើបទៀត បើឃើញកម្ទេចអ្វីៗ ( នៅក្នុងអង្ករ ក៏រើស ) បោះចោលទៅបណ្តើរ ៗ ប្រាប់ថា “១ . ១” ទៅ ន័យក្នុងការប្រាប់ថា “២ . ២”

ជាដើម ក៏មានន័យដូច្នេះ យ៉ាងណា សូម្បីអាទិកម្មិកកុលបុត្តនេះ ក៏គប្បីកាន់យកខ្យល់អស្សាសបស្សាសៈដែលប្រាកដ កំណត់ខ្យល់ដែលប្រព្រឹត្តទៅរឿយៗ នោះរាប់ ផ្ដើមពី " ១ . ១ " រហូតដល់ " ១០ . ១០ " ដូច្នោះដូចគ្នា កាលលោករាប់យ៉ាងនោះ ខ្យល់អស្សាសបស្សាសៈដែលចេញនិងចូល រមែងប្រាកដ ។

## រាប់រហ័ស

ពេលនេះ លោកគប្បីលះវិធីរាប់យឺត គឺ រាប់ដូចមនុស្សវាល់អង្ករនោះចេញ ហើយរាប់ដោយវិធីរាប់លឿន គឺ រាប់ដូចគោបាល ពិតហើយ គោបាលអ្នកឆ្លាតកាន់ដុំក្រួស យកខ្សែ និង ឈើប្រត់ ទៅកាន់ក្រោលគោ តាំងពីព្រឹក ( បើកក្រោល ) ដេញគោច្រើនក្បាលទៅក្រោយហើយ អង្គុយនៅលើក្បាលសសររាប់មេគោដែលចេញមកដល់មាត់ទ្វារថា ១ . ២ ... ដោយដាក់ដុំក្រួលជាតំណាងរឿយៗ ទៅ ហ្វូងគោដែលនៅជាមួយគ្នាយ៉ាងលំបាក ក្នុងទីចង្អៀតអស់ ៣ យាមនៃរាត្រី កាលចេញ ក៏ប្រជ្រៀតគ្នាចេញជាហ្វូងៗ ដោយរហ័ស នាយគោបាលនោះ ក៏រាប់រហ័ស ៗ ដូចគ្នាថា ៣.៤.៥....១០ ( យ៉ាងណា ) សូម្បីអាទិកម្មិកកុលបុត្តនេះ រាប់តាមន័យមុន ខ្យល់អស្សាសបស្សាសៈប្រាកដ កាន់តែញាប់ឡើងតទៅ លោកក៏ដឹងថា ខ្យល់ដើរញាប់ហើយ កុំកាន់យកខ្យល់ខាងក្នុង និង ខ្យល់ខាងក្រៅ កាន់យកតែត្រង់ដែលវាមកដល់ចុងច្រមុះប៉ុណ្ណោះ រាប់ញាប់ ៗ ថា ៖

១ . ២ . ៣ . ៤ . ៥

១ . ២ . ៣ . ៤ . ៥ . ៦

១ . ២ . ៣ . ៤ . ៥ . ៦ . ៧

១ . ២ . ៣ . ៤ . ៥ . ៦ . ៧ . ៨

១ . ២ . ៣ . ៤ . ៥ . ៦ . ៧ . ៨ . ៩

១ . ២ . ៣ . ៤ . ៥ . ៦ . ៧ . ៨ . ៩ . ១០

ដូច្នោះ ព្រោះថា ក្នុងកម្មដ្ឋានដែលទាក់ទងដោយការរាប់ ចិត្តនឹងមានអារម្មណ៍តែមួយបាន ក៏ដោយកម្លាំងនៃការរាប់ប៉ុណ្ណោះ ដូចការឈប់នៃទូកក្នុងក្រសែទឹកហូរ ឈប់បានក៏ដោយសារការទប់របស់ថ្នោលប៉ុណ្ណោះ កាលលោករាប់ដោយរហ័សៗ យ៉ាងនោះ កម្មដ្ឋានរមែងប្រាកដ ដូចជាប្រព្រឹត្តទៅមិនមានចន្លោះ កាលលោកដឹងថា កម្មដ្ឋានប្រព្រឹត្តទៅមិនមានចន្លោះ ក៏កុំកំណត់ខ្យល់ខាងក្នុង ខ្យល់ខាងក្រៅ គប្បីរាប់ឲ្យញាប់តាមន័យដូចពោលហើយនោះចុះ ព្រោះថា កាលបញ្ជូនចិត្តទៅតាមខ្យល់ចូលខាងក្នុង ចិត្តនឹងដឹងថា ដូចជាត្រូវខ្យល់ប៉ះ និងដូចជាពេញទៅដោយខ្យល់ខាំងខាងក្នុង កាលបញ្ជូនចិត្តចេញទៅព្រមជាមួយខ្យល់ដែលចេញក្រៅ ចិត្តនឹងស្ទុះទៅកាន់អារម្មណ៍ផ្សេងៗ ខាងក្រៅ កាលតាំងសតិដែលទុកត្រង់ឱកាសដែលខ្យល់ប៉ះខ្ទប់ ភាវនាទៅ ភាវនាទើបសម្រេចបាន ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបពោលថា កុំកំណត់ខ្យល់ខាងក្នុង ខ្យល់ខាងក្រៅ គប្បីរាប់ឲ្យរហ័ស តាមន័យដែលពោលហើយនោះចុះ ។

សួរថា ខ្យល់នោះត្រូវរាប់យូរប៉ុណ្ណា ?

ឆ្លើយថា គប្បីរាប់រហូត ឈប់រាប់ហើយ សតិក៏នៅតាំងមាំបានក្នុងអារម្មណ៍ គឺ អស្សាសបស្សាសៈ ព្រោះថា ការរាប់ ក៏ដើម្បីលះការពិចារណារាយមាយទៅខាងក្រៅ ហើយតាំងសតិទុកក្នុងអារម្មណ៍ គឺ អស្សាសបស្សាសៈ ឲ្យបានមាំ ។

# មហាដីកា

***វិបស្សនា*** ឈ្មោះថា ***សល្លក្ខណា*** ព្រោះជាការកំណត់ដោយល្អនូវភាពជារបស់មិនទៀងជាដើម ។ ***មគ្គ*** ឈ្មោះថា ***វិវដ្តនា*** ព្រោះជាការវិលត្រឡប់ចាក ***បវត្ត*** ( តណ្ហាដែលធ្វើឲ្យប្រព្រឹត្តទៅ ) និងការចេញចាកនិមិត្ត ( សង្ខារក្នុងកាល ៣ ) ។ ***ផល*** ឈ្មោះថា ***បារិសុទ្ធិ*** ព្រោះអត្ថថា ជាការបរិសុទ្ធិដោយប្រការទាំងពួងដោយការៈដែលរម្ងាប់សន្តិលេសទាំងអស់បានហើយ ។ បទថា ***តេសំ*** បានដល់ វិវដ្តនា និង បារិសុទ្ធិ ។ បទថា ***បដិបស្សនា*** បានដល់ ការមើល ឬពិចារណាឡើងវិញ គឺ កំណត់ជាផ្នែក ៗ ព្រោះហេតុនោះ លោកទើបពោលថា បានដល់ បច្ចវេក្ខណៈ ដូច្នេះ ។

*ពាក្យថា* ***ការដាច់*** *បានដល់ ការដាច់ ( លំដាប់ ) នៃការរាប់យ៉ាងនេះ គឺ ១-៣-៥ ជាដើម ។ ពាក្យថា* ***ក្នុងឱកាសដែលចន្លៀត*** *លោកពោលសំដៅយកវិធីរាប់ ។ ឈ្មោះថា ត្រូវអាស្រ័យការរាប់ប៉ុណ្ណោះ គឺ មិនអាស្រ័យ កម្មដ្ឋាន ។ ពាក្យថា* ***នឹងដល់ទីបំផុតឬទេហ្ន៎*** *នេះលោកពោលទុកដោយទាក់ទងនឹងព្រះយោគីដែលមនសិការដោយការរាប់ទៅបានយូរក្រៃលែង ។*

*ពិតណាស់ ព្រះយោគីអង្គនោះ នឹងគប្បីសម្គាល់យ៉ាងនេះបាន ក៏ព្រោះអាស្រ័យត្រឹមតែការមិនរាយមាយ ដែលខ្លួនបានហើយយ៉ាងនោះ ។ ពាក្យថា* ***ក្នុងបណ្តាខ្យល់ដង្ហើមចេញ-ចូល ខ្យល់ប្រភេទណាប្រាកដ*** *ក៏គប្បីចាប់យកខ្យល់ប្រភេទនោះ នេះលោកពោលសំដៅយកព្រះយោគីដែលមានខ្យល់ដង្ហើមចេញ-ចូល តែម្យ៉ាងប៉ុណ្ណោះប្រាកដមុន ។ ចំណែកព្រះយោគីដែលមានខ្យល់ទាំងពីរយ៉ាងប្រាកដ គួរចាប់យកខ្យល់ទាំងពីរយ៉ាងរាប់ទៅ ។ ម្យ៉ាងទៀត ដោយពាក្យថា*

ខ្យល់ប្រភេទណាប្រាកដ នេះគប្បីឃើញថា លោកបានសម្ដែងន័យនេះថា ក្នុងបណ្ដាខ្យល់ត្រង់ប្រហោងច្រមុះ ២ ប្រភេទ ប្រភេទណាប្រាកដច្បាស់ជាង ក៏គួរចាប់យកខ្យល់ប្រភេទនោះ ដូច្នេះ ។ ដោយពាក្យពោលត្រួតថា កំពុងប្រព្រឹត្តទៅ កំពុងប្រព្រឹត្តទៅ លោកសម្ដែងដល់ការចូលទៅកំណត់ខ្យល់ដង្ហើមចេញ-ចូលបានមិនដាច់ខ្សែ ។ ពាក្យថា **កាលព្រះយោគីរាប់ទៅយ៉ាងនេះ** មានសេចក្ដីថា កាលចូលទៅកំណត់រាប់ទៅតាមប្រការដែលពោលហើយ ។ ឈ្មោះថា **ជាធម្មជាតិប្រាកដច្បាស់** ព្រោះ មិនមានការរាយមាយទៅខាងក្រៅដោយអំណាចការរាប់ ។

សសរដែលគេដាក់ជុំស្នៀតទុក ឈ្មោះថា សសររនុក ។ បទថា **តិយាម-រត្តិំ** ជាទុតិយាវិភត្តិក្នុង **អច្ចន្តសំយោគ** ប្រែថា ៣ យាមនៃរាត្រី ។ ពាក្យថា **ដោយន័យមុន** គឺដោយការរាប់រហ័ស មានសេចក្ដីថា ដោយការរាប់ដូចអ្នកចិញ្ចឹមគោ ។ ពាក្យថា ១-២-៣-៤-៥ ជាការសម្ដែងវិធីរាប់ ។ ព្រោះដូច្នោះសូម្បីក្នុងពាក្យថា ៨ ជាដើម ក៏គួរផ្ដើមរាប់តាំងអំពី ១ នោះឯងទៅរហូតដល់ ៨ ជាដើម តែមួយវិធី ។ គប្បីរាប់ទៅរហ័សៗ នោះឯង ព្រោះហេតុអ្វី ? លោកអាចារ្យសម្ដែងហេតុ និងរឿងនិទស្សនៈក្នុងការរាប់រហ័សនោះដោយពាក្យថា ពិតណាស់ ក្នុងកម្មដ្ឋានដែលទាក់ទងនឹងការរាប់ជាដើមក្នុងពាក្យទាំងនោះ ពាក្យថា **អរិត្ត** មានវចនត្ថៈថា ទូករមែងរសាត់ទៅបានដោយឈើនោះ ហេតុនោះ ឈើនោះឈ្មោះថា **អរិត្ត** បានដល់ ឈើដែលធ្វើឲ្យរសាត់ទៅបាន ( ច្រវាល )។ ការប្រត់ទុកដោយច្រវាល ឈ្មោះថា **អរិត្តុបត្ថម្ភនំ** បានដល់ ដោយអំណាចការទប់ទុកដោយច្រវាលនោះ ។

ឈ្មោះថា **ការប្រព្រឹត្តទៅមិនដាច់ខ្សែ** រមែងមានបានក្នុងឋបនានោះឯង

ដោយនិប្បរិយាយ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ហាក់បីដូចប្រព្រឹត្តទៅមិនដាច់ខ្សែដូច្នោះ ។ កាលមនសិការខ្យល់ដែលចូលទៅខាងក្នុង ក៏ឈ្មោះថា បញ្ជូនចិត្តចូលទៅខាងក្នុង ។ សូម្បីក្នុងការនាំចិត្តចេញទៅខាងក្រៅ ក៏មានន័យនេះឯង ។ ពាក្យថា **នឹងដូចជាត្រូវខ្យល់ប៉ះ** មានសេចក្តីថា កាលមនសិការខ្យល់ដែលនៅខាងក្នុងច្រើនៗ ឋាននោះ រមែងដូចជាត្រូវខ្យល់វាយយក និងរមែងដូចជាពេញទៅដោយខ្លាញ់ខាប់ កម្មដ្ឋានរមែងប្រាកដយ៉ាងនោះ ។ ឈ្មោះថា **កាលនាំចិត្តចេញទៅ** គឺ អំពីកាលព្រះយោគីលែងឱកាស ដែលខ្យល់ប៉ះបោល ហើយនាំចិត្តចេញទៅយ៉ាងនោះ ចិត្តក៏រមែងរសាត់ទៅក្នុងអារម្មណ៍ផ្សេងៗ ដោយការស្វែងរកគតិ ការទៅរបស់ខ្យល់ជាគន្លង ព្រោះហេតុនោះ លោកទើបពោលថា ចិត្តក៏រមែងរាយមាយទៅក្នុងអារម្មណ៍ ដែលមានសភាវៈសន្ទឹកសន្ធាប់ ខាងក្រៅដូច្នេះ ។

ពាក្យថា **នឹងត្រូវរាប់ខ្យល់នេះ** គឺនឹងត្រូវរាប់ខ្យល់ដង្ហើមចេញ-ចូល ដែលកើតហើយនេះ ។

ពាក្យថា **ការតាមខ្យល់ទៅ** មានសេចក្តីថា ការធ្វើឲ្យប្រព្រឹត្តទៅរឿយ ៗ ដោយសតិ ដោយទាក់ទងនឹងការធ្វើខ្យល់ដង្ហើមចេញ-ចូលដែលប្រព្រឹត្តទៅហើយឲ្យជាអារម្មណ៍ ឈ្មោះថា **ការតាមខ្យល់ទៅ** ។ ព្រោះហេតុនោះ ៗ ឯងលោកទើបពោលថា ក៏ការតាមខ្យល់ទៅនោះឯង មិនមែនមានដោយអំណាចការតាមដើមខ្យល់ កណ្តាលខ្យល់ និង ចុងខ្យល់ទេ ។ ដូច្នេះ សម្រាប់ខ្យល់ដែលចេញទៅខាងក្រៅឈ្មោះថា មានផ្ចិតជាដើមខ្យល់ ក៏ព្រោះកើតឡើងជាគ្រាដំបូងត្រង់ផ្ចិតនោះ ។ ព្រោះថា ឈ្មោះថា ដើមខ្យល់ក្នុងទីនេះ ជាគំនិតទាក់ទងនឹងការ

កើតឡើងជាគ្រាដំបូង មិនមែនទាក់ទងគ្រាន់តែកើតឡើងប៉ុណ្ណោះឡើយ ។ ពិតហើយ ខ្យល់ដែលចេញទៅក្រៅទាំងនោះ រមែងកើតឡើងក្នុងទីទាំងពួង ផ្ដើមតាំងអំពីផ្ចិតរហូតទៅដល់ចុងច្រមុះនោះឯង នឹងកើតឡើងក្នុងទីណាៗ ក៏រមែងបែកធ្លាយទៅក្នុងទីនោះៗឯង ព្រោះធម៌ទាំងឡាយមិនមានការទៅអំពីទីនោះកាន់ទីដទៃ។ តែសមញ្ញាថា **គតិ** គឺ ការទៅមានប្រាកដ ព្រោះមានការកើតឡើងក្នុងទីដទៃបានតាមសមគួរដល់បច្ច័យ ។ ពាក្យថា **មានបេះដូងជាកណ្ដាលខ្យល់** បានដល់ មានបរិវេណជិតបេះដូង គឺចំណែកដែលនៅលើបេះដូងនោះជាកណ្ដាលខ្យល់ ។ ពាក្យថា **មានច្រមុះជាចុងខ្យល់** គឺស្ថានច្រមុះជាចុងខ្យល់នៃខ្យល់ដែលចេញទៅខាងក្រៅនោះ ព្រោះសមញ្ញាថា ខ្យល់អស្សាសៈនិងបស្សាសៈ ត្រូវមានឋានចុងច្រមុះនោះជាព្រំដែន ។ ពិតហើយ លោកពោលដល់ខ្យល់ដង្ហើមយ៉ាងនេះថា មានចិត្តជាសមុដ្ឋាន ព្រោះរូបដែលមានចិត្តជាសមុដ្ឋានទាំងឡាយ មិនមានការកើតឡើងខាងក្រៅ ។ ព្រោះហេតុនោះ លោកទើបពោលថា សម្រាប់ខ្យល់ដែលចូលទៅខាងក្នុងមានចុងច្រមុះជាដើមខ្យល់ដូច្នេះ ។ ពាក្យបរិយាយថា ចូលទៅ ចេញមក គប្បីជ្រាបថា លោកពោលទុកដោយទាក់ទងនឹងវា ដូចជាចូលទៅ និងចេញមកនោះ ។

ពាក្យថា **ចិត្តដែលដល់នូវភាពរាយមាយ** គឺ ចិត្តដែលចូលដល់នូវការរាយមាយ មានសេចក្ដីថា រសាត់ទៅ មិនតាំងមាំ ។ បទថា **សារទ្ធាយ** ប្រែថា ដើម្បីការរសាត់អណ្ដែត ។ ពាក្យថា **ដើម្បីការញាប់ញ័រ** គឺ ដើម្បីការមនសិការកម្មដ្ឋានឲ្យញាប់ញ័រ ។

ពាក្យថា **វិក្ខេបគតេន ចិត្តេន** ព្រោះចិត្តដែលដល់នូវភាពរាយមាយ ជាតតិយាវិភត្តិក្នុងអត្ថថា ជាហេតុ ឬ ក្នុងអត្ថថា ឥត្ថម្ភូតលក្ខណៈ គឺ ប្រែថា មាន

ចិត្តដែលដល់នូវការរាយមាយក៏បាន ។ បទថា **សារទ្ធា** ប្រែថា មានការអណ្តែត អណ្តូង ។ បទថា **ឥញ្ជិតា** កែជា **ឥញ្ជនកា** គឺមានការញាប់ញ័រ ។ ដែលឈ្មោះ ថា **ផន្ទិតា** គឺ យោងយោងក៏យ៉ាងនោះ គឺ កែជា **ផន្ទនកា** ប្រែថា មានការយោង យោង ។

ពាក្យថា **ក៏មិនគប្បីមនសិការដោយទាក់ទងនឹងដើមខ្យល់ កណ្តាលខ្យល់ និងចុងខ្យល់** ក្នុងសេចក្តីថា មិនគប្បីមនសិការដែលទាក់ទងនឹងការជាប់តាមដើម ខ្យល់ កណ្តាលខ្យល់ និង ចុងខ្យល់ ។ លោកអាចារ្យពោលថា លោកកាលនឹង មនសិការដោយអនុពន្ធនា គឺការជាប់តាមខ្យល់ ក៏គប្បីមនសិការដោយទាក់ទងនឹង ផុសនា និងដោយទាក់ទងនឹងឋបនា ដូច្នេះ ដោយមានគោលដៅណាដើម្បីនឹងបើក ផ្លូវគោលដៅនោះ ទើបពោលថា **គណនានុពន្ធនាវសេន វិយ** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **វិធីមនសិការយ៉ាងផ្សេងទៀតមិនមាន** មានសេចក្តីថា វិធីមនសិការកម្មដ្ឋានដោយទាក់ទងនឹងផុសនា និង ដោយទាក់ទងនឹងឋបនាតាម លំដាប់សុទ្ធ ៗ ដោយមិនវៀរគណនា និង អនុពន្ធនាទេ ។ សួរថា វិធី មនសិការ សូម្បីដោយគណនា វៀរផុសនាចេញ ក៏រមែងមានមិនបានដូចគ្នា , ដូចគ្នានឹងវិធីមនសិការដោយឋបនា វៀរផុសនាចេញ រមែងមានមិនបាន ដូច្នោះ មិនមែនឬ ? ឆ្លើយថា វិធីមនសិការដោយគណនាវៀរផុសនាចេញ រមែងមាន មិនបាន ដូចគ្នានឹងវិធីមនសិការដោយឋបនា វៀរផុសនាចេញក៏មិនបាន ដូច្នេះ ក៏ពិត , សូម្បីយ៉ាងនោះ ព្រះយោគីគប្បីកាន់យកគណនាបាន ដោយភាពជាវិធី ដែលជាប្រធាន ព្រោះភាពជាមូលនៃវិធីមនសិការកម្មដ្ឋាន យ៉ាងណា , សូម្បី អនុពន្ធនា ក៏គប្បីកាន់យកដោយភាពជាវិធីដែលជាប្រធាន ព្រោះភាពជាមូលនៃ

ឋបនាដូច្នោះ ព្រោះវៀរអនុពន្ធនានោះចេញ ឋបនាក៏មានមិនបាន ។ ព្រោះដូច្នោះ សូម្បីកាលផុសនា មានភាពជាវិធីដែលប្លែកផ្សេងទៅម្យ៉ាងទៀត លោកអាចារ្យកាលនឹងកាន់យកចំពោះ គណនានិងអនុពន្ធនាប៉ុណ្ណោះដោយជាវិធីដែលជាប្រធាន ព្រោះភាវៈដែលជាមូល ហើយសម្តែងដល់វិធីមនសិការក្រៅពីនេះ មិនមានភាវៈដែលជាមូលនោះ ទើបពោលថា សេចក្តីពិត វិធីមនសិការដែលទាក់ទងនឹងផុសនា និងឋបនាជាម្យ៉ាងដទៃទៀត ដូចជាវិធីមនសិការដែលទាក់ទងនឹងគណនា ឬ អនុពន្ធនាក៏ទេ ។ សួរថា ប្រសិនបើយ៉ាងនេះ ព្រោះហេតុអ្វី ក្នុងឧទ្ទេស លោកទើបកាន់យកវិធីមនសិការទាំងនោះ ចែកចេញតែមួយខទៅវិញ លោកអាចារ្យពោលឆ្លើយថា ក៏ព្រះយោគីកាលរាប់ខ្យល់នៅត្រង់ស្ថានដែលខ្យល់ប៉ះ ហើយប៉ះទៀតនោះឯង ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ **ដោយពាក្យថា កាលរាប់ខ្យល់នៅត្រង់ស្ថានដែលខ្យល់ប៉ះហើយប៉ះទៀត** នេះ លោកសម្តែងថា **ផុសនា** គឺ ស្ថានដែលខ្យល់ប៉ះ ជាអង្គនៃគណនា គឺ ការរាប់ ព្រោះហេតុនោះ ទើបពោលថា ឈ្មោះថា មនសិការដោយគណនាផង ដោយផុសនាផងដូច្នេះ ។ បទថា **តត្ថេវ** ប្រែថា ត្រង់ស្ថានដែលខ្យល់ប៉ះហើយប៉ះទៀតនោះឯង ។ បទថា **តេ** ( ខ្យល់ទាំងនោះ ) គឺ ខ្យល់ដកដង្ហើមចេញ-ចូល ។

( ចប់ មហាដីកា )

# អនុពន្ធនា – វិធីជាប់តាមខ្យល់

កាលមនសិការដោយវិធីរាប់យ៉ាងនេះហើយ គប្បីមនសិការដោយវិធីជាប់តាម ដូចតទៅ ៖

លើកការរាប់ចោល ហើយប្រកបសតិតាមខ្យល់អស្សាសបស្សាសៈ មិនឲ្យដាច់រយៈ ឈ្មោះថា **អនុពន្ធនា – ជាប់តាម** ក៏ឯការតាមទៅនោះ មិនគប្បីធ្វើដោយវិធីតាមទៅ ( កំណត់ ) ដើមខ្យល់ កណ្តាលខ្យល់ និង ចុងខ្យល់ ព្រោះថា សម្រាប់ខ្យល់ដែលចេញទៅក្រៅ ផ្ចិតជាដើម បេះដូងជាកណ្តាល ច្រមុះជាចុង សម្រាប់ខ្យល់ចូលមកខាងក្នុង ចុងច្រមុះជាដើម បេះដូងជាកណ្តាល ផ្ចិតជាចុង កាលអាទិកម្មិកនោះតាមខ្យល់នោះទៅ ចិត្តដែលវិលវល់ទៅមក និងប្រព្រឹត្តទៅដើម្បីការជ្រួលច្របល់ និង ញាប់ញ័រដោយពិត ដូចលោកពោលទុកក្នុងបាលីបដិសម្ភិទាថា កាលភិក្ខុប្រើសតិតាមខ្យល់អស្សាសបស្សាសៈទៅ ទាំងដើម កណ្តាល និងចុង ក៏នាំឲ្យមានចិត្តវិលវល់ទៅមកនៅខាងក្នុង ទាំងកាយ ទាំងចិត្តរបស់លោក រមែងនឹងជ្រួលច្របល់ ញាប់ញ័រ និង វិលវល់ទៅ កាលភិក្ខុប្រើសតិតាមខ្យល់អស្សាសបស្សាសៈទៅ ទាំងដើម កណ្តាល និង ចុង ក៏នាំឲ្យមានចិត្តធ្លាទៅមកនៅខាងក្នុង ទាំងកាយ ទាំងចិត្តរបស់លោក រមែងនឹងជ្រួលច្របល់ ញាប់ញ័រ និង វិលវល់ដូច្នេះ ព្រោះហេតុនោះ កាលនឹងមនសិការដោយវិធីអនុពន្ធនា កុំគប្បីមនសិការដោយតាមទៅកំណត់ដើម កណ្តាល ចុង ដែលពិតមនសិការដោយវិធីផុសនា និង ឋបនានោះឯង ។

មែនពិត ការមនសិការដោយវិធីផុសនា និង ឋបនាវិធី នឹងមានជាចំណែកមួយផ្សេងទៀត ដូចមនសិការដោយគណនាវិធី និងអនុពន្ធនាក៏ទេ តែថា អ្នកដែល

រាប់ខ្យល់នៅត្រង់ទីដែលខ្យល់ប៉ះនោះឯង ឈ្មោះថា មនសិការដោយគណនាវិធីផង ដោយផុសនាវិធីផង អ្នកដែលលើក ( ឈប់ ) រាប់ហើយ ជាប់តាមខ្យល់អស្សាសបស្សាសៈនោះទៅដោយសតិ និង តាំងចិត្តទុកតាមផ្លូវអប្បនាក្នុងទីដែលខ្យល់ប៉ះត្រូវៗ នោះឯង ក៏ហៅថា មនសិការដោយវិធីអនុពន្ធនាផង ដោយវិធីផុសនាផង ដោយវិធីឋបនាផង សេចក្ដីនេះនោះ បណ្ឌិតគប្បីជ្រាបដោយឧបមាដោយបុរសខ្វិន និង អ្នករក្សាទ្វារ ដែលពោលទុកក្នុងអដ្ឋកថាទាំងឡាយ និងដោយឧបមាដោយរណា ដែលពោលទុកក្នុងបដិសម្ភិទា ។

ក្នុង ៣ ឧបមានោះ នេះជាឧបមាដោយមនុស្សខ្វិន គឺមនុស្សខ្វិនយោលទោង ឲ្យម៉ែកូនដែលជិះទោងជុំគ្នា អង្គុយត្រង់គល់សសរទោងនោះឯង រមែងឃើញចុង ទាំងពីរខាង ទាំងត្រង់កណ្ដាលផងរបស់ក្ដារទោងដែលយោលមក និងទៅដោយលំដាប់ តែមិនបានខ្វល់ខ្វាយនឹងមើលចុងទាំងពីរខាង និងកណ្ដាលរបស់ក្ដារទោង យ៉ាងណាក្ដី ភិក្ខុក៏ដូច្នោះដូចគ្នា ឈរត្រង់គល់សសរដែលជាទីចងចិត្តគឺចុងច្រមុះ ដោយអំណាចនៃសតិ យោលទោង គឺ ខ្យល់អស្សាសបស្សាសៈហើយអង្គុយចុះ ត្រង់និមិត្តនោះឯងដោយសតិ កាលជាប់តាមទៅដោយសតិ តាំងចិត្តទុកមាំត្រង់ទី ខ្យល់ប៉ះនោះនុ៎ះឯង រមែងឃើញ ដើម កណ្ដាល ចុង របស់ខ្យល់អស្សាសបស្សាសៈក្នុងទីដែលវា មក និង ទៅ ប៉ះខ្ទប់តាមលំដាប់ តែមិនខ្វល់ខ្វាយថានឹងមើលវា នេះជាឧបមាដោយមនុស្សខ្វិន ។

ចំណែកសេចក្ដីតទៅនេះ ជាឧបមាដោយមនុស្សរក្សាទ្វារ គឺអ្នករក្សាទ្វារមិនត្រាច់សាកសួរមនុស្សម្នាដែលនៅក្នុងក្រុង និងក្រៅក្រុងថា អ្នកជានរណា ឬលោកមកពីណា ឬថា លោកនឹងទៅណា ឬថា អ្វីនៅក្នុងដៃលោក ព្រោះថា មនុស្សទាំង

នោះមិនមែនជាការៈរបស់គេ គេនឹងសាកសួរតែអ្នកដែលមកដល់ទ្វារចូលប៉ុណ្ណោះ យ៉ាងណាក្តី ខ្យល់ចូលខាងក្នុងក្តី ខ្យល់ចេញទៅក្រៅក្តី មិនជាការៈរបស់ភិក្ខុនេះ ខ្យល់ដែលមកដល់ប្រហោងច្រមុះប៉ុណ្ណោះជាការៈយ៉ាងនោះដូចគ្នាដែរ នេះជាឧបមាដោយអ្នករក្សាទ្វារ ។

ចំណែកឧបមាដោយរណា គប្បីជ្រាបតាំងអំពីដើមទៅ ( គឺតាំងអំពីពាក្យដែលជាឧបមេយ្យទៅ ) ដូច្នេះ ។

ក៏ឯពាក្យតទៅនេះ លោកពោលទុកក្នុងបដិសម្ភិទាមគ្គថា ៖

និមិត្តខ្យល់អស្សាសៈ ខ្យល់បស្សាសៈ មិនបានជាអារម្មណ៍របស់ចិត្តដួង១ តែកាលភិក្ខុមិនដឹងធម៌ ៣ យ៉ាងនេះ ការនាក៏មិនសម្រេច និមិត្តខ្យល់អស្សាសៈ ខ្យល់បស្សាសៈមិនបានជាអារម្មណ៍របស់ចិត្តដួងមួយ តែកាលភិក្ខុដឹងធម៌ ៣ យ៉ាងនេះ ការនារមែងសម្រេច ។

មានអធិប្បាយដូចម្តេច ? មានអធិប្បាយថា ធម៌ ៣ យ៉ាងនេះ មិនបានជាអារម្មណ៍របស់ចិត្តដួងមួយ តែធម៌ ៣ នេះ នឹងជាវត្ថុដែលព្រះយោគីមិនដឹងក៏ទេ ចិត្តសោតក៏មិនបានដល់នូវការរលាស់ទៅ **បធាន** គឺ សេចក្តីព្យាយាមសោត ក៏ប្រាកដ និង ព្រះយោគី ក៏ញុំាងប្រយោគឲ្យសម្រេចធម្មវិសេសបាន ប្រៀបដូចកំណាត់ឈើដែលគេដាក់លើផ្ទៃដីរាបហើយ បុរសគប្បីកាត់វាដោយរណា បុរសនោះតាំងសតិទុកត្រង់ទីដែលធ្មេញរណាប៉ះឈើ មិនមែនដាក់ចិត្តត្រង់ធ្មេញរណាដែលមក ឬទៅនោះឡើយ តែថា ធ្មេញរណាដែលមក ឬទៅ ក៏មិនមែនគេមិនដឹង **បធាន** គឺសេចក្តីព្យាយាមអារឈើសោត ក៏ប្រាកដ និងគេញុំាងប្រយោគ គឺកិរិយាអារឈើឲ្យសម្រេចបានទទួលប្រយោជន៍ដ៏កំពូល យ៉ាងណាក្តី **ឧបនិពន្ធនា**

**និមិត្ត** គឺ ទីជៅសម្រាប់ចងចិត្ត គឺ ត្រង់ប្រមុះ ឬ បបូរមាត់លើ ក៏ដូចកំណាត់ឈើ ដែលគេដាក់ទុកត្រង់ផ្ទៃដីរាប ខ្យល់អស្សាសបស្សាសៈដូចធ្មេញរណា ភិក្ខុអង្គុយតាំងសតិទុកត្រង់ចុងប្រមុះ ឬ មុខនិមិត្ត ( គឺ បបូរមាត់លើ ) មិនដាក់ចិត្តដល់ខ្យល់អស្សាសបស្សាសៈដែលមក ឬ ទៅក៏ដោយ តែខ្យល់អស្សាស-បស្សាសៈដែលមកក្តី ទៅក្តី នឹងជាវត្ថុដែលលោកមិនដឹងក៏ទេ **បធាន** សោតក៏ប្រាកដ និងលោកញុំាងប្រយោគឲ្យសម្រេចធម្មវិសេសបាន ក៏ដូចបុរសនោះ តាំងសតិទុកត្រង់ទីដែលធ្មេញរណាប៉ះឈើ មិនដាក់ចិត្តដល់ធ្មេញរណាមក ឬទៅ តែថា ធ្មេញរណាដែលមក ឬទៅ ក៏មិនមែនគេមិនដឹង , **បធាន** ( គឺសេចក្តីព្យាយាមអារឈើសោត ) ក៏ប្រាកដ និង គេញុំាងប្រយោគ ( គឺ កិរិយាអារឈើឲ្យសម្រេច ) ក៏បានទទួលប្រយោជន៍ដ៏កំពូលដូច្នោះ ។

គប្បីជ្រាបអធិប្បាយនៃពាក្យថា **បធានជាដើម** សួរថា បធានដូចម្តេច ? ឆ្លើយថា ទាំងកាយទាំងចិត្តរបស់ភិក្ខុដែលប្រាកដសេចក្តីព្យាយាមជា ( កម្មនិយៈ ) គួរដល់ ( ការភាវនាដោយសេចក្តីព្យាយាមណា សេចក្តីព្យាយាមដែលជាហេតុគួរដល់ការភាវនានៃកាយ ) និងចិត្តនេះហៅថា **បធាន** ( ពោលយ៉ាងនេះ លោកហៅថា **ផលេនហេតុទស្សន** គឺ សម្តែងហេតុ ដោយផល ) ។

សួរថា ប្រយោគដូចម្តេច ? ឆ្លើយថា ឧបក្កិលេសទាំងឡាយ ភិក្ខុដែលប្រារព្ធសេចក្តីព្យាយាមលះបាន វិតក្កទាំងឡាយរបស់លោករម្ងាប់ទៅ ដោយភាវនា-នុយោគណា ភាវនានុយោគ ដែលជាហេតុលះឧបក្កិលេស រម្ងាប់វិតក្កនោះ ហៅថា ប្រយោគ ។

សួរថា ធម្មវិសេសដូចម្តេច ? ឆ្លើយថា សំយោជនៈទាំងឡាយ ភិក្ខុដែល

ប្រារព្ធសេចក្ដីព្យាយាមលះបាន អនុស័យទាំងឡាយអស់សូន្យទៅ ដោយធម៌ណា ធម៌ដែលជាហេតុលះសំយោជនៈ ជាហេតុអស់អនុស័យនេះ ហៅថា **ធម្មវិសេស** ។

ធម៌ ៣ យ៉ាងនេះ មិនបានជាអារម្មណ៍របស់ចិត្តដួងមួយ តែធម៌ ៣ យ៉ាងនេះ នឹងជាវត្ថុដែលព្រះយោគីមិនដឹងក៏ទេ ចិត្តសោតក៏មិនបានដល់នូវភាពរាយមាយ , **បធាន** គឺសេចក្ដីព្យាយាមសោតក៏ប្រាកដ ព្រះយោគីនោះក៏ញុំាងប្រយោគឲ្យសម្រេចធម្មវិសេស ដោយប្រការដូច្នេះ ។

**អានាបានស្សតិដែលភិក្ខុណាបំពេញល្អហើយ សន្សំធ្វើឲ្យស្ទាត់ដោយលំដាប់តាមដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងទុក ភិក្ខុនោះរមែងញុំាងលោកនេះឲ្យភ្លឺស្វាងដូចព្រះចន្ទផុតចាកពពក បញ្ចេញពន្លឺដូច្នោះឯង ។**

នេះជាឧបមាដោយរណា ការដែលព្រះយោគីមិនត្រូវដាក់ចិត្តទៅតាមខ្យល់ដែលមក និងទៅតែម្យ៉ាងប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបថា ជាប្រយោជន៍ក្នុងសេចក្ដីនេះ ។

សម្រាប់បុគ្គលដែលមនសិការកម្មដ្ឋាននេះ អង្គខ្លះនិមិត្តនឹងកើត និង ឋបនាពោលគឺ អប្បនាដែលប្រដាប់ដោយអង្គឈានដ៏សេស នឹងសម្រេចមិនយឺតយូរឡើយ តែសម្រាប់អង្គខ្លះ កាលសេចក្ដីសោប់សល់ផ្លូវកាយរម្ងាប់ចុះ ដោយអំណាចការរលត់ទៅនៃខ្យល់អស្សាសបស្សាសៈ ដែលគ្រោតគ្រាតដោយលំដាប់ចាប់ពីកាលដែលមនសិការដោយវិធីរាប់ ទាំងកាយទាំងចិត្ត រមែងស្រាល សរីរៈហាក់បីដូចជាដល់នូវអាការអណ្ដែតនៅក្នុងអាកាស បើបុគ្គលមានកាយសោប់សល់ អង្គុយនៅលើគ្រែ ឬតាំងក៏ដោយ គ្រែ តាំងរមែងរង្គើ រមែងលាន់ កម្រាលរមែងទក់ទី តែកាលបុគ្គលមានកាយមិនសោប់សល់ អង្គុយ គ្រែ តាំង ក៏មិនយោគ

មិនលាន់ឡើយ កម្រាលក៏មិនជ្រួញ ក្រែ តាំងដូចជាទន់ ព្រោះអ្វី ? ព្រោះកាយដែលមិនរសាប់រសល់ រមែងស្រាល យ៉ាងណា កាលការរសាប់រសល់ផ្លូវកាយរម្ងាប់ចុះ ដោយអំណាចការរលត់ទៅនៃខ្យល់អស្សាសបស្សាសៈ ដែលគ្រោតគ្រាតដោយលំដាប់ ចាប់អំពីកាលដែលមនសិការដោយវិធីរាប់ ទាំងកាយ ទាំងចិត្តរមែងស្រាល សរីរៈហាក់បីដូចជាដល់នូវអាការអណ្តែតនៅក្នុងអាកាស ដូច្នោះដូចគ្នា កាលខ្យល់អស្សាសបស្សាសៈគ្រោតគ្រាតរលត់ទៅហើយ ចិត្តរបស់ព្រះយោគីនោះក៏នៅមាននិមិត្តនៃខ្យល់អស្សាសបស្សាសៈល្អិត ជាអារម្មណ៍ប្រព្រឹត្តទៅសូម្បីនិមិត្តនោះរលត់ទៅ ចិត្តដូងតៗទៅ ក៏នៅមាននិមិត្តនៃខ្យល់ដែលល្អិត ក្រៃលែងជាងនោះ ជាអារម្មណ៍តទៅនោះ សួរថា ប្រព្រឹត្តទៅដូចម្តេច ? ឆ្លើយថាបណ្ឌិតគប្បីជ្រាបថា ដូចជាបុរសគោះដួងដោយដុំលោហៈ សំឡេងដ៏ខ្លាំងគប្បីកើតឡើងមួយរំពេច ចិត្តរបស់គេគប្បីមានសំឡេងគ្រោតគ្រាតជាអារម្មណ៍ប្រព្រឹត្តទៅកាលសំឡេងគ្រោតគ្រាតរលត់ហើយ ក្រោយនោះទៅ ចិត្តរបស់គេក៏មាននិមិត្តនៃសំឡេងល្អិតជាអារម្មណ៍... សូម្បីកាលនិមិត្តនោះរលត់ ចិត្តដូងតៗទៅរបស់គេក៏នៅមាននិមិត្តនៃសំឡេងល្អិតក្រៃលែងជាងនោះជាអារម្មណ៍តទៅបាន ដូច្នោះ ពិតណាស់ សូម្បីព្រះសារីបុត្រក៏បានពោលសេចក្តីនេះទុកក្នុងបដិសម្ភិទាមគ្គថា “ កាលដួងត្រូវគោះហើយ... សូម្បីយ៉ាងណា ” ដូច្នេះជាដើម សេចក្តីពិស្តារ បណ្ឌិតគប្បីពោលតាមគន្លងបដិសម្ភិទាមគ្គនោះចុះ ។

## លក្ខណៈដែលផ្សេងអំពីកម្មដ្ឋានដទៃ

កម្មដ្ឋាននេះ នឹងដូចជាកម្មដ្ឋានដទៃ ៗ ដែលកាលចម្រើនទៅប្រាកដច្បាស់

ក្រៃលែងឡើងៗទៅក៏ទេ ចំពោះកម្មដ្ឋាននេះ កាលចម្រើនក្រៃលែងឡើងទៅត្រឡប់ដល់នូវភាពល្អិតចុះ រហូតដល់ខ្យល់មិនប្រាកដឡើយ តែកាលកម្មដ្ឋាន គឺ ខ្យល់នោះមិនប្រាកដទៅយ៉ាងនោះ ភិក្ខុនោះក៏កុំងើបក្រោកចាកទីអង្គុយ រលាស់ចម្ពរ័ណ្ឌទៅឡើយ សួរថា នឹងគប្បីធ្វើដូចម្តេចវិញ ? ឆ្លើយថា កុំគប្បីគិតថា នឹងទៅសួរអាចារ្យ ឬយល់ថា ឥឡូវនេះកម្មដ្ឋានរបស់យើងវិនាស ហើយក្រោកទៅព្រោះការផ្លាស់ប្តូរឥរិយាបថទៅ កម្មដ្ឋានក៏ក្លាយជាការថ្មីហើយ ព្រោះដូច្នោះលោកអង្គុយនៅដូចដើមនោះឯង គប្បីនាំខ្យល់មកអំពីកន្លែង គឺ ទីដែលវាប៉ះខ្ទប់ចុះ ។

## ឧបាយនាំខ្យល់ត្រឡប់មកវិញ

តទៅនេះជាឧបាយនាំខ្យល់ត្រឡប់មក ក្នុងពាក្យនោះ ភិក្ខុនោះដឹងភាវៈ គឺ ការមិនប្រាកដនៃកម្មដ្ឋានហើយ គប្បីគិតមើលខ្លួនឯងដូច្នេះថា “ ខ្យល់អស្សាស-បស្សាសៈនេះមាននៅទីណា មិនមាននៅទីណា មានដល់នរណា ឬមិនមានដល់នរណា ” ពេលលោកគិតមើលទៅយ៉ាងនោះ ក៏នឹងជ្រាបបានថា “ ខ្យល់អស្សាសបស្សាសៈ នេះមិនមាននៅក្នុងពោះរបស់មាតា ( ១ ) , មិនមានដល់ពួកអ្នកដែលជ្រមុជចុះក្នុងទឹក ( ១ ) , ដូចគ្នានោះដែរ គឺមិនមានដល់ពួកអ្នកដែលសន្លប់ ( ១ ) , អ្នកស្លាប់ហើយ ( ១ ) , អ្នកចូលចតុត្ថជ្ឈាន ( ១ ) , អ្នកប្រកបដោយរូបភព និងអរូបភព ( ១ ) , អ្នកចូលនិរោធ ( ១ ) ” ដូច្នោះហើយគប្បីដាស់តឿនខ្លួនដោយខ្លួនឯងដូច្នេះថា “ នែបាបណ្ឌិត ខ្លួនអ្នកមិនមែននៅក្នុងពោះរបស់មាតា មិនមែនអ្នកជ្រមុជចុះក្នុងទឹក មិនមែនអ្នកសន្លប់ មិនមែនអ្នកស្លាប់ហើយ មិនមែនអ្នកចូលចតុត្ថជ្ឈាន មិនមែនអ្នកប្រកបដោយរូបភព និង

អរូបកព មិនមែនអ្នកចូលនិរោធ មិនមែនឫ ខ្យល់អស្សាសបស្សាសៈរបស់អ្នក មាននៅពិត តែអ្នកមិនអាចកំណត់បាន ព្រោះភាពដែលអ្នកជាមនុស្សមានបញ្ញាទន់ទេ តអំពីនោះ អ្នកគប្បីតាំងចិត្តទុកតាមទីដែលខ្យល់ប៉ះដោយប្រក្រតី ញ៉ាំងមនសិការឲ្យប្រព្រឹត្តទៅចុះ ក៏ខ្យល់អស្សាសបស្សាសៈ នេះសម្រាប់អ្នកច្រមុះវែង ប៉ះក្ដោងច្រមុះប្រព្រឹត្តទៅ សម្រាប់មនុស្សច្រមុះខ្លី ប៉ះបបូរមាត់លើ ប្រព្រឹត្តទៅ ព្រោះដូច្នោះ លោកគប្បីតាំងទីដៅទុកថា ខ្យល់ប៉ះទីត្រង់នេះ , ពិតណាស់ ព្រះមានព្រះភាគទ្រង់អាស្រ័យអំណាចប្រយោជន៍ គឺ ហេតុនេះឯង ទើបត្រាស់ទុកថា " ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោលអានាបានស្សតិភាវនាដល់បុគ្គលដែលវង្វេងភ្លេចសតិ មិនមានសម្បជញ្ញៈ " ដូច្នេះ ។

ឯកម្មដ្ឋានគ្រប់យ៉ាង រមែងសម្រេចដល់អ្នកមានសតិសម្បជញ្ញៈប៉ុណ្ណោះ ក៏ពិត តែថាកម្មដ្ឋានដទៃអំពីនេះ កាលភិក្ខុមនសិការទៅរឿយៗ កាន់តែឃើញច្បាស់ ចំណែកអានាបានស្សតិកម្មដ្ឋាននេះធ្ងន់ ការភាវនាក៏ធ្ងន់ ជាភូមិមនសិការនៃព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះពុទ្ធបុត្រទាំងឡាយដែលជាមហាបុរសប៉ុណ្ណោះ មិនមែនជារឿងតូចតាច និង មិនមែនការដែលសត្វតូចតាច អាចសម្រេចបាននោះទេ មនសិការទៅដោយប្រការណាៗ ក៏រមែងស្ងប់ និង សុខុមទៅដោយប្រការនោះៗ ព្រោះហេតុនោះ ក្នុងកម្មដ្ឋាននេះចាំបាច់ត្រូវការសតិ និង បញ្ញាចាស់ក្លា ដូចក្នុងពេលដេរសំពត់សាច់ល្អិត សូម្បីម្ជុលក៏ត្រូវប្រើម្ជុលតូច អំបោះជ្នេរសម្រាប់ដេរត្រូវប្រើតូចជាងនោះ យ៉ាងណា ក្នុងពេលចម្រើនកម្មដ្ឋាននេះ ក៏ដូចសំពត់សាច់ល្អិត ចាំបាច់ត្រូវមានទាំងសតិដែលប្រៀបដូចម្ជុល ទាំងបញ្ញាសម្បយុត្តដោយសតិនោះដែលប្រៀបដូចអំបោះជ្នេរ គួបផ្ទុលក៏រឹងមាំដូច្នោះដូចគ្នា ។ ក៏ឯភិក្ខុអ្នកប្រកប

ដោយសតិបញ្ញានោះ កុំគប្បីស្វែងរកខ្យល់អស្សាសបស្សាសៈក្នុងទីដទៃ អំពីទីដែលខ្យល់ប៉ះតាមប្រក្រតី ដូចអ្នកស្រែ ភ្ជួរស្រែ ហើយលែងគោពលិពទ្ទ ( គោបាសម្រាប់ប្រើ ) ធ្វើឲ្យវាបែរមុខទៅកាន់ទីរកស៊ី ហើយគប្បីអង្គុយសម្រាកក្នុងម្លប់ រួចហើយ គោពលិពទ្ទទាំងនោះរបស់អ្នកស្រែនោះ ក៏ចូលក្នុងព្រៃទៅរកស៊ីដោយរហ័ស អ្នកស្រែដែលជាបុគ្គលឆ្លាតប្រាថ្នានឹងចាប់វាមកទឹមភ្ជួរទៀត នឹងមិនតាមស្នាមជើងវាត្រាច់ចូលទៅព្រៃចាប់ទេ តែគេនឹងកាន់ខ្សែ និងជន្ទួញតម្រង់ទៅកំពង់ដែលវាចុះទឹកនោះឯង អង្គុយ ឬដេកចាំនៅទីនោះ គេឃើញគោទាំងនោះដែលវាត្រាច់រកស៊ីពេលថ្ងៃ ហើយចុះ កាន់កំពង់ទឹកត្រាំ និងផឹកទឹក ហើយឡើងមកឈរនៅ ទើបចងដោយខ្សែ ចាក់ដោយជន្ទួញ ដឹកមកទឹមភ្ជួរ ធ្វើការទៀតយ៉ាងណា ភិក្ខុនោះក៏មិនគប្បីស្វែងរក ខ្យល់អស្សាសបស្សាសៈនោះក្នុងទីដទៃ អំពីទីដែលខ្យល់ប៉ះតាមប្រក្រតី តែគប្បីកាន់ខ្សែគឺសតិ និងជន្ទួញគឺបញ្ញា តាំងចិត្តទុកក្នុងទីដែលខ្យល់ប៉ះតាមប្រក្រតី ញុំាងមនសិការឲ្យប្រព្រឹត្តទៅ ដូច្នេះចុះ កាលលោកមនសិការទៅយ៉ាងនោះ ខ្យល់នោះនឹងប្រាកដមិនយូរឡើយ ដូចគោទាំងឡាយប្រាកដខ្លួនត្រង់កំពង់ទឹក ដូច្នោះ ។ តអំពីនោះ លោកគប្បីចងទុកដោយខ្សែ គឺ សតិ ទឹមទុកក្នុងទីត្រង់នោះឯង ចាក់ដោយជន្ទួញ គឺ បញ្ញា ប្រកបកម្មដ្ឋានទុករឿងទៅចុះ កាលលោកប្រកបទៅយ៉ាងនោះ មិនយូរ និមិត្តក៏នឹងប្រាកដ ។

## និមិត្តប្រាកដផ្សេងៗគ្នា

រីឯអាចារ្យពួកខ្លះពោលថា និមិត្តនេះនោះ នឹងដូចគ្នាដល់ព្រះយោគាវចរទាំង

ពួនក៏ទេ តែវាប្រាកដដល់អង្គខ្លះ ដូចជាប៉ុយគក៏មាន ដូចប៉ុយសំឡីក៏មាន ដូចខ្សែខ្យល់ក៏មាន ដែលញុំាងសុខសម្ផស្សឲ្យកើត ។

## ការវិនិច្ឆ័យរបស់អដ្ឋកថា

ក៏និមិត្តនេះ សម្រាប់អង្គខ្លះប្រាកដដូចដួងផ្កាយ ដូចដុំកែវមណី និងដូចដុំគជ់ក៏មាន អង្គខ្លះប្រាកដដូចវត្ថុមានសម្ផស្សគ្រោតគ្រាត ដូចគ្រាប់កប្បាស និងដូចចម្រូងឈើខ្លឹមក៏មាន អង្គខ្លះដូចខ្សែសង្វារវែង ដូចកម្រងផ្កា និងដូចកម្សួលផ្សែងក៏មាន អង្គខ្លះដូចសរសៃពីងពាងដែលសន្ធឹងហើយ ដូចដុំពពក ដូចផ្កាឈូក ដូចកង់រថ ដូចវង់ព្រះចន្ទ និងដូចវង់ព្រះអាទិត្យក៏មាន ក៏ឯកម្មដ្ឋាននេះនោះ តែមួយនោះឯង តែនិមិត្តប្រាកដផ្សេងៗ គ្នា ក៏ព្រោះភាពដែលព្រះយោគាវចរមានសញ្ញាផ្សេងៗ គ្នា ប្រៀបដូចកាលភិក្ខុច្រើនអង្គគង់ស្វាធ្យាយព្រះសូត្រ ( សូត្រមួយ ) ជាមួយគ្នា កាលភិក្ខុមួយអង្គពោល ឬសួរឡើងថា សូត្រនេះប្រាកដដល់លោកទាំងឡាយដូចម្តេច ? ភិក្ខុមួយអង្គក៏ប្រាប់ថា ប្រាកដដល់ខ្ញុំព្រះករុណាដូចខ្សែទឹកធំដែលហូរចុះអំពីភ្នំ មួយរូបទៀតប្រាប់ថា សម្រាប់ខ្ញុំព្រះករុណាដូចជួរព្រៃមួយដែលក្រាស់ដោយដើមឈើជាជួរ មួយអង្គប្រាប់ថា សម្រាប់ខ្ញុំព្រះករុណាដូចដើមឈើដែលពេញទៅដោយផ្លែផ្កា ដល់ព្រមទៅដោយមែកធាង មានម្លប់ត្រជាក់ដែលពិត ព្រះសូត្រនោះក៏សូត្រមួយនោះឯង តែប្រាកដដល់លោកទាំងឡាយផ្សេងគ្នា ព្រោះភាពដែលលោកទាំងឡាយមានសញ្ញាផ្សេងគ្នា ដូច្នោះ ព្រោះកម្មដ្ឋាននេះកើតអំពីសញ្ញា មានសញ្ញាជាហេតុ មានសញ្ញាជាដែនកើត ព្រោះដូច្នោះគប្បីជ្រាបថា រមែងប្រាកដបានផ្សេងៗ គ្នា ព្រោះមានសញ្ញាផ្សេងគ្នា ។

## បញ្ហាក់រឿងធម៌ ៣ ប្រការ

ក៏ក្នុងកម្មដ្ឋាននេះ ចិត្តដែលមានខ្យល់អស្សាសៈជាអារម្មណ៍ ជាចិត្តដួង ១ , ចិត្តដែលមានខ្យល់បស្សាសៈជាអារម្មណ៍ ក៏ជាចិត្តដួងមួយ ចិត្តដែលមាននិមិត្តជាអារម្មណ៍ ក៏ជាចិត្តដួងមួយពិត , ឯធម៌ ៣ ប្រការនេះ របស់បុគ្គលណាមិនមានកម្មដ្ឋានរបស់បុគ្គលនោះ រមែងមិនដល់អប្បនា មិនដល់ឧបចារៈឡើយ តែធម៌ ៣ ប្រការនេះរបស់បុគ្គលណាមានប្រាកដ កម្មដ្ឋានរបស់បុគ្គលនោះឯង រមែងដល់ឧបចារៈផង អប្បនាផង , ពិតណាស់ ពាក្យនេះ លោកពោលទុកក្នុងបដិសម្ភិទាមគ្គថា ៖

**និមិត្តខ្យល់អស្សាសៈ ខ្យល់បស្សាសៈមិនបានជាអារម្មណ៍របស់ចិត្តដួងមួយទេ តែកាលភិក្ខុមិនដឹងធម៌ ៣ យ៉ាងនេះ ភាវនាក៏មិនសម្រេច និមិត្តខ្យល់អស្សាសបស្សាសៈ មិនបានជាអារម្មណ៍របស់ចិត្តដួងមួយទេ តែកាលភិក្ខុដឹងធម៌ ៣ យ៉ាងនេះ ភាវនារមែងសម្រេច ។**

## និមិត្តប្រាកដហើយធ្វើដូចម្ដេច

ព្រះទីឃភាណកាចារ្យទាំងឡាយពោលយ៉ាងនេះមុនថា ក៏កាលនិមិត្តប្រាកដហើយដូច្នេះ ភិក្ខុនោះគប្បីទៅរកអាចារ្យ ហើយជម្រាបថា បពិត្រលោកដ៏ចម្រើន អារម្មណ៍ រូបយ៉ាងនេះប្រាកដដល់ខ្ញុំព្រះករុណា ចំណែកអាចារ្យកុំប្រញាប់ប្រាប់ថា នោះគឺនិមិត្ត ឬថា មិនមែននិមិត្ត គប្បីពោលថា វារមែងយ៉ាងនោះឯង អាវុសោ ( សម្រាប់អ្នកប្រកបភាវនា ) ហើយពោលជម្រុញថា អ្នកចូរមនសិការយ៉ាងនោះរឿយៗចុះ ព្រោះថា កាលអាចារ្យប្រាប់ថា ជានិមិត្ត លោកនឹងផ្អាក បើប្រាប់

ថា មិនមែននិមិត្ត លោកនឹងអស់សង្ឃឹមរាថយ ព្រោះហេតុនោះ ទើបមិនគួរប្រាប់ទាំងពីរយ៉ាង គ្រាន់តែជម្រុញក្នុងការមនសិការប៉ុណ្ណោះ ។

ចំណែកព្រះមជ្ឈិមភាណកាចារ្យទាំងឡាយពោលថា យោគាវចរភិក្ខុនោះជាអ្នកដែលអាចារ្យគួរប្រាប់ត្រង់ថា នេះនិមិត្តហើយ អាវុសោ អ្នកចូរមនសិការកម្មដ្ឋានរឿយ ៗ ចុះ សប្បុរស ។

លំដាប់នោះ យោគាវចរភិក្ខុនោះ គប្បីតាំងចិត្តទុកក្នុងនិមិត្តនោះឯងឲ្យមាំដោយការតាំងភាវនាចិត្តទុកក្នុងបដិភាគនិមិត្ត មានប្រការដូចពោលហើយ , ភាវនារបស់អ្នកនេះ ចាប់ផ្ដើមអំពីកើតបដិភាគនិមិត្តនេះឡើងទៅ ទើបជាភាវនាទាក់ទងដោយវិធីឋបនា សមដូចពាក្យព្រះបុរាណាចារ្យទាំងឡាយពោលទុកថា :-

**ព្រះយោគាវចរអ្នកមានបញ្ញាតាំងចិត្តទុកក្នុងបដិភាគនិមិត្ត ញុំាំងអាការផ្សេងៗក្នុងខ្យល់អស្សាសបស្សាសៈឲ្យអស់ទៅ រមែងចងចិត្តរបស់ខ្លួនទុកឲ្យជាអប្បនាបាន ។**

តាំងអំពីប្រាកដនិមិត្តយ៉ាងនោះទៅនីវរណៈទាំងឡាយក៏ជាទោសដែលលោកសង្កត់បានពិត កិលេសទាំងឡាយស្ងប់រម្ងាប់ទៅ សតិតាំងមាំ ចិត្តតម្កល់មាំដោយឧបចារសមាធិដោយពិត ។

លំដាប់តទៅ និមិត្តនោះ លោកកុំគប្បីដាក់ចិត្តក្នុងពណ៌ កុំគប្បីកំណត់ដោយលក្ខណៈឡើយ តែគប្បីជាអ្នកវៀរអសប្បាយ ៧ មានអាវាសដែលជាអសប្បាយជាដើម ហើយសេពសប្បាយ ៧ មានអាវាសដែលជាសប្បាយជាដើមទាំងនោះឯង រក្សាទុកឲ្យល្អ ដូចព្រះខត្តិយមហេសីរក្សាព្រះគភ៌ដែលកើតអំពីស្ដេចចក្រពត្តិ និង អ្នកស្រែរក្សាស្រែស្រូវសាលី និង ស្រូវដំណើបដូច្នោះ កាលលោក

រក្សានិមិត្តនោះទុកយ៉ាងនេះហើយ គប្បីធ្វើឲ្យដល់នូវភាពចម្រើនដុះដាល ដោយវិធីមានមនសិការរឿយៗ ញុំាងអប្បនាកោសល ១០ ប្រការឲ្យដល់ព្រម ប្រកបដោយសេចក្ដីព្យាយាមឲ្យស្មើទុកចុះ កាលលោកព្យាយាមយ៉ាងនោះ ចតុក្កឈាន ឬបញ្ចកឈានទឹងកើតឡើងក្នុងនិមិត្តនោះ តាមលំដាប់ដូចបានពោលហើយ ក្នុងបឋវីកសិណនោះឯង ។

# វិធីចម្រើនវិបស្សនា

## ( ការកំណត់នាមរូប )

រីឯភិក្ខុដែលមានចតុក្កឈាន ឬ បញ្ចកឈានកើតហើយយ៉ាងនេះ ជាអ្នកប្រាថ្នាទឹងចម្រើនកម្មដ្ឋានដោយវិធី សល្លក្ខណា គឺ វិបស្សនា និងវិវដ្ដនា គឺ មគ្គ ហើយសម្រេចបារិសុទ្ធិ គឺ ផល , ក្នុងអានាបានស្សតិភាវនានេះតទៅ គប្បីធ្វើឈាននោះឯងឲ្យដល់នូវភាពជាវសី ដោយអាការ ៥ ស្ទាត់ជំនាញហើយ កំណត់នាមរូប ផ្ដើមចម្រើនវិបស្សនា ។ សួរថា ផ្ដើមចម្រើនដូចម្ដេច ? ឆ្លើយថា កាលព្រះយោគាវចរ ភិក្ខុនោះចេញចាកសមាបត្តិហើយ រមែងឃើញបានថា ករជកាយនិងចិត្តផងជាសមុទយៈនៃខ្យល់អស្សាសបស្សាសៈទាំងឡាយ ប្រៀបដូចកាលជើងក្រាន ស្នប់របស់ជាងមាសត្រូវសប់ ខ្យល់ដែលអាស្រ័យស្នប់ និង សេចក្ដីព្យាយាមដែលគួរដល់ការនោះរបស់បុរស ( ប្រកបគ្នា ) រមែងចូលចេញបានយ៉ាងណា ខ្យល់អស្សាសបស្សាសៈក៏អាស្រ័យកាយ និងចិត្តប្រកបគ្នា ចូលចេញបាន ក៏យ៉ាងនោះដូចគ្នាដែរ តអំពីនោះទៅ លោករមែងកំណត់ចុះបានថា ខ្យល់អស្សាសបស្សាសៈ និងកាយផង ជារូប , ចិត្ត និង ធម៌ដែលសម្បយុត្តជាមួយ

និងចិត្តនោះផង ជាអរូប នេះជាសេចក្តីសង្ខេបក្នុងការកំណត់នាមរូបនោះ ចំណែកការកំណត់នាមរូបដោយពិស្តារ នឹងមានវចនាខាងមុខ ។

កាលកំណត់នាមរូបបានយ៉ាងនេះហើយ ក៏រកបច្ច័យរបស់នាមរូប កាលរកមើលឃើញហើយ ក៏ឆ្លងសេចក្តីសង្ស័យ ប្រារព្ធការប្រព្រឹត្តទៅនៃនាមរូបក្នុងកាលទាំងឡាយ ៣ ចេញបាន អ្នកឆ្លងសេចក្តីសង្ស័យបានហើយ លើកឡើងកាន់ត្រៃលក្ខណ៍ ដោយពិចារណាជាកលាបៈ លះវិបស្សនូបក្កិលេស ១០ មានឱភាសជាដើម ដែលកើតឡើងក្នុងចំណែកខាងដើមនៃឧទយព្វយញ្ញាណចេញ កំណត់ដឹងបដិបទាញាណដែលផុតចាកឧបក្កិលេសហើយ ថាជា ផ្លូវកើតហើយ ក៏ដល់ភង្គានុបស្សនា ( ឃើញតែការរលត់ ) ហើយក៏នឿយណាយប្រាសចាកតម្រេកក្នុងសង្ខារទាំងពួងដែលប្រាកដដោយភាពជារបស់គួរខ្លាច ព្រោះឃើញតែការរលត់រកចន្លោះមិនបាន ក៏រួចផុតទៅដោយអរិយមគ្គទាំង ៤ តាមលំដាប់ តាំងនៅក្នុងអរហត្តផល ដល់ទីបំផុតនៃបច្ចវេក្ខណញ្ញាណ ជាអគ្គទក្ខិណេយ្យនៃលោក និងទេវលោក ។

ឯការចម្រើនអានាបានស្សតិសមាធិនៃយោគាវចរភិក្ខុនោះ ដែលចាប់យកគណនា គឺ វិធីរាប់ជាខាងដើម មានបដិបស្សនា គឺ បច្ចវេក្ខណៈជាបរិយោសានក៏ត្រូវបញ្ចប់តែត្រឹមនេះឯង នេះជាវណ្ណនាចតុក្កៈទី ១ ( ចប់ ) ដោយអាការទាំងពួង ចំណែកក្នុងចតុក្កៈក្រៅអំពីនេះ ព្រោះមិនចាត់ថា មានន័យនៃការចម្រើនកម្មដ្ឋានមួយផ្នែកទៀត ព្រោះដូច្នោះ អត្ថន័យនៃចតុក្កន័យ ៣ នោះ បណ្ឌិតគប្បីជ្រាបដោយន័យនៃការពណ៌នាអនុបទ ( បទបន្ទាប់សន្សំ ) ចុះ ។

# មហាដីកា

ពាក្យថា ***ប្រកបសតិជាប់តាមទៅ*** មានសេចក្ដីថា ញុំាំងសតិជាប់តាមបណ្ដោយតាមវិធីនៃការរាប់ គឺ សម្លឹងមើលខ្យល់ទាំងនោះ មិនឲ្យដាច់រយៈ ក្នុងឱកាសដែលត្រូវខ្យល់ប៉ះនោះឯង ។ ពាក្យថា ***តាំងចិត្តទុកដោយអំណាចនៃអប្បនា*** គឺ តាំងទុកមាំដោយប្រពៃនូវចិត្តក្នុងនិមិត្តតាមដែលប្រាកដហើយ តាមប្រការដែលអប្បនា គប្បីកើតបាន ។

ក្នុងពាក្យថា ***អនុពន្ធនាយ ច*** ជាដើម មានពាក្យប្រកបសេចក្ដីថា ក៏ហៅថា មនសិការដោយអនុពន្ធនាផង ដោយផុសនាផង ដោយឋបនាផង ។ ពាក្យថា ***អត្ថាធិប្បាយនេះ*** មានសេចក្ដីថា អធិប្បាយ ដែលលោកពោលទុកថា ព្រះយោគីកាលកំពុងរាប់ខ្យល់ត្រង់ស្ថានដែលខ្យល់ប៉ះហើយប៉ះទៀតនោះឯង កាលលើកការរាប់ចេញ ហើយប្រកបសតិតាមខ្យល់ទាំងនោះ ទៅត្រង់ស្ថានដែលខ្យល់ប៉ះហើយប៉ះទៀតនោះឯង ដូច្នេះនេះ អធិប្បាយនេះ គឺ ដូចគ្នា ។ ***កថា*** គឺ ពាក្យពោលណារាប់មិនបាន គឺ កាត់សម្រេចមិនបាន ព្រោះជាពាក្យលើសចំណែក កថានោះឈ្មោះថា ឧបមា ព្រោះអត្ថថា ប្រព្រឹត្តទៅក្នុងទីជិតនៃការរាប់ , ដូចពាក្យថា ដូចគោ ទើបឈ្មោះថា គោព្រៃ ដូច្នោះ ។

បទថា ***បង្គុឡោ*** ប្រែថា មនុស្សខ្វិន ។ មនុស្សខ្វិននោះ ជាអ្នកយោលទោង ។ បទថា ***កីឡតំ*** កែជា ***កីឡន្តានំ*** ប្រែថា អ្នកលេងទោង ។ ពាក្យថា ដល់មាតានិងបុត្រ គឺ ដល់ភរិយា និងកូនរបស់ខ្លួន ។ ពាក្យថា ***ចុងទាំងពីរ*** បានដល់ ចុងទាំងពីរ គឺចុងមុខនៃបន្ទះក្ដារទោងដែលកំពុងមក ចុងក្រោយនៃបន្ទះក្ដារទោងដែលកំពុងទៅ ។ ពាក្យថា ***កណ្ដាល*** គឺ កណ្ដាលនៃបន្ទះក្ដារទោងនោះឯង ។

ពាក្យថា **ឈរត្រង់គល់សសរដែលជាទីចូលទៅចងទុក** មានសេចក្ដីថា ឈ្មោះថា គល់សសរដែលជាទីចូលទៅចងទុក បានដល់ ចុងច្រមុះ ឬ មុខនិមិត្ត ( ទីចំណាំត្រង់បបូរមាត់លើ ) បានដល់ ឈរជិតគល់សសរដែលជាទីចូលទៅចងទុកនោះ ។ ឈរដូចម្ដេច ? ឈរដោយអំណាចនៃសតិ ។ គឺថា ព្រះយោគាវចរកាលធ្វើសតិឲ្យតាំងមាំល្អត្រង់ចុងច្រមុះជាដើមនោះ ក៏ឈ្មោះថា ជាអ្នកឈរនៅក្នុងទីនោះ ព្រោះថា ប្រជុំធម៌ដែលរួមគ្នា បណ្ឌិតគប្បីចង្អុលបង្ហាញបានដោយធម៌ដែលជាចំណែកផ្សំ គឺជាអង្គប្រកប ។ ពាក្យថា **ត្រង់និមិត្ត** បានដល់ និមិត្តត្រង់ចុងច្រមុះជាដើម ។ ពាក្យថា **ប្រើសតិអង្គុយ** គឺ អង្គុយដោយអំណាចនៃសតិ ។ ដូចក្នុងឋានៈដែលគួរនឹងពោលទុក ដោយពាក្យថា គឺថា ព្រះយោគាវចរកាលប្រកបសតិឲ្យតាំងមាំល្អត្រង់ចុងច្រមុះជាដើមនោះ ដូច្នេះជាដើម ។ បទថា **តត្ថ** ប្រែថា ត្រង់ស្ថានដែលខ្យល់ប៉ះហើយប៉ះទៀត ។

ពាក្យថា **មនុស្សទាំងនោះ** បានដល់ ពួកអ្នកដែលនៅខាងក្នុង ខាងក្រៅក្រុង ក៏បណ្ដាពួកមនុស្សទាំងនោះ ពួកមនុស្សដែលនៅក្នុងកណ្ដាប់ដៃ ទើបនឹងមានការសង្គ្រោះបាន ។

ពាក្យថា **តាំងអំពីដើម** គឺ តាំងអំពីសម្ដែងន័យនៃឧបមេយ្យ ។ ក្នុងគាថា ពាក្យថា **និមិត្ត** បានដល់ និមិត្តដែលជាទីចូលទៅចងទុកនៃសតិ ។ បទថា **អនារម្មណមេកចិត្តស្ស** មានសេចក្ដីថា មិនបានជាអារម្មណ៍ គឺ ចិត្ត ១ ដួង មិនមានអារម្មណ៍បានច្រើនអារម្មណ៍ទេ ។ ពាក្យថា **តែកាលភិក្ខុមិនដឹងនូវធម៌ទាំង ៣** មានសេចក្ដីថា កាលភិក្ខុមិនដឹងនូវធម៌ទាំង ៣ ទាំងនេះ គឺ និមិត្ត ១ ខ្យល់ដង្ហើមចូល ១ ខ្យល់ដង្ហើមចេញ ១ ដោយទាក់ទងនឹងការធ្វើឲ្យជាអារម្មណ៍ ។ **ច** ស័ព្ទ

ប្រព្រឹត្តទៅក្នុងអត្ថថា **ព្យតិរេក** ប្រែថា បន្ទាប់ ។ ពាក្យថា **ភាវនា** គឺ អានា-បានស្សតិសមាធិភាវនា ។ បទថា **នបលព្ភតិ** កាត់បទជា **ន ឧបលព្ភតិ** ប្រែថា សម្រេចមិនបាន ។ នេះជាន័យនៃចោទនគាថា ( គាថារំលឹកដែលជាគាថាដំបូង ) ចំណែកបរិហាគាថា គឺ គាថាដោះស្រាយទី ២ មានអត្ថដែលគប្បីដឹងបានដោយងាយហើយ ។

ពាក្យថា គឺដូចម្តេច ជា **កថេតុកម្យតាបុច្ឆា** បំណងនឹងបើកផ្សាយអត្ថនៃគាថាទាំងនោះ ។ និទ្ទេសសម្តែងអត្ថ ព្រមទាំងពាក្យប្រកបបទក្នុងពាក្យថា ធម៌ទាំង ៣ នេះ ជាដើមនេះ មានថា ធម៌ទាំង ៣ មាននិមិត្តជាដើមទាំងនេះ មិនបានជាអារម្មណ៍របស់ចិត្តដូងតែមួយ យ៉ាងណា , តែថា សូម្បីយ៉ាងនោះ ធម៌ទាំង ៣ នេះ គឺ ភិក្ខុមិនដឹងក៏ទេ ឈ្មោះថា គឺភិក្ខុមិនដឹងក៏ទេ យ៉ាងណា , កាលភិក្ខុមានការមិនដឹងធម៌ទាំងនោះហើយ ចិត្តនឹងមិនដល់នូវការរាយមាយបានដូចម្តេច ទាំងបធាន គឺ ការព្យាយាមដែលធ្វើភាវនាឲ្យសម្រេចនឹងប្រាកដបានដូចម្តេច ទាំងប្រយោគ ពោលគឺ ការប្រកបរឿយៗនូវភាវនាដែលគ្របសង្កត់នីវរណៈបាន ក៏នាំមកនូវការតាំងមាំដោយប្រពៃ ព្រះយោគីនឹងគប្បីធ្វើឲ្យសម្រេចបានដូចម្តេច និងសម្រេចគុណវិសេសដែលជាលោកិយ និង លោកុត្តរៈខ្ពស់ឡើងទៅ បានដូចម្តេចដូច្នេះ ។

ឥឡូវនេះ ព្រះសារីបុត្តត្ថេរបំណងនឹងធ្វើន័យនោះឲ្យសម្រេចដោយឧបមាដូចរណា ទើបពោលថា **សេយ្យាថិ** ជាដើម ។ កិរិយាកាត់ដើមឈើដែលប៉ាក់ប៉ើកព្រោះការមានភូមិភាគមិនរាបស្មើ មិនអាចធ្វើបានស្រួល និងកាលបើដូច្នោះ គតិដែលទៅដែលមករបស់ធ្មេញរណា ក៏គប្បីដឹងបានលំបាក ព្រោះហេតុនោះ លោក

ទើបពោលថា លើភូមិភាគដែលរាបស្មើដូច្នេះ ។ ពាក្យថា **ប្រើរណា** គឺ ប្រើរណាខ្នាតតូច ។ ព្រោះហេតុនោះ លោកទើបពោលថា បុរសដូច្នេះ គឺបុរសដែលជាអ្នកប្រើរណា មិនមែនគ្រឿងយន្ត ទើបត្រូវប្រើរណាខ្នាតតូច ។ ពាក្យថា **ត្រង់ធ្មេញរណាដែលប៉ះ** គឺ ត្រង់ធ្មេញរណាដែលប៉ះហើយប៉ះទៀត ។ ដោយពាក្យនោះ លោកសម្តែងដល់បុរសមានសតិចូលទៅតាំងទុកត្រង់កន្លែងដែលធ្មេញរណា ប៉ះហើយប៉ះទៀតនោះឯង ។ ព្រោះហេតុនោះ ទើបពោលថា មិនដាក់ចិត្តត្រង់ធ្មេញរណាដែលមក និងទៅដូច្នេះ ធ្មេញរណាដែលប្រព្រឹត្តទៅត្រង់មុខបុរស ក្នុងវេលាដែលទាញរណាមក ហៅថា **មក** ដែលផ្លាស់ទៅអំពីទីត្រង់នោះ ក្នុងវេលារុញរណាទៅ ហៅថា **ទៅ** ។ តែថា ឈ្មោះថា ធ្មេញរណាដែលមក ឬទៅ នឹងត្រូវគេមិនដឹងក៏ទេ ព្រោះភាវៈដែលមានសតិចូលទៅតាំងទុកត្រង់ធ្មេញរណា ទាំងពួង ( គឺ ទាំងមក និង ទាំងទៅ ) ព្រោះធ្មេញរណាទាំងកំពុងទៅ និង កំពុងមក ដោយមិនប៉ះកន្លែងដែលត្រូវកាត់មិនមាន ។ ពាក្យថា **ទាំងសេចក្តីព្យាយាម** បានដល់ សេចក្តីព្យាយាមក្នុងការកាត់ដើមឈើ ។ ពាក្យថា **ទាំងសេចក្តីព្យាយាម** បានដល់ កិរិយាដែលកាត់ដើមឈើនោះឯង ។ ពាក្យថា **គុណវិសេស** បានដល់ការធ្វើឲ្យដល់ភាពជាច្រើនកំណាត់ និងប្រយោជន៍ផ្សេងៗដែលគប្បីធ្វើឲ្យសម្រេចបានដោយដើមឈើនោះ ។

ពាក្យថា **យថា រុក្ខោ** ជាដើម ជាពាក្យប្រៀបធៀប និងឧបមា ។ សតិឈ្មោះថា **ឧបនិពន្ធនា** ព្រោះអត្ថថា ជាគ្រឿងចូលទៅចងចិត្តទុកក្នុងអារម្មណ៍ ចុងច្រមុះ ឬ រីមបបូរមាត់លើ ហៅថា **ឧបនិពន្ធនានិមិត្ត** ព្រោះអត្ថថា ជានិមិត្ត គឺ ទីចំណាំសម្រាប់ការកំណត់ខ្យល់ដង្ហើមចេញ-ចូលនៃសតិ ដែលមានឈ្មោះថា

ឧបនិពន្ធនានោះ ។ ពាក្យថា **ឯវមេវ** មានសេចក្ដីថា បុរសនោះកាលប្រើរណា អារដើមឈើ សូម្បីមិនដាក់ចិត្តដល់ធ្មេញរណាដែលមក និងទៅ ក៏រមែងដឹងដល់ធ្មេញរណាដែលមក និងទៅបាន ដោយការមានសតិចូលទៅតាំងទុកត្រង់កន្លែងដែលធ្មេញរណាប៉ះហើយប៉ះទៀតនោះឯង និង កាលមិនធ្វើគន្លងរណាឲ្យខុសទៅ ក៏រមែងធ្វើកិច្ចនៃប្រយោជន៍ឲ្យសម្រេចបាន យ៉ាងណា ភិក្ខុអង្គនេះក៏យ៉ាងនោះដូចគ្នា ។ ពាក្យថា **ត្រង់ចុងច្រមុះ ឬ មុខនិមិត្ត** មានសេចក្ដីថា អ្នកមានច្រមុះវែង ក៏ចូលទៅតាំងសតិទុកត្រង់ចុងច្រមុះ អ្នកមានច្រមុះខ្លីក៏ចូលទៅតាំងសតិទុកត្រង់រឹមបបូរមាត់លើ ។ ដែលបានឈ្មោះថា **មុខនិមិត្ត** ព្រោះអត្ថថា ជាហេតុឲ្យចំណាំបាន គឺ កំណត់បានថាជាមុខ គឺ ប្រហោងដាក់របស់បរិភោគ ។

ពាក្យថា **នេះឈ្មោះថា បធាន** មានសេចក្ដីថា លោកសម្ដែងហេតុទុកដោយផលថា ទាំងកាយទាំងចិត្តរបស់ព្រះយោគីដែលប្រារព្ធសេចក្ដីព្យាយាម រមែងជាធម្មជាតិគួរដល់ការងារ គឺ គួរដល់ការងាររបស់ភាវនា ត្រឹមត្រូវចំពោះការងារនៃភាវនាបានដោយសេចក្ដីព្យាយាមជាដំបូងណា សេចក្ដីព្យាយាមនេះ ឈ្មោះថា **បធាន** ។ ពាក្យថា **ឧបក្កិលេសទាំងឡាយ រមែងត្រូវលះបង់ទៅ** មានសេចក្ដីថា នីវរណធម៌ទាំងឡាយដែលជាគ្រឿងសៅហ្មងនៃចិត្ត ក៏ត្រូវលះទៅដោយអំណាចនៃវិក្ខម្ភនប្បហាន ។ ពាក្យថា **វិតក្កទាំងឡាយរមែងស្ងប់ទៅ** មានសេចក្ដីថា ព្រោះហេតុដែលឧបក្កិលេសទាំងឡាយត្រូវលះទៅនោះឯង មិច្ឆាវិតក្កទាំងឡាយមានកាមវិតក្កជាដើម ទើបដល់នូវការស្ងប់ទៅ , ម្យ៉ាងទៀត លោកសម្ដែងការសម្រេចបឋមជ្ឈាន ទុកដោយការលះនីវរណៈណា ក៏ពោលដល់ការសម្រេចនូវទុតិយជ្ឈានជាដើម ដោយការបង្អួលដល់ការស្ងប់ទៅនៃវិតក្កនោះ ។ ពាក្យថា **នេះ**

**ឈ្មោះថា បយោគ** មានសេចក្តីថា ការបំពេញកម្មដ្ឋានដែលជាហេតុនៃការបំពេញឈាននេះ ឈ្មោះថា **បយោគ** ។ ពាក្យថា **សំយោជនៈទាំងឡាយរមែងត្រូវលះទៅ** មានសេចក្តីថា សំយោជនៈទាំង ១០ រមែងត្រូវលះបង់ទៅ ដោយអំណាចសមុច្ឆេទប្បហានតាមលំដាប់មគ្គ ។ ពាក្យថា **អនុស័យទាំងឡាយ ក៏រលត់ទៅ** មានសេចក្តីថា អនុស័យទាំង ៧ ក៏យ៉ាងនោះ គឺជាធម្មជាតិមានចំណែកទៅប្រាសហើយ ដោយមិនមានសេសសល់ សូម្បីការរលត់ដោយការធ្វើឲ្យដល់នូវការមិនកើតឡើងជាធម្មតា ។ ក្នុងប្រការនេះ លោកអាចារ្យបំណងសម្តែងថា ដែលបានឈ្មោះថា ការលះសំយោជនៈ រមែងសម្រេចបានដោយការរលត់ទៅនៃអនុស័យនោះឯង និង កាលសំយោជនៈទាំងឡាយត្រូវលះទៅហើយ សូម្បីអនុស័យដែលដេកត្រាំនៅ ក៏មិនមានដូច្នេះ ទើបពោលថា សំយោជនៈទាំងឡាយរមែងត្រូវលះទៅ អនុស័យទាំងឡាយក៏ត្រូវអស់ទៅ ដូច្នេះ ។ ពាក្យថា **នេះឈ្មោះថាគុណវិសេស** មានសេចក្តីថា គុណវិសេសមានការលះសំយោជនៈបានជាដើមនេះដែលព្រះយោគីអាស្រ័យសមាធិនេះបានតាមលំដាប់ ឈ្មោះថា គុណវិសេសរបស់សមាធិនេះ ។

បទថា **យស្ស** កែជា **យេន** ។ បទថា **អនុបុព្វំ** ប្រែថា តាមលំដាប់ ។ បទថា **បរិចិតា** ប្រែថា សន្សំហើយ ។ សេចក្តីសង្ខេបក្នុងគាថានេះ មានន័យថា អានាបានស្សតិ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្តែងទុកដោយប្រការណា ភិក្ខុអង្គណាសន្សំហើយ ចម្រើនល្អហើយតាមលំដាប់ដោយប្រការនោះៗ ឯង ដោយវិធីការ មានការកំណត់ដឹងនូវខ្យល់វែង និងខ្លីជាដើម ដែលជាហេតុឲ្យបរិបូណ៌បាន គឺពេញប្រៀបដោយប្រការទាំងពួង ព្រោះការបរិបូណ៌នៃវត្ថុ ១៦ ។ ភិក្ខុនោះរមែង

ធ្វើលោក មានខន្ធលោកជាដើមរបស់ខ្លួននេះ ឲ្យភ្លឺស្វាងដោយពន្លឺ គឺ បញ្ញា ។ ដូចអ្វី ? ដូចព្រះចន្ទដែលផុតចាកពពក គឺ ដូចចន្ទិមាដែលជាស្តេចនៃផ្កាយ បានផុតហើយចាកគ្រឿងសៅហ្មង គឺ ពពកដូច្នោះ ។

បទថា **ឥធ** ប្រែថា ក្នុងរឿងឧបមាដោយរណានេះ ។ បទថា **អស្ស យោគ យោគិនោ** បានដល់ ព្រះយោគី ។ ម្យ៉ាងទៀត បទថា **ឥធ** ប្រែថា ក្នុងឋានៈនេះ ។ បទថា **អស្ស** បានដល់ រណាដែលជាឧបមា ។ សេចក្តីថា ការមិនដាក់ចិត្តដោយទាក់ទងនឹងធ្មេញរណាដែលមក និង ទៅ ចាត់ជាកិច្ចដែលបុរសនោះគប្បីប្រកបយ៉ាងណា ត្រឹមតែការមិនដាក់ចិត្តដោយទាក់ទងនឹងខ្យល់អស្សាសៈ និង បស្សាសៈដែលមក និង ទៅប៉ុណ្ណោះ ចាត់ជាកិច្ចដែលព្រះយោគីនោះ គប្បីប្រកប ដូច្នេះ ។

ពាក្យថា **និមិត្ត** បានដល់ បដិភាគនិមិត្ត ។ ពាក្យថា **ដែលប្រដាប់ដោយអង្គឈានដ៏សេស** គឺ អាចារ្យច្រើននាក់ពោលថា ដែលប្រដាប់ដោយអង្គឈានដ៏សេស មានវិតក្កជាដើមដូច្នេះ តែគួរនឹងពោលថា មានវិចារៈជាដើម ព្រោះវិតក្កជាអប្បនាដោយនិប្បរិយាយ ។ ព្រោះថា វិតក្កៈនោះ ទ្រង់បានសម្តែងទុកក្នុងព្រះបាលីថា **អប្បនា ព្យប្បនា** ដូច្នេះ ឬព្រោះវិចារៈជាដើម មានការប្រកបរួមនឹងវិតក្កៈនោះ ព្រោះមានពាក្យពោលដល់ឈានទុកក្នុងអដ្ឋកថាថា ជាអប្បនា និងក្នុងបណ្តាអង្គឈានទាំងឡាយ សមាធិជាតួតាំងមាំ ដូច្នោះ លោកអាចារ្យកាលនឹងសម្តែងសមាធិនោះថា ជាអប្បនា ទើបពោលថា និងឋបនា ពោលគឺអប្បនាដែលប្រដាប់ដោយអង្គឈានដ៏សេស និងសម្រេចបានដូច្នេះ ។ ក្នុងពាក្យថា **កស្សចិ បន គណនាវសេន មនសិការកាលតោបភូតិ** នេះ មានបាឋៈត្រឹមប៉ុណ្ណោះ គឺ

**អនុក្កមតោ ។ បេ ។ បត្តំ វិយ ហោតិ** ដាច់បាត់ទៅ ( បច្ចុប្បន្ននេះបានបញ្ចូល បាឋៈដែលបាត់ទៅនោះ បានគ្រប់គ្រាន់បរិបូណ៌ហើយ ) ។

ចំពោះបុគ្គលខ្លះដែលមានកាយរសាប់រសល់ គ្រែ ឬតាំង ឈ្មោះថា រមែង រង្គើ ក៏ព្រោះការដែលខ្លួនទៅកាន់យកគ្រឿងកម្រាលរោមសត្វជាដើម ។ បទថា **វិកុជ្ជតិ** ប្រែថា រមែងលាន់សំឡេង ។ ក្នុងទីនេះ កម្រាលឈ្មោះថា រមែងជ្រួញ គឺ ត្រង់ទីតនៃថ្នេរជាដើម រមែងមានការទក់ខ្ញីខ្ញុកត្រង់ទីនោះ ។ ព្រោះហេតុអ្វី ព្រោះកាយដែលមានការរសាប់រសល់ រមែងជាធម្មជាតិដែលធ្ងន់ ព្រោះហេតុនោះ ក៏ជាហេតុឲ្យលោកពោលដល់ការរលត់ទៅនៃខ្យល់អស្សាសៈ និងបស្សាសៈដែល គ្រោតគ្រាត ដែលសម្រេចទៅព្រមនឹងការស្ងប់រម្ងាប់បាននូវការរសាប់រសល់នៃ កាយ ហាក់ដូចជាពោលនូវការធ្វើឲ្យរលត់ទៅនៃខ្យល់អស្សាសៈ និង បស្សាសៈ នោះ ឲ្យសម្រេចដោយពាក្យជំទាស់ជាគន្លង ដូច្នោះ ។ ពាក្យថា **ដោយអំណាច ការរលត់ទៅនៃខ្យល់អស្សាសៈ និង បស្សាសៈដែលគ្រោតគ្រាត** ជាពាក្យដែល ធ្វើន័យនោះឲ្យសម្រេច ដោយទាក់ទងនឹងធម៌ដែលប្រព្រឹត្តទៅស្របតាមគ្នា ។ ក្នុង ពាក្យទាំងនោះ ពាក្យថា **កាលការរសាប់រសល់នៃកាយស្ងប់រម្ងាប់ហើយ ដូច្នេះ** មានសេចក្តីថា ភាពជាធម្មជាតិដែលស្រាលជាដើម ស្ងួមប្បីនៃសន្តតិរូបដ៏សេស ឯណា រមែងមាន ព្រោះចិត្តជរូបទាំងឡាយ ជាធម្មជាតិដែលស្រាល ទន់ គួរដល់ ការងារ ភាពជាធម្មជាតិដែលស្រាលនោះ លោកបំណងថា ជាការស្រាលនៃកាយ ក្នុងទីនេះ ។ ភាពជាធម្មជាតិដែលស្រាលជាដើមនៃកាយនេះ ព្រោះហេតុដែលវៀរ ធម្មជាតិដែលស្រាលជាដើមនៃចិត្ត ក៏រមែងមិនមាន ។ ដូច្នោះ លោកទើបពោល ថា ទាំងកាយទាំងចិត្ត គឺជាធម្មជាតិដែលស្រាលដូច្នេះ ។

ពាក្យថា **កាលខ្យល់អស្សាសៈ និង បស្សាសៈដែលគ្រោតគ្រាតរលត់ទៅហើយជាដើម** សូម្បីថា មានន័យដូចបានពោលហើយខាងដើម លោកអាចារ្យក៏នាំមកពោលទៀត ដើម្បីសម្តែងវិធីពិនិត្យវិនិច្ឆ័យកាយសង្ខារដែលដល់នូវអាការដែលនឹងត្រូវស្វែងយល់ ។

ពាក្យថា **នឹងជាការដែលប្រាកដច្បាស់ក្រៃលែងឡើងៗ ទៅ** គឺ នឹងប្រាកដច្បាស់ក្រៃលែងឡើងៗ ទៅតាមកម្លាំងរបស់ភាវនា ។ ពាក្យថា **អំពីស្ថានទី** គឺ អំពីស្ថានទីដែលប៉ះតាមប្រក្រតី បានដល់ អំពីកន្លែងដែលខ្ទួនចូលទៅទ្រទ្រង់ទុកដោយទាក់ទងនឹងទីដែលខ្យល់ប៉ះក្នុងខាងដើម ។

លោកអាចារ្យបំណងបើកផ្លូវទៅព្រមគ្នានូវន័យដែលនឹងត្រូតពិនិត្យ ដោយទាក់ទងនឹងស្ថានទីដែលមានខ្យល់ ឬមិនមាន “ ថា មិនមានក្នុងទីណា ” ដោយទាក់ទងនឹងបុគ្គល “ ថា មិនមានដល់នរណា ” ទើបពោលថា មិនមានក្នុងពោះម៉ែដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ខ្យល់អស្សាសៈ និង បស្សាសៈ រមែងមិនប្រព្រឹត្តទៅដល់អ្នកជ្រមុជទឹក ព្រោះឱកាសត្រូវបិទហើយ យ៉ាងណា រមែងមិនប្រព្រឹត្តទៅក្នុងពោះម៉ែ ព្រោះឱកាសដែលត្រូវបិទហើយដូច្នោះ ។ រមែងមិនប្រព្រឹត្តទៅដល់អ្នកស្លាប់ ព្រោះមិនមានចិត្តដែលជាសមុដ្ឋានយ៉ាងណា ក៏រមែងមិនប្រព្រឹត្តទៅដល់បុគ្គលអ្នកមិនមានសញ្ញា គឺអ្នកដែលត្រូវសន្លប់គ្របសង្កត់ ឬអ្នកដែលកើតនៅក្នុងអសញ្ញីភព ព្រោះមិនមានចិត្តជាសមុដ្ឋាន ដូច្នោះ រមែងមិនប្រព្រឹត្តទៅដល់លោកអ្នកចូលនិរោធសមាបត្តិក៏យ៉ាងនោះដូចគ្នា គឺមិនមានចិត្តដែលជាសមុដ្ឋាន ។ ចំណែកការដែលខ្យល់ទាំងនោះមិនប្រព្រឹត្តទៅដល់បុគ្គលអ្នកចូលចតុត្ថជ្ឈាន ក៏ទាក់ទងដល់ភាពជាធម្មតានោះឯង ដល់អ្នកដែលព្រមព្រៀងដោយ

រូបកព អរូបកព ក៏យ៉ាងនោះ គឺជាធម្មតា ។ ចំណែកអាចារ្យពួកខ្លះពោលដល់ហេតុនៃការមិនប្រព្រឹត្តទៅ ទុកថា ខ្យល់អស្សាសៈ និង បស្សាសៈ រមែងមិនមានដល់អ្នកចូលចតុត្ថជ្ឈាន ព្រោះការដល់នូវភាពល្អិតក្រៃលែងទៅតាមលំដាប់ រមែងមិនមានដល់បុគ្គលដែលព្រមព្រៀងដោយរូបកព ព្រោះភាវៈដែលរូប និង កវឡិក្ខុងរូបកព ជាធម្មជាតិដែលល្អិត ដូច្នេះ , អធិប្បាយថា ខ្យល់ដង្ហើមចូល និងចេញរបស់គេនៅមានប្រាកដ ព្រោះនៅមានចំណែកនៅសល់ ដូច្នេះក៏បាន ព្រោះស្ថានដែលខ្យល់ដង្ហើមចេញ-ចូលកើតឡើងមិនបាន ដែលផុតអំពីស្ថាន ៧ តាមដែលពោលហើយមិនមាន ។ ពាក្យថា **ត្រង់ដែលខ្យល់ប៉ះតាមប្រក្រតី** គឺ ត្រង់កន្លែងដែលខ្យល់ប៉ះតាមប្រក្រតី ។ ពាក្យថា **គប្បីតាំងនិមិត្តចំណាំ** គឺ គប្បីធ្វើសញ្ញាចាំដ៏មាំទាំក្រៃលែងឲ្យប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ការប្រកបសតិឲ្យប្រព្រឹត្តទៅក្នុងខ្យល់ល្អិតត្រង់កន្លែងនោះៗ ។ ព្រោះថា សតិមានសញ្ញាដែលចាំមាំទាំជាសមុដ្ឋាន ។ បទថា **ឥមមេវ** បានដល់ វិធីការធ្វើកាយសង្ខារដែលមិនទាន់ប្រាកដ ឲ្យប្រាកដ ដោយន័យ គឺ ការធ្វើឲ្យប្រាកដតាំងអំពីឫសគល់នេះនោះឯង ។ ពាក្យថា **អំណាចនៃអត្ថ** បានដល់ ហេតុ ។ ពាក្យថា **អត្ថ** បានដល់ ផល ។ អត្ថនោះ រមែងប្រព្រឹត្តទៅដោយអំណាចនៃហេតុណា ហេតុនោះ ឈ្មោះថា **អត្ថវសោ** ។ ពាក្យថា **ដែលវង្វេងសតិ** គឺ ដែលមានសតិវិនាស ។ ពាក្យថា **មិនមានសម្បជញ្ញៈ** គឺ ប្រាសចាកការដឹងខ្លួន អធិប្បាយថា ព្រះយោគីដែលចម្រើនកម្មដ្ឋានប្រាសចាកសតិ និង បញ្ញា ដែលអាចដើម្បីការចូលទៅពិចារណាខ្យល់អស្សាសៈ និងបស្សាសៈដែលមិនប្រាកដតាមលំដាប់ហើយ ចងចាំទុកបាន និង ដឹងបានដោយប្រពៃនោះឯងថា ខ្យល់ទាំងនេះនៅមានប្រាកដដល់យើង ដូច្នេះ ។

ពាក្យពេញថា **ឥតោ អញ្ញំ កម្មដ្ឋានំ** ។ ពាក្យថា **គរុកំ** ប្រែថា ជារបស់ធ្ងន់ ។ អានាបានស្សតិកម្មដ្ឋាននេះមានភាពជារបស់ធ្ងន់នោះ ក៏ព្រោះភាពដែលធ្វើការចម្រើនបានសែនលំបាក ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា លំបាកចម្រើនដូច្នេះ ។ លោកពោលថា ចាំបាច់ត្រូវមានសតិ និង បញ្ញាដ៏មានកម្លាំង គឺ ដែលស្រួចស្រាវ និង ក្លៀវក្លា ដូច្នេះ ដោយការដល់នូវភាវៈដែលស្ងប់ និងល្អិតក្រៃលែងឡើងៗ ទៅ ហើយបំណងសម្តែងថា សូម្បីការធ្វើប្រយោជន៍ឈ្មោះថា តូចតាចឲ្យសម្រេច គប្បីមានបានដោយឧបករណ៍ដែលល្អិតប៉ុណ្ណោះ ដូច្នេះ ទើបពោលថា **ដូចជា** ដូច្នេះជាដើម ។ ឥឡូវនេះ លោកអាចារ្យកាលនឹងសម្តែងឧបាយស្វែងរកខ្យល់អស្សាសៈ និងបស្សាសៈដែលមិនប្រាកដ ទើបពោលថា ក៏ឯភិក្ខុដែលដល់ព្រមដោយសតិ និង បញ្ញាទាំងនោះដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **គោចរមុខេ** កែជា **គោចរាភិមុខេ** ប្រែថា ឲ្យបែរមុខទៅកាន់ទីរកស៊ី ។ បទថា **អនុបទំ** ប្រែថា ស្នាមជើង ។ ពាក្យថា **ត្រាច់ទៅ ( អស់ពេលថ្ងៃ )** គឺ កាន់យកនូវទីដែលដើររកស៊ី ។ ពាក្យថា **ក្នុងទីត្រង់នោះៗ ឯង** គឺ ក្នុងកន្លែងដែលបានដៅទុក ដែលជានិមិត្តក្នុងការចូលទៅចងទុក ( នៃសតិ ) ។ ពាក្យថា **ទឹមទុក** គឺ ទឹមទុកដោយមនសិការ ។ម្យ៉ាងទៀត ពាក្យដែលលោកពោលទុកថា ប្រើចំណង គឺ សតិចងទុកនោះឯង លោកពោលអត្ថន័យរបស់ពាក្យនោះទុកថា បានដល់ ទឹមទុកក្នុងទីត្រង់នោះឯង ដូច្នេះ ។ ព្រោះថា ក្នុងឧបមេយ្យ និងបានស្ថានទីដែលចង និងស្ថានទីដែលទឹម ញែកពីគ្នាក៏ទេ ។

ពាក្យថា **និមិត្ត** បានដល់ ឧគ្គហនិមិត្ត ឬបដិភាគនិមិត្ត ។ ព្រោះថា ក្នុងទីនេះ លោកពោលរួមនិមិត្តទាំង ២ ចូលតែ ១ ។ ពិតហើយ ឧបមា ៣ យ៉ាង មាន

ប៉ុយគជាដើម រមែងប្រើបានក្នុងឧគ្គហនិមិត្ត ឧបមាដ៏សេសរមែងប្រើបាន ក្នុងនិមិត្តទាំង ២ ។ ពាក្យថា **អាចារ្យពួកខ្លះ** បានដល់ អាចារ្យមួយពួក ។

ពាក្យថា **ដូចដួងផ្កាយ** គឺដូចរូបរស្មីនៃផ្កាយ ។ ឧបមាមានដុំកែវមណីជាដើម រមែងប្រើបានក្នុងបដិភាគនិមិត្ត ។ លោកអាចារ្យធ្វើការសាកសួរទុកក្នុងចិត្តថា កម្មដ្ឋានមួយប៉ុណ្ណោះនេះនឹងប្រាកដដោយអាការច្រើនយ៉ាងបានដូចម្តេច ដូច្នេះហើយទើបពោលថា ក៏ឯកម្មដ្ឋានដូចគ្នានេះនោះឯង ដូច្នេះជាដើម ។ ពាក្យថា **ព្រះសូត្រ** បានដល់ ព្រះសូត្រដូចគ្នា ។ ភិក្ខុមួយអង្គសំដៅយកការមិនដាច់ខ្សែ ដោយការៈដែលប្រព្រឹត្តទៅស្ទាត់ជំនាញ និងការមានវិស័យធំ ទើបពោលថា ដូចស៊ីងធំដែលហូរចុះអំពីភ្នំដូច្នោះ ។ ព្រះសូត្រមានលម្អគ្រប់អន្លើ ព្រោះការដល់ព្រមនៃ អត្ថនិងព្យញ្ជនៈ ដូចជាជួរព្រៃដែលចេញផ្កាស្គុសស្គាយគ្រប់មែកធាង គួរចាប់ចិត្តគ្រប់ចំណែក ព្រោះហេតុនោះ ភិក្ខុមួយអង្គទៀត ទើបពោលថា ដូចជួរព្រៃមួយកន្លែងដូច្នេះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ទុកថា ដូចជាគុម្ពឈើក្នុងព្រៃដែលចេញផ្កាស្គុសស្គាយ គ្រប់មែកធាង ដូច្នោះ ។ ព្រះសូត្រដែលមានអនុសន្ធិច្រើន មានភាពល្អិតសុខុម បេយ្យាលមានន័យផ្សេងៗ ជាមុខនៃកម្មដ្ឋានច្រើន ជាវត្ថុដែលអ្នកត្រូវការប្រយោជន៍ គប្បីតម្កល់ទុកដោយគោរព ព្រោះហេតុនោះ ភិក្ខុមួយអង្គទើបពោលថា ដូចដើមឈើដែលមានផ្លែស្អេកស្កះ ។ ល ។ មានម្លប់ត្រជាក់ ដូច្នេះ ។ ពាក្យថា **ព្រោះភាពផ្សេងគ្នានៃសញ្ញា** គឺ ព្រោះការដែលសញ្ញាប្រព្រឹត្តទៅក្នុងកាលមុន តែការប្រាកដនៃនិមិត្តមានបែបផ្សេងៗ គ្នា ។

ពាក្យថា **ធម៌ ៣ យ៉ាងទាំងនេះ** បានដល់ ធម៌ ៣ យ៉ាងទាំងនេះ គឺ ខ្យល់ដង្ហើមចូល ខ្យល់ដង្ហើមចេញ និមិត្ត ។ បទថា **នត្ថិ** បានដល់ មិនមាន គឺ មិន

បានដោយភាពជាវត្ថុគួរមនសិការដោយទាក់ទងជាកម្មដ្ឋាន ។ ពាក្យថា **ន ច ឧបចារំ** អធិប្បាយថា សូម្បីឧបចារៈក៏មិនសម្រេច នឹងពោលថ្វីដល់អប្បនានោះ ។ ពាក្យថា **ចំណែកព្រះយោគីអង្គណា** គប្បីជ្រាបថា សម្ព័ន្ធដល់ធម៌ដែលមានប្រាកដតាមទំនងនៃន័យដែលបានពោលហើយ ។

ឥឡូវនេះ ដើម្បីនឹងធ្វើអត្ថដែលបានពោលហើយនោះឯងឲ្យមាំមួន លោកអាចារ្យទើបនាំយកគាថា មានពាក្យថា **និមិត្តំ** ជាដើម ដែលមកហើយក្នុងឧបមាដោយរណាត្រឡប់មកទៀត ។

ពាក្យថា **កាលនិមិត្តប្រាកដហើយ** គឺ កាលបដិភាគនិមិត្តតាមដែលពោលហើយ ( ប្រាកដហើយ ) ។ ពាក្យថា **ក៏ជាយ៉ាងនេះឯង** គឺ សម្រាប់ព្រះយោគីដែលបំពេញភាវនា ក៏នឹងជាយ៉ាងនេះឯង ។ ព្រោះដូច្នោះ អាចារ្យគួរពោលនឹងព្រះយោគីថា ចូរមនសិការទៅរឿយៗ យ៉ាងនេះចុះ ដូច្នេះ ។ ពាក្យថា **លោកគប្បីឈប់សម្រាកសិន** គឺ លុះគិតថា ដែលបានឈ្មោះថា និមិត្តធ្វើឲ្យកើតបានដោយលំបាក និមិត្តនេះនោះ យើងក៏បានហើយ ណ្ហើយចុះ តពីនេះទៅ ទោះជាយ៉ាងណាយើងនឹងធ្វើគុណវិសេសឲ្យកើតឡើងបាន បើមិនពេលណា ក៏ពេលណាមួយដូច្នេះហើយ ក៏នឹងគប្បីដល់នូវភាពខ្ជិលច្រអូសទៅ ។ ពាក្យថា **នឹងគប្បីអស់សង្ឃឹម រួញរាទៅ** គឺ លុះគិតថា យើងបំពេញភាវនាមកអស់កាលត្រឹមប៉ុណ្ណោះ សូម្បីនិមិត្តក៏នៅមិនទាន់កើត យើងនឹងជាបុគ្គលអស់សង្ឃឹមចំពោះគុណវិសេសហើយ ដូច្នេះហើយ ក៏នឹងគប្បីដល់នូវការរួញរាទៅ ។

អាចារ្យអ្នកជំនាញក្នុងគម្ពីរមជ្ឈិមនិកាយ ធ្វើទុកក្នុងចិត្តថា កាលប្រាប់ថាជានិមិត្តដល់ព្រះយោគីដែលគិតថា យើងនឹងផុតចាកជរាមរណៈបានដោយបដិបទា

នេះ ដូច្នេះហើយ បដិបត្តិនឹងមានការដល់នូវភាពខ្ជិលច្រអូសបានដូចម្ដេច នឹង គប្បីធ្វើឧស្សាហ៍ក្រៃលែងឡើងទៅទៀតប៉ុណ្ណោះ ដូច្នេះហើយ ទើបពោលថា អាចារ្យគួរពោលនឹងព្រះយោគីថា នេះជានិមិត្តហើយលោក ។ល។ អ្នកសប្បុរស ដូច្នេះ ។ បទថា **ឯវំ** ប្រែថា ដោយប្រការដែលពោលហើយ គឺដោយការដែល តាំងភាវនាចិត្តទុកក្នុងបដិភាគនិមិត្តតែម្យ៉ាង ។ ពាក្យថា **ចាប់ផ្ដើមអំពីនេះទៅ** គឺ ចាប់ផ្ដើមអំពីបដិភាគនិមិត្តកើតឡើងទៅ ។ មានអត្ថាធិប្បាយថា ពាក្យដែលលោក ពោលទុកខាងដើមថា ក៏ហៅថា មនសិការដោយអនុពន្ធនាផង ដោយផុសនាផង ដោយឋបនាផង ដូច្នេះណា ក្នុងពាក្យនោះ វៀរចាកអនុពន្ធនា និងផុសនាចោល ភាវនាក៏នឹងមានដោយទាក់ទងនឹងឋបនា ព្រោះហេតុនោះ ព្រះយោគីគប្បីចម្រើន កម្មដ្ឋាន ដោយទាក់ទងនឹងឋបនាតែម្យ៉ាងចុះ ។

អធិប្បាយនេះ បុរាណាចារ្យទាំងឡាយក៏បានពោលទុកហើយដូចគ្នា ព្រោះ ហេតុនោះ លោកអាចារ្យទើបពោលពាក្យជាគាថាថា **និមិត្តេ** ជាដើម , ក្នុងគាថា នោះ ពាក្យថា **ក្នុងនិមិត្ត** បានដល់ ក្នុងបដិភាគនិមិត្ត ។ ពាក្យថា **កាលតាំងចិត្ត ទុក** គឺ កាលតាំងភាវនាចិត្តទុក មានសេចក្ដីថា កាលមនសិការដោយអំណាចនៃ ឋបនា ។ បទថា **នានា ការំ** បានដល់ អាការផ្សេងៗ ដែលលោកពោលទុកយ៉ាង នេះថា **បត្តាភេ វណ្ណា** អាការ ៤ ដូច្នេះ ។ ក៏ពាក្យថា **នានា ការំ** នេះ ជា ឯកវចនៈ មានទំនាក់ទំនងផ្សេង ក៏ជាអាការស្មើដូចគ្នា ។ បទថា **វិភាវយំ** ប្រែថា ធ្វើឲ្យបាត់ទៅ គឺ ឲ្យអន្តរធានទៅ ។ ពិតណាស់ ចាប់ផ្ដើមអំពីនិមិត្តកើតឡើង អាការទាំងនោះ រមែងហាក់ដូចជាអន្តរធានទៅដល់ព្រះយោគីដែលមិនដាក់ចិត្ត ។ ពាក្យថា **ក្នុងខ្យល់ដង្ហើមចេញ-ចូល** មានសេចក្ដីថា អាការផ្សេង ៗ ឯណាក្នុង

ខ្យល់ដង្ហើមចេញ-ចូល ឬ ក្នុងនិមិត្តដែលកើតអំពីខ្យល់ដង្ហើមចេញ-ចូល ធ្វើអាការផ្សេង ៗ នោះឲ្យវិនាសទៅ ។ ពាក្យថា **ក៏រមែងចងចិត្តរបស់ខ្លួនទុកបាន** គឺចូលទៅចងចិត្តរបស់ខ្លួនទុកបាន ដោយឋបនាវិធីនោះឯង មានសេចក្តីថា ធ្វើឲ្យដល់អប្បនាបាន ។ ចំណែកអាចារ្យពួកណាពោលអត្ថន័យទុកថា បទថា **វិភាវយំ** គឺធ្វើឲ្យបើកផ្សារ បានដល់ ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ ដូច្នេះ ពាក្យនោះគប្បីប្រើបានដោយទាក់ទងនឹងការនាក្នុងចំណែកខាងដើម ។ ក៏ក្នុងពាក្យរបស់អាចារ្យទាំងនោះ មានន័យដូចតទៅនេះ ព្រះយោគីដែលជាអ្នកប្រាជ្ញ ព្រោះភាពដែលដល់ព្រមដោយបញ្ញា កាលធ្វើអាការផ្សេងៗ ក្នុងខ្យល់ដង្ហើមចេញ-ចូល ឲ្យបើកផ្សារ គឺ កាលដឹងច្បាស់នូវខ្យល់ដង្ហើមទាំងនោះដោយអាការផ្សេងៗ បានដល់ធ្វើឲ្យជាក់ច្បាស់ ធ្វើឲ្យប្រាកដ ឬថា កាលធ្វើអាការផ្សេងៗ គឺខ្យល់ដង្ហើមដែលគ្រោតគ្រាតៗ ឲ្យរម្ងាប់ ឲ្យស្ងប់ កាលតាំងចិត្តទុកក្នុងនិមិត្តដែលបានក្នុងខ្យល់ដង្ហើមទាំងនោះ ក៏រមែងចងចិត្តរបស់ខ្លួនទុក គឺធ្វើឲ្យដល់អប្បនាបានតាមលំដាប់ដូច្នេះ ។

ពាក្យថា **ដោយពណ៌** គឺដោយពណ៌ដែលប្រាកដ ដូចដែលប្រាកដក្នុងប៉ុយគ ឬ រូបផ្កាយជាដើម ។ ពាក្យថា **ដោយលក្ខណៈ** គឺ ដោយសភាវៈ មានសភាវៈគ្រោតគ្រាតជាដើម ឬដោយលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ។ ក្លាប់សេចក្តីថា គប្បីរក្សានិមិត្តនោះ ។ ឈ្មោះថា ការរក្សានិមិត្ត រមែងមានបានដោយការកំណត់ឧបចារជ្ឈានដែលបានមក ព្រោះនិមិត្តនោះៗឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ធ្វើនិមិត្តនោះឲ្យដល់នូវសេចក្តីចម្រើន ការដុះដាលដោយអំណាចការជាក់ចិត្តរឿយៗ ដូច្នេះ ។

បទថា **ឯត្ថ** ប្រែថា ក្នុងកាយានុបស្សនានេះ ។ ពាក្យថា **ប្រាជ្ញានឹងសម្រេច**

**ដល់បារិសុទ្ធិ** គឺប្រាថ្នានឹងបានសម្រេចបារិសុទ្ធិ និងប្រាថ្នានឹងចូលបារិសុទ្ធិ ប្រាថ្នានឹងចូលផលសមាបត្តិនោះឯង ក្នុងពាក្យនោះគប្បីជ្រាបសេចក្តីថា ប្រាថ្នានឹងសម្រេចបារិសុទ្ធិដោយអំណាចនៃសល្លក្ខណា និង វិវដ្ដនា ប្រាថ្នានឹងចូលបារិសុទ្ធិដោយអំណាចនៃសល្លក្ខណា ។ លោកអាចារ្យបំណងសម្តែងអត្ថន័យដែលលោកពោលទុកដោយសង្ខេបថា ផ្ដើមតាំងវិបស្សនាកំណត់នាមរូបដូច្នេះ ដោយពិស្ដារទើបពោលថា គឺ ដូចម្ដេច ? ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ប្រៀបដូចជាដើម** ជាពាក្យដែលសម្តែងដល់ការៈដែលកាយ និង ចិត្ត ជាហេតុកើតឡើងនៃខ្យល់ដង្ហើមចេញ-ចូល ។ ពាក្យថា **ជើងក្រានរបស់ជាងមាស** គឺ ជើងក្រានរបស់ជាងមាសដែលមានស្នប់សម្រាប់ផ្លុំ ឬ សប់ភ្លើង ។ បទថា **ធម្មានាយ** ប្រែថា កាលកំពុងសប់ មានសេចក្ដីថា ធ្វើឲ្យចាប់យកខ្យល់ ។ បទថា **តជ្ជំ** ប្រែថា ដែលគួរដល់ការនោះ ។ ក្នុងពាក្យថា **ដូច្នោះដូចគ្នានេះ** គប្បីជ្រាបថា ករជកាយប្រៀបបាននឹងជើងក្រានរបស់ជាងមាស ចិត្តប្រៀបបាននឹងការព្យាយាមខ្យល់ដង្ហើមចេញ-ចូល មានចិត្តជាសមុដ្ឋានក៏ពិត តែព្រោះវៀរករជកាយចេញខ្យល់ដង្ហើមទាំងនោះក៏ប្រព្រឹត្តទៅមិនបាន លោកអាចារ្យទើបពោលថា ខ្យល់ដង្ហើមចេញ-ចូល រមែងចេញ-ចូលបាន ព្រោះអាស្រ័យកាយ និងចិត្ត ដូច្នេះ ។

បទថា **តស្ស** ប្រែថា របស់នាមរូបនោះ ។ ពាក្យថា **រមែងស្វែងរកបច្ច័យ** បានដល់ រមែងពិចារណា គឺ កំណត់បច្ច័យ មានអវិជ្ជាជាដើម ដោយន័យថា ព្រោះអវិជ្ជាកើតឡើង រូបទើបកើតឡើងដូច្នេះជាដើម ។ ពាក្យថា **រមែងឆ្លងសេចក្តីសង្ស័យ** បានដល់ រមែងឈានកន្លង គឺ រមែងលះសេចក្តីសង្ស័យ ដែលមានវត្ថុ ១៦ ដែលប្រព្រឹត្តទៅដោយន័យថា ក្នុងអតីតកាលយើងមានហើយឬហ្ន៎ ដូច្នេះ

ជាដើម ។ ការពិចារណាដែលប្រព្រឹត្តទៅដោយន័យថា រូបឯណាមួយដែលជា អតីត អនាគត បច្ចុប្បន្ន រូបនោះទាំងអស់មិនទៀង ដូច្នេះជាដើម ឈ្មោះថា ការពិចារណាកលាបៈ ។ ពាក្យថា **ក្នុងចំណែកខាងដើម** គឺ ក្នុងចំណែកខាងដើមនៃឧទយព្វយានុបស្សនាញាណ ដែលទាក់ទងក្នុងបដិបទាញាណទស្សនវិសុទ្ធិ ។ ពាក្យថា **វិបស្សនូបក្កិលេស ១០ មានឱភាសជាដើមដែលកើតឡើង** បានដល់ វិបស្សនូបក្កិលេស ១០ ទាំងនេះ គឺ **ឱភាស ១ ញាណ ១ បីតិ ១ បស្សទ្ធិ ១ សុខ ១ អធិមោក្ខ ១ បគ្គាហ ១ ឧបេក្ខា ១ ឧបដ្ឋាន ១ និកន្តិ ១** ដូច្នេះ ។ ពាក្យថា **លះបោលការកើត** គឺ ព្រលែងការកើតនៃសង្ខារដែលកាន់យកដោយឧទយព្វយានុបស្សនាញាណចេញ ។ ឈ្មោះថា **សម្រេចភង្គានុបស្សនាញាណ** ក៏ដោយការដែលតាមពិចារណាឃើញចំពោះការរលត់នៃសង្ខារទាំងនោះ ។ ឈ្មោះថា **កាលនឿយណាយ** ក៏ដោយនិព្វិទានុបស្សនាញាណ ដែលមានអាទីនវានុបស្សនាញាណជាខាងដើម ។ កាលប្រាសចាកតម្រេកក្នុងសង្ខារទាំងពួង ដោយមគ្គញ្ញាណដែលកើតឡើងក្នុងលំដាប់នៃគោត្រភូញាណ ដែលកើតឡើងក្នុងទីបំផុតនៃមុញ្ចិតុកម្យតាញាណ បដិសង្ខានុបស្សនាញាណ សង្ខារុបេក្ខាញាណ និងអនុលោមញ្ញាណដែលបានសន្សំហើយ ក៏ឈ្មោះថា រួចផុត ។ ពិតណាស់ ព្រះអរិយបុគ្គលបានពោលថា ប្រាសចាកតម្រេករួចផុតក៏ក្នុងខណៈនៃមគ្គ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា សម្រេចអរិយមគ្គ ៤ បានតាមលំដាប់ដូច្នេះ ។ ឈ្មោះថា បច្ចវេក្ខណញ្ញាណដែលមានប្រភេទ ១៩ ក៏ដោយប្រភេទនៃធម៌ដែលគប្បីពិចារណា ពោលគឺ មគ្គ ផល និព្វាន កិលេសដែលលះហើយ និងកិលេសដែលនៅសល់ ។ ពិតណាស់ ធម៌ដែលគប្បីពិចារណាមានភាពជា

១៩ យ៉ាង ក៏ព្រោះព្រះអរហន្តមិនមានកិលេសដែលនៅសល់ ។ ពាក្យថា **របស់ភិក្ខុនោះ** គឺ របស់ភិក្ខុដែលមានខ្យល់ដង្ហើមចេញ-ចូល ជាកម្មដ្ឋាន ។

ឈ្មោះថា **មិនមានការនាន័យនៃកម្មដ្ឋានជាផ្នែកមួយដទៃទៀត** ព្រោះទ្រង់សម្តែងទុកដោយទាក់ទងនឹងវេទនានុបស្សនា ចិត្តានុបស្សនា និង ធម្មានុបស្សនា របស់ព្រះយោគីដែលសម្រេចឈានដោយអំណាចនៃចតុក្កៈដំបូងហើយ ។ ពាក្យថា អត្ថាធិប្បាយនៃចតុក្កៈទាំងនោះ គឺ នៃចតុក្កៈទាំង ៣ ។

( ចប់ មហាដីកា )

( ចប់ ការអធិប្បាយ ចតុក្កៈ ទី ១ )

# ចតុក្កៈទី ២

ពាក្យថា **បីតិបដិសំវេទី.....** នោះ មានសេចក្ដីថា ភិក្ខុសិក្សាថា យើងនឹងធ្វើបីតិឲ្យជាវត្ថុដែលខ្លួនដឹងច្បាស់ គឺ ធ្វើឲ្យប្រាកដដកដង្ហើមចេញ-ចូល ក្នុងសេចក្ដីនោះមានអធិប្បាយថា បីតិជាវត្ថុដែលភិក្ខុដឹងច្បាស់ដោយអាការ ២ គឺ ដោយអារម្មណ៍ ២ ដោយអសម្មោហៈ ១ ។ សួរថា បីតិជាវត្ថុដែលភិក្ខុដឹងច្បាស់ដោយអារម្មណ៍ដូចម្ដេច ? ឆ្លើយថា ភិក្ខុចូលឈាន ២ ដែលមានបីតិជាអង្គ ( សំដៅដល់ចូលបឋមជ្ឈាន និងទុតិយជ្ឈានដោយលំដាប់ ) ព្រោះបានឈាន ២ នោះ បីតិ គឺ ភិក្ខុនោះដឹងច្បាស់បានដោយអារម្មណ៍ ព្រោះអារម្មណ៍របស់ឈាននោះ ជាវត្ថុដែលលោកដឹងប្រចក្សក្នុងខណៈដែលលោកចូលឈាននោះ ។

សួរថា បីតិជាវត្ថុដែលភិក្ខុដឹងច្បាស់ដោយអសម្មោហៈដូចម្ដេច ? ឆ្លើយថា កាលលោកចូលឈាន ២ ដែលមានបីតិជាអង្គ ចេញហើយក៏ពិចារណាបីតីដែលសម្បយុត្តដោយឈាននោះ ដោយការអស់ទៅវិនាសទៅ បីតិ គឺ លោកដឹងច្បាស់បានដោយអសម្មោហៈ ព្រោះដឹងច្បាស់លក្ខណៈក្នុងខណៈដែលឃើញដោយវិបស្សនាបញ្ញានោះ សមដូចពាក្យដែលលោកពោលទុកក្នុងបដិសម្ភិទាថា ៖

កាលភិក្ខុដឹងនូវភាពមានអារម្មណ៍តែមួយ ការមិនរាយមាយនៃចិត្តដោយអំណាចការដកដង្ហើមចេញវែងជាអារម្មណ៍... សតិរមែងតាំងមាំក្នុងអារម្មណ៍នោះ បីតិនោះ ក៏ជាវត្ថុដែលលោកដឹងបានច្បាស់ដោយសតិនោះ ដោយការដឹងនោះ កាលភិក្ខុដឹងនូវភាពមានអារម្មណ៍តែមួយ ការមិនរសាត់ទៅនៃចិត្ត ដោយអំណាចខ្យល់ដង្ហើមចូលវែងជាអារម្មណ៍... ដោយអំណាចការដកដង្ហើមចេញខ្លីជាអារម្មណ៍

... ដោយអំណាចការដកដង្ហើមចូលវែងជាអារម្មណ៍... ដោយអំណាចភាពជាអ្នកដឹងសព្វកាយទាំងអស់ ដកដង្ហើមចេញ-ចូលជាអារម្មណ៍... ដោយអំណាចភាពជាអ្នករម្ងាប់កាយសង្ខារ ដកដង្ហើមចេញ-ចូលជាអារម្មណ៍ សតិរមែងតាំងមាំនៅក្នុងអារម្មណ៍នោះ បីតិជាវត្ថុដែលលោកដឹងបានច្បាស់ដោយសតិនោះ ដោយការដឹងនោះ កាលភិក្ខុនឹកដញ្ញឹងនូវឈាននោះ បីតិនោះក៏ជាវត្ថុដែលលោកដឹងច្បាស់បានកាលភិក្ខុ ដឹងហើយ... ឃើញហើយ... បច្ចវេក្ខណៈហើយ... អធិដ្ឋានចិត្តហើយ ( គឺ អធិដ្ឋានឈានចិត្តថា នឹងនៅក្នុងឈានអស់វេលាប៉ុណ្ណោះ )... សម្រេចចិត្តដោយសទ្ធាហើយ... ផ្គងសេចក្ដីព្យាយាមហើយ... ញុំាងសតិឲ្យតាំងមាំហើយ... តាំងចិត្តឲ្យពិតប្រាកដហើយ... ដឹងដោយបញ្ញាហើយ... ដឹងក្រៃលែងនូវអភិញ្ញេយ្យធម៌ហើយ... កំណត់ដឹងនូវបរិញ្ញេយ្យធម៌ហើយ... លះនូវបហាតព្វធម៌ហើយ... ចម្រើនភាវេតព្វធម៌ហើយ... ធ្វើឲ្យជាក់ច្បាស់នូវសច្ឆិកាតព្វធម៌ហើយ បីតិនោះ ក៏ជាវត្ថុដែលលោកដឹងបានច្បាស់ បីតិនោះ ជាវត្ថុដែលភិក្ខុដឹងច្បាស់ដោយប្រការដូច្នេះ ។

សូម្បីបទដ៏សេស គឺ **សុខបដិសំវេទី ចិត្តសង្ខារបដិសំវេទី** ក៏គប្បីជ្រាបតាមន័យនេះចុះ តែនេះជាការប្លែកគ្នាបន្តិចបន្តួចក្នុងបទទាំងនោះ គឺ **សុខបដិ-សំវេទិតា** គឺ ភិក្ខុដឹងច្បាស់នូវសុខ គប្បីយល់ថា ទាក់ទងដោយឈាន ៣ ដែលមានសុខជាអង្គ , **ចិត្តសង្ខារបដិសំវេទិតា** គឺ ភាពដែលភិក្ខុដឹងច្បាស់នូវចិត្តសង្ខារ , គប្បីយល់ថា ទាក់ទងដោយឈានទាំង ៤ គឺ ដែលមានវេទនាជាអង្គសុទ្ធ , ខន្ធ ២ មានវេទនាជាដើម ឈ្មោះថា **ចិត្តសង្ខារ** , ក្នុងបទថា **សុខបដិសំវេទី** នោះ លោកខែទុកក្នុងបដិសម្ភិទាថា ពាក្យថា **សុខ** បានដល់ សុខ

២ គឺ កាយិកសុខ ១ ចេតសិកសុខ ១ ដូច្នេះ ដើម្បីសម្ដែងវិបស្សនាភូមិ ។

ពាក្យថា **បស្សម្ភយំ ចិត្តសង្ខារំ** នោះ មានសេចក្ដីថា រម្ងាប់ គឺ រលត់ចិត្តសង្ខារដែលគ្រោតគ្រាត ការរលត់ចិត្តសង្ខារនោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងពេលអធិប្បាយកាយសង្ខារដោយពិស្ដារ ( ផ្សេងគ្នាត្រង់ទីនោះ ជាកាយសង្ខារ ទីនេះជាចិត្តសង្ខារប៉ុណ្ណោះ ) ។ ម្យ៉ាងទៀត ក្នុងបទទាំងនោះ ក្នុងបទបីតិ លោកពោលនូវវេទនាដោយរូបនៃបីតិ , ក្នុងបទសុខ លោកពោលនូវវេទនាដោយរូបរបស់ខ្លួនវា , ក្នុងបទចិត្តសង្ខារ ២ បទ រាប់ថា ពោលវេទនាប្រកបនឹងសញ្ញា ព្រោះបាលីក្នុងបដិសម្ភិទាមគ្គថា **សញ្ញា** និង**វេទនា** ជាចេតសិកធម៌ ( ២ ) នោះ ទាក់ទងនឹងចិត្ត ជាចិត្តសង្ខារដូច្នេះឯង ។

បណ្ឌិតគប្បីជ្រាបថា ចតុក្កៈនេះ ទ្រង់ត្រាស់ដោយន័យនៃវេទនានុបស្សនាដោយប្រការដូច្នេះ ។

## មហាដីកា

បទថា **បីតិបដិសំវេទី** ប្រែថា ដែលមានប្រក្រតីដឹងដោយប្រពៃជាចំណែកៗនូវបីតិនោះ ឬប្រែថា ដឹងដោយប្រពៃជាចំណែកៗ នូវបីតិនោះ ប្រែឲ្យងាយស្ដាប់ថា ដែលធ្វើបីតិឲ្យជាការដែលដឹងច្បាស់ ។ ក្នុងពាក្យថា **បីតិបដិសំវេទី** នោះ ការៈដែលបីតិជាវត្ថុដែលព្រះយោគីដឹងយ៉ាងគោរព ទ្រង់ធ្វើឲ្យយើងជ្រាបបានដោយស័ព្ទថា **សំវេទន** នោះឯងក៏ពិត សូម្បីដូច្នោះ ការដឹងនូវបីតិនោះ ទ្រង់ត្រូវការហើយដោយប្រការណា ដើម្បីសម្ដែងនូវប្រការនោះ ទើបទ្រង់ប្រើស័ព្ទថា **បដិ** មានសេចក្ដីថា ឈ្មោះថា **បដិសំវេទី** ព្រោះអត្ថថា ជាអ្នកដឹងដោយប្រពៃ ជា

ចំណែកៗ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ដោយអាការ ២ ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា **បីតិជាធម្មជាតិដែលព្រះយោគីដឹងច្បាស់ដោយអារម្មណ៍ដូចម្តេច** ជាពាក្យសួរ ។ ពាក្យថា **ព្រះយោគីរមែងចូលឈាន ២ ដែលមានបីតិ** គឺ ព្រះយោគីរមែងចូលឈាន ២ គឺ ឈានទី ១ និងឈានទី ២ ដែលសហគតៈដោយបីតិតាមលំដាប់ ។ បទថា **តស្ស** កែជា **តេន** ។ ព្រោះថា សម្ព័ន្ធដល់បទថា **បដិសំវេទិតា** ហើយបទថា **តស្ស** នេះ ក៏ត្រូវជាឆដ្ឋីវិភត្តិ ក្នុងអត្ថន័យថា ជាកត្តុ ( អ្នកធ្វើ ) ។ បទថា **សមាបត្តិក្ខណេ** ប្រែថា ក្នុងខណៈដែលចូលឈាន ។ ពាក្យថា **ដោយការបានមកនូវឈាន** គឺ ដោយភាពជាអ្នកព្រមព្រៀងដោយឈាន ។ ពាក្យថា **ដោយអារម្មណ៍** គឺ ដោយអារម្មណ៍ជាគន្លង មានសេចក្តីថា បីតិដែលទាក់ទងក្នុងឈានដែលមាននិមិត្តនោះជាអារម្មណ៍ គឺ ព្រះយោគីដឹងច្បាស់ហើយ ក៏ព្រោះអារម្មណ៍ជាវត្ថុដែលលោកដឹងច្បាស់ហើយ , មានអធិប្បាយដូចម្តេច ? មានអធិប្បាយយ៉ាងនេះថា ប្រៀបដូចជាកាលបុរសអ្នកដើរស្វែងរកពស់ បានដឹងច្បាស់ទីអាស្រ័យនៅរបស់ពស់នោះហើយ ក៏ជាអ្នកបានដឹងច្បាស់ហើយ ចាប់មេពស់មួយនោះហើយ ព្រោះការចាប់ពស់ដោយកម្លាំងនៃការរាយមន្តនោះ ជាវត្ថុដែលធ្វើងាយហើយយ៉ាងណា កាលព្រះយោគីបានដឹងច្បាស់នូវអារម្មណ៍ដែលជាទីអាស្រ័យនៃបីតិហើយ គឺ ត្រូវបានដឹងច្បាស់នូវបីតិនោះហើយដូចគ្នា ព្រោះការកំណត់នូវបីតិនោះ ដោយវិសេសលក្ខណៈ និងសាមញ្ញលក្ខណៈ ជាវត្ថុធ្វើបានងាយហើយក៏ដូច្នោះ ដូច្នេះឯង។

គប្បីនាំពាក្យចូលមកភ្ជាប់គ្នាថា សួរថា បីតិជាធម្មជាតិដែលព្រះយោគីដឹង

ច្បាស់ដោយអសម្មោហៈដូចម្ដេច ? ពាក្យថា **ក្នុងខណៈនៃវិបស្សនា** គឺ ក្នុងខណៈឃើញបីតិដែលជាអារម្មណ៍ដោយវិបស្សនាបញ្ញា ដែលដល់នូវភាពចាស់ក្លារហ័សរហួន ។ ពាក្យថា **ដោយការចាក់ធ្លុះលក្ខណៈ** គឺ ដោយការចាក់ធ្លុះវិសេសលក្ខណៈ និងសាមញ្ញលក្ខណៈនៃបីតិ ។ ពិតណាស់ កាលព្រះយោគីដឹងច្បាស់លក្ខណៈដោយវិសេស និង ដោយសាមញ្ញនៃធម៌ណាបានហើយ គឺ បានដឹងច្បាស់ធម៌នោះ ទៅតាមសេចក្ដីពិតហើយនោះឯង ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា បីតិ គឺ ព្រះយោគីនោះដឹងច្បាស់ហើយ ដោយអសម្មោហៈដូច្នេះ ។

ឥឡូវនេះ លោកអាចារ្យបំណងនឹងបើកផ្សារនូវអត្ថន័យនោះ ដោយព្រះបាលីនោះឯង ទើបពោលថា សេចក្ដីនេះសមពិតតាមដែលព្រះសារីបុត្រពោលទុកដូច្នេះជាដើម ។ ក្នុងពាក្យថា **ដោយអំណាចនៃខ្យល់ដង្ហើមចូលវែងជាដើម** ក្នុងព្រះបាលីបដិសម្ភិទាមគ្គនោះ ខ្ញុំព្រះករុណាគួរពោលអធិប្បាយពាក្យណាទុក ពាក្យនោះខ្ញុំព្រះករុណាបានពោលអធិប្បាយទុកក្នុងខាងដើមហើយ ។ តែក្នុងទីនេះព្រះបាលីមកហើយដែលទាក់ទងក្នុងការសម្ដែងភាពជា **សតោការី** គឺ អ្នកមានប្រក្រតីបម្រើនសតិ , ក្នុងទីនេះ មកហើយដោយទាក់ទងនឹងបីតិដែលព្រះយោគីដឹងច្បាស់ហើយ និង ជាអ្នកកំណត់បីតិឲ្យបានដឹងច្បាស់ លោកក៏បានចែកទុកដោយអត្ថហើយនោះឯង ។ តទៅនេះជាន័យសង្ខេបក្នុងសេចក្ដីនេះ ន័យមួយទៀត គឺពាក្យថា **ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង** បានដល់ ដោយអំណាចនៃខ្យល់ដង្ហើមចូលវែងដែលជាអារម្មណ៍ ភ្ជាប់សេចក្ដីថា កាលភិក្ខុនោះកំពុងដឹងច្បាស់នូវបីតិនោះ គឺ លោកដឹងច្បាស់ហើយ ។ ពាក្យថា **កាលភិក្ខុកំពុងដឹងច្បាស់នូវឯកគ្គតានៃចិត្ត** គឺ

ការមិនរាយមាយ គឺ កាលភិក្ខុដឹងច្បាស់នូវឯកគ្គតានៃចិត្តដែលទាក់ទងក្នុងឈាន ដែលបានឈ្មោះថា ការមិនរាយមាយដោយបញ្ញាដែលសម្បយុត្តនឹងឯកគ្គតានោះ ។ ពិតណាស់ បីតិជាធម្មជាតិដែលភិក្ខុដឹងច្បាស់បានដោយអារម្មណ៍ជាគន្លងយ៉ាងណា សូម្បីធម៌ទាំងឡាយដែលសម្បយុត្តនឹងបីតិនោះ ក៏ជាធម្មជាតិដែលភិក្ខុដឹងច្បាស់បានដោយអារម្មណ៍ ជាគន្លងយ៉ាងនោះដូចគ្នានោះឯង ។ ពាក្យថា **សតិ គឺ ជាធម្មជាតិដែលចូលទៅតាំងទុកបានហើយ** មានសេចក្តីថា សតិដែលសម្បយុត្តនឹងឈាន ដែលភិក្ខុនោះ ចូលទៅតាំងទុកត្រង់អារម្មណ៍នោះបានហើយ ដោយអំណាចនៃខ្យល់ដង្ហើមចូលវែង ឈ្មោះថា ជាការចូលទៅតាំងទុកសូម្បីក្នុងឈានដោយអារម្មណ៍ជាគន្លង ។ ពាក្យថា **ដោយសតិនោះជាដើម** មានសេចក្តីថា បីតិនោះដែលមាននិមិត្តនោះជាអារម្មណ៍ គឺ ភិក្ខុដឹងច្បាស់ហើយ ដោយអំណាចនៃអារម្មណ៍នោះ ព្រោះអារម្មណ៍ជាវត្ថុដែលភិក្ខុដឹងច្បាស់ហើយយ៉ាងល្អ ដោយសតិដែលតាំងឡើងយ៉ាងនេះនោះ ដោយញាណតាមដែលពោលហើយនោះ ។ សូម្បីក្នុងពាក្យថា **ដោយអំណាចនៃខ្យល់ដង្ហើមចេញវែងជាដើម** ក៏គប្បីជ្រាបអត្ថន័យដោយន័យនេះឯង ។

លោកអាចារ្យបំណងសម្តែងការដឹងច្បាស់បីតិ ដែលសម្តែងទុកដោយទាក់ទងនឹងចតុក្កៈដំបូងហើយយ៉ាងនេះ ដោយការចែកតាមអារម្មណ៍ និងអសម្មោហៈ ទើបពោលថា កាលភិក្ខុកំពុងនឹកដល់ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **កាលភិក្ខុកំពុងនឹកដល់** គឺ កាលភិក្ខុកំពុងនឹកដល់ឈាន ។ ពាក្យថា **បីតិនោះ** បានដល់ បីតិដែលទាក់ទងក្នុងឈាននោះ ។ ពាក្យថា **កាលភិក្ខុកំពុងដឹង** គឺ កាលភិក្ខុកំពុងដឹងដោយអារម្មណ៍ជាគន្លងក្នុងខណៈដែលចូលឈាន ។ ភ្ជាប់សេចក្តីថា បីតិ

នោះ គឺ លោកដឹងច្បាស់ហើយ ។ ពាក្យថា **កាលភិក្ខុកំពុងឃើញ** គឺ កាលភិក្ខុចេញអំពីឈានហើយឃើញដោយញាណ ដែលជាគ្រឿងឃើញ ។ ពាក្យថា **កាលភិក្ខុកំពុងបច្ចវេក្ខណៈទៅ** គឺ កាលភិក្ខុកំពុងពិចារណាឈាន ។ ពាក្យថា **កាលភិក្ខុកំពុងអធិដ្ឋានចិត្ត** គឺ កាលភិក្ខុអធិដ្ឋានឈានចិត្តថា យើងនឹងជាអ្នកព្រមព្រៀងដោយឈាន ( ចូលឈាន ) តែម្យ៉ាងអស់កាលប៉ុណ្ណោះដូច្នេះ ។ តាមការដែលពោលហើយនេះ គឺ លោកអាចារ្យសម្ដែងការដឹងច្បាស់នូវបីតិជាអារម្មណ៍ ដោយការដឹងច្បាស់នូវឈានជាមុខ ដោយអំណាចនៃវសី ៥ យ៉ាង ។

ឈាន និងវិបស្សនានឹងសម្រេចបានដោយធម៌ពួកណា ឥឡូវនេះ លោកអាចារ្យបំណងសម្ដែងការដឹងច្បាស់នូវបីតិ ដោយទាក់ទងនឹងធម៌ មានសទ្ធាជាដើម ដែលទាក់ទងក្នុងឈាន និងទាក់ទងក្នុងវិបស្សនា និងមគ្គទាំងនោះ ទើបពោលថា កាលភិក្ខុបង្អោនចិត្តជឿដោយសទ្ធាដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **កាលភិក្ខុកំពុងបង្អោនចិត្តជឿ** គឺ កាលភិក្ខុកំពុងជឿ អធិប្បាយថា ដោយទាក់ទងជាមួយសមថៈនិងវិបស្សនា សូម្បីក្នុងពាក្យថា កាលភិក្ខុកំពុងផ្គងសេចក្ដីព្យាយាមជាដើមក៏មានន័យនេះឯង ។ ពាក្យថា **នូវអភិញ្ញេយ្យធម៌** គឺ នូវធម៌ដែលគួរដឹងដោយបញ្ញា ដ៏វិសេសក្រៃលែង ។ ពាក្យថា **កាលភិក្ខុដឹងក្រៃលែង** គឺ កាលភិក្ខុដឹងដោយមគ្គប្បញ្ញា ដែលមានវិបស្សនាបញ្ញាជាខាងដើម ។ ពាក្យថា **កាលភិក្ខុកំណត់ដឹងបរិញ្ញេយ្យធម៌** គឺ កាលភិក្ខុកំណត់ដឹងទុក្ខសច្ច ដោយតីរណ-បរិញ្ញា និងដោយមគ្គប្បញ្ញា ។ ពាក្យថា **កាលភិក្ខុកំពុងលះបង់បហាតព្វធម៌** គឺ កាលភិក្ខុលះសមុទយសច្ច ដោយបហានបរិញ្ញា និង មគ្គប្បញ្ញា ។ ឈ្មោះថា **ភិក្ខុកាលចម្រើនភាវេតព្វធម៌** គឺ ចម្រើនមគ្គសច្ច ធ្វើឲ្យច្បាស់សច្ចិកាតព្វធម៌ គឺ

ធ្វើឲ្យច្បាស់និរោធសច្ច ។ ក៏ក្នុងរឿងនេះ អាចារ្យពួកខ្លះលើកបទថា **អភិញ្ញេយ្យំ** គឺ នូវធម៌ដែលគួរដឹងក្រៃលែងជាដើមទុក ដោយទាក់ទងនឹងបីតិប៉ុណ្ណោះ ពាក្យនោះ មិនត្រឹមត្រូវ ព្រោះលោកបំណងនឹងលើកប្រជុំធម៌ មានឈានជាដើម ហើយដកយកបីតិចេញអំពីប្រជុំធម៌នោះ ។

ម្យ៉ាងទៀត ក្នុងអធិការនេះគប្បីជ្រាបថា ដោយបទថា ដោយអំណាចនៃខ្យល់ដង្ហើមចូលវែងជាដើម គឺ លោកពោលដល់ការដឹងនូវបីតិដោយអារម្មណ៍ ដោយទាក់ទងនឹងចតុក្កៈដំបូង , ក្នុង ៥ បទ មានបទថា កាលភិក្ខុកំពុងនឹកដល់ជាដើម ក៏យ៉ាងនោះដូចគ្នា ។ ចំណែកដោយបទថា កាលភិក្ខុដឹងក្រៃលែងនូវអភិញ្ញេយ្យធម៌ជាដើម គឺ លោកពោលដល់ការដឹងច្បាស់នូវបីតិ ដោយអសម្មោហៈ ។ ដោយបទថា **កាលភិក្ខុបង្អោនចិត្តជឿដោយសទ្ធាជាដើម** គឺ លោកពោលដល់ការដឹងច្បាស់បីតិ សូម្បីដោយប្រការទាំងពួង ព្រោះហេតុនោះ ដោយសង្ខេបគប្បីឃើញថា លោកពោលដល់ការដឹងច្បាស់នូវបីតិ ដោយអារម្មណ៍ ដោយអំណាចសមថៈ ដោយអសម្មោហៈ ដោយអំណាចវិបស្សនា ។ សួរថា ក៏ក្នុងវេទនានុបស្សនានេះ ព្រោះហេតុអ្វី លោកទើបកាន់យកវេទនាដោយបីតិជាសំខាន់ មិនកាន់យកដោយសភាវៈដែលមានប្រាកដ ( ដោយចំពោះទៅវិញ ) ? ឆ្លើយថា លោកកាន់យកវេទនាដោយបីតិជាសំខាន់ មិនកាន់យកដោយសភាវៈដែលមានប្រាកដ ក៏ដើម្បីនឹងចែកវេទនា ដោយអំណាចការចែកភូមិជាដើម ហើយសម្តែងវេទនានុបស្សនាទុកជា ៤ ប្រការ ។ ម្យ៉ាងទៀត ព្រោះបីតិជាធម្មជាតិដែលគ្រោតគ្រាត ព្រះមានព្រះភាគដែលនឹងទ្រង់សម្តែងវេទនាកម្មដ្ឋាន ទើបទ្រង់សម្តែងសុខដែលសម្បយុត្តនឹងបីតិនោះ ទុកដោយបីតិជាសំខាន់ ក៏ដើម្បីកាន់យក

( យល់បាន ) ដោយងាយ ។

ពាក្យថា **សូម្បីបទដ៏សេស ក៏គប្បីជ្រាបតាមន័យនេះដែរ** មានសេចក្តីថា បទថា **សុខបដិសំវេទីចិត្តសង្ខារបដិសំវេទី** ក៏គប្បីជ្រាបដោយអត្ថតាមន័យ ដែលមកក្នុងបទថា **បីតិបដិសំវេទី** នោះឯង ។ ពិតណាស់ បណ្ឌិតអាចនឹងដាក់ បទថា **សុខ** ជាដើម ជំនួសត្រង់បីតីបានដោយន័យថា ភាពជា **សុខបដិសំវេទី** រមែងមានបានដោយអាការ ២ គឺជា **ចិត្តសង្ខារបដិសំវេទី** រមែងមានបានដោយអារម្មណ៍ ដូច្នេះជាដើម ហើយយល់សេចក្តីបានដោយន័យថា ភិក្ខុរមែងចូលឈាន ៣ ឬ ឈាន ៤ ដែលសហគតៈដោយសុខ ដូច្នេះជាដើម ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា ដោយអំណាចនៃឈាន ៣ ដូច្នេះជាដើម ។ ដោយ **អាទិ** សព្ទ ក្នុងបទថា **វេទនាទយោ** គឺ មានវេទនាជាដើម លោកកាន់យកសញ្ញាផង ។ ព្រោះហេតុនោះ ទើបពោលថា ខន្ធ ២ ដូច្នេះ ។ ពាក្យថា **ដើម្បីសម្តែងភូមិរបស់វិបស្សនា** គឺ ដើម្បីសម្តែងភូមិរបស់វិបស្សនា ដោយទាក់ទងនឹងការពិចារណាបកិណ្ណកសង្ខារ លោកពោលថា បទថា **សុខ** បានដល់ សុខ ២ យ៉ាងជាដើម ព្រោះក្នុងសមថៈមិនមានសុខផ្លូវកាយទេ ។ បទថា **សោ** បានដល់ ការរលត់នោះ ដែលលោកពោលទុកដោយបរិយាយថា រម្ងាប់ ។ ដែលបានពោលទុកក្នុងមាតិកា ពោលដោយកាយសង្ខារយ៉ាងពិស្តារហើយ ដោយន័យថា គឺ កាយនិងចិត្តរបស់ភិក្ខុនេះ ក្នុងកាលមុនដែលនៅមិនទាន់បានកំណត់កាន់យកដូច្នេះជាដើម ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលបានពោលហើយនោះចុះៗ មានសេចក្តីផ្សេងគ្នាក្នុងសេចក្តីនេះប៉ុណ្ណោះ គឺ ក្នុងចតុក្កៈទី ១ នោះមកហើយ ដោយទាក់ទងនឹងកាយសង្ខារក្នុងចតុក្កៈទី ២ នេះ មកហើយដោយទាក់ទងនឹងចិត្តសង្ខារដូច្នេះ ។

លោកអាចារ្យ កាលសម្ដែងដោយការចង្អុលដល់ការធ្វើចិត្តសង្ខារ ឲ្យរម្ងាប់យ៉ាងនេះហើយ បំណងសម្ដែងពាក្យដែលគួរពោលផ្សេងៗ ក្នុងចតុក្កៈនេះ ទើបពោលថា ម្យ៉ាងទៀត ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា ក្នុងបទថា **បីតិ** គឺក្នុងចំណែករបស់ពាក្យពោលដែលសម្ដែងទុកដោយពាក្យថា **បីតិបដិសំវេទី** ជាដើម ។ ពាក្យថា **ត្រាស់ដល់វេទនាទុកដោយបីតិជាសំខាន់** គឺ ត្រាស់ដល់វេទនាដែលសម្បយុត្តនឹងបីតិនោះដោយការអាងដល់បីតិ អធិប្បាយថា មិនបានត្រាស់ដល់តួបីតិ ។ ហេតុក្នុងការត្រាស់ដល់វេទនា មិនបានត្រាស់ដល់តួបីតិនោះ ខ្ញុំព្រះករុណា បានពោលហើយក្នុងខាងដើមនោះឯង ។ ពាក្យថា **ក្នុងបទថា ចិត្តសង្ខារទាំងពីរបទ** បានដល់ ក្នុងពីរបទដែលទាក់ទងនឹងចិត្តសង្ខារ គឺបទថា **ចិត្តសង្ខារបដិសំវេទី បស្សម្ភយំ ចិត្តសង្ខារំ** ។ ឈ្មោះថា **ទាក់ទងនឹងចិត្ត** ព្រោះអត្ថថា ទាក់ទងនឹងចិត្ត តាមព្រះពុទ្ធវចនៈដែលថា ព្រោះវិញ្ញាណជាបច្ច័យទើបមាននាមរូប ។ ព្រោះហេតុនោះៗឯង ធម៌ទាំងឡាយ មានសញ្ញានិងវេទនាជាដើម ឈ្មោះថា **ចិត្តសង្ខារ** ព្រោះអត្ថថា ដែលចិត្តតាក់តែងដូច្នេះក៏ពិត តែក្នុងទីនេះ ត្រឹមតែជាប្រការកំណត់ថា ជាចិត្តសង្ខារយ៉ាងណា លោកទើបបំណងយកសញ្ញានិងវេទនាប៉ុណ្ណោះ ព្រោះហេតុនោះ ទើបពោលថា ត្រាស់ដល់វេទនាដែលសម្បយុត្តនឹងសញ្ញា ដូច្នេះ ។

( ចប់ មហាដីកា )

( ចប់ ការអធិប្បាយ ចតុក្កៈ ទី ២ )

# ចតុក្កៈទី ៣

សូម្បី **ចិត្តបដិសំវេទិតា** គឺ ការកំណត់ដឹងចិត្ត ក្នុងចតុក្កៈទី ៣ ក៏គប្បីជ្រាបថា ទាក់ទងដោយឈានទាំង ៤ , ពាក្យថា **អភិប្បមោទយំ ចិត្តំ** នោះមានសេចក្តីថា ភិក្ខុសិក្សាថា យើងនឹងជាអ្នកញ៉ាំងចិត្តឲ្យត្រេកអរក្រៃលែង ឲ្យសប្បាយ ឲ្យអាចហ៊ាន ឲ្យរីករាយ ដកដង្ហើមចេញ-ចូល ការរីករាយក្នុងប្រការនេះរមែងមានដោយអាការ ២ គឺ ដោយអំណាចសមាធិ ១ ដោយអំណាចវិបស្សនា ១ សួរថា រីករាយដោយអំណាចសមាធិដូចម្តេច ? ឆ្លើយថា ភិក្ខុចូលឈាន ២ ដែលមានបីតិជាអង្គ លោកញ៉ាំងចិត្តឲ្យរីករាយ ឲ្យសប្បាយដោយបីតិដែលជាសម្បយុត្តធម៌ក្នុងខណៈដែលកំពុងចូលឈាននោះ យ៉ាងនេះ ហៅថា រីករាយដោយអំណាចសមាធិ ។ សួរថា រីករាយដោយអំណាចវិបស្សនាដូចម្តេច ? ភិក្ខុកាលចូលឈាន ២ ដែលមានបីតិជាអង្គ ចេញហើយ ពិចារណានូវបីតិដែលសម្បយុត្តនឹងឈាន ដោយការអស់ទៅ សូន្យទៅ លោកធ្វើបីតិដែលសម្បយុត្តនឹងឈានជាអារម្មណ៍ ញ៉ាំងចិត្តឲ្យរីករាយ ឲ្យត្រេកអរ ក្នុងខណៈដែលឃើញដោយវិបស្សនានោះ យ៉ាងនេះ ។

អ្នកបដិបត្តិដូច្នេះ ឈ្មោះថា **សិក្សា** ថា យើងនឹងជាអ្នកញ៉ាំងចិត្តឲ្យរីករាយក្រៃលែង ដកដង្ហើមចេញ-ចូល ។

ពាក្យថា **សមាទហំ ចិត្តំ** នោះ មានសេចក្តីថា តម្រង់ចិត្តឲ្យស្មើ គឺតាំងចិត្តឲ្យស្មើក្នុងអារម្មណ៍ដោយអំណាចឈាន មានបឋមជ្ឈានជាដើម ឬម្យ៉ាងវិញទៀត កាលភិក្ខុចូលឈានទាំងនោះ ចេញហើយ ពិចារណាចិត្តដែលសម្បយុត្តនឹងឈាន ដោយការអស់ទៅសូន្យទៅ **ខណិកចិត្តេកគ្គតា** គឺ ការមានអារម្មណ៍តែមួយ នៃ

ចិត្តដែលតាំងនៅមួយជួរខណៈកើតឡើង ព្រោះការឃើញច្បាស់ត្រៃលក្ខណ៍ក្នុងខណៈវិបស្សនា កិច្ចតម្រង់ចិត្តឲ្យស្មើ គឺ តាំងចិត្តឲ្យស្មើក្នុងអារម្មណ៍ សូម្បីដោយអំណាចខណិកចិត្តេកគ្គតា ដែលកើតឡើងយ៉ាងនោះក្តី ហៅថា **សិក្ខា** ថា យើងនឹងតាំងចិត្តឲ្យមាំ ដកដង្ហើមចេញ-ចូល ។

ពាក្យថា **វិមោចយំ ចិត្តំ** នោះ មានសេចក្តីថា កិច្ចរដោះចិត្តចាកនីវរណៈទាំងឡាយដោយបឋមជ្ឈាន រដោះចិត្តចាកវិតក្កវិចារៈដោយទុតិយជ្ឈាន រដោះចិត្តចាកបីតិដោយតតិយជ្ឈាន រដោះចិត្តចាកសុខទុក្ខដោយចតុត្ថជ្ឈាន ឬ ម្យ៉ាងទៀតកិច្ចចូលឈានទាំងនោះ ចេញហើយ ពិចារណាចិត្តដែលសម្បយុត្តនឹងឈានដោយការអស់ទៅសូន្យទៅក្នុងខណៈនៃវិបស្សនានោះ លោកដោះចិត្តចាកនិច្ចសញ្ញាដោយអនិច្ចានុបស្សនា រដោះចិត្តចាកសុខសញ្ញាដោយទុក្ខានុបស្សនា... ចាកអត្តសញ្ញាដោយអនត្តានុបស្សនា... ចាកនន្ទិដោយនិព្វិទានុបស្សនា... ចាករាគៈដោយវិរាគានុបស្សនា... ចាកសមុទយដោយនិរោធានុបស្សនា... ចាកអាទាន គឺការប្រកាន់មាំដោយបដិនិស្សគ្គានុបស្សនា ដកដង្ហើមចេញ-ចូល ព្រោះហេតុនោះទើបហៅថា **សិក្ខា** យើងនឹងរដោះចិត្ត ដកដង្ហើមចេញ-ចូល ។

គប្បីជ្រាបថា ចតុក្កៈនេះ ទ្រង់ត្រាស់ដោយចិត្តានុបស្សនាដោយប្រការដូច្នេះ។

## មហាដីកា

ក្នុងបទថា **ចិត្តបដិសំវេទី** នេះ មានសេចក្តីថា ជាអ្នកធ្វើចិត្តឲ្យមានការដឹងច្បាស់ រមែងដឹងបានដោយអាការ ២ គឺដោយអារម្មណ៍ និងដោយអសម្មោហៈ ។ ដោយអារម្មណ៍ដូចម្តេច ? ពាក្យឆ្លើយទាំងអស់ បណ្ឌិតគប្បីជ្រាបបានដោយន័យ

តាមទំនងនៃន័យដែលបានពោលហើយ ដោយពាក្យថា ព្រះយោគីរមែងចូលឈាន ៤ , ក្នុងខណៈដែលព្រះយោគីនោះចូលឈាន ចិត្តក៏ត្រូវព្រះយោគីនោះដឹងច្បាស់ដោយអារម្មណ៍ ដោយការបានមកនូវឈានដូច្នេះជាដើម ព្រោះហេតុនោះលោកអាចារ្យទើបពោលថា បណ្ឌិតគប្បីជ្រាប **ចិត្តបដិសំវេទី** ដោយអំណាចនៃឈាន ៤ ដូច្នេះ ។ ពាក្យថា **ធ្វើចិត្តឲ្យរីករាយ** គឺ ធ្វើចិត្តដែលសម្បយុត្តនឹងឈានឲ្យរីករាយដោយបីតិដែលប្រកបរួមគ្នា ឬ ធ្វើវិបស្សនាចិត្តដែលប្រព្រឹត្តទៅធ្វើបីតិនោះឲ្យជាអារម្មណ៍ ឲ្យរីករាយដោយបីតិដែលជាអារម្មណ៍នោះ ៗ ឯង ។ បទថា **បមោទេន្តោ** គឺ ឲ្យត្រេកអរជាដើម ក៏ជាពាក្យវេវចនៈរបស់ពាក្យថា **មោទេន្តោ** គឺ ឲ្យរីករាយនោះឯង ព្រោះជាពាក្យបរិយាយរបស់បីតិ ។

ពាក្យថា **ឈ្មោះថា រមែងធ្វើចិត្តឲ្យរីករាយដោយបីតិដែលសម្បយុត្ត** មានសេចក្តីថា កាលចម្រើន គឺ កាលធ្វើឈានចិត្តនោះៗ ឯងឲ្យដល់អាការរីករាយស្រស់ស្រាយ ដោយបីតិក្នុងឈានដែលសម្បយុត្តនឹងឈានចិត្ត ដែលជាបីតិ-សម្ពោជ្ឈង្គដែលមានការផ្អែតជាលក្ខណៈ ដោយអំណាចនៃបច្ច័យ មានសហជា-តប្បច្ច័យជាដើម និងដោយអំណាចនៃឈានប្បច្ច័យ , ក៏ពោលបានថា ឈ្មោះថា ធ្វើឲ្យរីករាយ និង ធ្វើឲ្យត្រេកអរ ។ បទថា **អារម្មណំ កត្វា** មានសេចក្តីថា ព្រះយោគាវចរកាលធ្វើវិបស្សនាចិត្ត ដែលប្រព្រឹត្តទៅ ធ្វើបីតិដែលសម្បយុត្តនឹងឈានដ៏ឧឡារ គឺ ប្រសើរ ឲ្យជាអារម្មណ៍ ឲ្យដល់នូវអាការត្រេកអរ រីករាយដោយបីតិដែលជាអារម្មណ៍នោះ ៗ ឯង ក៏ពោលបានថា ឈ្មោះថា ធ្វើចិត្តឲ្យរីករាយ ឲ្យត្រេកអរ ។

ពាក្យថា **តម្រង់ទុកស្មើ** គឺ តម្រង់ទុកដោយអំណាចនៃអប្បនា ដោយប្រការ

ដែលចិត្តមិនស្រុតចុះ មិនប៉ោងឡើង ព្រោះមិនចូលដល់ធម៌ដែលជាបក្ខពួកនៃការរួញរា និងធម៌ដែលជាបក្ខពួកនៃការរាយមាយ សូម្បីត្រឹមបន្តិចបន្តួចដោយប្រការដែលចិត្តមិនប្រាសចាកការស្ងប់ ព្រោះការធ្វើឥន្ទ្រិយទាំងឡាយឲ្យដំណើរទៅដោយភាពស្មើគ្នាបាន ឬ ដោយប្រការដែលចិត្តត្រូវតាំងនៅបានដោយប្រពៃ ព្រោះដល់នូវការមិនញាប់ញ័រ ហេតុ ព្រោះសមាធិដល់នូវភាពខ្ពង់ខ្ពស់នោះឯង ។ ពាក្យថា **ដោយការចាក់ធ្លុះលក្ខណៈ** គឺ ដោយការចាក់ធ្លុះ បានដល់ ការដឹងលក្ខណៈនីមួយៗ នូវលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ។ ពាក្យថា **ខណិកចិត្តេកគ្គតា** បានដល់ សមាធិដែលមានការតាំងនៅបានជាខណៈៗ ។ ពិតណាស់ សមាធិនោះកាលប្រព្រឹត្តទៅមិនដាច់ខ្សែក្នុងអារម្មណ៍ ដោយអាការណាមួយ មិនត្រូវធម៌ដែលជាបដិបក្ខគ្របសង្កត់ ក៏ដូចជាដល់អប្បនា រមែងតាំងចិត្តទុកឲ្យអស់ការញាប់ញ័រៗ ព្រោះហេតុនោះ លោកទើបពោលថា កាលធ្វើចិត្តឲ្យតាំងមាំស្មើ ដែលកើតឡើងយ៉ាងនេះដូច្នេះជាដើម ។

ពាក្យថា **រដោះចិត្ត** គឺ ធ្វើឲ្យស្ងប់ទៅដោយអំណាចនៃវិក្ខម្ភនវិមុត្តិ មានសេចក្តីថា លះនីវរណៈទាំងឡាយតែម្យ៉ាងបាន ។ ពាក្យថា **ក្នុងខណៈនៃវិបស្សនា** គឺ ក្នុងខណៈនៃភង្គានុបស្សនាញាណ ។ ពិតណាស់ ខាងចុងបំផុត ដោយភាពជារបស់មិនទៀងឈ្មោះថា **ភង្គ** គឺ ការបែកធ្លាយ ព្រោះដូច្នោះ ព្រះយោគាវចរដែលតាមពិចារណាឃើញភង្គៈ ដោយភង្គានុបស្សនាញាណនោះ រមែងឃើញសង្ខារទាំងពួងថាមិនទៀងដោយមានចិត្តជាមុខ មិនមែនឃើញថា ទៀង ។ ព្រោះវត្ថុដែលមិនទៀងជាទុក្ខ និងព្រោះវត្ថុដែលជាទុក្ខ ជាអនត្តា ទើបតាមឃើញសង្ខារនោះៗ ឯងថាជាទុក្ខ មិនមែនតាមឃើញថាជាសុខ ។ រមែងតាមឃើញថាជាអនត្តា

មិនមែនតាមឃើញថាជាអត្តា ។ តែព្រោះហេតុដែលវត្ថុណាមិនទៀង ជាទុក្ខ ជាអនត្តា វត្ថុនោះមិនមែនវត្ថុដែលគួរត្រេកត្រអាល និងវត្ថុណាមិនមែនវត្ថុដែលគួរត្រេកត្រអាល វត្ថុនោះក៏មិនមែនជាវត្ថុដែលគួររីករាយ ។ ដូច្នោះ កាលព្រះយោគាវចរបានឃើញសង្ខារថា មិនទៀង ជាទុក្ខ ជាអនត្តាហើយ តាមគន្លងនៃការឃើញកង្គ: ព្រះយោគាវចរក៏រមែងនឿយណាយក្នុងសង្ខារនោះ មិនមែនភ្ញើតភ្ញើន មិនត្រេកត្រអាល មិនរីករាយ ។ ព្រះយោគាវចរនោះ កាលនឿយណាយប្រាសចាកតម្រេកយ៉ាងនេះ ក៏រមែងធ្វើរាគៈឲ្យរលត់ទៅ មិនមែនធ្វើឲ្យកើតឡើងដោយលោកិយញ្ញាណនោះ ៗ ឯងមុន , មានសេចក្ដីថា មិនសាងហេតុកើតឡើងនៃសង្ខារនេះ ។ ន័យម្យ៉ាងទៀត មានន័យថា ព្រះយោគាវចរដែលប្រាសចាកតម្រេកត្រេកអរហើយ យ៉ាងនេះនោះ រមែងធ្វើសង្ខារដែលនៅមិនទាន់ឃើញឲ្យរលត់ទៅ ដោយញាណរបស់ខ្លួន ដូចជាសង្ខារដែលបានឃើញហើយ មិនមែនធ្វើឲ្យកើតឡើង , គឺ រមែងដាក់ចិត្តចំពោះការរលត់របស់សង្ខារនេះប៉ុណ្ណោះ មិនមែនដាក់ចិត្តចំពោះការកើតឡើង ។ ព្រះយោគីដែលបដិបត្តិបានយ៉ាងនេះនោះ ឈ្មោះថា រមែងលះបង់ មិនមែនប្រកាន់មាំ ។ មានអធិប្បាយដូចម្ដេច អធិប្បាយថា បញ្ញាដែលតាមពិចារណាឃើញថា មិនទៀងជាដើមនេះ លោកហៅថា **បរិច្ចាគបដិនិស្សគ្គ** និង **បក្ខន្ទនបដិនិស្សគ្គ** ព្រោះលះបង់កិលេសទាំងឡាយ ព្រមទាំងខន្ធ និងអភិសង្ខារទាំងឡាយ ព្រោះការឃើញទោសនៃសង្ខតធម៌ ក៏ស្ទុះទៅ ដោយការៈដែលបង្អោនចិត្តទៅកាន់ព្រះនិព្វានដែលបដិបក្ខនឹងសង្ខតធម៌នោះ ។ ព្រោះដូច្នោះ ព្រះយោគាវចរដែលប្រកបព្រមដោយបញ្ញា ដែលតាមពិចារណាឃើញថា មិនទៀង ជាដើមនោះ ទើបឈ្មោះថា

រមែងលះបង់កិលេសទាំងឡាយ និងស្ទុះទៅក្នុងព្រះនិព្វាន តាមន័យដែលបាន ពោលហើយ ។ ព្រោះហេតុនោះ លោកអាចារ្យទើបបានពោលថា ក្នុងខណៈនៃ វិបស្សនា ព្រះយោគាវចរនោះ រដោះចិត្ត គឺ ធ្វើឲ្យផុតចាកនិច្ចសញ្ញា ដោយ អនិច្ចានុបស្សនា ។ ល ។ រដោះចិត្ត គឺ ធ្វើឲ្យផុតចាកអាទាន ដោយបដិនិ-ស្សគ្គានុបស្សនា ដកដង្ហើមចេញ-ចូល ដូច្នេះ ។

ក្នុងពាក្យទាំងនោះ បញ្ញាដែលតាមពិចារណាឃើញវត្ថុដែលមិនទៀង ឬ តាមពិចារណាឃើញថា មិនទៀង ឈ្មោះថា **អនិច្ចានុបស្សនា** ។ ពាក្យថា **អនិច្ចានុបស្សនានេះ** ជាឈ្មោះនៃវិបស្សនាបញ្ញាដែលប្រព្រឹត្តទៅកាន់យកភាវៈនៃធម៌ ទាំងឡាយដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ជារបស់មិនទៀង ។ ពាក្យថា **ចាក និច្ចសញ្ញា** គឺ ចាកមិច្ឆាសញ្ញាដែលប្រព្រឹត្តទៅក្នុងសង្ខតធម៌ថា ទៀង យឺនយូរ ។ គប្បីឃើញថា លោកកាន់យកទាំងចិត្ត និង ទិដ្ឋិទុកដោយសញ្ញាជាប្រធាន ។ សូម្បីក្នុងសុខសញ្ញាជាដើមក៏មានន័យនេះឯង ។ ពាក្យថា **ដោយនិព្វិទានុបស្សនា** គឺ ដោយអនុបស្សនាដែលប្រព្រឹត្តទៅដោយអាការនឿយណាយក្នុងសង្ខារទាំង-ឡាយ ។ ពាក្យថា **ចាកនន្ទិ** គឺ ការត្រេកត្រអាល គឺ ចាកតណ្ហាប្រកបដោយបីតិ ។ ពាក្យថា **ដោយវិរាគានុបស្សនា** គឺ ដោយអនុបស្សនាដែលប្រព្រឹត្តទៅយ៉ាងនោះ គឺ ដោយអាការដែលប្រាសចាកតម្រេក ។ ព្រោះហេតុនោះ លោកអាចារ្យទើប ពោលថា រដោះចិត្តចាករាគៈដូច្នេះ ។ ពាក្យថា **ដោយនិរោធានុបស្សនា** គឺ ដោយបញ្ញាដែលតាមពិចារណាឃើញការរលត់ទៅនៃសង្ខារទាំងឡាយ ។ម្យ៉ាង ទៀត បញ្ញាដែលតាមពិចារណាឃើញដោយប្រការដែលសង្ខារទាំងឡាយ នឹង រលត់ទៅតែម្យ៉ាង មិនកើតឡើងដោយអំណាចនៃកពប្ចិតទៅទៀត ឈ្មោះថា

**និរោធានុបស្សនា** ។ ក៏និរោធានុបស្សនានេះ បានដល់ មុញ្ចិតុកម្យតាញាណដែលមានកម្លាំង ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា រដោះចិត្តចាកសមុទយៈ ដូច្នេះ ។ អនុបស្សនាដែលប្រព្រឹត្តទៅដោយអាការលះបង់ ឈ្មោះថា **បដិនិស្សគ្គានុបស្សនា** ។ ពាក្យថា **ចាកអាទាន** គឺ ចាកការប្រកាន់មាំដោយទាក់ទងនឹងរបស់មិនទៀងជាដើម ឬ ចាកការកាន់យកបដិសន្ធិ ។ បណ្ឌិត គប្បីជ្រាបអត្ថាធិប្បាយក្នុងពាក្យទាំងនេះតាមប្រការ ដូចពោលមកនេះចុះ ។

( ចប់ មហាដីកា )

( ចប់ការអធិប្បាយ ចតុក្កៈ ទី ៣ )

# ចតុក្កៈទី ៤
# អនិច្ចានុបស្សី

*វីឯ ក្នុងចតុក្កៈទី ៤ មានពណ៌នាថា ក្នុងមាតិកាអនិច្ចានុបស្សីនោះ បណ្ឌិតគប្បីជ្រាប* ***អនិច្ចំ*** *គឺ វត្ថុដែលមិនទៀង , គប្បីជ្រាប* ***អនិច្ចតា*** *គឺ ភាពមិនទៀង , គប្បីជ្រាប* ***អនិច្ចានុបស្សនា*** *គឺ ការពិចារណាឃើញថា មិនទៀង , គប្បីជ្រាប* ***អនិច្ចានុបស្សី*** *គឺ អ្នកពិចារណាឃើញថា មិនទៀង មុន ។*

*ក្នុង ៤ បទនោះ បទថា* ***អនិច្ចំ*** *គឺ វត្ថុដែលមិនទៀង បានដល់ បញ្ចក្ខន្ធ ព្រោះហេតុអ្វី ? ព្រោះភាពដែលបញ្ចក្ខន្ធនោះ មានការកើតរលត់ទៅ និងជារបស់កន្សៀត ។ បទថា* ***អនិច្ចតា*** *គឺ ការមិនទៀង បានដល់ ការកើតឡើងហើយរលត់ទៅ និង ជារបស់កន្សៀត ឬការដែលមានហើយ ក៏មិនមាននៃបញ្ចក្ខន្ធទាំងនោះឯង អធិប្បាយថា* ***អនិច្ចតា*** *គឺ បញ្ចក្ខន្ធទាំងឡាយដែលកើតមកហើយមិនតាំងនៅតាមអាការដែលកើតមកនោះ ប្រែប្រួលទៅដោយកង្គក្ខណៈ គឺ រលត់ទៅគ្រប់ខណៈនោះឯង ។*

*បទថា* ***អនិច្ចានុបស្សនា*** *គឺ ការពិចារណាឃើញថា មិនទៀងក្នុងខន្ធទាំងឡាយ មានរូបជាដើមដោយអំណាចនៃអនិច្ចតាដែលពោលមកនោះ ។ បទថា* ***អនិច្ចានុបស្សី*** *បានដល់ ព្រះយោគាវចរ ដែលប្រកបដោយការពិចារណាឃើញនោះ ព្រោះដូច្នោះ ភិក្ខុដែលជាយ៉ាងនោះ កំពុងដកដង្ហើមចេញ-ចូល គប្បីជ្រាបថា ឈ្មោះថា* ***សិក្ខាថា*** *នឹងជាអ្នកពិចារណាឃើញថា មិនទៀងដកដង្ហើមចេញ-ចូល ក្នុងទីនេះ ។*

# វិរាគានុបស្សី - និរោធានុបស្សី

ចំណែកក្នុងបទថា **វិរាគានុបស្សី** នេះ **វិរាគៈ** គឺ ការប្រាសទៅមាន ២ គឺ **ខយវិរាគ** គឺ ការប្រាសទៅដោយការរលត់ ១ **អច្ចន្តវិរាគ** គឺ ការប្រាសទៅដ៏ឧត្តម ១ ។ ក្នុងវិរាគៈ ២ យ៉ាងនោះ ការប្រាសទៅគ្រប់ខណៈនៃសង្ខារទាំងឡាយ ឈ្មោះថា **ខយវិរាគ** , ព្រះនិព្វាន ឈ្មោះថា **អច្ចន្តវិរាគ** , វិបស្សនា និង មគ្គ ដែលប្រព្រឹត្តទៅដោយអនុបស្សនា ២ យ៉ាងនោះ ឈ្មោះថា **វិរាគានុបស្សនា** ព្រះយោគាវចរជាអ្នកប្រកបដោយអនុបស្សនាទាំង ២ យ៉ាងនោះ ដកដង្ហើមចេញ-ចូល គប្បីជ្រាបថា ឈ្មោះថា **សិក្ខាថា** យើងនឹងជាអ្នកពិចារណាឃើញការប្រាសទៅ ដកដង្ហើមចេញ និង ដកដង្ហើមចូល ។

ន័យសូម្បីក្នុងបទថា **និរោធានុបស្សី** ក៏មានន័យដូច្នេះដែរ ។

# បដិនិស្សគ្គានុបស្សី

សូម្បីក្នុងបទថា **បដិនិស្សគ្គានុបស្សី** នេះ **បដិនិស្សគ្គ** ក៏មាន ២ គឺ **បរិច្ចាគបដិនិស្សគ្គ** ( បដិនិស្សគ្គ គឺលះបង់ ) ១ **បក្ខន្ទនបដិនិស្សគ្គ** ( បដិនិស្សគ្គ គឺ ស្ទុះចូលទៅ ) ១ **អនុបស្សនា** គឺ **បដិនិស្សគ្គ** ឈ្មោះថា **បដិនិស្សគ្គានុបស្សនា** , ពាក្យនេះ **ជាឈ្មោះនៃវិបស្សនានិងមគ្គ** , ពិតហើយ វិបស្សនារមែងលះបង់នូវកិលេសព្រមទាំងខន្ធ គឺ វិបាក និងអភិសង្ខារ គឺ កម្ម ដោយអំណាចតទង្គប្បហាន និង រមែងស្ទុះចូលទៅក្នុងព្រះនិព្វានដែលបដិបក្ខនឹងកិលេសនោះ ដោយការបង្អោនទៅកាន់ផ្លូវនោះ ព្រោះឃើញទោសក្នុងសង្ខតធម៌ ព្រោះហេតុនោះ ទើបហៅ **បដិនិស្សគ្គ** មាន ២ គឺ **បដិនិស្សគ្គ** គឺ លះបង់ ១ , **បដិនិស្សគ្គ** គឺ ស្ទុះចូលទៅ

១ , ចំណែកមគ្គ ក៏លះបង់នូវកិលេស ព្រមទាំងខន្ធ និង អភិសង្ខារ ដោយអំណាចសមុច្ឆេទប្បហាន និង ស្ទុះចូលទៅកាន់ព្រះនិព្វាន ព្រោះធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ព្រោះហេតុនោះ ទើបហៅថា **បដិនិស្សគ្គ** មាន ២ គឺ **បដិនិស្សគ្គ** គឺ លះបង់ ១ , **បដិនិស្សគ្គ** គឺ ស្ទុះចូលទៅ ១ ដូច្នេះ , ក៏វិបស្សនាញាណ និង មគ្គញ្ញាណទាំង ២ នេះ ហៅថា **អនុបស្សនា** ព្រោះឃើញព្រះនិព្វានបន្ទាប់ពីញាណមុនៗ ព្រះយោគាវចរ ជាអ្នកប្រកបដោយបដិនិស្សគ្គានុបស្សនាទាំង ២ យ៉ាងនោះ ដកដង្ហើមចេញ-ចូល គប្បីជ្រាបថា ឈ្មោះថា **សិក្ខតិ** យើងនឹងពិចារណាឃើញការលះបង់ ដកដង្ហើមចេញ-ចូល ។

ចតុក្កៈទី ៤ នេះ ត្រាស់ដោយជាវិបស្សនាសុទ្ធ ចំណែក ៣ ចតុក្កៈមុន ត្រាស់ដោយជាសមថៈ និង វិបស្សនាលាយគ្នា ។

ការចម្រើនអានាបានស្សតិ មានវត្ថុ ( មាតិកា ) ១៦ ដោយចាត់ជាចតុក្កៈ ៤ ពួក ( ក្នុងចតុក្កៈមួយៗ មាន ៤ ) បណ្ឌិតគប្បីជ្រាបតាមន័យដែលពណ៌នាមកដូច្នេះ និងអានាបានស្សតិនេះ ( ដែលភិក្ខុចម្រើនហើយ ) តាមវត្ថុ ១៦ យ៉ាងនេះ រមែងមានផលច្រើន មានអានិសង្សច្រើន ។

## មហាដីកា

បុគ្គលពិចារណាឃើញរឿយៗ ថាមិនទៀង ឬបុគ្គលពិចារណាឃើញរឿយៗ នូវវត្ថុដែលមិនទៀងជាប្រក្រតី ឈ្មោះថា **អនិច្ចានុបស្សី** ក៏ក្នុងអធិការនេះ លោកអាចារ្យកាលនឹងសម្ដែងដល់ប្រការដែលថា បណ្ឌិតគប្បីជ្រាបចតុក្កៈថា វត្ថុដែលជា **អនិច្ចំ** នេះ គឺអ្វី , ជា **អនិច្ចំ** នេះដូចម្ដេច អ្វីឈ្មោះថា **អនិច្ចានុបស្សនា** និង

**អនិច្ចានុបស្សនា** មានដល់នរណា ដូច្នេះនោះ ទើបពោលថា គប្បីជ្រាប **អនិច្ចំ** ដូច្នេះ ជាដើម ។

ក្នុងពាក្យទាំងនោះ វត្ថុដែលសស្សតៈ ស្ថិតស្ថេរដូចជាព្រះនិព្វាន ឈ្មោះថា **និច្ចំ** ឈ្មោះថា **អនិច្ចំ** ព្រោះអត្ថថា មិនមែននិច្ចំ បានដល់ ធម្មជាតិដែលមានការកើតឡើងហើយរលត់ទៅ ដោយសភាវៈ បានដល់ សង្ខតធម៌ទាំងឡាយ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា បទថា **អនិច្ចំ** បានដល់ ខន្ធ ៥ ។ ព្រោះហេតុអ្វី ព្រោះមានការកើតរលត់ និង ជារបស់កន្សៀត ដូច្នេះ មានសេចក្តីថា ព្រោះភាវៈដែលមានការកើតឡើងរលត់ទៅ និង ជារបស់កន្សៀត ។ ក្នុងពាក្យថា ព្រោះមានការកើតឡើងនោះ ការកើតឡើងព្រោះហេតុ-បច្ច័យទាំងឡាយ គឺភាពដែលមិនមាន ហើយត្រឡប់មកមានឡើង ដែលជាការបានតួសភាវៈនៃសង្ខតធម៌ទាំងឡាយ ឈ្មោះថា **ឧប្បាទ** ការកើតឡើង ។ ការរលត់ទៅក្នុងខណៈ គឺការវិនាសទៅនៃសង្ខតធម៌ដែលកើតឡើងហើយទាំងនោះ ឈ្មោះថា **វយ** ការរលត់ទៅ ។ ភាពជាប្រការដទៃនៃជរា ឈ្មោះថា **អញ្ញថត្ត** ជារបស់កន្សៀត ។ ដូចជាថា កាលឧប្បាទក្ខណៈបែកធ្លាយហើយ គឺ ឧប្បាទក្ខណៈអស់ទៅត្រង់ភង្គក្ខណៈ ក៏មិនទាន់មានការបែកធ្លាយនៃតួវត្ថុ គឺ តួវត្ថុនៅប្រាកដ ត្រឹមតែថាមាននៅជាខណៈចុងបំផុត យ៉ាងណា សូម្បីត្រង់ខណៈដែលបែរមុខទៅកាន់ការរលត់ ក៏ហៅថា ឋិតិ ក៏មិនទាន់មានការបែកធ្លាយនៃវត្ថុដូច្នោះ ដែលជាខណៈត្រង់ដែលមានវោហារ ហៅថា ជរា ។ ព្រោះដូច្នោះ ជរាក៏រមែងសមគួរដល់ធម៌ដែលដូចគ្នាដែលជា ជរា ដែលលោកហៅថា **ខណិកជរា** ។ ក៏ត្រង់ឧប្បាទក្ខណៈ និង ភង្គក្ខណៈ បណ្ឌិតជ្រាបបាន នៅពេលដែលវត្ថុនៅមិនទាន់បែកធ្លាយដោយពិត

ប្រាកដ បើនឹងកាន់យកសេចក្ដីដោយប្រការដទៃ ក៏នឹងដូចជាថា ធម៌យ៉ាងកើតឡើង ធម៌យ៉ាងរលត់ទៅដូច្នេះ ។ លោកអាចារ្យសំដៅយកខណិកជាតនេះ ទើបពោលថា **អញ្ញថត្តំ** ភាពជាយ៉ាងដទៃដូច្នេះ ក៏ក្នុងពាក្យនេះនឹងមានពាក្យគួរពោលអធិប្បាយ ឯណាដែលខ្ញុំព្រះករុណានឹងពោលពាក្យគួរពោលអធិប្បាយនោះ មានខាងមុខ ។

សមញ្ញាថា **អនិច្ចំ** រមែងបានក្នុងខន្ធទាំងឡាយ ព្រោះមានលក្ខណៈ ៣ ឈ្មោះថា **អនិច្ចតា** ក៏រមែងបានក្នុងលក្ខណៈ ៣ នោះ ព្រោះហេតុនោះ លោកអាចារ្យកាលពោលថា បទថា **អនិច្ចតា** បានដល់ ភាវៈដែលកើតឡើង និងរលត់ទៅ និងជាប្រការដទៃនៃខន្ធទាំងនោះៗឯង ដូច្នោះហើយ កាលនឹងសម្ដែងថា ដោយពិសេស ធម៌ទាំងឡាយ មានវោហារថា **អនិច្ចតា** ព្រោះការរលត់ទៅជាខណៈ ដូច្នេះទើបពោលថា ឬបានដល់ ភាវៈដែលមានហើយត្រឡប់មិនមានដូច្នេះជាដើម ។ ក្នុងពាក្យនោះ លោកប្រើស័ព្ទថា **ហុត្វា** មានហើយ ព្រោះធម៌ដែលនឹងត្រឡប់មិនមាន នឹងត្រូវមានការកើតឡើងមុន ។ ដោយពាក្យនោះលោកសម្ដែងថា ធម៌ដែលមានការវិនាសទៅនោះ ត្រូវមានការចាស់គ្រាំគ្រាមុន ។ ពាក្យថា **ដោយអាការនោះៗ ឯង** គឺ ដោយអាការដែលកើតឡើងនោះឯង ។ ពាក្យថា **ដោយការបែករលត់ទៅក្នុងខណៈ** គឺ ដោយការរលត់ដែលមានក្នុងខណៈ ។ ពាក្យថា **ដោយអំណាចនៃអនិច្ចតានោះ** គឺ ដោយអំណាចនៃអនិច្ចតា ដែលហៅថា ការបែកធ្លាយក្នុងខណៈ ។ ពាក្យថា **ដោយអនុបស្សនានោះ** គឺ ដោយអនិច្ចានុបស្សនាតាមដែលពោលហើយ ។ ពាក្យថា **បុគ្គលអ្នកដល់ព្រម** បានដល់ ព្រះយោគាវចរ ដែលជាអ្នកដល់ព្រម ។

ឈ្មោះថា **ខយ** គឺ ការអស់ទៅ បានដល់ ការវិនាសទៅ គឺ ការប្រែប្រួលទៅនៃសង្ខារទាំងឡាយ ការទ្រុឌទ្រោមទៅនៃសង្ខារទាំងនោះៗឯង ឈ្មោះថា **វិរាគ** គឺ ការប្រាសទៅ **ខយ** នោះឯងជា **វិរាគ** ទើបឈ្មោះថា **ខយវិរាគ** បានដល់ការរលត់ទៅដែលមានជាខណៈ ។ ព្រះនិព្វាន ឈ្មោះថា **អច្ចន្តវិរាគ** ព្រោះអត្ថថា ជាធម៌យ៉ាង កាលបុគ្គលសម្រេចហើយ សង្ខារទាំងឡាយ ក៏រមែងប្រាសទៅ គឺ រលត់ទៅជាប្រាកដ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ការបែកធ្លាយទៅជាខណៈនៃសង្ខារទាំងឡាយ ឈ្មោះថា **ខយវិរាគ** , ព្រះនិព្វាន ឈ្មោះថា **អច្ចន្តវិរាគ** ដូច្នេះ ។ ពាក្យថា **ដែលប្រព្រឹត្តទៅដោយអំណាចនៃវិរាគៈទាំង ២** មានសេចក្តីថា សម្រាប់វិបស្សនា គប្បីប្រកបការប្រព្រឹត្តទៅដោយអំណាចនៃការតាមពិចារណាឃើញ **ខយវិរាគ** , សម្រាប់មគ្គ គប្បីប្រកបការប្រព្រឹត្តទៅដោយអំណាចនៃការតាមពិចារណាឃើញ **អច្ចន្តវិរាគ** ។ ម្យ៉ាងទៀត គប្បីជ្រាបថា **វិបស្សនា** មានការប្រព្រឹត្តទៅដោយអំណាចការតាមពិចារណាឃើញ **ខយវិរាគ** ដោយអារម្មណ៍ គឺ ធ្វើខយវិរាគៈឲ្យជាអារម្មណ៍ មានការប្រព្រឹត្តទៅដោយអំណាចនៃការតាមពិចារណាឃើញថា **អច្ចន្តវិរាគ** ដោយការៈដែលបង្អោនទៅក្នុងអច្ចន្ត-វិរាគៈនោះ ចំណែកមគ្គមានការប្រព្រឹត្តទៅដោយអំណាចការតាមពិចារណាឃើញ **ខយវិរាគ** ដោយអសម្មោហៈ គឺ មិនវង្វេង មានការប្រព្រឹត្តទៅដោយអំណាចការតាមពិចារណាឃើញអច្ចន្តវិរាគៈដោយអារម្មណ៍ ។ ដោយពាក្យថា ក៏មាននយ័នេះឯង ព្រោះហេតុដែលចង្អុលដល់ការអធិប្បាយ មានយ៉ាងនេះថា ឈ្មោះថា **និរោធ** មាន ២ យ៉ាង គឺ **ខយនិរោធ** និង **អច្ចន្តនិរោធ** ដូច្នេះជាដើម តាមទំនងនៃន័យដែលបានពោលទុកក្នុងបទថា **វិរាគានុបស្សនា** ដូច្នេះ បណ្ឌិតគប្បីដាក់បទថា **និរោធ**

ជំនួសត្រង់បទថា **វិរាគ** ហើយជ្រាបអធិប្បាយនៃបទថា **និរោធានុបស្សី** នោះតាមន័យដែលខ្ញុំព្រះករុណាបានពោលហើយក្នុងទីនេះ ដោយពាក្យថា ឈ្មោះថា **ខយ** ( ការអស់ទៅ ) គឺ ការវិនាសទៅនៃសង្ខារទាំងឡាយដូច្នេះជាដើមចុះ ។

ការបន្សាត់ទៅ គឺ បរិច្ចាគវត្ថុដែលគួរលះដោយអំណាចការបរិច្ចាគជាតទង្គៈ ឬដោយអំណាចការបរិច្ចាគជាសមុច្ឆេទ ឈ្មោះថា **បរិច្ចាគបដិនិស្សគ្គ** ។ ដូចគ្នានោះដែរ ការបន្សាត់ខ្លួនទៅក្នុងវិសង្ខារ គឺព្រះនិព្វានដែលជាទីបន្សាត់ឧបធិទាំងពួង គឺ ការស្ទុះទៅក្នុងព្រះនិព្វាននោះ ដោយភាវៈដែលមានចិត្តបង្អោនទៅក្នុងព្រះនិព្វាននោះក្តី ដោយភាវៈដែលមានព្រះនិព្វាននោះជាអារម្មណ៍ក្តី ឈ្មោះថា **បក្ខន្ទនបដិនិស្សគ្គៈ** ។ ក្នុងពាក្យថា ដោយអំណាចការលះជាតទង្គៈនេះ មានអធិប្បាយថា ដំបូងអនិច្ចានុបស្សនា រមែងបរិច្ចាគនិច្ចសញ្ញាដោយអំណាចការលះជាតទង្គៈ ម្យ៉ាងវិញទៀត ធម៌ពួកណា គឺកិលេសទាំងឡាយ អភិសង្ខារដែលមានកិលេសនោះជាមូល និងវិបាកខន្ធទាំងឡាយ ដែលមានកិលេស និងអភិសង្ខារនោះជាមូលគប្បីកើតឡើងបានក្នុងអនាគត ដោយអំណាចនៃការប្រកាន់ថា ទៀង ក្នុងកាលវាមិនប្រព្រឹត្តទៅយ៉ាងនោះ អនិច្ចានុបស្សនាកាលនឹងបរិច្ចាគ រមែងបរិច្ចាគធម៌ទាំងនោះសូម្បីទាំងអស់ ដោយអំណាចការធ្វើមិនឲ្យប្រព្រឹត្តទៅ ទុក្ខានុបស្សនាជាដើម រមែងលះសុខសញ្ញាជាដើមយ៉ាងនោះដូចគ្នា ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ពិតណាស់ វិបស្សនារមែងបរិច្ចាគកិលេសទាំងឡាយ ព្រមទាំងខន្ធ និងអភិសង្ខារ ដោយអំណាចការលះជាតទង្គៈ ដូច្នេះ ។

ពាក្យថា **ព្រោះឃើញទោសក្នុងសង្ខតៈ** គឺព្រោះឃើញទោស គឺភាពជារបស់មិនទៀងជាដើមក្នុងសង្ខតៈ គឺ ក្នុងសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ព្រះ

និព្វាន ឈ្មោះថា មានសភាវៈបដិបក្ខនឹងសង្ខតៈនោះ ក៏ដោយភាពដែលជារបស់ទៀងជាដើម ។ បទថា **តន្និន្នតាយ** ប្រែថា ដោយការៈដែលមានចិត្តបង្អោនទៅក្នុងព្រះនិព្វាននោះ ។ ពាក្យថា **ស្មុះទៅ** បានដល់ តាមចូលទៅ គឺដូចជាតាមចូលទៅ ។ ពាក្យថា **មគ្គ រមែងលះកិលេសទាំងឡាយព្រមទាំងខន្ធ និងអភិសង្ខារ** មានសេចក្ដីថា កាលកិលេសទាំងឡាយត្រូវមគ្គបរិច្ចាគទៅហើយ អភិសង្ខារទាំងឡាយក៏ឈ្មោះថា ក៏ត្រូវបរិច្ចាគទៅដែរ ដោយការធ្វើឲ្យដល់នូវភាពជាធម៌ដែលមិនមានវិបាក ខន្ធទាំងឡាយដែលមានកិលេស និង អភិសង្ខារទាំងនោះជាមូលក៏ឈ្មោះថា ក៏ត្រូវបរិច្ចាគទៅដែរ ដោយភាពជារបស់គួរដល់ការមិនកើតឡើង ព្រោះហេតុនោះ ទើបបានពោលថា មគ្គរមែងបរិច្ចាគធម៌ទាំងនោះសូម្បីទាំងអស់ ។ ពាក្យថា **ធម្មជាតិសូម្បីទាំង ២** បានដល់ វិបស្សនាញាណ និង មគ្គញ្ញាណ ។ ពិតណាស់ សូម្បីមគ្គញ្ញាណហៅថា អនុបស្សនាបាន ព្រោះឃើញព្រះនិព្វានតាម គឺ ខាងក្រោយគោត្រភូញាណ ។

ពាក្យថា **សោឡសវត្ថុវសេន ច** មានសេចក្ដីថា សូម្បីដោយអំណាចការៈដែលស្ងប់ជាដើម ដែលពោលទុកសូម្បីទាក់ទងនឹងវត្ថុ ១៦ ។ **ច** ស័ព្ទ មានអត្ថថា រួបរួម សូម្បីនាំបទចូលមកភ្ជាប់គ្នាថា **អានាបានសត្តិភាវិតា** អានាបានសត្តិដែលភិក្ខុធ្វើឲ្យកើតហើយ ។

( ចប់ មហាដីកា )

( ចប់ ការអធិប្បាយ ចតុក្កៈ ទី ៤ )

# អានិសង្សនៃអានាបានស្សតិ

ក្នុងអានិសង្សនៃអានាបានស្សតិនោះ មានអធិប្បាយថា អានាបានស្សតិនោះ មានអានិសង្សច្រើន បណ្ឌិតគប្បីជ្រាបថា ជាធម៌ដែលព្រះមានព្រះភាគទ្រង់សរសើរ មានភាពជាធម៌ស្ងប់ជាដើម តាមព្រះពុទ្ធវចនៈថា ភិក្ខុទាំងឡាយ អានាបានស្សតិសមាធិនេះឯង បុគ្គលធ្វើឲ្យមាន ធ្វើឲ្យច្រើនហើយ រមែងជាធម៌ស្ងប់ពិតផង ប្រណីតពិតផង ដូច្នេះជាដើមខ្លះ ដោយភាពជាធម៌អាចក្នុងការកាត់បង់នូវវិតក្ក មានកាមវិតក្កជាដើមខ្លះ ពិតណាស់ អានាបានស្សតិសមាធិនេះ ព្រោះជាធម៌ស្ងប់ ប្រណីត និង ជាធម៌គ្រឿងស្នាក់នៅដ៏ជាសុខ ទើបកាត់ភាពច្វាទៅមកនៃចិត្ត ដោយអំណាចវិតក្កទាំងឡាយ ដែលជាតួធ្វើអន្តរាយដល់សមាធិបាន ហើយធ្វើចិត្តឲ្យបែរមុខចំពោះអារម្មណ៍ គឺ ខ្យល់ដង្ហើមចេញ-ចូល ប៉ុណ្ណោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ទុកថា អានាបានស្សតិ ភិក្ខុគប្បីបំពេញដើម្បីលះបង់នូវវិតក្ក ។

ម្យ៉ាងទៀត អានាបានស្សតិនោះ មានអានិសង្សច្រើន បណ្ឌិតគប្បីជ្រាបដោយភាពជាមូលនៃការធ្វើវិជ្ជា និងវិមុត្តិឲ្យបរិបូណ៌ក៏បាន ពិតណាស់ ព្រះមានព្រះភាគក៏បានត្រាស់ពាក្យនេះទុកថា ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ភិក្ខុចម្រើន ធ្វើឲ្យច្រើនហើយ រមែងញ៉ាំងសតិប្បដ្ឋាន ៤ ឲ្យបរិបូណ៌ សតិប្បដ្ឋាន ៤ ភិក្ខុចម្រើន ធ្វើឲ្យច្រើនហើយ រមែងញ៉ាំងសម្ពោជ្ឈង្គ ៧ ឲ្យបរិបូណ៌ សម្ពោជ្ឈង្គ ៧ ភិក្ខុចម្រើន ធ្វើឲ្យច្រើនហើយ រមែងញ៉ាំងវិជ្ជា និងវិមុត្តិឲ្យបរិបូណ៌ដូច្នេះ ។

ម្យ៉ាងទៀត អានាបានស្សតិនោះ មានអានិសង្សច្រើន គប្បីជ្រាបដោយការ

ដឹងខ្យល់អស្សាសបស្សាសៈដែលជាចរិមកៈ គឺ គ្រាចុងក្រោយក៏បាន សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ក្នុងរាហុលោវាទសូត្រថា ម្នាលភិក្ខុទាំងឡាយ កាលអានាបានស្សតិដែលភិក្ខុចម្រើនហើយ ធ្វើយ៉ាងនេះ ធ្វើឲ្យចម្រើនហើយយ៉ាងនេះឯង សូម្បីខ្យល់អស្សាសបស្សាសៈដែលជាចរិមកៈរលត់ក៏ដឹង រលត់មិនដឹង មិនមានដូច្នេះ ។

ក្នុងខ្យល់ទាំងនោះ ពោលដោយការរលត់ មានចរិមកៈ ៣ គឺ ភវចរិមកៈ គឺ ចុងបំផុតដោយអំណាចភព ឈានចរិមកៈ គឺចុងបំផុតដោយអំណាចឈាន ចុតិចរិមកៈ គឺ ចុងបំផុតដោយចុតិ ។ ពោលខាងភព ខ្យល់អស្សាសបស្សាសៈទាំងឡាយរមែងប្រព្រឹត្តទៅក្នុងកាមភព មិនប្រព្រឹត្តទៅក្នុងរូបភព និងអរូបភពទេ ព្រោះដូច្នោះ ខ្យល់ទាំងនោះទើបឈ្មោះថា ភវចរិមកៈ គឺ ចុងបំផុតដោយអំណាចភព ។ ពោលខាងឈាន ខ្យល់អស្សាសបស្សាសៈរមែងប្រព្រឹត្តទៅក្នុងឈាន ៣ ខាងដើម មិនប្រព្រឹត្តទៅក្នុងឈានទី ៤ ទេ ព្រោះដូច្នោះ ខ្យល់ទាំងនោះ ទើបឈ្មោះថា ឈានចរិមកៈ គឺ ចុងបំផុតដោយអំណាចឈាន ។ ចំណែកខ្យល់អស្សាសបស្សាសៈ ពួកណាកើតឡើងព្រមនឹងចិត្តខណៈទី ១៦ ខាងមុខអំពីចុតិ ហើយរលត់ព្រមនឹងចុតិចិត្ត ខ្យល់ទាំងនោះ ឈ្មោះថា ចុតិចរិមកៈ គឺ ទីបំផុតដោយចុតិ ខ្យល់ចុតិចរិមកៈ នេះឯង ព្រះមានព្រះភាគបំណងយកថា ជាខ្យល់ចុងបំផុតក្នុងព្រះសូត្រនេះ ។

បានឮថា ព្រោះខ្យល់ដកដង្ហើមចេញ-ចូល ដែលភិក្ខុកំណត់ជាអារម្មណ៍ដោយល្អហើយ សូម្បីការកើតឡើងនៃខ្យល់ទាំងនោះ ក៏ប្រាកដដល់ភិក្ខុដែលប្រកបកម្មដ្ឋាននេះ កាលលោកពិចារណាដល់ការកើតរបស់វាក្នុងខណៈចិត្តដួង ទី

១៦ កើតមុនអំពីចុតិ សូម្បីការតាំងនៅនៃខ្យល់ទាំងនោះក៏ប្រាកដ កាលលោកពិចារណាដល់ការតាំងនៅរបស់វា សូម្បីការរលត់នៃខ្យល់ទាំងនោះក៏ប្រាកដ សូម្បីពិចារណាដល់ការរលត់របស់វា ។

មែនពិត ភិក្ខុដែលចម្រើនកម្មដ្ឋានឯណាមួយ ក្រៅអំពីកម្មដ្ឋាននេះហើយ បានសម្រេចព្រះអរហត្ត រមែងកំណត់រយៈកាលនៃអាយុបានខ្លះ មិនបានខ្លះ តែភិក្ខុដែលចម្រើនអានាបានស្សតិ មានវត្ថុ ១៦ នេះ ហើយបានសម្រេចព្រះអរហត្ត រមែងកំណត់រយៈកាលនៃអាយុបានទាំងអស់ ។

ភិក្ខុចម្រើនអានាបានស្សតិ បានសម្រេចព្រះអរហត្តនោះ រមែងដឹងថាឥឡូវនេះ អាយុសង្ខាររបស់យើងនឹងប្រព្រឹត្តទៅបានត្រឹមនេះ មិនហួសនេះទៅ ដូច្នេះហើយ ធ្វើកិច្ចទាំងពួង មានការជម្រះរាងកាយ និងការស្លៀកដណ្តប់ជាដើម តាមធម្មតារបស់ខ្លួននោះឯង ស្រេចហើយបិទភ្នែករលត់ទៅ ដូចព្រះតិស្សត្ថេរនៅវត្តកោដិបព៌តវិហារ ដូចព្រះមហាតិស្សត្ថេរនៅវត្តមហាករញ្ជនិយវិហារ ដូចព្រះបិណ្ឌបាតិកតិស្សត្ថេរក្នុងទេវបុត្តរដ្ឋ និងដូចព្រះថេរៈ ២ អង្គ បងប្អូន នៅវត្តចិត្តលបព៌តវិហារ ដូច្នោះ ។

តទៅនេះជាពាក្យសម្តែងរឿងមួយ ក្នុងរឿងនៃព្រះថេរៈទាំងឡាយនោះ ។

មានរឿងពោលថា លោកមួយអង្គនៃព្រះថេរៈពីរនាក់បងប្អូននោះធ្វើបាតិមោក្ខក្នុងថ្ងៃឧបោសថបុណ្ណមី ហើយមានពួកភិក្ខុហែហមទៅកាន់ទីលំនៅរបស់ខ្លួន ទៅឈរក្នុងទីចង្រ្កមក្រឡេកមើលផ្ទៃមេឃ និងផ្ទៃដីដែលភ្លឺដោយពន្លឺព្រះចន្ទពិចារណាមើលអាយុសង្ខាររបស់ខ្លួនហើយ ពោលនឹងពួកភិក្ខុថា លោកទាំងឡាយធ្លាប់ឃើញភិក្ខុដែលបរិនិព្វានដោយអាការដូចម្តេចខ្លះ ក្នុងភិក្ខុទាំងនោះ អង្គខ្លះក៏ថា ធ្លាប់

ឃើញអន្ទុយត្រង់អាសនៈនោះឯង បរិនិព្វាន អន្ទុខ្លះក៏ថា ធ្លាប់ឃើញអន្ទុយពែនក្អែនក្នុងអាកាសបរិនិព្វាន ព្រះថេរៈទើបថា ឥឡូវនេះ យើងនឹងបង្ហាញភិក្ខុដែលកំពុងចង្ក្រមនោះឯង បរិនិព្វានឲ្យលោកទាំងអស់មើល ពោលហើយក៏ធ្វើស្នាមគំនូសទុកលើទីចង្ក្រម ប្រាប់ថា យើងដើរទៅអំពីចុងទីចង្ក្រមនេះ ដល់ចុងទីចង្ក្រមម្ខាងទៀត ហើយត្រឡប់មក លុះដល់ស្នាមគំនូសនេះនឹងបរិនិព្វាន ដូច្នេះហើយចុះកាន់ទីចង្ក្រមទៅដល់ចុងម្ខាង ហើយត្រឡប់មក ក្នុងខណៈជើងម្ខាងជាន់គំនូស គឺ ទីដែលគូសទុក ក៏បរិនិព្វានល្មម ។

ព្រោះហេតុនោះ បណ្ឌិតគប្បីជាអ្នកមិនប្រមាទ ប្រកបអានាបានស្សតិដែលមានអានិសង្សជាអនេកដូចពោលមកដូច្នេះ គ្រប់ប្រការចុះ ។

( នេះជាកថាមុខ ដោយពិស្តារក្នុងអានាបានស្សតិ )

# មហាដីកា

ក្នុងពាក្យថា **នៃអានាបានស្សតិនេះ** គឺ នៃអានាបានស្សតិសមាធិ ។ ភ្ជាប់សេចក្តីថា គប្បីជ្រាបភាពជារបស់មានអានិសង្សច្រើន សូម្បីដោយភាពជាធម៌មានអំណាចកាត់វិតក្ក មានកាមវិតក្កជាដើមបាន ។ ពាក្យថា **សមាធិនេះ** គឺ អានាបានស្សតិសមាធិ ។ ការប្រព្រឹត្តទៅក្នុងអារម្មណ៍ទាំងឡាយទាំងខ្ពស់ ទាំងទាប នោះឯង ឈ្មោះថា ការឆ្ងាទៅខាងនោះខាងនេះនៃចិត្ត ។

**មគ្គ** ឈ្មោះថា វិជ្ជា ។ **ផល** ឈ្មោះថា វិមុត្តិ ភាពជាបាទនៃវិបស្សនា ឈ្មោះថា ភាពជាមូល ។ ឈ្មោះថា រមែងធ្វើសតិប្បដ្ឋាន ៤ ឲ្យបរិបូណ៌ ព្រោះការចម្រើនអានាបានស្សតិនោះ ប្រព្រឹត្តទៅដោយអំណាចនៃអនុបស្សនា ៤ មាន

កាយានុបស្សនាជាដើម ។ ឈ្មោះថា រមែងធ្វើពោជ្ឈង្គឲ្យបរិបូណ៌ ព្រោះវៀរចាក ការចម្រើនពោជ្ឈង្គ ក៏មិនមានការបរិបូណ៌នៃការចម្រើនសតិប្បដ្ឋាន ។ ឈ្មោះថា **រមែងធ្វើវិជ្ជា និង វិមុត្តិឲ្យបរិបូណ៌** ព្រោះវិជ្ជា និងវិមុត្តិទាំងនោះ មានការដល់ កំពូលបាន ក៏ដោយការចម្រើនពោជ្ឈង្គ ។ ពាក្យថា **ចរិមក** បានដល់ មានទី បំផុត ។

បទថា **និរោធវសេន** ប្រែថា ដោយទាក់ទងនឹងការរលត់ ។ ពាក្យថា **ភវចរិមក** បានដល់ មានទីបំផុតដោយទាក់ទងនឹងភព គឺមានការប្រព្រឹត្តទៅក្នុង ភពជាន់ទាប ។ គប្បីជ្រាប **ឈានចរិមក** ដោយន័យដូចគ្នានោះ ។ ពាក្យថា **ចុតិចរិមក** បានដល់ ទីបំផុតដោយចុតិ គឺ ខ្យល់ដង្ហើមដែលមានការប្រព្រឹត្តទៅ ទៀបខណៈចុតិ ជាខ្យល់គ្រាចុងក្រោយគេបង្អស់ ។ ពាក្យថា **ព្រោះដូច្នោះ** គឺ ព្រោះក្នុងបណ្ដាភព ៣ មានការប្រព្រឹត្តទៅក្នុងភពជាន់ទាប គឺ កាមភព ទើប ឈ្មោះថា ភវចរិមក ។ បទថា **តេ យោគអស្សាសបស្សាសា** ប្រែថា ខ្យល់ ដង្ហើមចេញ-ចូល ។ ពាក្យថា **មុន** ( ចុតិ ) បានដល់ មុន ។ ព្រោះហេតុ ដែលលោករចនាទុកក្នុងអដ្ឋកថាវិភង្គហើយថា រូបធម៌ទាំងឡាយមានអាយុ ១៦ ខណៈចិត្តដូច្នេះ លោកទើបពោលថា កើតឡើងព្រម នឹងចិត្តដួងទី ១៦ ដូច្នេះ ។ ម្យ៉ាងទៀត ពាក្យថា **មុនចុតិ** មានសេចក្ដីថា លោកកាន់យកចុតិដែលជាដែន កំណត់ ពោលថា កើតព្រមនឹងចិត្តដួងទី ១៦ រាប់ ថយចុះមកអំពីចុតិចិត្តនោះ ដូច្នេះ ក៏កាលកាន់យកន័យនេះ ក៏ពោលបានថា ខ្យល់ដកដង្ហើមចេញ-ចូល មាន អាយុ ១៧ ខណៈចិត្ត ។

គប្បីនាំបទមកភ្ជាប់គ្នាថា **ឥមេ កិរ ឥមំ កម្មដ្ឋានំ អនុយុត្តស្ស ភិក្ខុនោ**

**បាកដា ហោន្តិ** ដូច្នេះចុះ ។ ក្នុងបទទាំងនោះ លោកពោលដល់ហេតុទុកថា ព្រោះការដែលអារម្មណ៍ គឺខ្យល់ដង្ហើមចេញ-ចូល លោកកំណត់កាន់យកបានយ៉ាងល្អហើយ ដូច្នេះ ។ បំណងនឹងបើកផ្លូវន័យនោះៗ ឯង ទើបពោលថា **ចុតិចិត្តស្ស** ដូច្នេះជាដើម ។

ក្នុងបណ្ដាបទទាំងនោះ ឈ្មោះថា **អន្តរអាយុ** បានដល់ រយៈកាលនៃជីវិត គឺ ព្រំដែននៃខណៈរស់នៅ ។ ពាក្យថា **តាមធម្មតានោះឯង** គឺ តាមប្រក្រតីនោះឯង មានសេចក្ដីថា តាមការពេញចិត្តនោះឯង ។

ពាក្យថា **ក្រឡេកមើលពន្លឺព្រះចន្ទ** អធិប្បាយថា ក្នុងវេលាព្រលប់នាខាងខ្នើត ឃើញផ្ទៃមេឃដូចមានធារទឹកដោះស្រោចស្រប់នៅដោយជុំទិស និងឃើញភូមិភាគដែលដេរដាសដោយវាលខ្សាច់ស ដូចក្រាលដោយផែនប្រាក់ហើយ ក៏គិតថា វេលា និងស្ថានទីនេះគួរមនោរម្យហ្ន៎ ត្រូវអធ្យាស្រ័យរបស់យើង , យើងនឹងត្រូវដាក់ភារៈ គឺ ទុក្ខនៅយូរប៉ុនណាទៀតហ្ន៎ ដូច្នេះ រពឹកមើលអាយុសង្ខាររបស់ខ្លួនលោកជ្រាបថា អស់រលីងហើយ ។ ពាក្យថា **ធ្វើស្នាមគំនូសទុក** គឺ ធ្វើស្នាមគំនូសទុកលើទីចង្ក្រម គឺ កាត់ផ្លូវចង្ក្រម ។

បទថា **អនុយុញ្ជេថ** ប្រែថា គប្បីប្រកបរឿយៗ មានសេចក្ដីថា គប្បីចម្រើន ។

ពណ្ណនា

( អានាបានស្សតិនិទ្ទេស ចប់ហើយដោយប្រការដូច្នេះ )

# ឧបសមានុស្សតិ

រីឯ ព្រះយោគាវចរ គឺ ភិក្ខុដែលប្រាថ្នានឹងចម្រើនឧបសមានុស្សតិ ដែលលោកលើកឡើងសម្តែងទុកក្នុងលំដាប់នៃអានាបានស្សតិ ក៏គប្បីទៅក្នុងទីស្ងាត់មនុស្សសំងំនៅហើយ រឭកដល់គុណទាំងឡាយនៃព្រះនិព្វាន ដែលរាប់ថា ជាទីរម្ងាប់នៃទុក្ខទាំងពួង ក្នុងន័យព្រះបាលីយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយជាសង្ខតៈក្តី អសង្ខតៈក្តី មានប្រមាណត្រឹមណា **វិរាគធម៌** តថាគតពោលថា ជាធម៌ប្រសើរជាងធម៌ទាំងនោះ វិរាគធម៌នេះ គឺអ្វី ? វិរាគធម៌នេះ គឺ ធម៌ជាទីស្វាងស្រវឹង ជាទីកម្ចាត់ការស្រេកឃ្លាន ជាទីដកអាល័យ ជាទីកម្ចាត់វដ្តៈ ជាទីអស់តណ្ហា ជាទីខ្ជាក់តណ្ហា ជាទីរលត់តណ្ហា គឺ ព្រះនិព្វាន ដែនចេញចាកគ្រឿងរួបរឹត គឺ តណ្ហា ដូច្នេះ ។

## អធិប្បាយ អត្ថព្រះបាលី

ក្នុងបាឋៈទាំងនោះ ពាក្យថា **មានឧបមាត្រឹមណា** គឺមានប្រមាណប៉ុនណា ។ ពាក្យថា **ធម៌ទាំងឡាយ** សំដៅយកសភាវធម៌ ។ ពាក្យថា **ជាសង្ខតៈក្តី អសង្ខតៈក្តីនោះ** គឺ ដែលបច្ច័យទាំងឡាយប្រជុំធ្វើឡើងក្តី ដែលបច្ច័យទាំងឡាយមិនបានប្រជុំធ្វើឡើងក្តី ។ ពាក្យថា **វិរាគធម៌ តថាគតពោលថាប្រសើរជាងធម៌ទាំងនោះ** គឺថា វិរាគធម៌ តថាគតពោលថា ប្រសើរជាង គឺ ប្រសើរឧត្តមជាងសង្ខតធម៌ និងអសង្ខតធម៌ទាំងឡាយនោះ ។

មិនត្រឹមតែការមិនមានរាគៈប៉ុណ្ណោះ ឈ្មោះថា **វិរាគធម៌** ក្នុងបាលីនោះក៏ទេ ដែលពិត អសង្ខតធម៌ដែលបាននាមផ្សេង ៗ មាននាមថា **មទនិម្មទនោ** ជាដើម

តាមបាលីថា **យទិទំ មទនិម្មទនោ ។ បេ ។ និព្វានំ** នោះ ក៏គប្បីបានឈ្មោះថា វិរាគធម៌ផងដែរ ពិតមែន វិរាគធម៌នោះលោកហៅថា **មទនិម្មទន** ព្រោះការស្រវឹងទាំងឡាយទាំងពួង មានការស្រវឹងដោយអំណាចមានះ និងការស្រវឹងក្នុងភាពជាបុរសជាដើម មកដល់វិរាគធម៌នោះក៏ស្វាង គឺបាត់ស្រវឹងទៅ និងហៅថា **បិបាសវិនយ** ព្រោះការស្រេកក្នុងកាមទាំងឡាយទាំងពួង មកដល់វិរាគធម៌នោះ ក៏ដល់នូវភាពប្រាសទៅ គឺ ធ្លាក់ទៅ ម្យ៉ាងហៅថា **អាលយសមុគ្ឃាត** ព្រោះអាល័យ គឺបញ្ចកាមគុណ មកដល់វិរាគធម៌នោះ ក៏ដល់នូវការដកឡើងអស់ និង ហៅថា **វដ្ដុបច្ឆេទ** ព្រោះវដ្ដៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ មកដល់វិរាគធម៌នោះក៏ដាច់ ម្យ៉ាងហៅថា **តណ្ហក្ខយ វិរាគ និរោធ** ព្រោះតណ្ហាមកដល់វិរាគធម៌នោះ រមែងដល់នូវការអស់ទៅ ខ្ទាក់ចោលទៅ និងរលត់ទៅដោយប្រការទាំងពួង ម្យ៉ាងទៀត ហៅថា **និព្វាន** ព្រោះវិរាគធម៌នោះចេញទៅ គឺបន្សាត់ទៅចាកតណ្ហា ដែលបានវោហារហៅថា **វាន** ព្រោះដោតទុក ក្រងទុក ដោតទុកនូវកំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ និង សត្តាវាស ៩ ដើម្បីជាការបន្តទៅ ។ **ឧបសម** ពោលគឺ ព្រះនិព្វាន ព្រះយោគាវចរ គប្បីរឭកដល់ដោយអំណាចគុណទាំងឡាយ មានភាពជាទីស្វាងស្រវឹងជាដើមទាំងនោះ ដូចពោលមកដូច្នេះ ឬ ម្យ៉ាងវិញទៀត សូម្បីគុណនៃឧបសមៈដទៃណា ដែលព្រះមានព្រះភាគត្រាស់ទុកក្នុងសូត្រផ្សេង ៗ ដូចជាព្រះសូត្រថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំម្ដែងអសង្ខតធម៌ គឺ ធម៌ដែលមានបច្ច័យមិនប្រជុំតាក់តែងឡើងដល់អ្នកទាំងឡាយផង តថាគតនឹងសំម្ដែង **សច្ចធម៌** គឺ ធម៌ដែលពិតមែនផង... **បារធម៌** គឺ ធម៌ដែលជាត្រើយផង... **សុទុទ្ទសធម៌** គឺ ធម៌ដែលឃើញដោយលំបាកផង... **អជ្ជរធម៌** គឺ ធម៌ដែលមិនមានជរាផង ... **ធុវធម៌**

គឺ ធម៌ដែលស្ថិតស្ថេរផង... **និប្បបញ្ចធម៌** គឺ ធម៌ដែលមិនមានគ្រឿងធ្វើឲ្យយឺតយូរផង... **អមតធម៌** គឺ ធម៌ដែលមិនស្លាប់ផង... **សិវធម៌** គឺ ធម៌ដែលជាឱកាសទូលាយផង... **ខេមធម៌** គឺ ធម៌ដែលផុតភ័យផង... **អព្ភុតធម៌** គឺ ធម៌ដែលអស្ចារ្យផង... **អនីតិកធម៌** គឺ ធម៌ដែលមិនចម្រូងចម្រាស់ផង... **អព្យាបជ្ឈធម៌** គឺ ធម៌ដែលមិនមានការបៀតបៀនផង... **វិសុទ្ធិធម៌** គឺ ធម៌ដែលមានភាពបរិសុទ្ធផង... **ទីបធម៌** គឺ ធម៌ដូចជាកោះផង... **តាណធម៌** គឺ ធម៌ដែលជាគ្រឿងទប់ទល់ផង... **លេណធម៌** គឺ ជាធម៌ធ្វើទីពួនអំពីទុក្ខផង ដល់អ្នកទាំងឡាយដូច្នេះជាដើម ព្រះយោគាវចរគប្បីរឭកដល់ដោយអំណាចគុណទាំងនោះ ក៏បានដូចគ្នា ។

## មហាដីកា

## អធិប្បាយ ឧបសមានុស្សតិ

ពាក្យថា **តាមប្រការដែលត្រាស់ទុក** គឺ តាមប្រការ គឺ ការរឭករឿយៗនូវគុណ មានវិរាគគុណជាដើម តាមដែលបានត្រាស់ទុក ។ ពាក្យថា **ពោលគឺធម៌ដែលជាទីចូលទៅស្ងប់ទុក្ខទាំងពួង** គឺ ដែលហៅថា **សព្វទុក្ខូបសមោ** ព្រោះអត្ថថា ជាទីចូលទៅស្ងប់ទុក្ខ ដែលមានទុក្ខទុក្ខផ្សេងៗ ជាដើម សូម្បីទាំងពួង ។

សូម្បីវត្ថុដែលមិនមែនសភាវៈក៏ហៅថា **ធម៌** បាន ដូចជាក្នុងពាក្យថា បញ្ញត្តិធម៌ជាដើម ព្រោះអត្ថថា បណ្ឌិតទ្រទ្រង់ទុក គឺ កំណត់បានដោយញាណ ព្រោះហេតុនោះ លោកអាចារ្យ កាលនឹងលើកយកព្រះនិព្វានចេញអំពីធម៌ ដែលមិនមែនជាសភាវៈនោះ ទើបពោលថា **ពាក្យថា ធម៌ទាំងឡាយ** បានដល់ សភាវៈទាំងឡាយដូច្នេះ ។ ការមាន គឺ ភាពជាវត្ថុដែលមានដោយបរមត្ថ ឈ្មោះថា **ភាវ** ,

ឈ្មោះថា **សភាវ** ក៏ព្រោះអត្ថថា ប្រព្រឹត្តទៅនឹងភាវៈ មានសេចក្ដីថា បានដល់វត្ថុដែលរកបានដោយជារបស់មានពិត ជាបរមត្ថ ។ ពិតណាស់ វត្ថុទាំងនោះលោកហៅថា ធម៌ ព្រោះកិរិយាដែលទ្រទ្រង់ទុកនូវសភាវៈរបស់ខ្លួន និងហៅថា **សភាវ** ក៏ដោយអត្ថន័យតាមដែលពោលហើយ ។ បទថា **សង្គម** គឺ គប់រកគ្នាហើយ បានដល់ ប្រជុំគ្នា ដោយការដល់ព្រមគ្នា ដែលមានការតាំងចុះព្រមគ្នានៃបច្ច័យជាលក្ខណៈ ។ បទថា **សមាគម្ម** គឺ មកព្រមគ្នាហើយ ជាពាក្យវេវចនៈនៃបទ ថា **សង្គម** នោះឯង ។ ពាក្យថា **ដែលត្រូវបច្ច័យទាំងឡាយ** បានដល់ បច្ច័យដែលសមគួរទាំងឡាយ ។ ពាក្យថា **សាងឡើង** គឺ ធ្វើឲ្យកើតឡើង ។ ពាក្យថា **មិនសាងឡើង** គឺ ដែលបច្ច័យណាៗ ក៏មិនសាងឡើង ។ ហេតុនៃពាក្យពោលដែលជាពហុវចនៈថា **អសង្ខតា** ខ្ញុំព្រះករុណាបានពោលទុកក្នុងខាងដើមហើយ ។ បទថា **អគ្គមក្ខាយតិ** ពោលបានថា ជាកំពូល កាត់បទថា **អគ្គោ អក្ខាយតិ , ម** អក្ខរៈជាតួធ្វើការភ្ជាប់បទ ។ សភាវធម៌ដែលមានលក្ខណៈជាអសង្ខតៈ នោះគប្បីជឿបានថា ជាវិរាគធម៌ ព្រោះអត្ថថា ជាទីកម្ចាត់សង្កិលេសធម៌ គឺ កន្លែងខ្លះហៅថា ជាទីទៅប្រាសចាករាគៈ ។ ការស្រវឹងទាំងឡាយ មានការស្រវឹង គឺមានះដែលមានការប្រកាន់ខ្លួនជាដើម ព្រោះត្រូវអរិយមគ្គដែលប្រព្រឹត្តទៅធ្វើព្រះនិព្វានឲ្យជាអារម្មណ៍លះហើយ ក៏ឈ្មោះថា ត្រូវលះទៅ ព្រោះដល់នូវព្រះនិព្វាននោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា មកដល់អសង្ខតធម៌នោះ ក៏ត្រូវស្វាងទៅ ។ ល ។ បានដល់ វិនាសទៅដូច្នេះ ។ ក្នុងបទទាំងនោះ មានះដែលប្រព្រឹត្តទៅទាក់ទងនឹងការប្រកាន់ខ្លួនថា យើងល្អជាងជាដើមនោះឯង ឈ្មោះថា **មានមទ** គឺ ការស្រវឹង ឬ ការប្រកាន់ខ្លួន ។ ការស្រវឹងដែលអាស្រ័យភាពជាបុរស

កើតឡើង ឈ្មោះថា **បុរិសមទ** ។ ដោយ **អាទិ** ស័ព្ទ គប្បីឃើញថា លោកសង្គ្រោះយក **ជាតិមទ** គឺ ការស្រវឹងក្នុងជាតិត្រកូលជាដើមផង ។ ពាក្យថា **ស្វាងស្រវឹង** គឺ ការស្រវឹងប្រាសទៅ ។ ក៏ដើម្បីសម្ដែងន័យនេះនោះឯង លោកទើបពោលថា បាត់ស្រវឹង ។ អសង្ខតធម៌ ឈ្មោះថា **មទនិម្មទន** ព្រោះអត្ថថា ជាទីដែលការស្រវឹងទាំងឡាយ ស្វាងទៅ គឺ ដល់នូវភាពបាត់ស្រវឹង ការវិនាសទៅ ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យ ដូច្នេះ ។ ពាក្យថា **ការស្រេកកាម** គឺ សេចក្ដីប្រាថ្នានឹងក្រេបផឹកកាមទាំងឡាយ បានដល់ កាមតណ្ហា ។ កាមគុណនោះឯង ឈ្មោះថា **កាមគុណាលយ** អាល័យ គឺ កាមគុណ ព្រោះអត្ថថា ជាទីដែលសត្វទាំងឡាយមកជាប់ស្អិត ។ ពាក្យថា **វដ្ដៈ ដែលមាននៅក្នុងភូមិ ៣** បានដល់ វដ្ដៈ គឺ កម្ម កិលេស និងវិបាកក្នុងភូមិ ៣ ។ បទថា **ឯសោ** បានដល់ អសង្ខតធម៌ ។ ពាក្យថា **ដើម្បីឲ្យមានការបន្តទៅ** គឺ ដើម្បីឲ្យមានយោនិ គឺ កំណើតជាដើមបន្តៗទៅអំពីយោនិជាដើម ។ ឈ្មោះថា **កិរិយាដែលចង** បានដល់ កិរិយាដែលធ្វើឲ្យជាកំណួច ។ ឈ្មោះថា **កិរិយាដែលដេរ** បានដល់ កិរិយាដែលដោតក្រង ។ ក៏ឈ្មោះថា ការចេញ និងការលោស់ចេញ នៃអសង្ខតធម៌នេះ បានដល់ ការឃ្លាតចាកតណ្ហានោះឯង ព្រោះហេតុនោះ លោកទើបពោលថា ឃ្លាតចាកដូច្នេះ ។

ឈ្មោះទាំងឡាយ មានឈ្មោះថា **មទនិម្មទន** ជាដើម និយមប្រើក្នុងព្រះនិព្វាន ព្រោះធ្វើគុណទាំងឡាយពួកណាឲ្យជាហេតុ លោកអាចារ្យកាន់យកគុណរបស់ព្រះនិព្វានដែលធ្វើឲ្យកើតឡើងហើយ ដែលមានភាពជាធម៌ ដែលស្វាងស្រវឹងជាដើមតាមដែលពោលហើយទាំងនោះៗ ឯង ពោលថា ដោយទាក់ទងនឹងគុណមានភាពជាធម៌ដែលស្វាងស្រវឹងជាដើមដូច្នេះ តែលោកមិនបានកាន់យកគុណ មាន

យ៉ាងនេះថា ធម៌ជាគ្រឿងញ៉ាំញីការស្រវឹងជាដើម ។ ព្រោះថា **គុណ** គឺ ធម៌ជាគ្រឿងញ៉ាំញីការស្រវឹង គង់ហៅថា **មទនិម្មទន** ដូចគ្នាជាដើមទាំងនោះ ជាគុណរបស់អរិយមគ្គ ។ ភ្ជាប់សេចក្ដីថា **ភគវតា ឧបសមគុណាវុត្តា** ។ សួរថា តើត្រាស់ទុកក្នុងទីណា ? ឆ្លើយថា ត្រាស់ទុកក្នុង **អសង្ខតសំយុត្ត** ជាដើម ។ ក្នុងឧបសមគុណទាំងនោះ ពាក្យថា **សច្ចធម៌** គឺ ធម៌ដែលមិនមែនមិនពិត ។ ពិតណាស់ ព្រះនិព្វាន ឈ្មោះថា **សច្ចៈ** ដោយន័យថា មិនវិបរិត ព្រោះភាពជាធម៌ដែលស្ងប់តែម្យ៉ាងនោះឯង ព្រោះមិនមានការមិនស្ងប់ដោយបរិយាយណា ៗ ។ ព្រោះហេតុនោះ លោកទើបពោលទុកថា **សច្ចៈមានតែ ១** សច្ចៈទី ២ មិនមាន។ ពាក្យថា **បារធម៌** គឺ ធម៌ដែលជាត្រើយនាយនៃសង្សារវដ្ដ ។ ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ទុកថា **ចូងបានហើយដល់ត្រើយនាយ ឈរនៅលើគោកជាព្រាហ្មណ៍** ដូច្នេះ និងថា ក្នុងពពួកមនុស្សទាំងឡាយ ដែលជនជាអ្នកដល់ត្រើយនាយមានចំនួនតិចដូច្នេះ ។ ពាក្យថា **សុទុទ្ទសធម្ម** គឺ ធម៌ដែលឃើញបានសែនលំបាក ព្រោះបុគ្គលដែលមិនបានសន្សំញាណសម្ភារទុក មិនអាចនឹងឃើញបាន ព្រោះជាធម៌ដ៏ជ្រាលជ្រៅក្រៃលែង និង ជាធម៌ដែលមានសភាវធម៌ស្ងប់ដ៏យ៉ាងក្រៃលែង ។ ឈ្មោះថា **អជ្ជរធម៌** ព្រោះអត្ថថា ជាធម៌ដែលមិនមានជរា ឬថា បុគ្គលកាលបានសម្រេចធម៌នេះហើយ ក៏មិនមានជរា ។ ព្រោះហេតុនោះៗ ឯង ទើបឈ្មោះថា **ធុវធម៌** ដោយន័យថា មាំទាំ ព្រោះភាពដែលមិនទ្រុឌទ្រោមទៅ ព្រោះហេតុ មានជរាជាដើម ។ ឈ្មោះថា **និប្បបញ្ចធម៌** ព្រោះមិនមានគ្រឿងយឺតយូរ មានតណ្ហាជាដើម ។ ឈ្មោះថា **អមតធម៌** ព្រោះអត្ថថា មិនមានសេចក្ដីស្លាប់ ។ ឈ្មោះថា **សិវធម៌** ព្រោះមិនមានសង្កិលេសធម៌ទាំងឡាយ ដែលជាតួសាងភាពចង្អៀតចង្អល់។

ឈ្មោះថា **ខេមធម៌** ព្រោះមិនត្រូវយោគៈ ៤ ធ្វើឲ្យអន្តរាយ ។ ឈ្មោះថា **អព្ភុតធម៌** ព្រោះភាពជាធម៌ដែលគួរអស្ចារ្យដោយភាពជាវិសេសនិង ព្រោះភាពជាធម៌ដែលមិនធ្លាប់មានមកពីមុន គឺ មុនការឧប្បត្តិនៃព្រះពុទ្ធជាម្ចាស់ ។ ឈ្មោះថា **អនីតិកធម៌** ព្រោះមិនមានចង្រៃចង្រាស់ និង ភាពវិនាសទាំងឡាយ ។ ឈ្មោះថា **អព្យាបជ្ឈធម៌** ព្រោះជាធម៌ដែលមិនមានទុក្ខ ។ ឈ្មោះថា **វិសុទ្ធិធម៌** ព្រោះអត្ថថាជាសភាពបរិសុទ្ធដោយវិសេស ព្រោះបរិសុទ្ធចាកមន្ទិល គឺ សង្កិលេសទាំងឡាយពិតប្រាកដ ។ ឈ្មោះថា **ទីបធម៌** ព្រោះភាពដែលឱឃៈទាំង ៤ មិនអាចជន់លិចបាន ។ ឈ្មោះថា **តាណធម៌** ដោយន័យថា អភិបាលរក្សាទុកអំពីទុក្ខក្នុងវដ្តៈទាំងអស់ ។

ព្រះបាលីដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងសច្ចធម៌ដល់ពួកអ្នកផង ដូច្នេះជាដើម គប្បីជ្រាបថា លោកអាចារ្យបំព្រួញទុក ។ ដោយ **អាទិ** សព្ទ ( ប្រែថា ជាដើម ) សង្គ្រោះយកគុណទាំងឡាយដែលមិនបានពោលទុកក្នុងទីនេះ ដែលទ្រង់ប្រាប់ឲ្យដឹងដោយពាក្យថា **អនន្ត** គឺ មិនមានទីបំផុត , **អនាសវ** គឺ មិនមានអាសវៈ , **និបុន** គឺ ល្អិតល្អន់ , **អជ្ជរ** គឺ មិនគ្រាំគ្រា , **អបលោកិក** គឺ មិន ទ្រុឌទ្រោម , **អនិទស្សន** គឺ ឃើញមិនបាន , **បណីត** គឺ ប្រណីត, **អច្ឆរិយ** គឺ គួរអស្ចារ្យ , **អនីតិកធម៌** គឺ មិនមានចង្រៃចង្រាស់, **មុត្តិ** គឺ ជាហេតុរួចផុត, **លេណ** គឺ ជាទីពួនសំងំ , **បរាយន** ជាទីទៅខាងមុខ , **គម្ភីរ** គឺ ជ្រាលជ្រៅជាដើម ក្នុងគុណទាំងនោះ បណ្ឌិតគប្បីជ្រាបន័យយ៉ាងនេះថា **អសង្ខតធម៌** ឈ្មោះថា **អនន្ត** ព្រោះអត្ថថា មិនមានទីបំផុត គឺការកើតឡើង ឬ ទីបំផុតគឺការរលត់ទៅ ។ ឈ្មោះថា **អនាសវ** ព្រោះមិនមែនជាអារម្មណ៍របស់អាសវៈ ,

ឈ្មោះថា **និបុន** ត្រូវជាគោចរនៃញាណដ៏ល្អិតសុខុម ។ ឈ្មោះថា **អជ្ជរ** ព្រោះភាពដែលមិនត្រូវជរាធ្វើឲ្យគ្រាំគ្រាដូចសង្ខតធម៌ ។ ឈ្មោះថា **អបលោកិក** ព្រោះភាពដែលមិនត្រូវទុក្ខធម៌ មានព្យាធិជាដើម ធ្វើឲ្យទ្រុឌទ្រោមទៅ ។ ឈ្មោះថា **អនិទស្សន** ព្រោះភាពដែលមិនអាចដឹងបានដោយចក្ខុវិញ្ញាណ ។ ឈ្មោះថា **បណីត** ដោយន័យថា ធ្វើមិនឲ្យចេះឆ្អែត ។ ឈ្មោះថា **អច្ឆរិយ** ព្រោះភាពដែលមិនផ្សព្វផ្សាយច្រើន ឈ្មោះថា **អនីតិកធម៌** ព្រោះជាសភាវៈដែលចម្រូងចម្រាស់ ឬចង្រៃឧបទ្រពអពមង្គលទាំងឡាយ គ្រប់សង្កត់មិនបាន និង ព្រោះជាហេតុនៃការមិនមានភាពចម្រូងចម្រាស់ ។ ឈ្មោះថា **មុត្តិ** ព្រោះជាហេតុផុតចាកវដ្តទុក្ខ ។ ឈ្មោះថា **លេណ** ព្រោះជាទីដែលបុគ្គលទាំងឡាយ ឃើញសង្សារវដ្តថាជាភ័យគប្បីជ្រកកោន ។ ឈ្មោះថា **បរាយន** ព្រោះជាទីទៅខាងមុខនៃបុគ្គលដែលឃើញសង្សារវដ្តថាជាភ័យ ទាំងនេះ នោះឯង ។ ឈ្មោះថា **គម្ភីរ** ដោយន័យថា ស្ទង់ដល់មិនបាន ព្រោះភាពជាទីតាំងដែលនរណា មិនបានដោយបកតិញ្ញាណ ។ ឈ្មោះថា **ទុរនុពោធ** ព្រោះជាធម៌ដែលបុគ្គល សូម្បីថា បានធ្វើបុណ្យទុកហើយ ក៏នៅតាមដឹងបានដោយកម្រ គឺ លំបាក ។ ឈ្មោះថា **អតក្កាវចរ** គឺ មិនមែនធម៌ដែលគប្បីអាស្រ័យនៅនឹងញាណជាគ្រឿងត្រិះរិះ ព្រោះអត្ថថា ផុតចាកការធ្វើឲ្យជាក់ច្បាស់ហើយ ក៏មិនមែនជាធម៌ដែលត្រូវអាស្រ័យនឹងញាណជាគ្រឿងត្រិះរិះ ។ ឈ្មោះថា **បណ្ឌិតវេទនីយ** គឺ ធម៌ដែលអ្នកជាបណ្ឌិតគប្បីដឹង ព្រោះជាធម៌ដែលអ្នកជាបណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមប៉ុណ្ណោះ គប្បីដឹង គឺ គប្បីសម្រេច ។

( ចប់ មហាដីកា )

# អានិសង្សនៃឧបសមានុស្សតិ

កាលលោករឭកដល់ឧបសមៈដោយអំណាចគុណ មានភាពជាទីស្វាងស្រវឹងជាដើមយ៉ាងនេះ ក្នុងសម័យនោះ ចិត្តរបស់លោកមិនត្រូវរាគៈហ៊ុមព័ទ្ធ... មិនត្រូវទោសៈហ៊ុមព័ទ្ធ... មិនត្រូវមោហៈហ៊ុមព័ទ្ធ...ឡើយ ក្នុងសម័យនោះ ចិត្តរបស់លោកជាចិត្តដំណើរត្រង់ បែរមុខចំពោះឧបសមៈយ៉ាងប្រាកដ អង្គឈានទាំងឡាយរមែងកើតឡើងដល់លោកដែលសង្កត់នីវរណធម៌បានហើយ ក្នុងខណៈតែមួយតាមន័យដែលពោលហើយក្នុងអនុស្សតិមុនៗ មានពុទ្ធានុស្សតិជាដើម តែព្រោះភាពដែលឧបសមគុណទាំងឡាយ ជាគុណដ៏ជ្រៅ ឬ ព្រោះចិត្តដែលបង្អោនទៅក្នុងការរឭកដល់គុណ មានប្រការផ្សេងៗគ្នា ឈាននេះទើបជាឈានមិនដល់អប្បនាដល់ត្រឹមឧបចារៈប៉ុណ្ណោះ ឈាននេះនោះក៏បានឈ្មោះថា ឧបសមានុស្សតិនោះឯងព្រោះកើតឡើង ដោយអំណាចការរឭកដល់គុណនៃឧបសមៈ និង សូម្បីឧបសមានុស្សតិនេះ ក៏រមែងសម្រេចដល់ព្រះអរិយសាវកប៉ុណ្ណោះ ដូចគ្នានឹងឆអនុស្សតិដែលពោលហើយ សូម្បីដូច្នោះ សូម្បីបុថុជ្ជនដែលធ្ងន់ក្នុងឧបសមៈក៏គួរមនសិការដែរ ព្រោះសូម្បីដោយអំណាចការស្តាប់ ចិត្តក៏ជ្រះថ្លាក្នុងឧបសមៈបាន ។

រីឯភិក្ខុដែលប្រកបដោយឧបសមានុស្សតិនេះ រមែងដេកលក់ជាសុខ ភ្ញាក់ជាសុខ ជាអ្នកមានឥន្ទ្រិយស្ងប់ មានចិត្តស្ងប់ ដល់ព្រមដោយហិរិឱត្តប្បៈគួរជ្រះថ្លា មានអធ្យាស្រ័យប្រណីត ជាទីគោរព និង លើកសរសើរនៃសព្រហ្មចារីទាំងឡាយ ម្យ៉ាងទៀត កាលនៅមិនទាន់សម្រេចគុណដែលខ្ពស់ឡើងទៅ រមែងជាបុគ្គលមានសុគតិជាទីទៅខាងមុខ ។

ព្រោះហេតុនោះឯង បណ្ឌិតអ្នកឃើញច្បាស់ គប្បីជាអ្នកមិនប្រមាទ ចម្រើននូវការរឭកក្នុងអរិយឧបសមៈ ដែលមានអានិសង្សជាអនេក ដូចពោលមកដូច្នេះ នេះជាកថាមុខដោយពិស្តារក្នុងឧបសមានុស្សតិ ។

## មហាដីកា

ឈ្មោះថា **រមែងសម្រេចដល់ព្រះអរិយសាវកតែប៉ុណ្ណោះ** ព្រោះភាពដែលគុណទាំងឡាយរបស់ព្រះនិព្វានប្រាកដហើយ ដោយអំណាចការត្រាស់ដឹង គឺធ្វើឲ្យជាក់ច្បាស់ ។ ក៏ **ឯវ** ស័ព្ទ ដែលប្រែថា មែនពិតនេះ លោកពោលទុកខុសពីទីទៅ ត្រូវប្រកបថា **ឥជ្ឈតិ ឯវ** ។ ម្យ៉ាងទៀត លោកពោលទុកយ៉ាងនេះថា **អរិយសាវកស្សេវ** ក៏ទាក់ទងនឹងការសម្រេចបានដោយងាយ ។ព្រោះហេតុនោះឯង ទើបពោលថា សូម្បីថាជាយ៉ាងនេះដូច្នេះជាដើម ។ ពាក្យថា **ដែលធ្ងន់ក្នុងឧបសមធម៌** គឺ បុថុជ្ជនដែលបង្អោនចិត្តទៅក្នុងព្រះនិព្វាន ។ ក៏គប្បីមនសិការឧបសមគុណទាំងឡាយ តាមដែលពោលហើយ ។ ពាក្យដែលគួរពោលអធិប្បាយក្នុងពាក្យថា រមែងលក់ជាសុខជាដើម នឹងមានច្បាស់ក្នុងកថាពោលដោយមេត្តា ។ កិត្តុឈ្មោះថាជាអ្នកមានអធិមុត្តិដ៏ប្រណីត ក៏ព្រោះមានភាវៈដែលចិត្តបង្អោនទៅក្នុងព្រះនិព្វាន ។

បរិច្ឆេទទី ៨

ឈ្មោះ អនុស្សតិកម្មដ្ឋាននិទ្ទេស ក្នុង

អធិការនៃសមាធិភាវនា ក្នុងបករណ៍វិសេស ឈ្មោះ

វិសុទ្ធិមគ្គដែលខ្ញុំម្ចាស់ធ្វើដើម្បីប្រយោជន៍ដល់បាមោជ្ជនៃសាធុជនដូច្នេះឯង ។

# ព្រហ្មវិហារនិទ្ទេស

------◎------

## មេត្តាព្រហ្មវិហារ

រីឯក្នុងព្រហ្មវិហារ ៤ នេះ គឺ **មេត្តា ករុណា មុទិតា ឧបេក្ខា** ដែលលោកលើកឡើងសម្តែងទុកក្នុងលំដាប់នៃអនុស្សតិកម្មដ្ឋាន ព្រះអាទិកម្មិកយោគាវចរដែលប្រាថ្នានឹងចម្រើនមេត្តាព្រហ្មវិហារ ជាលំដាប់ដំបូង គប្បីជាអ្នកកាត់បលិពោធ កាន់យកកម្មដ្ឋានហើយ ធ្វើភត្តកិច្ច បន្ទោបង់សេចក្តីស្រវឹងក្នុងអាហារហើយ អង្គុយឲ្យសប្បាយ គឺ តាមបែបអង្គុយកម្មដ្ឋានក្នុងអាសនៈ ដែលរៀបចំទុកយ៉ាងល្អក្នុងទីស្ងាត់ ថ្នាក់ដំបូងគប្បីពិចារណាឲ្យឃើញទោសក្នុងទោសៈ និង អានិសង្សក្នុងខន្តីមុន ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះទោសៈគប្បីលះបង់បាន និង ខន្តីគប្បីសម្រេចបាន ក៏ដោយការនានេះ និងមិនមាននរណាអាចនឹងលះទោស ដែលខ្លួនមិនឃើញត្រឹមបន្តិចបន្តួច ឬ បានអានិសង្ស ដែលខ្លួនមិនជ្រាបត្រឹមបន្តិចបន្តួចបានឡើយ ព្រោះហេតុនោះព្រះយោគាវចរគប្បីឃើញទោសក្នុងទោសៈ តាមគន្លងព្រះសូត្រទាំងឡាយ ដូចជាសូត្រថា ម្នាលភិក្ខុទាំងឡាយ បុគ្គលដែលកើតទោសៈហើយ ដែលទោសៈគ្របសង្កត់ មានចិត្តត្រូវទោសៈប្រកាន់ទុកហើយ រមែងសម្លាប់សត្វខ្លះ ដូច្នេះជាដើមគប្បីជ្រាបអានិសង្សក្នុងខន្តីតាមគន្លងព្រះបាលីទាំងឡាយ ដូចបាលីថា ៖

**ខន្តិ បរមំ តបោ តីតិក្ខា និព្វានំ បរមំ វទន្តិ ពុទ្ធា**

**ខន្តិ** គឺ សេចក្តីអត់ធន់ ជាតបធម៌ដ៏ឧត្តម ព្រះពុទ្ធទាំងឡាយទ្រង់ត្រាស់ថា ព្រះនិព្វានជាគុណជាតិដ៏ឧត្តម ។

**ខន្តិ ពលំ ពលានីកំ តមហំ ព្រូមិ ព្រាហ្មណំ**

តថាគតពោលចំពោះបុគ្គលនោះ ដែលមានខន្តីជាកម្លាំង មានកម្លាំង គឺ ខន្តីជាកងទ័ព ថាជាព្រាហ្មណ៍ ។

**ខន្ត្យា ភិយ្យោ ន វិជ្ជតិ**

ប្រយោជន៍ក្រៃលែងជាងខន្តីមិនមាន ដូច្នេះជាដើមចុះ ។

បន្ទាប់មកគប្បីផ្តើមមេត្តាភាវនា ដើម្បីញ៉ាំងចិត្តឲ្យស្ងប់ចាកទោសៈមានទោសដែលខ្លួនបានឃើញហើយ គប្បីចងចិត្តទុកក្នុងខន្តី មានអានិសង្សដែលខ្លួនជ្រាបហើយយ៉ាងនេះតទៅ ។

## បុគ្គលដែលជាទោសដល់ភាវនា៦

កាលនឹងផ្តើមខាងដើមនោះឯង គួរជ្រាបបុគ្គលទោស គឺ បុគ្គលដែលជាទោសដល់ភាវនាថា ក្នុងបុគ្គលទាំងនោះមិនគួរចម្រើនមេត្តាទៅជាបឋម ក្នុងបុគ្គលទាំងនោះមិនគួរចម្រើនមេត្តាទៅឡើយនោះឯង មែនពិត មេត្តានេះមិនគួរចម្រើនជាបឋមក្នុងបុគ្គល ៤ នេះ គឺ ក្នុងបុគ្គលដែលស្អប់គ្នា ក្នុងបុគ្គលដែលស្រឡាញ់គ្នាខ្លាំង ក្នុងបុគ្គលដែលជាកណ្តាលៗនឹងគ្នា ក្នុងបុគ្គលដែលជាសត្រូវនឹងគ្នា ចំណែកក្នុងបុគ្គលដែលមានភេទផ្ទុយគ្នា មិនគួរចម្រើនដោយចោះចំពោះ ក្នុងបុគ្គលដែលធ្វើកាលកិរិយាហើយ មិនគួរចម្រើនតែម្តង ។

សួរថា ព្រោះហេតុអ្វីទើបមិនគួរចម្រើនទៅក្នុងបុគ្គល ៤ ប្រភេទ មានបុគ្គល

ដែលស្អប់គ្នាជាដើមជាដំបូង ?

ឆ្លើយថា ព្រោះថា ព្រះយោគាវចរកាលនឹកតាំងបុគ្គលដែលស្អប់គ្នាទុកក្នុងឋានៈនៃបុគ្គលជាទីស្រឡាញ់រមែងលំបាកចិត្ត កាលនឹកតាំងសម្លាញ់ដែលស្រឡាញ់គ្នាខ្លាំង ទុកក្នុងឋានៈនៃបុគ្គលកណ្តាលៗ ក៏លំបាក ទោះជាទុក្ខសូម្បីបន្តិចបន្តួចកើតឡើងដល់គេ លោកនឹងដល់នូវការយំចេញមកក៏ថាបាន កាលនឹកតាំងបុគ្គលកណ្តាលៗ ទុកក្នុងឋានៈនៃគ្រូ និងក្នុងឋានៈនៃបុគ្គលជាទីស្រឡាញ់ក៏លំបាក កាលរឭកដល់បុគ្គលដែលជាសត្រូវនឹងគ្នា សេចក្តីក្រោធរមែងកើតឡើង ព្រោះហេតុនោះទើបមិនគួរចម្រើនទៅក្នុងបុគ្គល ៤ ប្រភេទ មានបុគ្គលស្អប់ជាដើមជាដំបូង ។

ចំណែកក្នុងបុគ្គលដែលមានភេទផ្ទុយគ្នា កាលចម្រើនដោយចោះចំពោះដល់បុគ្គលដែលមានភេទផ្ទុយគ្នានោះ តម្រេករមែងកើតឡើង ដូចមានរឿងពោលថា កូននាហ្មឺនម្នាក់នឹកចង់ចម្រើនមេត្តា សួរព្រះជីតុនថា លោកម្ចាស់ មេត្តាគួរចម្រើនក្នុងបុគ្គលណា ? ព្រះថេរៈប្រាប់ដោយមិនអស់សេចក្តីថា ក្នុងបុគ្គលដែលជាទីស្រឡាញ់ ភរិយារបស់ខ្លួន គឺជាទីស្រឡាញ់របស់គេ ទើបចម្រើនមេត្តាដល់នាងក៏ត្រូវធ្វើការទម្លាយជញ្ជាំងមួយយប់ទល់ភ្លឺ ព្រោះដូច្នោះ ក្នុងបុគ្គលដែលមានភេទផ្ទុយគ្នា ទើបមិនគួរចម្រើនដោយចោះចំពោះ ។

ចំណែកក្នុងបុគ្គលដែលធ្វើកាលកិរិយាហើយ ចម្រើនទៅក៏មិនដល់អប្បនា មិនដល់ឧបចារៈបានឡើយ មានរឿងពោលថា ភិក្ខុកំលោះមួយរូបធ្វើមេត្តាភាវនាដល់អាចារ្យ មេត្តាប្រព្រឹត្តទៅមិនបាន លោកទើបទៅរកព្រះមហាថេរៈមួយរូប សួរថា លោកដ៏ចម្រើន ការចូលមេត្តាឈានរបស់ខ្ញុំព្រះករុណាស្ទាត់ជំនាញហើយដែរ តែពេលនេះខ្ញុំព្រះករុណាមិនអាចចូលមេត្តាឈាននោះបាន ព្រោះហេតុអ្វី ? ព្រះថេរៈ

ដីកនាំថា លោកចូររកនិមិត្តមើលចុះ អាវុសោ ភិក្ខុនោះរកនិមិត្តមើលទៅ ទើបដឹងភាពដែលអាចារ្យដល់មរណភាពហើយ ក៏ធ្វើមេត្តាដល់អ្នកដទៃតទៅ ទើបញ៉ាំងសមាបត្តិឲ្យជាក់ច្បាស់បាន ព្រោះហេតុនោះ មិនគួរចម្រើនទៅក្នុងបុគ្គលដែលធ្វើកាលកិរិយាហើយនោះទេ ។

# មហាដីកា
# ពណ៌នា ព្រហ្មវិហារនិទ្ទេស

## ការចម្រើនមេត្តា

បុគ្គលប្រាថ្នាចម្រើនព្រហ្មវិហារ គឺ មេត្តា ។ ពាក្យថា **អ្នកប្រាថ្នាចម្រើន** គឺ អ្នកប្រាថ្នាធ្វើឲ្យកើតឡើង ភ្ជាប់ចូលនឹងពាក្យថា **បច្ចវេក្ខិតព្វោ** គឺ គប្បីពិចារណា។ ពាក្យថា **អន្ទុយជាសុខ** គឺ កុំអន្ទុយមិនរៀបរយ អន្ទុយជាសុខដោយអាការពែនភ្នែន ។

ពាក្យថា **ព្រោះហេតុអ្វី ជាពាក្យសួរដល់ហេតុនៃការពិចារណា** អធិប្បាយថា ការដែលភិក្ខុអ្នកប្រាថ្នាសម្រេចធម៌យ៉ាង ត្រឡប់ពិចារណាទោស និងអានិសង្សក្នុងធម៌យ៉ាងទៀត មានប្រយោជន៍អ្វី ។ ឈ្មោះថា **មេត្តា** ដោយសភាវៈក៏បានដល់អទោសៈ ។ ពិតហើយ ក្នុងពាក្យសម្ដែងខៃមេត្តា ទ្រង់សម្ដែងខៃទុកហើយថា មេត្តី អាការដែលស្រឡាញ់ ភាពជាបុគ្គលដែលព្រមព្រៀងដោយសេចក្ដីស្រឡាញ់ដូច្នេះ ។ ចំណែកពាក្យថា ខន្តីក្នុងទីនេះ បំណងយកអធិវាសនខន្តី ( ខន្តី គឺការអត់ធន់ ការព្រមទទួល ) ។ ខន្តីនោះ ដោយសភាវៈ បានដល់ នាមក្ខន្ធ ៤ ដែលមាន

អទោសៈជាប្រធាន ព្រោះហេតុនោះ កាលសម្រេចមេត្តា ក៏ជាការសម្រេចការអត់ធន់ គឺ ខន្តីនោះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ដែលគប្បីសម្រេចខន្តីបាន ដូច្នេះ ។ ដោយពាក្យនោះលោកសម្តែងថា ការពិចារណាអានិសង្សក្នុងខន្តីមានប្រយោជន៍ពិតមែន ។ ឈ្មោះថា **ត្រូវទោសៈគ្របសង្កត់** ក៏ដោយអាការរួបរឹត ។ ឈ្មោះថា **មានចិត្តត្រូវទោសៈប្រកាន់ទុក** ក៏ដោយអាការដែលមិនបានឱកាសនៃការប្រព្រឹត្តទៅរបស់កុសល ។ ឈ្មោះថា **គប្បីឃើញទោសក្នុងទោសៈ** ក៏ដោយភាពដែលវាជាមូលនៃហាយនភាព ដែលមានក្នុងអត្តភាពនេះ និងដែលមានក្នុងពេលខាងមុខជាដើម ដោយទាក់ទងនឹងហេតុនាំឲ្យសម្លាប់សត្វជាដើម ។

ពាក្យថា **ខន្តិ** គឺ ការអត់ធន់ ជាតបធម៌ដ៏ឧត្តម មានសេចក្តីថា ខន្តីដែលមានអាការអត់ធន់ជាលក្ខណៈ មានការអត់ធន់ចំពោះការធ្វើផ្សេងៗ របស់អ្នកដទៃជាដើម ជាតបធម៌ដ៏ឧត្តម ព្រោះជាមូលនៃការបដិបត្តិត្រូវ ដែលមានការមិនធ្វើកម្មដែលមិនគួរធ្វើ និងការធ្វើកម្មដែលគួរធ្វើជាលក្ខណៈ ។ ពាក្យថា **ខន្តិ ពលំ ពលានីកំ** មានសេចក្តីថា ឈ្មោះថា **ខន្តិ ពលំ** ព្រោះអត្ថថា មានខន្តីដែលជាមន្តលដ៏ឧត្តមនោះឯងជាកម្លាំង ។ សមពិតតាមដែលត្រាស់ទុកថា សមណៈ និងព្រាហ្មណ៍ទាំងឡាយមានខន្តីជាកម្លាំងដូច្នេះ ។ និងឈ្មោះថា **ពលានីកំ** គឺមានកម្លាំងជាកងទ័ព ក៏ដោយកម្លាំង គឺ ខន្តីនោះៗ ឯង ដែលជាកងទ័ព ព្រោះអាចកម្ចាត់ធម៌ដែលជាបដិបក្ខ មានទោសៈជាដើម ។ ពាក្យថា **ទីពឹងក្រៃលែងជាងខន្តីមិនមាន** មានសេចក្តីថា ទីពឹងរបស់ខ្លួន និងមនុស្សពួកដទៃដែលការពារហាយនភាពបានព្រមទាំងនាំទៅកាន់ប្រយោជន៍បានក្រៃលែងជាងខន្តី មិនមាន ។

ពាក្យថា **ដើម្បីប្រយោជន៍ដល់ការធ្វើចិត្តឲ្យស្ងាត់** គឺដើម្បីប្រយោជន៍ដល់ការ

គ្របសង្កត់ចិត្ត ។ អធិប្បាយថា ដើម្បីប្រយោជន៍ដល់ការចងខ្ញុំទុកនឹងខន្តី ។ បុគ្គលទាំងឡាយឈ្មោះថា ជាទោសក៏ព្រោះអត្ថថា ធ្វើការនាំឲ្យសាបសូន្យ បុគ្គលទាំងឡាយនោះឯងជាទោស ទើបឈ្មោះថា **បុគ្គលទោសា** គឺបុគ្គលដែលជាទោស។ គឺថាការនាំមិនសម្រេច រមែងវិបរិតទៅជាប្រាកដ ព្រោះបុគ្គលពួកណា លោកក៏ពោលសំដៅយកបុគ្គលទាំងនោះៗ ឯង ។ ពាក្យថា **ជាលំដាប់ដំបូង** គឺ មិនគួរចម្រើនមេត្តាទៅមុន វៀរតែដោយន័យដែលយកមនុស្សមួយពួកទៅធៀបនឹងមនុស្សមួយពួកទៀត ដែលលោកនឹងពោលដល់ ។

បុគ្គលដែលគេគប្បីស្រឡាញ់រាប់អាន ឈ្មោះថា **បិយ** គឺបុគ្គលជាទីស្រឡាញ់ ដែលផ្ទុយគ្នានឹងបុគ្គលជាទីស្រឡាញ់គ្នា ក៏ឈ្មោះថា **អប្បិយ** គឺបុគ្គលសម្អប់ ។ អប្បិយបុគ្គលនោះដោយសង្ខេបមាន ២ ប្រភេទ គឺបុគ្គលដែលមិនធ្វើប្រយោជន៍ឲ្យ និងបុគ្គលដែលសាងតែហាយនភាពឲ្យ ។ ក្នុង ២ ប្រភេទនោះ អ្នកដែលសាងតែភាពហាយនៈឲ្យដល់ខ្លួន និង ដល់អ្នកជាទីស្រឡាញ់ គប្បីឃើញថា ឈ្មោះថាបុគ្គលដែលមានពៀរនឹងគ្នា ។ ចំណែកបុគ្គលដែលមិនធ្វើប្រយោជន៍ឲ្យដល់ខ្លួន និងបុគ្គលជាទីស្រឡាញ់ ធ្វើតែប្រយោជន៍ឲ្យដល់បុគ្គលជាទីស្អប់ ដែលជាអាឃាតវត្ថុ ដោយន័យថា គេមិនបានប្រព្រឹត្តប្រយោជន៍ដល់យើងជាដើម និង ដោយន័យថា គេបានប្រព្រឹត្តប្រយោជន៍ដល់បុគ្គលដែលយើងស្អប់ យើងមិនពេញចិត្តដូច្នេះជាដើម ក៏ឈ្មោះថា បុគ្គលជាទីស្អប់នោះឯង ន័យថា ជាបុគ្គលដែលមានការប្រព្រឹត្តមិនសមគួរ ជាបុគ្គលមិនគួរប្រាថ្នា ។ ពាក្យថា **ក្នុងបុគ្គលដែលមានភេទផ្ទុយគ្នា** គឺក្នុងបុគ្គលដែលមិនដូចគ្នាដោយភេទ មានភេទស្រីជាដើម ។ ពាក្យថា **ដោយចោះចំពោះ** គឺ ដែលជាចំណែកមួយ ។ សំដៅសេចក្ដីថា ប្រារព្ធយកបុគ្គលដោយន័យ

ថា **នាយតិស្សៈ នាយទត្តៈ** ជាដើម ។

ឥឡូវនេះ លោកអាចារ្យកាលនឹងសម្តែងហេតុនៃភាពដែលមិនគួរចម្រើនទៅក្នុងបុគ្គល ៦ ជំពូក តាមដែលពោលហើយ ទើបពោលថា ព្រោះថា កាលនឹងតាំងបុគ្គលដែលស្អប់ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា កាលនឹងតាំងបុគ្គលដែលស្អប់ទុកក្នុងឋានៈនៃបុគ្គលដែលជាទីស្រឡាញ់ រមែងលំបាក លោកពោលដល់ភាវនាមានអន្តរាយដោយទោសៈ , ព្រោះថា ការស្អប់ជាបដិបក្ខចំពោះសេចក្តីស្រឡាញ់ និងកាលតាំងបុគ្គលដែលស្អប់នោះ ទុកក្នុងឋានៈបុគ្គលជាទីស្រឡាញ់ហើយ ភាវនាក៏នឹងសម្រេចមិនបាន ។ ពាក្យថា កាលនឹងតាំងបុគ្គល ដែលជាទីស្រឡាញ់ក្រៃលែងទុកក្នុងឋានៈនៃបុគ្គលកណ្តាលៗ រមែងលំបាក លោកពោលដល់ភាពដែលភាវនា មានការអន្តរាយដោយរាគៈ ព្រោះសម្មាញ់ជាទីស្រឡាញ់ក្រៃលែង ជាទីតាំងនៃសេចក្តីស្រឡាញ់ប្រភេទអាស្រ័យផ្ទះ ។ ព្រោះហេតុនោះ លោកទើបពោលថា ដោយថា កាលទុក្ខសូម្បីបន្តិចបន្តួចដូច្នេះជាដើម ។ ឈ្មោះថា **បុគ្គលដែលជាកណ្តាលៗ** បានដល់ បុគ្គលដែលមានសភាវៈជាកណ្តាល អំពីភាពជាបុគ្គលជាទីប្រាថ្នា និងមិនគួរប្រាថ្នា មានសេចក្តីថា បុគ្គលដែលមិនស្រឡាញ់មិនស្អប់ ។ ឈ្មោះថា កាលនឹងតាំងទុកក្នុងឋានៈនៃបុគ្គលដែលគួរគោរព និងក្នុងឋានៈនៃបុគ្គលជាទីស្រឡាញ់ រមែងលំបាក ព្រោះក្នុងបុគ្គលដែលជាកណ្តាល មិនបានមានភាពជាបុគ្គលគួរលើកសរសើរ និងបុគ្គលជាទីស្រឡាញ់ ។ ពិតណាស់ ក្នុងបុគ្គលដែលយើងគប្បីព្រងើយកន្តើយ រមែងមិនប្រាកដដល់ភាពជាបុគ្គលគួរលើកសរសើរ ឬ ភាពជាបុគ្គលគួរពេញចិត្ត តែថា ព្រះយោគីនឹងត្រូវចម្រើនមេត្តា ក្នុងបុគ្គលដែលដល់ព្រមដោយភាពគួរស្រឡាញ់ និង គួរគោរពមុន ។ ឈ្មោះថា

សេចក្ដីក្រោធក៏នឹងកើតឡើង ក៏ព្រោះការមិននាំចូលទៅកាន់ភាពជាបុគ្គលចំណែកមួយ គឺ គប្បីផ្សាយមេត្តាបាន ។

ពាក្យថា **ដោយបោះចំពោះប្រាវព្ធយកបុគ្គលនោះប៉ុណ្ណោះ** គឺបុគ្គលដែលមានភេទខុសគ្នាប៉ុណ្ណោះ ។ ដោយពាក្យថា **ក្នុងបុគ្គលដែលមានភេទខុសគ្នា** លោកពោលថា ក្នុងបុគ្គលដែលជាទីស្រឡាញ់ មិនបានធ្វើឲ្យប្លែកគ្នា ។ ពាក្យថា **បានធ្វើការទម្លាយជញ្ជាំង** មានសេចក្ដីថា កាលបានអធិដ្ឋានសីលហើយ អង្គុយលើគ្រែដេកក្នុងបន្ទប់បិទទ្វារ ហើយចម្រើនមេត្តាទៅ ត្រូវរាគៈដែលកើតឡើងជាចន្លោះនៃមេត្តា ធ្វើឲ្យជាបុគ្គលខ្វាក់ទៅ ប្រាថ្នានឹងទៅកាន់ទីនៅរបស់ភរិយា កំណត់ទ្វារមិនបាន ទើបវាយជញ្ជាំងព្រោះសេចក្ដីត្រូវការនឹងចេញទៅ រហូតដល់ ទម្លាយជញ្ជាំង ព្រោះហេតុនោះ លោកទើបពោលថា រាគៈ រមែងចក់ឱកាសបាន ជាចន្លោះ ៗ នៃមេត្តា និងថា ភាពងងឹតងងល់ រមែងមានបានក្នុងវេលាដែលត្រូវរាគៈគ្របសង្កត់ដូច្នេះ ។

ក្នុងទីនេះ ស័ព្ទថា សត្វជាដើម ប្រព្រឹត្តទៅក្នុងការបន្តនៃខន្ធដែលជាកាលបច្ចុប្បន្ន ដែលខណ្ឌដោយ **អាទាន** គឺ **បដិសន្ធិ** , **និក្ខេប** គឺ **ចុតិ** ដូចយល់ដោយប្រចក្សស្រោប់ ព្រោះភាពដែលកំពុងតាំងនៅ មិនមែនប្រព្រឹត្តទៅក្នុងការបន្តនៃខន្ធដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ ទេ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ចំណែកកាលចម្រើនទៅក្នុងបុគ្គលដែលធ្វើកាលកិរិយាទៅហើយ ដូច្នេះជាដើម ។ សួរថា ព្រោះហេតុអ្វី ការចម្រើនមេត្តាទៅក្នុងបុគ្គលដែលធ្វើកាលកិរិយាហើយ ទើបមិនសម្រេច ? ឆ្លើយថា ព្រោះបុគ្គលដែលធ្វើកាលកិរិយាហើយ ជាឋានៈដែលមិនគួរដល់សេចក្ដីព្យាយាមនៃមេត្តា ។ ពិតណាស់ បុគ្គលដែលស្លាប់ហើយ

ជាបុគ្គលមិនគួរដល់ការបង្អោនយកប្រយោជន៍ចូលទៅ ។ ការបង្អោនយកប្រយោជន៍ចូលទៅដោយសេចក្តីព្យាយាមតាមផ្លូវកាយ និង ផ្លូវវាចា គប្បីបានក្នុងបុគ្គលណា ក្នុងកាលគេនៅមានជីវិត គឺ មិនទាន់ស្លាប់ ការបង្អោនយកប្រយោជន៍ចូលទៅនៃចិត្ត ក៏គប្បីប្រើបានក្នុងបុគ្គលនោះប៉ុណ្ណោះ ។ សូម្បីក្នុងការប្រព្រឹត្តទៅនៃអាការដែលកម្ចាត់ទុក្ខនៃករុណា និងអាការដែលត្រេកអរផងនៃមុទិតា ក៏មានន័យនេះឯង ព្រោះហេតុនោះ ទើបគួរជ្រាបថា ជាការដែលលោកពោលដល់ សូម្បីការចម្រើនករុណាជាដើម ក៏រកភាពសម្រេចមិនបាន ក្នុងបុគ្គលដែលធ្វើកាលកិរិយាហើយ ។ ពាក្យថា ផ្តើមមេត្តាការនាប្រារព្ធដល់អាចារ្យ លោកពោលដល់ភិក្ខុមួយរូបដែលមានមេត្តាឈានស្ទាត់ជំនាញហើយ ក្នុងបុគ្គលដទៃ មិនជ្រាបថា អាចារ្យធ្វើកាលកិរិយាហើយ ប្រាថ្នានឹងផ្សាយមេត្តាទៅកាន់អាចារ្យនោះ ។ ព្រោះហេតុនោះភិក្ខុរូបនោះ ទើបពោលថា មេត្តាឈានសមាបត្តិរបស់ខ្ញុំស្ទាត់ជំនាញហើយដូច្នេះ ។ ពាក្យថា **និមិត្ត** បានដល់ អារម្មណ៍ ។ ពាក្យថា **លោកចូរស្វែងរក** មានសេចក្តីថា លោកចូរដឹងថា បុគ្គលដែលនឹងផ្តើមផ្សាយមេត្តាឲ្យ នៅមានជីវិត ឬ មិនមានជីវិត ។ បទថា **មេត្តាយន្តោ** មានសេចក្តីថា កាលធ្វើមេត្តា គឺ កាលចម្រើនមេត្តា ។

( ចប់ មហាដីកា )

# ចម្រើនមេត្តាចំពោះខ្លួនឯងមុន

តែថា មុនដំបូងបង្អស់ គួរចម្រើនក្នុងខ្លួនឯងរឿយៗ យ៉ាងនេះថា សូមយើងជាអ្នកដល់នូវសេចក្ដីសុខ មិនមានទុក្ខចុះ ឬថា សូមយើងជាអ្នកមិនមានពៀរ មិនមានការបៀតបៀន មិនមានសេចក្ដីទុក្ខ មានសេចក្ដីសុខបរិហារខ្លួនទៅចុះ ដូច្នេះក៏បាន ។ ប្រសិនបើមានសេចក្ដីសង្ស័យថា កាលបើដូច្នោះ ពាក្យណា ដែលត្រាស់ទុកក្នុងវិភង្គថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តប្រកបដោយមេត្តាផ្សាយទៅអស់ទិសមួយដូចម្ដេច ប្រៀបដូចបុគ្គលឃើញបុគ្គលម្នាក់ ដែលជាទីស្រឡាញ់ជាទីចម្រើនចិត្ត គប្បីសម្ដែងសេចក្ដីស្រឡាញ់ ចេញទៅយ៉ាងណា ភិក្ខុរមែងផ្សាយមេត្តាទៅដល់សត្វទាំងឡាយក៏ដូច្នោះនោះឯង ដូច្នេះក្ដី ពាក្យណាដែលពោលទុកក្នុងបដិសម្ភិទាថា មេត្តាចេតោវិមុត្តិ ដែលផ្សាយទៅដោយមិនចោះចំពោះ ដោយអាការ ៥ គឺអ្វីខ្លះ គឺដោយការប្រាថ្នាថា សត្វទាំងឡាយទាំងពួងចូរជាអ្នកមិនមានពៀរ មិនមានការបៀតបៀន មិនមានសេចក្ដីទុក្ខ មានសេចក្ដីសុខបរិហារខ្លួនទៅចុះ បាណៈទាំងឡាយទាំងពួង... ភូតទាំងឡាយទាំងពួង... បុគ្គលទាំងឡាយទាំងពួង... បុគ្គលទាក់ទងនៅក្នុងអត្តភាពទាំងឡាយទាំងពួង ចូរជាអ្នកមិនមានពៀរ មិនមានការបៀតបៀន មិនមានសេចក្ដីទុក្ខ មានសេចក្ដីសុខបរិហារខ្លួនចុះ ដូច្នេះជាដើមក្ដី ។ ពាក្យណាដែលត្រាស់ទុកក្នុងមេត្តាសូត្រថា សត្វទាំងឡាយទាំងពួង ចូរជាអ្នកមានសេចក្ដីសុខ សេចក្ដីក្សេម ចូរជាអ្នកមានខ្លួនដល់ហើយនូវសេចក្ដីសុខសាន្តដូច្នេះជាដើមក្ដី ពាក្យក្នុងវិភង្គជាដើមនោះក៏ខុសទៅហើយឬ ព្រោះក្នុងពាក្យនោះ មិនបានត្រាស់ដល់ការចម្រើនមេត្តាក្នុងខ្លួនទុកដូច្នេះសោត គប្បីឆ្លើយថា ពាក្យក្នុងវិភង្គជាដើមនោះ មិនខុសទេ ព្រោះហេតុអ្វី ព្រោះពាក្យនោះត្រាស់ចំពោះភាវនាដែលដល់អប្បនា

ចំណែកពាក្យផ្សាយមេត្តាក្នុងខ្លួន មានពាក្យថា សូមយើងជាអ្នកដល់នូវសេចក្ដីសុខ ជាដើមនេះ ខ្ញុំព្រះករុណាពោល ដោយការធ្វើខ្លួនឲ្យជាឧបមា ពិតណាស់ សូម្បីបុគ្គលនឹងចម្រើនមេត្តាចំពោះខ្លួន ដោយន័យថា សូមឲ្យយើងជាអ្នកដល់នូវសេចក្ដីសុខដូច្នេះជាដើមទៅ ១០០ ឆ្នាំ ឬ ១០០០ ឆ្នាំ អប្បនាក៏មិនកើតឡើងដល់គេបានឡើយ តែថា កាលចម្រើនមេត្តាចំពោះខ្លួនថា សូមយើងជាអ្នកដល់នូវសេចក្ដីសុខដូច្នេះជាដើមទៅ ភាពជាអ្នកប្រាថ្នាសុខក្នុងសត្វដទៃៗ រមែងកើត ដោយធ្វើខ្លួនឲ្យជាឧបមាថា យើងជាអ្នកស្រឡាញ់សេចក្ដីសុខ ស្អប់ទុក្ខ និងចង់រស់នៅ មិនចង់ស្លាប់យ៉ាងណា សូម្បីសត្វដទៃៗ ក៏ដូច្នោះ , ម្យ៉ាងទៀត សូម្បីព្រះមានព្រះភាគដែលត្រាស់ថា ៖

***បុគ្គលតាមពិចារណាទៅដោយចិត្តសព្វទិស ក៏មិនបានជួបអ្នកដែលជាទីស្រឡាញ់ក្រៃលែងជាងខ្លួនក្នុងទីណាឡើយ យ៉ាងណា ខ្លួនរបស់អ្នកដទៃៗ ក៏រមែងជាទីស្រឡាញ់របស់គេខ្លាំង ក៏ដូច្នោះ ព្រោះដូច្នោះ អ្នកស្រឡាញ់ខ្លួន ទើបមិនគួរបៀតបៀនអ្នកដទៃ ។***

ដូច្នេះក៏ទ្រង់សម្ដែងន័យនេះនោះឯង ព្រោះហេតុនោះ ព្រះយោគាវចរទើបគួរផ្សាយមេត្តាឲ្យខ្លួនជាបឋមដើម្បីជាឧបមា ហើយក្នុងលំដាប់នោះ ដើម្បីញ៉ាំងមេត្តាភាវនាឲ្យប្រព្រឹត្តទៅដោយស្រួល លោកអ្នកណាដែលជាទីស្រឡាញ់ ជាទីចម្រើនចិត្ត ជាទីគោរព ជាទីគួរសរសើរ ជាអាចារ្យ ឬអាចរិយមត្ត ( គឺ ភិក្ខុប្រហាក់ប្រហែលនឹងអាចារ្យ ) ជាឧបជ្ឈាយ៍ ឬឧបជ្ឈាយមត្តរបស់លោក គប្បីរឭកដល់ហេតុនៃភាពជាទីស្រឡាញ់ ជាទីចម្រើនចិត្ត ការចែករំលែក និង ការនិយាយពីរោះជាដើម និង ហេតុនៃភាពជាទីគោរព និង ជាទីកោតសរសើរ មានសីល និង

សុតៈជាដើមនៃលោកអ្នកនោះហើយ ចម្រើនមេត្តាទៅដោយន័យថា សូមលោកសប្បុរសនោះជាអ្នកដល់នូវសេចក្តីសុខ មិនមានទុក្ខចុះ ដូច្នេះជាដើម ក៏ឯកាលចម្រើនទៅក្នុងបុគ្គលបែបនោះ អប្បនារមែងនឹងសម្រេចដោយពិត ។

## មហាដីកា

ឈ្មោះថា **ការចម្រើនទៅចំពោះខ្លួន** បានដល់ ការមានខ្លួនជាឧបមា ព្រោះហេតុនោះ សេចក្តីសុខមាន **អនវជ្ជសុខ** គឺ សុខដែលមិនមានទោស , **អព្យាសេកសុខ** គឺ សុខដែលប្រណីតមិនបៀតបៀនជាដើម , ការជាប់តាមដោយសុខផ្សេងៗច្រើនយ៉ាងឯណា មាននៅក្នុងខ្លួន លោកអាចារ្យកាលនឹងសម្តែងសុខនោះតាមភាពដែលសុខនោះប្រព្រឹត្តទៅ ទើបពោលថា សូមយើងជាអ្នកដល់នូវសេចក្តីសុខចុះដូច្នេះ ។ ដែលបានឈ្មោះថា សរីរសុខ គឺ សុខផ្លូវកាយ ជារបស់មិនពិតប្រាកដសម្រាប់បុគ្គលប្រភេទនេះ ចិត្តដែលជាទុក្ខរកឱកាសមិនបាន ព្រោះហេតុនោះ លោកអាចារ្យសំដៅយកភាពមិនមាននៃចិត្តដែលជាទុក្ខនោះ ទើបពោលថា មិនមានទុក្ខចុះដូច្នេះក៏បាន ។ សម្ពន្ធចូលនឹង **ហោមិ** ។ សូម្បីក្នុងពាក្យថា **អវេរោ** ( ជាអ្នកមិនមានពៀរជាដើម ) ក៏យ៉ាងនោះដូចគ្នា លោកអាចារ្យកាលនឹងសម្តែងថា តែដោយពិសេសសេចក្តីសម្គាល់ថា ជាសុខនឹងមានបាន ក៏ព្រោះការមិនមានទុក្ខ ។ ក៏ភាពមិនមានទុក្ខនេះនោះ នឹងមានបានក៏ព្រោះមិនមានបុគ្គលដែលមានពៀរនឹងគ្នា មិនមានបាបធម៌ទាំងឡាយ ដែលហៅថា ពៀរ ។ ដោយពិសេសនឹងមានបាន ក៏ព្រោះវៀរចាកព្យាបាទ ព្រោះមិនមាន **ឦតិ** គឺ ចង្រៃ ដែលធ្លាប់ហៅថា **ឦឃ** ( សេចក្តីទុក្ខ ឬ គ្រោះកាច ) និង ព្រោះភាពជាបុគ្គលព្រមព្រៀងដោយសេចក្តី

សុខកាយ ដែលមិនមានទោសដូច្នេះ ទើបពោលថា សូមយើងជាអ្នកមិនមានពៀរ មិនមានព្យាបាទ មិនមានសេចក្ដីទុក្ខ មានសេចក្ដីសុខដូច្នេះ ។ ពាក្យថា **បរិហារខ្លួន** មានសេចក្ដីថា សូមយើងធ្វើអត្តភាពរបស់យើងឲ្យប្រព្រឹត្តទៅ ឲ្យដំណើរទៅជាយ៉ាងនេះចុះ ។

ភ្ជាប់សេចក្ដីថា កាលបើយ៉ាងនេះ ពាក្យដែលត្រាស់ទុកក្នុងគម្ពីរវិភង្គឯណា ពាក្យនោះក៏ខុសទៅហើយឬ ។ ពាក្យថា **ឯវំ សន្តេ** ប្រែថា កាលបើយ៉ាងនេះ មានសេចក្ដីថា ប្រសិនបើត្រូវចម្រើនមេត្តាទៅ សូម្បីក្នុងខ្លួនឯងហើយសោត ។ លោកអាចារ្យកាលពោលថា ពាក្យដែលត្រាស់ទុកក្នុងគម្ពីរវិភង្គឯណា ដូច្នេះហើយ កាលនឹងនាំយកបទនៃព្រះសូត្រ ដែលមានគតិស្មើគ្នានឹងទេសនាក្នុងព្រះវិភង្គ ទើបពោលថា ម្នាលភិក្ខុទាំងឡាយ ដូចម្ដេច ដូច្នេះជាដើម ។ អត្ថន័យនៃពាក្យនោះនឹងមានខាងមុខ ។

បទថា **តំ** បានដល់ ពាក្យពោលក្នុងគម្ពីរវិភង្គជាដើម ។ ពាក្យថា **ដោយទាក់ទងនឹងអប្បនា** គឺ ដោយទាក់ទងនឹងការនាំមកនូវអប្បនា ។ បទថា **ឥទំ** បានដល់ ពាក្យថា សូមយើងជាអ្នកដល់នូវសេចក្ដីសុខចុះ ដូច្នេះជាដើម ។ ពាក្យថា **ដោយទាក់ទងនឹងការធ្វើខ្លួនជាឧបមា** គឺដោយទាក់ទងនឹងការតាំងខ្លួនទុកក្នុងភាពជាឧបមាក្នុងទីនោះយ៉ាងនេះថា សត្វទាំងឡាយទាំងពួងឯណោះ ក៏ត្រូវការសេចក្ដីសុខដល់ខ្លួនដូចគ្នានឹងយើង ព្រោះដូច្នោះ យើងគួរធ្វើការបង្អោនយកសេចក្ដីសុខទៅក្នុងសត្វទាំងនោះ ដូចគ្នានឹងក្នុងខ្លួនយើងនេះឯង ដូច្នេះ ។ ព្រោះហេតុនោះទើបលោកពោលថា ពិតណាស់ ប្រសិនបើដូច្នេះជាដើម ។ សួរថា ព្រោះហេតុអ្វីការចម្រើនមេត្តាទៅចំពោះខ្លួនឯង ទើបមិនមានការនាំមកនូវអប្បនា ? ឆ្លើយថា

ព្រោះមានអន្តរាយ ដែលទាក់ទងនឹងសេចក្តីស្រឡាញ់ខ្លួនឯង ។ តែសម្រាប់ព្រះយោគីដែលសម្រេចការនាទៅក្នុងពួកជនដទៃ **សីមាសម្ភេទ** គឺ ការទម្លាយព្រំដែនធ្វើសត្វទាំងឡាយឲ្យជាអ្នកស្មើដូចគ្នា រមែងមានសូម្បីក្នុងបុគ្គលពួកនោះបាន នោះឯងដែលជាហេតុឲ្យដល់អប្បនាបាន ។

ពាក្យថា **សព្វទិសទាំងពួង** គឺ គ្រប់ទិសទាំង ១០ មិនមានសល់ ។ ពាក្យថា យើងតាមពិចារណាដោយចិត្ត គឺ យើងជាប់តាមដោយអំណាចការត្រាច់ស្វែងរកទៅដោយចិត្ត ។ ពាក្យថា **ក្នុងទិសណាៗ ក៏មិនជួបបុគ្គលដែលជាទីស្រឡាញ់ក្រៃលែងជាងខ្លួន** គឺកាលស្វែងរកទៅដោយសេចក្តីឧស្សាហ៍ទាំងពួង ក្នុងទិសណាៗ ក៏មិនជួប គឺ មិនឃើញឡើយនូវសត្វដទៃដែលជាទីស្រឡាញ់ក្រៃលែងជាងខ្លួនដោយការប្រសើរលើស ។ ពាក្យថា **ដល់តួខ្លួន រមែងដល់បុគ្គលពួកដទៃសូម្បីតែម្នាក់រមែងជាទីស្រឡាញ់យ៉ាងនេះ** មានសេចក្តីថា ដល់តួខ្លួនរបស់សត្វពួកនោះៗ តែម្នាក់ក៏ជាទីស្រឡាញ់ ដោយទាក់ទងនឹងការដែលនរណាៗ សឹងជាទីស្រឡាញ់ក្រៃលែងជាងខ្លួន មិនមានយ៉ាងនេះ ។ ព្រោះដូច្នោះ គឺ ព្រោះហេតុនោះ អ្នកស្រឡាញ់ខ្លួន គឺ អ្នកប្រាថ្នាប្រយោជន៍សុខដល់ខ្លួន ទើបមិនគួរបៀតបៀន គឺ មិនគប្បីសម្លាប់ បានដល់ មិនគប្បីគំរាមកំហែងសត្វដទៃ ដោយហោចសូម្បីតែស្រមោចខ្មៅ ឬ ស្រមោចក្រហម ។

ពាក្យថា **ន័យនេះ** មានសេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងខែសេចក្តីដែលខ្លួនឯងជាទីស្រឡាញ់យ៉ាងក្រៃលែងជាងសត្វទាំងពួង ទ្រង់ត្រាស់ការធ្វើសេចក្តីករុណាក្នុងសត្វទាំងនោះទុក គឺ ទ្រង់ធ្វើការសម្តែងន័យនៃការចម្រើនមេត្តាទុកថាគួរតាំងខ្លួនឯងទុកក្នុងភាពជាឧបមាហើយ ចម្រើនមេត្តាទៅក្នុងសត្វទាំងឡាយដូច្នេះ

ក្នុងកាលជាអ្នកស្វែងរកសេចក្ដីសុខនោះឯង ។

បទថា **សុខប្បវត្តនត្ថំ** ប្រែថា ដើម្បីធ្វើមេត្តាឲ្យប្រព្រឹត្តទៅដោយងាយ គឺដោយមិនលំបាក ។ ពាក្យថា **យ្វាស្ស ( យោ អស្ស )** ប៉ុនគ្នានឹង **យោ បុគ្គលោ អស្ស យោគិនោ** ។ ពាក្យថា **ជាទីស្រឡាញ់** គឺ គួរប្រាថ្នា ។ ពាក្យថា **ជាទីពេញចិត្ត** គឺ ជាទីចម្រើនចិត្ត ។ ពាក្យថា **គួរគោរព** គឺជាអ្នកដែលគួរធ្វើសេចក្ដីគោរព ដោយទាក់ទងនឹងការមានគុណវិសេស ។ ពាក្យថា **គួរលើកសរសើរ** គឺជាអ្នកដែលគួរលើកសរសើរ ។ ពាក្យថា **ជាអ្នកធៀបប៉ុននឹងអាចារ្យ** គឺ ធៀបបាននឹងអាចារ្យដោយគុណ មានសីលជាដើម ។ ដោយ **អាទិ** ស័ព្ទ ដែលប្រែថា ជាដើម ក្នុងពាក្យថា **ទានបិយវចនាទីនិ** មានទានបិយវាចាជាដើម លោករួមយកហេតុ មានអត្ថចរិយា គឺ ការប្រព្រឹត្តតែប្រយោជន៍ជាដើម ។ ដោយ **អាទិ** ស័ព្ទក្នុងពាក្យថា **សីលសុត្តាទីនិ** មានសីល សុតៈជាដើម លោករួមយកហេតុមានសទ្ធាជាដើម និងហេតុ មានធុតធម៌ ការប្រកបរឿយ ៗ នូវជាគរិយធម៌ជាដើម ។

ស័ព្ទថា **កាមំ** ដោយពិតនេះជានិបាត ដែលសម្ដែងដល់ការសម្រេចបានដោយងាយនៃភាពជាអ្នកមានប្រក្រតីធ្វើភាវនាឲ្យដំណើរទៅក្នុងបុគ្គលដែលសមគួរៗ ព្រោះហេតុនោះ លោកទើបសម្ដែងស័ព្ទថា **កាមំ** នេះទុកថា ព្រះយោគីដែលប្រារព្ធភាវនាចោះចំពោះបុគ្គលដែលជាដូច្នោះ ឈ្មោះថា ជាអ្នកមានប្រក្រតីធ្វើភាវនាឲ្យដំណើរទៅក្នុងបុគ្គលដែលសមគួរ ហើយលោកអង្គនេះ ក៏នឹងសម្រេចភាវនាក្នុងបុគ្គលទាំងនោះបានដោយងាយ តែថា ព្រះយោគីនោះមិនគួរធ្វើសេចក្ដីត្រេកអរដោយហេតុត្រឹមតែប៉ុណ្ណោះ ឡើយ ។ ព្រោះហេតុនោះ លោកទើបពោលថា អប្បនាវមែង

សម្រេចដូច្នេះជាដើម ។

( ចប់ មហាដីកា )

# ចម្រើនមេត្តារួមដែន

បើព្រះយោគាវចរភិក្ខុនេះជាអ្នកមិនដល់នូវការពេញចិត្ត ដោយការសម្រេចតែត្រឹមនោះ ប្រាថ្នានឹងធ្វើសីមាសម្ភេទ គឺ ការរួមដែនតទៅ ទើបក្នុងលំដាប់នោះ គប្បីចម្រើនមេត្តា ទៅក្នុងបុគ្គលដែលជាសម្លាញ់នឹងគ្នា ចំពោះបុគ្គលដែលជាសម្លាញ់នឹងគ្នា គប្បីចម្រើនទៅក្នុងបុគ្គលដែលកណ្តាលៗ ចំពោះបុគ្គលដែលកណ្តាលៗ គប្បីចម្រើនទៅក្នុងបុគ្គលដែលជាសត្រូវ ហើយកាលចម្រើនទៅគប្បីធ្វើចិត្តឲ្យទន់គួរដល់ការងារតែម្យ៉ាង នាំការនាចិត្តទៅក្នុងលំដាប់ៗគ្នាឲ្យបាន ចំណែកយោគាវចរ ភិក្ខុណា មិនមានបុគ្គលដែលជាសត្រូវក្តី សូម្បីកាលអ្នកដទៃធ្វើអនត្ថឲ្យ ក៏មិនសម្គាល់ថាជាសត្រូវ ព្រោះភាពដែលលោកជាបុគ្គលជំពូកមហាបុរសក្តី យោគាវចរភិក្ខុនោះមិនត្រូវធ្វើសេចក្តីខ្វល់ខ្វាយថា មេត្តាចិត្តរបស់យើងក្នុងបុគ្គលដែលកណ្តាលៗ កើតជាចិត្តគួរដល់ការងារហើយ ឥឡូវនេះ យើងនឹងនាំមេត្តានោះចូលទៅក្នុងបុគ្គលដែលជាសត្រូវដូច្នេះឡើយ , រីឯពាក្យដែលថា ឲ្យចម្រើនមេត្តាដល់បុគ្គលជាសត្រូវនឹងគ្នា បន្ទាប់ពីបុគ្គលជាកណ្តាល នោះខ្ញុំព្រះករុណាពោលសំដៅយកអ្នកដែលមានបុគ្គលជាសត្រូវប៉ុណ្ណោះ ។

# មហាដីកា

ពាក្យថា **សីមាសម្ភេទ** គឺ ការទម្លាយព្រំដែន បានដល់ ការកម្ចាត់ព្រំដែន សំដៅសេចក្តីថា មិនធ្វើការចែកថាជា ខ្លួនឯង បុគ្គលជាទីស្រឡាញ់ បុគ្គលដែលជាកណ្តាលៗ បុគ្គលដែលមានពៀរ ។ ពាក្យថា **ក្នុងលំដាប់បន្ទាប់អំពីបុគ្គលនោះ** គឺ ក្នុងលំដាប់បន្ទាប់អំពីបុគ្គលដែលជាទីស្រឡាញ់ ជាទីពេញចិត្ត គួរគោរព និងគួរលើកសរសើរនោះ ឬ ក្នុងលំដាប់បន្ទាប់អំពីសម្រេចមេត្តាក្នុងបុគ្គលដែលជាទីស្រឡាញ់ជាដើមនោះ ។ ភ្ជាប់សេចក្តីថា ក្នុងលំដាប់បន្ទាប់អំពីបុគ្គលនោះ ក៏ចម្រើនមេត្តាទៅក្នុងបុគ្គលដែលជាសម្លាញ់ ជាទីស្រឡាញ់ក្រៃលែង មានសេចក្តីថា គួរបង្អោនយកមេត្តាមនសិការដែលបានមក , ព្រោះបុគ្គលដែលតាំងនៅក្នុងឋានៈគួរគោរព ចាត់ចូលទៅក្នុងបុគ្គលដែលជាសម្លាញ់ជាទីស្រឡាញ់ក្រៃលែង។ សេចក្តីនោះនឹងមានបាន ក៏សម្រាប់ភិក្ខុដែលធ្វើការបង្អោនការនាមនសិការបានដោយងាយហើយ ព្រោះធម៌ដែលជាបដិបក្ខទាំងឡាយត្រូវគ្របសង្កត់ទុកបានមុនហើយនោះឯង ។ ក្នុងលំដាប់បន្ទាប់អំពីបុគ្គលដែលជាសម្លាញ់ ជាទីស្រឡាញ់ក្រៃលែង គួរចម្រើនមេត្តាទៅក្នុងបុគ្គលដែលជាកណ្តាលៗ ព្រោះការដែលនឹងតាំងបុគ្គលដែលជាកណ្តាលៗ ទុកក្នុងឋានៈនៃបុគ្គលជាទីស្រឡាញ់ ឬគួរគោរពធ្វើបានងាយហើយ ។ ក៏ពាក្យថា បន្ទាប់អំពីបុគ្គលដែលជាសម្លាញ់ ជាទីស្រឡាញ់ក្រៃលែង នេះលោកពោលកាន់យកតំណែងនៃបុគ្គលដំបូង គឺបុគ្គលដែលជាទីស្រឡាញ់ ឬគួរគោរព ។ ពិតណាស់ រាប់តាំងអំពីបានសម្រេចមនសិការដែលស្ទាត់ជំនាញហើយ បុគ្គលដែលជាកណ្តាលៗនោះ រមែងតាំងនៅក្នុងឋានៈនៃបុគ្គលជាទីស្រឡាញ់សម្រាប់ភិក្ខុអង្គនេះបានផងដែរ ។ ពាក្យថា **បន្ទាប់អំពីបុគ្គលដែលជាកណ្តាល ៗ ក្នុងបុគ្គល**

**ដែលមានពៀរ** មានសេចក្តីថា ដែលភិក្ខុអ្នកធ្វើមេត្តាក្នុងបុគ្គលដែលជាកណ្តាលៗ បង្អោនសេចក្តីស្រឡាញ់ចូលទៅក្នុងបុគ្គលជាកណ្តាលៗ នោះបានហើយ ព្រោះសម្រេចមនសិការ ដែលស្ទាត់ជំនាញបាន ក្នុងលំដាប់បន្ទាប់អំពីបុគ្គលដែលជាកណ្តាលៗនោះ គួរចម្រើនមេត្តាទៅក្នុងបុគ្គលដែលមានពៀរ ដោយការដែលតាំងបុគ្គលដែលមានពៀរក្នុងភាពជាបុគ្គលកណ្តាលៗ ដោយភាវនាបានហើយ ក៏លះបង់ភាពជាបុគ្គលកណ្តាល ៗ នោះចោល បង្អោនចូលទៅកាន់ភាពជាបុគ្គលជាទីស្រឡាញ់ ។ ក៏ពាក្យថា ក្នុងបុគ្គលដែលមានពៀរនេះ លោកពោលថា លោកកាន់យកតំណែងបុគ្គលមុនៗ ។ ពាក្យថា **ធ្វើចិត្តឲ្យទន់គួរដល់ការងារក្នុងបុគ្គលតែមួយចំណែក** មានសេចក្តីថា ក្នុងបុគ្គល ៤ ចំណែក គឺ បុគ្គលដែលតាំងនៅក្នុងឋានៈនៃបុគ្គលជាទីស្រឡាញ់ ឬ គួរគោរព បុគ្គលដែលស្រឡាញ់ក្រៃលែង បុគ្គលដែលជាកណ្តាលៗ បុគ្គលដែលមានពៀរនឹងគ្នាដូច្នេះ ភិក្ខុសម្រេចមេត្តាភាវនាក្នុងបុគ្គលដែលតាំងនៅក្នុងឋានៈ នៃបុគ្គលជាទីស្រឡាញ់ ឬគួរគោរពបានមុនជាលំដាប់ដំបូងហើយ ក៏គួរធ្វើចិត្តដែលប្រព្រឹត្តទៅយ៉ាងនោះ ឲ្យជាចិត្តដែលទន់គួរដល់ការងារ ដោយការដល់នូវភាពជាវសី ដើម្បីប្រយោជន៍ដល់ការចូលទៅកាន់បុគ្គលចំណែកដទៃ ក្នុងលំដាប់តអំពីនោះ ក៏សង្កត់ភាពជាបុគ្គលជាទីស្រឡាញ់ក្រៃលែងក្នុងសម្លាញ់ដែលជាទីស្រឡាញ់ក្រៃលែងហើយ តាំងចិត្តទុកក្នុងអាការត្រឹមតែជាបុគ្គលជាទីស្រឡាញ់យ៉ាងធម្មតាប៉ុណ្ណោះ ។ បង្អោនភាវនាចូលទៅចុះ គួរធ្វើចិត្តនោះ ឲ្យជាចិត្តដែលទន់ គួរដល់ការងារ ដោយការធ្វើឲ្យដល់ភាពជាវសី ក្នុងលំដាប់តអំពីនោះ ក៏គ្របសង្កត់ភាពព្រងើយក្នុងបុគ្គលដែលជាកណ្តាលៗ ចេញចូលទៅតាំងភាពជាបុគ្គលជាទីស្រឡាញ់ទុក បង្អោនភាវនាចូលទៅចុះ គួរធ្វើចិត្ត

នោះឲ្យជាចិត្តដែលទន់គួរដល់ការងារ ដោយការធ្វើឲ្យដល់ភាពជាវសីទៀត ក្នុងលំដាប់តអំពីនោះ ក៏សង្កត់សង្កិនសេចក្តីសម្គាល់ថា ជាអ្នកមានពៀរក្នុងបុគ្គលដែលមានពៀរនោះចេញ ធ្វើភាពជាបុគ្គលដែលជាទីស្រឡាញ់ឲ្យកើតឡើង ដោយការតាំងភាពជាបុគ្គលកណ្តាលៗ ចូលទុកជាប្រក បង្អោនភាវនាចូលទៅចុះ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា បង្អោនចូលទៅក្នុងបុគ្គលតាមលំដាប់តទៅបន្ទាប់អំពីបុគ្គលនោះៗ ដូច្នេះ មានសេចក្តីថា ធ្វើឈានចិត្តចូលទៅ គឺ ធ្វើឲ្យកើតឡើង ។

ឈ្មោះថា មិនមានបុគ្គលដែលមានពៀរ ក៏ដោយមិនមានបុគ្គលដែលសាងហាយនភាពឲ្យ ដោយប្រការទាំងពួង ព្រោះកម្លាំងរបស់កម្មចាស់ ឬព្រោះប្រយោគសម្បត្តិ គឺ ការព្យាយាមត្រូវក្នុងបច្ចុប្បន្ននេះ ។ ពាក្យថា **ភាពដែលលោកមានជាតិជាមហាបុរស** គឺ ព្រោះលោកមានសភាពជាមហាបុរស មានសេចក្តីថា ព្រោះភាពដែលលោកមានអធ្យាស្រ័យដ៏ប្រសើរ ដោយភាពជាអ្នកដល់ព្រមទៅដោយគុណមានខន្តី មេត្តា ការអាណិតអាសូរជាដើម ដែលដល់ព្រមហើយ ព្រោះការសន្សំមកអស់កាលដ៏យូរ ។ ពិតណាស់ ភិក្ខុដែលជាដូច្នោះ រមែងជាអ្នកអត់ធន់ចំពោះវត្ថុគ្រប់យ៉ាង មិនប្រកាន់ទោសកំហុសរបស់អ្នកដទៃសូម្បីប៉ុនចុងស្មៅ ។ ព្រោះហេតុនោះ លោកទើបពោលថា សូម្បីកាលអ្នកដទៃធ្វើភាពវិនាសឲ្យ ក៏មិនកើតសេចក្តីសម្គាល់ថា ជាបុគ្គលមានពៀរនឹងខ្លួនដូច្នេះ ។ ពាក្យថា **ភិក្ខុអង្គនោះ** គឺភិក្ខុដែលជាព្រះយោគីនោះ ។ ភ្ជាប់សេចក្តីថា **អត្ថិ វេរិបុគ្គលោ** ។

( ចប់ មហាដីកា )

# ការទូន្មានខ្លួនកាលកើតបដិឃៈ

## ( ន័យទី ១ )

## " រឭកដល់ទោសរបស់សេចក្ដីក្រោធ "

តែប្រសិនបើកាលលោកនាំចិត្តចូលទៅក្នុងបុគ្គលដែលជាសត្រូវ បដិឃៈកើតឡើងព្រោះការរឭកដល់កំហុសដែលគេធ្វើឲ្យសោត កាលបើដូច្នោះ លោកគប្បីចូលមេត្តាឈានក្នុងបុគ្គលលំដាប់មុនៗ មានបុគ្គលជាទីស្រឡាញ់ជាដើម ក្នុងបុគ្គលណាក៏បានរឿយៗ ចេញហើយ ធ្វើមេត្តាដល់បុគ្គលនោះបណ្ដើរៗទៅ បន្ទោបង់បដិឃៈឲ្យបាន ។

ប្រសិនបើលោកព្យាយាមទៅយ៉ាងនោះ វាក៏មិនរលត់សោត ពេលនោះលោកគប្បីព្យាយាមដើម្បីលះបដិឃៈ ដោយរឭកដល់ព្រះពុទ្ធោវាទទាំងឡាយ មាន **កកូចូបមឱវាទ** ( ព្រះឱវាទដែលមានសេចក្ដីឧបមាដោយរណា ) ជាដើម រឿយៗ ចុះ ។

ក៏ឯយោគាវចរភិក្ខុនោះ កាលនឹងទូន្មានខ្លួន គប្បីទូន្មានដោយអាការតទៅនេះឯងថា អ្នកជាបុរសខឹងក្រោធ គួរឬ ? ព្រះមានព្រះភាគត្រាស់ទុកមិនមែនឬថា ៖

**១- ម្នាលភិក្ខុទាំងឡាយ ប្រសិនបើពួកចោរព្រៃ នឹងគប្បីចាប់ខ្លួន កាត់អវយវៈដោយរណាដែលមានដងទាំងពីរខាង ប្រសិនបើបុគ្គលណាញុំាងចិត្តឲ្យគិតប្រទូស្តក្នុងពួកចោរនោះ ព្រោះហេតុចិត្តប្រទូស្តនោះ មិនបានឈ្មោះថា សាសនករ ( អ្នកធ្វើតាមពាក្យប្រៀនប្រដៅរបស់តថាគតឡើយ ) ។**

**២- បុគ្គលណាក្រោធតបនឹងបុគ្គលដែលក្រោធហើយមុន ព្រោះហេតុដែល**

ក្រោធតបនោះ បុគ្គលនោះត្រឡប់ជាអាក្រក់ជាងបុគ្គលដែលក្រោធមុននោះទៅទៀត បុគ្គលមិនក្រោធតបនឹងអ្នកដែលក្រោធ ឈ្មោះថា ឈ្នះសង្គ្រាមដែលគេឈ្នះដោយលំបាក បុគ្គលណាដឹងថា បុគ្គលដទៃអាក់អន់ចិត្តឡើងមកហើយ មានសតិរម្ងាប់ចិត្តចេញបាន គឺមិនអាក់អន់តប បុគ្គលនោះឈ្មោះថា ប្រព្រឹត្តជាប្រយោជន៍ទាំងពីរចំណែក គឺ ទាំងចំណែកខ្លួន និងចំណែកអ្នកដទៃ ។

៣- ម្នាលភិក្ខុទាំងឡាយ ធម៌ដែលសត្រូវប្រាថ្នាឲ្យមានដល់អ្នកដែលជាសត្រូវ ដែលសត្រូវគប្បីធ្វើឲ្យដល់អ្នកជាសត្រូវ ៧ ប្រការនេះ រមែងមានដល់បុគ្គលដែលច្រើនដោយសេចក្តីក្រោធ នឹងជាស្ត្រី ឬបុរសក៏ដោយ ធម៌ ៧ ប្រការគឺអ្វីខ្លះ ម្នាលភិក្ខុទាំងឡាយ សត្រូវក្នុងលោកនេះ រមែងប្រាថ្នាយ៉ាងនេះ ចំពោះបុគ្គលដែលជាសត្រូវនឹងគ្នាថា អើហ្ន៎ សូមឲ្យវាជាបុគ្គលមានសម្បុរអាក្រក់ចុះដូច្នេះ សេចក្តីនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសត្រូវរមែងមិនត្រេកអរ ដោយភាពដែលមានពណ៌សម្បុរស្អាតនៃបុគ្គលដែលជាសត្រូវនឹងគ្នាទេ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលដែលក្រោធនេះ ត្រូវសេចក្តីក្រោធគ្របសង្កត់ហើយ ក្រោធពេញទំហឹងហើយ សូម្បីគេនឹងជាបុគ្គលងូតទឹកហើយយ៉ាងល្អលាបលនកាយយ៉ាងល្អ កាត់សក់ និងពុកមាត់ ស្លៀកដណ្តប់សំពត់សស្អាត ក៏ដោយចុះ សូម្បីយ៉ាងនោះ គេត្រូវសេចក្តីក្រោធគ្របសង្កត់ ក៏ជាបុគ្គលមានពណ៌សម្បុរអាក្រក់ដែរ ម្នាលភិក្ខុទាំងឡាយ ធម៌ដែលសត្រូវប្រាថ្នាឲ្យមានដល់បុគ្គលដែលជាសត្រូវនឹងគ្នា ដែលសត្រូវគប្បីធ្វើ ( ឲ្យដល់អ្នកជាសត្រូវ ) ជាខាងដើមរមែងមានដល់បុគ្គលក្រោធ ទោះជាស្ត្រី ឬបុរសក៏ដោយ , ប្រការមួយទៀត ម្នាលភិក្ខុទាំងឡាយ សត្រូវរមែងប្រាថ្នាយ៉ាងនេះ ចំពោះបុគ្គលដែលជាសត្រូវនឹងគ្នាថា

អើហ្ន៎ ! សូមឲ្យវាដេកជាទុក្ខចុះ ។ល។ សូមឲ្យវាជាបុគ្គលអត្តខាត់ ។ល។ សូមឲ្យវាជាបុគ្គលមិនមានភោគៈចុះ ។ល។ សូមឲ្យវាជាបុគ្គលមិនមានកិត្តិយសចុះ ។ល។ សូមឲ្យវាជាបុគ្គលមិនមានមិត្រចុះ ។ល។ ព្រោះកាយបែកធ្លាយស្លាប់ទៅ សូមឲ្យវាកុំបានចូលដល់សុគតិលោកសួគ៌ឡើយ ដូច្នេះ សេចក្តីនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះសត្រូវមែនមិនត្រេកអរដោយការទៅសុគតិនៃបុគ្គលដែលជាសត្រូវនឹងគ្នាឡើយ ម្នាលភិក្ខុទាំងឡាយ បុរសបុគ្គលដែលខឹងក្រោធនេះ ត្រូវសេចក្តីក្រោធគ្របសង្កត់ហើយ ក្រោធពេញទំហឹងហើយ រមែងប្រព្រឹត្តអាក្រក់ដោយកាយ ប្រព្រឹត្តអាក្រក់ដោយវាចា ប្រព្រឹត្តអាក្រក់ដោយចិត្ត គេត្រូវសេចក្តីក្រោធគ្របសង្កត់ កាលប្រព្រឹត្តអាក្រក់ ដោយកាយ វាចា ចិត្តហើយ ព្រោះកាយបែកធ្លាយស្លាប់ទៅ រមែងចូលដល់អបាយ ទុគ្គតិ វិនិបាត នរក ។

៤- ម្នាលភិក្ខុទាំងឡាយ អង្កត់អុសដែលដុតខ្មោច ភ្លើងឆេះទាំងពីរខាង ត្រង់កណ្តាលប្រឡាក់លាមក ប្រើប្រយោជន៍ជាគ្រឿងឈើក្នុងស្រុកក៏មិនបាន ជាអុសក្នុងព្រៃក៏មិនបាន យ៉ាងណាក្តី តថាគតពោលដល់បុរសបុគ្គលនេះថា មានឧបមាដូច្នោះ ។

ឥឡូវនេះ អ្នកនោះ រវល់ក្រោធយ៉ាងនេះ ក៏នឹងមិនឈ្មោះថា ជាសាសនករ គឺ អ្នកធ្វើតាមពាក្យប្រៀនប្រដៅរបស់ព្រះមានព្រះភាគផង រវល់ក្រោធតបគេ ក៏ត្រឡប់ជាបុគ្គលអាក្រក់ជាងបុគ្គលដែលក្រោធមុន ហើយក៏នឹងមិនបានឈ្មោះថា ឈ្នះសង្គ្រាមដែលគេឈ្នះបានដោយកម្រផង និងបានឈ្មោះថា ធ្វើសបត្តករណធម៌ គឺ វត្ថុដែលសត្រូវធ្វើឲ្យដល់អ្នកដែលជាសត្រូវ ដល់ខ្លួនដោយខ្លួនឯងផង និងជាបុគ្គល ដូចអង្កត់អុសដុតខ្មោចផងដោយពិត ។

## ( ន័យទី ២ )

## " ពេញកដល់សេចក្ដីល្អរបស់គេ "

កាលលោកព្យាយាមទូន្មានខ្លួនយ៉ាងនេះ បើបដិឃៈនោះរម្ងាប់ចុះបានសោត ការរម្ងាប់បានដូច្នោះនោះជាការល្អ បើមិនស្ងប់រម្ងាប់ទេ ធម៌ណាៗរបស់បុគ្គលនោះ ជាចំណែកដែលរៀបរយបរិសុទ្ធ ពេញកដល់ធម៌នោះនឹងនាំមកនូវសេចក្ដីជ្រះថ្លាបាន ក៏គប្បីពេញកដល់ធម៌នោះៗ របស់គេ កម្ចាត់សេចក្ដីអាឃាតចោលឲ្យបានចុះ ។

ពិតណាស់ សម្រាប់បុគ្គលពួកខ្លះ កាយសមាចារតែម្យ៉ាងជាចំណែកដែលរៀបរយ ហើយភាពដែលកាយសមាចាររបស់គេរៀបរយនោះ កាលគេធ្វើវត្តបដិបត្តិដ៏ច្រើនឲ្យឃើញ ជនទាំងពួងក៏ដឹងបាន ចំណែកវចីសមាចារ និងមនោសមាចារមិនរៀបរយ ព្រះយោគាវចរកុំគិតដល់វចីសមាចារ និងមនោសមាចារដែលមិនរៀបរយរបស់គេនោះ ពេញកដល់តែសេចក្ដីរៀបរយនៃកាយសមាចាររបស់គេតែម្យ៉ាងចុះ ។

សម្រាប់បុគ្គលខ្លះ វចីសមាចារតែម្យ៉ាងជាចំណែកដែលរៀបរយ ហើយការរៀបរយនៃវចីសមាចាររបស់បុគ្គលនោះ ជនទាំងពួងដឹងបាន ព្រោះតាមប្រក្រតីគេជាបុគ្គលឆ្លាតក្នុងការបដិសណ្ឋារៈទន់ភ្លន់ និយាយដោយងាយ និយាយឲ្យអ្នកដទៃរីករាយចិត្ត មានមុខស្រស់ស្រាយរាក់ទាក់ សូធ្យធម៌ដោយសំឡេងដ៏ពីរោះ ពោលធម្មកថាដោយបទព្យញ្ជនៈដ៏ក្រអួន ចំណែកកាយសមាចារ និងមនោសមាចារមិនរៀបរយ ព្រះយោគាវចរក៏កុំគិតដល់កាយសមាចារ និងមនោសមាចារនោះ ពេញកដល់តែសេចក្ដីរៀបរយនៃវចីសមាចាររបស់គេតែម្យ៉ាងចុះ ។

សម្រាប់បុគ្គលខ្លះ មនោសមាចារតែម្យ៉ាងរៀបរយ ហើយការរៀបរយនៃមនោសមាចាររបស់គេនោះ ប្រាកដដល់ជនទាំងពួងក្នុងការធ្វើវត្តផ្សេង ៗ មានការ

ថ្វាយបង្គំព្រះចេតិយជាដើម ពិតណាស់ បុគ្គលណាជាអ្នកមានចិត្តមិនរៀបរយ បុគ្គលនោះទោះថ្វាយបង្គំព្រះចេតិយក៏ដោយ ដើមពោធិព្រឹក្សក៏ដោយ ព្រះថេរៈទាំងឡាយក៏ដោយ រមែងថ្វាយបង្គំដោយមិនគោរព អង្គុយចិត្តអណ្តែតអណ្តូងខ្លះ ផក់ខ្លះនៅក្នុងមណ្ឌលដែលស្តាប់ធម៌ ចំណែកអ្នកដែលមានចិត្តរៀបរយ រមែងដាក់ចិត្តចុះ ថ្វាយបង្គំដោយគោរព ការស្តាប់ធម៌ក៏ផ្ទៀងសោតៈស្តាប់ ធ្វើធម៌ឲ្យជារបស់សំខាន់ ធ្វើចិត្តដែលជ្រះថ្លាឲ្យប្រាកដចេញមកតាមផ្លូវកាយខ្លះ ផ្លូវវាចាខ្លះ ស្តាប់ធម៌ , សម្រាប់បុគ្គលខ្លះ មនោសមាចារតែម្យ៉ាងជាចំណែកដែលរៀបរយ តែកាយសមាចារ និង វចីសមាចារមិនរៀបរយ ព្រះយោគាវចរក៏កុំគិតដល់កាយសមាចារ និងវចីសមាចាររបស់គេនោះ រឭកដល់ការរៀបរយនៃមនោសមាចាររបស់គេតែម្យ៉ាងចុះ ។

រីឯសម្រាប់បុគ្គលខ្លះ ក្នុងធម៌ ៣ ប្រការនេះ សូម្បីធម៌ ១ ប្រការ ក៏មិនរៀបរយ ព្រះយោគាវចរចូលទៅតាំងសេចក្តីករុណាក្នុងបុគ្គលនោះ ដោយគិតអាណិតថា ពេលនេះគេរស់នៅក្នុងលោកមនុស្សពិតៗ តែថា កន្លងទៅមិនប៉ុន្មានថ្ងៃ គេក៏នឹងត្រូវទៅចម្រើនឲ្យមហានរកទាំង ៨ និងឧស្សទនរក ១៦ ឲ្យពេញព្រោះថា សេចក្តីអាឃាតរមែងរម្ងាប់ចុះ ព្រោះអាស្រ័យសេចក្តីករុណាក៏បាន ។

សម្រាប់បុគ្គលខ្លះ ធម៌ទាំង ៣ នេះរៀបរយទាំងអស់ ព្រះយោគាវចរត្រូវការចំណែកធម៌ណាៗ របស់គេ ក៏គប្បីរឭកយកធម៌ចំណែកនោះៗ ចុះ ។

ម្យ៉ាងទៀត ដើម្បីនឹងញ៉ាំងសេចក្តីប្រការនេះថា ការចម្រើនមេត្តានោះ មិនមែនបុគ្គលទាំងឡាយនោះគប្បីធ្វើបានដោយលំបាកទេ ដូច្នេះគប្បីបំភ្លឺដោយអាឃាតបដិវិនយសូត្រ ក្នុងបញ្ចកនិបាតដូចនេះថា ម្នាលអាវុសោ អាឃាតបដិវិនយ ៥ នេះ

សឹងជាទីដែលសេចក្ដីអាឃាតកើតឡើងដល់ភិក្ខុហើយ អាចត្រូវកម្ចាត់ចេញបាន ដោយប្រការទាំងពួងដូច្នេះជាដើម បណ្ឌិតគប្បីជ្រាបនាំមកពោលឲ្យពិស្ដារចុះ ។

( ន័យទី ៣ )

“ ក្រោធ គឺ ធ្វើទុក្ខឲ្យខ្លួនឯង ”

តែបើកាលព្រះយោគាវចរនោះព្យាយាមដល់យ៉ាងនោះ សេចក្ដីអាឃាតក៏នៅកើតឡើងនោះសោត ពេលនោះ លោកគប្បីទូន្មានខ្លួនដូច្នេះថា ៖

១- បើសត្រូវធ្វើទុក្ខឲ្យដល់អ្នកក្នុងវត្ថុដែលជាវិស័យ គឺកាយរបស់ខ្លួនសោត ហេតុអ្វីអ្នកទើបប្រាថ្នានឹងធ្វើទុក្ខក្នុងចិត្តរបស់ខ្លួនដែលមិនមែនវិស័យ គឺមិនមែនកាយរបស់គេទៅវិញ ។

២- ខ្លួនកាលចេញបួស គង់លះមាតាបិតា ដែលមានឧបការគុណច្រើន និងពពួកញាតិដែលស្រែកយំ ទឹកភ្នែកជោកមុខ ចេញមកបានហើយ ហេតុអ្វីទើបលះសេចក្ដីក្រោធដែលជាសត្រូវធ្វើសេចក្ដីវិនាសធំឲ្យ មិនបានទៅវិញ ។

៣- អ្នកទៅយកចិត្តយកថ្នើមសេចក្ដីក្រោធ ដែលជាអ្នកកាត់ឫសគល់របស់សីលទាំងឡាយនោះវិញ សូមសួរបន្តិច អ្នកណាល្ងង់ដូចអ្នកខ្លះហ្ន៎ ។

៤- អ្នកក្រោធថា អ្នកដទៃធ្វើកម្មថោកទាបឲ្យ ហេតុអ្វីហ្ន៎ អ្នកទើបប្រាថ្នានឹងធ្វើកម្មដូចគ្នានោះឲ្យខ្លួនឯងទៀត ។

៥- បើអ្នកដទៃចង់ឲ្យអ្នកក្រោធ ទើបធ្វើការមិនពេញចិត្តឲ្យ ហេតុអ្វីអ្នកទើបត្រូវជួយធ្វើមនោរថរបស់គេឲ្យសម្រេច បណ្ដោយឲ្យសេចក្ដីក្រោធកើតឡើងហ្ន៎ ។

៦-ម្យ៉ាងទៀត គួរគិះដៀល អ្នកក្រោធហើយនឹងបានធ្វើទុក្ខឲ្យដល់គេ ឬមិន

មែនក៏ដោយ តែឥឡូវនេះ អ្នកក៏បានបៀតបៀនខ្លួនឯង ដោយកោធទុក្ខ គឺសេចក្តីទុក្ខ ព្រោះក្រោធពិតៗ ។

៧- ម្យ៉ាងទៀត ប្រសិនបើឃើញថា ពួកសត្រូវឡើង គឺ ដើរទៅកាន់ផ្លូវវិនាស គឺ សេចក្តីក្រោធហើយសោត ហេតុអ្វីអ្នកទើបក្រោធត្រាប់តាមគេដែរទៅវិញ ។

៨- សត្រូវអាស្រ័យសេចក្តីក្រោធឯណារបស់អ្នក ទើបធ្វើវត្ថុមិនជាទីពេញចិត្តឲ្យអ្នកបាន អ្នកចូរកាត់សេចក្តីក្រោធនោះចេញឲ្យបានចុះ អ្នកនឹងមកក្តៅក្រហាយក្នុងឋានៈដែលមិនគួរនឹងក្តៅក្រហាយធ្វើអ្វី ។

៩- ម្យ៉ាងទៀត សត្រូវធ្វើវត្ថុមិនពេញចិត្តដល់អ្នក ដោយខន្ធពួកណា ខន្ធពួកនោះក៏រលត់ទៅហើយ ព្រោះធម៌ទាំងឡាយប្រព្រឹត្តទៅជាខណៈៗ ហើយពេលនេះអ្នកមកក្រោធឲ្យនរណា ក្នុងទីនេះ ។

១០- សត្រូវណាធ្វើទុក្ខឲ្យដល់បុគ្គលណា វៀរ ( គឺ មិនមែនខ្លួន ) បុគ្គលនោះចេញ សត្រូវនោះនឹងធ្វើទុក្ខឲ្យអ្នកណាបាន ខ្លួនឯងជាហេតុនៃទុក្ខខ្លួនឯង ដូច្នេះហេតុអ្វីទើបក្រោធនឹងគេទៅវិញ ។

## ( ន័យទី ៤ )

## " ពិចារណាកម្មស្សកតា "

តែប្រសិនបើលោកទូន្មានខ្លួនយ៉ាងនេះ បដិឃៈ ក៏នៅមិនរម្ងាប់នោះសោត ពេលនោះលោកគប្បីពិចារណាឲ្យឃើញភាពដែលខ្លួន និងអ្នកដទៃមានកម្មជារបស់ខ្លួនតទៅ ក្នុងពីរចំណែកនោះ គប្បីពិចារណាចំណែកខ្លួនមុនដូច្នេះ នែបាអើយ

អ្នកក្រោធគេហើយ នឹងធ្វើអ្វីកើត កម្មដែលមានទោសៈជាហេតុនោះ វានឹងប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាសដល់ខ្លួនឯងមិនមែនឬ ព្រោះថា អ្នកជាអ្នកមានកម្មជារបស់ខ្លួន ជាអ្នកទទួលមត៌ករបស់កម្ម ជាអ្នកមានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាទីអាស្រ័យ អ្នកធ្វើកម្មណា អ្នកជាអ្នកទទួលផលនៃកម្មនោះម្យ៉ាងទៀត កម្មនេះនឹងបានអំណាច ញ៉ាំងព្រះសម្មាសម្ពោធិញ្ញាណឲ្យសម្រេចដល់អ្នកមិនបាន ញ៉ាំងព្រះបច្ចេកពោធិញ្ញាណឲ្យសម្រេចដល់អ្នកក៏ទេ ញ៉ាំងសាវកភូមិញ្ញាណឲ្យសម្រេចដល់អ្នកក៏ទេ ញ៉ាំងសម្បត្តិទាំងឡាយមានសភាពជាព្រហ្ម ជាព្រះឥន្ទ្រ ជាស្តេចចក្រពត្តិ និងជាព្រះរាជាចំពោះក្នុងប្រទេសណាមួយជាដើម សម្បត្តិយ៉ាងណាមួយឲ្យសម្រេចដល់អ្នកក៏រកមិនបានឡើយ ដែលពិត កម្មនេះ មានតែញ៉ាំងអ្នកឲ្យឃ្លាតចាកព្រះពុទ្ធសាសនា ហើយញ៉ាំងការៈនៃបុគ្គលក្រីក្រ មានភាពជាវិឃាសាទៈគឺ បុគ្គលគោកយ៉ាកជាដើម និងញ៉ាំងទុក្ខវិសេសទាំងឡាយ មានទុក្ខក្នុងនរកជាដើមឲ្យប្រព្រឹត្តទៅដល់អ្នក ខ្លួនអ្នកនោះ កាលធ្វើកម្មបែបនេះចុះទៅក៏ប៉ុនគ្នានឹងដុតខ្លួនឯងមុន និងធ្វើខ្លួនឯងឲ្យស្អុយមុន ដូចបុរសដែលចាប់រងើកភ្លើង ដែលភ្លើងក្តៅសព្វទូទៅហើយ ប្រាសចាកអណ្តាតភ្លើងក្តី លាមកក្តី ដោយដៃទាំងពីរមកបំណងនឹងប្រហារអ្នកដទៃ ក៏ប៉ុនគ្នានឹងដុតដៃខ្លួនឯងមុន ឬធ្វើដៃខ្លួនឯងឲ្យស្អុយមុនដូច្នោះ ។

កាលលោកពិចារណាកម្មស្សកតាចំណែកខ្លួនយ៉ាងនេះហើយ ទើបពិចារណាចំណែកអ្នកដទៃខ្លះដូច្នេះថា សូម្បីគេក្រោធអ្នកហើយ នឹងធ្វើអ្វីកើត កម្មដែលមានទោសៈជាហេតុនោះ នឹងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាសដល់គេខ្លួនឯង មិនមែនឬព្រោះថា លោកអ្នកនេះក៏ជាអ្នកមានកម្មជារបស់ផងខ្លួន ជាអ្នកទទួលមត៌ករបស់

កម្ម ។ ល ។ គេនឹងធ្វើកម្មឯណាទុក គេក៏នឹងត្រូវជាអ្នកទទួលផលរបស់កម្មនោះ ហើយកម្មនេះ នឹងបានអំណាចញ៉ាំងព្រះសម្មាសម្ពោធិញ្ញាណឲ្យសម្រេចដល់គេ ក៏មិនបាន ញ៉ាំងព្រះបច្ចេកពោធិញ្ញាណឲ្យសម្រេចដល់គេក៏មិនបាន ញ៉ាំងសាវកភូមិញ្ញាណឲ្យសម្រេចដល់គេក៏មិនបាន ញ៉ាំងសម្បត្តិទាំងឡាយ មានភាពជាព្រហ្មជាព្រះឥន្ទ្រ ជាស្តេចចក្រពត្តិ និងជាព្រះរាជាចំពោះក្នុងប្រទេសណាមួយ ជាដើម ឯណានីមួយ ឲ្យសម្រេចដល់គេក៏មិនបានឡើយ ដែលពិត កម្មនេះមាន តែញ៉ាំងគេឲ្យឃ្លាតចាកព្រះសាសនា ហើយញ៉ាំងការៈនៃបុគ្គលខ្វះខាត មានភាពជាវិឃាសាទៈជាដើម និង ញ៉ាំងទុក្ខដ៏ខ្លាំងក្លាទាំងឡាយ មានទុក្ខក្នុងនរកជាដើមឲ្យប្រព្រឹត្តទៅដល់គេ ខ្លួនគេនោះនឹងធ្វើកម្មនេះចុះទៅ ក៏ប៉ុន្តែនឹងបាចទោសដល់ខ្លួនឯង ដូចបុរសដែលឈរក្រោមខ្យល់ បំណងនឹងបាចធូលីដាក់អ្នកដទៃ ក៏ប៉ុន្តែនឹងបាចដាក់ខ្លួននោះឯងដូច្នោះ ពិតណាស់ សេចក្តីនេះព្រះមានព្រះភាគជាម្ចាស់ក៏បានត្រាស់ទុកថា ៖

**បុគ្គលពាលណាធ្វើអាក្រក់ចំពោះបុគ្គលដែលមិនបានប្រទូស្ត ដែលជាបុគ្គលបរិសុទ្ធ មិនបានមានការគិតអាក្រក់ ផលអាក្រក់ក៏រមែងត្រឡប់ទៅដល់បុគ្គលពាលនោះឯង ដូចធូលីល្អិតដែលបុគ្គលបាចទៅច្រាសខ្យល់ ក៏រមែងហុយត្រឡប់មកដល់បុគ្គលនោះឯង ដូច្នោះ ។**

## ( ន័យទី ៥ )

## “ ពិចារណាដល់បុព្វចរិយារបស់ព្រះសាស្តា ”

តែថា បើព្រះយោគាវចរនោះ សូម្បីពិចារណាកម្មស្សកតាហើយយ៉ាងនេះ

បដិឃៈក៏នៅ មិនរម្ងាប់ទៀតសោត ពេលនោះ លោកគប្បីពិចារណាដល់ព្រះគុណផ្នែកបុព្វចរិយារបស់ព្រះសាស្តាតទៅៗ នេះជាន័យនៃការពិចារណាក្នុងបុព្វចរិយាគុណរបស់ព្រះសាស្តានោះ គឺ ទូន្មានខ្លួនថា នែបាអ្នកបួស ព្រះសាស្តារបស់អ្នកក្នុងកាលមុន អំពីសម្ពោធិសម័យ សូម្បីជាព្រះពោធិសត្វមិនទាន់បានត្រាស់ដឹង ទ្រង់បំពេញព្រះបារមីរហូតអស់ ៤ អសង្ខេយ្យ និងមួយសែនកប្ប ក៏មិនបានទ្រង់ញុំាងព្រះហឫទ័យ ឲ្យគិតប្រទូស្តក្នុងបុគ្គលទាំងឡាយដែលជាសត្រូវ សូម្បីដល់ទៅជាអ្នកផ្តាច់ព្រះជន្មក្នុងជាតិនោះៗ ក៏មិនមែនឬ សេចក្តីនេះមានរឿងដូចម្តេចខ្លះ ?

## សីលវជាតក

គប្បីជ្រាបរឿងក្នុងសីលវជាតកមុន ព្រះបាទសីលវពោធិសត្វ កាលព្រះរាជាជាបដិបក្ខដែលអមាត្យអាក្រក់អ្នកប្រទូស្តក្នុងព្រះទេវីរបស់ព្រះអង្គ នាំមកដណ្តើមយករាជ្យ អាណាខេត្តដែលមានទំហំដល់ទៅ ៣ រយយោជន៍ ក៏មិនបានឲ្យពួកអមាត្យក្រោកឡើងការពារ ប៉ះត្រូវដោយអាវុធ កាលត្រូវពួកបដិបក្ខជីកដីជម្រៅត្រឹមក ចាប់ព្រះអង្គកប់ទុកក្នុងព្រៃខ្មោចជាមួយអមាត្យ មួយពាន់នាក់ ក៏មិនបានទ្រង់ធ្វើព្រះវិការសូម្បីត្រឹមតែញុំាងចិត្តឲ្យគិតប្រទូស្តគេ តែអាស្រ័យការកាយដីរបស់ហ្វូងឆ្កែចចកដែលមករកស៊ីសាកសព ធ្វើឲ្យដីរលុង ទើបទ្រង់ធ្វើការបុរសគឺប្រើកម្លាំងរបស់កូនប្រុសជួយព្រះអង្គឯងឡើងពីរណ្តៅរួចមកបាន ស្តេចសម្រុកចូលទៅដល់បន្ទប់របស់ព្រះអង្គបានដោយអានុភាពរបស់យក្ខ ( ដែលស្វាមីភក្តិក្នុងព្រះអង្គ ) ទតព្រះនេត្រឃើញសត្រូវដេកនៅលើក្រឡាបន្ទំ ក៏មិនបានក្រោធ ( ទ្រង់ជាស់ឡើង ) ទ្រង់ធ្វើសម្បថឲ្យគ្នានិងគ្នាហើយ បានតែងតាំងព្រះរាជាបដិបក្ខអង្គ

នោះ ទុកក្នុងតំណែងជាសម្លាញ់ ក្នុងទីបំផុតបានពោលនូវឧទានថា ៖

**បុគ្គលឈ្លាសគប្បីសង្ឃឹម មិនគប្បីនឿយណាយ យើងបានឃើញខ្លួនយើងជាបន្ទាល់ស្រាប់ថា យើងបានរស់តាមដែលយើងប្រាថ្នាពិតៗ ។**

## ខន្តិវាទីជាតក

រឿងក្នុងខន្តិវាទីជាតក ខន្តិវាទីតាបសពោធិសត្វ កាលព្រះរាជាកលាពុ ដែនកាសីដែលល្ងង់ខ្លៅ សួរថា សមណៈឯងមានវាទៈដូចម្ដេច ឆ្លើយថា អាត្មាឈ្មោះខន្តិវាទី , ត្រូវវាយដោយផ្ដៅទាំងបន្លា ហើយកាត់ដៃ និងកាត់ជើងចេញ ក៏មិនបានធ្វើសូម្បីតែអាការអាក់អន់ ។

សេចក្ដីដែលខន្តិវាទីតាបសជាមនុស្សធំ សូម្បីបានបួសហើយ គប្បីធ្វើបានយ៉ាងនោះ រាប់ថា មិនអស្ចារ្យប៉ុន្មានទេ ។

## ចូឡធម្មបាលជាតក

តែក្នុងចូឡធម្មបាលជាតក ព្រះធម្មបាលកុមារពោធិសត្វ សូម្បីនៅជាកុមារតូចដេកផ្ងារនៅឡើយ កាលដែលព្រះមាតាទ្រង់ព្រះពិលាបថា ៖

**ឱព្រះអង្គ បើដើមដៃទាំងពីរ ដែលលាបលនដោយចន្ទន៍រស គឺ ទឹកអប់ខ្លឹមចន្ទន៍របស់ធម្មបាល ដែលជាទាយាទនៃរាជសម្បត្តិក្នុងប្រឹថពីដាច់ទៅ ជីវិតរបស់ខ្ញុំម្ចាស់ក៏នឹងរលត់ដែរ ។**

ដូច្នេះ ក៏ត្រូវព្រះរាជាទ្រង់ព្រះនាមមហាតាបនៈ ដែលជាព្រះបិតាបញ្ជាឲ្យកាត់ដៃ និងកាត់ជើងទាំង ៤ ដ៏រៀវស្រឡូន បីដូចពន្លកទំពាំង , ប៉ុណ្ណឹងហើយ ក៏នៅ

មិនពេញព្រះទ័យ ត្រាស់បញ្ជាថា ពួកឯងចូរកាត់ក្បាលវាចេញដូច្នេះទៀត ទើបជាស់តឿនខ្លួនថា កាលឥឡូវនេះ ជាកាលដែលអ្នកត្រូវសង្កត់ចិត្តរបស់អ្នកទុកឲ្យល្អ នៃធម្មបាល គ្រានេះ អ្នកចូរជាអ្នកមានចិត្តស្មើក្នុងបុគ្គលទាំង ៤ គឺ ក្នុងព្រះបិតា ដែលទ្រង់បញ្ជាឲ្យកាត់ក្បាល ក្នុងពេជ្ឈឃាតដែលជាអ្នកកាត់ក្បាល ក្នុងព្រះមាតាដែលកំពុងខ្សឹកខ្សួល និងក្នុងខ្លួនឯងចុះ ដូច្នេះហើយ ទ្រង់អធិដ្ឋានទឡ្ហសមាទាន គឺការធ្វើចិត្តឲ្យមាំ មិនបានទ្រង់ធ្វើសូម្បីតែអាការប្រទូស្តឲ្យប្រាកដ ។

សូម្បីកាលដែលព្រះធម្មបាលកុមារជាមនុស្ស ធ្វើបានយ៉ាងនេះ ក៏រាប់ថានៅមិនទាន់អស្ចារ្យទេ ។

## ឆទ្ទន្តជាតក

តែក្នុងឆទ្ទន្តជាតក ព្រះពោធិសត្វសូម្បីជាតិរច្ឆាន គឺជាដំរីឈ្មោះឆទ្ទន្ត សូម្បីត្រូវព្រានបាញ់ចូលត្រង់នាភី គឺផ្ចិតដោយព្រួញលាបថ្នាំពិសហើយ មិនបានញ៉ាំងចិត្តឲ្យប្រទូស្តក្នុងព្រានឲ្យដល់សេចក្តីវិនាស ដូចព្រះអដ្ឋកថាចារ្យពោលទុកថា ៖

**ដំរីមានអាការធ្ងន់ ដោយត្រូវសរធំ ក៏មិនមានចិត្តគិតប្រទូស្ត ពោលសួរព្រានដោយល្អថា ម្នាលព្រានអ្នកជាសម្លាញ់ លោកបាញ់ខ្ញុំដើម្បីប្រយោជន៍អ្វី ឬថាព្រោះហេតុអ្វី ឬមិនដូច្នោះ ប្រយោគ គឺការធ្វើនេះ លោកធ្វើដើម្បីនរណា ។**

កាលពោលសួរយ៉ាងនេះហើយ ព្រានក៏ប្រាប់ថា បាដ៏ចម្រើន ខ្ញុំជាអ្នកដែលព្រះអគ្គមហេសីរបស់ព្រះបាទកាសីទ្រង់បញ្ជាមកដើម្បីត្រូវការភ្លុកទាំងពីររបស់អ្នក ដូច្នេះ នៅជួយឲ្យមនោរថរបស់គេសម្រេច ទើបឲ្យកាត់ភ្លុកទាំងពីររបស់ខ្លួនដែលផ្សាយឆព្វណ្ណរង្សី ជាភ្លុកល្អស្អាតគួរស្រឡាញ់ឲ្យទៅហើយ ។

# មហាកបិជាតក

ក្នុងមហាកបិជាតក ព្រះពោធិសត្វជាស្វាធំ កាលត្រូវបុរសអ្នកដែលខ្លួនឯងជួយទាញឡើងអំពីជ្រោះ ឲ្យរស់រានមានជីវិតហើយ បែរគិតប្រទូស្តថា ៖

**ស្វានេះក៏ជាអាហាររបស់ពួកមនុស្សដូចសត្វព្រៃដទៃៗ ក្នុងព្រៃនោះឯង កុំគិតអ្វី យើងក៏ឃ្លានហើយ សម្លាប់ស្វានេះស៊ីសិនចុះ យើងស៊ីឆ្អែតហើយ ក៏នឹងត្រូវកាន់យកសាច់វាជាស្បៀងទៅផង កាលបើដូច្នោះ យើងក៏នឹងឆ្លងផ្លូវកន្តារទៅបាន ស្បៀងក៏នឹងមានដល់យើងផង ។**

ដូច្នេះហើយ លើកដុំថ្មគប់ក្បាលតែម្តង ក៏នៅក្រឡេកមើលបុរសនោះដោយកែវភ្នែកដែលបៀមដោយទឹកភ្នែក ពោលនឹងបុរសនោះដោយល្អថា ៖

**អ្នក ! អ្នកកុំធ្វើនឹងខ្ញុំបែបនេះ កោតតែអ្នកធ្វើកម្មដូច្នេះបាន , អ្នកដែលនឹងបានឈ្មោះថា ជាអ្នកមានអាយុវែង គួរតែហាមអ្នកដទៃមិនឲ្យប្រទូស្តគ្នា តែនេះអ្នកធ្វើអាក្រក់ដោយខ្លួនឯង ។**

មិនញ៉ាំងចិត្តឲ្យគិតប្រទូស្តក្នុងបុរសនោះ មិនគិតដល់សេចក្តីទុក្ខរបស់ខ្លួនឡើយ នៅនាំបុរសនោះទៅឲ្យដល់ទីដែលផុតភ័យបាន ។

# ភូរិទត្តជាតក

ក្នុងភូរិទត្តជាតក ព្រះពោធិសត្វជានាគរាជឈ្មោះភូរិទត្ត អធិដ្ឋានអង្គឧបោសថហើយ ដេកវៀននៅលើដំបូក សូម្បីកាលត្រូវព្រាហ្មណ៍អាយលម្ពាយប្រើថ្នាំពិសដែលក្តៅដូចភ្លើងប្រល័យកប្បស្រោចស្រប់ខ្លួន ចាប់ដាក់ហិបនាំទៅឲ្យលេងរបាំពស់ទៅទូទាំងជម្ពូទ្វីប ក៏មិនបានធ្វើវិការសូម្បីតែការគិតប្រទូស្តក្នុងព្រាហ្មណ៍នោះ ដូចដែល

លោកខ្លួនឯងពោលថា ៖

សូម្បីកាលអាយលម្ពាយចាប់យើងដាក់បាវ និងសូម្បីអាយលម្ពាយទាត់យើង ដោយស្មូង យើងក៏មិនក្រោធនឹងអាយលម្ពាយ ព្រោះខ្លាចសីលរបស់យើងដាច់ ។

## ចម្បេយ្យជាតក

សូម្បីកាលជានាគរាជឈ្មោះចម្បេយ្យ ត្រូវគ្រូពស់បៀតបៀន មិនបានញ៉ាំង វិការសូម្បីត្រឹមតែការគិតប្រទូស្តឲ្យកើតឡើង ដូចលោកពោលថា ៖

គ្រូពស់ចាប់យើងដែលប្រព្រឹត្តធម៌ រក្សាឧបោសថសីល នាំទៅឲ្យលេងរបាំ ពស់ ត្រង់ទ្វាររាជវាំង គ្រាកាលនោះ គេគិតឲ្យខ្លួនយើងជាពណ៌ណា ខៀវ លឿង ឬក្រហមក្តី យើងកាលតាមចិត្តគេ ក៏បញ្ចេញរស្មីឲ្យជាពណ៌ដែលគេគិត យើងមាន អានុភាពនឹងគប្បីធ្វើទីគោកឲ្យជាទឹកក៏បាន ធ្វើទឹកឲ្យជាគោកក៏បាន ប្រសិនបើយើង ខឹងនឹងគេ នឹងអាចធ្វើរាងកាយគេឲ្យឆេះជាផ្សែងទៅដោយមួយរំពេចក៏បាន តែ បើយើងនឹងជាអ្នកតាមចិត្តខ្លួន ប្រទូស្តនឹងគេដូចពោលមកនោះសោត យើងក៏នឹង វិនាសចាកសីល កាលយើងវិនាសចាកសីលហើយ ប្រយោជន៍ដ៏ឧត្តមដែលយើង ប៉ង គឺព្រះពោធិញ្ញាណក៏នឹងមិនសម្រេច ។

## សង្ខចាលជាតក

សូម្បីកាលជាសង្ខបាលនាគរាជ ត្រូវកូនព្រាហ្មណ៍ ១៦ នាក់ ចាក់ដោយ ជន្ទញដ៏មុត ៨ កន្លែង ហើយស៊កវល្លិ៍មានបន្លាចូលតាមមុខរបួស ស៊កខ្សែយ៉ាង ស្វិតតាមច្រមុះ លើកដាក់ជាលអូសទៅ ខ្លួនកេតផែនដី រងទុក្ខដ៏ខ្លាំង សូម្បីជាអ្នក

អាចធ្វើកូនព្រាហ្មណ៍ទាំងអស់ឲ្យឆេះជាផេះទៅបាន ដោយត្រឹមតែក្រោធឡើងមក ហើយសម្លឹងប៉ុណ្ណោះ តែក៏មិនបានធ្វើ សូម្បីត្រឹមអាការដែលនឹងប្រើភ្នែកឡើងប្រទូស្តគេ ដូចលោកពោលនឹងមេកង្វរទេះដែលជួយលោកឲ្យផុតអំពីដៃព្រានថា ៖

**ម្នាលមេកង្វរទេះ ខ្ញុំរក្សាឧបោសថសីល ក្នុងថ្ងៃចាតុទ្ទសី និងបញ្ចទសី ជានិច្ច តមក កូនព្រាហ្មណ៍ ១៦ នាក់ បានមកជួបខ្ញុំ ពួកព្រាហ្មណ៍ទាំងនោះ កាន់ខ្សែ និងអន្ទាក់ដ៏មាំ ស៊កចូលច្រមុះរបស់ខ្ញុំ ហើយទាញខ្សែត្រង់ស្នាមច្រមុះ ចោមរោមចាប់ខ្ញុំនាំទៅ ខ្ញុំស៊ូអត់ធន់នូវសេចក្តីទុក្ខបែបនោះ មិនធ្វើឧបោសថសីលឲ្យកម្រើក ។**

ហើយព្រះសាស្តានោះ ទ្រង់បានធ្វើគុណគួរអស្ចារ្យមានប្រការដូចពោលមកប៉ុណ្ណោះក៏ទេ ទ្រង់បានធ្វើគុណគួរអស្ចារ្យដទៃៗ ទៀតជាអនេក ដូចពោលក្នុងជាតកទាំងឡាយ មានមាតុបោសកជាតកជាដើម អ្នកបានញ៉ាំងបដិឃចិត្តឲ្យកើតឡើងជាការមិនប្រពៃ មិនគួរពន់ពេកដល់ខ្លួនអ្នក ដែលយកព្រះមានព្រះភាគ ដែលឥឡូវនេះ សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ទ្រង់មានខន្តិគុណដែលនរណាៗ ក្នុងលោកនេះ ព្រមទាំងទេវលោកមិនមានស្មើនោះថា ជាព្រះសាស្តារបស់ខ្លួន ដូច្នេះ ។

### ( ន័យទី ៦ )

### “ ពិចារណាដល់ការធ្លាប់ទាក់ទងគ្នាក្នុងវដ្តសង្សារ ”

តែប្រសិនបើលោកសូម្បីពិចារណាដល់ព្រះគុណ ដែលជាចំណែកបុព្វចរិយារបស់ព្រះសាស្តាដូចពោលមកនេះ បដិឃៈរបស់លោកដែលធ្លាក់ជាទាសៈរបស់កិលេសទាំងឡាយមកអស់កាលដ៏យូរនោះ ក៏នៅមិនរម្ងាប់នោះសោត ពេលនោះ

លោកគប្បីពិចារណាដល់បទព្រះសូត្រទាំងឡាយ ដែលមានការទាក់ទងដោយស័ព្ទ អនមតគ្គ គឺសង្សារដែលមិនប្រាកដដើមចុង ក្នុងសុត្តបទទាំងនោះ សុត្តបទតទៅនេះ ព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សត្វដែលមិនធ្លាប់ជាមាតា មិនធ្លាប់ជាបិតា មិនធ្លាប់ជាបងប្អូនប្រុស មិនធ្លាប់ជាបងប្អូនស្រី មិនធ្លាប់ជាបុត្រ មិនធ្លាប់ជាធីតារបស់យើង មិនមានឡើយ ព្រោះហេតុនោះ ព្រះយោគាវចរគប្បីញ៉ាំងចិត្តយ៉ាងនេះឲ្យកើតឡើងក្នុងបុគ្គលនោះថា ន័យថា បុគ្គលនេះជាមាតាក្នុងអតីតរបស់យើង រក្សាយើងនៅក្នុងពោះគ្រប់ទសមាស ប្រសូតហើយ មិនសម្តែងអាការខ្ពើមរ្ពុបដិកូលទាំងឡាយ មានមូត្រ លាមក ទឹកមាត់ ទឹកសម្បោរជាដើម ជូតបានហាក់បីដូចចន្ទន៍ក្រហម ឲ្យយើងដេកប្របទ្រូង បី.ពយើងគ្រប់ប្រការ ចិញ្ចឹមយើងមក... ជាបិតាដើរផ្លូវលំបាកផ្សេងៗ មានអជបថ គឺ ផ្លូវពពែដើរ និងសង្កុបថ គឺ ផ្លូវដែលមនុស្សប្រើទម្លាក់ទាញខ្លួនឡើងទៅជាដើម ប្រកបការលក់ដូរ លះបង់សូម្បីតែជីវិត ចូលសង្គ្រាមដែលរៀបចំក្បួនហើយទាំងពីរចំណែកខ្លះ ឡើងទូកទៅក្នុងមហាសមុទ្រខ្លះ ធ្វើការដែលលំបាកដទៃៗ ខ្លះ ដើម្បីប្រយោជន៍ដល់ខ្លួនយើងគិតថា នឹងចិញ្ចឹមកូនតូច ឧស្សាហ៍ស្វែងរកទ្រព្យដោយឧបាយនោះៗ ចិញ្ចឹមយើងមក... សូម្បីជាបងប្អូនប្រុស បងប្អូនស្រី បុត្រ និងធីតាវិញ ក៏បានធ្វើឧបការវត្ថុនេះៗ ដល់យើង ព្រោះដូច្នោះ ឯការធ្វើចិត្តប្រទូស្តដល់បុគ្គលនោះនឹងគួរដល់យើងក៏ទេ ។

## ( ន័យទី ៧ )

## “ ពណ៌នា អានិសង្សនៃមេត្តា ”

ប្រសិនបើសូម្បីយ៉ាងនេះ លោកក៏នៅមិនអាចរម្ងាប់ចិត្តប្រទូស្តចុះបានសោត

ពេលនេះ លោកគប្បីពិចារណាដល់អានិសង្សនៃមេត្តាតទៅយ៉ាងនេះថា នៃបញ្ជិត ព្រះមានព្រះភាគត្រាស់ទុកមិនមែនឬថា ម្នាលភិក្ខុទាំងឡាយ កាលចេតោវិមុត្តិ គឺ មេត្តា ភិក្ខុសេពដោយអើពើ ចម្រើន ធ្វើឲ្យច្រើន ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាវត្ថុសន្សំ ឲ្យសម្រេចយ៉ាងល្អហើយ អានិសង្ស ១១ យ៉ាង នឹងសម្រេច អានិសង្ស ១១ គឺ អ្វីខ្លះ អានិសង្ស ១១ គឺ អ្នកចម្រើនមេត្តារមែង ៖

១- ដេកលក់ជាសុខ

២- ភ្ញាក់ជាសុខ

៣- មិនសុបិនអាក្រក់

៤- ជាទីស្រឡាញ់របស់មនុស្សទាំងឡាយ

៥- ជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ

៦- ទេវតារក្សា

៧- ភ្លើងក្តី ពិសក្តី សស្ត្រាក្តី មិនប៉ះពាល់បាន

៨- ចិត្តតាំងមាំបានរហ័ស

៩- ទឹកមុខស្រស់ថ្លា

១០- មិនវង្វេងក្នុងពេលធ្វើមរណកាល

១១- កាលមិនទាន់សម្រេចគុណដ៏ក្រៃលែង រមែងចូលដល់ព្រហ្មលោក

ដូច្នេះ បើអ្នកនឹងមិនញុំាងចិត្តប្រទូស្តនេះឲ្យរម្ងាប់សោត អ្នកក៏នឹងជាអ្នករបូត ចាកអានិសង្សទាំងនេះទៅ ។

## ( ន័យទី ៨ )

## “ ពិចារណាបែកធាតុ ”

បើព្រះយោគាវចរមិនអាចញុំាងចិត្តប្រទូស្តឲ្យរលត់ទៅ សូមប្បីដោយឧបាយយ៉ាងនេះ គប្បីធ្វើធាតុវិនិព្ភោគ គឺ បែកធាតុតទៅ សួរថា ធ្វើដូចម្តេច ? ឆ្លើយថា គប្បីទូន្មានខ្លួនដោយវិធីបែកយ៉ាងនេះថា នែបាបពុជិត ក៏ខ្លួនអ្នកកាលខឹងនឹងបុគ្គលនោះ ខឹងនឹងអ្វី ខឹងនឹងសក់ឬ ឬថា ខឹងនឹងរោម ខឹងនឹងក្រចក ។ល ។ ខឹងនឹងមូត្រ ឬមិនដូច្នោះ ខឹងនឹងធាតុដី ខឹងនឹងធាតុទឹក ខឹងនឹងធាតុភ្លើង ខឹងនឹងធាតុខ្យល់ ក្នុងកោដ្ឋាសទាំងឡាយមានសក់ជាដើម ឬថា លោកអ្នកនេះបានឈ្មោះយ៉ាងនេះ ព្រោះអាស្រ័យខន្ធ ៥ ពួកណា ព្រោះអាស្រ័យអាយតនៈ ១២ ពួកណា ព្រោះអាស្រ័យធាតុ ១៨ ពួកណាក្នុងធម៌ទាំងឡាយ មានខន្ធជាដើមទាំងនោះ អ្នកខឹងនឹងរូបក្ខន្ធឬ ឬថា ខឹងនឹងវេទនាខន្ធ... សញ្ញាខន្ធ... សង្ខារក្ខន្ធ... វិញ្ញាណក្ខន្ធ មិនដូច្នោះ អ្នកខឹងនឹងចក្ខាយតនៈឬ ខឹងនឹងរូបាយតនៈឬ ។ ល ។ ខឹងនឹងមនាយតនៈឬ ខឹងនឹងធម្មាយតនៈឬ មិនដូច្នោះ អ្នកខឹងនឹងចក្ខុធាតុឬ ខឹងនឹងរូបធាតុឬ ខឹងនឹងចក្ខុវិញ្ញាណធាតុឬ ។ល។ ខឹងនឹងមនោធាតុឬ ខឹងនឹងធម្មធាតុឬ ខឹងនឹងមនោវិញ្ញាណធាតុឬ កាលធ្វើធាតុវិនិព្ភោគយ៉ាងនេះ ឋានៈដែលតាំងនៃសេចក្តីក្រោធក៏មិនមាន ដូចឋានៈដែលតាំងគ្រាប់ស្ពៃលើចុងដែកស្រួចមិនបាន និងឋានៈដែលតាំងចិត្តកម្ម គឺ ការគូសវាស ក្នុងអាកាសមិនមានដូច្នោះ ដូច្នេះ ។

## ( វិធីចុងបញ្ចប់ - ធ្វើទានសំវិភាគ )

បើព្រះយោគាវចរដែលមិនអាចធ្វើធាតុវិនិព្ភោគ ក៏គប្បីធ្វើទានសំវិភាគៈ គឺ

ការឲ្យ និងការចែករំលែកចុះ គប្បីឲ្យរបស់ផងខ្លួនដល់បរបក្ខ ទទួលវត្ថុនៃបរបក្ខមកដើម្បីខ្លួន ប្រសិនបើបរបក្ខជាភិន្នាជីវៈ ( មានអាជីវៈបែកធ្លាយ គឺមិនបរិសុទ្ធ ) មានបរិក្ខារមិនជារបស់គួរដល់ការបរិភោគសោត ក៏គប្បីឲ្យតែរបស់ផងខ្លួនទៅតែមួយចំណែក កុំទទួលរបស់គេឡើយ កាលលោកធ្វើទៅយ៉ាងនោះ សេចក្ដីអាឃាតក្នុងបុគ្គលនោះ នឹងស្ងប់រម្ងាប់ទៅបានយ៉ាងពិតប្រាកដ ហើយសេចក្ដីក្រោធម្នាងទៀត សូម្បីនឹងជាប់តាមមកតាំងអំពីអតីតជាតិ ក៏នឹងស្ងប់រម្ងាប់ទៅមួយរំពេចដូចគ្នា ដូចសេចក្ដីក្រោធរបស់ព្រះមហាថេរៈដែលបានបាត្រ ដែលព្រះបិណ្ឌ-បាតិកត្ថេរត្រូវដេញចេញពីសេនាសនៈ ក្នុងចិត្តលបព៌តវិហារដល់ទៅ ៣ ដង នាំបាត្រចូលទៅពិតថេរដីកាថា បពិត្រព្រះមហាថេរៈដ៏ចម្រើន បាត្រមួយនេះតម្លៃ ៨ កហាបណៈ ឧបាសិកា ញោមស្រីរបស់ខ្ញុំព្រះករុណាប្រគេន ទើបជាលាភដែលប្រកបដោយធម៌ សូមលោកម្ចាស់ មេត្តាប្រោសជួយមហាឧបាសិការបស់ខ្ញុំព្រះករុណាឲ្យបានបុណ្យផងចុះ ដូច្នេះហើយ បង្អោនថ្វាយរម្ងាប់ទៅដូច្នោះ ដែលឈ្មោះថា ការឲ្យនេះ មានអានុភាពច្រើនយ៉ាងនេះ សមដូចបុរាណថា :

**ការឲ្យ រមែងបង្ក្រាបបុគ្គលដែលនរណាៗ បង្ក្រាបមិនបាន ក៏បាន ការឲ្យរមែងញុំាងវត្ថុបំណងទាំងពួងឲ្យសម្រេចក៏បាន ដោយការឲ្យ និង ការចរចាពីរោះប្រកបគ្នា ធ្វើឲ្យជនទាំងឡាយងើយឡើងក៏មាន ឱនចុះក៏មាន ។**

កាលព្រះយោគាវចរនោះ មានបដិឃៈក្នុងបុគ្គលដែលជាសត្រូវ រម្ងាប់ទៅដោយការទូន្មានខ្លួន មានប្រការផ្សេងៗ ដូចពោលមកហើយ ចិត្តរបស់លោកក៏រមែងប្រព្រឹត្តទៅដោយធ្វើមេត្តាឲ្យមានឡើង សូម្បីក្នុងបុគ្គលដែលជាសត្រូវនោះបាន ដូចក្នុងបុគ្គលដែលជាទីស្រឡាញ់ បុគ្គលដែលជាសម្លាញ់ស្រឡាញ់គ្នាខ្លាំង

និង បុគ្គលដែលជាកណ្តាលៗ ដូច្នោះ ។

## សីមាសម្ភេទ-រួមដែន

តទៅនេះព្រះយោគាវចរនោះដែលធ្វើមេត្តា ឲ្យកើតឡើងបានរឿយៗ រហូតញ៉ាំងសមចិត្តតា គឺ ការមានចិត្តស្មើក្នុងជនទាំង ៤ គឺ ក្នុងខ្លួនឯង ក្នុងបុគ្គលជាទីស្រឡាញ់ ក្នុងបុគ្គលកណ្តាលៗ ក្នុងបុគ្គលដែលជាសត្រូវ ឲ្យសម្រេចបាន គប្បីធ្វើសីមាសម្ភេទ គឺ ការរួមដែនតទៅ នេះជាលក្ខណៈនៃសីមាសម្ភេទនោះ គឺ ៖

ប្រសិនបើបុគ្គលដែលជាព្រះយោគាវចរនេះ ព្រមដោយភិក្ខុជាទីស្រឡាញ់ និងដែលកណ្តាលៗ ដែលជាសត្រូវគ្នា មាន ៤ រូប ទាំងខ្លួនឯង អង្គុយនៅក្នុងទីកន្លែងមួយ បើមានពួកចោរមកប្រាប់ថា លោកឲ្យភិក្ខុមួយរូបដល់ពួកខ្ញុំ កាលលោកសួរថា ព្រោះហេតុអ្វី ក៏តបថា ដើម្បីសម្លាប់ភិក្ខុអង្គនោះ ហើយយកឈាមមកធ្វើពលីកម្មដូច្នេះសោត ប្រសិនបើភិក្ខុដែលជាព្រះយោគាវចរនោះគិតថា ក្នុងភិក្ខុទាំងនោះ ពួកចោរចាប់ភិក្ខុអង្គនោះៗ ទៅ ដូច្នេះ ក៏ជាហេតុមិនបានធ្វើសីមាសម្ភេទឡើយ សូម្បីប្រសិនបើលោកគិតថា ពួកចោរចូរចាប់យើងចុះ កុំចាប់ភិក្ខុ ៣ អង្គនេះឡើយ ដូច្នេះក៏នៅតែមិនបានធ្វើសីមាសម្ភេទ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះលោកត្រូវការឲ្យចោរចាប់ភិក្ខុអង្គណាៗ ក៏ឈ្មោះថា លោករកសេចក្តីវិនាសឲ្យដល់ភិក្ខុអង្គនោះៗ រកប្រយោជន៍ឲ្យដល់ភិក្ខុក្រៅពីនេះតែម្ខាង លុះតែកាលណាលោកមិនឃើញនរណាសូម្បីតែម្នាក់ ក្នុងរវាង ៤ នាក់ នឹងគួរឲ្យដល់ពួកចោរ ចិត្តប្រព្រឹត្តទៅស្មើពិត ទាំងក្នុងខ្លួនឯង និងបុគ្គលទាំង ៣ នោះ កាលនោះទើបឈ្មោះថា ជាការដែលបានធ្វើសីមាសម្ភេទ ហេតុនោះ បុរាណាចារ្យទាំងឡាយទើប

ពោលទុកថា ៖

កាលណាព្រះយោគាវចរ ដែលមានចិត្តគិតធ្វើឧបការគុណដល់សត្វទាំង-ឡាយ នៅឃើញភាពផ្សេងៗ គ្នា ក្នុងជន ៤ នាក់ គឺក្នុងខ្លួនឯង ក្នុងបុគ្គលដែលជាទីស្រឡាញ់ ក្នុងបុគ្គលកណ្តាលៗ និងក្នុងបុគ្គលជាទីស្អប់នៅឡើយ កាលនោះមិនទាន់ហៅថា ជាបុគ្គលឈ្លាស បានមេត្តាឈានដូចដែលត្រូវការ លុះតែកាលណាដែនទាំង ៤ ភិក្ខុដែលជាព្រះយោគាវចររួមចូលគ្នាហើយ ផ្សាយមេត្តាទៅកាន់សត្វលោកទាំងពួង ព្រមទាំងទេវតាផងស្មើគ្នាទាំងអស់ កាលនោះលោកជាអ្នកមានមេត្តាមិនប្រាកដដែន ទើបបានឈ្មោះថា ជាបុគ្គលមហាវិសេសក្នុងមេត្តាភាវនាជាងព្រះយោគាវចរអង្គមុន ។

## មហាដីកា

ពាក្យថា **ក្នុងបុគ្គលលំដាប់មុនៗ** គឺ ក្នុងបុគ្គលលំដាប់មុនៗ មានបុគ្គលជាទីស្រឡាញ់ក្រៃលែងជាដើម ដែលជាអារម្មណ៍របស់ឈាន ។ ពាក្យថា **ចូលមេត្តា** គឺ ចូលមេត្តាឈានដែលលោកសង្កត់បដិឃៈហើយ ធ្វើឲ្យកើតឡើងបាន ។ ក៏ក្នុងពាក្យថា អ្នកផ្សាយមេត្តានឹងបន្ទោបង់បដិឃៈបាននេះ អាចារ្យពួកខ្លះពោលអធិប្បាយថា សម្រេចឧបចារជ្ឈាន ក៏គួរនឹងសំដៅយក សូម្បីការចេញចាកឧបចារជ្ឈានផងព្រោះអាចារ្យទាំងនោះពោលទុកថា ចេញ ។ ការសង្កត់បដិឃៈនោះហើយ ធ្វើឈានឲ្យកើតឡើង និងការចូលឈាន លោកអាចារ្យពោលទុកដោយជាសាធារណៈដល់ព្រះយោគីដែលមិនបានធ្វើបដិឃៈឲ្យកើតឡើង ព្រោះក្នុងខាងដើមមិនទាន់មានការរៀក មិនទាន់មានការដាក់ចិត្តក្នុងបុគ្គលនោះ តែឥឡូវនេះ លោកបំណងសម្តែង

វិធីដែលជាហេតុមិនឲ្យបដិឃៈកើតឡើងដល់ព្រះយោគី សូម្បីថា វឮកដល់ សូម្បីថា ដាក់ចិត្តក្នុងបុគ្គលមានពៀរនោះ ទើបពោលពាក្យនេះទុកថា បុគ្គលផ្សាយមេត្តាទៅកាន់បុគ្គលនោះ នឹងបន្ទោបង់បដិឃៈបានដូច្នេះ ។ ព្រោះក្នុងទីនេះលោកបំណងក្នុងការប្រើមេត្តានោះឯងដើម្បីបន្ទោបង់បដិឃៈ ។ ពាក្យថា **បដិឃៈក៏មិនរលត់** គឺប្រសិនបើ បដិឃៈមិនស្ងប់ ។

ពាក្យថា **ដោយការរឮកដល់** មានសេចក្តីថា ដោយការពិចារណាតាមអាគម គឺ ព្រះពុទ្ធវចនៈដែលជាគោល ។ បទថា **ឃដិតព្វំ** ប្រែថា គប្បីព្យាយាម ។

ក៏សេចក្តីព្យាយាម គឺ សេចក្តីខ្នះខ្នែងនោះឯង ។ ឈ្មោះថា **ដោយអាការដូចតទៅនេះ** គឺ ដោយអាការដែលនឹងពោលដល់ក្នុងឥឡូវនេះ ។

វណា ឈ្មោះថា **ឧភតោទណ្ឌកំ** ព្រោះអត្ថថា មានដងទាំងពីរខាង គឺត្រង់ទីពីរកន្លែង បានដល់ ប្រើរណានោះ ។ ពួកចោរឈ្មោះថា អ្នកប្រព្រឹត្តថោកទាប គឺជាអ្នកអាក្រក់ មានការប្រព្រឹត្តថោកទាប ។ ពាក្យថា **ក្នុងពួកចោរនោះ** គឺ សូម្បីក្នុងពួកចោរដែលកំពុងកាត់អវយវៈតែមួយចំណែក សូម្បីទាំងនោះ ។ បទថា **តេន** បានដល់ ព្រោះការធ្វើចិត្តឲ្យខឹងក្រោធ ។ ឈ្មោះថា មិនជាអ្នកធ្វើតាមពាក្យប្រៀនប្រដៅរបស់តថាគត ព្រោះថា ការមិនធ្វើបាបទាំងពួង ជាពាក្យប្រៀនប្រដៅក្នុងគាថា ។ បទថា **តស្សេវ** កែជា **តតោបិ** គឺជាងអ្នកដែលក្រោធមុននោះទៅទៀត ។ ព្រោះថា បទនេះជាឆដ្ឋីវិភត្តិ ក្នុងអត្ថនៃបញ្ចមីវិភត្តិ , រីឯ **ឯវ** ស័ព្ទ ក្នុងអត្ថថា **សមុច្ចយ** គឺ បន្ថែមសេចក្តីថា អាក្រក់ជាងបុគ្គលដែលក្រោធមុននោះទៅទៀត ។ បទថា **តេន** បានដល់ ព្រោះការក្រោធតប ។ ពាក្យថា **ឈ្មោះថាអាក្រក់ជាង** គឺ ឈ្មោះថាអាក្រក់ជាង ។ សូម្បីជ្រាបហើយថា សេចក្តីក្រោធមានតែទោស ព្រោះ

ជាទីតាំងនៃការតាមជាប់ស្អិតនៃកិលេស មានការប្រណាំងវាសនាជាដើម ក៏ក្រោធតបវិញបាន អាចារ្យពួកខ្លះពោលថា ប្រសិនបើកើតសេចក្ដីសម្គាល់ក្នុងសេចក្ដីក្រោធថា ជាធម៌ដែលមានទោស ក៏មិនគួរក្រោធតបនឹងបុគ្គលដែលក្រោធមុន ដូចគ្នានោះឯង ដូច្នេះ ។ បទថា **ឧភិន្នំ** ប្រែថា ដល់បុគ្គលពីរចំណែក ។ ព្រោះហេតុនោះ ទើបត្រាស់ទុកថា គឺ ដល់ខ្លួន និង អ្នកដទៃដូច្នេះ ។

ន័យម្យ៉ាងទៀត **ឧភិន្នំ** មានសេចក្ដីថា ដល់លោកទាំងពីរ គឺ លោកនេះនិងលោកខាងមុខ ។

ពាក្យថា **ដែលសត្រូវពេញចិត្ត** គឺ ដែលសត្រូវជាបដិបក្ខប្រាថ្នា ។ បទថា **សបត្តករណា** គឺ បុគ្គលដែលជាសត្រូវទាំងនោះគប្បីធ្វើ ។ បទថា **កោធនំ** គឺ បុគ្គលក្រោធដែលមានប្រក្រតីក្រោធ ។ បទថា **កោធនាយំ** កាត់បទជា **កោធនោ អយំ** ក៏ **អយំ** ស័ព្ទ ត្រឹមតែជានិបាត ។ បទថា **កោធបរេតោ** ប្រែថា ប្រព្រឹត្តទៅតាមសេចក្ដីក្រោធ ឬប្រែថា ត្រូវសេចក្ដីក្រោធគ្របសង្កត់ ។ ពាក្យថា **ឈ្មោះថានៅជាអ្នកមានពណ៌សម្បុរអាក្រក់នោះឯង** មានសេចក្ដីថា សូម្បីជាបុគ្គលមានពណ៌ស្អាតតាមប្រក្រតី សូម្បីតុបតែងខ្លួនហើយ ក៏ឈ្មោះថា ជាបុគ្គលអាក្រក់នោះឯងទាក់ទងនឹងការមានភាពពិការ ( ក្រញូវ , កន្ទួល )នៃទឹកមុខជាដើម ទាំងក្នុងបច្ចុប្បន្ននេះ និងក្នុងអនាគត ។ ទ្រង់ធ្វើការភ្ជាប់ថា **ទុព្វណ្ណោវ** ដូច្នេះហើយ ក៏ត្រាស់ថា **កោធាភិភូតោ** គឺ អ្នកត្រូវសេចក្ដីក្រោធគ្របសង្កត់ទៀត ជាពាក្យមួយដើម្បីសម្ដែងថា នេះគឺផលដែលពិតប្រាកដនៃការគ្របសង្កត់របស់សេចក្ដីក្រោធ ។ ពាក្យថា **សូមកុំឲ្យវាជាអ្នកមានផលប្រយោជន៍ច្រើន** គឺ សូមកុំឲ្យវាជាអ្នកមានទ្រព្យច្រើន ។ ពាក្យថា **សូមកុំឲ្យវាជាអ្នកមានភោគទ្រព្យ** គឺ ឲ្យវាជាអ្នកខ្វះខាតវត្ថុដែល

ជាគ្រឿងឧបភោគបរិភោគ ។ ពាក្យថា **សូមកុំឲ្យវាជាបុគ្គលមានយសសក្តិ** គឺ សូមកុំឲ្យវាជាបុគ្គលមានយសសក្តិ ។

បទថា **ឆវាលាតំ** ប្រែថា អុសសម្រាប់ដុតខ្មោច អាចារ្យច្រើនទាក់ពោលថា បានដល់ អុសសម្រាប់ដុតក្នុងជើងថ្ករ ដូច្នេះក៏មាន ។ ពីរបទថា **ឧភតោ បទិត្តំ** ប្រែថា ត្រង់ចុងទាំងពីរក៏ត្រូវភ្លើងឆេះ ។ ពាក្យថា **ត្រង់កណ្តាលប្រឡាក់លាមក** បានដល់ ត្រង់កណ្តាលប្រឡាក់លាមក គឺវត្ថុដែលក្តៅ ឬចចកបន្ទោបង់ ។ ពាក្យថា **ដើម្បីជាគ្រឿងឈើ** គឺ វត្ថុដែលគួរធ្វើដោយឈើ ។ ឈ្មោះថា **នឹងប្រើក៏មិនបាន** គឺ មិនសម្រេច ។ បទថា **តថូបមាហំ** គឺយើងពោលដល់បុគ្គលនេះថា មានឧបមាដូច្នោះ គឺ ដូចជាអុសសម្រាប់ដុតសពនោះ ។ បទថា **បុគ្គលនេះ ព្រះសាស្តាត្រាស់សំដៅយកបុគ្គល ដែលបានត្រាស់ទុកក្នុងខាងដើមដោយពាក្យថា តែគេជាអ្នកច្រើនដោយអភិជ្ឈាដូច្នេះជាដើម ព្រោះដូច្នោះ ទើបមានអធិប្បាយថា** បានដល់ បុគ្គលដែលប្រាសចាកសីល ព្រោះមានតម្រេកខ្លាំងក្លាក្នុងកាមទាំងឡាយជាដើម ។ តែក្នុងរឿងការចម្រើនមេត្តានេះ បណ្ឌិតគប្បីប្រកបពាក្យពោល ដោយទាក់ទងនឹងការមានចិត្តព្យាបាទ មានការត្រិះរិះដោយចិត្តដែលប្រទូស្ត ។

ពាក្យថា **ឥឡូវនេះ ខ្លួនអ្នកនោះជាដើម** ជាពាក្យសម្តែងអាការដែលប្រើបទព្រះសូត្រទាំងឡាយតាមដែលពោលហើយទូន្មានខ្លួន ។

ពាក្យថា **ធម៌ណាៗ** បានដល់ សុចរិតធម៌ណាៗ ក្នុងបណ្តាសមាចារទាំងឡាយ មានកាយសមាចារជាដើម ។ ពាក្យថា **ស្ងប់** គឺ សង្រួម ។ ពាក្យថា **បរិសុទ្ធ** គឺ ផូរផង់ ព្រោះប្រាសចាកមន្ទិល គឺ កិលេស ។ ម្យ៉ាងទៀត ឈ្មោះថា ស្ងប់ ព្រោះមិនមានការក្តៅក្រហាយ គឺ កិលេស ឈ្មោះថា បរិសុទ្ធ ព្រោះភាព

ដែលមិនមានទោស បុគ្គលនឹងគប្បីជ្រាបសេចក្តីស្ងប់នៃកាយសមាចារនោះឯង ក៏ដោយភាពដែលគេជាបុគ្គលមានកាយកម្មបានសង្រួមហើយ អស់កាលដ៏យូរ ។ សូម្បីក្នុងសមាចារ ដ៏សេសក៏យ៉ាងនេះ ។

បទថា **គេ** បានដល់ វចីសមាចារ និង មនោសមាចារ ។

ពាក្យថា **នោះ** គឺ បុគ្គលដែលមានវចីសមាចារស្ងប់ ។ ពាក្យថា **ជាបុគ្គលឆ្លាតក្នុងបដិសណ្ឋារៈ** គឺ ជាបុគ្គលឆ្លាតក្នុងបដិសណ្ឋារៈដោយប្រការដែលមិនមានទីទំនេររវាងខ្លួន និងអ្នកដទៃ ។ ពាក្យថា **ផ្អែមពីរោះ** គឺ ដល់ព្រមដោយភាពទន់ផ្អែម ពោលគឺ អធិវាសនខន្តិ ការអត់ធន់ គឺ ការអត់សង្កត់ ។ បទថា **សុខសម្ភាសោ** បានដល់ មានពាក្យពោលគួរស្រឡាញ់ ។ ពាក្យថា **ធ្វើឲ្យរីករាយចិត្ត** គឺ ជាអ្នកមានប្រក្រតីធ្វើឲ្យរីករាយចិត្ត ដោយសម្មោទនីយកថា ។ ពាក្យថា **មានទឹកមុខស្រស់ថ្លា** គឺ មិនជាបុគ្គលដែលមានទឹកមុខក្រញូវ គឺ មានទឹកមុខរីករាយដោយអំណាចនៃបីតិសោមនស្ស ។ ពាក្យថា **រាក់ទាក់** គឺ ជាអ្នកមានប្រក្រតីជួបនឹងនរណាៗម្នាក់ គេក៏រាក់ទាក់ ទាក់ទងជាបដិសណ្ឋារៈមុននោះឯង ។ ឈ្មោះថា សូធ្យធម៌ដោយសំឡេងដ៏ពីរោះ ក៏ដោយទាក់ទងនឹងការសូធ្យសរភញ្ញ ។ ក៏កាលធ្វើការសូធ្យសរភញ្ញ ឈ្មោះថា ពោលធម្មកថា ដោយបទ និងព្យញ្ជនៈដែលសមគួរ គឺ បរិបូណ៌ មិនរលាក់រលើក ។

អធិប្បាយថា ភាវៈដែលស្ងប់នៃមនោសមាចារនេះ ប្រាកដដល់ជនទាំងពួងបានដោយការធ្វើយ៉ាងគោរព ។ ព្រោះហេតុនោះ លោកទើបពោលថា ពិតណាស់ បុគ្គលណាដូច្នេះជាដើម ។ បទថា **ឱកប្បេត្វា** ប្រែថា ជឿហើយ ។ ព្រោះថា សទ្ធាមានការដាក់ចិត្តជឿជាលក្ខណៈ ។ ពាក្យថា **ផ្ទៀងសោតៈ** គឺ ផ្ទៀងត្រចៀក

មានសេចក្ដីថា ស្ដាប់ដោយល្អ ។ ពីរបទថា **អត្ថំ កត្វា** ប្រែថា ធ្វើឲ្យជារបស់មានប្រយោជន៍ ឬជាអ្នកប្រាថ្នាប្រយោជន៍ ។

បាឋៈថា **ឯកោបិ អវូបសន្តោ ហោតិ** ដូច្នេះ លោកអាចារ្យបំណងសម្ដែងថា បុគ្គលមានសភាពយ៉ាងនេះ រមែងចេញពីនរកចូលទៅកាន់នរក ត្រាច់ទៅក្នុងនរកនោះៗឯង អស់កាលដ៏យូរ ដូច្នេះទើបពោលថា គេនឹងជាអ្នកធ្វើនរក ៨ រណ្ដៅ និងឧស្សទនរក ១៦ រណ្ដៅឲ្យពេញដូច្នេះ ។ ក្នុងបណ្ដានរកទាំងនោះ នរក ៨ រណ្ដៅ មានសញ្ជីវនរកជាដើម គឺ ក្នុងសញ្ជីវ ១ កាឡសុត្តៈ ១ មហារោរុវៈ ១ ចូឡរោរុវៈ ១ បតាបនៈ ១ អវីចី ១ សង្ឃាតៈ ១ តាបនៈ ១ ឈ្មោះថា មហានរក ៨ រណ្ដៅ ។ ត្រង់ទ្វារនីមួយៗនៃអវីចីមហានរក មាននរកមួយទ្វារ ៤ រណ្ដៅ មានកុក្កុលនរកជាដើម ឈ្មោះថា ឧស្សទនរក ១៦ រណ្ដៅ ។ ឈ្មោះថា គប្បី ចូលទៅតាំងសេចក្ដីករុណាទុក ដោយភាពជាអ្នកមានចំណែកនៃទុក្ខដ៏ធំធេង ។ សេចក្ដីប្រាថ្នាក្នុងការកម្ចាត់ទុក្ខ ដែលជាការមិនបៀតបៀន ចូលទៅតាំងទុកបានក្នុងបុគ្គលណា ក្នុងបុគ្គលនោះបដិឃៈរកឱកាសមិនបានឡើយ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា ព្រោះថា ការអាឃាត និងការស្ងប់ ព្រោះអាស្រ័យសេចក្ដីករុណា ក៏បានដូច្នេះ ។

ពាក្យថា ដើម្បីការជាក់ច្បាស់នៃសេចក្ដីប្រកាន់នេះ គឺនៃអត្ថន័យដែលលោកពោលទុកដោយពាក្យថា **យោ យោ ធម្មោ** ជាដើម ។

បុគ្គលដែលមានពៀរនឹងគ្នា អាចធ្វើវត្ថុណាឲ្យជាទុក្ខ វត្ថុនោះបានដល់កាយរបស់កិក្ខុដែលលោកពោលថា ក្នុងវិស័យរបស់ខ្លួនដោយអំណាចនៃកាយ ដែលជាវិស័យនោះ ។ បទថា **កឹ** ប្រែថា ព្រោះហេតុអ្វី ។ ពាក្យថា **របស់គេ** គឺ របស់ជន

ដែលមានពៀរ ។ ពាក្យថា **មិនមែនវិស័យ** គឺ មិនមែនគោចរ ព្រោះភាពជាទីដែលមិនអាចធ្វើទុក្ខឲ្យកើតឡើងបាន ។ បទថា **សចិត្តេ** ប្រែថា ក្នុងចិត្តរបស់ខ្លួន ។ ពាក្យថា **ដែលសាងតែសេចក្ដីវិនាសដ៏ធំ** គឺដែលសាងតែសេចក្ដីវិនាសមហន្ត គឺ សន្ទឹកសន្ធាប់ និងមានបែបផ្សេងៗ ដែលមានប្រភេទទិដ្ឋធម្មិក គឺការវិនាសដែលមានក្នុងអត្តភាពនេះជាដើម ដោយទាក់ទងនឹងការធ្វើប្រយោជន៍ក្នុងលោកនេះ ប្រយោជន៍ក្នុងលោកខាងមុខ និងបរមត្ថប្រយោជន៍ឲ្យវិនាសបង់ ។ ពាក្យថា **ជាតួកាត់ឫសគល់** មានសេចក្ដីថា ហិរិឱត្តប្បៈ ខន្តី មេត្តា និងសេចក្ដីអាណិតអាសូរ ឈ្មោះថា ឫសគល់របស់សីល បានដល់ ជាតួកាត់ឫសគល់របស់សីល មានហិរិឱត្តប្បៈជាដើមទាំងនោះ ។ ពិតណាស់ សេចក្ដីក្រោធកំពុងកើតឡើងនោះឯង រមែងកាត់ហិរិឱត្តប្បៈនោះឯងដោយអំណាចបាណាតិបាតជាដើម ។ បទថា **ជឡោ** គឺបុគ្គលល្ងង់ បានដល់ បុគ្គលពាលដែលងងឹតងងល់ ។

ពាក្យថា **កម្មព្រៃផ្សៃ** លោកពោលដល់កំហុសដ៏ធំដែលបុគ្គលមានពៀរនឹងគ្នាបានធ្វើទុក ។ ពាក្យថា **យោ សយំ** កែជា **យោ ត្វំ សយម្បិ** គឺខ្លួនអ្នកទើបជាអ្នកបំផ្លាញខ្លួនឯង ។ ពាក្យថា **ដែលប្រាថ្នាធ្វើឲ្យក្រោធ** គឺ ដែលត្រូវការឲ្យសេចក្ដីក្រោធកើតឡើង ។ ឈ្មោះថា **ប្រសិនបើបានសាង** គឺ ប្រសិនបើបានធ្វើទុក ។ បទថា **កោសុប្បាទេន** ប្រែថា ដោយការធ្វើសេចក្ដីក្រោធឲ្យកើតឡើង មានសេចក្ដីថា ឈ្មោះថា **ធ្វើទុក្ខឲ្យដល់គេ** គឺ នឹងសាងទុក្ខដល់គេដែលមានកំហុសនោះ ។ ស័ព្ទថា **នាម** ជានិបាតប្រើក្នុងអត្ថ **អសម្ភាវន** គឺ មិនលើកតម្កើងមិនសរសើរ ដោយ ស័ព្ទថា **នាម** នោះ លោកសម្ដែងថា ការសាងទុក្ខឲ្យដល់គេ មិនមានភាពពិតប្រាកដ ។ ព្រោះហេតុនោះ លោកទើបពោលថា នឹងសាងបានក៏ដោយ មិនបាន

ក៏ដោយ ដូច្នេះ មានន័យថា នឹងធ្វើបានក៏ដោយ ធ្វើមិនបានក៏ដោយ ។ ពាក្យថា **ផ្លូវវិនាស** គឺ ផ្លូវទៅកាន់ទុគ្គតិ ដែលនាំមកនូវសេចក្តីវិនាសដល់ខ្លួន ។

ពាក្យថា **ក្នុងឋានៈដែលមិនគួរ** មានសេចក្តីថា ការក្រោធជាអ្នកសាងវត្ថុដែលគួរស្អប់ឲ្យដល់ខ្លួនអ្នក , តែសត្រូវដូចជាទាសៈរបស់សេចក្តីក្រោធ ព្រោះប្រព្រឹត្តទៅក្នុងអំណាចរបស់សេចក្តីក្រោធនោះ ព្រោះហេតុនោះ ទើបឈ្មោះថាជាឋានៈដែលមិនគួរដើម្បីធ្វើជំនួស ។ ព្រោះដូច្នោះ អ្នកចូរកាត់ គឺ កម្ចាត់សេចក្តីក្រោធនោះៗ ឯង ។ ពាក្យថា **ព្រោះភាពដែលធម៌ទាំងឡាយមានជួរខណៈ** មានសេចក្តីថា ធម៌ទាំងឡាយឈ្មោះថា ខណិកា គឺ មានជួរខណៈ ក៏ព្រោះអត្ថថាមានខណៈ គឺ កាលប្រព្រឹត្តទៅរបស់ខ្លួន ដែលខណ្ឌដោយការកើតឡើង និងការរលត់ទៅ បានដល់ ព្រោះមានភាវៈនោះ គឺព្រោះមានការបែកធ្លាយទៅជាខណៈ ។ ពាក្យថា **ឥឡូវនេះ ក្នុងទីនេះអ្នកនឹងក្រោធចំពោះអ្នកណា** មានសេចក្តីថា ខន្ធទាំងឡាយពួកណាក្នុងសន្តាន របស់សត្រូវដែលធ្វើខុស បានសាងការខុសដល់គេទុក ខន្ធទាំងនោះបានរលត់ទៅហើយដោយប្រការទាំងពួងក្នុងខណៈនោះៗ ឯង ។ តែថា ក្នុងឥឡូវនេះ ខន្ធពួកដទៃតាំងនៅ ព្រោះហេតុនោះ ក្នុងទីនេះអ្នកនឹងក្រោធចំពោះនរណាបាន អធិប្បាយថា មែនពិត ខឹងក្រោធក្នុងវត្ថុដែលគ្មានកំហុសមិនសមគួរ ។ ឈ្មោះថា វៀរបុគ្គលនោះចេញ គេនឹងគប្បីសាងទុក្ខឲ្យដល់នរណាបាន មានសេចក្តីថា បុគ្គលណានឹងសាងទុក្ខឲ្យដល់បុគ្គលណាបាន វៀរបុគ្គលដែលជាខេត្តនៃការសាងទុក្ខនោះចេញ គេអ្នកសាងទុក្ខនឹងគប្បីសាង នឹងគប្បីធ្វើទុក្ខឲ្យដល់នរណាបាន ។ ពាក្យថា **សូម្បីអ្នកខ្លួនឯងក៏ជាហេតុនៃទុក្ខបានយ៉ាងនេះ** គឺ សូម្បីខ្លួនឯង ក៏ជាហេតុនៃទុក្ខនោះបានយ៉ាងនេះ គឺ កាលទាំងខ្លួនគេ និងខ្លួនយើង ក៏ជា

ហេតុនៃទុក្ខ នោះបានដូចគ្នាយ៉ាងនេះ ព្រោះហេតុអ្វី ទើបក្រោធចំពោះគេប៉ុណ្ណោះ មិនក្រោធនឹងខ្លួនឯងផង ។

សត្វទាំងឡាយឈ្មោះថា **កម្មស្សកតា** ព្រោះអត្ថថា មានកម្មនោះឯងជារបស់ខ្លួន គឺជារបស់ខ្លួន ដោយភាពជាវត្ថុដែលជាប់តាមទៅបាន សូម្បីក្នុងលោកខាងមុខ ភាវៈនៃសត្វទាំងនោះឈ្មោះថា **កម្មស្សកតា** គឺ ភាវៈដែលសត្វទាំងឡាយជាអ្នកមានកម្មជារបស់ខ្លួន ។ ដែលបានឈ្មោះថា ការពិចារណាមានការហាមទុកបានជាប្រយោជន៍ និងការហាមទុកបាន ក៏រមែងមានដល់កម្មដែលមានការកើតឡើងជាប្រក្រតី ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា នឹងធ្វើកម្មណាៗដូច្នេះ , ឯកម្មដែលប្រព្រឹត្តទៅដោយអំណាចការអាក់អន់ រមែងនៅក្នុងទីជិត និងឃើញបានប្រចក្ស ព្រោះភាពដែលប្រាកដច្បាស់ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា តែថា កម្មនេះ ដូច្នេះជាដើម ។ **ច** ស័ព្ទ ប្រព្រឹត្តទៅក្នុងអត្ថថាជំទាស់ ប្រែថា ប៉ុន្តែ , **ច** ស័ព្ទនោះ រមែងផ្ទុះបញ្ចាំងដល់អត្ថដែលត្រូវពោលដោយការជំទាស់ដោយពាក្យថា មិនអាចនឹងធ្វើព្រះសម្មាសម្ពោធិញ្ញាណឲ្យសម្រេចបានឡើយ ដូច្នេះជាដើមនោះឯង ព្រោះជាផលហូរតាមកម្មនោះ ។ ភ្ជាប់សេចក្តីថា **នេវ សមត្ថំ** ។ ទុក្ខ ឈ្មោះថា **នេរយិកំ** គឺមានក្នុងនរក ព្រោះអត្ថថា ប្រកបក្នុងនរក ឬព្រោះអត្ថថា កើតក្នុងនរក អធិប្បាយថា ឈ្មោះថា រោយធូលី គឺ ទោសដាក់ខ្លួននោះឯង ។

ឈ្មោះថា គួរពិចារណាបុព្វចរិយាគុណរបស់ព្រះសាស្តា ព្រោះថា បដិឃៈគប្បីស្ងប់បាន សូម្បីព្រោះសេចក្តីគោរពចំពោះព្រះសាស្តា ។

អធិប្បាយថា ព្រោះព្រះសាស្តារបស់អ្នក សូម្បីថា ទ្រង់ជាព្រះពោធិសត្វ ក៏

មិនបានធ្វើចិត្តឲ្យប្រទូស្ត មិនមែនឬ នឹងពោលទៅថ្វីដល់ព្រះអង្គដែលត្រាស់ដឹងក្រៃលែងហើយ ។ ពាក្យថា **ដែលប្រទូស្តចំពោះព្រះទេវី** គឺ ធ្វើអាក្រក់ បានដល់ធ្វើខុស ទាក់ទងនឹងមិច្ឆាចារជាមួយព្រះទេវី ។ មនុស្សទាំងឡាយចោលសាកសពទុកត្រង់ព្រៃណា ព្រៃនោះឈ្មោះថា ព្រៃខ្មោចស្រស់ ។ បទថា **និក្ខញ្ញមានោ** ប្រែថា ទ្រង់ត្រូវគេកប់ ។ ពាក្យថា **ធ្វើការបុរស** គឺ ធ្វើការរបស់បុរសដោយកម្លាំងដៃ ដើម្បីប្រយោជន៍ដល់ការចេញចាករណ្តៅ ។ ពាក្យថា **ដោយអានុភាពរបស់យក្ខ** គឺ ដោយអានុភាពរបស់យក្ខដែលមានចិត្ត ត្រូវព្រះអង្គទ្រង់ធ្វើឲ្យត្រេកអរដោយការកាត់ក្តីឲ្យ ។ ពាក្យថា **ក្រឡាបន្ទំ** គឺ ព្រះដំណាក់ដែលអាស្រ័យនៅ ។

ពាក្យថា **គប្បីសង្ឃឹមរឿយៗទៅ** មានន័យថា គប្បីធ្វើការសង្ឃឹមប្រយោជន៍តាមដែលបំណងដោយធម៌ គឺដោយមិនមានទោសប៉ុណ្ណោះ ។ ពាក្យថា **កុំគប្បីនឿយណាយ** គឺ កុំគប្បីនឿយណាយថា សម្រាប់យើងដែលជួបតែសេចក្តីលំបាកយ៉ាងនេះ នឹងគប្បីបានភាពសួស្តីអំពីណាហ្ន៎ ដូច្នេះ ។ សេចក្តីនេះសមពិតតាមដែលត្រាស់ទុកថា មហាបពិត្រ កាលភាពវិបត្តិទាំងឡាយមានហើយ សូមព្រះអង្គទ្រង់ដឹង ប្រើកម្លាំងកាយចុះ ដូច្នេះ ។ ពាក្យថា **ប្រាថ្នាខ្លួនឯងទុកដោយប្រការណា** មានសេចក្តីថា យើងមិនធ្វើការបន្ទាប់បន្ថោនរណាៗ ប្រាថ្នាខ្លួនឲ្យតាំងនៅក្នុងរាជ-សម្បត្តិដោយប្រការណា ក៏ប្រសព្វថា យើងបានរស់ដោយប្រការនោះហើយ ។ ក៏សព្ទថា **វោ** ត្រឹមតែជានិបាត ។

ពាក្យថា **ព្រះរាជានៃដែនកាសី** គឺព្រះរាជានៃដែនកាសីព្រះនាមថា កលាពុ ។ ពាក្យថា **ខ្សែតីផ្តៅមានបន្លា** មានសេចក្តីថា ខ្សែតីផ្តៅដែលមានបន្លាដែក ឈ្មោះថា

ខ្សែតីផ្ដៅមានបន្ទា ។

ពាក្យថា **មនុស្សធំ** បានដល់ អ្នកមានវ័យចម្រើនតាមលំដាប់ហើយ ។ បទថា **វុឌ្ឍន្តិ** ប្រែថា នឹងរលត់ទៅ ។

ពាក្យថា **ជាកាលសម្រាប់សង្កត់ចិត្តទុកឲ្យល្អ** គឺជាកាលសម្រាប់ទូន្មានចិត្តដោយប្រពៃនោះឯង មិនព្រមឲ្យធ្វើការសេពខុស ។

បទថា **បុថុសល្វេន** ប្រែថា ព្រោះកូនសរធំ ។ បទថា **នាគោ** បានដល់ នាគៈ គឺ ដំរី ។ បទថា **វធិ** ប្រែថា បាញ់ ឬមានន័យថា សម្លាប់ ។ មានអធិប្បាយថា ឈ្មោះថា ការដែលលោកមកកាន់ស្ថានទីនេះ ហើយធ្វើចំពោះយើងយ៉ាងនេះ មិនមែនមានការទាក់ទងនឹងខ្លួនលោកខ្លួនឯង ព្រោះដូច្នោះ នេះជាការប្រកប គឺជាការសរសើររបស់នរណា គឺ របស់ព្រះរាជា ឬ របស់រាជអមាត្យ ។

ពាក្យថា **រស្មីមានពណ៌ ៦** គឺជាភ្លុកដែលប្រកបដោយវណ្ណៈ ( ពណ៌ ) ៦ មានពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហមជាដើម ។ ពិតណាស់ ព្រោះជាភ្លុកដែលមានពណ៌ ៦ ភ្លឺព្រោងព្រាយទៅ ទើបហៅដំរីនោះថា ឆទ្ទន្ត មិនមែនហៅថា ឆទ្ទន្ត ព្រោះជាដំរីមានភ្លុក ៦ នោះទេ ។

បទថា **ធាតោ** ប្រែថា ឃ្លាន ។ បទថា **ខាទេយ្យ** កែជា **ខាទេយ្យំ** ប្រែថា យើងស៊ី ឬបាឋៈជា **ខាទេយ្យំ** នេះឯង ។ បទថា **អាសិតោ** ប្រែថា ឆ្អែតស្កប់ស្កល់ហើយ ។ បទថា **សម្ពលំ** បានដល់ អាហារសម្រាប់ដើរផ្លូវ ទើបប្រែថា ស្បៀង ។ ក៏អាហារនោះ ព្រោះហេតុដែលពោលដោយឧបចារវោហារបានថា ជាប្រយោជន៍ដល់ការដើរផ្លូវ ដូច្នោះ ទើបហៅថា **បាថេយ្យំ** ក៏បាន ។ ស្ដេចកបិជ្រាបថា បុគ្គលនេះជាអន្ធពាល បៀតបៀនមិត្រហ្ន៎ ដូច្នេះហើយ ក៏មានសេចក្ដីករុណា

ប្រើខ្សែក្អែកដែលជោកដោយទឹកក្អែកសម្លឹងមើលបុរសនោះ ។

ក្នុងពាក្យថា **មា អយ្យោសិ មេ ភទន្តេ** នេះ ស័ព្ទថា **មា** ត្រឹមតែជានិបាត , ម្យ៉ាងទៀត ស័ព្ទថា **មា** ជាពាក្យហាម ប្រែថា កុំ , ដោយស័ព្ទថា **មា** នោះ ស្តេចកបិហាមការធ្វើខុសផ្សេងៗ ដែលបុរសនោះធ្វើតទៅ ។ បទថា **អយ្យោសិ មេ** មានសេចក្តីថា អ្នកជានាយ ឬធំដោយភាពដែលជាភ្ញៀវរបស់យើង ។ បទថា **ភទន្តេ** គឺ អ្នកដ៏ចម្រើន ជាពាក្យដែលបន្ទឹចេញមក ជាបិយវាចា ។ បទថា **ត្វំ នាម** មានសេចក្តីថា ឈ្មោះថា សូមឲ្យខ្លួនអ្នកកុំធ្វើកម្មដែលជាយ៉ាងនេះឡើយ ។

ប្រកបសេចក្តីថា ក៏ព្រះពោធិសត្វនោះជាតិរច្ឆាន គឺជាស្វាធំ គង់នាំបុរសនោះៗ ឯងទៅ រហូតដល់ភូមិប្រទេសដែលផុតភ័យ ។

ពាក្យថា **សូមឲ្យចាប់យើងដាក់ហិប** មានសេចក្តីថា សូមឲ្យប្រើជើងទាត់ហើយចាប់យើងដាក់ហិបតូច ។ ពាក្យថា **សូមឲ្យបោក** គឺ សូមឲ្យវាយដោយប្រការផ្សេងៗ ដើម្បីធ្វើឲ្យខ្សោយកម្លាំង ។ ពាក្យថា **ព្រាហ្មណ៍អាយលម្ពាយ** គឺ ព្រាហ្មណ៍គ្រូពស់ ដែលមានឈ្មោះយ៉ាងនេះ ។

**វា** ស័ព្ទ ក្នុងបទថា **បីតំ វា** នេះ ប្រព្រឹត្តទៅក្នុងវិកប្ប កំណត់ដល់អត្ថន័យដែលមិនទាន់បានពោលទុក ។ ដោយ **វា** ស័ព្ទនោះ សង្គ្រោះយកពណ៌ដែលមិនបានពោលដល់ មានពណ៌ស ពណ៌ក្រហមខ្ចីជាដើម ។ បទថា **ចិត្តានុវត្តន្តោ** ប្រែថា កាលនឹងអនុលោមតាមការពិត ។ យើងព្រោះគិតថា គ្រូពស់នេះនឹងបានលាភច្រើន ក៏ដោយប្រការយ៉ាងនេះ ដូច្នេះ ទើបនិម្មិតខ្លួនឲ្យជាអ្នកមានរស្មី មានពណ៌ដូចដែលគេគិត ។ ព្រះមានព្រះភាគទ្រង់សម្តែងទោសក្នុងការបៀតបៀនគ្រូពស់នោះដែលទ្រង់ឃើញហើយក្នុងគ្រានោះ ដោយព្រះអង្គឯងថា បើដោយអានុភាពរបស់

យើង យើងធ្វើទីគោកឲ្យមានទឹកក៏បាន ។ ល ។ គប្បីធ្វើគេឲ្យជាផេះទៅក៏បាន ។ តែប្រសិនបើយើង អ្នកមានអំណាចនៃចិត្តយ៉ាងនេះ គប្បីបៀតបៀនគេសោត ។ល។ នឹងមិនសម្រេចប្រយោជន៍ដ៏ឧត្តម ដូច្នេះ ។ ក្នុងព្រះតម្រាស់នោះ ពាក្យថា **ប្រយោជន៍ដ៏ឧត្តម** គឺ ត្រាស់ដល់ភាពជាព្រះពុទ្ធ ។ បទថា **ភោជបុត្តេហិ** កែជា **លុទ្ទបុត្តេហិ** គឺ កូនព្រាន ។

ពាក្យថា **ម្នាលលោកឧឡារ** អធិប្បាយថា ស្តេចនាគហៅនាយកងវេទះ អ្នកដែលជួយដោះខ្លួនឲ្យផុតចាកកណ្តាប់ដៃរបស់ពួកព្រានក្នុងវេលានោះ ដោយឈ្មោះ ។ បទថា **អតិកស្ស** កន្ត្រាក់ចេញ គឺ កញ្ឆក់ខ្សែស៊កចូលទៅក្នុងច្រមុះចេញមក ។ ពាក្យថា **ចោមរោមគ្នាចាប់** គឺប្រើផ្តៅ លតាវល្លិ៍ជាដើមដោតចងត្រង់រាងកាយគ្រប់កន្លែង អធិប្បាយថា ឈ្មោះថា ជាវត្ថុដែលគួរអស្ចារ្យ ក៏ដោយទាក់ទងនឹងភាពអត់ធន់ចំពោះការធ្វើដែលអត់ធន់បានដោយលំបាកទាំងឡាយ ។

ឈ្មោះថា មិនគួរ មិនសមគួរយ៉ាងក្រៃលែង ព្រោះដោយការដែលធ្វើបដិឃចិត្តឲ្យកើតឡើង ក៏សង្ឃឹមបាននូវភាពឃ្លាតចាកព្រះសាសនារបស់ខ្លួនដែលមានខន្តិគុណដែលនរណាៗ ប្រៀបស្មើមិនបាន ។

បទព្រះសូត្រទាំងឡាយ ដែលមកហើយដោយពាក្យថា **អនមតគ្គោ យំ ភិក្ខវេ សំសារោ** ជាដើម ឈ្មោះថា **អនមតគ្គិយានិ** ព្រោះអត្ថថា មានស័ព្ទថា **អនមតគ្គ** គឺសង្សារវដ្តដែលមានខាងដើម និងទីបំផុតដែលបុគ្គលតាមដឹងមិនបាន ឬព្រោះមានអនមតគ្គនោះជាអត្ថន័យ ។

ផ្លូវដែលត្រូវដើរទៅជាមួយនឹងហ្វូងពពែ ឈ្មោះថា **អជបថ** គឺ ផ្លូវពពែ ។ ផ្លូវដែលត្រូវប្រើទំពក់ទាញឈ្មោះថា **សង្កុបថ** គឺ ផ្លូវដែលត្រូវប្រើទំពក់ទាញ ។

ដោយពាក្យថា **សន្ទុ** លោកហៅឈើវែង ដែលមានអាការដូចទំពក់ ។ ដោយ **អាទិ** ស័ព្ទ លោករួមយកផ្លូវជ្រោះ ផ្លូវដែលដើរបានដោយលំបាកជាដើមចូលទុកផង ។ ពាក្យថា **ដែលមានក្បួនទ័ពពីរចំណែក** គឺ ដែលមានក្បួនទ័ពត្រង់ពីរបក្ខ ចូលសន្ទាប់ដើម្បីច្បាំងគ្នា ។ អធិប្បាយថា ឈ្មោះថា ធ្វើការងារដែលធ្វើបានដោយលំបាកផ្សេងៗ ក៏ដោយទាក់ទងនឹងការទៅក្នុងស្ថានទីដែលទៅបានដោយលំបាកនៃភ្នំ ដូចជាទីដែលចោទ ជ្រោះជ្រៅជាដើម ស្ថានទីទៅបានលំបាកនៃស្ទឹង ដូចជាអន្លង់ទឹកកួចជាដើម ដោយមិនរួញរា ។ ភ្ជាប់សេចក្តីថា គប្បីធ្វើចិត្ត គឺ ការគិតឲ្យកើតឡើងយ៉ាងនេះថា គេធ្លាប់ចិញ្ចឹមបីបាច់យើង ធ្វើឧបការគុណដល់យើង ការដែលយើងធ្វើចិត្តឲ្យប្រទូស្ត ក្នុងបុគ្គលនោះមិនសមគួរឡើយ ដូច្នេះ ។ ការធ្វើចិត្តឲ្យកើតឡើងតាមប្រការដូចពោលនេះ គប្បីជ្រាបដោយអំណាចការកាន់យកដោយកិច្ចមានការចិញ្ចឹមបីបាច់ជាដើម នូវបុត្រជាដើមដែលឃើញនៅក្នុងបច្ចុប្បន្ននេះ សម្រាប់អតីតដោយការឧបមាយក ។

ពាក្យថា **មេត្តា** បានដល់ ពោលគឺ មេត្តា ឬប្រកបដោយមេត្តា ។ ពាក្យថា **ចេតោវិមុត្តិ** គឺការតាំងមាំដោយប្រពៃនៃចិត្ត ។ បទថា **អាសេវិតាយ** ប្រែថា សេពដោយគោរពហើយ ។ ពាក្យថា **អប់រំហើយ** គឺ ចម្រើនហើយ ។ ពាក្យថា **ធ្វើឲ្យច្រើនហើយ** គឺ ធ្វើទុករឿយៗហើយ ។ ពាក្យថា **ធ្វើឲ្យដូចជាយានហើយ** គឺ ធ្វើឲ្យដូចជាយានដែលទឹមគោហើយ ។ ពាក្យថា **ធ្វើឲ្យដូចជាវត្ថុហើយ** បានដល់ ធ្វើឲ្យដូចជាវត្ថុ គឺ ដែលតាំងមាំហើយ ។ បទថា **អនុដ្ឋិតាយ** ប្រែថា តាំងមាំបានហើយ។ ពាក្យថា **សន្សំហើយ** បានដល់ ស្ទាត់ជំនាញហើយ គឺ សន្សំភាពជាវសីទុកហើយ។ ពាក្យថា **ប្រារព្ធល្អហើយ** គឺ ធ្វើឲ្យដល់ព្រមដោយល្អហើយ ។ ពាក្យថា **ក៏គប្បី**

**សង្ឃឹម** គឺ គប្បីប្រាថ្នា បានដល់ ត្រូវមានដោយពិត ។ ពាក្យដ៏សេសនឹងមកដល់ខាងមុខ ។

ពាក្យថា **ញែកធាតុ** គឺការបំបែកធាតុទាំងឡាយដោយវិធីបំព្រួញធាតុ ព្រមទាំងសម្ភារៈ គឺ គ្រឿងប្រកបជាដើម ។ លោកអាចារ្យធ្វើទុកក្នុងចិត្តថា ដែលបានឈ្មោះថា កំហុស ដែលគិតថា អ្នកដទៃគេធ្វើចំពោះយើង បុគ្គលរមែងកាន់យកបានដោយអាស្រ័យរូបធម៌របស់បុគ្គល ដែលធ្វើខុសជាហេតុ ព្រោះហេតុនោះ ទើបលោកពោលថា ខឹងនឹងសក់ឬ ? ដូច្នេះជាដើម ព្រោះបុគ្គលដែលធ្វើខុស ផុតទៅអំពីកោដ្ឋាស មានសក់ជាដើមមិនមាន ។ ឥឡូវនេះ ដើម្បីនឹងសម្តែងវិធីញែកធាតុដោយអំណាចបរមត្ថធម៌ដែលមិនមានទោសប៉ុណ្ណោះ លោកទើបពោលថា ក៏ម្យ៉ាងទៀតជាដើម ។ គប្បីប្រកប **ឧបាយ** ស័ព្ទ ទុកតែមួយបទយ៉ាងនេះថា **បញ្ចក្ខន្ធេឧបាទាយ** ព្រោះអាស្រ័យខន្ធ ៥ , **ទ្វាទសាយ ទនានិ ឧបាទាយ** ព្រោះអាស្រ័យអាយតនៈ ១២ , **អដ្ឋារធាតុយោ ឧបាទាយ** ព្រោះអាស្រ័យធាតុ ១៨ ដូច្នេះចុះ ។ ពាក្យថា **ស្ថានទីតាំងនៃសេចក្តីក្រោធរមែងមិនមាន** មានសេចក្តីថា ស្ថានទីតាំងនៃគ្រាប់ស្ពៃលើចុងដែកស្រួច និងនៃភាពចិត្តកម្មក្នុងអាកាស រមែងមិនមានយ៉ាងណា ស្ថានទីតាំងនៃសេចក្តីក្រោធក្នុងបុគ្គលដែលកំណត់ទុកថា មានពៀរនឹងគ្នានោះរមែងមិនមានក៏យ៉ាងនោះ ព្រោះធម្មជាតិទាំងឡាយ មានសក់ជាដើម មិនមែនវត្ថុដែលគប្បីក្រោធ និងព្រោះបុគ្គលដែលផុតទៅអំពីសក់ជាដើមនោះមិនមាន ។

ពាក្យថា **ការចែករំលែក** បានដល់ ការចែករំលែកអាមិស ។ ពាក្យថា **គួរឲ្យរបស់ផងខ្លួនដល់អ្នកដទៃ** គឺ ដល់អ្នកដែលជាសត្រូវ ។ ពាក្យថា **ជាអ្នកមានអាជីវៈបែកធ្លាយ** គឺជាអ្នកមានអាជីវៈមិនបរិសុទ្ធ ។ ពាក្យថា **កាលព្រះយោគីនោះ**

**ធ្វើយ៉ាងនេះ** គឺ កាលព្រះយោគីនោះ ធ្វើការចែករំលែក គឺជាអ្នកឲ្យដល់បុគ្គលដែលជាសត្រូវនឹងគ្នានោះយ៉ាងនេះ ។ ពាក្យថា **របស់បុគ្គលក្រៅអំពីនេះ** គឺ ព្រមទាំងសេចក្តីក្រោធរបស់បុគ្គលដែលជាបដិគ្គាហកៈ ។ ពាក្យថា **នេះជាបាត្រដែលឧបាសិកា ជាមាតារបស់ខ្ញុំព្រះករុណាប្រគេន** នេះជាពាក្យពោលដល់ហេតុនៃពាក្យថា ទើបជាលាភដែលកើតឡើងដោយធម៌នេះ ក៏ដោយពាក្យនោះ លោកសម្តែងភាពបរិសុទ្ធនៃការមករបស់បាត្រនោះ ។

ពាក្យថា **ក្នុងគាថាថា ធ្វើប្រយោជន៍ទាំងពួងឲ្យសម្រេច** បានដល់ ធ្វើវត្ថុដែលត្រូវការ គឺវត្ថុដែលឧបការៈ និងប្រយោជន៍ទាំងពួង មានយ៉ាងនេះថា ប្រយោជន៍ខ្លួន ប្រយោជន៍អ្នកដទៃ ប្រយោជន៍ដែលមានក្នុងអត្តភាពនេះ ប្រយោជន៍ដែលមានក្នុងចំណែកខាងមុខដូច្នេះជាដើមឲ្យសម្រេច ។ ចំណែកឯើយ បានដល់ ពួកទាយក ។ ចំណែកឱន បានដល់ ពួកបដិគ្គាហកៈ ។

ពាក្យថា **យ៉ាងនេះ** គឺ ដោយអាការដែលទូន្មានខ្លួន មានការរឭកដល់ព្រះពុទ្ធោវាទ ដែលមានឧបមាដោយរណាជាដើម តាមដែលពោលហើយ ។ ពាក្យថា **ស្ងប់បដិឃៈ** គឺ បន្ទោបង់សេចក្តីអាឃាតដោយកម្លាំងនៃការពិចារណា ។ ពាក្យថា **ក្នុងបុគ្គលនោះ** គឺសូម្បីក្នុងបុគ្គលដែលមានពៀរ ។ ដោយស័ព្ទថា **វេរី** គឺបុគ្គលមានពៀរនោះ ក្នុងទីនេះគប្បីជ្រាបដល់ការកាន់យក សូម្បីបុគ្គលសម្អប់ ព្រោះកាលសម្រេចមេត្តាក្នុងបុគ្គលដែលមានពៀរបានហើយ ក៏សម្រេចមេត្តាសូម្បីក្នុងបុគ្គលសម្អប់នោះផងដែរ ចំណែកការដែលលោកកាន់យកបុគ្គលជាសម្លាញ់ជាទីស្រឡាញ់ក្រៃលែង ទុកជាពួកមួយទៀតដទៃអំពីបុគ្គលដែលជាទីស្រឡាញ់យ៉ាងធម្មតា ក៏ដើម្បីសម្តែងភាវៈដែលធម៌ជាសត្រូវជិត ជាវត្ថុដោះបានដោយលំបាក ។

ពាក្យថា **ចិត្តក៏ប្រព្រឹត្តទៅដោយអំណាចមេត្តា** គឺដោយអំណាចការចម្រើនមេត្តា ។ ពាក្យថា **ភាពជាអ្នកមានចិត្តស្មើគ្នា** គឺភាពជាអ្នកមានចិត្តស្មើគ្នា ដោយការបង្អោនប្រយោជន៍ចូលទៅក្នុងជនទាំង ៤ ជំពូក ។ ដែលឈ្មោះថា **សីមាសម្ភេទ** គឺ ការទម្លាយព្រំដែន គឺ ភាពជាអ្នកមានចិត្តស្មើគ្នានោះៗ ឯង ក្នុងជនទាំង ៤ ជំពូក ។ ពាក្យថា **កាលបុគ្គលនេះ** គឺ កាលដែលបុគ្គលចម្រើនមេត្តាកម្មដ្ឋាននេះ ។ បទថា **និសិន្នេ**-អគ្គុយ ជាសត្តមីវិភត្តិ ក្នុងការលក្ខណៈដោយការៈ ។

ពាក្យថា **បុគ្គលចម្រើនដល់គ្នា បុគ្គលកណ្តាលៗ** គឺ ក្នុងបុគ្គលជាទីស្រឡាញ់ និងក្នុងបុគ្គលកណ្តាលៗ ។ បទថា **ចតុព្វិធេ** ប្រែថា ក្នុងជន ៤ ជំពូក អធិប្បាយថា ក្នុងជនជំពូកណានីមួយ ។ ពាក្យថា **ការប្លែកផ្សេងគ្នា** គឺ ការធ្វើផ្សេងៗគ្នា ដោយជាបុគ្គលជាទីស្រឡាញ់ បុគ្គលកណ្តាលៗ ជាដើម ។ ពាក្យថា **ជាអ្នកមានចិត្ត ប្រាថ្នាប្រយោជន៍ចំពោះសត្វទាំងឡាយប៉ុណ្ណោះ** មានសេចក្តីថា ហៅថា ជាអ្នកមានចិត្តប្រាថ្នាប្រយោជន៍ក្នុងសត្វទាំងឡាយតែម្យ៉ាងប៉ុណ្ណោះ តែមិនហៅថា ជាអ្នកបានមេត្តាតាមត្រូវការ ឬ មិនហៅថា ជាអ្នកឈ្លាសក្នុងមេត្តា ។ ព្រោះហេតុអ្វី ? ព្រោះហេតុដែលនៅឃើញសេចក្តីផ្សេងគ្នាក្នុងជនទាំង ៤ មានខ្លួនឯងជាដើមដូច្នេះ ។ ព្រោះហេតុអ្វី ទើបមិនហៅព្រះយោគីដែលមានចិត្តប្រាថ្នាប្រយោជន៍នេះថា ជាអ្នកឈ្លាសក្នុងមេត្តាផង ? មិនហៅថាបុគ្គលឈ្លាស ព្រោះលោកបំណងយកភាពជាបុគ្គលឈ្លាសដោយអំណាចនៃកុសល ដែលមានភាពល្អដ៏ក្រៃលែង ។ តែថា មេត្តាភាវនារបស់បុគ្គលនេះ មិនមែនមេត្តាភាវនាដែលមានភាពវិសេសទេៗ ន័យម្យ៉ាងទៀត គប្បីឃើញអត្ថក្នុងគាថានេះយ៉ាងនេះថា មិនហៅថាជាអ្នកបានមេត្តាតាមសេចក្តីត្រូវការ ព្រោះហេតុដែលនៅឃើញភាពផ្សេងគ្នាក្នុង

ជនទាំង ៤ មានខ្លួនឯងជាដើម ។ មិនហៅថាជាអ្នកឈ្លាស ព្រោះហេតុដែលជាបុគ្គលមានចិត្តឧបការៈចំពោះសត្វទាំងឡាយតែម្នាក់ៗ ដូច្នេះចុះ ។ ជន ៤ ជំពូកមានខ្លួនឯងជាដើម ឈ្មោះថា **សីមា** គឺ ព្រំដែនក្នុងទីនេះ ព្រោះក្នុងខាងដើមនៃការនាំដែលប្រព្រឹត្តទៅក្នុងអារម្មណ៍របស់មេត្តា ពោលគឺ សត្វតាំងនៅដោយរូបរបស់ព្រំដែន ដែលមិនលាយឡំគ្នានិងគ្នា ដូចតាមសីមា គឺ ដែននៃស្រុកជាដើម ដែលឈ្មោះថា **សីមា** ព្រោះតាំងនៅមិនលាយឡំគ្នា និងគ្នា និងស្រុកដទៃជាដើម ដូច្នោះ ព្រោះហេតុនោះ លោកទើបពោលថា ព្រំដែនទាំង ៤ ដូច្នេះ ។ ដើម្បីនឹងសម្តែងការទម្លាយដែលបានពោលទុកក្នុងពាក្យថា មានការទម្លាយបានហើយដូច្នេះ នេះលោកអាចារ្យពោលថា ផ្សាយមេត្តាបានស្មើគ្នាដូច្នេះ ។ ពាក្យថា **បុគ្គលមហាវិសេស** គឺ អ្នកដែលធំវិសេសក្រៃលែង គឺ អ្នកល្អក្រៃលែងដោយការនាំ។ ពាក្យថា **ជាងភិក្ខុអង្គមុន** គឺ ជាងភិក្ខុដែលនៅឃើញការផ្សេងគ្នាក្នុងខ្លួនឯងជាដើម។ បទថា **ន នាយតិ** ប្រែថា មិនប្រាកដ ។

( ចប់ មហាដីកា )

# មេត្តាឈាន

ក្នុងកាលស្មើគ្នានឹងកាលដែលរួមដែនបានយ៉ាងនេះនោះឯង ភិក្ខុ ( ព្រះយោគាវចរ ) នេះ គឺ បាននិមិត្ត និង ឧបចារៈផង កាលធ្វើការរួមដែនហើយ លោកសេពគ្រែលែងឡើងទៅ ចម្រើន ធ្វើឲ្យច្រើនឡើងទៅនូវនិមិត្តនោះឯង ក៏នឹងសម្រេចអប្បនាតាមន័យដែលពោលហើយ ក្នុងបឋវីកសិណ ដោយមិនលំបាកឡើយ ។

ដោយការនានុយោគត្រឹមប៉ុណ្ណោះ បឋមជ្ឈានដែលសហគតៈនឹងមេត្តា ដែលលះអង្គ ៥ ប្រកបដោយអង្គ ៥ មានលម្អ ៣ ប្រការ ដល់ព្រមដោយលក្ខណៈ ១០ គឺ ភិក្ខុ ( ព្រះយោគាវចរ ) នោះ បានសម្រេចហើយ និង កាលបានសម្រេចបឋមជ្ឈាននោះហើយ លោកសេពគ្រែលែងឡើងទៅ ចម្រើន ធ្វើឲ្យច្រើនឡើងទៅនូវនិមិត្តនោះឯង ក៏នឹងសម្រេចទុតិយជ្ឈាន និងតតិយជ្ឈានក្នុងចតុក្កន័យ និងទុតិយជ្ឈាន តតិយជ្ឈាន និង ចតុត្ថជ្ឈានក្នុងបញ្ចកន័យតាមលំដាប់ ពិតណាស់ព្រះយោគាវចរនោះ នឹងឈ្មោះថា មានចិត្តសហគតៈជាមួយមេត្តាផ្សាយទៅសព្វទិស ១ ទិសទី ២ ក៏យ៉ាងនោះ ទិសទី ៣ ក៏យ៉ាងនោះ ទិសទី ៤ ក៏យ៉ាងនោះ ទិសខាងលើ ទិសខាងក្រោម ទិសទទឹង ក៏ដោយន័យនោះឯង លោកមានចិត្តសហគតៈដោយមេត្តា ជាចិត្តធំទូលាយប្រមាណមិនបាន ជាចិត្តមិនមានពៀរ មិនមានព្យាបាទផ្សាយទៅក្នុងទិសទាំងពួង សព្វលោក ដែលមានសព្វសត្វ ដោយការមានខ្លួនស្មើគ្នា ក្នុងសត្វទាំងពួងបានដូច្នេះហើយ ក៏ដោយអំណាចឈាន មានបឋមជ្ឈានជាដើម ឈានណានីមួយ ព្រោះថា **វិកុព្វនា** គឺ ការធ្វើមេត្តាបានផ្សេងៗ នេះរមែងសម្រេចដល់ព្រះយោគាវចរដែលមានចិត្តដល់អប្បនា ដោយអំណាចនៃឈាន

មានបឋមជ្ឈានជាដើមប៉ុណ្ណោះ ( មិនមែនសម្រេចដល់អ្នកបានឧបចារៈ ) ទេ ។

## អធិប្បាយ បាលី អប្បមញ្ញា

ក្នុងបាលីនេះ បទថា **មេត្តាសហគតេន** គឺ សហគតៈនឹងមេត្តា មានសេចក្តីថា ប្រកបទៅដោយមេត្តា , បទថា **ចេតសា** គឺ មានចិត្ត ក៏គឺ **ចិត្តេន** គឺ មានចិត្ត ។ ពាក្យថា **ឯកំ ទិសំ** អស់ទិស ១ ត្រាស់ដោយការផ្សាយទៅដល់សត្វដែលទាក់ទងនៅក្នុងទិស ១ សំដៅយកសត្វដែលព្រះយោគាវចរកំណត់គ្រាជំបូងក្នុងទិស ១ ( ន័យថា ពោលថាទិស តែដែលពិតសំដៅដល់សត្វដែលនៅក្នុងទិសនោះ ) ។ បទថា **ផរិត្វា** ផ្សាយ គឺ សម្ផស្សដោយចិត្ត បានដល់ ធ្វើឲ្យជាអារម្មណ៍ ។ បទថា **វិហរតិ** ( នៅ ) សំដៅយកសេចក្តីថា ញុំាងឥរិយាបថវិហារ គឺ ការផ្លាស់ឥរិយាបថដែលអធិដ្ឋានដើម្បីព្រហ្មវិហារឲ្យប្រព្រឹត្តទៅ ។ ពាក្យថា **តថាទុតិយំ** គឺ ទិសទី ២ ក៏យ៉ាងនោះជាដើម មានសេចក្តីថា ក្នុងទិសទាំងឡាយ មានទិសខាងកើតជាដើម លោកផ្សាយទៅដល់ទិសណាៗ ក៏ដោយ ទិស ១ យ៉ាងណា ក៏ផ្សាយទៅអស់ទិសទី ២-៣ និងទី ៤ ក្នុងលំដាប់គ្នាក៏យ៉ាងនោះ ។ ពាក្យថា **ឥតិ ឧទ្ធំ** ខែសេចក្តីថា តាមន័យដូចគ្នានោះ ផ្សាយទៅក្នុងទិសខាងលើ ។ ពីរបទថា **អធោ តិរិយំ** គឺ សូម្បីក្នុងទិសខាងក្រោម សូម្បីក្នុងទិសទទឹងក៏យ៉ាងនោះដូចគ្នា ឯក្នុងពីរបទនោះ បទថា **អធោ** ទិសខាងក្រោម បានដល់ ទិសក្រោមខ្លួនយើងចុះទៅ ។ បទថា **តិរិយំ** ទិសទទឹង បានដល់ ទិសតូចទាំងឡាយ ។

ដោយន័យដូច្នេះ ព្រះយោគាវចរ ឈ្មោះថា ញុំាងចិត្តប្រកបទៅដោយមេត្តាឲ្យស្ទុះទៅខ្លះ ឲ្យត្រឡប់មកខ្លះក្នុងទិសទាំងពួង ដូចសារថីញុំាងសេះឲ្យរត់ទៅមកក្នុង

ទីលានសេះរាងវង្វង់មូលដូច្នោះឯង ។

ការកំណត់យកទិសនីមួយៗ ផ្សាយមេត្តាទៅជាផ្នែកៗ ព្រះមានព្រះភាគទ្រង់សម្តែងដោយបទព្រះបាលីត្រឹមនេះ គឺ ត្រឹម **ឧទ្ធមធោតិរិយំ** ចំណែកបទព្រះបាលីមានបទថា **សព្វធិ** ជាដើមទៅ ត្រាស់ដើម្បីសម្តែងការផ្សាយដោយមិនចោះចំពោះ គឺ រួមទាំងអស់ ។

ក្នុងបទទាំងនោះ បទថា **សព្វធិ** ក៏គឺ **សព្វត្ថ** ក្នុងទិសទាំងពួង បទថា **សព្វត្តតាយ** មានសេចក្តីថា ដោយភាពជាខ្លួនក្នុងសត្វទាំងពួង ដែលមានប្រភេទផ្សេងៗ ដូចជា ថ្នាក់ទាប ថ្នាក់កណ្តាល និង ថ្នាក់ខ្ពស់ ដែលជាមិត្រនឹងគ្នា ជាសត្រូវគ្នា និងកណ្តាលៗ ជាដើម មានអធិប្បាយថា ដោយភាពស្មើគ្នានឹងខ្លួន មិនបែងចែក ថាយើង ថាសត្វដទៃ , ន័យម្យ៉ាងទៀត បទថា **សព្វត្តតាយ** នោះសំដៅយកសេចក្តីថា ដោយចិត្តភាព គឺ កម្លាំងចិត្តទាំងអស់ អធិប្បាយថា មិនបណ្តោយឲ្យភ្លាត់ទៅខាងក្រៅកម្មដ្ឋាន សូម្បីតែបន្តិចបន្តួច , បទថា **សព្វាវន្តំ** មានសេចក្តីថា មានសព្វសត្វ គឺប្រកបដោយសព្វសត្វ , បទថា **លោកំ** សំដៅយកសត្វលោក ។

ឯពាក្យថា **មេត្តាសហគតេន** ត្រាស់ដដែលទៀតក្នុងពេល **អនោធិសោផរណា** គឺផ្សាយរួមនេះ ព្រោះដើម្បីសម្តែងបរិយាយ គឺ វេវចនៈនៃមេត្តាសហគតចិត្ត ។ មានពាក្យថា **វិបុលេន** ដូច្នេះជាដើម ឬព្រោះក្នុងវគ្គ **អនោធិសោផរណា** នេះមិនបានប្រើ **តថា** ស័ព្ទ ឬ **ឥតិ** ស័ព្ទទៀតទេ ដូចក្នុងវគ្គ **ឱធិសោផរណា** គឺ ផ្សាយជាផ្នែកៗ ព្រោះហេតុនោះ ទើបត្រាស់ពាក្យថា **មេត្តាសហគតេន ចេតសា** ដដែលទៀត ឬ មិនដូច្នោះ ពាក្យថា **មេត្តាសហគតេន ចេតសា** ក្នុងវគ្គនេះនោះ គប្បីជ្រាបថា ត្រាស់ជាពាក្យនិយមក៏បាន ។

## អត្ថនៃ វិកុព្វនា

ក្នុងបទថា **វិបុលេន** ជាដើមនោះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ តាមដែលមេត្តាសហគតចិត្ត ជាចិត្តទូលាយ បណ្ឌិតគប្បីឃើញថា ដោយអំណាចការផ្សាយ និងម្យ៉ាងទៀត ចិត្តនោះជាចិត្តធំដោយអំណាចភូមិ គឺជារូបាវចរ ជាចិត្តមិនមានប្រមាណដោយអំណាចការស្ទាត់ជំនាញ និង ដោយអំណាចភាពដែលមានសត្វមិនមានប្រមាណជាអារម្មណ៍ ឈ្មោះថា ជាចិត្តមិនមានពៀរ ព្រោះលះសត្រូវ គឺព្យាបាទចេញបាន , ឈ្មោះថា **ជាចិត្តមិនមានការបៀតបៀន** អធិប្បាយថា មិនមានទុក្ខ ព្រោះលះបង់ទោមនស្សបាន ។

នេះជាន័យនៃ **វិកុព្វនា** ដែលពោលដោយន័យថា **មេត្តាសហគតេន ចេតសា** ជាដើម និង **វិកុព្វនា** នេះ រមែងសម្រេចដល់ព្រះយោគាវចរ ដែលមានចិត្តដល់អប្បនាប៉ុណ្ណោះ យ៉ាងណា សូម្បីលក្ខណៈដែលរាប់ថាជា **វិកុព្វនា** ឯណា ដែលលោកពោលទុកក្នុងបដិសម្ភិទាថា **មេត្តាចេតោវិមុត្តិ** ជា **អនោធិសោ-ផរណា** ដោយអាការ ៥ , **មេត្តាចេតោវិមុត្តិ** ជា **ឱធិសោផរណា** ដោយអាការ ៧ , **មេត្តា ចេតោវិមុត្តិ** ជា **ទិសាផរណា** ដោយអាការ ១០ ដូច្នេះ សូម្បីលក្ខណៈវិកុព្វនានោះ បណ្ឌិតគប្បីជ្រាបថា រមែងសម្រេចដល់ព្រះយោគាវចរ ដែលមានចិត្តដល់អប្បនា ដូច្នោះដូចគ្នា ។

## អនោធិសោផរណា ៥

រីឯ ក្នុងលក្ខណៈទាំងនោះ **មេត្តាចេតោវិមុត្តិ** បណ្ឌិតគប្បីជ្រាបថា ជា **អនោធិសោផរណា** ដោយអាការ ៥ នេះ គឺ ៖

**១- សព្វេ សត្តា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ** សូមសត្វទាំងឡាយទាំងពួង ចូរជាអ្នកមិនមានពៀរ មិនមានព្យាបាទ មិនមានទុក្ខ មានសេចក្តីសុខ រក្សាខ្លួនចុះ ។

**២- សព្វេ បាណា...** សូមបាណៈ គឺ សត្វដែលទាក់ទងដោយខ្យល់ដង្ហើមទាំងឡាយទាំងពួង ។

**៣- សព្វេ ភូតា...** សូមភូត គឺ អ្នកកើតហើយទាំងឡាយទាំងពួង... ។

**៤- សព្វេ បុគ្គលា...** សូមបុគ្គលទាំងឡាយទាំងពួង... ។

**៥- សព្វេ អត្តភាវបរិយាបន្នា អវេរា ។ បេ ។ បរិហរន្តុ** សូមអ្នកដែលទាក់ទងនៅក្នុងអត្តភាពទាំងឡាយទាំងពួង ចូរជាអ្នកមិនមានពៀរ ។ ល ។ រក្សាខ្លួនចុះ ។

## ឱធិសោផរណា ៧

**មេត្តាចេតោវិមុត្តិ** បណ្ឌិតគប្បីជ្រាបថា ជា **ឱធិសោផរណា** ដោយអាការ ៧ នេះគឺ ៖

**១- សព្វេ ឥត្ថិយោ អវេរា ។ បេ ។ អត្តានំ បរិហរន្តុ** សូមស្រ្តីទាំងឡាយទាំងពួង ចូរជាអ្នកមិនមានពៀរ ។ ល ។ រក្សាខ្លួនចុះ ។

**២- សព្វេ បុរិសា...** សូមបុរសទាំងឡាយទាំងពួង... ។

**៣- សព្វេ អរិយា...** សូមអរិយជនទាំងឡាយទាំងពួង... ។

**៤- សព្វេ អនរិយា...** សូមអនរិយជនទាំងឡាយទាំងពួង... ។

**៥- សព្វេ ទេវា...** សូមទេពទាំងឡាយទាំងពួង... ។

**៦- សព្វេ មនុស្សា...** សូមមនុស្សទាំងឡាយទាំងពួង... ។

**៧- សព្វេ អវិនិបាតិកា អវេរា ។បេ។ អត្តានំ បរិហរន្តុ** សូមវិនិបាត គឺអ្នកធ្លាក់នៅក្នុងអបាយភូមិទាំងឡាយទាំងពួង ចូរជាអ្នកមិនមានពៀរ ។ល។ រក្សាខ្លួនទៅចុះ ។

## ទិសាផរណា ១០

**មេត្តាចេតោវិមុត្តិ** បណ្ឌិតគប្បីជ្រាបថា ជា **ទិសាផរណា** គឺ ផ្សាយជាទិសៗ ដោយអាការ ១០ នេះ គឺ ៖

**១- សព្វេ បុរត្ថិមាយ ទិសាយ សត្តា អវេរា ។បេ។ អត្តានំ បរិហរន្តុ** សូមសត្វទាំងឡាយទាំងពួងក្នុងទិសខាងកើត ចូរជាអ្នកមិនមានពៀរ ។ល។ រក្សាខ្លួនទៅចុះ ។

**២- សព្វេ បច្ឆិមាយ ទិសាយ សត្តា...** សូមសត្វទាំងឡាយទាំងពួងក្នុងទិសខាងលិច... ។

**៣- សព្វេ ឧត្តរាយ ទិសាយ សត្តា...** សូមសត្វទាំងឡាយទាំងពួងក្នុងទិសខាងជើង... ។

**៤- សព្វេ ទក្ខិណាយ ទិសាយ សត្តា...** សូមសត្វទាំងឡាយទាំងពួងក្នុងទិសខាងត្បូង... ។

**៥- សព្វេ បុរត្ថិមាយ អនុទិសាយ សត្តា...** សូមសត្វទាំងឡាយទាំងពួងក្នុងទិសឦសាន គឺ ទិសខាងកើតធៀងខាងជើង... ។

**៦- សព្វេ បច្ឆិមាយ អនុទិសាយ សត្តា...** សូមសត្វទាំងឡាយទាំងពួងក្នុង

ទិសនិរតី គឺ ទិសខាងលិចឆៀងខាងត្បូង... ។

**៧- សព្វេ ឧត្តរាយ អនុទិសាយ សត្តា...** សូមសត្វទាំងឡាយទាំងពួងក្នុងទិសពាយព្យ គឺ ទិសខាងលិចឆៀងខាងជើង... ។

**៨- សព្វេ ទក្ខិណាយ អនុទិសាយ...** សូមសត្វទាំងឡាយទាំងពួងក្នុងទិសអគ្នេយ៍ គឺ ទិសខាងកើតឆៀងខាងត្បូង... ។

**៩- សព្វេ ហេដ្ឋិមាយ ទិសាយ សត្តា...** សូមសត្វទាំងឡាយទាំងពួងក្នុងទិសខាងក្រោម... ។

**១០- សព្វេ ឧបរិមាយ សត្តា អវេរា ។ បេ ។ បរិហរន្តុ** សូមសត្វទាំងឡាយទាំងពួងក្នុងទិសខាងលើ ចូរជាអ្នកមិនមានពៀរ ។ល ។ រក្សាខ្លួនទៅចុះ ។

នេះបទសម្តែង **សត្តា** ជាតួយ៉ាង បទតទៅមានបទ " **បាណា** " ជាដើម ក៏គប្បីប្រកបសេចក្តីឲ្យដូចគ្នាតទៅនេះ លោកបេយ្យាលទុក ។

**សព្វេ បុរត្ថិមាយ ទិសាយ បាណា... ភូតា បុគ្គលា... អត្តភាវបរិយាបន្នា... សព្វេ បុរត្ថិមាយ ទិសាយ ឥត្ថិយោ... បុរិសា... អរិយា... អនរិយា... ទេវា... មនុស្សា... វិនិបាតិកា អវេរា ។បេ។ បរិហរន្តុ** សូមបាណៈទាំងឡាយ... ភូតទាំងឡាយ... បុគ្គលទាំងឡាយ បុគ្គលដែលទាក់ទងក្នុងអត្តភាពទាំងឡាយទាំងពួងក្នុងទិសខាងកើត... សូមស្រ្តីទាំងឡាយ... បុរសទាំងឡាយ... អរិយជនទាំងឡាយ... អនរិយជនទាំងឡាយ... ទេពទាំងឡាយ... មនុស្សទាំងឡាយ... វិនិបាតទាំងឡាយទាំងពួងក្នុងទិសខាងកើត ចូរជាអ្នកមិនមានពៀរ ។ ល ។ រក្សាខ្លួនចុះ ។

**សព្វេ បច្ឆិមាយ ទិសាយ... ឧត្តរាយ... ទក្ខិណាយ... អនុទិសាយ... ហេដ្ឋិមាយ ទិសាយ... ឧបរិមាយ ទិសាយ បាណា ។ បេ ។ ឥត្ថិយោ ។ បេ ។**

**វិទិសាតិកា អវេរា អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តុ** សូមបាណៈទាំង-ឡាយ ។ល ។ ស្ត្រីទាំងឡាយ ។ ល ។ វិនិបាតិកៈទាំងឡាយទាំងពួងក្នុងទិសខាងលិច… ទិសខាងជើង… ទិសខាងត្បូង… ទិសឦសាន… ទិសនិរតី ទិសពាយព្យ ទិសអគ្នេយ៍ ទិសខាងក្រោម ទិសខាងលើ ចូរជាអ្នកមិនមានពៀរ មិនមានការព្យាបាទ មិនមានទុក្ខ មានសេចក្តីសុខ រក្សាខ្លួនចុះ ។

## អធិប្បាយអត្ថ សព្វេ សត្តា ជាដើម

ក្នុងបទទាំងនោះ បទថា ទាំងពួងនោះ ជាពាក្យកាន់យកទាំងអស់មិនមានសល់ ជនដែលជំពាក់នៅ ជាប់នៅដោយឆន្ទរាគៈក្នុងខន្ធទាំងឡាយ មានរូបជាដើម ឈ្មោះថា សត្វ ពិតណាស់ ព្រះមានព្រះភាគក៏បានត្រាស់ពាក្យនេះដល់ព្រះរាធៈថា ម្នាលរាធៈ បុគ្គលណាមានសេចក្តីពេញចិត្ត មានតម្រេក មានសេចក្តីត្រេកអរ សេចក្តីប្រាថ្នាក្នុងរូប បុគ្គលនោះ ឈ្មោះថា ជាប់នៅក្នុងរូបនោះ ដោយហេតុនោះឯង ទើបបានឈ្មោះថា សត្វ បុគ្គលណាមានការពេញចិត្ត មានតម្រេក មានសេចក្តីត្រេកអរ មានសេចក្តីប្រាថ្នាក្នុងវេទនា… ក្នុងសញ្ញា… ក្នុងសង្ខារ… ក្នុងវិញ្ញាណ បុគ្គលនោះឈ្មោះថា ជាប់នៅក្នុងវេទនា… សញ្ញា… សង្ខារ… វិញ្ញាណនោះជាប់នៅក្នុងវេទនា ។ល។ វិញ្ញាណនោះ ហេតុនោះឯង ទើបបានឈ្មោះថា សត្វ ដូច្នេះ តែដោយ **រុឡ្ហិ** សត្តូ ( សត្តូ ហៅ )វោហារថា សត្វនេះ ប្រើក្នុងលោកអ្នកប្រាសចាករាគៈហើយ ក៏បានដូចគ្នា ដូចពាក្យថា **តាលវណ្ត** ( ផ្លិតធាងត្នោត ) ប្រើក្នុងផ្លិតមួយប្រភេទ ដែលធ្វើដោយឫស្សីត្បាញក៏បាន ដូច្នេះ ចំពោះពួកអក្ខរ-ចិន្តកៈ ( អ្នកគិត ក្នុងអក្សរ ) មិនវិចារសេចក្តី ក៏កាន់យកថា នោះជាពាក្យនាម

ប៉ុណ្ណោះ ខាងពួកលោកអ្នកដែលវិចារសេចក្តីបំណង សេចក្តីថា ឈ្មោះថា សត្វ ព្រោះប្រកបដោយសត្វក៏មាន ។

សត្វទាំងឡាយ ឈ្មោះថា **បាណា** ព្រោះភាវៈ គឺ ការដកដង្ហើម សេចក្តីថា ព្រោះមានការប្រព្រឹត្តទៅ ទាក់ទងដោយខ្យល់ដង្ហើមចេញ-ចូល ។

ឈ្មោះថា **ភូត** ព្រោះកើតហើយ សេចក្តីថា ព្រោះកើតឡើងព្រម គឺ កើតធំឡើង ។

**និរយ** លោកហៅថា **បុំ** សត្វទាំងឡាយរមែងធ្លាក់ចុះ មានសេចក្តីថា រមែងទៅក្នុងនិរយដែលហៅថា **បុំ** នោះ ព្រោះហេតុនោះ ទើបឈ្មោះថា បុគ្គល ។

**រាងកាយ** ហៅថា **អត្តភាព** ម្យ៉ាងទៀត **អត្តភាព** ក៏គឺខន្ធ ៥ នោះឯង ពាក្យថា **អត្តភាព** នេះ ក៏ជាពាក្យដែលសំដៅដល់ខន្ធ៥ បញ្ញត្តឡើងដោយសភាវៈ , សត្វទាំងឡាយទាក់ទងនៅក្នុងអត្តភាពនោះ ហេតុនោះ ទើបឈ្មោះថា **អត្តភាវ-បរិយាបន្ន** ពាក្យ **បរិយាបន្ន**-ទាក់ទង មានសេចក្តីថា កំណត់ទុកក្នុងនោះ នៅក្នុងនោះ ។

ឯពាក្យថា **សត្តា**-សត្វទាំងឡាយ ( មានន័យ ) យ៉ាងណា សូម្បីពាក្យដ៏សេស ( មានពាក្យថា **បាណា** ជាដើម ក៏មានន័យ ) ដូចគ្នា បណ្ឌិតគប្បីជ្រាបពាក្យនោះជាវេវចនៈរបស់ពាក្យថា **សព្វសត្វ** ទាំងនោះឯង ព្រោះលើកឡើងដោយអំណាច **រុឡ្ហិ** ស័ព្ទ ។

វេវចនៈរបស់ពាក្យសព្វសត្វដទៃៗ ដូចជា **សព្វេ ជន្តូ សព្វេ ជីវា** នៅមានទៀតក៏ពិត តែ ( ក្នុងបដិសម្ភិទាលោកកាន់យកពាក្យ ៥ ពាក្យនេះប៉ុណ្ណោះ ពោលទុកថា មេត្តាចេតោវិមុត្តិ ជាអនោធិសោផរណាដោយអាការ ៥ ដូច្នេះ ក៏ដោយ

( ពាក្យទាំង ៥ នោះ ) ជាពាក្យប្រាកដ , ចំណែកកេចិអាចារ្យពួកណាមិនត្រូវការ ( ឲ្យកើត ) ត្រឹមសេចក្ដីដែលពាក្យទាំងឡាយ មាន **សត្តា បាណា** ជាដើម ជាវេវចនៈគ្នាប៉ុណ្ណោះ តែបើត្រូវការដល់សេចក្ដីដែលពាក្យទាំងនោះផ្សេងគ្នាដោយអត្ថផង សេចក្ដីត្រូវការរបស់កេចិអាចារ្យទាំងនោះ ខុសអំពីអនោធិសោផរណា ព្រោះដូច្នោះ ព្រះយោគាវចរមិនគួរកាន់យកន័យដូច ( កេចិអាចារ្យ ) នោះ គប្បីផ្សាយអនោធិសោមេត្តាក្នុងអាការទាំង ៥ នេះ ដោយអាការណានីមួយទៅចុះ ។

## អប្បនា

ក៏ក្នុងមេត្តាភាវនានេះ ការនាថា **សព្វេ សត្តា អវេរា ហោន្តុ** សូមសត្វទាំងឡាយទាំងពួង ចូរជាបុគ្គលមិនមានពៀរចុះ នេះក៏ជាអប្បនាមួយបាន ការនាថា **សព្វេ សត្តា អព្យាបជ្ឈា ហោន្តុ** សូមសត្វទាំងឡាយទាំងពួង ចូរជាអ្នកមិនមានការបៀតបៀនគ្នាចុះ នេះក៏ជាអប្បនាមួយបាន ។

ពាក្យថា **អព្យាបជ្ឈា** មិនមានការបៀតបៀននោះ គឺ **ព្យាបាទរហិតា** ប្រាសចាកព្យាបាទ ។

ការនាថា **សព្វេ សត្តា អនីឃា ហោន្តុ** សូមសត្វទាំងឡាយទាំងពួង ចូរជាអ្នកមិនមានទុក្ខចុះ នេះក៏ជាអប្បនាមួយបាន ។

ពាក្យថា **អនីឃា** បានដល់ **និទ្ទុក្ខា** មិនមានទុក្ខ ។

ការនាថា **សព្វេ សត្តា សុខី អត្តានំ បរិហរន្តុ** សូមសត្វទាំងឡាយទាំងពួង ចូរជាអ្នកមានសេចក្ដីសុខ រក្សាខ្លួនចុះ នេះក៏ជាអប្បនាមួយបាន ។

ព្រោះហេតុនោះ ក្នុងបទទាំងនោះ សូម្បីបទណា ៗ ប្រាកដ ( ឃើញច្បាស់

ឡើង ) ព្រះយោគាវចរ ក៏គប្បីផ្សាយមេត្តាទៅតាមកម្លាំងរបស់បទនោះៗ ចុះ ។

ដោយន័យដូចពោលមកដូច្នេះ អប្បនាក្នុងអនោធិសោផរណា ទើបមាន ២០ ទាក់ទងដោយអប្បនា ៤ ៗ ក្នុងអាការ ៥ ចំណែកក្នុងឱធិសោផរណាមាន ២៨ ទាក់ទងដោយអប្បនា ៤ ៗ ក្នុងអាការ ៧ ។

ឯក្នុងអាការ ៧ នោះ ពាក្យថា **ឥត្ថិយោ បុរិសា** ស្ត្រី បុរស លោកពោលដោយភេទ , ពាក្យថា **អរិយា អនរិយា** អរិយជន អនរិយជន ពោលដោយញែកជាព្រះអរិយៈ និងបុថុជ្ជន , ពាក្យថា **ទេវា មនុស្សា វិនិបាតិកា** ទេវតា មនុស្ស វិនិបាតិកៈ ពោលដោយឧប្បត្តិ ( កំណើត ) ។

ចំណែកក្នុង ទិសាផរណអប្បនាមាន ៤៨០ គឺ តាមន័យ ( វគ្គអាការ ៥ ) មាន **សព្វេ បុរត្ថិមាយ ទិសាយ សត្តា**... ជាប្រការដំបូង ធ្វើទិសមួយ ២០ ( រួម ១០ ទិស ) បាន ២០០ ។ តាមន័យ ( វគ្គអាការ ៧ ) មាន **សព្វេ បុរត្ថិមាយ ទិសាយ ឥត្ថិយោ**... ជាប្រការដំបូង ធ្វើក្នុងទិសមួយ ២៨ ( រួម ១០ ទិស ) បាន ២៨០ ។

ទាំងអស់តាមដែលពោលមកនេះ ជាអប្បនា ៥២៨ ដែលលោកពោលទុកក្នុងបដិសម្ភិទា ដូច្នេះ ។

## មហាដីកា

ពាក្យថា **និមិត្ត** មានសេចក្ដីថា ក្នុងបណ្ដាកម្មដ្ឋានទាំងឡាយ មានកសិណកម្មដ្ឋានជាដើម **បដិភាគនិមិត្ត** រមែងប្រាកដដោយភាពជាអារម្មណ៍របស់ឈានបាន ព្រោះបានអាស្រ័យឧគ្គហនិមិត្តដែលព្រះយោគីបានហើយ ដោយវិធីចម្រើន ដោយ

ការកំណត់ដួងកសិណជាដើមនោះៗ ជាមុខយ៉ាងណា ក្នុងមេត្តាកម្មដ្ឋាននេះ ឈ្មោះថា និមិត្តដែលប្រាកដដូចគ្នានោះមិនមាន ។ តែថា **សីមាសម្ភេទ** តាមដែលពោលហើយ ដែលព្រះយោគីបានហើយ គឺ ធ្វើបានហើយនេះឯណា សីមាសម្ភេទនោះៗ ឯងឈ្មោះថា និមិត្ត ព្រោះអត្ថថា ដូចជានិមិត្ត ។ ពិតណាស់ ព្រះយោគីបានធ្វើសីមាសម្ភេទនោះហើយ នីវរណៈទាំងឡាយត្រូវគ្របសង្កត់ទុកបានហើយ យ៉ាងនោះឯង ព្រោះភាពដែលភាវនា មានភាពល្អក្រៃលែង ។ កិលេសទាំងឡាយស្ងប់រម្ងាប់ទៅផងដែរ ចិត្តមានការតាំងមាំដោយឧបចារសមាធិហើយផងដែរ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ជាការបាននិមិត្ត និងឧបចារៈដូច្នេះ ។ ពាក្យថា **សេពនូវនិមិត្តនោះៗ ឯង** គឺ នូវសមថនិមិត្តដែលប្រព្រឹត្តទៅ ទាក់ទងនឹងសីមាសម្ភេទ ។ ឈ្មោះថា រមែងសម្រេចអប្បនាដោយមិនលំបាកឡើយ គឺ ដោយមិនលំបាកឡើយ ព្រោះភាពដែលព្រះយោគីជម្រះគ្រឿងកង្វល់ចេញស្រេចហើយនោះឯង ។ ពាក្យថា **ដោយសេចក្ដីព្យាយាមត្រឹមប៉ុណ្ណោះ** គឺដោយការប្រកបរឿយៗ នូវភាវនាត្រឹមប៉ុណ្ណោះ ។ ភិក្ខុនោះ ក៏គឺ ព្រះយោគី ។ អត្ថន័យនៃបទទាំងឡាយថា លះអង្គ ៥ ជាដើម ខ្ញុំព្រះករុណាបានពោលទុកក្នុងខាងដើមហើយនោះឯង ។

ពាក្យថា **ដោយទាក់ទងនឹងបឋមជ្ឈានជាដើមយ៉ាងណានីមួយ** នេះលោកពោលទុកព្រោះការធ្វើបានបែបផ្សេងៗ ដែលពោលជារបស់សាធារណៈដល់ឈានទាំងនោះ ។ ឈ្មោះថា **ចំពោះភិក្ខុដែលមានចិត្តដល់អប្បនា** គឺមិនប្រើសម្រាប់ភិក្ខុបានត្រឹមឧបចារៈទេ ។ ធ្វើអធិប្បាយបានថា សម្រាប់ព្រះយោគីដែលសម្រេចគុណវិសេស មានភាពជាឈានដែលបរិបូណ៌ជាដើម ដោយការធ្វើឲ្យដល់នូវភាព

ស្អាត់ជំនាញ និង មានកម្លាំងប៉ុណ្ណោះ ទើបនឹងមានការស្ទាត់នៃឈាន គឺ ការធ្វើបានជាបែបផ្សេងៗ ដោយទាក់ទងនឹងឈាន ដែលមានការផ្សាយទៅក្នុងទិសទាំងឡាយ ដោយមានព្រំដែនក៏បាន ដោយមិនមានព្រំដែនក៏បាន ។

បទថា **មេត្តាសហគតេន** ដែលសហគតៈដោយមេត្តា មានសេចក្តីថា ដែលប្រព្រឹត្តទៅ គឺ ប្រកបព្រមនឹងមេត្តា ចាប់តាំងអំពីកើតឡើងរហូតទល់រលត់ទៅ ។ តែព្រោះហេតុដែលចិត្តសហគតៈដោយមេត្តា តាមន័យដែលពោលហើយនោះ ជាការមកហើយដោយប្រពៃ ដោយវិធី ធ្វើឲ្យកើតឡើងព្រមគ្នានឹងមេត្តាជាដើម ព្រោះហេតុនោះលោកអាចារ្យទើបពោលថា គឺ ដែលប្រកបព្រមដោយមេត្តា ដូច្នេះ ។ **ចេត** ស័ព្ទ សូម្បីជាស័ព្ទប្រើជំនួសស័ព្ទថា **សមាធិ** ក៏មាន ដូចនៅក្នុងពាក្យថា **អធិចេតសោ** ជាដើម ព្រោះហេតុនោះ ដើម្បីឲ្យផ្សេងទៅអំពី **ចេត** ស័ព្ទ ដែលជាស័ព្ទប្រើជំនួសស័ព្ទថា **សមាធិ** នោះ លោកអាចារ្យទើបពោលថា បទថា **ចេតសា** ប្រែថា ដោយចិត្តដូច្នេះ ។ បទថា **ឯតំ** ប្រែថា បទនេះ ។ កាលនឹងសម្តែងថា ការកំណត់កាន់យកព្រំដែន គឺ ទិសរមែងមានបានដោយការកំណត់ គឺ យកព្រំដែន គឺសត្វជាមុខនោះឯង ដូច្នេះ លោកអាចារ្យទើបពោលថា កាន់យកសត្វដែលកំណត់ទុកមុនក្នុងទិស ១ ដូច្នេះ ។ ពិតណាស់ ពួកសត្វដែលតាំងនៅក្នុងទិសទាំងឡាយ ព្រះយោគីនឹងកាន់យកបាន ក៏ដោយការកាន់យកទិស ។ ព្រោះហេតុនោះទើបលោកពោលថា ត្រាស់ទុកដោយទាក់ទងនឹងការផ្សាយទៅ កាន់យកសត្វដែលទាក់ទងនៅក្នុងទិស ១ ដូច្នេះ ។ ការផ្សាយទៅ បានដល់ កិរិយាដែលធម៌ប្រព្រឹត្តទៅក្នុងអារម្មណ៍បានខ្ទប់អារម្មណ៍របស់ខ្លួន ។ ជាការឃើញដោយប្រចក្ស ជាការកាន់យក ជាការធ្វើឲ្យជាអារម្មណ៍នោះឯង ព្រោះហេតុនោះ លោកអាចារ្យទើប

ពោលថា បទថា **ផរិត្វា** គឺប៉ះខ្ទប់ធ្វើឲ្យជាអារម្មណ៍ ដូច្នេះ ។ ពាក្យថា **គឺធ្វើឥរិយាបថវិហារដែលតាំងមាំដោយព្រហ្មវិហារ** គឺ ធ្វើឥរិយាបថវិហារដែលមេត្តាឈានទ្រទ្រង់ឲ្យប្រព្រឹត្តទៅ ។ បទថា **តថា** ដូច្នោះដូចគ្នា ជាពាក្យនិយម គឺ កំណត់ពិតប្រាកដ ។ បទថា **តថា** នោះ ជាពាក្យដែលកំណត់ពិតប្រាកដដល់អាការដែលឧបមាដោយពាក្យដែលមានការសម្ពន្ធ និងការសម្លឹងដល់អត្ថដែលមិនបានកំណត់ពិតប្រាកដ ទុក ។ បទថា **ទុតិយំ** ទិសទី ២ ជាពាក្យសម្តែងឧបមេយ្យ គឺ ទិសដែលគប្បីឧបមា តែដែលបានឈ្មោះថា ឧបមេយ្យវៀរឧបមា និងការសម្ពន្ធនឹងឧបមានោះចេញ ក៏មានមិនបាន ព្រោះហេតុនោះ លោកអាចារ្យបំណងសម្តែងឧបមា និងឧបមេយ្យទាំងពីរយ៉ាងនោះ ទើបពោលថា ក្នុងបណ្តាទិសទាំងឡាយមានទិសខាងកើតជាដើម យ៉ាងណា ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ គប្បីនាំយក ២បទថា **ផរិត្វា វិហរតិ** មកភ្ជាប់ទុកក្នុង ២បទថា **យថា ទុតិយំ** នេះ ។ សូម្បីក្នុងពីរបទថា **តតិយំ ចតុត្ថំ** ក៏គប្បីនាំយក ២បទថា **ផរិត្វា វិហរតិ** មកភ្ជាប់ទុកយ៉ាងនេះ ។ ចំណែកស័ព្ទថា **អនន្តរំ** ដែលប្រែថា ក្នុងលំដាប់ ក្នុងពាក្យថា **តទនន្តរំ** ក្នុងលំដាប់នោះ សម្លឹងដល់ការផ្សាយទៅ មិនមែនសម្លឹងដល់ទិសដែលនឹងគប្បីផ្សាយទៅទេ ព្រោះទិសទាំងឡាយមិនមែនសភាវៈដែលឃើញបាន ។ ពិតណាស់ ភាពជាលំដាប់ទី ២ ជាដើម នៃទិសទាំងនោះ រមែងមានដោយលំដាប់ការផ្សាយទៅ មិនមែនដោយជាសភាវៈមានប្រាកដទេ ។ ព្រោះហេតុនោះៗឯង លោកអាចារ្យទើបពោលថា រមែងផ្សាយទៅ កាន់យកទិសណានីមួយ ១ ទិស ដូច្នេះ ។ ស័ព្ទថា **ឥតិ** ដោយន័យនេះ មានន័យថា រមែងផ្សាយទៅកាន់ទិសទាំង ៤ តាមដែលពោលហើយ ក៏ដោយន័យនេះ ទៅកាន់ទិសខាងលើក៏ដោយន័យនេះ ។ ព្រោះ

ហេតុនោះ លោកអាចារ្យទើបពោលថា ម្យ៉ាង ក៏ដោយន័យនេះឯង ។ សូម្បីពាក្យនេះ ក៏ជាពាក្យសម្ដែងអត្ថន័យនៃ **ឥតិ** ស័ព្ទនោះឯង ។ លោកអាចារ្យបំណងសម្ដែងក្នុងបទថា **អធោតិរិយំ** គឺ ទិសខាងក្រោម , ទិសទទឹង ។ ក្នុងព្រះបាលីនេះ ទ្រង់សម្ដែង **បិ** ស័ព្ទ ( ដែលប្រែថា ទាំង ) ទុកជា **លុត្ត** ស័ព្ទ ( ត្រូវលុបចេញទៅ ) ដូច្នេះ ទើបពោលថា **អធោទិសម្បិ តិរិយំទិសម្បិ** ទាំងទិសខាងក្រោម ទាំងទិសទទឹងដូច្នេះ ។ គប្បីជ្រាបថា សូម្បីក្នុងបទថា **ទុតិយំ** ជាដើម ក៏ធ្វើបញ្ចាំងដល់ភាពដែលទ្រង់បានសម្ដែង **បិ** ស័ព្ទ ជា **លុត្ត** ស័ព្ទ ទុកដោយពាក្យនេះឯង ។ សូម្បីពាក្យថា **ឯវមេវ** នេះ ក៏ជាពាក្យដែលសម្ដែងអត្ថនៃ **ឥតិ** ស័ព្ទនោះឯង ។ ម្យ៉ាងទៀត ក្នុងបណ្ដាបទទាំងនោះ ដោយបទថា **អធោ** គឺ ទិសខាងក្រោមនេះ លោកកាន់យកសត្វទាំងឡាយក្នុងទិសដែលទាបជាងខ្លួន គឺ ក្នុងនរក ឬ ក្នុងទីណានីមួយ មានពិភពនាគជាដើម យ៉ាងណា ដោយបទថា **ឧទ្ធំ** គឺ ទិសខាងលើនេះ ក៏គប្បីជ្រាបថា លោកកាន់យកសត្វទាំងឡាយក្នុងទិសខ្ពស់ជាងខ្លួន គឺ ក្នុងទេវលោក ឬ ក្នុងទីណានីមួយ ដូច្នោះ ។

ដោយ **អាទិ** ស័ព្ទ ក្នុងបទថា **មជ្ឈត្តាទិ** គឺ បុគ្គលជាកណ្ដាលៗជាដើម រួមយកសត្វច្រើនប្រភេទ មានស្ត្រី បុរស ព្រះអរិយបុគ្គល បុថុជ្ជន សត្វនរក ទេវតា មនុស្សជាដើម ។ ពាក្យថា **មិនរាយមាយទៅខាងក្រៅសូម្បីត្រឹមតែបន្តិចបន្តួច** គឺ មិនដល់នូវភាពរាយមាយទៅខាងក្រៅកម្មដ្ឋាន សូម្បីបន្តិចបន្តួច បានដល់ មិនប្រព្រឹត្តទៅ ដោយប្រការផ្សេងៗ មុននឹងបង្អោនយកប្រយោជន៍សុខចូលទៅកាន់សត្វទាំងឡាយឡើយ សូម្បីត្រឹមតែបន្តិច ។ ម្យ៉ាងទៀត បទថា **សព្វត្តតាយ** ប្រែថា ដោយអត្តភាពទាំងពួង មានន័យថា ភាពជាអ្នកស្វែងរកប្រយោជន៍សុខខ្លួនឯង គឺ

ក្នុងអត្តភាពរបស់ខ្លួន រមែងមាន ព្រោះមានដល់គ្រប់គ្នាយ៉ាងណា ក៏រមែងផ្សាយមេត្តាទៅក្នុងសត្វទាំងឡាយទាំងពួងក្នុងទីទាំងពួងក៏យ៉ាងនោះ , ព្រោះកំពុងពោលដល់មេត្តា , **សព្វ** ស័ព្ទ ក្នុងបទថា **សព្វាវន្តំ** ទើបមានសត្វជាព្រំដែន ក៏ **សព្វ** ស័ព្ទនោះ បានត្រាស់ធ្វើឲ្យជាទីយៈថា **សព្វាវន្ត** ព្រោះដូច្នោះ លោកអាចារ្យកាលនឹងសម្តែងអត្ថន័យរបស់បទ ទុកថា **លោក** ឈ្មោះថា **សព្វាវន្ត** ព្រោះអត្ថថា មានប្រជា ពោលគឺ ពពួកសត្វទាំងពួង ដូច្នោះ ទើបពោលថា បទថា **សព្វាវន្តំ** ប្រែថា ដែលមានសត្វទាំងពួង ។ ម្យ៉ាងទៀត ក្នុងបណ្តាបទទាំងនោះ បទថា **សព្វធិ** គឺ ក្នុងទីទាំងពួង ត្រាស់ដល់ការផ្សាយទៅ ដោយមិនមានព្រំដែន ដោយព្រំដែន គឺ ទិស និងដោយព្រំដែន គឺ ស្ថានទី ។ ពីរបទថា **សព្វត្តតាយ** ដោយភាពជាតួខ្លួនទាំងពួង **សព្វាវន្តំ** ដែលមានសត្វទាំងពួង ត្រាស់ដល់ការផ្សាយទៅដោយមិនមានព្រំដែន ដោយព្រំដែន គឺ សត្វ ។ ពិតហើយ លោកបានពោលទុកហើយថា ត្រាស់ទុកដើម្បីសម្តែងការផ្សាយមេត្តាទៅ ដោយមិនមានព្រំដែន ដូច្នេះ ។ ពាក្យថា **វិបុល** ជាដើម , ឈ្មោះថា ពាក្យដែលជាបរិយាយ ព្រោះអត្ថថា បរិយាយ គឺ ធ្វើឲ្យដឹងសេចក្តីដែលដូចគ្នានោះឯង ដោយប្រការទាំងពួង បានដល់ ជាវេវចនៈស័ព្ទ អធិប្បាយថា ក៏ក្នុងបណ្តាស័ព្ទទាំងនោះ ស័ព្ទថា **វិបុល** គឺ បរិបូណ៌ជាដើម ក៏ដូចគ្នានឹងស័ព្ទថា **មហគ្គត** ជាដើមនោះ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ព្រោះជាការសម្តែងដល់ពាក្យដែលជាបរិយាយ មានយ៉ាងនេះថា **វិបុលេន** ជាដើមដូច្នេះ ។ ក្នុងការសម្តែងដោយពាក្យដែលជាបរិយាយ រមែងកាន់យកបទទាំងឡាយដែលបានកាន់យកហើយក្នុងពេលមុន មួយទៀត ដូចជាបទថា **សទ្ធា** សូម្បីត្រាស់ទុកហើយ ក្នុងព្រះតម្រាស់ដែលថា **សទ្ធា** គឺ ការជឿ ,

**សទ្ទហនា** គឺ កិរិយាដែលជឿនេះ ក្នុងការសម្តែងដោយពាក្យដែលជាបរិយាយ មានពាក្យថា ឥន្ទ្រិយជាដើម ក៏នៅត្រាស់ដល់បទ **សទ្ធា** ថា **សទ្ធា សទ្ធិន្ទ្រិយំ** ដូច្នេះទៀត ។ ពាក្យថា ស័ព្ទថា **តថា** ក្តី ស័ព្ទថា **ឥតិ** ក្តី មិនបានត្រាស់ទុក មានសេចក្តីថា ស័ព្ទថា **តថា** និង ស័ព្ទថា **ឥតិ** ដែលជាប់តាមពាក្យថា រមែង ផ្សាយទៅកាន់ទិស ១ ដោយចិត្តដែលសហគតៈដោយមេត្តា នេះមិនបានត្រាស់ ស័ព្ទទាំងនោះទុក ព្រោះធ្វើអធិប្បាយថា ជាឋានៈដែលមិនសមគួរនៃសត្វទាំងឡាយ ដែលបានឃើញហើយក្នុងលំដាប់នៃការផ្សាយទៅទាំងនោះ ព្រោះហេតុនោះ ទើប ត្រាស់ពាក្យថា **មេត្តាសហគតេន ចេតសា** ទុកម្តងទៀត ។ ពាក្យពោលដល់ អត្ថន័យដែលបានពោលហើយនោះៗ ឯងម្តងទៀត ឈ្មោះថា ពាក្យនិគម ឬ ពាក្យ សំយោគ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ឬថា **មេត្តាសហគតេន ចេតសា** នេះ ត្រាស់ទុកដោយទាក់ទងនឹងពាក្យជានិគម ដូច្នេះ ។ សួរថា ក៏ពាក្យ ពោលដល់អត្ថន័យ ដែលបានពោលហើយនោះឯងម្តងទៀត ដោយទាក់ទងនឹង ពាក្យចុងបញ្ចប់ ទើបឈ្មោះថា ជាពាក្យនិគម មិនមែនឬ ? ឆ្លើយថា ប្រការដែល ពោលមកនេះក៏មិនខុសទេ ព្រោះការផ្សាយទៅដោយមានព្រំដែន ដោយមិនមាន ព្រំដែន ក៏ត្រាស់ទុកក្នុងពាក្យចុងបញ្ចប់នោះឯង ។ ពាក្យថា **ដែលបរិបូណ៌** គឺ ដែលទូលាយ ក៏មេត្តាចិត្តនេះមានការទូលំទូលាយ ក៏ដោយទាក់ទងនឹងការកាន់យក អារម្មណ៍មិនមានសល់ មិនកាន់យកត្រឹមចំណែកមួយប៉ុណ្ណោះ ដូចក្នុងកម្មដ្ឋានដទៃ មានអសុភកម្មដ្ឋានជាដើមទេ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា គប្បី ជ្រាប ភាពបរិបូណ៌ ទាក់ទងដោយការផ្សាយទៅ ដូច្នេះ ។

មេត្តាចិត្ត ឈ្មោះថា មហគ្គតៈ ព្រោះអត្ថថា ទៅកាន់ភាពធំក្រៃលែងដោយ

ហេតុទាំងឡាយ មានភាពជាចិត្តដែលអាចសង្កត់កិលេសទាំងឡាយបានជាដើម ឬ ព្រោះអត្ថថា គឺ ដំណើរទៅដោយធម៌ដ៏ធំក្រៃលែង គឺ ឆន្ទៈ វីរិយៈ ចិត្ត និងបញ្ញាដ៏ប្រសើរ ។ ព្រោះហេតុដែលមេត្តាចិត្តនេះនោះជារូបាវចរតែម្យ៉ាង ដូច្នោះ លោកអាចារ្យទើបពោលថា ចិត្តនេះឈ្មោះថា **មហគ្គតៈ** ក៏ដោយទាក់ទងនឹងភូមិ ដូច្នេះ ។ ពិតណាស់ វោហារប្បញ្ញត្តិថា មហគ្គតៈ និយមប្រើក្នុងធម៌ដែលជា រូបាវចរ និងដែលជាអរូបាវចរ ។ ពាក្យថា ***ដោយទាក់ទងនឹងជាចិត្តដែលស្ទាត់ជំនាញ*** មានសេចក្ដីថា ចិត្តដែលសន្សំ បានដល់ ធ្វើឲ្យច្រើនហើយដោយប្រការទាំងឡាយឈ្មោះថា **បគុណ** គឺ ស្ទាត់ជំនាញ ដោយទាក់ទងនឹងគុណចិត្តនោះ មានន័យថា ជាចិត្តដែលចម្រើនល្អហើយ ។ ពិតណាស់ ចិត្តនោះ ព្រោះដែលនរណាៗមិនអាចនឹងកាន់យកប្រមាណបាន ទើបឈ្មោះថា ជាចិត្តដែលរកប្រមាណមិនបាន ។ ពាក្យថា ***ដោយទាក់ទងនឹងការមានសត្វដែលមិនមានប្រមាណ ជាអារម្មណ៍*** គឺ ទាក់ទងនឹងការធ្វើសត្វដែលរាប់ចំនួនមិនបានឲ្យជាអារម្មណ៍ ។ ឈ្មោះថា មិនមានពៀរ ព្រោះសូម្បីតួចិត្តខ្លួនឯង ក៏វៀរចាកពៀរ និងព្រោះជាហេតុឲ្យព្រះយោគាវចរព្រមព្រៀងដោយចិត្តនោះមិនមានពៀរ ។ ចិត្តដូចនេះ ទើបបានឈ្មោះទាំងពីរថា **អវេរំ** មិនមានពៀរ និងថា **អព្យាបជ្ឈំ** មិនមានការបៀតបៀនបានដោយអាស្រ័យហេតុណា លោកអាចារ្យបំណងសម្ដែងនូវហេតុនោះ ព្រោះហេតុនោះ ទើបពោលថា ដោយការលះធម៌ដែលជាសត្រូវ គឺ ព្យាបាទបាន ។ ឈ្មោះថា **ព្យាបជ្ឈំ** ការបៀតបៀន ព្រោះជាការបៀតបៀនដោយទាក់ទងនឹងការធ្វើចិត្តឲ្យដល់នូវភាពវិនាសបានដល់ ការមិនសុខសាន្តផ្លូវចិត្ត, **ចិត្ត** ឈ្មោះថា **អព្យាបជ្ឈំ** គឺមិនមានការបៀតបៀន ព្រោះមិនមាន **ព្យាបជ្ឈ** នោះ។ ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា

មិនមានទុក្ខដូច្នេះ ។ លោកអាចារ្យកាលនឹងសម្តែងថា ក៏ភាវៈដែលចិត្តនេះមិនមានការបៀតបៀននោះ រមែងមានសភាវៈដូចចិត្តទាំងឡាយ មានពួកបញ្ចវិញ្ញាណជាដើមក៏ទេ ដែលពិតនោះ រមែងមានបានដោយការស្វាត់ចាកធម៌ដែលជាសត្រូវ ដូច្នេះ ទើបពោលថា ដោយការលះបង់ទោមនស្សបានដូច្នេះ ។ ពាក្យថា **ដែលពោលមកនេះ** បានដល់ ពាក្យតាមដែលលោកនាំមកក្នុងទីនេះ លោកពោលដល់ **វិកុព្វនា** នៃមេត្តាព្រហ្មវិហារ ដែលមានមកក្នុងអប្បមញ្ញាវិភង្គ និងក្នុងចំណែកនៃព្រះសូត្រទាំងឡាយនោះៗ ។

ដោយពាក្យថា **តថា** - ដូច្នោះ នេះលោកប្រៀបធៀបដល់ភាពដែលវិកុព្វនានេះ មិនមានការផ្សេងគ្នានឹងវិកុព្វនា ដែលព្រះសារីបុត្តត្រូវពោលទុកនៅក្នុងគម្ពីរបដិសម្ភិទាមគ្គ ដោយការចែកអាការទុកថា ដោយអាការ ៥ , ដោយអាការ ៧ , ដោយអាការ ១០ ដូច្នេះ ដូចមាសដែលបាក់ត្រង់កណ្តាល ព្រោះទេសនាមកហើយដោយទាក់ទងនឹងការផ្សាយទៅ ដោយមានព្រំដែន ការផ្សាយទៅដោយការមិនមានព្រំដែន និងការផ្សាយទៅក្នុងទិស ។ តែថា មានខនេះប៉ុណ្ណោះដែលផ្សេងគ្នា គឺក្នុងបាទព្រះបាលីនេះ មិនបានកាន់យកព្រំដែន គឺ សត្វ ដូចក្នុងបដិសម្ភិទាមគ្គទេ ។ ពាក្យថា **ពាក្យ ( ដែលព្រះសារីបុត្រពោលទុក ) ឯណា** លោកអាចារ្យពោលសំដៅយកវិកុព្វនា ។

ឥឡូវនេះ លោកអាចារ្យបំណងនឹងធ្វើព្រះបាលីបដិសម្ភិទាមគ្គ ដែលបាននាំមកដោយពាក្យឧទ្ទេសឲ្យប្រាកដ ក្នុងពាក្យនិទ្ទេស ដោយអាការសម្តែងដល់ប្រការដែលមិនមានការផ្សេងគ្នាជាមុខ ( ប្រក - ហេតុ - ប្រធាន ) ហើយធ្វើការពណ៌នាបទដ៏ជ្រាលជ្រៅនៃព្រះបាលីនោះ ទើបពោលថា ក៏ក្នុងបណ្តាអាការទាំង

នោះ ដូច្នេះជាដើម ។

ក្នុងបណ្តាបទទាំងនោះ ពីរបទថា **សព្វេ សត្តា** មានអធិប្បាយថា **សព្វ** សត្វ ជាសត្វមានវិស័យទាំងអស់ចំពោះកន្លែង មិនមែនសត្វមានវិស័យទាំងអស់ទាំងពួង ដូចពាក្យថា ឈ្មោះថា ព្រះសព្វញ្ញុតញ្ញាណ ព្រោះអត្ថថា ដឹងវត្ថុទាំងពួង ដូច្នេះ ដូច្នោះក៏ពិត សូម្បីយ៉ាងនោះ ដោយបទថា **សត្តា** ក៏រមែងគ្របដណ្តប់ទុកមិនមានសល់នូវវិស័យរបស់ខ្លួនមិនបានដាច់ឡើយ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ពាក្យថាទាំងពួងនេះ ជាពាក្យកាន់យកយ៉ាងមិនមានសល់ ដូច្នេះ ។

បទថា **តត្រ** ប្រែថា ក្នុងរូបនោះ ។ ពាក្យថា **អ្នកជាប់ជំពាក់** គឺអ្នកជាប់នៅជំពាក់ដោយលាកដែលមានការជាប់ជំពាក់ដោយកិច្ច ដែលមានពាក្យហៅជំនួសថា ឆន្ទៈ ជាដើម ។ ម្យ៉ាងទៀត បទថា **តត្រ** ជាសត្តមីវិភត្តិក្នុងអត្ថនៃករណៈ ទើបមានន័យថា ដោយឆន្ទៈជាដើមនោះ ។

លោកអាចារ្យធ្វើពាក្យសួរទុកក្នុងចិត្តថា ប្រសិនបើឈ្មោះថា **សត្វ** ព្រោះភាពជាអ្នកជាប់ជំពាក់សោត , នឹងប្រើវោហារថាសត្វក្នុងលោកដែលប្រាសចាករាគៈទាំងឡាយបានដូចម្តេចទៅ ដូច្នេះហើយ ទើបពោលថា រមែងប្រព្រឹត្តទៅដោយជា **រុឡ្ហិ** សត្វ ( សត្វដែលប្រើតាមការនិយម ) ដូច្នេះជាដើម ។ សេចក្តីថា ប្រព្រឹត្តទៅក្នុងលោកដែលមិនទាន់ប្រាសចាករាគៈ ដោយជា **រុឡ្ហិ** សត្វ ឬថា ប្រព្រឹត្តទៅក្នុងលោកដែលមិនទាន់ប្រាសចាករាគៈ ហើយក៏ប្រព្រឹត្តទៅក្នុងបុគ្គលដែលប្រាសចាករាគៈ ដែលជាបុគ្គល ដូចគ្នានឹងបុគ្គលដែលនៅមិនទាន់ប្រាសចាករាគៈនោះ ដោយការៈដែលផ្សេង ក៏មានខន្ធសន្តានទាក់ទងដោយឥន្ទ្រិយ ដោយជា **រុឡ្ហិ** សត្វ។ ន័យម្យ៉ាងទៀត សូម្បីកាលវិស័យដទៃខ្លះៗ ផ្សេងទៀត ដែលប្រកបដោយហេតុខ្លះ

នោះនឹងមានប្រាកដ ការដែលសន្ទតឈ្មោះកាន់យកហេតុខ្លះៗ ហើយប្រព្រឹត្តទៅក្នុងវិស័យសូម្បីវៀរចាកហេតុខ្លះៗនោះ ដោយកាលយូរ ឈ្មោះថា **រុឡ្ហិ** ដូចដែលហៅថា **គោ** ព្រោះអត្ថថា **ទៅ** ដូច្នោះ បណ្ឌិតគប្បីឃើញភាពជា **រុឡ្ហិ** សព្ទ នៃ **សត្ត** សព្ទ ដូចគ្នានេះចុះ ។ ម្យ៉ាងទៀត គប្បីឃើញថា ក្នុងលោកដែលប្រាសចាករាគៈហើយទាំងឡាយ មានវោហារហៅថា **សត្វ** បាន ក៏ដោយគតិដែលធ្លាប់ជា ( សត្វ-អ្នកជាប់ជំពាក់ ) មកអំពីមុន ។ ក្នុងពាក្យថា ព្រោះប្រកបដោយសត្តនេះ មានសេចក្ដីថា **ពុទ្ធិ** ( ការដឹង ) **វីរិយៈ** ( សេចក្ដីព្យាយាម ) ឬថា **តេជះ** ឈ្មោះថា **សត្ត** , ឈ្មោះថា សត្វ ក៏ព្រោះប្រកបដោយសត្តនោះ ដូចជាថាសំពត់ឈ្មោះថា សំពត់ខៀវ ព្រោះប្រកបដោយគុណសម្បត្តិ គឺ ពណ៌ខៀវ ។

ខ្យល់អស្សាសៈ និង ខ្យល់បស្សាសៈ ឈ្មោះថា **បាណន** ព្រោះអត្ថថា ជាហេតុដកដង្ហើមបាន , ការធ្វើខ្យល់ដង្ហើមនោះឲ្យកើតឡើង ឈ្មោះថា **បាណនតា** បានដល់ ព្រោះបាណនតានោះ សេចក្ដីថា ព្រោះប្រកបដោយខ្យល់អស្សាសៈ និង បស្សាសៈ។ ពាក្យថា **ព្រោះកើតហើយ** គឺព្រោះកើតហើយចាកកម្ម និងកិលេស ។ អាចារ្យខាងនិរុត្តិច្រើនទាក់ពោលថា ឈ្មោះថា **បុគ្គល** ព្រោះមានការធ្វើឲ្យពេញ និង ព្រោះមានការទៅ ។ មានអធិប្បាយថា ពិតណាស់ សត្វទាំងឡាយកាលកើតឡើង ក៏រមែងដូចជាធ្វើសត្តនិកាយនោះៗ ឲ្យពេញ និង រមែងទៅ គឺ ឃ្លាតទៅដោយភាវៈដែលធ្លាក់ទៅក្នុងភូមិទាំងពួង ។ សរីរៈ ឬថាខន្ធ ៥ នោះឯង ហៅថា អត្តភាព ព្រោះអត្ថថា ជាទីមានឈ្មោះថា **អត្តា** , និងមានចិត្តដែលហៅថា **អត្តា** សម្រាប់បុគ្គលដែលមិនទាន់កំណត់ដឹងវត្ថុ ( ថាត្រឹមតែជានាម និងរូបប៉ុណ្ណោះ ) ។ បទថា **តំ** បានដល់ ខន្ធ ៥ ។ ពាក្យថា **អាស្រ័យ** គឺ កាន់យក បានដល់ ធ្វើឲ្យជាទី

ប្រកាន់មាំ គឺជាទីអាស្រ័យ ។ ពាក្យថា **ត្រឹមតែជាការបញ្ញត្តិទៅតាមសភាវៈ** គឺ សូម្បីវត្ថុដែលសម្គាល់ថា សត្វ នឹងមិនមានដោយបរមត្ថ ក៏ហៅថា អត្ថភាពបាន ដោយគ្រាន់តែជាការបញ្ញត្តិទៅតាមសភាវៈ ។

ពាក្យថា ដូចជាពាក្យថា **សត្តា** មានសេចក្តីថា ដូចជា **សត្ត** ស័ព្ទ សូម្បី មានការប្រព្រឹត្តទៅ ( ប្រើហៅ ) ក្នុងជនមួយចំណែកដោយនិប្បរិយាយ ដោយ អធិប្បាយ ដែលបានពោលហើយ ក៏ចាត់ថាជាស័ព្ទដែលគ្របដណ្តប់យកជនទាំង-ឡាយ មិនមានសល់ ដោយទាក់ទងជា **រុឡ្ហិ** ស័ព្ទ ដូច្នោះ ។ ពាក្យថា **ពាក្យសូម្បី ដ៏សេស** បានដល់ សូម្បីពាក្យថា **បាណា** ជាដើម ។ ពិតណាស់ សូម្បីពាក្យថា បាណាជាដើមទាំងនោះ ក៏មានការប្រព្រឹត្តទៅ ( ប្រើហៅ ) ក្នុងជនមួយចំណែក ព្រោះអ្នកចូលទៅដល់រូបភព ឬអរូបភព និងអ្នកដែលព្រមព្រៀងដោយចតុត្ថជ្ឈាន ជាដើម មិនមានខ្យល់អស្សាសបស្សាសៈ និងព្រោះជនដែលមិនមានការធ្លាក់ទៅ ក្នុងអបាយជាធម្មតា មិនមែនជាបុគ្គល ( បុគ្គល=អ្នករំកិលទៅក្នុងនរក ) ។ ពាក្យ ថា លោកលើកឡើងដោយទាក់ទងនឹង **រុឡ្ហិ** ស័ព្ទ គឺ លោកលើកភាពជាបាណៈ និងភាពជាបុគ្គលសូម្បីថា មិនមានពិត ឡើងទុកក្នុងវិស័យខ្វះៗ ក៏ដោយទាក់ទង នឹង **រុឡ្ហិ** ស័ព្ទ តាមពោលហើយ ។ លោកអាចារ្យសំដៅយកពាក្យសាកសួរថា ប្រសិនបើព្រះសារីបុត្តត្ថេរកាន់យកថា ជាពាក្យវេវចនៈរបស់ពាក្យថា សត្ត ( សត្វ ) ព្រោះជាពាក្យសាធារណៈ ហើយពោលដល់មេត្តាដែលមានការផ្សាយទៅ ដោយ មិនមានព្រំដែនសោត កាលបើដូច្នេះ ព្រោះហេតុអ្វីលោកទើបពោលដល់មេត្តាដែល មានការផ្សាយទៅ ដោយមិនមានព្រំដែនទុក ដោយអាការ ៥ ប៉ុណ្ណោះទៅវិញ ( គួរនឹងមានអាការដទៃៗផង ដូចជា**សព្វជន្តូ** - ជនទាំងឡាយទាំងពួងដូច្នេះជាដើម )

ដូច្នេះ ទើបពោលថា **កាមញ្ច** ដូច្នេះជាដើម ។ ចំណែកអាចារ្យពួកខ្លះពោលថា ក៏បទថា **សត្តា** ជាដើមទាំងនេះឯង លោកមិនបានកាន់យកដោយអាស្រ័យត្រឹមតែភាពជាពាក្យវេវចនៈគ្នាប៉ុណ្ណោះទេ ព្រោះជាហេតុឲ្យដល់នូវការកាន់យកបទថា **ជន្តុ** ( ជន ) ជាដើមផង តែលោកកាន់យក ដោយអាស្រ័យអត្ថន័យផ្សេងៗគ្នា ដែលជាហេតុដូច្នេះ លោកអាចារ្យសំដៅយកអាចារ្យពួកនោះ ទើបពោលថា ចំណែកអាចារ្យពួកណាដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ដោយអត្ថ** គឺដោយអត្ថ ( ន័យរបស់ពាក្យ ) មានយ៉ាងនេះថា ឈ្មោះថា **សត្វ** ដោយអត្ថថា ជាប់ជំពាក់, ឈ្មោះថា **បាណ** ដោយអត្ថថា មានខ្យល់ដង្ហើមដូច្នេះជាដើម ។ លោកអាចារ្យកាលនឹងសម្តែងថា សេចក្តីនោះត្រឹមតែជាមតិ ( ការយល់ឃើញ ) របស់អាចារ្យទាំងនោះ ដូច្នេះទើបពោលថា មេត្តាដែលផ្សាយទៅដោយមិនមានព្រំដែន ក៏នឹងត្រូវខុសដូច្នេះ ។ ព្រោះហេតុអ្វី ? ព្រោះត្រូវដល់នូវភាពជាយ៉ាងនេះថា ពួកខ្លះជាសត្វ ពួកខ្លះជាបាណៈ ពួកខ្លះជាបុគ្គលដូច្នេះទៅ ។ ពាក្យថា **កុំកាន់យកអត្ថន័យយ៉ាងនោះ** គឺ កុំបានកាន់យកអត្ថន័យយ៉ាងនេះថា ស័ព្ទថា **សត្តា** ជាដើម ជាសប្បទេសវិស័យ ( មានសត្វមួយចំណែកជាវិស័យ ) អធិប្បាយថា គួរកាន់យកអត្ថន័យយ៉ាងនេះថា ជានិប្បទេសវិស័យ ( មានសត្វ មិនមានចំណែកសល់ជាវិស័យ ) ដោយន័យដូចពោលហើយពីមុន ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា **ឥមេសុ** ជាដើម ។

ពីរបទថា **បញ្ចសុ អាការេសុ** គឺ ក្នុងអាការនៃការនា ៥ យ៉ាងដែលមកហើយក្នុងព្រះបាលីដោយពាក្យថា **សព្វេ សត្តា** ជាដើម ។ បទថា **អញ្ញតរវសេន** គឺ ដោយអំណាចនៃអាការយ៉ាងណានីមួយ ។

ឥឡូវនេះ លោកអាចារ្យបំណងនឹងកំណត់សម្ដែងអប្បនាក្នុងអាការនៃភាវនា ២២ អាការ ( អនោធិសោផរណា ៥ អាការ , ឱធិសោផរណា ៧ អាការ , ទិសាផរណា ១០ អាការ ) ទើបពោលថា ក្នុងបណ្ដាបទទាំងនោះ ដូច្នេះជាដើម ។ ពាក្យថា ***វៀរចាកព្យាបាទ*** មានន័យថា វៀរចាកព្យាបាទ គឺទោមនស្ស ។ ពាក្យថា ព្រោះដូច្នោះ មានសេចក្ដីថា ព្រោះហេតុដែលការចែកអប្បនា រមែងមានបានដោយត្រឹមតែចែកអាការ តាមដែលពោលហើយតែម៉្យាងក៏ទេ ។ ពាក្យថា ***ក្នុងបណ្ដាបទទាំងឡាយនេះ*** គឺ សូម្បីក្នុងកោដ្ឋាស ( ចំណែក , ភាគ ) ទាំងឡាយ មានពាក្យថា ***សព្វេ សត្តា អវេរា ហោន្តុ*** ជាដើម ។ ពាក្យថា ***បទណាៗ ប្រាកដច្បាស់*** មានសេចក្ដីថា ក្នុងវគ្គខាងដើម ព្រះយោគីត្រូវកាន់យកសព្ទក្នុងទីនោះៗ ធ្វើមនសិការឲ្យប្រព្រឹត្តទៅដោយអំណាចនៃកោដ្ឋាសច្រើនកោដ្ឋាសក៏ពិត សូម្បីយ៉ាងនោះក្នុងខណៈដែលភាវនាសម្រេចបទ ( ឬ កោដ្ឋាស ) ណា ក្នុងបណ្ដាបទទាំងនោះ ជាធម្មជាតិដែលប្រាកដច្បាស់ល្អ ព្រោះភាពដែលស្ទាត់ជំនាញក្រៃលែង , អប្បនាក៏រមែងមានដោយអំណាចនៃបទនោះ , សេចក្ដីនេះក៏ដូចក្នុងអាការ ៣២ ។ តែមានសេចក្ដីផ្សេងគ្នា ចំពោះសេចក្ដីនេះប៉ុណ្ណោះ គឺ ក្នុងអាការ ៣២ នោះ អារម្មណ៍ជាធម្មជាតិដែលប្រាកដច្បាស់ , ចំណែកក្នុងកម្មដ្ឋាននេះ អាការនៃភាវនាជាធម្មជាតិដែលប្រាកដច្បាស់ ។ បទថា ***ចតុន្នំ*** គឺ មានអាការនីមួយៗ ៤ អប្បនាៗ ព្រោះថា ជាពាក្យដែលលោកសម្ដែងខេទុក ដោយការលុបពាក្យដែលត្រូវនិយាយដដែលៗ ចេញ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។

ឈ្មោះថា លោកពោលទុកដោយទាក់ទងនឹងភេទ ក៏ព្រោះភាពដែលសត្វមានភេទជាស្ត្រី ឬ ប្រុសទាំងនោះមានដោយច្រើន ។ ការផ្សាយទៅដែលលោក

ធ្វើទុកជាលំដាប់ទី ៣ ( ដែលថាបានអប្បនា ៤៨០ ) សង្គ្រោះដោយទុកៈដំបូង ( គឺ ស្ត្រីនិងបុរស ) បានក៏ពិត , សូម្បីយ៉ាងនោះ ក៏សង្គ្រោះចូលក្នុងទុកៈទី ២ ( ព្រះអរិយៈ និង អ្នកមិនមែនព្រះអរិយៈ ) និង ដោយតិកៈ ( ទេវតា មនុស្ស និង វិនិបាតិកៈ ) បានផងដែរ ។

ពាក្យថា **អប្បនា** ទាំងអស់ដោយប្រការដែលពោលហើយនេះ គឺ អប្បនាទាំងអស់តាមប្រការដែលពោលហើយយ៉ាងនេះថា អប្បនា ២០ ក្នុងការផ្សាយទៅដោយមិនមានព្រំដែន , អប្បនា ២៨ ក្នុងការផ្សាយទៅដោយមានព្រំដែន និង អប្បនា ៤៨០ ក្នុងការផ្សាយទៅក្នុងទិស ដូច្នេះ ។ កាលសម្តែងខែនបុំសកលិង្គនេះ ធ្ងះបញ្ចាំងដល់ **សត** ស័ព្ទ ( ប្រែថា ១០០ ) ។

( ចប់ មហាដីកា )

# អធិប្បាយ អត្ថនៃមេត្តានិសង្ស

ព្រះយោគាវចរនេះកាលចម្រើនមេត្តាចេតោវិមុត្តិតាមផ្លូវអប្បនាទាំងនោះ ផ្លូវណានីមួយ ដូចពោលមកដូច្នេះហើយ រមែងបានអានិសង្ស ១១ ប្រការ ដែលព្រះមានព្រះភាគត្រាស់ទុកដោយន័យថា អ្នកចម្រើនមេត្តាចេតោវិមុត្តិ រមែងដេកជាសុខ ដូច្នេះជាដើម ។

ក្នុងអានិសង្ស ១១ នោះ មាតិកាថា ដេកលក់ជាសុខ មានអធិប្បាយថា ជនទាំងឡាយក្រៅអំពីនោះ ( ដែលមិនបានមេត្តាចេតោវិមុត្តិ ) រមែងដេកលក់បម្រះកាយទៅមក និងស្រមុកមើលទៅដូចជាទុក្ខ យ៉ាងណា លោកដែលបានមេត្តា

ចេតោវិមុត្តិ ដេកលក់យ៉ាងនោះក៏ទេ រមែងដេកលក់ជាសប្បាយ សូម្បីលក់ស្និទ្ធ ហើយ ក៏ដូចចូលសមាបត្តិ ។

មាតិកាថា ភ្ញាក់ជាសុខ មានអធិប្បាយថា ជនទាំងឡាយដទៃ ភ្ញាក់ឡើងធ្វើសំឡេងធ្ងូរ ពត់កាយរមៀលទៅមក មើលទៅជាទុក្ខយ៉ាងណា លោកដែលបានមេត្តាចេតោវិមុត្តិ ភ្ញាក់យ៉ាងនោះក៏ទេ រមែងភ្ញាក់ជាសប្បាយ គឺ មិនមានវិការ ( អាការខុសប្លែក ) ដូចផ្កាឈូកក្រពុំដូច្នោះ ។

ប្រការថា មិនយល់សុបិនអាក្រក់ អធិប្បាយថា លោកដែលបានមេត្តាចេតោវិមុត្តិនោះ សូម្បីយល់សុបិន ក៏យល់សុបិនឃើញតែនិមិត្តដែលល្អ ដូចជាថា កំពុងថ្វាយបង្គំព្រះចេតិយ ដូចជាកំពុងធ្វើការបូជា និងដូចជាកំពុងស្តាប់ធម៌ ចំណែកជនទាំងឡាយដទៃ យល់សុបិនឃើញខ្លួនដូចជាត្រូវពួកចោរហ៊ុមព័ទ្ធ ដូចជាត្រូវហ្វូងសត្វកាចធ្វើអន្តរាយ និងដូចជាកំពុងធ្លាក់ជ្រោះយ៉ាងណា លោកអ្នកបានមេត្តាចេតោវិមុត្តិយល់សុបិនអាក្រក់យ៉ាងនោះក៏ទេ ។

ប្រការថា **ជាទីស្រឡាញ់របស់មនុស្សទាំងឡាយ** គឺថា ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មនុស្សទាំងឡាយ ហាក់បីដូចកម្រងគជ់ដែលពាក់នៅទ្រូង និងបីដូចកម្រងផ្កាដែលប្រដាប់ទុកលើក្បាលដូច្នោះ ។

ប្រការថា **ជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ** គឺថា បុគ្គលចម្រើនមេត្តាចេតោវិមុត្តិនោះ ជាទីស្រឡាញ់របស់មនុស្សទាំងឡាយ យ៉ាងណា ក៏រមែងជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ ក៏ដូច្នោះ ដូចព្រះវិសាខត្ថេរ ។

# រឿងព្រះវិសាខត្ថេរ

បានឮថា ព្រះវិសាខត្ថេរនោះ ( កាលជាគ្រហស្ថ ) ជាកុដុម្ពិកនៅក្នុងក្រុងបាដលីបុត្ត លោកនៅក្នុងក្រុងនោះឯង បានឮដំណឹងថា តម្ពបណ្ណិទ្វីប ( គឺ កោះលង្កា ) ប្រដាប់ទៅដោយជួរព្រះចេតិយ រុងរឿងដោយសំពត់កាសាវៈក្នុងទ្វីបនោះនរណាៗក៏អាចអង្គុយ ឬដេកបានក្នុងទីគ្រប់កន្លែងដែលខ្លួនប្រាថ្នា សប្បាយទាំងពួងគឺ ឧតុជាទីសប្បាយ សេនាសនៈជាទីសប្បាយ បុគ្គលជាទីសប្បាយ ធម្មស្សវនៈជាទីសប្បាយរកបានងាយ ក្នុងទ្វីបនោះ ដូច្នេះ លោកទើបប្រគល់ភោគទ្រព្យរបស់ខ្លួនឲ្យដល់បុត្រ និងភរិយាអស់ , ខ្លួនឯងមាន ១ កហាបណៈ ចងវេចទុកត្រង់ជាយសំពត់ប៉ុណ្ណោះ ចេញអំពីផ្ទះទៅ រង់ចាំទូកត្រង់មាត់ប្រាំងទន្លេ ១ ខែ និងព្រោះជាបុគ្គលឆ្លាតក្នុង ( ជំនួញ ) លោកទិញរបស់មុខជំនួញត្រង់ប្រកនេះទៅលក់ត្រង់នោះ ដោយកាលក្នុងរវាងដែលរង់ចាំទូក ១ ខែនោះឯង អាចរកទ្រព្យបាន ១០០០ កហាបណៈ ដោយការលក់ដូរតាមធម៌ លោកមកដល់មហាវិហារ គឺក្នុងកោះលង្កា ដោយលំដាប់ ហើយសូមបព្វជ្ជា កាលភិក្ខុទាំងឡាយនាំលោកទៅកាន់សីមាដើម្បីបព្វជ្ជាលោកធ្វើថង់ប្រាក់ ១០០០ កហាបណៈនោះ ធ្លាក់ចុះត្រង់ផែនដីតាមចន្លោះជាយសំពត់ ហើយកាលភិក្ខុ ទាំងឡាយសួរថា នុ៎ះជាអ្វី លោកប្រាប់ថា កហាបណៈ ១០០០ លោកម្ចាស់ ភិក្ខុទាំងឡាយដាស់តឿនថា នែឧបាសក តាំងអំពីកាលដែលបព្វជ្ជាហើយទៅ លោកនឹងចាត់ការមិនបាន លោកចូរចាត់ការវាចេញឥឡូវនេះឯង ដូច្នេះ លោកទើបប្រកាសថា “ មនុស្សទាំងឡាយ អ្នកមកកាន់ស្ថានទីនាយវិសាខបព្វជ្ជា កុំមានដៃទទេ ត្រឡប់ទៅវិញឡើយ ហើយស្រាយថង់រោយទានកហាបណៈក្នុងវង់សីមាហើយ ទើបបព្វជ្ជា ឧបសម្បទា ” ។ លោកនៅរហូត

មានវស្សាគ្រប់ ៥ ហើយ រៀនធ្វើមាតិកា ២ មាតិកា ឲ្យស្ទាត់ហើយ បវារណាចេញវស្សា ហើយរៀនយកកម្មដ្ឋានដែលជាទីសប្បាយដល់ខ្លួន រួចត្រាច់ទៅបំពេញវត្តស្មោះស្មើគ្នា ទៅក្នុងវិហារណានីមួយៗ ៤ ខែ ។

**ព្រះវិសាខត្ថេរនោះត្រាច់បំពេញវត្តទៅយ៉ាងនោះ ថ្ងៃមួយ ឈរនៅក្នុងកណ្តាលព្រៃ ពិចារណាពិនិត្យពិច័យមើលគុណធម៌របស់ខ្លួនទៅ និងបន្លឺសំឡេងឲ្យប្រាកដទុក ទើបបានពោលសេចក្តីនេះថា ខ្ញុំព្រះករុណាបួសមកដោយកាលប៉ុនណា និងមកក្នុងទីនេះដោយកាលប៉ុនណា ក្នុងរវាងកាលប៉ុណ្ណោះនេះ ការខុសរបស់ខ្ញុំព្រះករុណាមិនមានឡើយ ឱ ! ជាលាភពិតហ្ន៎ លោកនិរទុក្ខទាំងឡាយ ។**

លោកកំពុងនិមន្តទៅចិត្តលបព៌តវិហារ ដល់ផ្លូវបែកជា ២ ក៏ឈប់ គិតថាផ្លូវនោះ ឬផ្លូវនេះហ្ន៎ កាលនោះទេវតាដែលអាស្រ័យនៅត្រង់ភ្នំ លាតដៃចង្អុលឲ្យលោកថា នុ៎ះផ្លូវ ។ លោកនៅត្រង់ចិត្តលបព៌ត ៤ ខែ ហើយគិតថា នឹងទៅក្នុងពេលព្រឹក ហើយ ( ចូល ) សឹង ទេវតាដែលអាស្រ័យនៅត្រង់ដើមមណិលត្រង់ក្បាលទីចង្រ្កមមកអង្គុយយំនៅត្រង់ក្បាលជណ្តើរ ព្រះថេរៈសួរថា នរណានុ៎ះ ?

ខ្ញុំព្រះករុណាឈ្មោះ មណិលិយា លោកម្ចាស់ ។

យំធ្វើអ្វី ?

ទាក់ទងនឹងការទៅរបស់លោក ។

កាលអាត្មាមកនៅទីនេះ មានគុណអ្វីដល់លោកទាំងឡាយ ?

ករុណា បើលោកម្ចាស់នៅទីនេះ ពួកអមនុស្សមានមេត្តាគ្នានិងគ្នា ទីនេះកាលលោកម្ចាស់ទៅបាត់ គេទាំងឡាយក៏នឹងបង្កការឈ្លោះគ្នា ពោលពាក្យទ្រគោះដល់គ្នានិងគ្នា ។

ព្រះថេរៈទើបថា បើកាលអាត្មានៅទីនេះ ភាពផាសុកកើតមានដល់លោកទាំងឡាយសោត ក៏រាប់ជាការល្អ ហើយនៅត្រង់ចិត្តលបពិតនោះទៀត ៤ ខែ ហើយញុំាងគមនចិត្ត ( ការគិតនឹងទៅ ) ឲ្យកើតឡើងដូចដើមទៀត ខាងទេវតាក៏មកស្រែកយំដូច្នោះទៀតដោយឧបាយនោះ ព្រះថេរៈនៅទីនោះ រហូតបរិនិព្វានទៅក្នុងទីនោះឯង ភិក្ខុដែលមានមេត្តាជាវិហារធម៌ រមែងជាទីស្រឡាញ់របស់អមនុស្សទាំងឡាយ ដូច្នេះ ។

មាតិកាថា ទេវតារក្សា គឺទេវតាទាំងឡាយរមែងរក្សាអ្នកមានមេត្តាជាវិហារធម៌ ដូចមាតាបិតាទាំងឡាយរក្សាបុត្រ ដូច្នោះ ។

ប្រការថា ភ្លើងក្តី ថ្នាំពិសក្តី សស្ត្រាក្តី មិនបំពារបំពានគេ អធិប្បាយថា ភ្លើងវិញក៏មិនរោលរាល គឺមិនចូលក្នុងរាងកាយរបស់អ្នកមានមេត្តាជាវិហារធម៌ ដូចភ្លើងមិនចូលក្នុងរាងកាយរបស់ឧត្តរាឧបាសិកា ដូច្នោះ ពិសវិញក៏មិនជ្រាប គឺមិនចូលក្នុងរាងកាយរបស់អ្នកមានមេត្តាជាវិហារធម៌ ដូចពិសមិនចូលក្នុងរាងកាយរបស់ព្រះចូឡសិវត្ថេរ អ្នកសូធ្យសំយុត្តនិកាយ ដូច្នោះ សស្ត្រាវិញក៏មិនបំពាន គឺមិនចូលក្នុងរាងកាយរបស់អ្នកមានមេត្តាជាវិហារធម៌ ដូចសស្ត្រាមិនចូលក្នុងរាងកាយរបស់សង្កិច្ចសាមណេរ ដូច្នោះ មានអធិប្បាយថា ភ្លើងក្តី ពិសក្តី សស្ត្រាក្តី រមែងមិនធ្វើរាងកាយរបស់លោកអ្នកមានមេត្តាជាវិហារធម៌នោះឲ្យកម្រើកបាន ក្នុងសេចក្តីនេះ បណ្ឌិតទាំងឡាយពោលរឿងមេគោ ( ជានិទស្សនៈ ) ខ្លះក៏បាន ។

មានរឿងនិទានថា មេគោ ១ ឈរបញ្ចុកក្សីរធារា ( ធារទឹកដោះ ) ឲ្យដល់កូនគោ ។ ព្រានម្នាក់គិតនឹងចាក់វា ទើបឆាលំពែងដងវែងពួយទៅ លំពែងនោះទៅដល់សរីរៈមេគោនោះ ក៏ហើរទៅដូចស្លឹកត្នោត ចូលមិនដល់ នេះដោយកម្លាំង

ឧបចារសមាធិក៏ទេ ដោយកម្លាំងអប្បនាសមាធិក៏ទេ តែដោយភាពដែលមេគោនោះ មានចិត្តស្រឡាញ់ជាកម្លាំងក្នុងកូនគោនោះប៉ុណ្ណោះ មេត្តាមានអានុភាពច្រើនដូច្នេះ ឯង ។

ប្រការថា **ចិត្តតាំងមាំរហ័ស** គឺ ចិត្តរបស់អ្នកមានមេត្តាជាវិហារធម៌ រមែងជាសមាធិបានរហ័សតែម្តង ការយឺតយូរនៃសមាធិចិត្តនោះមិនមាន ។

ប្រការថា **ទឹកមុខផូរផង់** គឺ ប្រការមួយ មុខរបស់អ្នកមានមេត្តាជាវិហារធម៌នោះ រមែងមានទឹកមុខផូរផង់ ដូចក្បាលត្នោតទុំ ដែលទើបតែជ្រុះអំពីទងដូច្នោះ ។

ប្រការថា **មិនវង្វេងក្នុងកាលធ្វើកាលកិរិយា** មានសេចក្តីថា ដែលបានឈ្មោះថា សម្មោហមរណៈ ( ការវង្វេងក្នុងកាលស្លាប់ ) របស់អ្នកមានមេត្តាជាវិហារធម៌ រមែងមិនមាន លោកជាអ្នកមិនវង្វេងក្នុងកាលធ្វើកាលកិរិយា ដូចជាដេកលក់ទៅដូច្នោះ ។

ប្រការថា កាលនៅមិនទាន់សម្រេចគុណធម៌ដ៏ក្រៃលែងជាង...នោះ មានសេចក្តីថា ប្រការ ១ អ្នកមានមេត្តាជាវិហារធម៌នោះ កាលមិនអាចសម្រេចព្រះអរហត្ត ដែលជាគុណក្រៃលែងជាងមេត្តាសមាបត្តិ ឃ្លាតចាកភពនេះហើយ រមែងចូលដល់ព្រហ្មលោក ដូចជា លក់ហើយភ្ញាក់ឡើង ដូច្នោះ ។

( នេះជាកថា យ៉ាងពិស្តារក្នុងការចម្រើនមេត្តា )

## មហាដីកា

លោកអាចារ្យកាលសម្តែងការចម្រើនមេត្តាយ៉ាងនេះហើយ ឥឡូវនេះបំណងសម្តែងអានិសង្សទាំងឡាយក្នុងការចម្រើនមេត្តានោះ ទើបផ្តើមពាក្យថា **ឥតិ** ដូច្នេះ

ជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ជនដ៏សេស** បានដល់ បុគ្គលដែលមិនបានមេត្តាចេតោវិមុត្តិ ។ ពាក្យថា **បម្រះ** គឺមិនដេកផ្អៀងខាងស្តាំតែម្យ៉ាង ប្រែប្រួលទៅគ្រប់ខាង ។ បទថា **កាកច្ឆមានា** ( ស្រមុក ) គឺ ធ្វើសំឡេងខុសប្លែក ដោយទាក់ទងនឹងខ្យល់ដង្ហើមយូៗ ក្នុងពាក្យថា **លក់ជាសុខនេះ** ឈ្មោះថា **សុបនា** ( ការលក់ ) មាន ២ យ៉ាង គឺ ការលក់ដែលមានលក្ខណៈប្រាសខ្នងចុះទៅខាងលើទីដេកតែម្យ៉ាង , ការលក់ដែលមានលក្ខណៈជាការប្រព្រឹត្តទៅនៃភវង្គ ដែលមិនលាយឡំដោយចិត្ត ( វីថិចិត្ត ) ទាំងឡាយដែលសម្រេចដោយកិរិយាម្យ៉ាង ។ ក្នុង **សុបនា** ២ យ៉ាងនោះ ព្រះយោគីនេះ ឈ្មោះថារមែងលក់ជាសុខ សូម្បីដោយការលក់ទាំងពីរយ៉ាងនោះឯង ។ ព្រោះហេតុដែលដេកសន្សឹមៗ រួមអវយវៈតូចធំដេកទៅដោយអាការដែលគួរជ្រះថ្លា សូម្បីក្នុងវេលាដែលឈានចុះកាន់ការលក់ ក៏ដូចកំពុងចូលឈានដូច្នោះ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា មិនលក់ដូចគ្នានោះ ដូច្នេះជាដើម ។

ព្រោះជនពួកដទៃលក់ដូចជាទុក្ខ មិនបានសេចក្តីសុខក្នុងវេលាដែលលក់នោះឯង ក្នុងវេលាដែលភ្ញាក់ឡើងទើបមានការដកដង្ហើមធំ ការពត់កាយ និងការប្រមៀលខ្លួនទៅខាងនោះខាងនេះ ព្រោះការចុករោយនៃរាងកាយ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ដកដង្ហើមធំ ពត់កាយ បម្រះនទៀល ឈ្មោះថា រមែងភ្ញាក់ជាទុក្ខដូច្នេះ ។ ក៏ព្រះយោគីអង្គនេះ ព្រោះភាពដែលលក់បានយ៉ាងជាសុខ ទើបភ្ញាក់ឡើងជាអ្នកប្រាសចាកការដកដង្ហើមធំ ព្រោះមិនមានការចុកស្រពន់នៃរាងកាយ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា មិនភ្ញាក់ដូចគ្នានោះជាដើម ។ ម្យ៉ាងឈ្មោះថាមានការភ្ញាក់ជាសុខ ក៏ដោយមិនមានអាការខុសប្លែកនៃរាងកាយ ព្រោះហេតុនោះ

លោកទើបពោលថា រមែងភ្ញាក់ជាសុខ គឺ រកអាការខុសប្លែកមិនបាន ដូច្នេះ ។

ដោយពាក្យថា រមែងយល់សុបិនឃើញតែវត្ថុដែលល្អស្អាតប៉ុណ្ណោះ នេះ លោកអាចារ្យពោលទុក ព្រោះធ្វើទុកក្នុងចិត្តថា សម្រាប់ព្រះយោគីអង្គនេះ រមែងមានតែការយល់សុបិនល្អប៉ុណ្ណោះ ដោយទាក់ទងជាអារម្មណ៍ល្អៗ ដែលធ្លាប់សោយ និង ដោយទាក់ទងនឹងការបណ្ដាលចិត្តនៃទេវតា មិនមានការយល់សុបិនអាក្រក់ ដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកពោលថា ដូចជាថ្វាយបង្គំព្រះចេតិយ ដូច្នេះជាដើម ។ ម្យ៉ាងព្រះយោគីនេះ គប្បីមានការយល់សុបិនល្អច្រើនយ៉ាង សូម្បីដែលមានការកម្រើកនៃធាតុជាហេតុនោះឯង ព្រោះដោយច្រើន រូបដែលកើតអំពីឧតុ និងអាហារ សឹងជារឿងការកម្រើកនៃធាតុ មានការបណ្ដាយតាមរូបដែលកើតអំពីចិត្ត ។

ពាក្យថា **ដូចជាកម្រងគជ់ដែលពាក់នៅឱ្យជីក** អាចារ្យពួកខ្លះពោលអធិប្បាយថា ដូចជាកម្រងកែវមុក្តាដែលគេក្រងទុកសំយុងនៅត្រង់ទ្រូង ។ ក៏គប្បីជាការដែលថា ពាក្យនោះលោកពោលទុកដោយទាក់ទងនឹងខ្សែកម្រងសរសៃ ១ តែថា កម្រងកែវមុក្តាដែលជាចង្កោមខ្សែកម្រងច្រើនសរសៃដែលសំយុងចុះមកចាប់អំពីបរិវេណស្មារហូតដល់បរិវេណចង្កេះផ្នែកខាងក្រោម ក៏ឈ្មោះថា ជាកម្រងកែវមុក្តាដែលក្រងទុកត្រង់ទ្រូងដូចគ្នា ។

បទថា **តត្ថេវ** ប្រែថា នៅក្រុងបាដលីបុត្តនោះៗ ឯង ។ ឈ្មោះថា អាចនឹងអន្តរាយ ឬដេក ក៏ព្រោះភាពជាប្រទេសដែលផុតភ័យ និង ព្រោះភាពដែលស្ថានទីនោះៗ គួរមនោរម ។

កំណួចសំពត់នោះឯងឈ្មោះថា ជាយថ្នក់ បានដល់ កំណួចសំពត់ត្រង់ជាយ

បំផុតនៃសំពត់ ។

ពាក្យថា **សមវត្តវាស** បានដល់ ការនៅដែលមានការប្រព្រឹត្តវត្តបានស្មើគ្នាក្នុងវិហារនោះៗ ។ ពួមកថា ក្នុងវិហារតែមួយកន្លែងដែលលោកចូលទៅ ព្រះថេរៈមិនបានគិតថា ក្នុងវិហារនេះ យើងជាភ្ញៀវ ក្នុងវិហារនោះៗ លោកនៅធ្វើវត្តដែលខ្លួនគួរធ្វើឲ្យបរិបូណ៌តាមសមគួរនោះឯង ។ ចំណែកអាចារ្យមួយពួកទៀតពោលថា បានដល់ ការនៅដោយវិហារធម៌ គឺមេត្តាដែលប្រព្រឹត្តទៅស្មើគ្នាក្នុងសត្វទាំងឡាយទាំងពួង ។ ពិតណាស់ ព្រះថេរៈអង្គនេះជាអ្នកមានមេត្តាជាវិហារធម៌ ទាំងក្នុងកាលមុន ទាំងក្នុងខាងក្រោយអំពីការសម្រេចព្រះអរហត្ត ។

ពាក្យថា **ឈរនៅកណ្ដាលព្រៃ** មាននិទានថា ព្រះថេរៈអ្នកប្រព្រឹត្តដោយអំណាចការនៅដែលមានការប្រព្រឹត្តវត្តបានស្មើគ្នាយ៉ាងនោះ ថ្ងៃមួយ ជួបព្រៃជាទីមនោរមមួយកន្លែង ទើបចូលសមាបត្តិក្នុងទីនោះ ក្បែរគល់ឈើមួយកន្លែងចេញចាកឈាននោះតាមវេលាដែលបានកំណត់ទុក កាលនឹងឧទានដោយបីតិ និងសោមនស្សដែលមានការនឹកដល់គុណរបស់ខ្លួនជាហេតុ ទើបបានពោលគាថាថា ខ្ញុំព្រះករុណាឧបសម្បទាហើយអស់កាលត្រឹមណាដូច្នេះ ។ លោកអាចារ្យបំណងសម្ដែងសេចក្ដីដែលពោលនោះ ទើបលើកគាថាដំបូងថា ឈរនៅកណ្ដាលព្រៃដូច្នេះ ។ ក្នុងបាឋៈគាថាទាំងនោះ ពាក្យថា **កាលនឹងបន្លឺសំឡេង** គឺកាលនឹងបន្លឺសំឡេងដូចសំឡេងដែលរាជសីហ៍បន្លឺ ។ ពាក្យថា **កាលស្វែងរកគុណរបស់ខ្លួន** បានដល់ ស្វែងរក គឺពិចារណាការកើតឡើងនៃគុណរបស់ខ្លួន ។

ជនទាំងឡាយរមែងហៅទេវតាដើមឈើនោះថា **មណិលិយទេវតា** ព្រោះភាពជាទេវតាដែលអាស្រ័យនៅត្រង់ដើមមណិល ព្រោះដូច្នោះ សូម្បីទេវតាដើមឈើនោះ

ក៏ពោលថា លោកដ៏ចម្រើន ខ្ញុំព្រះករុណាមណិលិយទេវតា ដូច្នេះ ។ ពិតណាស់ ពួករុក្ខទេវតាទាំងឡាយ ដោយច្រើនមានឈ្មោះហៅ ដោយអំណាចដើមឈើដែលជាទីលំនៅ ដូចជាឈ្មោះហៅថា **ផន្ទនទេវតា** ( ទេវតាដែលអាស្រ័យនៅត្រង់ដើមផន្ទន ) ជាដើម ។ បទថា **តត្ថេវ** ប្រែថា ក្នុងចិត្តលបពិតនោះៗ ឯង ។

ដោយពាក្យថា ព្រោះភាពដែលមានចិត្តស្រឡាញ់យ៉ាងមានកម្លាំង នេះលោកសម្តែងថា សូម្បីព្រោះហេតុត្រឹមតែមានចិត្តស្រឡាញ់យ៉ាងមានកម្លាំង សស្ត្រា ក៏បៀតបៀនមិនបាន នឹងពោលថ្វីដល់មេត្តាចេតោវិមុត្តិនោះ ។

ពាក្យថា **ចិត្តរមែងតាំងមាំបានរហ័សនោះឯង** មានសេចក្តីថា ឈ្មោះថា ចិត្តរមែងតាំងមាំបានរហ័សនោះឯង ព្រោះព្យាបាទរបស់បុគ្គលដែលមានឈាន វិនាសដោយធម៌ជាសត្រូវខ្លះៗ ត្រូវដកចោលហើយឲ្យនៅក្នុងទីឆ្ងាយ ។ អាចារ្យពួកខ្លះពោលថា ព្រោះអាសវៈទាំងឡាយអស់ទៅ ។ ពាក្យដ៏សេសគប្បីយល់ងាយហើយម្យ៉ាងទៀត ក្នុងសេចក្តីនេះ អានិសង្សទាំងឡាយ មានដេកលក់ជាសុខជាដើម រមែងមានដល់បុគ្គលសម្រេចឈាន ដោយអំណាចនៃកម្មដ្ឋានដទៃអំពីកម្មដ្ឋាននេះ ដូចដែលលោកពោលទុកថា :

**មុនីទាំងឡាយ ដែលមានចិត្តតាំងមាំល្អក្នុងខាងក្នុង រមែងដេកលក់ជាសុខ សាវកទាំងឡាយរបស់ព្រះគោតមរមែងភ្ញាក់ជាសុខអស់កាលជានិច្ច ដូច្នេះ ។**

ជាដើមក៏ពិត សូម្បីយ៉ាងនោះ អានិសង្សទាំងនេះ សម្រាប់ព្រះយោគីដែលបានព្រហ្មវិហារ រមែងបានមិនមានសល់ ព្រោះភាពដែលព្រហ្មវិហារទាំងឡាយ ជាសត្រូវដោយត្រង់របស់ព្យាបាទជាដើម ។ ព្រោះហេតុនោះៗ ឯង លោកទើបពោលទុកថា ម្នាលលោកដ៏មានអាយុទាំងឡាយ មេត្តាចេតោវិមុត្តិនេះ ជាហេតុរលាស់

ចេញចាកព្យាបាទជាដើម ។ មួយ៉ាងទៀត សត្វទាំងឡាយ មានការដេកលក់ជាទុក្ខជាដើម ក៏ដោយអំណាចនៃព្យាបាទជាដើម ព្រោះហេតុនោះ កាលព្រហ្មវិហារទាំងឡាយ ដែលជាបដិបក្ខចំពោះព្យាបាទជាដើមនោះ សម្រេចហើយ អានិសង្សទាំងឡាយ មានការដេកលក់ជាសុខជាដើម ក៏ដូចជានៅក្នុងដៃហើយផងដែរ ។

( ចប់ មហាដីកា )

( ការអធិប្បាយ មេត្តាព្រហ្មវិហារ ចប់ដោយប្រការដូច្នេះ )

# ករុណាព្រហ្មវិហារ

*រីឯព្រះយោគាវចរដែលប្រាថ្នានឹងចម្រើនករុណាព្រហ្មវិហារ គប្បីពិចារណាឲ្យឃើញទោសនៃការមិនមានករុណា និងអានិសង្សរបស់ករុណាហើយ ទើបផ្ដើមចម្រើនករុណាព្រហ្មវិហារតទៅ កាលនឹងផ្ដើមចម្រើនករុណាព្រហ្មវិហារនោះ មិនគួរផ្ដើមក្នុងបុគ្គលដែលជាទោសដល់ការនា មានបុគ្គលជាទីស្រឡាញ់ជាដើមមុនឡើយ ព្រោះបុគ្គលជាទីស្រឡាញ់ ក៏តាំងនៅក្នុងស្ថាននៃបុគ្គលជាទីស្រឡាញ់នោះឯង ជាទីតាំងនៃករុណាក៏ទេ បុគ្គលជាសម្លាញ់ជាទីស្រឡាញ់ក្រៃលែងវិញ ក៏តាំងនៅក្នុងឋានៈនៃសម្លាញ់ជាទីស្រឡាញ់ក្រៃលែង បុគ្គលកណ្ដាលៗ ក៏តាំងនៅក្នុងឋានៈនៃបុគ្គលកណ្ដាលៗ បុគ្គលដែលមិនស្រឡាញ់ ក៏តាំងនៅក្នុងឋានៈនៃបុគ្គលមិនស្រឡាញ់ បុគ្គលដែលជាសត្រូវ ក៏តាំងនៅក្នុងឋានៈនៃបុគ្គលជាសត្រូវដដែល ( ទាំងអស់នេះ មិនមែនជាទីតាំងនៃករុណា ) ចំណែកបុគ្គលដែលមានភេទដូចគ្នានឹងបុគ្គលដែលធ្វើកាលកិរិយាហើយ ក៏មិនមែនជាដែន ( ដែលគួរផ្សាយករុណាទៅ ) ឡើយ តែព្រោះពោលទុកក្នុងវិភង្គថា ម្យ៉ាងទៀត ភិក្ខុមានចិត្តសហគតៈដោយករុណាផ្សាយទៅកាន់ទិស ១ ដូចម្ដេច គឺភិក្ខុមានករុណាផ្សាយទៅកាន់សត្វទាំងពួង ដូចជាឃើញបុគ្គលម្នាក់ ដែលជាជនលំបាកតោកយ៉ាកហើយ គប្បីអាណិត ព្រោះដូច្នោះ មុនដំបូង ព្រះយោគាវចរបានជួបនរណាត្រឹមតែម្នាក់ដែលគួរអាណិត គឺ មានរាងកាយគួរខ្ពើម ដល់នូវកាពលំបាកពេញបន្ទុក តោកយ៉ាកសែនលំបាក ជាបុគ្គលកំព្រា ថែមទាំងដៃ និងជើងកំបុត ដេកនៅត្រង់សាលាជនអនាថាដាក់អំបែងសុំទានទុកខាងមុខ មានពួកដង្កូវចេញអំពីដៃ និងជើង ធ្វើសំឡេងថ្ងូចថ្ងូរ គប្បីញ៉ាំងករុណាឲ្យប្រព្រឹត្តទៅថា សត្វនេះដល់នូវសេចក្ដីទុក្ខលំបាកហ្ន៎ ធ្វើម្ដេចហ្ន៎*

គេនឹងផុតចាកទុក្ខបាន ។

បើមិនបានជនទុគ៌តដូចនោះជាអារម្មណ៍ សូម្បីបុគ្គលដែលមានសេចក្តីសុខ តែកំពុងធ្វើបាប គប្បីចម្រើនករុណាបាន ដោយប្រៀបនឹងចោរដែលគេត្រូវសម្លាប់មុន សួរថា ប្រៀបដូចម្តេច ? ឆ្លើយថា ប្រៀបដូចរាជបុរសទាំងឡាយចងចោរ ដែលចាប់បានព្រមទាំងរបស់ ដោយព្រះរាជបញ្ជាថា ចូរសម្លាប់វាចោល ឲ្យប្រហារ ឬវាយ ១០០ រំពាត់ គ្រប់ៗ ទីផ្លូវបែកជា ៤ នាំទៅកាន់ផ្លូវត្រៃឡែងកែង ជនទាំងឡាយអាណិតវា ឲ្យរបស់ទំពាខ្លះ ឲ្យរបស់ស៊ីខ្លះ ផ្កាឈើ គ្រឿងក្រអូប គ្រឿងលាប និងស្លាម្លូខ្លះដល់វា វាទំពា និងស៊ីរបស់ទាំងនោះទៅ មើលទៅហាក់បីដូចមានសេចក្តីសុខដល់ព្រមដោយភោគៈក៏ពិតណាស់ សូម្បីយ៉ាងនោះ នរណាក៏មិនបានសម្គាល់ឃើញវាថា ចោរនេះជាអ្នកមានសេចក្តីសុខ មានភោគៈច្រើនហ្ន៎ ដូច្នេះឡើយ ដែលពិត មនុស្សម្នាក់គេករុណាវាថា បុគ្គលគួរអាណិតនេះនឹងស្លាប់ឥឡូវនេះឯង ព្រោះវាឈានជើងទៅមួយជំហានៗ វាក៏ខិតចូលទៅរកសេចក្តីស្លាប់គ្រប់ជំហានដោយជើងខាងនោះៗ ដូច្នេះ យ៉ាងណាក្តី សូម្បីបុគ្គលដែលមានសេចក្តីសុខ តែកំពុងធ្វើបាបភិក្ខុដែលបំពេញករុណាកម្មដ្ឋាន ក៏គប្បីផ្សាយករុណាបានយ៉ាងនេះថា បុគ្គលគួរអាណិតនេះក្នុងកាលឥឡូវនេះ ជាអ្នកដល់នូវសេចក្តីសុខ រៀបចំសុខវត្ថុទុកយ៉ាងល្អបរិភោគភោគៈក៏ពិត តែគេនឹងត្រូវបានសោយទុក្ខទោមនស្សមិនមែនតិចក្នុងអបាយទាំងឡាយមិនយូរឡើយ ព្រោះមិនមានកល្យាណកម្មដែលបានធ្វើទុក ដោយទ្វារទាំង ៣ សូម្បីតែទ្វារ ១ ដូច្នេះ ដូច្នោះដូចគ្នា កាលករុណាបុគ្គល ( ដែលមានសេចក្តីសុខ តែកំពុងធ្វើបាប ) នោះបានយ៉ាងនេះហើយ តពីនោះទៅ ទើបញ៉ាំងករុណាឲ្យប្រព្រឹត្តទៅ ដោយលំដាប់ គឺ ក្នុងបុគ្គលដែលជាទីស្រឡាញ់ , តអំពីនោះ ក្នុង

បុគ្គលដែលជាកណ្តាលៗ , តអំពីនោះ ក្នុងបុគ្គលដែលជាសត្រូវគ្នាដោយឧបាយវិធីដូចគ្នានោះ តែបើ បដិឃៈ គឺ ការថ្នាំងថ្នាក់ក្នុងសត្រូវកើតឡើងដល់លោកដោយន័យដែលពោលមកពីមុននោះសោត បដិឃៈនោះ លោកគប្បីរម្ងាប់ចេញតាមន័យដែលពោលក្នុងមេត្តាភាវនានោះចុះ , ម្យ៉ាងទៀត ក្នុងការផ្សាយករុណាវិធីនេះ ព្រះយោគាវចរបានជួប ឬបានឮដំណឹង បុគ្គលដែលបានធ្វើសេចក្តីល្អទុក តែមកជួបប្រសព្វសេចក្តីវិនាស មានការវិនាសញាតិ វិនាសព្រោះកើតរោគ វិនាសភោគទ្រព្យជាដើមឯណានីមួយហើយ ក៏គប្បីចម្រើនករុណាបានគ្រប់ប្រការយ៉ាងនេះថា បុគ្គលនេះសូម្បីមិនមានសេចក្តីវិនាសទាំងនោះ តែក៏ជាបុគ្គលឈ្មោះថាមានទុក្ខដែរ ព្រោះនៅមិនទាន់កន្លងវដ្តទុក្ខ... ដូច្នេះហើយ ទើបធ្វើសីមាសម្ភេទ ( រួមដែន ) ក្នុងជនទាំង ៤ គឺ ក្នុងខ្លួនឯង ក្នុងបុគ្គលជាទីស្រឡាញ់ ក្នុងបុគ្គលកណ្តាលៗ ក្នុងបុគ្គលដែលជាសត្រូវតាមន័យដែលពោលហើយនោះចុះ ហើយសេពចម្រើនធ្វើឲ្យច្រើននូវនិមិត្តនោះទៅ ក៏ធ្វើអប្បនាឲ្យចម្រើនបានដោយអំណាចនៃឈាន ៣ ក្នុងចតុក្កន័យ និងឈាន ៤ ក្នុងបញ្ចកន័យ តាមន័យដែលពោលហើយក្នុងមេត្តាភាវនានោះចុះ ។

ចំណែកក្នុងអដ្ឋកថាអង្គុត្តរនិកាយពោលលំដាប់ ( អារម្មណ៍របស់ករុណាភាវនា ) ទុកដូច្នេះថា បុគ្គលដែលជាសត្រូវ ព្រះយោគាវចរគប្បីចម្រើនករុណាមុនគេ ធ្វើចិត្តឲ្យទន់ក្នុងបុគ្គលជាសត្រូវនោះបានហើយ ទើបចម្រើនករុណាឲ្យដល់បុគ្គលទុគ៌ត តអំពីនោះ ឲ្យបុគ្គលជាទីស្រឡាញ់ តអំពីនោះឲ្យខ្លួនឯងដូច្នេះ លំដាប់ដែលពោលក្នុងអដ្ឋកថានេះ មិនត្រូវនឹងព្រះបាលីក្នុងវិភង្គ ដែលមានពាក្យថា **ទុគ្គតំ ទុរូបេតំ** ( ក្រីក្រ តោកយ៉ាក ) ជាដើម ព្រោះហេតុនោះ ព្រះយោគាវចរគប្បីផ្តើម

ភាវនាក្នុងករុណានេះ តាមន័យដែលពោលហើយនោះឯង ហើយធ្វើសីមាសម្ភេទ ញុំាងអប្បនាឲ្យចម្រើនចុះ ខាងមុខអំពីនោះ **វិកុព្វនា** គឺ ករុណាភាវនាជាអនោធិ-សោផរណា ដោយអាការ ៥ ជាឱធិសោផរណា ដោយអាការ ៧ ជាទិសាផរណា ដោយអាការ ១០ ដូច្នេះ និងអានិសង្សទាំងឡាយ មានមាតិកាថា ដេកលក់ជាសុខជាដើម បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលហើយក្នុងមេត្តាភាវនានោះចុះ ។

( នេះជាកថា យ៉ាងពិស្តារក្នុងការចម្រើនករុណា )

# មហាដីកា

# ពណ៌នា ការចម្រើនករុណា

ពាក្យថា **ករុណា** បានដល់ ករុណាព្រហ្មវិហារ ។ ពាក្យថា **ព្រោះភាពមិនមានករុណា** បានដល់ ព្រោះការបៀតបៀន មានសេចក្តីថា ព្រោះការបៀតបៀនដែលត្រាស់ទុកយ៉ាងនេះថា ស្ត្រី ឬ បុរសពួកខ្លះក្នុងលោកនេះ ជាអ្នកកើតមកបៀតបៀនសត្វទាំងឡាយដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយកំណាត់ឈើខ្លះ ដោយសស្ត្រាខ្លះ ដោយអំពើផ្សេងៗខ្លះ ដូច្នោះ ។ បទថា **អាទីនវំ** ប្រែថា ទោស ។ គប្បីពិចារណាដល់ការបៀតបៀន មានហាយនភាពច្រើនប្រការជាប់តាមជាដើម យ៉ាងនេះថា វិបាកដែលអាក្រក់ថោកទាបក្នុងលោកនេះ និងក្នុងលោកខាងមុខរមែងមានព្រោះការបៀតបៀនសត្វទាំងឡាយដោយប្រការណានីមួយ ។ ពិតហើយ បុគ្គលណាបៀតបៀនសត្វទាំងឡាយ ដោយការផ្តាច់ផ្តិលជីវិតក្តី ដោយការកាត់អវយវៈតូចធំក្តី ឬដោយការព្យាយាមដើម្បីឲ្យវិនាសទ្រព្យក្តី ដើម្បីឲ្យវិនាសលាភក្តី ដើម្បីឲ្យ

វិនាសយសក្តី ដើម្បីហាយនភាពក្តី ដើម្បីប្រយោជន៍ដល់ភាពជាបុគ្គលមិនមានយសក្តី ដោយហោចទៅ សូម្បីដោយការព្យាយាមរកតែកំហុស ចាប់កំហុស , សេចក្តីនោះជាការដែលនៅដោយភាពប្រមាទរបស់គេ រមែងមានដើម្បីការវិនាសលាភក្នុងអត្តភាពនេះនោះឯង រមែងមានដើម្បីភាពវិនាសទៅនៃលាភ ដែលបានហើយ កិត្តិស័ព្ទដែលថោកទាបព្រោះហេតុនៃការធ្វើនោះ រមែងផ្សាយទៅ គេរមែងជាបុគ្គលមិនអង់អាចចូលទៅរកបរិស័ទ ។ ជាបុគ្គលមានមុខសំយុងចុះ ជាបុគ្គលវង្វេងធ្វើកាលកិរិយា ក្រោយអំពីកាយបែកធ្លាយ ក៏សង្ឃឹមទុគ្គតិបាន សូម្បីជាមនុស្សក្នុងសុគតិ ក៏រមែងជាមនុស្សខ្វាក់អំពីកំណើតកើតក្នុងត្រកូលទាបខ្លះ ជាអ្នកមានពណ៌សម្បុរអាក្រក់ មិនគួរមើលខ្លះ ជាមនុស្សមានអាពាធច្រើន មានរោគច្រើនខ្លះ ជាបុគ្គលគោកយ៉ាក មានបាយ និងទឹកតិចខ្លះ ជាបុគ្គលមានអាយុខ្លី រស់នៅបានបន្តិចបន្តួចខ្លះ ដូច្នេះ គប្បីពិចារណាអានិសង្សទាំងឡាយរបស់ករុណាដោយប្រការដែលជាបដិបក្ខចំពោះទោសទាំងនោះ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា គប្បីពិចារណាទោសព្រោះការមិនមានករុណា និងអានិសង្សក្នុងករុណាដូច្នេះ ។ ដោយពាក្យថា **ព្រោះថា បុគ្គលដែលជាទីស្រឡាញ់ជាដើម** លោកពោលដល់ហេតុនៃព្រះយោគីដែលផ្តើមចម្រើនក្នុងបុគ្គលដែលជាទីស្រឡាញ់ជាដើមមុន ។ ពិតណាស់ កាលព្រះយោគីប្រារព្ធករុណាដល់បុគ្គលជាទីស្រឡាញ់ ភាពជាបុគ្គលជាទីស្រឡាញ់មិនបានប្រាសទៅព្រោះករុណានោះ , កាលភាពជាបុគ្គលជាទីស្រឡាញ់នោះនៅមិនទាន់ប្រាសទៅ សេចក្តីករុណានឹងមានបានអំពីណា ។ ព្រោះហេតុនោះ លោកទើបពោលថា ក៏តាំងនៅក្នុងឋានៈបុគ្គលជាទីស្រឡាញ់ដដែលដូច្នេះ ។ សូម្បីក្នុងបុគ្គលដ៏សេសទាំងឡាយ ក៏មានន័យដូច្នេះដែរ ។ ហេតុដែល

បុគ្គលមានភេទខុសគ្នា និង បុគ្គលដែលធ្វើកាលកិរិយាហើយ មិនមែនជាដែននៃករុណានោះ លោកបានពោលទុកខាងដើមហើយផងដែរ ។

ព្រះយោគីគប្បីចម្រើនករុណាក្នុងបុគ្គលណាជាលំដាប់ដំបូង លោកអាចារ្យបំណងសម្តែងបុគ្គលនោះតាមន័យព្រះបាលីនោះឯង ទើបផ្តើមពាក្យថា ម្យ៉ាងទៀត ដូចម្តេច ភិក្ខុ ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ទុគ្គតំ** ( បុគ្គលទុគ៌ត ) គឺ បុគ្គលអត្តខាត់ ។ ពិតណាស់ បុគ្គលនោះជាអ្នកដល់ហើយ ចូលដល់ហើយនូវសេចក្តីទុក្ខ ព្រោះមិនមានគ្រឿងអំណោយឲ្យសុខ ព្រោះមានភាពសូន្យចាកភោគសម្បត្តិ ទើបហៅថា ទុគ៌ត ។ ន័យម្យ៉ាងទៀត បទថា **ទុគ្គតំ** បានដល់ បុគ្គលដែលព្រមព្រៀងដោយសេចក្តីទុក្ខ ។ បទថា **ទុរបេតំ** ( ប្រព្រឹត្តគួរខ្ពើម ) គឺ ដល់ព្រមដោយទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ។ ម្យ៉ាងទៀត ក្នុងពីរបទនេះ គប្បីជ្រាបអត្ថយ៉ាងនេះថា បុគ្គលដែលតាំងនៅក្នុងភាពងងឹតងងល់ ទាក់ទងនឹងគតិ ត្រកូល រូបរាងជាដើម ឈ្មោះថា ទុគ៌ត អ្នកតាំងនៅក្នុងភាវៈ ដែលមានភាពងងឹតជាទីទៅខាងមុខ ព្រោះដល់ព្រមដោយទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ឈ្មោះថា **ទុរបេត** ដូច្នេះ ។ ពាក្យថា **ជួបប្រសព្វសេចក្តីលំបាកយ៉ាងក្រៃលែង** បានដល់ សេចក្តីលំបាកប្រមាណមិនបាន គឺ លិចនៅក្នុងសេចក្តីវិនាសដ៏ធំ ។ ពាក្យថា **ហេតុអ្វីហ្ន៎** គឺ ជាការល្អហ្ន៎ ។

ពាក្យថា **ចូរសម្លាប់វាចោល** មានសេចក្តីថា ដោយព្រះរាជឱង្ការដែលទ្រង់តាំងទុកយ៉ាងនេះថា ពួកអ្នកចូរសម្លាប់ចោរម្នាក់នោះចោលដូច្នេះ ។មនុស្សទាំងឡាយរមែងឲ្យ ។ល។ របស់ទំពាខ្លះ ព្រោះគិតថា ត្រឹមតែមួយសន្ទុះប៉ុណ្ណោះ វាក៏នឹងត្រូវសម្លាប់ សូមឲ្យវាបានទទួលសេចក្តីសុខត្រឹមប៉ុណ្ណោះខ្លះចុះ ដូច្នេះ ។ ពាក្យថា **ចាត់**

**បែងទុកល្អហើយ** គឺ បម្រុងនឹងសោយសុខ ។

ពាក្យថា **ដោយឧបាយនោះឯង** មានសេចក្តីថា ព្រះយោគីបំណងចម្រើនករុណាទៅក្នុងបុគ្គលដែលដល់នូវកាលពលំបាកយ៉ាងក្រៃលែង តាមដែលពោលហើយក្នុងបច្ចុប្បន្ននេះ ឬក្នុងបុគ្គលដែលមានចំណែកនៃទុក្ខក្នុងអនាគត ធ្វើករុណាឲ្យកើតឡើងបានដោយវិធីណាៗ តអំពីនោះទៅ ក៏គប្បីធ្វើករុណាឲ្យប្រព្រឹត្តទៅតាមន័យនេះឯង ។ ពាក្យថា **ក្នុងបុគ្គលដែលជាទីស្រឡាញ់** គឺក្នុងបុគ្គលដែលគួរស្រឡាញ់ ។ សម្ពន្ធសេចក្តីថា គប្បីចាប់យកការប្រសព្វសេចក្តីទុក្ខ ដែលឃើញក្នុងបច្ចុប្បន្ន ឬការប្រសព្វសេចក្តីទុក្ខដែលត្រូវមានជាធម្មតាក្នុងអនាគត ហើយធ្វើករុណាឲ្យប្រព្រឹតទៅចុះ ដូច្នេះ ។ សូម្បីក្នុងបុគ្គលដែលជាកណ្តាលៗ និងបុគ្គលដែលមានពៀរនឹងគ្នាក៏មានន័យនេះដែរ ។ ការចម្រើនករុណាទៅក្នុងបុគ្គលពីរប្រភេទដែលជាទីតាំងនៃករុណា ដែលលោកអាចារ្យពោលទុកសម្រេចបានងាយនោះឯងក៏ពិត សូម្បីយ៉ាងនោះ ភិក្ខុអង្គនេះបំណងនឹងធ្វើភាវនាក្នុងបុគ្គលពីរប្រភេទនោះ ឲ្យស្ទាត់ជំនាញក្រៃលែងឡើង ហើយធ្វើសីមាសម្ភេទ ក៏គួរចម្រើនករុណាទៅក្នុងបុគ្គល ដែលជាទីស្រឡាញ់ ក្នុងលំដាប់នៃបុគ្គលពីរប្រភេទនោះ តអំពីនោះ ក្នុងបុគ្គលដែលជាកណ្តាលៗ តអំពីនោះ ក្នុងបុគ្គលដែលមានពៀរ ។ កាលនឹងចម្រើនក៏គួរធ្វើចិត្តឲ្យទន់ គួរដល់ការងារក្នុងបុគ្គលតែមួយចំណែក បង្អោនចូលទៅក្នុងលំដាប់បុគ្គលនោះៗ ។ ចំណែកភិក្ខុអង្គណាមិនមានបុគ្គលដែលមានពៀរ ឬសូម្បីកាលជនដទៃធ្វើសេចក្តីវិនាសឲ្យ ក៏មិនមានសេចក្តីសម្គាល់ថា អ្នកនោះជាអ្នកមានពៀរសោះឡើយ ព្រោះភាពដែលខ្លួនមានជាតិជាមហាបុរស ភិក្ខុអង្គនោះក៏មិនត្រូវធ្វើសេចក្តីព្យាយាមថា ចិត្តរបស់យើងជាធម្មជាតិដែលគួរដល់ការងារ កើតហើយក្នុងបុគ្គល

ដែលជាកណ្តាលៗ ឥឡូវនេះ យើងនឹងបង្អោនចូលទៅក្នុងបុគ្គលដែលមានពៀរដូច្នេះ សោះឡើយ ។ ចំណែកភិក្ខុអង្គណាមានបុគ្គលដែលមានពៀរ លោកអាចារ្យសំដៅយកភិក្ខុអង្គនោះ ពោលថា តែប្រសិនបើដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា **តាមន័យដែលបានពោលហើយក្នុងវគ្គមុន** គឺ តាមន័យដែលបានពោលទុកសម្រាប់ព្រះយោគីដែលចម្រើនមេត្តាកម្មដ្ឋាន ។ ពាក្យថា **គប្បីធ្វើបដិឃៈឲ្យស្ងប់ទៅតាមន័យដែលពោលហើយក្នុងមេត្តានោះឯង** មានសេចក្តីថា លោកក៏គប្បីធ្វើបដិឃៈនោះ ឲ្យស្ងប់ទៅតាមន័យដែលបានពោលហើយក្នុងការចម្រើនមេត្តា ដោយពាក្យថា លំដាប់នោះ លោកគួរចូលមេត្តាក្នុងបុគ្គលលំដាប់មុនៗជាដើម និងដោយពាក្យថា លោកគប្បីព្យាយាមលះបដិឃៈ ដោយរឭកដល់ព្រះឱវាទដែលមានការឧបមាដោយរណាជាដើម ដូច្នេះជាដើម ។ លោកអាចារ្យកាលសម្តែងវិធីចម្រើនករុណា ទៅក្នុងបុគ្គលដែលប្រសព្វទុក្ខធំក្នុងបច្ចុប្បន្ននេះ ក្នុងបុគ្គល សូម្បីថា ដល់ហើយនូវសុខ ( ក៏ជាអ្នកប្រសព្វទុក្ខដ៏ធំ ) ដោយទាក់ទងនឹងការប្រសព្វសេចក្តីទុក្ខក្នុងអនាគត ព្រោះការដែលមិនបានធ្វើកុសលទុកតាមប្រការដូចពោលមកនេះហើយ ឥឡូវនេះ បំណងសម្តែងវិធីចម្រើនករុណាទៅសូម្បីក្នុងបុគ្គលដែលបានធ្វើកម្មល្អ ទុកទើបពោលថា ម្យ៉ាងទៀត ក្នុងអធិការនេះ ព្រះយោគីណា ដូច្នេះជាដើម ។ បទថា **គេសំ** បានដល់ សេចក្តីវិនាស ។ ពាក្យថា **ព្រោះមិនទាន់កន្លងវដ្តទុក្ខទៅបាន** គឺ ព្រោះការដែលមិនទាន់កន្លងសង្សារទុក្ខ ដែលនរណាៗ ប្រមាណមិនបាន គឺ ទុក្ខក្នុងអនាគត ដែលសូម្បីព្រះសម្មាសម្ពុទ្ធក៏មិនអាចត្រាស់ឲ្យចប់បាន ដោយការត្រាស់ប្រាប់ទុក្ខមានក្នុងអបាយ ទុក្ខដែលផ្សេងគ្នាដោយជាតិជរាជាដើម សូម្បីក្នុងសុគតិ ។ ពាក្យថា **ចម្រើនករុណាទៅសូម្បីដោយ**

**ប្រការទាំងពួង** បានដល់ ធ្វើករុណា គឺ ធ្វើករុណាភាវនាឲ្យចម្រើនទៅក្នុងបុគ្គលនោះៗ ដោយកំណត់ដល់ភាពជាទីអាស្រ័យ នៃករុណា ដោយប្រការទាំងពួង គឺដោយការប្រសព្វសេចក្ដីទុក្ខ ព្រោះមិនបានធ្វើកុសលទុក ឬដោយការប្រសព្វសេចក្ដីសុខ ព្រោះបានធ្វើកុសលទុក ។ ពាក្យថា **តាមន័យដែលបានពោលហើយនោះឯង** គឺ តាមន័យដែលបានពោលហើយ ក្នុងការចម្រើនមេត្តាដោយពាក្យថា លំដាប់នោះគប្បីជាអ្នកចម្រើនមេត្តាទៅរឿយៗជាដើម ។ ពាក្យថា **នូវនិមិត្តនោះ** គឺ នូវសមថនិមិត្ត ដែលប្រព្រឹត្តទៅដោយទាក់ទងនឹងសីមាសម្ភេទ ។ ពាក្យថា **តាមន័យដែលបានពោលហើយក្នុងមេត្តានោះឯង** មានសេចក្ដីថា ក្នុងការចម្រើនមេត្តា លោកពោលអប្បនាទុកដោយទាក់ទងនឹងឈាន ៣ - ៤ ដោយពាក្យថា រមែងសម្រេចអប្បនាតាមន័យដែលបានពោលហើយ ក្នុងបឋវីកសិណបាន ដោយមិនលំបាកឡើយ ដូច្នេះជាដើម និងពោលការធ្វើអប្បនានោះឲ្យចម្រើនដោយ ពាក្យថា **រមែងផ្សាយទៅកាន់ទិស ១ ដូច្នេះជាដើម** យ៉ាងណា ក្នុងការចម្រើនករុណា នេះក៏គប្បីជ្រាបអប្បនាដោយទាក់ទងនឹងឈាន ៣ - ៤ និងគប្បីធ្វើអប្បនាឲ្យចម្រើនដូចគ្នានោះ អធិប្បាយថា គប្បីជ្រាបវិធីធ្វើអប្បនានេះ ឲ្យចម្រើនដោយប្រការដូចគ្នានោះ ៗ ឯង ។ ពាក្យថា **តាមន័យដែលពោលហើយប៉ុណ្ណោះ** មានសេចក្ដីថា ដោយពាក្យដែលជា អវធារណៈ ( ពាក្យថា **ឯវ** ប្រែថា ប៉ុណ្ណោះ ) លោកអាចារ្យសម្ដែងដល់សេចក្ដីប្រការនេះថា ពាក្យថា **បុគ្គលដែលមានពៀរ ជាអ្នកគួរចម្រើនករុណាមុន** ដូច្នេះនេះ ជាពាក្យពោលដែលខុសនឹងព្រះបាលី យ៉ាងណា ក៏គង់ខុសនឹងយុត្តិ ( ហេតុផលដែលសមគួរ ) ផងយ៉ាងនោះ គឺថា ការរឭកដល់បុគ្គលដែលមានពៀរមុន សេចក្ដីក្រោធនឹងកើតឡើង ករុណាកើតឡើងមិនបាន ។

សូម្បីខ្លួនឯងជាបុគ្គល ដែលគប្បីកាន់យកដោយទាក់ទងនឹងការចម្រើនករុណាដោយភាពជាសាក្សី ( បន្ទាល់ ) នោះ ក៏ត្រឡប់មកកាន់យកក្នុងខាងក្រោយ ដោយប្រយោជន៍អ្វី ដូច្នេះឯង ។ម្យ៉ាងទៀត ដោយពាក្យថា ធ្វើអប្បនាឲ្យចម្រើនចុះនេះ គឺ លោកសម្តែងសេចក្តីប្រការនេះថា **វិកុព្វនា** ដែលពោលបានដោយពាក្យថាផ្សាយទៅកាន់ទិស ១ ដោយចិត្តដែលសហគតៈដោយករុណា ដូច្នេះជាដើម និងសម្រេចបានក៏សម្រាប់ព្រះយោគីដែលមានចិត្តសម្រេចអប្បនាហើយប៉ុណ្ណោះ ដូច្នេះ ។

ឯព្រះបាលីនេះមានត្រឹមបទថា ករុណាប៉ុណ្ណោះជាប្រការដែលប្លែក ព្រោះហេតុនោះ លោកអាចារ្យទើបមិនប៉ះពាល់ប្រការដែលប្លែកទៅនោះ បំណងសម្តែងថា វិកុព្វនាដែលព្រះសារីបុត្តត្ថេរពោលទុកក្នុងគម្ពីរបដិសម្ភិទាមគ្គ និង អានិសង្សរបស់មេត្តាដែលបានពោលហើយ ក៏រមែងមានក្នុងករុណានេះ ទើបពោលថា បន្ទាប់អំពីនោះទៅ ។ល។ ក៏គប្បីជ្រាបដូច្នេះ ។ ក្នុងពាក្យទាំងនោះ ពាក្យថា **បន្ទាប់អំពីនោះទៅ** គឺ ខាងមុខអំពីវិកុព្វនាដែលបានពោលទុកថា ផ្សាយទៅកាន់ទិស ១ ដោយចិត្តដែលសហគតៈដោយករុណាដូច្នេះ ។ ពាក្យដ៏សេស ក៏មានន័យដូចបានពោលមកហើយនោះឯង ។

( ចប់ មហាដីកា )

( ការអធិប្បាយ ករុណាព្រហ្មវិហារ ចប់ដោយប្រការដូច្នេះ )

# មុទិតាព្រហ្មវិហារ

ព្រះយោគាវចរដែលនឹងផ្ដើមធ្វើមុទិតាភាវនា ក៏មិនគួរផ្ដើមធ្វើក្នុងបុគ្គលដែលជាទោសដល់ភាវនា មានបុគ្គលជាទីស្រឡាញ់ជាដើមមុន ព្រោះថា បុគ្គលជាទីស្រឡាញ់ជាបទដ្ឋាននៃមុទិតា ដោយត្រឹមតែភាពជាទីស្រឡាញ់ ប៉ុណ្ណោះ ក៏ទេ នឹងពោលថ្វីដល់បុគ្គលដែលជាកណ្ដាលៗ និងដែលជាសត្រូវនោះ ចំណែកបុគ្គលដែលមានភេទផ្ទុយគ្នា និងបុគ្គលដែលធ្វើកាលកិរិយាហើយ ក៏មិនមែនដែន ( ដែលគួរចម្រើនមុទិតា ) ដូចគ្នា តែបុគ្គលដែលជាសម្លាញ់ជាទីស្រឡាញ់ក្រៃលែងដែលក្នុងអដ្ឋកថាហៅថា សម្លាញ់អ្នកលេង គប្បីជាបទដ្ឋានបាន ព្រោះសម្លាញ់អ្នកលេងនោះជាបុគ្គលគួររីករាយមនោរមពិត ជួបគ្នាក៏សើចមុន ហើយទើបនិយាយខាងក្រោយ ព្រោះហេតុនោះ សម្លាញ់ជិតស្និទ្ធនោះ ព្រះយោគាវចរគប្បីផ្សាយមុទិតាឲ្យមុនក៏បាន ឬបើមិនដូច្នោះ បានជួប ឬបានឮដំណឹងថា បុគ្គលជាទីស្រឡាញ់បានទទួលសេចក្ដីសុខក្ដី មានសុខវត្ថុកដាក់ក្ដី កំពុងរីករាយ គប្បីញ៉ាំងមុទិតាឲ្យកើតឡើងថា សត្វនេះរីករាយហ្ន៎ ឱ ! សាធុ ល្អពិត ពិតណាស់ លោកអាស្រ័យអំណាចនៃសេចក្ដីប្រការនេះឯង ពោលទុកក្នុងវិភង្គថា ម្យ៉ាងទៀត ភិក្ខុមានចិត្តសហគតៈដោយមុទិតា ផ្សាយទៅអស់ទិស ១ ដូចម្ដេច គឺភិក្ខុមានមុទិតាផ្សាយទៅកាន់សត្វទាំងឡាយទាំងពួង ដូចជាឃើញបុគ្គលម្នាក់ដែលជាទីស្រឡាញ់ ចម្រើនចិត្តហើយ គប្បីជាអ្នករីករាយចិត្តដូច្នោះ ដូច្នេះ ។

ប្រសិនបើសម្លាញ់អ្នកលេង ឬបុគ្គលជាទីស្រឡាញ់របស់លោកនោះ ជាអ្នកបានទទួលសេចក្ដីសុខមកហើយក្នុងអតីត តែឥឡូវនេះជាទុគ៌ត លំបាកលំបិន ក៏គប្បីរឭកដល់ភាវៈដែលគេបានទទួលសេចក្ដីសុខដែលជាអតីតនោះឯង ហើយកាន់យក

អាការរីករាយចិត្តក្នុងអតីតរបស់គេនោះឯង ញ៉ាំងមុទិតាឲ្យកើតឡើងថា គេនោះក្នុងអតីតបានជាអ្នកមានភោគៈច្រើនយ៉ាងនោះ មានបរិវារច្រើនយ៉ាងនោះ កំពុងរីករាយចិត្តជានិច្ចយ៉ាងនោះ ឬថា កាន់យកអាការរីករាយចិត្តរបស់គេដែលជាអនាគតក៏បានញ៉ាំងមុទិតាឲ្យកើតឡើងថា ក្នុងអនាគតគេនឹងបានសម្បត្តិនោះទៀត ហើយត្រាច់ទៅដោយយានវិសេសទាំងឡាយ មាន កដំរី ខ្នងសេះ និងវិមានជាដើម ។

កាលញ៉ាំងមុទិតា ឲ្យកើតឡើងក្នុងបុគ្គលដែលជាទីស្រឡាញ់បានយ៉ាងនេះហើយ ពេលនោះទើបញ៉ាំងមុទិតាឲ្យប្រព្រឹត្តទៅក្នុងបុគ្គលកណ្តាលៗ តអំពីនោះ ក្នុងបុគ្គលជាសត្រូវដូច្នេះ តាមលំដាប់ តែបើបដិឃៈក្នុងបុគ្គលដែលជាសត្រូវកើតឡើងដល់លោកតាមន័យដែលពោលហើយពីមុននោះសោត ក៏គប្បីរម្ងាប់ពៀរចេញតាមន័យដែលពោលក្នុងមេត្តាភាវនានោះ ហើយធ្វើសីមាសម្ភេទដោយការមានចិត្តស្មើក្នុងជនទាំង ៤ គឺ ក្នុងបុគ្គល ៣ ដែលពោលហើយនេះ និងក្នុងខ្លួនឯងផងទើបសេព ចម្រើន ធ្វើឲ្យច្រើននូវនិមិត្តនោះទៅ ក៏នឹងអាចញ៉ាំងអប្បនាឲ្យចម្រើនបានដោយអំណាចនៃឈាន ៣ ក្នុងចតុក្កន័យ និងឈាន ៤ ក្នុងបញ្ចកន័យ តាមន័យដែលពោលហើយក្នុង មេត្តាភាវនានោះឯង តអំពីនោះទៅ **វិកុព្វនា** គឺ មុទិតាភាវនាជាអនោធិសោផរណា ដោយអាការ ៥ ជាឱធិសោផរណា ដោយអាការ ៧ ជាទិសាផរណា ដោយអាការ ១០ នេះ និងអានិសង្សទាំងឡាយ មានប្រការថាដេកលក់ជាសុខជាដើម បណ្ឌិតគប្បី ជ្រាបតាមន័យដែលពោលហើយក្នុងមេត្តា-ភាវនានោះចុះ ។

( នេះជាកថា យ៉ាងពិស្តារក្នុងការចម្រើនមុទិតា )

# មហាដីកា
# ពណ៌នា ការចម្រើនមុទិតា

ពាក្យថា **ក្នុងបុគ្គលដែលជាទីស្រឡាញ់ជាដើម** មានពាក្យប្រកបសេចក្តី ធ្វើការចែកឲ្យប្រែប្រួលទៅថា មិនគួរផ្តើមចម្រើនមុទិតាក្នុងបុគ្គលដែលជាទីស្រឡាញ់ បុគ្គលដែលជាកណ្តាលៗ និងបុគ្គលដែលមានពៀរទេ ។ ពាក្យថា **ន ហិ** ( ព្រោះថា... ក៏ទេ ) ជាដើម ជាពាក្យពោលដល់ហេតុ ក្នុងការដែលមិនគួរផ្តើមចម្រើនមុទិតាក្នុងបុគ្គលដែលជាទីស្រឡាញ់ជាដើមនោះ ។ **មត្ត** ស័ព្ទ ប្រែថា **ត្រឹមតែ** ក្នុងបទថា **បិយការមត្តេនេវ** ដោយហេតុត្រឹមតែជាទីស្រឡាញ់ប៉ុណ្ណោះនេះ មានអត្ថថា ហាមប្រការវិសេសដោយ **មត្ត** ស័ព្ទ នោះលោកបង្ហាញប្រការពិសេសទាំងឡាយដែលជាបទដ្ឋាននៃមុទិតាជាដើម យ៉ាងនេះថា ការៈដែលមានមុខញញឹមញញែមជានិច្ចដែលសម្រេច អំពីភាពជាបុគ្គល មានបដិសន្ធិសហគតៈដោយសោមនស្សជាដើម ភាពជាអ្នករាក់ទាក់មុន ភាពជាអ្នកពោលផ្អែម ភាពជាអ្នកចរចាទន់ភ្លន់ ភាពជាអ្នកនិយាយឲ្យរីករាយចិត្តដូច្នេះ ជាការពោលអធិប្បាយបានថា វៀរប្រការពិសេសទាំងឡាយដែលជាដូច្នេះ ( គឺ វៀរប្រការពិសេសទាំងឡាយដែលជាដូច្នេះហើយ បុគ្គលដែលជាទីស្រឡាញ់នោះ ជាបទដ្ឋានដល់មុទិតាមិនបាន ) ។ រីឯដោយ **ឯវ** អក្ខរៈ ( ប្រែថា ប៉ុណ្ណោះ ) លោកហាមសេចក្តីដល់ព្រមដោយសេចក្តីសុខជាដើមនៃបុគ្គលជាទីស្រឡាញ់ និង ការប្រព្រឹត្តទៅនៃការរីករាយដែលជាហេតុនៃមុទិតា ។ ពិតណាស់ មុទិតារបស់ភិក្ខុគប្បីបានឱកាសសួម្បីក្នុងបុគ្គលដែលជាទីស្រឡាញ់ ដែលរីករាយត្រេកអរដោយសម្បត្តិយ៉ាងក្រៃលែង ។ ពិត

ណាស់ លោកអាចារ្យនឹងពោលថា ម្យ៉ាងទៀត ព្រះយោគីជួប ឬបានដំណឹងអំពីបុគ្គលដែលជាទីស្រឡាញ់ដូច្នេះជាដើម ។ កាលព្រះយោគី វេញកដល់បុគ្គលដែលជាកណ្តាលៗ មកតាំងអំពីដើម ភាពព្រងើយកន្តើយរមែងប្រាកដ ការវេញកដល់បុគ្គលដែលមានពៀរ ការក្រោធក៏រមែងកើតឡើង ។ព្រោះហេតុនោះ លោកទើបពោលថា នឹងពោលថ្វីដល់បុគ្គលដែលជាកណ្តាលៗ និងបុគ្គលដែលមានពៀរនោះ ដូច្នេះ ។

សម្លាញ់ដែលដូចជាអ្នកលេង ព្រោះមានតែការរីករាយប្រព្រឹត្តទៅ ឈ្មោះថាសម្លាញ់អ្នកលេង ។ ពាក្យថា **ជាអ្នកយកតែរីករាយមនោរមតែម្យ៉ាង** គឺជាអ្នកដែលរីករាយក្រៃលែងតែម្យ៉ាង ព្រោះភាពជាអ្នកមានចិត្តផូរផង់ ត្រជាក់ត្រជុំ ។ពិតណាស់ពាក្យពោលដដែលៗ ( ថា **មុទិត មុទិតោវ** ដែលប្រែថា រីករាយមនោរម ) នេះប្រព្រឹត្តទៅក្នុងអត្ថថា ផូរផង់ ។ លោកអាចារ្យ កាលសម្តែងវត្ថុនៃការចម្រើនមុទិតាតាំងអំពីដើម តាមន័យនៃអដ្ឋកថាយ៉ាងនេះហើយ ឥឡូវនេះបំណងសម្តែងតាមន័យព្រះបាលីទើបពោលថា ម្យ៉ាងទៀត ព្រះយោគីជួប ឬបានដំណឹងអំពីបុគ្គលដែលជាទីស្រឡាញ់ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **សុខិតំ** គឺ មានសុខដែលកើតឡើងហើយ មានសេចក្តីថា ដល់ហើយនូវសេចក្តីសុខ ។ បទថា **សជ្ជិតំ** ( ចាត់ចែងហើយ ) គឺ ដល់ព្រមក្នុងការសោយសុខដែលបានប្រុងប្រៀបគ្រឿងអំណោយសុខទុកហើយ ។ ពាក្យថា **ឱ សាធុ** ជាពាក្យសម្តែងអាការត្រេកអរដែលមានសម្បជញ្ញៈចេញមុខ ក្នុងសម្បត្តិរបស់សត្វនោះ ។ ពាក្យថា **ឱ ! ល្អពិតជាពាក្យមួយទៀត** ជាពាក្យសម្តែងការធ្វើឲ្យច្រើននូវសេចក្តីត្រេកអរនោះ ។ ដោយស័ព្ទថា គួរពេញចិត្តក្នុងពាក្យថា គួរស្រឡាញ់ គួរពេញចិត្តនេះ អាចារ្យពួកមួយពោលថា សូម្បីក្នុងព្រះបាលីក៏ទ្រង់បំណងយកបុគ្គលដែលជាសម្លាញ់ជាទីស្រឡាញ់

ក្រៃលែង ។

ពាក្យថា **ក្នុងអតីត** បានដល់ ក្នុងអត្តភាពនោះៗឯង ដែលជាអតីត ។ សូម្បីក្នុងពាក្យថា ក្នុងអនាគតក៏មានន័យនេះដែរ ។ ព្រោះថា ការចម្រើនព្រហ្មវិហារក្នុងបុគ្គលដែលនៅក្នុងភពដទៃ រមែងមិនចម្រើន ឬ លូតលាស់ ។

សួរថា ប្រសិនបើយ៉ាងនេះ នឹងចម្រើនព្រហ្មវិហារទៅក្នុងអតីត ឬអនាគតបានដូចម្ដេច ? ឆ្លើយថា សេចក្ដីនេះមិនខុសទេ ។ ព្រោះបុគ្គលដែលគប្បីកាន់យកថា បុគ្គលនេះនោះឯងឈ្មោះថា **ទត្ត** ឈ្មោះថា **តិស្ស** ដូច្នេះ ក៏ដោយភាពជាបុគ្គលដែលមានប្រាកដដោយភាពជាអទ្ធាបច្ចុប្បន្ន ( អទ្ធា គឺ កាលវេលាដែលទាក់ទងក្នុងភព ១ ចាប់តាំងអំពីបដិសន្ធិទល់ចុតិ ) ។ សួរថា សម្បត្តិ ( ការដល់ព្រម , សេចក្ដីសម្រេច ) ក្នុងអនាគតរបស់បុគ្គលនេះនឹងជាអារម្មណ៍បានដូចម្ដេច ? ឆ្លើយថា នឹងជាអារម្មណ៍បានដោយការសម្ដែងអាងជាដើម ឬដោយជាសម្បត្តិដែលគប្បីកាន់យកបាន ដោយការអនុមានយកតាមប្រយោគសម្បត្តិដែលបានជាបច្ចុប្បន្នរួចមកហើយ ។

ពាក្យថា ( **កាលធ្វើមុទិតាឲ្យកើតឡើង** ) **ក្នុងបុគ្គលដែលជាទីស្រឡាញ់** គឺ ក្នុងបុគ្គលដែលស្រឡាញ់ក្រៃលែង ដែលសម្គាល់ថា សម្លាញ់អ្នកលេង និងក្នុងបុគ្គលដែលជាទីស្រឡាញ់ ( យ៉ាងកណ្ដាល ) ។ ក៏បុគ្គលទាំងពីរជំពូកនេះ ក្នុងទីនេះលោកហៅថា បុគ្គលជាទីស្រឡាញ់ ព្រោះមានភាពជាបុគ្គលជាទីស្រឡាញ់ស្មើគ្នា ។ ពាក្យថា **តាមលំដាប់** គឺ តាមលំដាប់នៃការធ្វើកម្មដ្ឋានក្នុងបុគ្គល ៤ ចំណែក តែ ១ ចំណែក គឺ បុគ្គលជាទីស្រឡាញ់ក្រៃលែង បុគ្គលជាទីស្រឡាញ់ បុគ្គលជាកណ្ដាល ៗ បុគ្គលដែលមានពៀរ ឲ្យស្ទាត់ជំនាញ ទន់ភ្លន់ និង គួរដល់

ការងារ ហើយក៏បង្អោនចូលទៅក្នុងបុគ្គលដ៏សេស ។ សេចក្ដីពិត ភាពជាអ្នកមានចិត្តស្មើក្នុងជនជំពូកនោះឯង ឈ្មោះថា **សីមាសម្ភេទ** ព្រោះធ្វើអត្ថន័យរបស់ពាក្យថា ជាហេតុទម្លាយព្រំដែន ។ សូម្បីយ៉ាងនោះ កាលភាវនាប្រព្រឹត្តទៅដោយប្រការនោះ ដោយច្រើន លោកអាចារ្យទើបធ្វើហេតុដែលសម្រេចជាខាងដើមឲ្យជាហេតុ និងធ្វើហេតុក្រៅអំពីនេះឲ្យជាផល ពោលថា ធ្វើសីមាសម្ភេទ ដោយភាពជាអ្នកមានចិត្តស្មើដូច្នេះ ។ម្យ៉ាងទៀត ការមិនមានសីមា ( ព្រំដែន ) តាមដែលពោលហើយ ឈ្មោះថា **សីមាសម្ភេទ** ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ធ្វើសីមាសម្ភេទ ដោយភាពជាអ្នកមានចិត្តស្មើដូច្នេះ ។ ក្នុងអធិការនៃមុទិតាភាវនានេះ មានពាក្យដែលគួរពោលដល់ណា នៅសល់ ពាក្យនោះមានន័យដូចខ្ញុំព្រះករុណាបានពោលហើយ ក្នុងខាងដើមនោះឯង ។

( ចប់ មហាដីកា )

( ការអធិប្បាយ មុទិតាព្រហ្មវិហារ ចប់ដោយប្រកាដូច្នេះ )

# ឧបេក្ខាព្រហ្មវិហារ

ចំណែកព្រះយោគាវចរដែលនឹងផ្ដើមធ្វើឧបេក្ខាភាវនា ចេញអំពីឈានទី ៣ ឬទី ៤ ដែលស្ទាត់ជំនាញហើយ តាមដែលជាតិកឈាន ឬចតុក្កឈានដែលខ្លួនបានក្នុងភាវនា ៣ មានមេត្តាភាវនាជាដើមហើយ ឃើញទោសក្នុងភាវនា ៤ ខាងដើម ព្រោះជាភាវនាប្រកបដោយមនសិការ ដែលប្រព្រឹត្តទៅដោយសេចក្ដីស្រឡាញ់ក្នុងសត្វទាក់ទងដោយការនឹកផ្សាយទៅថា សូមសត្វទាំងពួងជាអ្នកដល់នូវសេចក្ដីសុខចុះ ដូច្នេះជាដើម ១ ព្រោះជាភាវនាដែលនៅជិតសេចក្ដីមិនត្រេកអរ ( បដិឃៈ ) និងសេចក្ដីត្រេកអរ ១ ព្រោះជាភាវនាដែលគ្រោតគ្រាត ព្រោះនៅប្រកបដោយសោមនស្ស ១ និង ឃើញអានិសង្សក្នុងឧបេក្ខាដោយភាពជាធម៌ស្ងប់ហើយ បុគ្គលណាជាកណ្ដាលៗ នៅដោយប្រក្រតីរបស់លោក គប្បីព្រងើយក្នុងបុគ្គលនោះញុំាងឧបេក្ខាឲ្យកើតឡើង តអំពីនោះ ទើបញុំាងឧបេក្ខាឲ្យកើតឡើងក្នុងបុគ្គលដទៃៗ មានបុគ្គលជាទីស្រឡាញ់ជាដើម សមដូចពាក្យដែលពោលទុកក្នុងវិភង្គថា ម្យ៉ាងទៀត ភិក្ខុមានចិត្តសហគតៈនឹងឧបេក្ខាផ្សាយទៅអស់ទិស ១ ដូចម្ដេច គឺ ភិក្ខុផ្សាយឧបេក្ខាទៅកាន់សត្វទាំងពួង ដូចជាបានឃើញបុគ្គលម្នាក់ ដែលជាទីពេញចិត្តក៏មិនមែន មិនពេញចិត្តក៏មិនមែន ហើយគប្បីនៅព្រងើយដូច្នោះ ព្រោះហេតុនោះ ព្រះយោគាវចរ កាលញុំាងឧបេក្ខាឲ្យកើតឡើងបានក្នុងបុគ្គលដែលជាកណ្ដាល ៗ តាមន័យដែលពោលហើយ ទើបញុំាងឧបេក្ខាឲ្យកើតឡើងក្នុងបុគ្គលជាទីស្រឡាញ់ តអំពីនោះ ក្នុងសម្លាញ់អ្នកលេង តអំពីនោះ ក្នុងបុគ្គលដែលជាសត្រូវ ហើយធ្វើសីមាសម្ភេទដោយដាក់ចិត្ត ជាកណ្ដាលក្នុងបុគ្គលទាំងពួង គឺ ក្នុងបុគ្គល ៣ តាមដែលពោលមកនេះ និងក្នុងខ្លួនឯង ហើយសេពនិមិត្តនោះឲ្យក្រៃលែង ចម្រើននិមិត្ត

នោះ ធ្វើនិមិត្តនោះឲ្យច្រើន កាលព្រះយោគាវចរធ្វើទៅយ៉ាងនោះ ចតុត្ថជ្ឈាន ( ឬ បញ្ចមជ្ឈាន ) នឹងកើតឡើងតាមន័យដែលពោលហើយក្នុងបឋវីកសិណនោះឯង ។

មានសំណួរថា ចតុត្ថជ្ឈានដែលពោលនេះ កើតដល់ព្រះយោគាវចរអ្នកបានតតិយជ្ឈានដែលកើតក្នុងកម្មដ្ឋានដទៃ មានបឋវីកសិណជាដើមផងឬ ?

ឆ្លើយថា កើតមិនបាន ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះភាពដែលមានអារម្មណ៍មិនត្រូវគ្នា តែកើតដល់បុគ្គលដែលបានតតិយជ្ឈាន ដែលកើតក្នុងព្រហ្មវិហារភាវនា មានមេត្តាភាវនាជាដើមប៉ុណ្ណោះ ព្រោះមានអារម្មណ៍ត្រូវគ្នា ។

ចំណែកវិកុព្វនា និងការបានអានិសង្សតអំពីនោះទៅ បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលហើយក្នុងមេត្តាភាវនានោះចុះ ។

( នេះជាកថា យ៉ាងពិស្តារក្នុងការចម្រើនឧបេក្ខា )

## មហាដីកា

## ពណ៌នា ការចម្រើនឧបេក្ខា

ពាក្យថា **ចម្រើនឧបេក្ខា** គឺ ចម្រើនឧបេក្ខាព្រហ្មវិហារ ព្រោះហេតុដែលព្រហ្មវិហារទី ៤ ( ឧបេក្ខាព្រហ្មវិហារ ) ជាផលដែលបានមកអំពីព្រហ្មវិហារ ៣ ខាងដើម ដូច្នោះ លោកអាចារ្យទើបពោលថា ដែលជាអ្នកបានឈាន ៣-៤ ក្នុងព្រហ្មវិហារ ៣ ខាងដើម មានមេត្តាជាដើមដូច្នេះ ។ ពាក្យថា **ចេញចាកឈានទី ៣ ដែលស្ទាត់ជំនាញ** មានសេចក្ដីថា ឈានទី ៣ ដែលអប់រំល្អហើយ ធ្វើឲ្យដល់

ភាពជាវសីបានហើយ ឈ្មោះថា ស្ទាត់ជំនាញ បានដល់ ចេញអំពីឈានទី ៣ ក្នុងព្រហ្មវិហារដែលជាដូច្នោះ ។ ព្រោះថា ឈានដែលនៅមិនទាន់ស្ទាត់ជំនាញ រមែងមិនជាបទដ្ឋាននៃឈានជាន់លើឡើយ ។ ឯសព្ទថា ទី ៣ ក្នុងពាក្យនេះ លោកពោលទុកដោយទាក់ទងនឹងឈានចតុក្កន័យ ។ ដោយ **អាទិ** សព្ទ ( ប្រែថា ជាដើម ) ។ ក្នុងពាក្យថា ដោយទាក់ទងនឹងមនសិការថា សូមជាអ្នកដល់នូវសុខចុះជាដើម គប្បីឃើញថា សង្គ្រោះយកមនសិការមានយ៉ាងនេះថា សូមជាអ្នកមិនមានទុក្ខចុះ ដូច្នេះជាដើម ។ ឈ្មោះថា **ការជាប់ជំពាក់ក្នុងសត្វ** បានដល់ ការប្រព្រឹត្តថា របស់យើង គឺ ការធ្វើឲ្យមានភាពជារបស់យើងក្នុងសត្វទាំងឡាយការប្រកបដោយមនសិការយ៉ាងនោះ , ឈ្មោះថា **ភាពជាភាវនាប្រកបដោយមនសិការដែលប្រព្រឹត្តទៅដោយការជាប់ជំពាក់ក្នុងសត្វ** បានដល់ ព្រោះភាពជាភាវនា...ជាប់ជំពាក់ក្នុងសត្វនោះ ។ គប្បីជ្រាបសេចក្ដីជាភាវនាដែលនៅជិតសេចក្ដីត្រេកអរ មិនត្រេកអរ តាមសមគួរដោយភាវៈ ដែលមេត្តាជាដើមប្រព្រឹត្តទៅជិតរាគៈ ទោមនស្ស និងសោមនស្សដែលអាស្រ័យផ្ទះ ។ ន័យម្យ៉ាងទៀត ភាវនាទាំង ៣ ឈ្មោះថា ត្រាច់ទៅជិតសេចក្ដីត្រេកអរ ព្រោះប្រព្រឹត្តទៅដោយភាពជាអ្នកស្វែងរកប្រយោជន៍ឧបការៈ ( ក្នុងសត្វទាំងឡាយ ) ថា ចូរជាអ្នកដល់នូវសេចក្ដីសុខចូរផុតចាកទុក្ខចុះ ចូររីករាយចុះដូច្នេះ និង កាលបរិយាយដែលខុសគ្នានឹងសភាវៈនោះ ( គឺ មិនជាអ្នកដល់នូវសុខជាដើម ) មានប្រាកដ បដិឃៈក៏បានឱកាស ព្រោះបរិយាយដែលខុសទៅនេះ ដូចកាលមានការកម្រើកនៃលោហិត ខ្ទុះក៏បានឱកាសដូច្នោះ ព្រោះហេតុនោះ ទើបគប្បីជ្រាបថា ភាវនាទាំង ៣ នោះ មានការត្រាច់ទៅជិតសេចក្ដីត្រេកអរ មិនត្រេកអរ បានដោយមិនប្លែកគ្នា ។

ពាក្យថា **ព្រោះជាភាវនាដែលគ្រោតគ្រាត** ព្រោះប្រកបដោយសោមនស្ស នេះ លោកពោលទុកដោយទាក់ទងនឹងឈានទី ៣ តែកាលនឹងពោលដល់ ភាវនាដែលគ្រោតគ្រាត ដោយទាក់នឹងធម្មជាតិ មានមេត្តាជាដើមថា ព្រះយោគាវចរដែលចេញអំពីមេត្តាឈានជាដើមនោះ មានការសម្លឹងឃើញនូវទោស ដូច្នេះ ក៏ត្រូវពោលដល់ភាពជាភាវនា ដែលគ្រោតគ្រាតទុកដោយការប្រកបនឹងវិតក្ក វិចារៈ និង បីតិនោះឯង ព្រោះភាវនាទាំងនោះ មានការប្រកបរួមគ្នានឹងធម្មជាតិ មានវិតក្កជាដើម ទាំងនោះក៏មានប្រាកដ និងព្រោះឧបេក្ខាភាវនាមិនមានការប្រកបរួមគ្នានឹងធម្មជាតិ មានវិតក្កជាដើមនោះ ។ ឬមិនត្រូវពោលដល់ក៏បាន ព្រោះក្នុង ទីនេះ លោកបំណងយកភាវនា មានមេត្តាជាដើម ដែលប្រកបដោយឈានទី ៣ ប៉ុណ្ណោះ , ម្យ៉ាងទៀត ដោយការឈានកន្លងឈាននោះៗ បាននោះឯង សម្បយុត្តធម៌ ទាំងឡាយ មានមេត្តាជាដើម ដែលមាននៅក្នុងឈាននោះៗ ក៏ឈ្មោះថា ត្រូវឈានកន្លងផងដែរ ទើបមានត្រឹមតែវោហារថា ( មិនទាន់ឈានកន្លង ) ព្រោះ ( ឈានទី២ ជាដើម ) មានមេត្តាជាដើមដូចគ្នា ជាឈានដូចគ្នា ។ ពាក្យថា **ក្នុងភាវនា ៣ ខាងដើម** គឺ ក្នុងមេត្តា ករុណា និងមុទិតា ។ ពាក្យថា **ភាពជាធម៌ស្ងប់** ( គឺ សម្លឹងអានិសង្ស ) របស់ឧបេក្ខាថាជាធម៌ស្ងប់ ព្រោះមិនមានភាពមិនស្ងប់ មានការជាប់ជំពាក់ក្នុងសត្វជាដើមតាមដែលពោលហើយ ។ ពាក្យថា **ភាពជាធម៌ស្ងប់នេះ** គប្បីឃើញថា ត្រឹមតែជានិទស្សនៈ ។ គប្បីជ្រាបអានិសង្សរបស់ឧបេក្ខាមានជាអាទិ៍យ៉ាងនេះថា ភាពជាធម៌ដែលល្អិត ភាពជាធម៌ដែលប្រណីត ភាពជាធម៌ដែលមានកិលេសនៅឆ្ងាយ ភាពជាធម៌ដែលមានផលបរិបូណ៌ ដូច្នេះ ។ ពាក្យថា **ជាកណ្តាលៗ តាមប្រក្រតី** មានសេចក្តីថា ព្រោះមិនសម្លឹងដល់ហេតុការណ៍ អ្វីៗ ក៏

ចាត់ថាជាបុគ្គលដែលតាំងនៅក្នុងចំណែកដែលគួរព្រងើយកន្តើយ សម្រាប់ភិក្ខុអង្គនេះ តាមប្រក្រតី គឺ តាមសភាវៈនោះឯង ។ ពាក្យថា **ព្រងើយក្នុងបុគ្គលនោះ** មានសេចក្តីថា រមែងព្រងើយ ៗ ចំពោះបុគ្គលនោះ ដែលផ្សេងគ្នាដោយភាពជាបុគ្គលគួរគោរព គួររាប់អានជាដើម ដែលព្រះយោគី ចូលទៅធ្វើឲ្យកើតឡើងព្រមនឹងភាពជាកណ្តាលៗ ដោយអាស្រ័យសេចក្តីវង្វៀស ចំពោះ ( ការធ្លាក់ទៅក្នុង ) ចំណែកតែម្ខាង ( បុគ្គលដទៃម្ខាង ខ្លួនឯងម្ខាង ) ជាគន្លង យ៉ាងនេះថា លោកដ៏មានអាយុនេះ មកហើយ ហើយនឹងទៅ ក៏ដោយអំណាចនៃកម្ម ដែលខ្លួនធ្វើទុកប៉ុណ្ណោះ សូម្បីអ្នកមកហើយ ក៏នឹងទៅ ក៏ដោយអំណាចនៃកម្ម ដែលខ្លួនធ្វើទុកដូចគ្នា ការដែលអ្នកនឹងប្រើសេចក្តីព្យាយាមរបស់អ្នកនាំយកសុខអ្វីៗ ឬ កម្ចាត់ទុក្ខឲ្យដល់គេ មិនបានទេ តែថា ការជាប់ជំពាក់ក្នុងសត្វទាំងឡាយដោយការធ្វើមេត្តាជាដើមនេះណា នេះមិនមែនការធ្វើចិត្ត ( ឲ្យដំណើរទៅ ) ត្រង់ឡើយ ។ តែថា ភាពជាកណ្តាលក្នុងសត្វទាំងឡាយទាំងពួងនេះ នេះជាផ្លូវដែលព្រះអរិយៈទាំងឡាយមានព្រះពុទ្ធជាដើមទ្រង់យាងទៅ ជាអបណ្ណកបដិបទា ( បដិបទាដែលមិនខុស ) ដូច្នេះ ព្រះយោគីរមែងធ្វើឧបេក្ខាដែលមានភាពពិសេសឲ្យតាំងឡើងក្នុងបុគ្គលនោះ ភាពជាកណ្តាលក្នុងបុគ្គលនោះ រមែងតាំងឡើងដ៏យ៉ាងល្អក្រៃលែង ព្រោះព្រះយោគីនោះ បដិបត្តិយ៉ាងនោះ មានភាពជាកណ្តាលបានជាប្រក្រតី ។ នីវរណៈទាំងឡាយត្រូវគ្របសង្កត់ទៅ ដោយកម្លាំងរបស់ភាវនានោះឯង , កិលេសទាំងឡាយ ក៏ស្ងប់រម្ងាប់ទៅ ព្រះយោគីនោះ ក៏បង្អោនយកឧបេក្ខានោះទៅក្នុងបុគ្គលដ៏សេស មានបុគ្គលដែលជាទីស្រឡាញ់ជាដើម ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ធ្វើឧបេក្ខាឲ្យកើតឡើងចុះ តអំពីនោះ ទើបផ្សាយឧបេក្ខាទៅក្នុងបុគ្គលដ៏សេស មាន

បុគ្គលដែលជាទីស្រឡាញ់ជាដើម ដូច្នេះ ។

ក្នុងពាក្យថា ឃើញបុគ្គលម្នាក់នេះ **ឯក** សព្ទ ( ដែលប្រែថា ១ ) មានអត្ថថា **ដទៃ** ( ប៉ុនគ្នានឹងឃើញបុគ្គលដទៃ ) ដូចក្នុងប្រយោគថា ( ១ ពួករមែងអះអាងយ៉ាងនេះ ពួកដទៃ រមែងអះអាងយ៉ាងនេះ ) ។ ក្នុងពាក្យនេះសម្រេចជាសង្ខ្យាវិសេស ( ការរាប់ថាជាបុគ្គលម្នាក់ទៀត ) ហើយដោយពាក្យពោលដែលជាឯកវចនៈនោះឯង ព្រោះដូច្នោះ ក្នុងពាក្យនេះ ទើបមានន័យនេះថា ឃើញបុគ្គលដទៃម្នាក់ដូច្នេះ ។ ពាក្យនោះ ទ្រង់បដិសេធកិច្ច ។ ដោយពាក្យថា សឹងជាបុគ្គលដែលគួរពេញចិត្តក៏មិនមែន នេះទ្រង់បដិសេធបុគ្គលដែលជាទីស្រឡាញ់ និងបុគ្គលដែលជាសម្លាញ់ ជាទីស្រឡាញ់ក្រៃលែង ឬសូម្បីតែខ្លួនឯង ព្រោះក្នុងខ្លួនឯង មិនមានភាពជាបុគ្គលដែលមិនគួរពេញចិត្ត ។ ដោយពាក្យថា ជាបុគ្គលដែលមិនគួរពេញចិត្តក៏មិនមែន នេះទ្រង់បដិសេធ បុគ្គលដែលស្អប់ និងបុគ្គលដែលមានពៀរ ជាការដល់នូវការកាន់យកបុគ្គលដែលជាកណ្តាលៗ ព្រោះជាចំណែកដ៏សេស ។ ព្រោះហេតុនោះ ដោយព្រះតម្រាស់ថា ឃើញបុគ្គលម្នាក់ដែលជាបុគ្គលគួរពេញចិត្តក៏មិនមែន ជាបុគ្គលដែលមិនគួរពេញចិត្ត ក៏មិនមែន ដូច្នេះ នេះទ្រង់សម្តែងដល់បុគ្គលដែលគួរព្រងើយ ដោយការដែលត្រាស់បដិសេធព្រះយោគីខ្លួនឯង និងបុគ្គលដែលជាទីស្រឡាញ់ជាដើមជាគន្លង ។

ពាក្យថា **តាមន័យដែលពោលហើយ** គឺតាមន័យដែលពោលហើយក្នុងលំដាប់ដោយពាក្យថា បុគ្គលណាជាកណ្តាលៗ តាមប្រក្រតីសម្រាប់លោក ដូច្នេះជាដើម។ លោកពោលដល់ព្រះយោគី ទុកក្នុងឃ្លាខាងចុងថា ក្នុងបុគ្គលពួកនេះ និងក្នុងខ្លួនឯង ដូច្នេះ ព្រោះព្រះយោគីបង្អោនយកភាពជាកណ្តាលចូលទៅក្នុងខ្លួនឯង បានដោយ

លំបាកជាងបុគ្គលសូម្បីដែលមានពៀរ ព្រោះភាពស្នេហាក្នុងខ្លួនឯង ជាធម្មជាតិមានកម្លាំង ។ ពាក្យថា **តាមន័យដែលពោលហើយក្នុងបឋវីកសិណនោះឯង** គឺតាមន័យដែលពោលហើយ ក្នុងបឋវីកសិណ ដោយពាក្យថា សមាបត្តិនេះ មានបីតិជាសត្រូវជិត ដូច្នេះជាដើម ។ ពាក្យដែលលោកពោលទុកក្នុងខាងដើមថា ចេញអំពីឈានទី ៣ ដែលស្ទាត់ជំនាញដូច្នេះឯណា ពាក្យនោះ លោកពោលទុកដោយទាក់ទងនឹងការសម្តែងទោសក្នុងព្រហ្មវិហារ ៣ ជាន់ក្រោម និង អានិសង្សក្នុងព្រហ្មវិហារទី ៤ ។ ចំណែកពាក្យថា ( ឈានទី ៤ រមែងកើតឡើងតាមន័យដែលបានពោលហើយក្នុងបឋវីកសិណនោះឯង ) នេះជាពាក្យសម្តែងដល់អាការដែលកើតឡើងនៃឈានទី ៤ នៃព្រះយោគីដែលសម្លឹងឃើញទោសក្នុងតតិយជ្ឈាន និង អានិសង្សក្នុងចតុត្ថជ្ឈាន ហើយធ្វើសេចក្តីព្យាយាមដើម្បីការបានសម្រេចនូវចតុត្ថជ្ឈាន ។ ព្រោះដូច្នោះ ក្នុងបណ្តាពាក្យទាំងនោះ ពាក្យដែលលោកពោលទុកហើយ គប្បីប្រកបសេចក្តីដោយពាក្យថា កាត់យកស័ព្ទថា **បឋវី** ចេញទៅមនោទ្វារាវជ្ជនៈរមែងកើតឡើង ធ្វើនិមិត្តនោះឯង ឲ្យជាអារម្មណ៍ដូច្នេះជាដើមចុះ ។

ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) ក្នុងបទថា **បឋវីកសិណាទីសុ** ( ឯក្នុងបឋវីកសិណជាដើម ) សង្គ្រោះយកកសិណដ៏សេស និង និមិត្តនៃខ្យល់ដង្ហើមចេញ-ចូល ។ តតិយជ្ឈានដែលកើតឡើងក្នុងកសិណ និងអានាបានៈ មានភាពជាសភាគៈ ( មានចំណែកដូចគ្នា ) នឹងឧបេក្ខាព្រហ្មវិហារ ដោយភាពជារូបាវចរជ្ឈានផងជាដើម ដូចគ្នាក៏ពិត តែថា សេចក្តីនោះ មិនមែនហេតុដែលនឹងធ្វើឲ្យសម្រេចឈានទី ៤ ក្នុងឧបេក្ខាព្រហ្មវិហារ ក្នុងលំដាប់តអំពីឈានទី ៣ ដែលបានក្នុងបឋវីកសិណជាដើមទេ ព្រោះអារម្មណ៍មិនដូចគ្នា ព្រោះហេតុនោះ លោក

ទើបពោលថា ព្រោះភាពដែលមានអារម្មណ៍ជាវិសភាគៈគ្នាដូច្នេះ ។ សួរថា ការចម្រើនកសិណជាដើម រមែងប្រព្រឹត្តទៅដោយប្រការម្យ៉ាង ការចម្រើនព្រហ្មវិហារក៏ប្រព្រឹត្តទៅដោយប្រការម្យ៉ាងទៀត ព្រោះហេតុនោះ ឈានទាំងឡាយតាមដែលពោលហើយ ក៏មានការមិនដូចគ្នា សូម្បីដោយទាក់ទងនឹងការចម្រើនផង មិនមែនឬ ( មិនមែនទាក់ទងនឹងអារម្មណ៍ប៉ុណ្ណោះឬ ) ? ឆ្លើយថា ប្រការដែលមានមកនេះក៏ជាសេចក្តីពិត តែថា ភាពមិនដូចគ្នា ទាក់ទងនឹងការចម្រើន មិនមែនហេតុដែលពិតប្រាកដនៃការមិនកើតឡើង ( នៃឈានទី ៤ ក្នុងឧបេក្ខាព្រហ្មវិហារទេ ) ។ ពិតហើយ ការចម្រើនមេត្តាជាដើមក៏ប្រព្រឹត្តទៅដោយប្រការមួយ ការចម្រើនឧបេក្ខាក៏ប្រព្រឹត្តទៅដោយប្រការមួយទៀត , សូម្បីយ៉ាងនោះ ឧបេក្ខាដែលជាព្រហ្មវិហាររមែងចាប់អាការ គឺ ភាពជាអ្នកស្វែងរកប្រយោជន៍ឧបការៈជាដើម តាមដែលធ្វើឲ្យប្រព្រឹត្តទៅក្នុងសត្វទាំងឡាយ ( កាលដែលចម្រើនព្រហ្មវិហារ ៣ ខាងដើម ) ដោយការបដិសេធជាមុខ ប្រព្រឹត្តទៅដោយអាការព្រងើយកន្តើយដែលមានសភាវៈបែរត្រឡប់អំពីអាការដែលស្វែងរកប្រយោជន៍ជាដើមនោះ ។ ពិតហើយ លោកពោលថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន សត្វទាំងនោះ នឹងជាអ្នកដល់នូវសុខបាន តាមការពេញចិត្តរបស់កម្ម ដូច្នេះជាដើម ។ សូម្បីការមានអារម្មណ៍ជាសភាគៈគ្នា រមែងមាននៅក្នុងព្រហ្មវិហារទាំងនេះ ព្រោះហេតុនោះ ឧបេក្ខាព្រហ្មវិហារទើបសម្រេចដល់ព្រះយោគីដែលបានឈានទី ៣ ទាក់ទងនឹងមេត្តាជាដើម មកហើយ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ( តែថា នឹងកើតឡើងដល់... ) ក្នុងព្រហ្មវិហារ ៣ ខាងដើម មានមេត្តាជាដើម ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ក្នុងព្រហ្មវិហារ ៣ ខាងដើម មានមេត្តាជាដើម** គឺ ក្នុងព្រហ្មវិហារ ៣ ខាង

ដើម មានមេត្តាជាដើម ដែលព្រះយោគីគប្បីធ្វើឲ្យសម្រេច មានសេចក្តីថា ដោយអំណាចនៃព្រហ្មវិហារ ៣ មានមេត្តាជាដើម ។ ពាក្យដ៏សេសមានន័យដូចបានពោលមកហើយ ក្នុងខាងដើមនោះឯង ។

( ចប់ មហាដីកា )

( ការអធិប្បាយ ឧបេក្ខាព្រហ្មវិហារ ចប់ដោយប្រការដូច្នេះ )

# បកិណ្ណកកថា

បណ្ឌិតបានដឹងព្រហ្មវិហារ ដែលព្រះព្រហ្មឧត្តមាចារ្យ ត្រាស់ទុកទាំងនេះ ដូច្នេះហើយ គប្បីជ្រាបបកិណ្ណកៈកថា ក្នុងព្រហ្មវិហារទាំងឡាយនោះទៀត ខ្លះ ៗ តទៅនេះ ។

# ការវិនិច្ឆ័យ អត្ថ

ក៏ក្នុង **មេត្តា** **ករុណា** **មុទិតា** **ឧបេក្ខា** នេះ បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យដោយអត្ថមុនដូចតទៅនេះ ៖

ធម្មជាតិណា រមែងស្រឡាញ់ ដោយសេចក្តីថា មានជ័រ ព្រោះហេតុនោះ ធម្មជាតិនោះទើបឈ្មោះថា **មេត្តា** ប្រែថា **ធម្មជាតិដែលស្រឡាញ់** ន័យមួយទៀត ធម្មជាតិនោះមាននៅក្នុងមិត្រ ឬថា រមែងប្រព្រឹត្តទៅដល់មិត្រ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា **មេត្តា** ប្រែថា ធម្មជាតិដែលមាននៅក្នុងមិត្ត ។

ធម្មជាតិណា កាលអ្នកដទៃដល់នូវសេចក្តីទុក្ខ រមែងធ្វើការអាណិតអាសូរដល់សាធុជនទាំងឡាយ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា **ករុណា** ប្រែថា ធម្មជាតិដែលធ្វើការអាណិតអាសូរ , ម្យ៉ាងទៀត ធម្មជាតិណា រមែងទិញយក គឺ ច្រឹះយកនូវសេចក្តីទុក្ខរបស់អ្នកដទៃ ដោយន័យថា ធ្វើទុក្ខរបស់អ្នកដទៃឲ្យបាត់ទៅ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា **ករុណា** ប្រែថា ធម្មជាតិដែលទិញយកទុក្ខរបស់អ្នកដទៃ , ន័យម្យ៉ាងទៀត ធម្មជាតិណា ដែលសាធុជនរមែងធ្វើ គឺ លាតចេញ ដោយការផ្សាយទៅ ក្នុងសត្វទាំងឡាយដែលបានទទួលសេចក្តីទុក្ខ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា **ករុណា** ប្រែថា ធម្មជាតិដែលគេធ្វើ

បេញទៅ ។

សាធុជនទាំងឡាយ រមែងរីករាយចំពោះបុគ្គល ដែលដល់ព្រមទៅដោយសម្បត្តិនោះ ដោយធម្មជាតិនោះ ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា **មុទិតា** ប្រែថា ធម្មជាតិដែលជាហេតុរីករាយនៃសាធុជន ,ម្យ៉ាងទៀត ធម្មជាតិនោះ រីករាយក្នុងខ្លួនឯង ព្រោះហេតុនោះ ទើបឈ្មោះថា **មុទិតា** ប្រែថា ធម្មជាតិដែលរីករាយ , ន័យម្យ៉ាងទៀត ពាក្យថា **មុទិតានោះ** បានដល់ កិរិយារីករាយប៉ុណ្ណោះឯង ន័យនេះ **មុទិតា** ប្រែថា ការត្រេកអរ ។

ធម្មជាតិណា **ព្រងើយ** ដោយលះបង់នូវការខ្វះខ្វែងក្នុងការមនសិការ មានមនសិការថា **សព្វេ សត្តា អវេរា ហោន្តុ** ជាដើម ព្រមទាំងចូលដល់នូវការដាក់ចិត្តជាកណ្តាល ព្រោះហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា **ឧបេក្ខា** ប្រែថា ធម្មជាតិ ដែលព្រងើយកន្តើយ ។

## ការវិនិច្ឆ័យ លក្ខណៈ ជាដើម

ចំណែកវិនិច្ឆ័យដោយប្រការដទៃ មានលក្ខណៈជាដើម ក្នុងព្រហ្មវិហារធម៌ ៤ នោះ គប្បីជ្រាបតទៅនេះ ៖

**មេត្តា** មានការប្រព្រឹត្តទៅដោយអាការគិតឧបការៈដល់សត្វទាំងឡាយ ជាលក្ខណៈ , មានការនាំយកប្រយោជន៍ឧបការៈចូលទៅឲ្យជារស គឺជាកិច្ច , មានការនាំសេចក្តីអាឃាតចេញទៅបាន ជាអាការប្រាកដ គឺ ជាផល , មានការសម្លឹងឃើញភាពដែលសត្វទាំងឡាយ ជាទីចម្រើនចិត្តជាហេតុជិត ការរម្ងាប់ទៅនៃព្យាបាទដោយអំណាចវិក្ខម្ភនប្បហាន ជាសម្បត្តិ គឺ ការពាល់ត្រូវនៃមេត្តានោះ ការកើតឡើងនៃ

ស្នេហា គឺ ក្លាយជាសេចក្ដីស្រឡាញ់ដោយតណ្ហា ជាវិបត្តិ គឺ វិបរិតទៅនៃមេត្តានោះ ។

**ករុណា** មានការប្រព្រឹត្តទៅ ដោយអាការគិតដោះទុក្ខរបស់សត្វទាំងឡាយជាលក្ខណៈ , មានការអត់ធន់មិនបានចំពោះសេចក្ដីទុក្ខរបស់អ្នកដទៃជារស , មានការមិនបៀតបៀនសត្វ ជាអាការប្រាកដ , មានការសម្លឹងឃើញភាពដែលសត្វត្រូវទុក្ខគ្របសង្កត់ទាំងឡាយ ជាអ្នកអនាថាគ្មានទីពឹង ជាហេតុជិត ការរម្ងាប់ទៅនៃវិហិង្សាដោយអំណាចនៃវិក្ខម្ភនប្បហាន ជាសម្បត្តិនៃករុណានោះ ការកើតឡើងនៃសេចក្ដីសោក គឺ ក្លាយជាសេចក្ដីសោក ជាវិបរិតនៃករុណានោះ ។

**មុទិតា** មានការរីករាយចិត្តក្នុងសម្បត្តិរបស់អ្នកដទៃជាលក្ខណៈ , មានការមិនច្រណែន ជារស , មានការកម្ចាត់បង់បាននូវការច្រណែនឈ្នានីសក្នុងសម្បត្តិរបស់អ្នកដទៃ ជាអាការប្រាកដ , មានការសម្លឹងឃើញសម្បត្តិនៃសត្វទាំងឡាយជាហេតុជិត ការស្ងប់រម្ងាប់ទៅនៃអរតិដោយអំណាចវិក្ខម្ភនប្បហាន ជាសម្បត្តិនៃមុទិតានោះ ការកើតឡើងនៃការរីករាយ គឺ ក្លាយជារីករាយក្អឹតក្អឹនដោយកិលេស ជាវិបរិតនៃមុទិតានោះ ។

**ឧបេក្ខា** មានការប្រព្រឹត្តទៅដោយអាការជាកណ្ដាលៗ ក្នុងសត្វទាំងឡាយជាលក្ខណៈ , មានការសម្លឹងឃើញភាពស្មើគ្នាក្នុងសត្វទាំងឡាយ ជារស , មានការស្ងប់រម្ងាប់ទៅនូវការប្រទូស្ត និង ការត្រេកអរជាអាការប្រាកដ , មានការឃើញកម្មស្សកតាដែលប្រព្រឹត្តទៅដោយន័យថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន សត្វទាំងនោះនឹងជាអ្នកដល់នូវសេចក្ដីសុខក្ដី និងផុតចាកទុក្ខក្ដី និងមិនវិនាសចាកសម្បត្តិដែលបានទទួលហើយក្ដី តាមការពេញចិត្តរបស់កម្ម ដូច្នេះ ជាហេតុជិត

ការស្ងប់រម្ងាប់ទៅនៃការប្រទូស្ត និងការត្រេកអរដោយអំណាចនៃវិក្ខម្ភនប្បហានជាសម្បត្តិនៃឧបេក្ខានោះ ការកើតឡើងនៃអញ្ញាណុបេក្ខា គឺ ការព្រងើយកន្តើយដោយល្ងង់ ជាគេហសិតៈ គឺ ( ដោយអាស្រ័យកាមគុណ ) ជាវិបត្តិនៃឧបេក្ខានោះ ។

# ប្រយោជន៍របស់ព្រហ្មវិហារ

រីឯវិបស្សនាសុខ ( សេចក្ដីសុខក្នុងវិបស្សនា ) ក្ដី ភពសម្បត្តិ ( ការបានកំណើតក្នុងរូបភព ) ក្ដី ជាប្រយោជន៍ទូទៅ ការកម្ចាត់បដិបក្ខធម៌ មានព្យាបាទជាដើមបាន ជាប្រយោជន៍ចំពោះព្រហ្មវិហារទាំង ៤ នោះ , ពិតណាស់ ក្នុងព្រហ្មវិហារ ៤ នោះ មេត្តាមានការកម្ចាត់ព្យាបាទបានជាប្រយោជន៍ , ៣ ប្រការក្រៅអំពីនេះ មានការកម្ចាត់ វិហិង្សា អរតិ និង រាគៈជាប្រយោជន៍តាមលំដាប់សមដូចពាក្យព្រះសារីបុត្តពោលទុកថា ម្នាលអាវុសោ វត្ថុដែលជាផ្លូវចេញចាកព្យាបាទ គឺ មេត្តាចេតោវិមុត្តិ , វត្ថុដែលជាផ្លូវចេញចាកវិហិង្សា គឺ ករុណាចេតោវិមុត្តិ , វត្ថុដែលជាផ្លូវចេញចាកអរតិ គឺ មុទិតាចេតោវិមុត្តិ , វត្ថុដែលជាផ្លូវចេញចាករាគៈ គឺ ឧបេក្ខាចេតោវិមុត្តិ ដូច្នេះ ។

# សត្រូវជិត និង ឆ្ងាយរបស់ព្រហ្មវិហារ

ម្យ៉ាងទៀត ក្នុងព្រហ្មវិហារ ៣ នោះ ព្រហ្មវិហារ ១ មានសត្រូវពីរ ៗ ដោយជាសត្រូវជិត និងសត្រូវឆ្ងាយដោយពិស្ដារថា រាគៈជាសត្រូវជិតរបស់មេត្តាព្រហ្មវិហារ ព្រោះភាពដែលមេត្តា និងរាគៈ មានចំណែកស្មើគ្នា ដោយសម្លឹងមើលតែចំណែកដែលជាគុណ ដូចសត្រូវរបស់បុគ្គលដែលវាត្រាច់នៅក្បែរៗ វារមែងបាន

ឱកាសដោយងាយ ព្រោះហេតុនោះ មេត្តាព្រះយោគាវចរត្រូវរក្សាឲ្យល្អ ឲ្យឆ្ងាយចាករាគៈ , ចំណែកព្យាបាទជាសត្រូវឆ្ងាយរបស់មេត្តា ព្រោះមេត្តា និងព្យាបាទមានចំណែកដែលជារបស់ខ្លួនមិនដូចគ្នា ដូចសត្រូវរបស់បុគ្គលដែលវាពួននៅ ក្នុងព្រៃជ្រៅ ( ព្រៃក្រាស់ ) មានភ្នំជាដើម ព្រោះដូច្នោះ ព្រះយោគាវចរទើបមិនត្រូវខ្លាចអំពីព្យាបាទនោះឡើយ ចម្រើនមេត្តាទៅចុះ ហើយប្រការដែលថា បុគ្គលនឹងចម្រើនមេត្តាផង ធ្វើអាការក្រោធទៅផង ទុំះជាអឋានៈ គឺ ប្រព្រឹត្តទៅមិនបាន ។

គេហសិតទោមនស្សដែលមកក្នុងបាលីដោយន័យថា កាលបុគ្គលឃើញការមិនបាននូវរូបទាំងឡាយដែលគប្បីដឹងតាមផ្លូវភ្នែក ដែលគួរប្រាថ្នា គួរស្រឡាញ់ គួរបម្រើនចិត្ត គួរមនោរមនៃចិត្ត ប្រកបទៅដោយលោកាមិសៈ ដោយការខូចចិត្តថា មិនបានក្តី កាលរឭកដល់រូបារម្មណ៍បែបនោះ ដែលមិនធ្លាប់បានមកអំពីមុនដែលកន្លងទៅហើយ ដែលរលត់ទៅហើយ ដែលប្រែប្រួលទៅហើយក្តី ទោមនស្សកើតឡើង ទោមនស្សណាមានរូបសភាពយ៉ាងនេះ ទោមនស្សនោះ ហៅថាគេហសិតទោមនស្ស គឺ ការខូចចិត្តអាស្រ័យកាមគុណ ដូច្នេះជាដើម ជាសត្រូវជិតរបស់ករុណាព្រហ្មវិហារ ព្រោះករុណា និងគេហសិតទោមនស្ស មានចំណែកស្មើគ្នា ដោយសម្លឹងមើលតែវិបត្តិ ( ចំណែកខូចខាត ) រីឯវិហេសាជាសត្រូវឆ្ងាយរបស់ករុណា ព្រោះមានសភាព ចំណែកដែលជារបស់ខ្លួនមិនដូចគ្នា ព្រោះហេតុនោះ ព្រះយោគាវចរ ទើបមិនត្រូវខ្លាចអំពីវិហេសានោះ ចម្រើនករុណាទៅចុះ ប្រការដែលថា បុគ្គលនឹងធ្វើសេចក្តីករុណាផង នឹងបៀតបៀនសត្វដោយគ្រឿងប្រហារ មានបាតដៃជាដើមផង ទុំះជាអឋានៈ គឺ ប្រព្រឹត្តទៅមិនបាន ។

គេហសិតសោមនស្សដែលមកក្នុងបាលីដោយន័យថា កាលបុគ្គលឃើញការ

បាននូវរូបទាំងឡាយ ដែលគប្បីដឹងទៅតាមផ្លូវភ្នែក ដែលគួរប្រាថ្នា គួរស្រឡាញ់ គួរបម្រើនចិត្ត គួរមនោរមនៃចិត្ត ប្រកបទៅដោយលោកាមិសៈ ដោយការសប្បាយចិត្តថា បានក្តី កាលរឭកដល់រូបារម្មណ៍បែបនោះ ដែលធ្លាប់បានមកអំពីមុនដែលកន្លងទៅហើយ ដែលរលត់ទៅហើយ ដែលប្រែប្រួលទៅហើយក្តី សោមនស្សកើតឡើង សោមនស្សណាមានរូបសភាពយ៉ាងនេះ សោមនស្សនោះហៅថា **គេហ-សិតសោមនស្ស** ( ការសប្បាយចិត្តអាស្រ័យកាមគុណ ) ដូច្នេះជាដើម ជាសត្រូវជិតរបស់មុទិតាព្រហ្មវិហារ ព្រោះមុទិតា និង គេហសិតសោមនស្សមានចំណែកស្មើគ្នា ដោយសម្លឹងមើលតែសម្បត្តិ គឺ ចំណែកដែលបាន , ចំណែកអរតិជាសត្រូវឆ្ងាយរបស់មុទិតា ព្រោះមានសភាព ចំណែកដែលជារបស់ខ្លួនមិនដូចគ្នា ព្រោះហេតុនោះ ព្រះយោគាវចរទើបមិនត្រូវខ្លាចអំពីអរតិនោះ ចម្រើនមុទិតាទៅចុះ ប្រការដែលថា បុគ្គលនឹងជាអ្នករីករាយចិត្ត ( ក្នុងការបានល្អរបស់អ្នកដទៃ ) ផង និងនឿយណាយក្នុងសេនាសនៈស្ងាត់ ឬក្នុងអធិកុសលទាំងឡាយផង នុ៎ះជាអឋានៈ គឺ ប្រព្រឹត្តទៅមិនបាន ។

ចំណែកគេហសិតអញ្ញាណុបេក្ខា ដែលមកក្នុងបាលីដោយន័យថា ព្រោះឃើញរូបដោយចក្ខុ ឧបេក្ខា ( ការដឹងព្រងើយៗ ) កើតឡើងដល់បុថុជ្ជនល្ងង់ខ្លៅ ដែលជាអ្នកក្រាស់ទៅដោយកិលេស នៅមិនទាន់ជា **ឱធិជិន** ( អ្នកឈ្នះដែន ) មិនជា **វិបាកជិន** ( អ្នកឈ្នះវិបាក ) មិនឃើញទោស ( ក្នុងការវង្វេង ) មិនបានស្តាប់ ( អរិយធម៌ ) ឧបេក្ខាណាមានរូបយ៉ាងនេះ ឧបេក្ខានោះ រមែងមិនកន្លងរូបទៅបាន ព្រោះហេតុនោះ ឧបេក្ខានោះ ទើបហៅថា **គេហសិតា** ( អាស្រ័យកាម ) ដូច្នេះ ជាដើម ជាសត្រូវជិតរបស់ឧបេក្ខាព្រហ្មវិហារ ព្រោះឧបេក្ខា-

ព្រហ្មវិហារ និងគេហសិតអញ្ញាណុបេក្ខា មានចំណែកស្មើគ្នា ដោយមិនពិចារណាទោស និងគុណដូចគ្នា , រាគៈ និងបដិឃៈជាសត្រូវឆ្ងាយរបស់ឧបេក្ខា ព្រោះមានចំណែករបស់ខ្លួនមិនដូចគ្នា ព្រោះហេតុនោះ ព្រះយោគាវចរ ទើបមិនត្រូវខ្លាចរាគៈ និងបដិឃៈឡើយ ចម្រើនឧបេក្ខាទៅចុះ ប្រការដែលថា បុគ្គលនឹងមានឧបេក្ខាផង នឹងត្រេកអរ នឹងប្រទូស្តទៅផង នុ៎ះជាអឋានៈ គឺ ប្រព្រឹត្តទៅមិនបាន ។

## ខាងដើម កណ្តាល ចុង
## អារម្មណ៍ និង ការពង្រីកអារម្មណ៍នៃព្រហ្មវិហារ

ម្យ៉ាងទៀត ព្រហ្មវិហារគ្រប់ប្រការនោះ មានកត្តុកាមតាឆន្ទៈ ( ឆន្ទៈ គឺការប្រាថ្នានឹងធ្វើ ) ជាខាងដើម មានការសង្កត់នីវរណៈបានជាដើម ជាកណ្តាល មានអប្បនា ជាទីបំផុត ដោយអំណាចបញ្ញត្តិធម៌ ចាត់ថាមានឯកសត្វជាអារម្មណ៍ ឬថា ( ដោយសម្មតិធម៌ ) មានអនេកសត្វជាអារម្មណ៍ កាលដល់ឧបចារៈ ឬដល់អប្បនាហើយ ការពង្រីកអារម្មណ៍ទើបមានបាន ។

ការពង្រីកអារម្មណ៍នោះ បណ្ឌិតគប្បីជ្រាបលំដាប់ការពង្រីកដូចតទៅនេះ ដូចជាអ្នកស្រែដែលឈ្លាសកំណត់ទីដែលត្រូវភ្ជួរហើយ ទើបទៅភ្ជួរ យ៉ាងណា ព្រះយោគាវចរក៏ដូច្នោះ ដំបូងនោះឯង គប្បីកំណត់យកផ្ទះ ១ ខ្នង ដោយន័យថា សូមសត្វទាំងឡាយក្នុងផ្ទះនេះ ចូរជាអ្នកមិនមានពៀរចុះ ដូច្នេះជាដើម ធ្វើចិត្តឲ្យទន់ គួរដល់ការងារក្នុងការនាចំពោះផ្ទះមួយខ្នងនោះហើយ ទើបកំណត់ពីរខ្នង តអំពីនោះទើបកំណត់ ៣-៤-៥-៦-៧-៨-៩-១០ ខ្នង ហើយថ្នល់ ១ ខ្សែ កន្លះភូមិ មួយភូមិ ជនបទ ឬខេត្ត១ រាជអាណាចក្រ១ ទិស១ ដោយន័យដូចនេះទៅ រហូតទាំងចក្រវាល

១ ឬថា នឹងគប្បីចម្រើនមេត្តាទៅក្នុងសត្វទាំងឡាយក្នុងទីនោះៗ ក្រៅលែងជាងនោះទៅទៀតក៏បាន ព្រហ្មវិហារដ៏សេស មានករុណាជាដើម ក៏គប្បីចម្រើនតាមន័យដូចគ្នានោះឯង នេះជាលំដាប់នៃការពង្រីកអារម្មណ៍ក្នុងព្រហ្មវិហារភាវនានោះ ។

## ឧបេក្ខាព្រហ្មវិហារ
## ជាលទ្ធផលនៃព្រហ្មវិហារ ៣ ខាងដើម

ម្យ៉ាងទៀត អរូបជាផលនៃកសិណទាំងឡាយ នេវសញ្ញានាសញ្ញាយតនៈជាផលនៃសមាធិទាំងឡាយ ផលសមាបត្តិជាផលនៃវិបស្សនា និរោធសមាបត្តិជាផលនៃសមថវិបស្សនា យ៉ាងណា ឧបេក្ខាព្រហ្មវិហារ ក្នុងព្រហ្មវិហារភាវនានេះ ក៏ជាផលនៃព្រហ្មវិហារ ៣ ខាងដើម ក៏ដូច្នោះ ព្រោះបើថា មិនទាន់លើកសសរ មិនបានលើកធ្នៀន ឬធ្នឹម និងផ្ទោងហើយ ក៏មិនអាចដាក់មេដំបូល និងដៃរណែងក្នុងអាកាសបាន យ៉ាងណា វៀរតតិយជ្ឈានក្នុងព្រហ្មវិហារ ៣ ខាងដើមចេញ ក៏មិនអាចធ្វើឧបេក្ខាចតុត្ថជ្ឈានឲ្យកើតបាន ក៏ដូច្នោះដែរ ។

## ព្រោះហេតុអ្វីទើបហៅថា
## ព្រហ្មវិហារ ព្រោះហេតុអ្វីទើបមាន ៤ ។ល។

ក្នុងទីនេះបញ្ហាគប្បីមានថា ក៏ព្រោះហេតុអ្វី មេត្តា ករុណា មុទិតា ឧបេក្ខានោះ លោកទើបហៅព្រហ្មវិហារប្រការ ១ ព្រោះហេតុអ្វីទើបមាន ៤ ប្រការ អ្វីជាលំដាប់នៃគុណជាតិទាំងនោះប្រការ ១ ហេតុអ្វីក្នុងអភិធម្ម ទើបលោកហៅ អប្បមញ្ញាប្រការ ១ ខ្ញុំព្រះករុណាសូមឆ្លើយដូចតទៅនេះ ៖

ប្រការដំបូងភាពជាព្រហ្មវិហារ ក្នុងគុណជាតិមានមេត្តាជាដើមនោះ គប្បីជ្រាបថា ព្រោះអត្ថថា ជាធម៌ប្រសើរ និងព្រោះជាធម៌មិនមានទោស , ពិតណាស់ ធម៌ទាំងនោះចាត់ថាជាវិហារធម៌ដ៏ប្រសើរ ព្រោះភាវៈដែលជាការបដិបត្តិត្រូវ ក្នុងសត្វទាំងឡាយ ,ម្យ៉ាងទៀត ព្រហ្មទាំងឡាយជាអ្នកមានចិត្តរកទោសមិនបាន យ៉ាងណា ព្រះយោគីទាំងឡាយដែលប្រកបព្រមដោយធម៌ទាំងនោះ ក៏ជាអ្នកមានចិត្តស្មើដូចព្រហ្មពិតយ៉ាងនោះ ព្រោះហេតុនោះ ធម៌ទាំងនោះ លោកទើបហៅថា ព្រហ្មវិហារ ព្រោះអត្ថថា ជាធម៌ប្រសើរប្រការ ១ ព្រោះជាធម៌មិនមានទោសប្រការ ១ ។

ចំណែកពាក្យតទៅនេះ ជាពាក្យដោះស្រាយបញ្ហា ៣ ប្រការទៀត មានប្រការថា ម្យ៉ាងទៀត ព្រោះហេតុអ្វីទើបមាន ៤ ជាដើម ។

**ភាវនាមានមេត្តាជាដើម មាន ៤ ព្រោះអំណាចនៃកិច្ច មានភាពជាផ្លូវនៃវិសុទ្ធិជាដើម ចំណែកលំដាប់នៃភាវនាទាំងនោះ កើតព្រោះអំណាចនៃអាការ មានការគិតឧបការៈជាដើម , ម្យ៉ាងទៀត ព្រោះហេតុដែលភាវនាទាំងនោះប្រព្រឹត្តទៅក្នុងអារម្មណ៍ គឺ សត្វ មិនមានប្រមាណ ទើបឈ្មោះថា អប្បមញ្ញា ។**

ក៏ព្រោះក្នុងភាវនា ៤ ប្រការនោះ **មេត្តា** ជាផ្លូវបរិសុទ្ធនៃបុគ្គលដែលច្រើនទៅដោយព្យាបាទ , **ករុណា** ជាផ្លូវបរិសុទ្ធនៃបុគ្គលដែលច្រើនទៅដោយវិហេសា , **មុទិតា** ជាផ្លូវបរិសុទ្ធនៃបុគ្គលដែលច្រើនទៅដោយអរតិ , **ឧបេក្ខា** ជាផ្លូវបរិសុទ្ធនៃបុគ្គលដែលច្រើនទៅដោយរាគៈ និង ព្រោះហេតុដែលធ្វើមនសិការទៅក្នុងសត្វទាំងឡាយ ក៏មានប្រាកដ ៤ ផ្លូវប៉ុណ្ណោះ ដោយជាអាការគិតរកប្រយោជន៍ឲ្យ គិតបំបាត់វត្ថុដែលមិនមែនប្រយោជន៍ ត្រេកអរក្នុងការបានល្អ និង ការមិនគិតជញ្ជឹងដល់ គឺ ព្រងើយកន្តើយ , ម្យ៉ាងទៀត ព្រោះឧបមាដូចមាតា ក្នុងបុត្រ ៤ នាក់

ដែលម្នាក់ជាទារក ម្នាក់ជាកូនឈឺ ម្នាក់ជាយុវវ័យ និងម្នាក់ចេញចាកផ្ទះទៅប្រកប ការងារផ្ទាល់ខ្លួន រមែងជាអ្នកប្រាថ្នាការចម្រើនជំពាត់ដល់កូនតូច , ប្រាថ្នាបំបាត់ជម្ងឺដល់កូនដែលឈឺ , ប្រាថ្នាភាពស្ថិតស្ថេរនៃសម្បត្តិ ភាពជាកំលោះក្រមុំដល់កូនដែលជាយុវវ័យ , មិនខ្វល់ខ្វាយ មិននិយាយក្នុងផ្លូវណាៗដល់កូនដែលចេញពីផ្ទះទៅប្រកប ការងារផ្ទាល់ខ្លួនហើយ យ៉ាងណា សូម្បីព្រះយោគាវចរ ក៏គប្បីជាបុគ្គលមានអប្បមញ្ញាជាវិហារធម៌ ដោយអំណាចការចម្រើនធម៌ ៤ មានមេត្តាក្នុងសត្វទាំងពួងជាដើមក៏យ៉ាងនោះ ព្រោះហេតុនោះ អប្បមញ្ញាក៏មាន ៤ ព្រោះអំណាចនៃកិច្ច មានភាពជាផ្លូវនៃវិសុទ្ធិជាដើមនេះ ដូចគ្នា ។

ម្យ៉ាងទៀត ព្រោះហេតុដែលព្រះយោគាវចរ ប្រាថ្នានឹងចម្រើនអប្បមញ្ញានោះ គ្រប់ទាំង ៤ , ដំបូង គប្បីបដិបត្តិក្នុងសត្វទាំងអស់ ដោយញ៉ាំងអាការគិតឧបការៈឲ្យប្រព្រឹត្តទៅ ការនាដែលមានការប្រព្រឹត្តទៅនៃអាការគិតឧបការៈ ជាលក្ខណៈ នោះឯងជាមេត្តា , តអំពីនោះ បានជួបក្តី បានឮក្តី ពិចារណាឃើញក្តីនូវភាពដែលសត្វទាំងឡាយ ដែលប្រាថ្នាតែប្រយោជន៍ឧបការៈ យ៉ាងនេះហើយត្រូវទុក្ខគ្របសង្កត់ គប្បីបដិបត្តិដោយញ៉ាំងអាការគិតបំបាត់ទុក្ខ ឲ្យប្រព្រឹត្តទៅ ការនាដែលមានការប្រព្រឹត្តទៅនៃអាការគិតបំបាត់ទុក្ខ ជាលក្ខណៈ នោះឯងជាករុណា , ពេលបានឃើញការបានល្អនៃសត្វទាំងឡាយនោះ ដែលប្រាថ្នាប្រយោជន៍ និង ប្រាថ្នាភាពប្រាសចាកទុក្ខយ៉ាងនោះហើយ គប្បីបដិបត្តិដោយញ៉ាំងចិត្តឲ្យរីករាយត្រេកអរក្នុងការបានល្អរបស់គេ ការនាដែលមានការត្រេកអរ ជាលក្ខណៈ នោះឯងជាមុទិតា , ចំណែកតអំពីនោះ ក៏គប្បីបដិបត្តិដោយអាការជាកណ្តាលពោលគឺ ការព្រងើយកន្តើយ ព្រោះការមិនមានកិច្ចដែលគួរធ្វើការនាដែលមានការ

ប្រព្រឹត្តទៅនៃអាការជាកណ្តាល ជាលក្ខណៈ នោះឯងជាឧបេក្ខា , ព្រោះដូច្នោះ បណ្ឌិតគប្បីជ្រាបថា ក៏ព្រោះអំណាចនៃអាការ មានការគិតឧបការៈជាដើមនេះ លំដាប់នេះ គឺ មេត្តាត្រាស់ជាប្រការដំបូង ហើយករុណា ហើយមុទិតា ហើយ ឧបេក្ខា ទើបជាលំដាប់របស់អប្បមញ្ញា ៤ នោះ ។

ម្យ៉ាងទៀត ព្រោះហេតុដែលមេត្តា ករុណា មុទិតា ឧបេក្ខានោះគ្រប់ប្រការ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍មិនមានប្រមាណ ពិតណាស់ សត្វទាំងឡាយមិនមាន ប្រមាណជាអារម្មណ៍របស់ភាវនាទាំងនោះ ព្រោះសូម្បីសម្រាប់ឯកសត្វ ( សត្វ ១ ) ភាវនាទាំងនោះក៏ប្រព្រឹត្តទៅដោយអំណាចដែលផ្សាយទៅទូទាំងរាងកាយ មិនបាន កាន់យកប្រមាណយ៉ាងនេះថា ភាវនាមានមេត្តាជាដើម និងត្រូវចម្រើនក្នុងទីចំណែក ១ របស់រាងកាយប៉ុណ្ណេះដូច្នេះឯង ព្រោះហេតុនោះ ខ្ញុំព្រះករុណាទើបបានពោលថា

**ភាវនាមានមេត្តាជាដើម មាន ៤ ព្រោះអំណាចនៃកិច្ច មានភាពជាផ្លូវនៃ វិសុទ្ធិជាដើម ចំណែកលំដាប់នៃភាវនាទាំងនោះ កើតព្រោះអំណាចនៃអាការមាន ការគិតឧបការៈជាដើម , ម្យ៉ាងទៀត ព្រោះហេតុដែលភាវនាទាំងនោះ ប្រព្រឹត្តទៅ ក្នុងអារម្មណ៍ មិនមានប្រមាណ ទើបឈ្មោះថា អប្បមញ្ញា ។**

## ព្រហ្មវិហារ ៣ ខាងដើម
## សម្រេចឈានត្រឹមតតិយជ្ឈាន

រីឯ ក្នុងភាវនាទាំងនោះ ទោះបីមានលក្ខណៈតែមួយដូចគ្នា ព្រោះមាន អារម្មណ៍មិនមានប្រមាណ យ៉ាងនេះ , ភាវនា ៣ ខាងដើម ក៏ជា តិកឈានិកា ( ប្រព្រឹត្តទៅត្រឹមឈាន ៣ ក្នុងចតុក្កន័យ ) ឬ ជាចតុក្កឈានិកា ( ប្រព្រឹត្តទៅ

ត្រឹមឈាន ៤ ក្នុងបញ្ចកន័យ ) ប៉ុណ្ណោះ ព្រោះហេតុអ្វី ព្រោះឃ្លាតអំពីសោមនស្សមិនបាន ការព្រាត់អំពីសោមនស្សមិនបាន មានដល់ការនាទាំងនោះ ព្រោះហេតុអ្វី ព្រោះការនាទាំងនោះជាផ្លូវចេញចាកបដិបក្ខធម៌ មានព្យាបាទជាដើម ដែលកើតចាកទោមនស្ស ចំណែកការនាចុងបំផុត ជាអវសេសឯកឈានិកា ( ប្រព្រឹត្តទៅក្នុងឈាន ១ ដ៏សេស គឺ ចតុត្ថជ្ឈានក្នុងចតុក្កន័យ ឬបញ្ចមជ្ឈានក្នុងបញ្ចកន័យ ) ព្រោះហេតុអ្វី ព្រោះប្រកបដោយឧបេក្ខាវេទនា ពិតណាស់ ឧបេក្ខាព្រហ្មវិហារដែលប្រព្រឹត្តទៅដោយអាការជាកណ្តាលក្នុងសត្វទាំងឡាយ វៀរឧបេក្ខាការនាចេញប្រព្រឹត្តទៅមិនបាន ។

ចំណែកបុគ្គលណា គប្បីពោលយ៉ាងនេះ ព្រោះព្រះមានព្រះភាគត្រាស់ទុកក្នុងអដ្ឋកនិបាត ( អង្គុត្តរនិកាយ ) ដោយភាពមិនប្លែកគ្នាក្នុងអប្បមញ្ញាទាំង ៤ ថា ម្នាលភិក្ខុ កាលនោះ អ្នកគប្បីចម្រើនសមាធិនេះ ដែលមានទាំងវិតក្កវិចារៈខ្លះ គប្បីចម្រើនសមាធិនេះ ដែលមិនមានវិតក្កមានតែវិចារៈខ្លះ គប្បីចម្រើនសមាធិនេះ ដែលមិនមានវិតក្កមិនមានវិចារៈខ្លះ គប្បីចម្រើនសមាធិនេះដែលមានបីតិខ្លះ គប្បីចម្រើនសមាធិនេះដែលមិនមានបីតិខ្លះ គប្បីចម្រើនសមាធិនេះដែលប្រកបទៅដោយសេចក្តីសម្រាន្ត ( សុខខ្លះ ) គប្បីចម្រើនសមាធិនេះដែលប្រកបទៅដោយឧបេក្ខាខ្លះ ដូច្នេះ ព្រោះហេតុនោះ អប្បមញ្ញាទាំង ៤ ក៏ជាចតុក្កឈានិកា ( ប្រព្រឹត្តក្នុងឈានទាំង ៤ ក្នុងចតុក្កន័យ ឬ ជាបញ្ចកឈានិកា ប្រព្រឹត្តទៅក្នុងឈានទាំង ៥ ) ក្នុងបញ្ចកន័យប៉ុនៗ គ្នា ។

បុគ្គលនោះជាអ្នកដែលភិក្ខុទាំងឡាយគប្បីពោលថា លោកកុំពោលយ៉ាងនោះ ព្រោះកាលបើដូច្នោះ សូម្បីការនាទាំងឡាយ មានកាយានុបស្សនាជាដើម ក៏គប្បី

ជាចតុក្កឈានិកា ឬ បញ្ចកឈានិកាផងដែរ និង ក្នុងការនាមានវេទនានុបស្សនា ជាដើម សូម្បីតែបឋមជ្ឈានក៏មិនមាន នឹងពោលអ្វី ដល់ទុតិយជ្ឈានជាដើមនោះ ព្រោះហេតុនោះ អ្នកកុំកាន់យកត្រឹមតែស្រមោលរបស់សមាធិតាមព្យញ្ជនៈ ហើយ ពោលបន្ទាច់ព្រះមានព្រះភាគឡើយ ដែលព្រះពុទ្ធវចនៈជាពាក្យជ្រាលជ្រៅ ព្រះពុទ្ធវចនៈលោកគួរចូលទៅរកអាចារ្យ សួរអាចារ្យឲ្យអធិប្បាយហើយ កាន់យកសេចក្តី ឯសេចក្តីតទៅនេះ ជាអត្ថន័យក្នុងព្រះពុទ្ធវចនៈនោះ ន័យថា ព្រះមានព្រះភាគទ្រង់តិះដៀលភិក្ខុមួយអង្គ ដែលជាអ្នកក្រាបទូលសូមព្រះធម៌ទេសនាយ៉ាងនេះថា បពិត្រព្រះមានព្រះភាគដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គដោយសង្ខេបចុះ ខ្ញុំព្រះអង្គបានស្តាប់ធម៌ហើយ នឹងគប្បីជាអ្នកចៀសចេញចាកពួកគណៈទៅ មិនប្រមាទ ធ្វើសេចក្តីព្យាយាមជានិច្ច ម្នាក់ឯង ដូច្នេះថា ក៏យ៉ាងនេះឯង មោឃបុរសពួកខ្លះក្នុងលោកនេះអារាធនាតថាគត ឲ្យសម្តែងធម៌ តែកាលតថាគតសម្តែងធម៌ហើយ ក៏នៅសម្គាល់ឃើញតថាគត ជាអ្នកដែលគេគប្បីជាប់តាមដដែល ដូច្នេះ ព្រោះហេតុដែលភិក្ខុនោះ សូម្បីស្តាប់ធម៌កាលមុនហើយ ក៏នៅតែនៅទីនោះដដែល មិនប្រាថ្នានឹងទៅធ្វើសមណធម៌ តែបើភិក្ខុដល់ព្រមដោយឧបនិស្ស័យនៃព្រះអរហត្ត ព្រោះដូច្នោះ កាលនឹងទ្រង់ទូន្មានគេ ទើបទ្រង់ត្រាស់ទៀតថា ម្នាលភិក្ខុ ព្រោះហេតុនោះ ក្នុងខនេះអ្នកគប្បីសិក្សាយ៉ាងនេះថា ចិត្តរបស់យើងនឹងជាចិត្តតាំងមាំខាងក្នុង ព្រមទាំងធម៌ទាំងឡាយជា បាបអកុសលដែលកើតឡើងហើយ មិនត្រូវជាប់ចិត្តនៅ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះឯង ក៏មើលថែមូលសមាធិ អំណាចដែលបានដល់អាការដែលល្មមជាចិត្តេកគ្គតាដោយអំណាចដែលចិត្តតម្កល់នៅខាងក្នុងខ្លួន ជាការត្រាស់ដល់ភិក្ខុនោះ ព្រះឱវាទនេះ

តអំពីនោះ ដើម្បីនឹងទ្រង់សម្តែងព្រះពុទ្ធបំណងថា ភិក្ខុនោះមិនគួរដល់នូវការពេញចិត្ត ដោយសមាធិត្រឹមប៉ុណ្ណោះហើយ ធ្វើមូលសមាធិនោះ ឲ្យចម្រើនដូចតទៅនេះ ទើបត្រាស់ការចម្រើនសមាធិទៅដោយផ្លូវមេត្តាដល់ភិក្ខុនោះ យ៉ាងនេះថា ម្នាលភិក្ខុ កាលណាចិត្តរបស់អ្នក ជាចិត្តតាំងមាំនៅខាងក្នុង និង ធម៌ទាំងឡាយជាបាប អកុសលដែលកើតឡើងហើយ មិនជាប់ចិត្តនៅ កាលនោះ អ្នកគប្បីសិក្សាយ៉ាងនេះថា មេត្តាចេតោវិមុត្តិនឹងជាភាវនា ដែលយើងចម្រើន ធ្វើឲ្យច្រើន ធ្វើឲ្យដូចជាយាន ធ្វើឲ្យដូចជារបស់ប្រើ សាងសន្សំ ធ្វើឲ្យសម្រេចយ៉ាងល្អ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះឯង ដូច្នេះហើយ ទើបត្រាស់តទៅទៀតថា ម្នាលភិក្ខុ កាលណាមូលសមាធិនេះ ជាធម៌អ្នកចម្រើន ធ្វើឲ្យច្រើន យ៉ាងនេះហើយ កាលនោះ អ្នកគប្បីចម្រើនសមាធិនេះ ដែលមានទាំងវិតក្ក មានទាំងវិចារៈខ្លះ ។ ល ។ គប្បីចម្រើនសមាធិនេះ ដែលប្រកបទៅដោយឧបេក្ខាខ្លះ ។

អត្ថន័យនៃព្រះឱវាទនោះថា ម្នាលភិក្ខុ កាលណាមូលសមាធិនេះ ជាធម៌ដែលអ្នកចម្រើនដោយផ្លូវមេត្តាយ៉ាងនោះហើយ កាលនោះ អ្នកកុំពេញចិត្តដោយសមាធិតែត្រឹមនោះ កាលនឹងញុំាងមូលសមាធិឲ្យសម្រេចដល់ចតុក្កជ្ឈាន ឬបញ្ចកឈានក្នុងអារម្មណ៍ដទៃៗតទៅ គប្បីចម្រើនសមាធិនេះដោយន័យថា ***សវិតក្កម្បិ សវិចារំ***-សមាធិមានទាំងវិតក្កមានទាំងវិចារៈខ្លះជាដើម , ម្យ៉ាងទៀត កាលត្រាស់យ៉ាងនេះហើយ និង ទ្រង់សម្តែងសេចក្តីថា ភិក្ខុគប្បីធ្វើការចម្រើនសមាធិសូម្បីដែលមានព្រហ្មវិហារដ៏សេស មានករុណាជាដើមជាតួនាំ ដោយឲ្យដល់ចតុក្កជ្ឈាន ឬបញ្ចកឈានក្នុងអារម្មណ៍ដទៃៗផង ទើបត្រាស់ដល់ភិក្ខុនោះតទៅទៀតថា ម្នាលភិក្ខុ កាលណាសមាធិនេះជាធម៌ ដែលអ្នកចម្រើនធ្វើឲ្យច្រើនយ៉ាងនេះហើយ កាលនោះ អ្នក

គប្បីសិក្សាយ៉ាងនេះថា  ករុណាចេតោវិមុត្តិ  នឹងជាការនាដែលយើងចម្រើនធ្វើឲ្យច្រើន... ដូច្នេះ ជាដើម  កាលទ្រង់សម្តែងការចម្រើនចតុក្កឈាន  ឬបញ្ចកឈានដែលមានព្រហ្មវិហារ  ៤  មានមេត្តាជាដើម  ជាតួនាំយ៉ាងនេះហើយ  ទ្រង់សម្តែងសមាធិដែលមានអនុបស្សនា ៤ មានកាយានុបស្សនាជាដើម ជាតួនាំ ទើបត្រាស់តទៅទៀតថា ម្នាលភិក្ខុ កាលណាសមាធិនេះ ជាធម៌ដែលអ្នកចម្រើន ធ្វើឲ្យច្រើនយ៉ាងនេះហើយ  កាលនោះ អ្នកគប្បីសិក្សាយ៉ាងនេះថា យើងនឹងជាអ្នកពិចារណាឃើញកាយក្នុងកាយដូច្នេះជាដើមហើយ  ទើបទ្រង់ញ៉ាំងភិក្ខុនោះឲ្យកាន់យកព្រះធម៌ទេសនាដោយកំពូល  គឺ  ព្រះអរហត្តថា  ម្នាលភិក្ខុ  កាលណាសមាធិនេះ  អ្នកចម្រើនធ្វើឲ្យល្អហើយយ៉ាងនេះ    កាលនោះអ្នកនឹងដើរទៅកាន់ផ្លូវណាក្តី    អ្នកនឹងដើរជាសុខពិត  អ្នកនឹងឈរនៅទីណាៗក្តី  អ្នកនឹងឈរជាសុខ  អ្នកនឹងអង្គុយក្នុងទីណាៗក្តី  អ្នកនឹងអង្គុយជាសុខ  អ្នកនឹងសម្រេចការដេកក្នុងទីណាៗក្តី  អ្នកក៏នឹងសម្រេចការដេកជាសុខដូច្នេះ ។

ព្រោះហេតុនោះ  អប្បមញ្ញា  ៣  មានមេត្តាជាដើម  បណ្ឌិតជ្រាបថា  ជាតិកឈានិកា  ឬចតុក្កឈានិកា  គឺ  ប្រព្រឹត្តទៅក្នុងឈាន ៣ ខាងដើម  ក្នុងចតុក្កន័យ  ឬប្រព្រឹត្តទៅក្នុងឈាន  ៤  ខាងដើមក្នុងបញ្ចកន័យប៉ុណ្ណោះ  ចំណែកឧបេក្ខា  ក៏គប្បីជ្រាបថា   ជាអវសេសឯកឈានិកា   (  ប្រព្រឹត្តទៅក្នុងឈាន   ១  ដ៏សេស   គឺចតុត្ថជ្ឈាន  ក្នុងចតុក្កន័យ  ឬបញ្ចមជ្ឈាន  ក្នុងបញ្ចកន័យ ) ប៉ុណ្ណោះ  និងក្នុងអភិធម្មលោកក៏ចែកទុកយ៉ាងនេះដូចគ្នា ។

# អប្បមញ្ញា មានអានុភាពផ្សេងគ្នា

បណ្ឌិតគប្បីជ្រាបថា អប្បមញ្ញា ៤ នោះ សូម្បីតាំងទុកជា ២ ចំណែក ជាតិកឈាន ឬ ចតុក្កឈានចំណែក ១ ជាអវសេសឯកឈានចំណែក ១ ដូចពោលមកនេះហើយក្តី គង់មានអានុភាពវិសេសមិនដូចគ្នា ដោយការៈមានភាពជាសុភបរមា ( មានសុភវិមោក្ខយ៉ាងក្រៃលែង ) ជាដើម ពិតណាស់ ក្នុងហលិទ្ទវសនសូត្រ អប្បមញ្ញាទាំងនោះ ព្រះមានព្រះភាគត្រាស់ទុកប្លែកគ្នាដោយការៈ មានភាពជាសុភបរមាជាដើម ត្រាស់ទុកដូចម្តេច ត្រាស់ទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលមេត្តាចេតោវិមុត្តិថា មានសុភវិមោក្ខដ៏យ៉ាងក្រៃលែង ពោលករុណាចេតោវិមុត្តិថា មានអាកាសានញ្ចាយតនវិមោក្ខ ដ៏យ៉ាងក្រៃលែង ពោលមុទិតាចេតោវិមុត្តិថា មានវិញ្ញាណញ្ចាយតនវិមោក្ខដ៏យ៉ាងក្រៃលែង ពោលឧបេក្ខាចេតោវិមុត្តិថា មានអាកិញ្ចញ្ញាយតនវិមោក្ខដ៏យ៉ាងក្រៃលែងដូច្នេះ ។ សួរថា ព្រោះហេតុអ្វី អប្បមញ្ញាទាំងនោះព្រះមានព្រះភាគទើបត្រាស់ថា យ៉ាងនោះ ? ឆ្លើយថា ព្រោះអប្បមញ្ញាទាំងនោះ ជាឧបនិស្ស័យនៃវិមោក្ខនោះៗ , ពិតណាស់ សត្វទាំងឡាយ រមែងជាវត្ថុមិនបដិកូល មិនគប្បីខ្ពើមសម្រាប់ព្រះយោគាវចរ ដែលជាមេត្តាវិហារី ពេលនោះ ព្រោះសេពក្នុងវត្ថុមិនបដិកូល កាលព្រះយោគាវចរមេត្តាវិហារីនោះ ធ្វើចិត្តចូលក្នុងវណ្ណកសិណទាំងឡាយ មាននីលកសិណជាដើម ដែលជាពណ៌បរិសុទ្ធមិនបដិកូល , ចិត្តរបស់លោក រមែងស្ទុះទៅក្នុងវណ្ណកសិណនោះ ដោយមិនលំបាកឡើយ មេត្តាជាឧបនិស្ស័យនៃ សុភវិមោក្ខដោយន័យដូចពោលនេះ មិនជាឧបនិស្ស័យនៃវិមោក្ខក្រៃលែងជាងសុភវិមោក្ខនោះទេ ព្រោះហេតុនោះ មេត្តានោះទើបត្រាស់ថា ជាសុភបរមា ( មានសុភវិមោក្ខដ៏យ៉ាងក្រៃលែង ) ។

សម្រាប់ព្រះយោគាវចរដែលជាករុណាវិហារី ជាអ្នកសម្លឹងឃើញសេចក្តីទុក្ខរបស់សត្វដែលមានរូបរាងកាយជាហេតុឲ្យត្រូវវាយដោយដំបង ទោសក្នុងរូបរាងកាយក៏មានការដឹងច្បាស់ ទាំងដែលមានការប្រព្រឹត្តទៅនៃករុណា ពេលនោះ ព្រោះការដឹងទោសក្នុងរូបច្បាស់ កាលលោកបើកកសិណឯណាមួយ ក្នុងបណ្តាកសិណមានបឋវីកសិណជាដើម វៀរអាកាសកសិណ ហើយនាំចិត្តចូលក្នុងអាកាសដែលជារូបនិស្សរណៈ ( ដែលចេញចាករូប គឺ ទទេចាករូប ) ចិត្តរបស់លោក រមែងស្ទុះទៅក្នុងអាកាសនោះដោយមិនលំបាកឡើយ ករុណាជាឧបនិស្ស័យនៃអាកាសានញ្ចាយតនវិមោក្ខដោយន័យដូចពោលមកនេះ មិនជាឧបនិស្ស័យនៃវិមោក្ខក្រៃលែងជាងនោះទេ ព្រោះហេតុនោះ ករុណានោះ ទើបត្រាស់ថា ជាអាកាសានញ្ចាយតនបរមា ( មានអាកាសានញ្ចាយតនវិមោក្ខ ដ៏ក្រៃលែង ) ។

ចំណែកចិត្តរបស់ព្រះយោគាវចរមុទិតាវិហារី អ្នកពិចារណាឃើញវិញ្ញាណ ( ចិត្ត ) របស់សត្វដែលកើតសេចក្តីរីករាយចិត្ត ដោយហេតុនៃការរីករាយនោះៗ រមែងជាចិត្តគិតគ្នេរក្នុងការប្រកាន់វិញ្ញាណ ទាំងដែលមានការប្រព្រឹត្តទៅនៃមុទិតា ពេលនោះ កាលលោកឈានកន្លងអាកាសានញ្ចាយតនៈដែលបានសម្រេចដោយលំដាប់ហើយ នាំចិត្តចូលក្នុងវិញ្ញាណដែលនៅមាននិមិត្ត គឺ អាកាសជាអារម្មណ៍ចិត្តរបស់លោករមែងស្ទុះទៅក្នុងវិញ្ញាណនោះ ដោយមិនលំបាកឡើយ មុទិតាជាឧបនិស្ស័យនៃវិញ្ញាណញ្ចាយតនវិមោក្ខដោយន័យដូចពោលនេះ មិនជាឧបនិស្ស័យនៃវិមោក្ខក្រៃលែងជាងនោះទេ ព្រោះហេតុនោះ មុទិតានោះ ទើបត្រាស់ថា ជាវិញ្ញាណញ្ចាយតនបរមា ( មានវិញ្ញាណញ្ចាយតនវិមោក្ខដ៏យ៉ាងក្រៃលែង ) ។

ចំណែកចិត្តរបស់ព្រះយោគាវចរឧបេក្ខាវិហារី ជាចិត្តលំបាកនឹងកាន់យកវត្ថុ

ដែលមិនមាន ព្រោះភាពដែលជាអ្នកព្រងើយកន្តើយចំពោះការកាន់យកប្រយោជន៍អ្នកដទៃ មានសេចក្តីសុខសេចក្តីទុក្ខជាដើម ព្រោះមិនមានការជញ្ជឹងថា សូមសត្វទាំងឡាយ ចូរជាអ្នកដល់នូវសេចក្តីសុខចុះ ឬថា សូមសត្វទាំងឡាយចូរផុតចាកទុក្ខចុះ ឬថា សូមសត្វទាំងឡាយកុំបានព្រាត់ប្រាសចាកសេចក្តីសុខដែលដល់ព្រមហើយឡើយ ដូច្នេះក្តី ពេលនោះ កាលលោកដែលមានចិត្តគិតគ្នេរក្នុងការព្រងើយកន្តើយចំពោះការកាន់យកប្រយោជន៍អ្នកដទៃ នឹងមានចិត្តលំបាកដែលត្រូវកាន់យកវត្ថុមិនមានដោយបរមត្ថ ឈានកន្លងវិញ្ញាណញ្ចាយតនៈ ដែលបានសម្រេចដោយលំដាប់ហើយ នាំចិត្តចូលទៅក្នុងវត្ថុដែលមិនមានដោយសភាវៈ គឺ ក្នុងការមិនមាននៃវិញ្ញាណដែលជាបរមត្ថ ចិត្តរបស់លោក រមែងស្ទុះទៅក្នុងការមិនមាននៃវិញ្ញាណនោះ ដោយមិនលំបាកឡើយ ឧបេក្ខាជាឧបនិស្ស័យនៃអាកិញ្ចញ្ញាយតនៈ-វិមោក្ខដោយន័យដូចពោលមកនេះ មិនជាឧបនិស្ស័យនៃវិមោក្ខក្រៃលែងជាងនោះ ព្រោះហេតុនោះ ឧបេក្ខានោះ ទើបត្រាស់ថា ជាអាកិញ្ចញ្ញាយតនបរមា ( មានអាកិញ្ចញ្ញាយតនវិមោក្ខ ដ៏យ៉ាងក្រៃលែង ) ។

## អប្បមញ្ញា
## ធ្វើកល្យាណធម៌ឱ្យបរិបូណ៌

បណ្ឌិតបានជ្រាបអានុភាពរបស់អប្បមញ្ញាទាំងនោះ ដោយភាពជាសុភបរមាជាដើមយ៉ាងនេះហើយ គួរជ្រាបតទៅទៀតថា អប្បមញ្ញាទាំងនោះជាភាវនាដែលធ្វើកល្យាណធម៌ទាំងមូល មានទានជាដើមឲ្យបរិបូណ៌ ពិតណាស់ ព្រះមហាសត្វទាំងឡាយដែលមានចិត្តប្រព្រឹត្តទៅស្មើល្អ ដោយភាពជាអ្នកមានអជ្ឈាស្រ័យក្នុងការ

ការធ្វើប្រយោជន៍ អនុគ្រោះក្នុងសត្វទាំងឡាយ ដោយភាពដែលអត់ធន់មិនបាន ចំពោះសេចក្ដីទុក្ខរបស់សត្វទាំងឡាយ ដោយភាពជាអ្នកប្រាថ្នាការតាំងនៅយឺនយូរនៃសម្បត្តិផ្សេងៗរបស់សត្វ និង ដោយការមិនបែងចែកជាបក្ខពួកក្នុងសត្វទាំងពួង ទ្រង់បំពេញបារមី ទាំងឡាយដោយអាការយ៉ាងនេះ គឺ ៖

១- ទ្រង់ឲ្យទានដែលជាហេតុនៃសេចក្ដីសុខដល់សត្វទូទៅ ទ្រង់មិនធ្វើការបែងចែកថា គួរឲ្យដល់អ្នកនេះ មិនគួរឲ្យដល់អ្នកនេះ ។

២- ទ្រង់វៀរការប្រទូស្តគេ មិនបែងចែកថា គួរប្រទូស្តបុគ្គលនេះ មិនគួរប្រទូស្តបុគ្គលនេះ សមាទានសីលដែលជាហេតុនៃសេចក្ដីសុខដល់សត្វគ្រប់គ្នា ។

៣- ទ្រង់សេពនេក្ខម្មៈ ដែលជាហេតុនៃសេចក្ដីសុខដល់សត្វគ្រប់គ្នា មិនបែងចែក ដើម្បីទ្រង់បំពេញសីលឲ្យបរិបូណ៌ ។

៤- ទ្រង់ជម្រះបញ្ញាឲ្យផូរផង់ ដើម្បីប្រយោជន៍ដល់ការមិនវង្វេងក្នុងវត្ថុដែលជាប្រយោជន៍ និងមិនមែនប្រយោជន៍របស់សត្វទាំងឡាយ គ្រប់មុខ មិនបែងចែក។

៥- ទ្រង់ធ្វើសេចក្ដីព្យាយាមជានិច្ច ដើម្បីប្រយោជន៍សុខដល់សត្វទាំងឡាយ គ្រប់មុខ មិនបែងចែក ។

៦- មួយ៉ាងទៀតសូម្បីទ្រង់ដល់នូវភាពជាវីរបុរស ដោយអំណាចនៃសេចក្ដីព្យាយាមដ៏កំពូល ក៏ទ្រង់នៅអត់ទោសមានប្រការផ្សេងៗ ឲ្យដល់សត្វទាំងឡាយ គ្រប់មុខ មិនបែងចែក ។

៧- ទ្រង់មិនញុំាងបដិញ្ញាដែលធ្វើទុកថា ខ្ញុំនឹងឲ្យវត្ថុនេះដល់លោក នឹងធ្វើវត្ថុនេះដល់លោក ដូច្នេះឲ្យឃ្លាតទៅ ។

៨- ទ្រង់ជាអ្នកមានការតាំងចិត្តមាំ មិនញាប់ញ័រ ដើម្បីប្រយោជន៍សុខរបស់

សត្វទាំងនោះ គ្រប់សត្វមិនបែងចែក ។

៩- ទ្រង់ជាបុព្វការី ក្នុងសត្វទាំងនោះ ដោយព្រះមេត្តាដែលមិនញាប់ញ័រ ។

១០- តែទ្រង់មិនសង្ឃឹមការតបស្នងដោយព្រះឧបេក្ខាដូច្នេះ រហូតដល់ទ្រង់ធ្វើកល្យាណធម៌គ្រប់យ៉ាង មានប្រការផ្សេងៗ គឺ ពលញ្ញាណ ១០ វេសារជ្ជញ្ញាណ ៤ អសាធារណញ្ញាណ ៦ ពុទ្ធធម៌ ១៨ ឲ្យបរិបូណ៌ , អប្បមញ្ញាទោះជាការនាដែលធ្វើកល្យាណធម៌ទាំងពួង មានទានជាដើម ឲ្យបរិបូណ៌យ៉ាងនេះឯង ។

## មហាដីកា

## អធិប្បាយ បកិណ្ណកកថា

ក្នុងពាក្យថា ដែលទ្រង់ជាព្រហ្មដ៏ឧត្តមនេះ ឈ្មោះថា ព្រហ្មមាន ៣ ជំពូក គឺ សម្មតិព្រហ្ម ឧបបត្តិព្រហ្ម វិសុទ្ធិព្រហ្ម ។ ពិតណាស់ ដោយស័ព្ទថា **ព្រហ្ម** ក្នុងប្រយោគមានអាទិយ៉ាងនេះថា ៖

***បពិត្រកោសេយ្យ សេកទាំងឡាយ បរិភោគស្រូវសាលីដ៏សម្បូរ បពិត្រលោកដ៏ជាព្រហ្ម ខ្ញុំដឹងថា ជាសេកទាំងនោះ លោកមិនអាចនឹងការពារសេក ទាំងនោះបាន បពិត្រព្រះអង្គដ៏ទ្រង់ជាព្រហ្ម ធំក្រៃលែង ព្រោះព្រះអង្គទ្រង់បណ្តេញចេញ សត្វដទៃក៏រមែងក្តៅក្រហាយផង ។***

ដូច្នេះជាដើម ជាការពោលដល់សម្មតិព្រហ្ម ( ព្រហ្មដោយសន្មត បានដល់ក្សត្រ ឬ ព្រះរាជា ) ។ ពិតណាស់ ដោយស័ព្ទថា **ព្រហ្ម** ក្នុងប្រយោគមានអាទិ៍យ៉ាងនេះថា ៖

**តថាគត បានបើកទ្វារអមតនិព្វានទុក សម្រាប់សត្វទាំងឡាយបញ្ចេញនូវសទ្ធា ( ការជឿរបស់ខ្លួន ) ម្នាលអ្នកដ៏ជាព្រហ្ម តថាគតមានសេចក្តីសម្គាល់ថាលំបាក ទើបមិនសម្តែងធម៌ដ៏ប្រណីត ដែលតថាគតស្ទាត់ជំនាញហើយ ក្នុងពពួកមនុស្សទាំងឡាយ ។**

និងថា កាលនោះឯង សហម្បតីព្រហ្មដូច្នេះជាដើម ជាការពោលដល់ឧបបត្តិព្រហ្ម ( ព្រហ្មដោយឧប្បត្តិ ) ។ អរិយធម៌ ក៏ហៅថា **ព្រហ្ម** ដោយពាក្យពោលដែលថា ទ្រង់ធ្វើព្រហ្មចក្រឲ្យប្រព្រឹត្តទៅដូច្នេះជាដើម ព្រះអរិយបុគ្គលសូម្បីគ្រប់អង្គ ឈ្មោះថា វិសុទ្ធិព្រហ្មដោយមិនប្លែកគ្នា ដោយភាពជាបរមត្ថព្រហ្ម ព្រោះភាពដែលកើតឡើងពីអរិយធម៌នោះ ។ តែដោយវិសេស ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ព្រះនាមថា ឧត្តមព្រហ្ម ដោយព្រះតម្រាស់ដែលថា **ម្នាលភិក្ខុទាំងឡាយ ពាក្យថាព្រហ្មនេះ ជាឈ្មោះរបស់តថាគតដូច្នេះជាដើម** ព្រោះទ្រង់សម្រេចព្រះបារមីដ៏ឧត្តមដោយគុណ ទាំងឡាយដែលជាព្រហ្ម របស់ប្រសើរក្នុងលោក ព្រមទាំងទេវតា ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **ព្រហ្មុត្តម** ព្រោះអត្ថថា ទ្រង់ជាបុគ្គលឧត្តមក្នុងបណ្តាព្រហ្មទាំងឡាយ ឬ ទ្រង់ជាព្រហ្មឧត្តមតាមប្រការដែលពោលនេះ ។ សេចក្តីថា នូវព្រហ្មវិហារដែលព្រះអង្គជាព្រហ្មដ៏ឧត្តមនោះ ត្រាស់ទុក គឺ ទ្រង់សម្តែងទុកដល់វេនេយ្យសត្វទាំងឡាយក្នុងសូត្រនោះ ដោយពាក្យថា គេរមែងផ្សាយទៅកាន់ទិស ១ ដោយចិត្តដែលសហគតៈដោយមេត្តា ដូច្នេះជាដើម ។ ស័ព្ទថា **ឥតិ** មានសេចក្តីថា កាលជ្រាប គឺ កាលដឹងនូវព្រហ្មវិហារដោយលំដាប់នៃភាវនា និងដោយលំដាប់នៃពាក្យពណ៌នាអត្ថយ៉ាងនេះហើយ គឺតាមដែលពោលហើយ ។ ពាក្យថា **ក៏គប្បីជ្រាប បកិណ្ណកកថា** គឺគប្បីជ្រាបបកិណ្ណកកថាដែលខ្ញុំព្រះករុណា ( ព្រះ

ពុទ្ធឃោសាចារ្យ ) មិនកាន់យកអត្ថាធិប្បាយដែលមិនសាធារណៈ គឺ ប្រចាំចំពោះព្រហ្មវិហារនោះប៉ុណ្ណោះ ដូចជាក្នុងវគ្គដំបូង កាន់យកអត្ថាធិប្បាយដែលជាបកិណ្ណកៈ គឺ ពង្រីកទៅបានក្នុងព្រហ្មវិហារនោះៗ ដោយភាពជាអត្ថាធិប្បាយសាធារណៈហើយ ប្រកាសទុក ។

បទថា **មេជ្ជតិ** ( ស្រឡាញ់ ) លោកសម្ដែងខែទុកធ្វើតួធម្មៈនោះឯង ឲ្យជាកត្តុ ( អ្នកធ្វើ ) ដើម្បីហាមកត្តុ អ្នកធ្វើដទៃអំពីធម្មៈ ។ ក្នុងបទថា **សិនិយ្ហតិ** ( ស្នេហា ) នេះ គប្បីឃើញថា ជាសេចក្ដីស្នេហាទាក់ទងនឹងការប្រព្រឹត្តទៅដោយអាការដែលឧបការៈ មានញាណចេញមុខ ជាបដិបក្ខចំពោះការសៅហ្មង ដោយអំណាចការព្យាបាទក្នុងសត្វទាំងឡាយ មិនមែនជាសេចក្ដីស្នេហាដោយអំណាចការប្រព្រឹត្តទៅនៃតណ្ហា ។ សេចក្ដីស្នេហាដោយអំណាចការប្រព្រឹត្តទៅនៃតណ្ហានោះ មានមោហៈជាប្រធាន មានការចង់បានជាសភាវៈ តែសេចក្ដីស្នេហានេះមានការមិនប្រទូស្ដ ជាសភាវៈសម្បយុត្តនឹងអលោភៈ ។ សួរថា សូម្បីសេចក្ដីស្នេហា គឺ តណ្ហា ក៏ជាសត្រូវរបស់ព្យាបាទ ព្រោះមិនមានការតាំងចុះព្រមគ្នានឹងព្យាបាទនោះទេ ( គឺ មិនតាំងនៅក្នុងចិត្តដួងជាមួយគ្នានឹងព្យាបាទ ) មិនមែនឬ ? ឆ្លើយថា សេចក្ដីស្នេហា គឺ តណ្ហាមិនប្រព្រឹត្តទៅក្នុងចិត្តដួង ១ ជាមួយនឹងព្យាបាទនោះក៏ពិត សូម្បីយ៉ាងនោះ ក៏មិនឈ្មោះថា ជាសត្រូវ ( របស់ព្យាបាទ ) ព្រោះមិនមែនជាអ្នកលះ ។ ឈ្មោះថា **មិត្រ** ក៏ព្រោះអត្ថថា ស្រឡាញ់ បានដល់ ការបន្តនៃខន្ធ ដែលមានអជ្ឈាស្រ័យក្នុងប្រយោជន៍ឧបការៈ , គប្បីជ្រាបថា ធម្មជាតិនេះ ឈ្មោះថា មានក្នុងចិត្ត ក៏ព្រោះភាពដែលទាក់ទងនៅក្នុងការបន្តនៃខន្ធ ដែលមានអជ្ឈាស្រ័យក្នុងប្រយោជន៍ឧបការៈនោះ ឬបានដល់ មានក្នុងមិត្រ គឺ ក្នុងបុគ្គលជាទីស្រឡាញ់ ជា

អារម្មណ៍ , ឈ្មោះថា ការប្រព្រឹត្តទៅរបស់បុគ្គលជាមិត្រនេះ ក៏ដោយទាក់ទងនឹងសេចក្តីស្រឡាញ់នោះឯង ។

ឈ្មោះថា **ករុណា** ព្រោះអត្ថថា ធ្វើ លោកអាចារ្យធ្វើពាក្យសាកសួរទុកក្នុងចិត្តថា ធ្វើអ្វី នរណាធ្វើ ព្រោះហេតុអ្វី ដូច្នេះហើយ ទើបពោលថា កាលទុក្ខរបស់អ្នកដទៃមានហើយ ក៏ធ្វើការរំជួលចិត្តដល់សាធុជនដូច្នេះ ។ ការកើតដោយប្រការដទៃនៃចិត្ត ដោយអាការដែលអត់ធន់មិនបាន នៃបុគ្គលដែលឃើញទុក្ខរបស់អ្នកដទៃ ហើយក៏ប្រាថ្នានឹងកម្ចាត់ទុក្ខនោះ ឈ្មោះថា ការធ្វើឲ្យញាប់ញ័រចិត្ត ។ ភាវៈនេះនោះ រមែងមានដល់បុគ្គលដែលជាសប្បុរសប៉ុណ្ណោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ដល់សាធុជនដូច្នេះ ។ ពិតណាស់ បុគ្គលជាសប្បុរសទាំងឡាយ លោកហៅថា សាធុជន ព្រោះការដែលធ្វើប្រយោជន៍ឧបការៈរបស់ខ្លួននិងរបស់អ្នកដទៃឲ្យសម្រេច ។ ពាក្យថា **ធ្វើឲ្យវិនាសទៅ** គឺធ្វើឲ្យដល់នូវភាពមិនប្រាកដ សេចក្តីថា កម្ចាត់ចេញទៅ ។ ពាក្យថា **ធ្វើឲ្យវិនាសទៅនោះ** ក្នុងទីនេះ លោកសម្តែងថា ការកម្ចាត់ គឺការកម្ចាត់ចេញទៅ ។ ពិតណាស់ ករុណា មានការប្រព្រឹត្តទៅដោយអាការដែលកម្ចាត់ចេញទៅ នូវទុក្ខរបស់អ្នកដទៃជាលក្ខណៈ ។ ពាក្យថា **ដោយទាក់ទងនឹងការផ្សាយទៅ** គឺ ទាក់ទងដោយការប៉ះខ្ទប់ សេចក្តីថា ទាក់ទងដោយការធ្វើឲ្យជាអារម្មណ៍ ។ ការធ្វើឲ្យជាអារម្មណ៍ក្នុងទីនេះ គប្បីជ្រាបថា ប្រព្រឹត្តទៅដោយអាការដែលកម្ចាត់ចេញទៅ នូវទុក្ខក្នុងសត្វទាំងឡាយ ដែលដល់នូវទុក្ខនោះឯង ។

ពាក្យថា **រមែងត្រេកអរ ព្រោះធម្មជាតិនោះ** ជាពាក្យសម្តែងអធិប្បាយសេចក្តីជាករណៈ ( ហេតុករណៈ ) នៃមុទិតាដែលមានកិរិយាត្រេកអរ ក៏ពាក្យសម្តែង

អធិប្បាយដែលសម្រេច ជាឧបការៈដោយវោហារនេះនោះ ដែលផុតទៅអំពីមុទិតាមិនមាន លោកសម្ដែងអធិប្បាយមុទិតានោះៗ ឯង ដោយភាពជាកត្តុ ( អ្នកធ្វើ ) ថា ក្នុងការធ្វើការត្រេកអរនោះ មានធម៌ខ្លះជាអ្នកធ្វើវចនត្ថៈ ( អត្ថរបស់ពាក្យ ) សូម្បីដែលថា ម្យ៉ាងទៀត ធម្មជាតិ ឈ្មោះថា **មុទិតា** ព្រោះអត្ថថា ត្រេកអរឯងនេះក៏ជាពាក្យសម្ដែង ជាឧបចារវោហារប៉ុណ្ណោះ ព្រោះធម៌ទាំងឡាយមិនប្រព្រឹត្តទៅក្នុងអំណាច ព្រោះហេតុនោះ កាលនឹងហាមការ ( យល់ថា ) ប្រព្រឹត្តទៅក្នុងអំណាច លោកអាចារ្យទើបពោលថា ម្យ៉ាងទៀត ធម្មជាតិឈ្មោះថា **មុទិតា** ព្រោះអត្ថថា ត្រឹមតែជាការត្រេកអរប៉ុណ្ណោះ ដូច្នេះ ។

ការសម្លឹងមើលដោយការឧបេក្ខា ( គឺ មិនបង្អោនចិត្តចូលទៅជាប់ជំពាក់ ) ពោលគឺ ភាពព្រងើយកន្តើយ ដោយមិនមានការលំអៀងក្នុងបុគ្គលដែលជាទីស្រឡាញ់ជាដើមជាសំខាន់ ឈ្មោះថា **ឧបេក្ខា** ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ចូរកុំជាអ្នកមានពៀរ ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ហេតុក្នុងការសម្ដែងជាកត្តុថា **ឧបេក្ខតិ** ( រមែងព្រងើយកន្តើយ ) ដូច្នេះ ខ្ញុំព្រះករុណាបានពោលអធិប្បាយក្នុងខាងដើមហើយនោះឯង ។

ការប្រព្រឹត្តតែប្រយោជន៍ ឈ្មោះថា **ហិត** ព្រោះដូច្នោះ បទថា **ហិតាការប្បវត្តិលក្ខណា** ទើបមានន័យថា មានការប្រព្រឹត្តទៅដោយអាការដែលប្រព្រឹត្តតែប្រយោជន៍ដល់សត្វទាំងឡាយ ជាលក្ខណៈ ឬថា ធ្វើអាការដែលប្រព្រឹត្តតែប្រយោជន៍ ឲ្យប្រព្រឹត្តទៅជាលក្ខណៈ ។ ពាក្យថា **មានការបង្អោនយកប្រយោជន៍ចូលទៅជារស** គឺ មានការបង្អោនយកប្រយោជន៍ចូលទៅឲ្យដល់សត្វទាំងឡាយជាកិច្ច ឬមានការបង្អោនប្រយោជន៍ចូលទៅឲ្យសត្វទាំងឡាយជាសម្បត្តិ ។ ឈ្មោះ

ថា មានការកម្ចាត់ភាពអាឃាតបានជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា ប្រាកដ គឺ ដល់នូវភាពជាអារម្មណ៍របស់ញាណ ដោយអាការដែលកម្ចាត់ភាពដែលប្រព្រឹត្តទៅដោយន័យថា គេបានធ្វើសេចក្តីវិនាសឲ្យដល់យើងហើយជាដើម ឬថា កើតឡើងឯងក្នុងសន្តានណា ក៏ធ្វើការកម្ចាត់ភាពអាឃាតឲ្យប្រាកដក្នុងសន្តាននោះ ។ ការឃើញភាវៈដែលសត្វទាំងឡាយ សូម្បីថា ជាអ្នកមិនគួរពេញចិត្ត ថាជាអ្នកគួរពេញចិត្ត ព្រោះជាអ្នកមានការសម្គាល់ក្នុងអារម្មណ៍ដែលគួររង្កៀស ថា មិនគួររង្កៀស ជាសភាវៈ នឹងពោលទៅថ្វីដល់ការឃើញសត្វទាំងឡាយដែលគួរពេញចិត្ត ( តាមប្រក្រតី ) ថាជាអ្នកគួរពេញចិត្តនោះ បានដល់ យោនិសោមនសិការដែលប្រព្រឹត្តទៅដោយអាការយ៉ាងនោះ យ៉ាងណា , នោះជាបទដ្ឋានរបស់មេត្តា ព្រោះហេតុនោះ **មេត្តា** ទើបឈ្មោះថា មានការសម្លឹងឃើញភាវៈដែលសត្វទាំងឡាយ ជាអ្នកគួរពេញចិត្តជាបទដ្ឋាន ។

ពាក្យថា **ការស្ងប់ព្យាបាទបាន** បានដល់ សេចក្តីស្ងប់ព្យាបាទ ដោយទាក់ទងនឹងការគ្របសង្កត់ទុកបាន ។ ពាក្យថា **សម្បត្តិ** គឺជាភាពសម្រេច បានដល់ការកើតឡើងដោយប្រពៃនោះឯង ។ ពាក្យថា **ការកើតឡើងនៃសេចក្តីស្នេហា** បានដល់ ការឧប្បត្តិនៃសេចក្តីស្នេហា គឺ តណ្ហា ។

ពាក្យថា **វិបត្តិ** បានដល់ សេចក្តីវិនាស ។ ពិតណាស់ រាគៈរមែងបោកបញ្ឆោតបាន ដោយមានមេត្តាជាប្រមុខ ។

គប្បីជ្រាបន័យនៃអាការ ៤ មានលក្ខណៈជាដើម នៃព្រហ្មវិហារ ៣ ដ៏សេស មានករុណាព្រហ្មវិហារជាដើម តាមន័យនេះចុះ ។ ខ្ញុំព្រះករុណានឹងសូមពណ៌នាចំពោះប្រការដែលប្លែកប៉ុណ្ណោះ ។ ករុណាមានអាការដែលកម្ចាត់ចេញទៅ

នូវទុក្ខដែលប្រព្រឹត្តទៅហើយដល់សត្វទាំងឡាយ ។ តែថា នឹងមានការកម្ចាត់ចេញទៅបាន ( ពិត ) ឬមិនបានក៏ដោយ អាការដែលកម្ចាត់ចេញទៅនូវទុក្ខឯណា ករុណាមានការប្រព្រឹត្តទៅដោយអាការនោះជាលក្ខណៈ ឈ្មោះថា មានការប្រព្រឹត្តទៅដោយអាការដែលកម្ចាត់ចេញទៅនូវទុក្ខជាលក្ខណៈ ។ ការអត់ធន់មិនបាន គឺ ការមិនព្រមឲ្យអ្នកដទៃដល់នូវសេចក្តីទុក្ខ ដោយភាពជាអ្នកប្រាថ្នាកម្ចាត់ចេញ ឈ្មោះថា ការអត់ធន់នូវទុក្ខរបស់អ្នកដទៃមិនបាន ។ ការមិនបៀតបៀន ឈ្មោះថា **អវិហិង្សា** បានដល់ ការមិនបៀតបៀនសត្វទាំងឡាយ ។ **ករុណា** ឈ្មោះថា មានការមិនបៀតបៀនជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា ធ្វើការមិនបៀតបៀននោះឲ្យប្រាកដ ឬថា ប្រាកដដោយភាពជាបដិបក្ខចំពោះការបៀតបៀន ។ ក្នុងពាក្យថា **ការស្ងប់នូវការបៀតបៀននេះ** មានអធិប្បាយថា ធម្មជាតិឈ្មោះថា **វិហិង្សា** ព្រោះអត្ថថា ជាហេតុបៀតបៀនសត្វទាំងឡាយ ឬថា ការបៀតបៀនសត្វទាំងឡាយនោះ បានដល់ចិត្តុប្បាទដែលសម្បយុត្តដោយបដិឃៈ ដែលជាបដិបក្ខចំពោះករុណា ប្រព្រឹត្តទៅដោយអាការដូចជាការវាយសត្វទាំងឡាយ ។ សេចក្តីសោករមែងបោកបញ្ឆោតបានដោយករុណាជាប្រមុខ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា មានការកើតឡើងនៃសេចក្តីសោកជាវិបត្តិ ដូច្នេះ ។

ពាក្យថា **មានការត្រេកអរជាលក្ខណៈ** គឺ មានការត្រេកអរដោយសម្បត្តិរបស់អ្នកដទៃជាលក្ខណៈ ។ ពាក្យថា **មានការមិនច្រណែនជារស** គឺ មានភាពជាបដិបក្ខចំពោះការឫស្យាជាកិច្ច ។ ការអត់ធន់មិនបាន ការមិនរីករាយក្នុងសម្បត្តិរបស់សត្វទាំងឡាយ ក្នុងសេនាសនៈដែលស្ងាត់ និងក្នុងអធិកុសលធម៌ទាំងឡាយ ដល់ការសង្គ្រោះថា ជាអរតិ ( គឺមិនត្រេកអរ ) ទាំងអស់ **មុទិតា** ឈ្មោះថា មាន

ការកម្ចាត់អរតិជាបច្ចុប្បដ្ឋាន ព្រោះអត្ថថា ប្រាកដដោយអាការដែលកម្ចាត់អរតិនោះ ឬថា ធ្វើការកម្ចាត់ គឺ ធ្វើភាពស្ងប់នៃអរតិនោះឲ្យប្រាកដ ។

ឈ្មោះថា **ភាពត្រេកអរ** បានដល់ ការមនោរម គឺ ការរីករាយចិត្ត ដោយទាក់ទងនឹងបីតិអាស្រ័យផ្ទះ ( បីតិអាស្រ័យកាមគុណ ) ។ ពាក្យថា **មានការសម្លឹងឃើញភាពស្មើគ្នាក្នុងសត្វទាំងឡាយជារស** គឺ មានការសម្លឹងឃើញភាពស្មើគ្នាដោយការប្រព្រឹត្តព្រងើយក្នុងសត្វទាំងពួង ដែលមានការផ្សេងគ្នា ដោយបុគ្គលដែលជាទីស្រឡាញ់ជាដើមប៉ុណ្ណោះជាកិច្ច សេចក្តីថា មានការកាន់យកសត្វទាំង-នោះដោយភាពជាបុគ្គលស្មើគ្នា ដោយការសម្លឹងមើលទៅតាមការឧប្បត្តិប៉ុណ្ណោះជាកិច្ច ។ ព្រោះមានការប្រព្រឹត្តទៅដោយអាការដែលស្ងប់សេចក្តីត្រេកអរ និង មិនត្រេកអរក្នុងសត្វទាំងនោះ ដោយការមិនកាន់យកអាការដែលគួររង្កៀស និង មិនគួររង្កៀសក្នុងពពួកសត្វ ទើបឈ្មោះថា ធ្វើសេចក្តីស្ងប់ គឺ ការគ្របសង្កត់សេចក្តីត្រេកអរ និង មិនត្រេកអរទាំងនោះឲ្យប្រាកដបាន ព្រោះហេតុនោះ ទើបឈ្មោះថា មានការស្ងប់ភាពត្រេកអរ និងមិនត្រេកអរបានជាបច្ចុប្បដ្ឋាន ។ ដោយពាក្យថា **ឯវំ** ( យ៉ាងនេះ ) នេះ ក្នុងពាក្យថា មានការសម្លឹងឃើញភាវៈដែលសត្វទាំងឡាយជាអ្នកមានកម្មជារបស់ខ្លួន ដែលប្រព្រឹត្តទៅយ៉ាងនេះជាបទដ្ឋាន នេះលោកអាចារ្យកាលពោលចំពោះ ដោយអាការដែលបង្អោនយកប្រយោជន៍ចូលទៅ ( នៃមេត្តា ) អាការដែលកម្ចាត់ចេញទៅនូវទុក្ខ ( នៃករុណា ) និងអាការដែលត្រេកអរក្នុងសម្បត្តិ ( នៃមុទិតា ) ដោយដើងបដិសេធ ទើបសម្តែងថា កម្មស្សកតាញាណដែលប្រព្រឹត្តទៅ ដោយការបដិសេធអាការប្រព្រឹត្តទៅនៃធម្មជាតិ ៣ យ៉ាង មានមេត្តាជាដើមជាប្រមុខ ជាហេតុជិត នៃឧបេក្ខាព្រហ្មវិហារ នឹងប្រើហេតុយ៉ាងណា

មួយក៏ទេ ។

ក្នុងពាក្យថា **វិបស្សនាសុខ និង ភពសម្បត្តិនេះ** លោកគួរនឹងពោលពាក្យថា ព្រមទាំងទិដ្ឋធម្មសុខវិហារ ( ធម៌ដែលជាទីនៅជាសុខក្នុងអត្តភាពនេះ ) ។ ព្រោះថា សូម្បីប្រការនោះក៏ជាប្រយោជន៍សាធារណៈនៃព្រហ្មវិហារ ៣ ទាំងនោះ ។ អានិសង្ស ១១ យ៉ាង មានការដេកលក់ជាសុខជាដើម ជាប្រយោជន៍សាធារណៈដូចគ្នា ។ តែអានិសង្ស ១១ យ៉ាងនោះ លោកបានពោលទុកក្នុងខាងដើមហើយនោះឯង ព្រោះហេតុនោះ ក្នុងទីនេះលោកទើបមិនកាន់យក ។

ឈ្មោះថា **និស្សរណៈ** ព្រោះអត្ថថា ជាហេតុចេញទៅប្រាស គឺជាអ្នកលះ ។ ក៏នីវរណធម៌ទាំង ៥ និងបាបធម៌ទាំងឡាយ ដែលតាំងនៅក្នុងចិត្តប្បាទជាមួយគ្នានឹងនីវរណៈនោះ ត្រូវព្រហ្មវិហារទាំងនោះលះបង់ដោយអំណាចនៃវិក្ខម្ភនប្បហានក៏ពិត សូម្បីយ៉ាងនោះ ក្នុងព្រះបាលីពោលដល់ធម៌ទាំងឡាយ មានព្យាបាទជាដើមទុក ( ជំនួសពាក្យពោលដល់នីវរណៈ ៥ ) ដោយទាក់ទង នឹងការសម្តែងដល់ធម៌ ដែលជាសត្រូវដោយត្រង់ ( របស់ព្រហ្មវិហារ ) ក៏បណ្ឌិតគប្បីឃើញថាពាក្យពោលដល់ ឧបេក្ខាព្រហ្មវិហារជាហេតុចេញចាកនៃរាគៈ និងជាការតាំងមាំដោយល្អ ក៏ព្រោះបានធ្វើអធិប្បាយយ៉ាងនេះ ។

បទថា **ឯត្ថ** ប្រែថា ក្នុងបណ្តាព្រហ្មវិហារទាំងនេះ ។ សេចក្តីថា មេត្តារមែងប្រព្រឹត្តទៅដោយទាក់ទងនឹងការកាន់យកគុណ មានទាន បិយវាចាជាដើម និងគុណមានសីល សុតៈជាដើម ក្នុងសត្វទាំងឡាយតាមសមគួរ ។ ព្រោះហេតុនោះលោកទើបពោលថា មានការសម្លឹងឃើញភាវៈដែលសត្វទាំងឡាយ ជាអ្នកគួរពេញចិត្តជាបទដ្ឋាន ដូច្នេះ ។ សូម្បីរាគៈ ក៏រមែងប្រព្រឹត្តទៅដោយការកាន់យកគុណក្នុងសត្វ

ទាំងនោះ ដោយប្រការណានីមួយជាប្រមុខដូចគ្នា ព្រោះបានទទួលការសម្គាល់ ( ក្នុងសត្វទាំងនោះ ) ថាជាបុគ្គលគួរពេញចិត្ត ព្រោះហេតុនោះ លោកទើបពោលថា ព្រោះភាពដែលជាសភាគៈគ្នា ដោយការសម្លឹងឃើញតែគុណ ។ ព្រោះដូច្នោះ រាគៈទើបឈ្មោះថា ជាសត្រូវជិតរបស់មេត្តា ដោយការធ្វើមេត្តាឲ្យវិនាសទៅដោយអាការដែលប្រៀបធៀបគ្នាបាន ដូចសត្រូវមានមុខដូចមិត្រ ដូច្នោះ ឈ្មោះថា រាគៈនោះ រមែងបានឱកាសដោយងាយ ក៏ព្រោះមេត្តាប្រាសទៅ សូម្បីព្រោះហេតុត្រឹមតែមិនមានសតិ ក៏គួរកើតក្នុងវត្ថុ ( ដែលជាអារម្មណ៍របស់មេត្តានោះ ) បាន ។ បទថា **តតោ** សេចក្តីថា គប្បីរក្សាមេត្តាឲ្យឆ្ងាយពីរាគៈ ឬអំពីការបានឱកាសនៃរាគៈ ។ បទថា **សភាគវិសភាគតាយ** ប្រែថា ព្រោះជាវិសភាគៈគ្នា ( មានចំណែកខុសគ្នា ) នឹងចំណែករបស់ខ្លួន ឬប្រែថា ព្រោះជាវិសភាគៈគ្នាដោយសភាវៈ ។ ពិតណាស់ ព្យាបាទដែលមានសភាពផ្ទុយគ្នានឹងមេត្តាព្រហ្មវិហារនោះ ចាត់ជាវិសភាគៈគ្នានៃធម៌ដែលមានចំណែកស្មើគ្នានឹងមេត្តា ដែលមានប្រក្រតីកាន់យកអាការដែលគួរពេញចិត្តក្នុងសត្វទាំងឡាយ ។ ព្រោះដូច្នោះ ព្យាបាទនោះកាលមិនបានឱកាស តែក៏អាចបានដោយកាលយូរនោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា ជាសត្រូវឆ្ងាយរបស់មេត្តា ដូចសត្រូវដែលតាំងនៅក្នុងទីឆ្ងាយនៃបុរសដូច្នោះ ។ បទថា **តតោ** ប្រែថា អំពីព្យាបាទនោះ ។ ពាក្យថា **មិនត្រូវខ្លាច** អធិប្បាយថា មិនត្រូវខ្លាចក្រែងរអែងចិត្ត ព្រោះមេត្តាដែលបានទីតាំងមាំហើយ ព្យាបាទញាំញីបានដោយលំបាក ។ ព្រោះហេតុនោះ លោកទើបពោលថា ប្រការថា នឹងចម្រើនមេត្តាផង ដូច្នេះជាដើម ។

ពាក្យថា **ជារូបគួរប្រាថ្នា** គឺ រូបជាទីស្រឡាញ់ ។ ពាក្យថា **គួរពេញចិត្ត** គឺ

គួរត្រេកអរ ។ ពាក្យថា **គួរពេញចិត្ត** គឺ គួរបម្រើនចិត្ត ។ ព្រោះហេតុនោះៗ ឯង ទើបឈ្មោះថា គួរមនោរមចិត្ត ព្រោះអត្ថថា ធ្វើចិត្តឲ្យមនោរម ។ ពាក្យថា **ទាក់ទងដោយលោកាមិសៈ** គឺ អាស្រ័យតណ្ហា ។ ពាក្យថា **សម្លឹងឃើញដោយការមិនបានមក** គឺ ក្តៅក្រហាយចិត្ត ដោយការដែលមិនទាន់បានមក យើងនៅមិនទាន់បានរបស់ទាំងនេះ ដូច្នេះ ។ ពាក្យថា **កន្លងទៅហើយ** គឺ ឈានកន្លងទៅហើយ ។ ពាក្យថា **រលត់ទៅហើយ** គឺ ដល់នូវការរលត់ទៅហើយ ។ ពាក្យថា **ប្រែប្រួលទៅហើយ** គឺ ប្រាសទៅហើយ ដោយការប្រាសទៅនៃចំណែករបស់ខ្លួន ។ ពាក្យថា **កាលតាមរលឹក** គឺ កាលគិតដល់ដោយអំណាចការកន្លល់ចិត្ត ។ បទថា **គេហសិតំ** ( អាស្រ័យផ្ទះ ) គឺ អាស្រ័យកាមគុណ ។ ដោយពាក្យថា **អាទិនា** ( ប្រែថា ជាដើម ) នេះ លោករួមយកពាក្យមានយ៉ាងនេះថា នូវសំឡេងទាំងឡាយដែលគប្បីដឹងតាមផ្លូវត្រចៀក ដូច្នេះជាដើមផង ។

ពាក្យថា **ព្រោះជាសភាគៈគ្នា ដោយការសម្លឹងឃើញតែវិបត្តិ** មានន័យថា ករុណា រមែងប្រព្រឹត្តទៅ ដោយអាស្រ័យការសម្លឹងឃើញតែវិបត្តិ មានភោគ-វិបត្តិជាដើម ក្នុងសត្វទាំងឡាយពួកណាជាហេតុ កាលមានការគិតដល់ហេតុការណ៍ គឺ កាលវិបត្តិនោះក្នុងសត្វទាំងនោះៗឯង ដោយអយោនិសោ , សេចក្តីសោកក៏គប្បីកើតឡើងបានដោយគន្លង គឺ ទោមនស្សតាមដែលពោលហើយ សេចក្តីសោកនោះ ជាសត្រូវជិតរបស់ករុណា ។ ពិតណាស់ ក្នុងទីនេះលោកពោលដល់សេចក្តីសោកទុក ដោយសំដៅដល់ទោមនស្សជាសំខាន់ ។ ក្នុងពាក្យថា **ព្រោះភាពដែលជាវិសភាគៈគ្នានឹងចំណែករបស់ខ្លួននេះ** មានអត្ថាធិប្បាយថា ធម៌ដែលមានចំណែកស្មើគ្នានឹងវិហិង្សា ដែលមានការនាំទុក្ខចូលទៅក្នុងសត្វទាំងនោះ ចាត់ជាវិសភាគៈ

គ្នានៃធម៌ដែលមានចំណែកស្មើគ្នានឹងករុណា ដែលមានអាការជាទីប្រាថ្នានឹងកម្ចាត់ចេញទៅនូវទុក្ខក្នុងសត្វទាំងឡាយ ព្រោះហេតុនោះ ព្រោះជាវិសភាគៈគ្នានឹងចំណែករបស់ខ្លួននោះ វិហិង្សានោះ កាលនឹងបានឱកាសគប្បីបានដោយកាលយូរនោះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ជាសត្រូវឆ្ងាយរបស់ករុណា ដូចសត្រូវដែលតាំងនៅក្នុងទីឆ្ងាយរបស់បុរស ដូច្នោះ ។

ពាក្យថា **ព្រោះភាពដែលជាសភាគៈគ្នា ដោយការសម្លឹងឃើញតែសម្បត្តិ** មានសេចក្តីថា មុទិតារមែងប្រព្រឹត្តទៅដោយអាស្រ័យការសម្លឹងឃើញតែសម្បត្តិ មានភោគសម្បត្តិជាដើមក្នុងសត្វទាំងឡាយពួកណាជាប្រក្រតី កាលមានការគិតជញ្ជឹងដល់ហេតុការណ៍ គឺសម្បត្តិនោះក្នុងសត្វទាំងនោះៗឯង មិនត្រូវឧបាយ សេចក្តីរីករាយគប្បីកើតឡើងបាន ដោយអាស្រ័យសោមនស្សដែលបានត្រាស់ទុកដោយពាក្យថា **នូវរូបទាំងឡាយដែលគប្បីដឹងតាមផ្លូវភ្នែកជាដើមជាហេតុ សេចក្តីរីករាយជាសត្រូវជិតរបស់មុទិតា** ។ ពិតណាស់ ក្នុងទីនេះលោក ពោលដល់សេចក្តីរីករាយទុក ដោយសំដៅដល់សោមនស្សជាសំខាន់ ។ ពាក្យថា **ព្រោះជាវិសភាគៈគ្នានឹងចំណែករបស់ខ្លួន** មានសេចក្តីថា ការមិនត្រេកអរដែលមានអាការមិនអភិរម្យក្នុងសត្វទាំងនោះ ចាត់ជាវិសភាគៈនៃធម៌ ដែលមានចំណែកស្មើគ្នានឹងមុទិតា ដែលមានអាការត្រេកអរក្នុងសត្វទាំងឡាយ ដែលត្រេកអរដោយសម្បត្តិមានភោគសម្បត្តិជាដើម ហេតុនោះ ព្រោះភាពដែលអរតិនោះ ជាវិសភាគៈគ្នានឹងចំណែករបស់ខ្លួនយ៉ាងនេះ អរតិនោះ កាលនឹងបានឱកាស ក៏បានដោយកាលយូរនោះឯង ព្រោះដូច្នោះ លោកទើបពោលថា ជាសត្រូវឆ្ងាយរបស់មុទិតា ដូចសត្រូវដែលឋិតនៅក្នុងទីឆ្ងាយពីបុរស ដូច្នោះ ។ បទថា **បមុទិតោ ច** ជាដើម លោក

ពោលទុកដោយទាក់ទងនឹងការសម្ដែងដល់គុណដែលគប្បីបានទទួលថា កាលមុទិតាសម្រេចហើយ អរតិនេះក៏រមែងមានមិនបាន មិនបានពោលទុកដោយទាក់ទងនឹងការសម្ដែងដល់ការសង្កត់អរតិដែលបំណាងក្នុងទីនេះ ។ ម្យ៉ាងទៀត គប្បីឃើញថា លោកសម្ដែងអរតិទុកដោយចំណែកមួយប៉ុណ្ណោះ ដើម្បីសម្ដែងថា កាលអរតិជាចំណែកដែលជាបដិបក្ខចំពោះកាយវិវេក និងចិត្តវិវេក ត្រូវគ្របសង្កត់បានហើយ អរតិជាចំណែកដែលជាបដិបក្ខចំពោះមុទិតា ក៏ជាធម្មជាតិដែលព្រះយោគី អាចគ្របសង្កត់បានដោយងាយ ។ ពាក្យថា **ក្នុងអធិកុសលធម៌ទាំងឡាយ** គឺ ក្នុងសមថធម៌ និង វិបស្សនាធម៌ទាំងឡាយ ។

បុថុជ្ជន ឈ្មោះថា ជាបុគ្គលពាល ព្រោះប្រកបដោយធម៌ដែលសាងភាពជាពាល ។ ឈ្មោះថា ជាបុគ្គលវង្វេង ព្រោះភាពដែលវង្វេងក្នុងប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ។ ឈ្មោះថា បុថុជ្ជន ព្រោះហេតុទាំងឡាយ មានការធ្វើកិលេសជាដើម ឲ្យកើតសន្ទឹកសន្ធាប់ជាដើម ។ ឈ្មោះថា អ្នកមិនឈ្នះកិលេសដូចជាព្រំដែន ព្រោះមិនឈ្នះព្រំដែនគឺកិលេស ដោយព្រំដែនគឺមគ្គ , ម្យ៉ាងទៀត ព្រះសេក្ខៈទាំងឡាយ ឈ្មោះថា ឱធិជិនៈ ព្រោះលោកឈ្នះកិលេសទាំងឡាយដោយព្រំដែន គឺ មគ្គទាំងឡាយបានហើយនោះឯង ។ ដោយពាក្យថា **អនោធិជិនស្ស** នោះ លោកបដិសេធភាពដែលបុគ្គលនេះជាព្រះសេក្ខៈ ដែលឈ្មោះថា **ឱធិជិន** ។ ឈ្មោះថា ដែលមិនឈ្នះវិបាក ព្រោះមិនឈ្នះវិបាក ដែលមានការប្រព្រឹត្តលើសកពទី ៧ ជាដើម , ម្យ៉ាងទៀត ព្រះអរហន្តទាំងឡាយឈ្មោះថា **វិបាកជិន** គឺ អ្នកឈ្នះវិបាក ព្រោះលោកជាអ្នកមិនមានបដិសន្ធិ ។ ដោយពាក្យថា ដែលមិនឈ្នះវិបាកនោះ លោកបដិសេធភាវៈដែលបុគ្គលនេះជាព្រះអសេក្ខៈ ។ ឈ្មោះថា ដែលមិនសម្លឹង

ឃើញទោស ព្រោះជាអ្នកមានប្រក្រតីមិនសម្លឹង ឃើញទោសក្នុងការវង្វេងដែលមានទោសច្រើន ដែលជាមូលនៃបាបធម៌ទាំងឡាយទាំងពួង ។ ឈ្មោះថា ដែលមិនមានការស្តាប់ ក៏ព្រោះមិនមានអាគម (ការរៀនព្រះបរិយត្តិ) និងអធិគម ( ការសម្រេចមគ្គ-ផល ) ។ ទ្រង់បំណងសម្តែងភាវៈដែលបុគ្គលនោះ ជាអន្ធបុថុជ្ជន ( បុគ្គលល្ងង់ខ្លៅ ) ថា បុគ្គលដែលជាដូច្នេះ ឈ្មោះថា ជាអន្ធបុថុជ្ជនតែម្យ៉ាងដូច្នេះ ទើបបានត្រាស់ទុកសូម្បី ពាក្យមួយទៀតថា ដែលជាបុថុជ្ជនដូច្នេះ ។ ពាក្យថា **មានសភាពយ៉ាងនេះ** គឺ ឧបេក្ខាដែលមានការវង្វេងចេញមុខ ដោយអាការដែលពោលហើយ ។ ពាក្យថា **ឧបេក្ខានោះប្រព្រឹត្តទៅកន្លងរូបបានក៏ទេ** គឺ មិនជាហេតុនៃការឈានកន្លងដោយប្រពៃនូវរូបទាំងឡាយ អធិប្បាយថា ប្រព្រឹត្តទៅក្នុងកិលេសដែលមានរូបជាអារម្មណ៍បាន ក៏ទេ ។ ការមិនដឹងដែលវៀរចាកសោមនស្ស និងទោមនស្សនោះឯង ឈ្មោះថា **អញ្ញាណុបេក្ខា** ។ ពាក្យថា **ព្រោះជាសភាគៈគ្នា ដោយទាក់ទងនឹងការមិនពិចារណាដល់គុណ និង ទោស** មានសេចក្តីថា ឧបេក្ខា-ព្រហ្មវិហារ មិនពិចារណាដល់គុណនិងទោស ដោយទាក់ទងនឹងការបង្អោនយកប្រយោជន៍ចូលទៅក្នុងសត្វទាំងឡាយជាដើម ដូចជាព្រហ្មវិហារ ៣ មានមេត្តាជាដើម រមែងប្រព្រឹត្តទៅដោយអំណាចការព្រងើយកន្តើយតែម្យ៉ាង ប៉ុណ្ណោះ យ៉ាងណា , អញ្ញាណុបេក្ខា ( ឧបេក្ខាដែលជាការមិនដឹង ) មិនគិតដល់គុណ និងទោស ដែលមាននៅក្នុងសត្វទាំងឡាយ រមែងប្រព្រឹត្តទៅដោយអំណាចការព្រងើយកន្តើយតែម្យ៉ាង ប៉ុណ្ណោះ យ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា ជាសភាគៈគ្នា ដោយទាក់ទងនឹងការមិនពិចារណាដល់គុណនិងទោស ។ ព្រោះដូច្នោះ ឧបេក្ខាដែលជាការមិនដឹងនោះ រមែងបានឱកាសងាយ ព្រោះហេតុនោះ លោកអាចារ្យទើប

ពោលថា ជាសត្រូវជិតរបស់ឧបេក្ខាដែលជាព្រហ្មវិហារ ។ ពាក្យថា **ព្រោះភាពដែលជាវិសភាគៈគ្នា នឹងចំណែករបស់ខ្លួន** មានសេចក្ដីថា កាមរាគៈ និងបដិឃៈដែលប្រព្រឹត្តទៅដោយទាក់ទងនឹងការត្រេកអរ និង មិនត្រេកអរក្នុងអារម្មណ៍ទាំងនោះ ចាត់ជាវិសភាគៈគ្នានៃធម៌ដែលមានចំណែកស្មើគ្នានឹងឧបេក្ខាដែលមានអាការជាកណ្ដាលក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ទាំងឡាយ ព្រោះហេតុនោះ ព្រោះភាពដែលជាវិសភាគៈគ្នានឹងចំណែករបស់ខ្លួននៃឧបេក្ខានោះ រាគៈ និងបដិឃៈទាំងនោះកាលនឹងបានឱកាស ក៏គប្បីបានដោយកាលយូរនោះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ជាសត្រូវឆ្ងាយរបស់ឧបេក្ខាព្រហ្មវិហារ ដូចសត្រូវដែលនៅក្នុងទីឆ្ងាយពីបុរស ដូច្នោះ ។

ឈ្មោះថា មានកត្តុកាមតាឆន្ទៈជាខាងដើម ក៏ដោយពាក្យពោលដែលថា កុសលធម៌ទាំងឡាយមានឆន្ទៈជាមូលដូច្នេះ ន័យម្យ៉ាងទៀត ព្រោះមានការប្រព្រឹត្តទៅដោយអំណាចនៃសេចក្ដីប្រាថ្នាដែលរកទោសមិនបាន ដោយអាការជាអ្នកស្វែងរកប្រយោជន៍ឧបការៈ និង ភាពជាអ្នកប្រាថ្នាកម្ចាត់បេញទៅនូវទុក្ខជាដើមក្នុងសត្វទាំងឡាយ លោកទើបពោលថា មានកត្តុកាមតាឆន្ទៈជាដើម ដូច្នេះ ។ ពិតណាស់សូម្បី ឧបេក្ខាព្រហ្មវិហារក៏ចាត់ថាជាឆន្ទៈក្នុងប្រយោជន៍ឧបការៈ ដែលបំពេញទៅដោយមិនតឹងតែងក្នុងសត្វទាំងឡាយនោះឯង រមែងប្រព្រឹត្តទៅដោយអាការដែលព្រងើយថា ជាអបណ្ណកបដិបទា ( បដិបទាដែលមិនខុស ) ដែលមិនមានសេចក្ដីខ្វល់ខ្វាយក្នុងសត្វទាំងនោះ ដូច្នេះ ដូចជាមាតាប្រព្រឹត្តទៅដោយអាការព្រងើយកន្តើយក្នុងបុត្រដែលចាត់ចែងក្នុងកិច្ចការងាររបស់ខ្លួនឯងបានហើយ ដូច្នោះ ។ ពាក្យថា **នូវនីវរណៈជាដើម** ដោយ **អាទិ** ស័ព្ទ ប្រែថា **ជាដើម** គប្បីឃើញថា លោក

សង្គ្រោះយកកិលេសទាំងឡាយ ដែលតាំងនៅក្នុងចិត្តប្បាទ១ ជាមួយនឹងនីវរណៈនោះ ។ ក្នុងទីខ្លះសព្ទថា **សត្វ** គឺ ជាសព្ទថា **សង្ខារ** នោះឯង ដោយជាទេសនាបុគ្គលាធិដ្ឋាន ដូចជាពាក្យថា សត្វទាំងឡាយទាំងពួង មានការតាំងនៅបានព្រោះអាហារដូច្នេះ , ដូច្នោះ ក្នុងព្រហ្មវិហារនេះយ៉ាងនោះក៏ទេ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា មានសត្វ ១ ឬ សត្វច្រើនជាអារម្មណ៍ ដោយទាក់ទងនឹងបញ្ញត្តិធម៌ ដូច្នេះ ។ ពាក្យថា **ដោយទាក់ទងនឹងបញ្ញត្តិធម៌** គឺ ដោយទាក់ទងនឹងធម៌ដែលរាប់ថាជាបញ្ញត្តិ ។ ក្នុងព្រហ្មវិហារទាំងនេះ ក្នុងការចម្រើនដោយន័យថា សូមជាអ្នកដល់នូវសេចក្តីសុខចុះដូច្នេះជាដើម រមែងបានសូម្បីការកាន់យកសុខជាដើម ( ដែលមិនមែនបញ្ញត្តិ ) ក៏ពិត , សូម្បីយ៉ាងនោះ ការកាន់យកសុខជាដើមនោះ មិនបានជាប្រធានដូចជាការកាន់យកអនិច្ចលក្ខណៈនៃវិបស្សនា ដែលប្រព្រឹត្តទៅថា សង្ខារទាំងឡាយមិនទៀង គប្បីជ្រាបថា រមែងកាន់យកសត្វបញ្ញត្តិដោយភាពជាប្រធានយ៉ាងនេះ , អធិប្បាយថា កាលបានសម្រេចឧបចារៈទើបមានការពង្រីកអារម្មណ៍បាន ព្រោះក្នុងឧបចារៈនោះក៏សម្រេច **សីមាសម្ភេទ** ( ការទម្លាយព្រំដែន ) បានដែរ ។

ក្នុងពាក្យថា **កំណត់អាវាសមួយកន្លែងនេះ** មានពាក្យប្រកបសេចក្តីថា គប្បីធ្វើការកំណត់ទុកដោយញាណយ៉ាងនេះថា យើងនឹងផ្សាយមេត្តាទៅកាន់សត្វទាំងឡាយ ដូច្នេះហើយ ក៏កំណត់ថ្នល់មួយខ្សែ ។ ដោយសព្ទថា ផ្លូវមួយខ្សែ ជាការកាន់យកសត្វទាំងឡាយដែលអាស្រ័យនៅក្នុងផ្លូវមួយខ្សែ ។ គប្បីកំណត់ហើយផ្សាយមេត្តាទៅអស់ទិស ១ យ៉ាងណា ក៏គប្បីកំណត់ហើយផ្សាយមេត្តាទៅក្នុងទិសទាំងពួង ក៏ដូច្នោះ ។

ពាក្យថា **ជាអានិសង្សរបស់កសិណទាំងឡាយ** មានសេចក្តីថា អរូបទាំងឡាយ បានដល់ អរូបជ្ឈានទាំងឡាយ ដូចជាផលដែលហូរចេញនៃកសិណឈានទាំងឡាយ ព្រោះសម្រេចបានដោយភាពបរិបូណ៌នៃកសិណឈាននោះឯង ។ អាចារ្យខ្លះពោលថា ព្រោះវៀរកសិណទាំងនោះចេញ ក៏សម្រេចមិនបាន ។ ពាក្យថា **ជាអានិសង្សនៃសមាធិទាំងឡាយ** មានសេចក្តីថា នេវសញ្ញានាសញ្ញាយតនៈ ឈ្មោះថា ជាផលដែលហូរចេញរបស់រូបជ្ឈានសមាធិទាំងឡាយ និង អរូបជ្ឈានសមាធិ៣ខាងក្រោម ព្រោះត្រូវសម្រេចសមាធិទាំងនោះ តាមលំដាប់ហើយប៉ុណ្ណោះ ទើបនឹងបានមក ។ **ផលសមាបត្តិ** ឈ្មោះថា ជាអានិសង្សរបស់វិបស្សនា ព្រោះព្រះអរិយបុគ្គលគប្បីបានទទួលដោយអានុភាពរបស់វិបស្សនា និងអាចចូលផលសមាបត្តិនោះៗបាន ដោយអំណាចនៃវិបស្សនា នោះឯង ។ **និរោធសមាបត្តិ** ឈ្មោះថា ជាអានិសង្សរបស់សមថៈ និងវិបស្សនា , ដូចដែលលោកពោលទុកថា បញ្ញាដែលមានភាពជាវសី ព្រោះការដល់ព្រមដោយកម្លាំង ២ ( គឺ កម្លាំងសមថៈ និងកម្លាំងវិបស្សនា ។ ល ។ ឈ្មោះថា និរោធសមាបត្តិញ្ញាណ ) ដូច្នេះជាដើម ។ ដោយពាក្យថា ( ឧបេក្ខាព្រហ្មវិហារ ) ជាអានិសង្សរបស់ព្រហ្មវិហារ ៣ ខាងដើមនេះ លោកអាចារ្យសម្តែងថា សម្រាប់ព្រះយោគី ដែលបានសម្រេចឈាន ៣ ដោយអំណាចនៃមេត្តាជាដើម មិនវិនាសប៉ុណ្ណោះ ទើបសម្រេចឧបេក្ខាព្រហ្មវិហារបាន មិនមែនសម្រាប់បុគ្គលក្រៅអំពីនេះទេ ។ ដើម្បីនឹងសម្តែងអត្ថន័យនោះៗឯងធ្វើឲ្យប្រាកដច្បាស់ក្រៃលែងឡើងដោយឧបមា លោកទើបពោលថា **យថា ហិ** ( ដូចជា... យ៉ាងណា ) ដូច្នេះជាដើម ។ ក្នុងពាក្យនេះ មានពាក្យដែលខ្ញុំព្រះករុណាបានពោលអធិប្បាយក្នុងខាងដើមនោះហើយ ។

ពាក្យថា **គប្បីមានសំណួរ** មានសេចក្តីថា សម្រាប់បុគ្គលខ្លះ គប្បីមានការគិតដោយអាស្រ័យអាការដែលកំពុងពោលដល់ ។ ពាក្យថា **ក្នុងបណ្តាគុណជាតិទាំងនេះ** មានសេចក្តីថា គប្បីជ្រាបភាពជាព្រហ្មវិហារ ក្នុងគុណជាតិមានមេត្តាជាដើមទាំងនេះ , កម្មដ្ឋានក្រៅអំពីនេះ ត្រឹមតែជាគោលបដិបត្តិដើម្បីជាប្រយោជន៍ខ្លួន ។ ចំណែកកម្មដ្ឋានទាំងនេះជាគោលបដិបត្តិដើម្បីប្រយោជន៍អ្នកដទៃ ដោយន័យថា សូមសត្វទាំងឡាយទាំងពួង ចូរជាអ្នកដល់នូវសេចក្តីសុខចុះ ដូច្នេះជាដើម ។ ព្រោះដូច្នោះ ធម៌ទាំងនេះទើបឈ្មោះថា ជាវិហារធម៌ដ៏ប្រសើរ ព្រោះភាពជាគោលបដិបត្តិប្រពៃក្នុងសត្វទាំងឡាយ ។ ពាក្យថា **ព្រហ្មទាំងឡាយ** បានដល់ ឧបបត្តិព្រហ្ម ( ព្រហ្មដោយឧប្បត្តិ ) ទាំងឡាយ ។ ពិតណាស់ ព្រហ្មទាំងនោះជាអ្នកមានចិត្តប្រាសចាកនីវរណៈ ដោយការចម្រើនឈានក្នុងលោកនេះហើយ ក៏ទៅកើតក្នុងព្រហ្មលោក ជាអ្នកមានចិត្តប្រាសចាកនីវរណៈ រហូតអស់អាយុក្នុងព្រហ្មលោកនោះៗឯង ។ ព្រោះដូច្នោះ លោកទើបពោលថា ជាអ្នកមានចិត្តប្រាសចាកទោសៈត្រាច់ទៅដូច្នេះ ។ ម្យ៉ាងទៀត ពាក្យថា **ព្រហ្មទាំងឡាយ** បានដល់ សត្វដ៏ធំក្រៃលែង គឺ ព្រះពោធិសត្វដែលមានគុណស្រស់បំព្រង ដោយអំណាចការធ្វើឲ្យបរិបូណ៌នូវធម៌ទាំងឡាយដែលសាងភាពជាព្រះពុទ្ធ មានទានបារមីជាដើម ដែលជាហេតុនៃព្រះពុទ្ធគុណទាំងមូល ។ ពិតណាស់ លោកទាំងនោះ ឈ្មោះថា ជាអ្នកមានចិត្តប្រាសចាកទោសៈ ត្រាច់ទៅ ក៏ដោយការដែលស្វែងរកប្រយោជន៍ដល់សត្វទាំងឡាយទាំងពួង , ដោយការកម្ចាត់ចេញទៅនូវវត្ថុដែលគ្មានប្រយោជន៍ឧបការៈដល់សត្វទាំងឡាយទាំងពួង , ដោយការត្រេកអរចំពោះសម្បត្តិរបស់សត្វទាំងឡាយទាំងពួង និង ដោយការវៀរចាកការដល់នូវអគតិ និង តាំងមាំក្នុងភាពជាកណ្តាល

ក្នុងសត្វទាំងឡាយទាំងពួង ។ ពាក្យថា **យ៉ាងនោះ** មានសេចក្ដីថា ឧបបត្តិព្រហ្ម ឬព្រហ្ម គឺ ព្រះមហាពោធិសត្វទាំងនោះ ជាអ្នកប្រកបព្រម គឺជាអ្នកដល់ព្រម ដោយព្រហ្មវិហារទាំងនោះ យ៉ាងណា ព្រះយោគាវចរ ក៏ជាអ្នកដល់ព្រម គឺជាអ្នកព្រមព្រៀងដោយព្រហ្មវិហារទាំងឡាយនោះ ក៏ដូច្នោះ ។

ពាក្យថា **សម្រាប់សំណួរថា ព្រោះហេតុអ្វីទើបមាន ៤ ជាដើម** គឺ សម្រាប់សំណួរ ៣ ប្រការ មានសំណួរថា ព្រោះហេតុអ្វីទើបមាន ៤ ជាដើម ។ ក្នុងពាក្យថា **ដោយទាក់ទងនឹងផ្លូវបរិសុទ្ធជាដើមនេះ** មានសេចក្ដីថា ឧបាយបរិសុទ្ធចាកសង្កិលេស គឺព្យាបាទជាដើម ឈ្មោះថា ផ្លូវបរិសុទ្ធ ។ ដោយ **អាទិ** ស័ព្ទ ( ប្រែថា ជាដើម ) សង្គ្រោះយកមនសិការដែលផ្សេងគ្នាដោយកិច្ច មានការបង្អោនយកប្រយោជន៍ឧបការៈចូលទៅជាដើម ។ ឈ្មោះថា លំដាប់នៃគុណជាតិទាំងនោះ គឺ លំដាប់នៃគុណជាតិទាំងឡាយ មានមេត្តាជាដើម ។ ពាក្យថា **មិនមានប្រមាណ** គឺ ក្នុងអារម្មណ៍ដែលប្រាសចាកប្រមាណ ។ បទថា **យេន** កែជា **យេនការណេន** ។ បទថា **តំ** កែជា **តស្មា** ។ **ទ** អក្សរ ជាតួធ្វើការភ្ជាប់បទ ។

គប្បីនាំយកពាក្យពោលមកសម្ពន្ធគ្នាថា **ព្យាបាទ ពហុលស្ស វិសុទ្ធិមគ្គោ** ( ជាផ្លូវបរិសុទ្ធនៃបុគ្គលដែលច្រើនដោយព្យាបាទ ) អធិប្បាយថា ឈ្មោះថា ជាផ្លូវបរិសុទ្ធនៃបុគ្គលដែលច្រើនដោយព្យាបាទ ក៏ព្រោះជាសត្រូវដោយត្រង់ ។ សូម្បីក្នុងធម៌ដ៏សេសក៏មានន័យនេះ , អធិប្បាយថា ការមិននឹកគិតដោយទាក់ទងនឹងការធ្លាក់ទៅ ( ក្នុងចំណែកម្ខាងៗ ឬ លំអៀង ) ឈ្មោះថា ការមិនជញ្ជឹងដល់បានដល់ អាការដែលជាកណ្ដាល ។ មនសិការក្នុងសត្វទាំងឡាយ ៤ យ៉ាងដែលលោកពោលទុក ដើម្បីសម្ដែងមនសិការ ៤ យ៉ាង នោះៗឯង ដោយឧបមា លោក

ទើបពោលថា **យស្មា ច យថា មាតា** ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ **ច** ស័ព្ទ ក្នុងពាក្យថា **យស្មា ច** ( ព្រោះហេតុដែលថា ប្រៀបបាន ) មានអត្ថថា នាំយកសភាវៈចូលទៅ ដើម្បីនាំចូលទៅសម្ដែងការឧបមេយ្យនៃសភាវៈ ដែលបង្អោនយកប្រយោជន៍ឧបការៈចូលទៅជាដើម សូម្បីដែលបានពោលហើយ ។ ពាក្យថា **ក្នុងបរិយាយ** គឺ ក្នុងវារៈ ( ណាៗ ) មានសេចក្ដីថា ក្នុងការដំណើរការផ្លាស់ប្ដូរទាក់ទងនឹងកិច្ចនោះ ៗ ។ បទថា **អព្យាវដា** ប្រែថា ជាអ្នកមិនខ្វល់ខ្វាយ។ ពាក្យថា **យ៉ាងនោះ** មានពាក្យប្រកបថា មាតាជាអ្នកនៅដោយការចម្រើនមេត្តាជាដើម ក្នុងកូន ៤ នាក់ ដែលម្នាក់ជាកុមារតូចជាដើម យ៉ាងណា ព្រះយោគីក៏គួរជាអ្នកនៅដោយការចម្រើនមេត្តាជាដើម ដោយទាក់ទងនឹងគុណជាតិ ៤ មានមេត្តាជាដើមក្នុងសត្វទាំងឡាយទាំងពួង ក៏យ៉ាងនោះ ។ ពាក្យថា **ព្រោះដូច្នោះ** មានសេចក្ដីថា ព្រោះហេតុដែលសន្តិលេសធម៌ទាំងឡាយ សូម្បីទាំងពួងជាបក្ខពួកនៃទោសៈ មោហៈ និងរាគៈតាមសមគួរ , អប្បមញ្ញាជាឧបាយបរិសុទ្ធចាកកិលេសធម៌ទាំងនោះ និង មនសិការចាកសត្វទាំងឡាយក៏មាន ៤ យ៉ាង ដោយទាក់ទងនឹងកិច្ច មានការបង្អោនយកឧបការៈចូលទៅជាដើម , ដូច្នោះ អប្បមញ្ញាទើបមាន ៤ ប៉ុណ្ណោះ ដោយទាក់ទងនឹងផ្លូវបរិសុទ្ធជាដើម ។

អធិប្បាយថា ព្រះយោគីដែលប្រាថ្នាចម្រើនអប្បមញ្ញាទាំង ៤ នេះ មិនមែនអប្បមញ្ញាតែម្យ៉ាងទេ ។ ពិតណាស់ ការចម្រើនមេត្តា ដោយភាពជាអ្នកស្វែងរកប្រយោជន៍ឧបការៈ គប្បីមានតាមលំដាប់គ្នាបាន ក្នុងកាលមានការរួបរួមយកសត្វគ្រប់ជំពូកទុក ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា តអំពីនោះ បុគ្គលដែលខ្វនប្រាថ្នាប្រយោជន៍ឧបការៈយ៉ាងនេះដូច្នេះ ។ ពាក្យថា **ឬបានជ្រាបដល់** បាន

ដល់ ឬបានត្រិះរិះថា បុគ្គលនេះគប្បីកើតឡើងក្នុងអបាយ មាននរកជាដើម ព្រោះវត្តបដិបត្តិនេះ ។ ភ្ជាប់សេចក្តីថា **ទុក្ខាបនយនាការប្បវត្តិវសេន បដិបជ្ជិតព្វំ** ( ត្រូវបដិបត្តិដោយទាក់ទងនឹងការធ្វើអាការដែលកម្ចាត់ចេញទៅនូវទុក្ខឲ្យប្រព្រឹត្តទៅ ) ។ បទថា **តតោ បរំ** គឺ តអំពីនោះ គឺ តអំពីការធ្វើអាការដែលឧបការៈឲ្យប្រព្រឹត្តទៅជាដើម ។ ពាក្យថា **ព្រោះមិនមានកិច្ចដែលត្រូវធ្វើ** គឺ ព្រោះមិនមានកិច្ចប្រភេទទី ៤ ដែលត្រូវធ្វើ ។ ពាក្យថា **លំដាប់នេះ លោកអាចារ្យពោលទុក** ព្រោះធ្វើអធិប្បាយថា នេះជាលំដាប់នៃការធ្វើឲ្យប្រព្រឹត្តទៅដោយច្រើននូវអប្បមញ្ញាទាំងនេះ នឹងបានពោលទុក ព្រោះធ្វើអធិប្បាយថា អប្បមញ្ញាទាំងនេះមានប្រការប្រព្រឹត្តទៅតាមលំដាប់នេះ ប៉ុណ្ណោះ មិនមែនដោយប្រការដទៃ ដូច្នេះក៏ទេ ។ ព្រោះថាភាវនា ៣ មានមេត្តាជាដើម មានគោលកំណត់ពិតប្រាកដដល់លំដាប់នៃការចម្រើនក៏ទេ ព្រះយោគីអាចចម្រើនភាវនាប្រការណាមួយមុនក៏បាន , ម្យ៉ាងទៀត លោកពោលទុកយ៉ាងនេះ ក៏ដោយទាក់ទងនឹងលំដាប់នៃទេសនា ។

បទថា **ឯកសត្តស្សាបិ** ប្រែថា សម្រាប់សត្វសូម្បីម្នាក់ ។ ព្រោះភាពដែលអារម្មណ៍មិនមែនជាបដិភាគនិមិត្ត ទើបមិនមានការកាន់យក ( អារម្មណ៍ ) ដោយការខណ្ឌយក និងការកាន់យកសត្វដែលប្រព្រឹត្តទៅ ដោយទាក់ទងនឹងសម្មតិសច្ចៈ រមែងមិនជាការកាន់យកបរិច្ឆិន្នរូប (រូបដែលកំណត់ទុកចំណែក ១ ដើម្បីប្រយោជន៍ដល់ការសម្លឹង) ជាដើម ព្រោះហេតុនោះ គុណជាតិទាំងឡាយ មានមេត្តាជាដើម ដែលជាកំពូលនៃការកាន់យកសត្វយ៉ាងពេញទី ដើម្បីការសម្រេចអប្បនា សូម្បីមានសត្វ ១ ជាអារម្មណ៍ , លោកក៏ពោលថា មានអារម្មណ៍មិនមានប្រមាណ ។ ពាក្យថា **មិនកាន់យកប្រមាណយ៉ាងនេះ** មានសេចក្តីថា ក្នុងឧទ្ធុមាតកអសុភជាដើម

ព្រះយោគី រមែងកាន់យកនិមិត្តត្រង់បរិវេណ ដែលដល់នូវការហើមប៉ោង ( ហើមប៉ោងជាងបរិវេណដទៃជាដើម ) យ៉ាងណា ( ក្នុងគុណជាតិ មានមេត្តាជាដើមនេះ ) នឹងកាន់យកប្រមាណដូចគ្នានោះក៏ទេ ។ ពាក្យថា **ដោយអំណាចការផ្សាយទូទៅក្នុងរាងកាយ** គឺ ដោយអំណាចការផ្សាយទៅដោយមិនមានសល់ ។

ក្នុងពាក្យថា **ព្រោះជាហេតុនាំចេញនេះ** មានសេចក្តីថា ហេតុណាជាហេតុចេញចាកនៃធម៌ណា ហេតុនោះ រមែងជាបដិបក្ខដោយត្រង់ចំពោះធម៌នោះតែម្តង ។ ប្រៀបដូចជានេក្ខម្មៈ ជាហេតុចេញចាកកាមទាំងឡាយ អរូបជាហេតុចេញចាកនៃរូបទាំងឡាយ ព្រះនិព្វានជាហេតុចេញចាកសង្ខារទាំងឡាយ យ៉ាងណា មេត្តា ករុណា និងមុទិតាក៏ជាហេតុចេញចាកនៃព្យាបាទ វិហិង្សា និងអរតិ ដែលប្រព្រឹត្តទៅរួមនឹងទោមនស្ស ក៏យ៉ាងនោះ ទើបមិនជាធម្មជាតិដែលវៀរចាកសោមនស្ស ។ និងដោយស័ព្ទថា **ជាហេតុចេញចាកនោះឯង** គប្បីឃើញថា លោកអាចារ្យឃើញត្រូវសូម្បី ភាពដែលអប្បមញ្ញា ៣ មានមេត្តាជាដើមនោះ ដែលជាចំណែកខាងដើមប្រកបរួមគ្នានឹងឧបេក្ខា ដោយភាវៈមិនជាហេតុចេញចាក ។ ពិតហើយ អាចារ្យទាំងឡាយ ត្រូវការការប្រព្រឹត្តទៅនៃករុណា និង មុទិតាក្នុងចិត្តុប្បាទ ២៨ ដួង ( មហាកុសលចិត្ត ៨ , មហាកិរិយាចិត្ត ៨ , រូបាវចរចិត្ត ១២ ) ។ មាតិកាថាពិតណាស់ ឧបេក្ខាដែលជាព្រហ្មវិហារ មិនប្រព្រឹត្តទៅដោយវៀរឧបេក្ខាវេទនា ក៏ដូចគ្នានឹងបារិសុទ្ធិឧបេក្ខា ព្រោះថា ក្នុងកាលណាក៏ដោយបារិសុទ្ធិឧបេក្ខា រមែងមិនប្រព្រឹត្តទៅដោយវៀរវេទនាដែលជាឧបេក្ខាឡើយ ។

ពាក្យថា **ដែលសហគតៈដោយសាតៈ ( សម្រាន្ត )** គឺ សហគតៈដោយសុខ ។ ពាក្យថា **ព្រោះដូច្នោះ** មានសេចក្តីថា ព្រោះហេតុដែលភាវៈនៃអប្បមញ្ញា

ទាំង ៤ ជាសមាធិសហគតៈដោយឧបេក្ខាវេទនាបាន ក៏ប្រាកដទៅតាមទេសនា ដែលថា ម្នាលភិក្ខុ កាលនោះអ្នកគប្បីចម្រើនសមាធិនេះ ដូច្នេះជាដើម ដូចគ្នា នឹងការៈដែលជាសមាធិ មានវិតក្កជាដើមដូច្នោះ ។ ពាក្យថា **អប្បមញ្ញាទាំង ៤ ជាចតុក្កឈានិកា ឬបញ្ចកឈានិកា** ជាពាក្យអធិប្បាយរបស់អាចារ្យអ្នកជំទាស់ ។ ពាក្យថា **ព្រោះថា កាលបើដូច្នេះ** អធិប្បាយថា ប្រសិនបើលោកដាក់អត្ថន័យ ដែលត្រាស់ទុកក្នុងមូលសមាធិចូលទៅ ក្នុងមូលព្រហ្មវិហារ ព្រោះភាពជាអត្ថន័យ ដែលត្រាស់ទុកជាប់តគ្នាទៅសោត កាលបើយ៉ាងនេះ ភាវនាទាំងឡាយ មាន កាយានុបស្សនាជាដើម ក៏គប្បីជាចតុក្កឈានិកា ឬបញ្ចកឈានិកាបាន , តែក៏កើត មិនបាន ព្រោះទ្រង់សម្តែងទុកដោយទាក់ទងនឹងវិបស្សនា លោកអាចារ្យសង្ស័យថា មនុស្សខ្វះគប្បីពោលថា កាយានុបស្សនាជាដើម ក៏ជាចតុក្កឈានិកា ឬ បញ្ចក-ឈានិកាបាន ដោយទាក់ទងនឹងពួកអានាបានភាវនា ដូច្នេះ ទើបពោលថា ក្នុងវេទនានុបស្សនាជាដើម ដូច្នេះជាដើម ។ ពាក្យថា **កុំបានកាន់យកត្រឹមស្រមោល នៃព្យញ្ជនៈ** មានសេចក្តីថា ចិត្តសមាធិទ្រង់ប្រកាសហើយដោយព្យញ្ជនៈទាំងឡាយ ថា **មេត្តាចេតោវិមុត្តិ** នឹងជាភាវនាដែលយើងធ្វើឲ្យកើតបានជាដើម ទ្រង់ប្រកាស ទុកដោយព្យញ្ជនៈទាំងឡាយថា ចិត្តរបស់យើងនឹងតាំងនៅខាងក្នុងជាដើម ព្រោះ ដូច្នោះ កុំបានកាន់យកត្រឹមស្រមោលរបស់សមាធិដែលបានដោយព្យញ្ជនៈ គឺ កុំ បានកាន់យកពាក្យអធិប្បាយដែលបាននៅក្នុងទីទាំង ២ ។ បុគ្គលកាលពោលដល់ អត្ថនៃព្រះសូត្រ ទៅដោយប្រការដទៃ ព្រោះភាពដែលពោលទៅដោយប្រការដទៃ ក៏រមែងជាអ្នកឈ្មោះថា ពោលបង្កាច់ព្រះសាស្តា ។ ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា លោកកុំពោលបង្កាច់ព្រះមានព្រះភាគឡើយ ដូច្នេះ ។

លោកអាចារ្យកាលនឹងសម្ដែងថា ភិក្ខុដែលប្រាថ្នានឹងចៀសវាងការភ្លេចភ្លាំងក្នុងសេចក្ដីនេះនោះ មិនគួរកាន់យកព្រះសូត្រគ្រប់សូត្រ ដែលបានណែនាំអត្ថទុកប៉ុណ្ណោះទេ ព្រោះដូច្នោះ គួរស្វែងរកពាក្យអធិប្បាយអំពីវង្សគ្រូ ដូច្នេះលោកពោលថា ព្រោះថាព្រះពុទ្ធវចនៈជារបស់ជ្រាលជ្រៅដូច្នេះជាដើម ហើយបំណងសម្ដែងពាក្យអធិប្បាយចាប់ផ្ដើមអំពីដើមក្នុងព្រះពុទ្ធវចនៈនោះ ទើបពោលថា ពាក្យអធិប្បាយក្នុងព្រះពុទ្ធវចនៈនោះ មានដូចតទៅនេះ ដូច្នេះជាដើម ។

ភិក្ខុឈ្មោះថា **អាយាចិតធម្មទេសនា** ព្រោះអត្ថថា ទូលអង្វរឲ្យទ្រង់សម្ដែងធម៌ បានដល់ ភិក្ខុដែលទូលអង្វរឲ្យទ្រង់សម្ដែងធម៌អង្គនោះ ។ ពាក្យថា **ឯវមេវ** ( ក៏ជាយ៉ាងនេះឯង ) ជានិបាតស័ព្ទក្នុងអត្ថថា តិះដៀល មានសេចក្ដីថា **មុធាឯវ** ( ខុសទទេនោះឯង ) ។ ពាក្យថា **ក្នុងខាងក្នុង** គឺ ក្នុងអារម្មណ៍ខាងក្នុង មានសេចក្ដីថា ក្នុងអារម្មណ៍ដែលជាកម្មដ្ឋាន ។ ព្រោះហេតុ ដែលបានឈ្មោះថាឯកគ្គតានៃចិត្តជារបស់ដែលទាក់ទងនៅក្នុងការបន្ត ( នៃខន្ធ ) របស់ខ្លួន ដូច្នោះក្នុងពាក្យពណ៌នាអត្ថ លោកទើបពោលថា ដោយទាក់ទងនឹងរបស់ខាងក្នុង ទាក់ទងនឹងខ្លួន ដូច្នេះ ។ ពាក្យថា **ចិត្ត ( របស់យើង ) នឹងតាំងនៅ** មានសេចក្ដីថានឹងតាំងនៅដោយភាវៈដែលមានអារម្មណ៍ ១ មិនរាយមាយទៅខាងក្រៅ ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា នឹងតាំងមាំ មានសេចក្ដីថា នឹងតាំងមាំស្មើដោយល្អ ។ ពាក្យថា **ដែលកើតឡើងហើយ** គឺ គ្របសង្កត់មិនទាន់បាន ។ បទថា **បាបកា** ប្រែថា ដែលអាក្រក់ ។ ពាក្យថា **អកុសលធម៌ទាំងឡាយ** បានដល់ ធម៌ទាំងឡាយ មានកាមច្ឆន្ទៈជាដើម , ដែលឈ្មោះថា **អកុសល** ព្រោះអត្ថថា កើតអំពីការមិនឆ្លាត ។ មានពាក្យប្រកបសេចក្ដីថា ហើយនឹងមិនតាំងនៅ គ្របសង្កត់ចិត្ត

គឺ ធ្វើកុសលចិត្តឲ្យអស់ទៅ ដោយការមិនឲ្យឱកាសដើម្បីការប្រព្រឹត្តទៅ ដោយពាក្យនេះ លោកពោលដល់ហេតុនៃការតាំងមាំរបស់ចិត្តតាមដែលពោលមកហើយ ។

ពាក្យថា **ត្រឹមតែជាឯកគ្គតានៃចិត្ត** បានដល់ ការតាំងមាំដោយប្រពៃនៃចិត្តដែលព្រះយោគីអ្នកបំពេញភាវនា ទើបតែបានសម្រេច មិនទាន់ចម្រើនបានល្អ ។ ការតាំងមាំដោយប្រពៃនោះ ជាសមាធិដែលលោកហៅថា មូលសមាធិ ព្រោះភាពជាមូលហេតុនៃសមាធិវិសេសទាំងឡាយ ដែលនឹងពោលដល់តទៅ ។ សមាធិដែលឈ្មោះថា ត្រឹមតែជាឯកគ្គតានៃចិត្តនេះនោះ លោកបំណងយកខណិកសមាធិ ដូចជាក្នុងប្រយោគថា យើងនឹងធ្វើចិត្តឲ្យតាំងមាំនៅក្នុងខាងក្នុងប៉ុណ្ណោះ នឹងធ្វើឲ្យស្ងប់ នឹងធ្វើឲ្យជាឯកោទិ ( ជាធម៌ឯកផុតឡើង ) ធ្វើឲ្យតាំងមាំស្មើដូច្នេះជាដើម ។ ពិតណាស់ សូម្បីក្នុងទីដទៃ ឯកគ្គតានៃចិត្តដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីព្យាយាមដែលតថាគតបានប្រារព្ធហើយមិនធូរថយ ។ល។ ចិត្តក៏តាំងមាំស្មើ ជាឯកគ្គៈ ( មានអារម្មណ៍តែមួយ ) ដូច្នេះ ហើយត្រាស់ទុកមុន ព្រោះព្រះបាលីថា **វិវិច្ចេវ កាមេហិ** ជាដើម បណ្ឌិតរមែងដឹងថា ជាខណិកសមាធិយ៉ាងណា , សូម្បីក្នុងទីនេះក៏យ៉ាងនោះៗឯង ។ ដោយពាក្យថា គួរចម្រើនសមាធិនោះ យ៉ាងនេះ ត្រាស់ដល់មូលសមាធិ ។

បទថា **អស្ស** ប្រែថា ដល់ភិក្ខុនោះ , ឬប្រែថា នៃមូលសមាធិនោះ ។ បទថា **ភាវនំ** ប្រែថា ការចម្រើន ។ ពាក្យថា សមាធិនេះ ទ្រង់បំណងយកមូលសមាធិនោះឯង ។ ពាក្យថា **ចម្រើនបានយ៉ាងនេះហើយ** លោកពោលទុក ព្រោះធ្វើអធិប្បាយថា ប្រៀបដូចជាភ្លើងដែលបុគ្គលប្រើឈើកួតៗ ឲ្យកើតឡើងពង្រីកខ្ទួន ( ជាគំនរភ្លើងធំ ) ឡើងបានដោយលម្អិតអាចម៍គោជាដើម សូម្បីថាដល់នូវភាព

ជាភ្លើងដែលកើតអំពីអាចម៍គោជាដើមហើយ គេក៏នៅហៅថា មូលភ្លើង ដែលបុគ្គលប្រើឈើក្ដួតៗ ឲ្យកើតឡើងនោះឯង យ៉ាងណា , សូម្បីក្នុងទីនេះ សមាធិដែលភិក្ខុចម្រើនហើយ ដោយទាក់ទងនឹងព្រហ្មវិហារ មានមេត្តាជាដើម ក៏នៅឈ្មោះថា មូលសមាធិ នោះឯង ដូច្នោះ ។

ឈ្មោះថា **ក្នុងអារម្មណ៍យ៉ាងដទៃ** គឺក្នុងអារម្មណ៍ទាំងឡាយ មានបឋវីកសិណជាដើម ។ ក្នុងពាក្យនោះ ត្រាស់ដល់ការចម្រើនមូលសមាធិ ដោយវិធីធ្វើឲ្យសម្រេចឈាន ៤-៥ ក្នុងអារម្មណ៍ទាំងឡាយ មានបឋវីកសិណជាដើម ដោយទាក់ទងនឹងឈាន មានវិតក្កជាដើម តាមន័យនៃការចម្រើន ដែលមានមេត្តាភាវនាជាខាងដើម យ៉ាងណា , ព្រះមានព្រះភាគទ្រង់សម្ដែងវិធីចម្រើន សូម្បីក្នុងអារម្មណ៍ទាំងឡាយ មានបឋវីកសិណជាដើម ដែលមានករុណាភាវនាជាដើម ជាខាងដើមហើយ កាលនឹងទ្រង់សម្ដែងវិធីចម្រើន ដែលមានកាយានុបស្សនាជាដើម ជាខាងដើមបន្ទាប់តទៅ ទើបទ្រង់សម្ដែងធម៌ដើម្បីការអស់ទៅនៃអាសវៈដូច្នេះ ។ ព្រោះហេតុនោះ ទើបត្រាស់ថា ករុណាចេតោវិមុត្តិនឹងជាភាវនាដែលតថាគតធ្វើឲ្យកើតបាន ដូច្នេះជាដើម ។ សួរថា ប្រសិនបើយ៉ាងនេះ ព្រោះហេតុអ្វី ( ក្រោយអំពីការត្រាស់ការចម្រើនធម្មានុបស្សនាហើយ ) ទើបត្រាស់ថា ម្នាលភិក្ខុ កាលនោះអ្នកគប្បីចម្រើនសមាធិនេះ ដែលមានវិតក្កខ្លះ ដូច្នេះជាដើមទុកទៀតវិញ ព្រោះភាពដែលព្រះធម៌ទេសនាចប់ត្រឹមធម្មានុបស្សនា ក៏ជាហេតុឲ្យត្រាស់ដល់កម្មដ្ឋានដើម្បីការសម្រេចព្រះអរហត្តហើយឬ ? ឆ្លើយថា ត្រាស់ពាក្យនោះទុកទៀត ក៏ដើម្បីសម្ដែងការដល់កំពូលនៃធម្មានុបស្សនា ។ ពិតណាស់ ធម្មានុបស្សនានោះ កាលប្រព្រឹត្តទៅដោយភាពជាសង្ខារុបេក្ខាញាណ ពិចារណានូវឈានធម៌ទាំងឡាយតាម

ដែលពោលហើយ ក៏ឈ្មោះថា ជាធម្មជាតិដែលដល់កំពូលហើយដោយពិសេស ។ អាចារ្យពួកខ្លះពោលថា ត្រាស់ទុកទៀត ដើម្បីនឹងទ្រង់សម្ដែងភូមិនៃផលរបស់សមាធិ ដូច្នេះ ។

មាតិកាថា **យតោ ខោ តេ** ដូច្នេះជាដើម ប្រការមួយទៀត ជាខសម្ដែងការនៅជាសុខដែលភិក្ខុគប្បីបានទទួល ក្រោយអំពីការសម្រេចព្រះអរហត្ត ។ ក្នុងប្រការនោះ បទថា **គច្ឆសិ** ប្រែថា នឹងដើរទៅ ។ ពាក្យថា **ព្រោះដូច្នោះ** មានសេចក្ដីថា ព្រោះហេតុដែលព្រះធម៌ទេសនាថា **សវិតក្កម្បិ** ( គប្បីចម្រើនសមាធិនេះដែលមានវិតក្កខ្លះ ) ជាដើម ត្រាស់សំដៅយកសមាធិក្នុងអារម្មណ៍ដទៃអំពីអារម្មណ៍របស់មេត្តាជាដើម , មិនបានត្រាស់សំដៅយកអប្បមញ្ញា ដូច្នោះទេ ។ ដោយពាក្យថា ( ទ្រង់ចែកទុក ) យ៉ាងនោះដូចគ្នា នេះលោកអាចារ្យធ្វើអធិប្បាយនោះៗឯង ឲ្យមាំមួនស្នូម្បីដោយគម្ពីរដទៃ ។ ក្នុងពាក្យនោះ ពាក្យថា **យ៉ាងនោះដូចគ្នា** គឺ ដោយអំណាចនៃឈាន ៣-៤ ដូចគ្នា ។ ពាក្យថា **ក្នុងព្រះអភិធម្ម** គឺ ក្នុងធម្មសង្គណីចិត្តុប្បាទកណ្ឌ និង ក្នុងអប្បមញ្ញាវិភង្គជាដើម ដែលជាចំណែកនៃគម្ពីរព្រះអភិធម្មនោះៗ ។

**សុភ** ស័ព្ទ ក្នុងបទថា **សុភបរមាទិវិសេន** ( ដោយទាក់ទងនឹងអប្បមញ្ញាដែលមានសុភវិមោក្ខយ៉ាងក្រៃលែង ) ព្រះអង្គត្រាស់ទុកដោយលុបបទចុង ( គឺ បទថា **វិមោក្ខ** ) សំដៅយកសុភវិមោក្ខដែលត្រាស់ទុកយ៉ាងនេះថា រមែងជាអ្នកមានចិត្តបង្អោនទៅថាស្អាតនោះឯង ដូច្នេះ ។ **បរម** ស័ព្ទ មានអត្ថថា ឧត្តម ។ មេត្តាចេតោវិមុត្តិ ឈ្មោះថា **សុភបរមា** ព្រោះអត្ថថា **មានសុភ** គឺ សុភវិមោក្ខដ៏យ៉ាងក្រៃលែង គឺ ឧត្តម បានដល់ ជាទីបំផុតយ៉ាងក្រៃលែង មានន័យថា

សម្រាប់មេត្តាចេតោវិមុត្តិនោះ ប្រយោជន៍ដែលគប្បីធ្វើឲ្យសម្រេចដទៃអំពីសុភវិមោក្ខនោះ មិនមាន ។ ព្រោះទ្រង់បំណងយកប្រយោជន៍ដែលមិនជាសាធារណៈ ទើបមិនត្រាស់ដល់ប្រយោជន៍ មានវិបស្សនាសុខ ( ជាគ្រឿងឲ្យការងាយស្រួលដល់ការចម្រើនវិបស្សនា ) ជាដើម ។ ក៏ក្នុងបណ្តាអប្បមញ្ញាទាំងនេះ អានុភាពពិសេសទាំងនេះ សូម្បីត្រឹមតែម្យ៉ាងក៏មិនដូចគ្នា , គឺ ខុសប្លែកអំពីអានុភាពក្រៅអំពីនេះ , នឹងពោលថ្វីថា នឹងមិនខុសប្លែកអំពីអានុភាពដទៃទាំងឡាយនោះ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា គប្បីជ្រាបថា មានអានុភាពពិសេសដែលមិនដូចគ្នានិងគ្នា ដូច្នេះ ។ ពាក្យថា **ដោយទ្រង់ធ្វើឲ្យផ្សេងគ្នា** គឺ ទ្រង់ធ្វើឲ្យខុសប្លែកគ្នានិងគ្នា ។

ពាក្យថា **ព្រោះអប្បមញ្ញាទាំងនោះជាឧបនិស្ស័យនៃវិមោក្ខនោះៗ** គឺ ព្រោះអប្បមញ្ញាទាំងនោះជាឧបនិស្សយប្បច្ច័យ គឺបកតូបនិស្សយប្បច្ច័យដល់វិមោក្ខនោះៗ មានសុភវិមោក្ខជាដើម ។ ឥឡូវនេះ ដើម្បីនឹងសម្តែងអត្ថន័យនោះឲ្យជាក់ច្បាស់ក្រៃលែងឡើង លោកអាចារ្យទើបពោលថា សម្រាប់ភិក្ខុដែលជាមេត្តាវិហារី ដូច្នេះជាដើម ។ ភ្ជាប់សេចក្តីថា កាលលោក គឺ ភិក្ខុដែលជាមេត្តាវិហារីបង្អោនចិត្តទៅៗ ពាក្យថា **ព្រោះមានការធ្លាប់កាន់យកអារម្មណ៍ដែលមិនបដិកូល** មានសេចក្តីថា ព្រោះការទម្លាប់ចំពោះការកាន់យកដោយអាការដែលមិនជាបដិកូល ( មិនគួររង្កៀស ) ក្នុងអារម្មណ៍ឯណានីមួយដែលសម្គាល់ថាជាសត្វ ដោយអំណាចនៃមេត្តាភាវនានោះឯង ។ អារម្មណ៍ឯណានីមួយ សូម្បីថា ជាសង្ខារ ( មិនមែនសត្វ ) ក៏ប្រាកដដល់ភិក្ខុនោះ ដោយអាការដែលមិនជាបដិកូលដូចគ្នា , នឹងពោលទៅថ្វីដល់អារម្មណ៍ដែលមិនជាបដិកូលដោយសភាវៈស្រាប់ហើយនោះ ។ ចិត្តរបស់

ភិក្ខុនោះ រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍នោះថា មិនជាបដិកូល ដោយមិនមានការសន្និះសង្ស័យ ដោយអំណាចសេចក្តីត្រេកអរក្រៃលែង , និងរមែងផុតចាកធម៌ដែលជាសត្រូវទាំងឡាយបានដោយងាយ និងដោយល្អ ដែលបានន័យថា ជាវិមោក្ខនៃឈាននោះ ដែលព្រះមានព្រះភាគបានត្រាស់ទុក ។ ព្រោះហេតុនោះលោកអាចារ្យទើបពោលថា **អប្បដិកូលេសុ** ( កាលលោកបង្អោនចិត្តទៅ... ដែលជាពណ៌បរិសុទ្ធ មិនបដិកូល ) ដូច្នេះជាដើម ។ អធិប្បាយតាមដែលពោលហើយ បណ្ឌិតគប្បីជាក់ច្បាស់ដោយន័យផុយ ក្នុងការដែលបុគ្គលធ្វើអាឃាត ឲ្យកើតឡើងក្នុងអារម្មណ៍ដែលមានចេតនា ( គឺ សត្វដែលមានចិត្ត ) ដោយបំណងធ្វើឲ្យគេដល់នូវសេចក្តីវិនាសជាដើម ទាល់តែមានការស្និទ្ធស្នាលក្នុងអារម្មណ៍ ដែលជាបដិកូល ( គឺ ក្នុងសត្វដែលខ្វះមិនពេញចិត្ត ) ក៏កើតសេចក្តីអាឃាតបាន សូម្បីក្នុងអារម្មណ៍ដែលមិនមានចេតនា ( គឺ វត្ថុដែលមិនមានជីវិត ) មានខ្យល់ ពន្លឺថ្ងៃជាដើម ។ ពាក្យថា **មិនក្រៃលែងជាងសុភវិមោក្ខនោះ** មានន័យថា មិនជាឧបនិស្ស័យនៃវិមោក្ខណាៗ ដែលក្រៃលែងជាងសុភវិមោក្ខនោះ ។

ឈ្មោះថា **អភិឃាតោ** ព្រោះអត្ថថា ជាគ្រឿងវាយដំ , រូបដែលមានដំបងជាគ្រឿងវាយ ឈ្មោះថា **ទណ្ឌាភិឃាតំ** , រូបដែលមានដំបងជាគ្រឿងវាយដំជាដើម ឈ្មោះថា **ទណ្ឌាភិឃាតាទិ** , ទុក្ខដែលមានរូប មានដំបងជាគ្រឿងប្រហារជាដើមជាហេតុ ឈ្មោះថា **ទណ្ឌាភិឃាតាទិរូបនិមិត្តំ** ប្រែតាមវចនត្ថៈនេះហើយលំបាកស្តាប់ , សូមប្រែឲ្យស្តាប់ងាយឡើងថា ( ទុក្ខដែលមានរូបជាហេតុ មានការត្រូវវាយដំដោយដំបងជាដើម ) ។ លោកអាចារ្យធ្វើពាក្យសាកសួរទុកក្នុងចិត្តថា ទុក្ខនោះបានដល់អ្វី ដូច្នេះហើយ ទើបពោលថា បានដល់ ទុក្ខរបស់សត្វ

មានសេចក្តីថា ទុក្ខដែលកើតឡើងដល់សត្វទាំងឡាយ ដែលមានការប្រទូស្តដោយដំបងជាដើម ធ្វើឲ្យកើតឡើង មានករជរូបជាហេតុ ។ អធិប្បាយថា ទោសក្នុងរូបឈ្មោះថា កិក្ខុដែលជាករុណាវិហារី ដឹងបានល្អហើយ ព្រោះទុក្ខរបស់សត្វ មានរូបជាហេតុ , ព្រោះករុណារបស់លោកមានការអត់ធន់នឹងទុក្ខរបស់អ្នកដទៃមិនបានជារស ។ បទថា **តត្ថ** ប្រែថា ក្នុងអាកាស ។ ឈ្មោះថា ចិត្តក៏រមែងស្ទុះទៅ គឺស្ទុះទៅក្នុងអាកាស ដែលលោកពោលថាជាការមិនមាន គឺ ភាពទទេ ភាពប្រាសទៅនៃរូបទាំងឡាយដោយប្រការទាំងពួង ដូច្នេះ ។

តទៅនេះជាពាក្យប្រកបសេចក្តីក្នុងពាក្យថា **ព្រោះហេតុនៃការត្រេកអរនោះៗជាដើម** មានសេចក្តីថា សម្រាប់ព្រះយោគីដែលសម្លឹងឃើញរឿយ ៗ នូវវិញ្ញាណដែលត្រេកអរ ដែលកើតឡើងហើយរបស់សត្វទាំងឡាយ ដែលកំពុងត្រេកអរព្រោះហេតុត្រេកអរ មានភោគសម្បត្តិជាដើមនោះៗ ចិត្តរមែងជាធម្មជាតិដែលស្ទិទ្ធស្ទាលក្នុងការកាន់យកវិញ្ញាណ ដោយការដែលឃើញវិញ្ញាណត្រេកអរតាមដែលជាហេតុនៃការប្រព្រឹត្តទៅរបស់មុទិតាថា សាធុ សត្វនេះត្រេកអរហ្ន៎ ដូច្នេះ ។

ពាក្យថា **ដែលបានសម្រេចហើយតាមលំដាប់** គឺ ដែលបានសម្រេចហើយដោយភាវនា ដែលប្រព្រឹត្តទៅដើម្បីការប្រាសចាកតម្រេកក្នុងរូប ( រូបវិរាគភាវនា ) តាមលំដាប់នៃការសម្រេចរូបាវចរជ្ឈាន ក្នុងកសិណឯណានីមួយ វៀរអាកាសកសិណ ។ វិញ្ញាណ ឈ្មោះថា **អាកាសនិមិត្តគោចរំ** ព្រោះអត្ថថា មានអាកាសនិមិត្តជាអារម្មណ៍ បានដល់ ( បង្អោនចិត្តទៅ ) ក្នុងអរូបវិញ្ញាណទី ១ ដែលមានអាកាសនិមិត្តជាអារម្មណ៍នោះ ។ ពាក្យថា **បង្អោនចិត្តទៅ** គឺ ធ្វើភាវនាចិត្តឲ្យកើតឡើង ដើម្បីការសម្រេចអរូបវិញ្ញាណទី ២ មានសេចក្តីថា ធ្វើឲ្យកើតដោយ

ប្រការនោះ ។ ពាក្យថា **ក្នុងវិញ្ញាណនោះ** គឺ ក្នុងអរូបវិញ្ញាណទី ១ នោះ ។ ពាក្យថា **ចិត្ត** គឺ វិញ្ញាណញ្ចាយតនចិត្ត ។ ពាក្យថា **រមែងស្ទុះទៅ** គឺ រមែងតាមចូលទៅ បានដល់ ដល់អប្បនាដោយភាពជាវិមោក្ខ ។

ពាក្យថា **ព្រោះមិនមានការជញ្ជឹង** គឺ ព្រោះមិនមានការជញ្ជឹងទាក់ទងនឹងការសង្ឃឹមដល់សេចក្តីសុខជាដើម ដោយន័យថា សូមជាអ្នកដល់នូវសេចក្តីសុខចុះ ដូច្នេះជាដើម ។ ភាវនា ៣ មានមេត្តាជាដើម ដែលប្រព្រឹត្តទៅដោយទាក់ទងនឹងការសង្ឃឹមដល់សេចក្តីសុខជាដើម ដល់សត្វទាំងឡាយ រមែងធ្វើសត្វទាំងឡាយឲ្យជាអារម្មណ៍ដោយការកាន់យកបរមត្ថធម៌ ( វត្ថុដែលមានពិត គឺ សេចក្តីទុក្ខ សេចក្តីសុខរបស់សត្វ ) ជាគន្លង តែឧបេក្ខាភាវនាមិនបានប្រព្រឹត្តទៅយ៉ាងនោះ រមែងធ្វើសត្វទាំងឡាយឲ្យជាអារម្មណ៍ ដោយទាក់ទងនឹងការព្រងើយកន្តើយតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា សម្រាប់ភិក្ខុដែលជាឧបេក្ខាវិហារី មានចិត្តជាធម្មជាតិដែលលំបាកចំពោះការមិនកាន់យកវត្ថុដែលមិនមាន ដោយភាវៈដែលបែរមុខចំពោះការកាន់យកសុខ និង ទុក្ខជាដើមដែលជាបរមត្ថ ដូច្នេះ ។ សួរថា សូម្បីឧបេក្ខាព្រហ្មវិហារ ក៏រមែងធ្វើសត្វទាំង-ឡាយឲ្យជាអារម្មណ៍ដោយការកាន់យកបរមត្ថធម៌ ( គឺ កម្មរបស់សត្វ ) ជាគន្លងដូចគ្នា សូម្បីដោយអំណាចនៃការបដិសេធ ( មិនជាប់ជំពាក់ ) ដោយន័យថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន សត្វទាំងនោះនឹងជាអ្នកដល់នូវសេចក្តីសុខ ឬជាអ្នកដល់នូវសេចក្តីទុក្ខ ក៏តាមការពេញចិត្តរបស់កម្ម ដូច្នេះជាដើម មិនមែនឬ ? ឆ្លើយថា ដែលពោលមកនេះ ជាសេចក្តីពិត តែប្រការនោះនឹងមានបានក្នុងចំណែកខាងដើមនៃភាវនា , ចំណែកក្នុងវេលាដែលភាវនាដល់កំពូលហើយ រមែងធ្វើសត្វ

ទាំងឡាយឲ្យជាអារម្មណ៍ដោយទាក់ទងនឹងភាពព្រងើយកន្តើយ តែម៉្យាងប៉ុណ្ណោះ ព្រោះហេតុនោះ ឧបេក្ខាព្រហ្មវិហារនោះ ទើបមានការប្រព្រឹត្តទៅក្នុងអារម្មណ៍ដែលមិនមានប្រាកដដោយបរមត្ថប៉ុណ្ណោះ យ៉ាងពិសេស ។ ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាប ភាពជាចិត្តដែលលំបាកចំពោះការមិនកាន់យកវត្ថុដែលមិនមាន ប្រាកដដោយបរមត្ថបាន ក៏ដោយភាពជាចិត្តដែលដល់កំពូល ក្នុងការកាន់យកសត្វ ដោយមិនបោះចំពោះ ដើម្បីការសម្រេចអប្បនា ដោយអំណាចការព្រងើយកន្តើយ ។ ពាក្យដ៏សេស ក៏មានន័យដូចបានពោលហើយនោះឯង ។

បទថា **សព្វាបេតា** ប្រែថា អប្បមញ្ញាទាំងនេះ សូម្បីទាំងអស់ ។ ពាក្យថា ( **កល្យាណធម៌ទាំងឡាយ** ) មានទានជាដើម បានដល់ ធម៌ទាំងឡាយដែលសាងភាពជាព្រះពុទ្ធ មានទានជាដើម ដែលដល់ភាពជាបារមី ។ ពាក្យថា កល្យាណធម៌ទាំងពួង បានដល់ ធម៌ដែលរកទោសមិនបានទាំងពួង គឺ បារមី ៣០ និងធម៌ទាំងឡាយ ដែលជាយានជំនិះរបស់ព្រះពុទ្ធ មានបារមី ៣០ នោះជាហេតុ , ឬថា បានដល់ ធម៌ដែលសភាវៈល្អស្អាតជាងធម៌ទាំងពួង ។ ពិតណាស់ លោកិយធម៌ទាំងឡាយ ឈ្មោះថា ឧត្តមជាងធម៌ទាំងឡាយ ដែលសាងភាពជាព្រះពុទ្ធជាម្ចាស់ដោយអានុភាពក៏ទេ , ក្នុងពុទ្ធធម៌ ( ធម៌ដែលកើតចំពោះព្រះសម្ពុទ្ធ ) ទាំងឡាយ មិនមានពាក្យដែលនឹងត្រូវពោលដល់គ្នាឡើយ ។ បទថា **បរិបូរិកា** កែជា **បារិបូរិកា** ( ប្រែថា ដែលធ្វើឲ្យបរិបូណ៌ ) ។ ពិតណាស់ **អប្បមញ្ញាទាំងឡាយ** ឈ្មោះថា ជាធម៌ដែលធ្វើបារមីទាំងពួងឲ្យបរិបូណ៌ ដូចជាទីតាំងមាំ ។ ដោយពាក្យថា ដោយភាពដែលមានអជ្ឈាស្រ័យឧបការៈជាដើម លោកអាចារ្យសម្តែងសេចក្តីនេះថា ព្រះមហាពោធិសត្វទាំងឡាយ ទ្រង់ជាអ្នកដែលអាចធ្វើព្រះ

បារមីទាំងឡាយ មានទានជាដើមឲ្យពេញប្រៀបបាន ព្រោះព្រះអង្គទ្រង់បានតាក់តែងព្រះសន្តាន របស់ព្រះអង្គឯងទុកមុនហើយដោយអប្បមញ្ញា ៤ មិនមែនដោយប្រការដទៃ ដូច្នេះ ដោយការសម្តែងការៈដែលព្រហ្មវិហារ ៣ ខាងដើម មានមេត្តាព្រហ្មវិហារជាដើម ជាទីតាំងនៃឧបេក្ខាព្រហ្មវិហារ ។ ពាក្យថា **វត្ថុនេះ គួរឲ្យដល់បុគ្គលនេះ មិនគួរឲ្យដល់បុគ្គលនេះ** គប្បីឃើញថា ត្រឹមតែជានិទស្សនៈ ព្រោះនៅមានពាក្យដែលគួរ ពោលថា មិនធ្វើការបែកថា វត្ថុនេះគួរឲ្យ វត្ថុនេះមិនគួរឲ្យដូច្នេះទៀតផង ។ ពិតណាស់ ទានបារមីជាគុណជាតិដែលវៀរប្រការកំណត់នៃទេយ្យធម៌ និងបដិគ្គាហកៈ ( គឺ មិនជ្រើសរើស ) ។ ដូចដែលទ្រង់ត្រាស់ទុកថា ៖

**ប្រៀបដូចឆ្នាំងទឹកដែលពេញប្រៀប ត្រូវបុគ្គលណាមួយផ្កាប់ចុះហើយ ទឹករមែងហូរចេញអស់ មិនមានដក់នៅក្នុងឆ្នាំងនោះដូច្នោះ ដូច្នេះជាដើម ។**

បទថា **សព្វសត្តានំ** ( ដល់សត្វទាំងឡាយទាំងពួង ) នេះ គប្បីភ្ជាប់ចូលសូម្បីនឹងបទថា **សុខនិទានំ** ( ដែលជាហេតុនៃសេចក្តីសុខ ) និងជាមួយបទថា **ទេន្តិ** ( ទ្រង់ឲ្យ ) នេះ ។ ដោយពាក្យនោះ គឺ លោកពោលដល់ភាពដែលព្រះមហាសត្វទាំងឡាយ ជាអ្នកមានឧបការៈច្រើនចំពោះសត្វលោក សូម្បីដោយទានធម៌ ( ការឲ្យ គឺ ដឹកនាំឲ្យជាអ្នកស្គាល់ទាន ) ដូចគ្នានឹងទេយ្យធម៌ ( របស់ដែលគួរឲ្យ ) , ព្រោះធ្វើសត្វលោកនោះឲ្យមានចិត្តបង្អោនទៅដោយប្រការនោះ ។ លោកអាចារ្យបំណងសម្តែងសេចក្តីប្រការនោះ សូម្បីពោលថា មិនធ្វើការបែកទើបបានពោលថា ដល់នូវសត្វទាំងឡាយទាំងពួង ដូច្នេះ ។ បទថា **តេសំ** បានដល់ សត្វទាំងឡាយទាំងពួង ។ សូម្បីក្នុងពាក្យថា **ឧបឃាតំ** ( ការប្រទូស្ត ) នេះ ក៏គួរនាំយកពាក្យថា **វិភាគំ អកត្វា** ( មិនធ្វើការបែក ) មកភ្ជាប់ផង ។

ពាក្យប្រកបបទក្នុងសេចក្តីនេះ មានដូចតទៅនេះ គឺ ទ្រង់វៀរចាកការប្រទូស្តសត្វទាំងនោះ សមាទានសីលដែលជាហេតុនៃសេចក្តីសុខដល់សត្វទាំងឡាយទាំងពួង ព្រោះមិនធ្វើការចែក ( កាល ) ដូច្នេះ ។ ព្រោះថា សីលបារមីជាគុណជាតិដែលវៀរចាកការកំណត់កាលវេលា ( ថានឹងសមាទានអស់កាលត្រឹមប៉ុណ្ណេះ នឹងឈប់សមាទានជាដើម ) ក្នុងសត្វ , និង ព្រះអង្គទ្រង់បង្អោនផលនៃការសមាទាននេះទៅ ដើម្បីប្រយោជន៍ដល់សត្វលោកប៉ុណ្ណោះ ។ ពាក្យថា **ទ្រង់សេពនេក្ខម្មៈ** គឺ ទ្រង់ចូលដល់ការបួស ។ ព្រោះថា សីលនឹងបរិបូណ៌បានដោយប្រការទាំងពួងសម្រាប់បុគ្គលដែលជាអ្នកបួស , មិនមែនសម្រាប់អ្នកដែលជាគ្រហស្ថទេ ។ សូម្បីក្នុងពីរបទថា **នេក្ខម្មំ ភជន្តិ** ( ទ្រង់សេពនេក្ខម្មៈ ) នេះ ក៏គប្បីនាំច្រើនបទថា **វិភាគំ អកត្វា សព្វសត្តានំ សុខនិទានំ** ព្រោះដូច្នេះ មកភ្ជាប់ផង ។ ពិតណាស់ ព្រះពោធិសត្វ ទាំងឡាយនឹងបានតាំងការបួសទុក ឬថា សមាទានសីលដោយធ្វើការចែកកាល ក៏ទេ ។ ប្រការដែលថា ទ្រង់សេពនេក្ខម្មៈ គឺ ការបួសនេះត្រឹមតែជានិទស្សនៈ ព្រោះបណ្ឌិតគង់ប្រាថ្នាសូម្បីការសេពនេក្ខម្មៈ មានឈានជាដើមបាន។ ភាពដែល ការសេពនេក្ខម្មៈនោះ ជាហេតុនៃសេចក្តីសុខដល់សត្វទាំងពួង មានន័យដូចខ្ញុំម្ចាស់បានពោលហើយក្នុងខាងដើមនោះឯង ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យដូច្នេះ ។ ពាក្យថា **ក្នុងវត្ថុដែលជាប្រយោជន៍ និងមិនជាប្រយោជន៍** គឺ ក្នុងវត្ថុ ដែលជាប្រយោជន៍ និង ជាហាយនភាព ។ ពាក្យថា **ដើម្បីប្រយោជន៍ដល់ការមិនវង្វេង** គឺ ដើម្បីកម្ចាត់សេចក្តីវង្វេង ។ ពាក្យថា **ទ្រង់ជម្រះព្រះបញ្ញាឲ្យបរិសុទ្ធ** មានសេចក្តីថា កាលទ្រង់ស្តាប់វិជ្ជាដែលធ្វើឲ្យសម្រេច បានឲ្យឧបាយជាដើម ដែលមិនធ្លាប់ស្តាប់ កាលទ្រង់ជម្រះវត្ថុដែលធ្លាប់បានស្តាប់ហើយឲ្យបរិសុទ្ធ

កាលទ្រង់កម្ចាត់អហង្ការ ( ការប្រកាន់ថាជាអញ ) និងមមង្ការ ( ការប្រកាន់ថាជារបស់អញ ) បានជាដើម ក៏ឈ្មោះថា ទ្រង់ជម្រះព្រះញាណឲ្យបរិសុទ្ធ ។ ព្រោះថា បញ្ញាបារមីជាគុណជាតិដែលវៀរចាកការប្រកាន់ថា យើង របស់យើង។ ពាក្យថា **ដើម្បីប្រយោជន៍ដល់វត្ថុដែលឧបការៈ និងសេចក្តីសុខ** គឺ ដើម្បីសេចក្តីចម្រើននៃវត្ថុដែលឧបការៈ និងសេចក្តីសុខជាដើមដល់សត្វទាំងឡាយតែម្យ៉ាង ។ ពាក្យថា **ជានិច្ច** គឺ ជាប្រចាំដោយមិនដាច់ខ្សែ បានដល់ មិនកម្រើកដោយធម៌ដែលជាបដិបក្ខ ។ ពាក្យថា **ទ្រង់ប្រារព្ធសេចក្តីព្យាយាម** គឺ ទ្រង់ធ្វើសេចក្តីព្យាយាមដែលប្រយោជន៍សុខ នៅមិនទាន់កើតឡើង ឲ្យកើតឡើងដល់សត្វទាំងឡាយដែលកើតឡើងហើយ ឲ្យចម្រើនក្រៃលែងឡើងទៅ ។ ព្រោះថា វីរិយបារមីជាគុណជាតិដែលវៀរចាកការរាយមាយទៅ ព្រោះការរួញរាចិត្ត ។ ដោយពាក្យថា ព្រះអង្គ សូម្បីទ្រង់ដល់នូវភាពជាអ្នកក្លាហាន នេះលោកអាចារ្យសម្តែងដល់ភាពដែលទ្រង់ជាអ្នកអាចក្នុងការគ្របសង្កត់សត្វទាំងឡាយដែលធ្វើខុស ។ ពាក្យថា **ទ្រង់អត់ធន់ចំពោះទោសមានប្រការផ្សេងៗ** គឺ ទ្រង់អត់ធន់ចំពោះទោសច្រើនប្រការដែលសត្វទាំងឡាយធ្វើឲ្យប្រព្រឹត្តទៅក្នុងព្រះអង្គ ដោយអាការដូចជាកម្ចាត់ចោលនូវសេចក្តីស្រឡាញ់ចំពោះគ្នា ។ ដោយថា ការអត់ធន់ចំពោះទោសដែលវៀរចាកការប្រកាន់ថា ជាខ្លួន ជាអ្នកដទៃ ជាខន្តិបារមី ។

ពាក្យថា **ទ្រង់មិនធ្វើការប្តេជ្ញាឲ្យឃ្លៀងឃ្លាត ដោយពាក្យពោលសាមញ្ញថា** មិនធ្វើឲ្យឃ្លៀងឃ្លាត លោកពោលដល់ធម៌ ដែលជាបដិបក្ខចំពោះហេតុនៃពាក្យពោលឡេះឡោះទាំងពួង ។ ព្រោះថា សច្ចបារមីជាគុណជាតិ ដែលវៀរចាកការកំណត់ត្រឡប់ត្រឡិនក្នុងវត្ថុ ដែលបានឃើញហើយជាដើម ដែលបានអះអាងថា

( ឃើញហើយជាដើម ) និងមិនបានអះអាងថា ( ឃើញហើយជាដើម ) ។ ពាក្យថា **ទ្រង់ជាអ្នកមានការតាំងចិត្តមាំ មិនញាប់ញ័រ** គឺ ទ្រង់ជាអ្នកមានចិត្តមាំទាំ មិនញាប់ញ័រក្នុងធម៌ទាំងឡាយ មានទានជាដើម តាមដែលទ្រង់សមាទានទុក ។ ការតាំងចិត្តក្នុងការសមាទានទុកមិនញាប់ញ័រ គឺ ការផ្តោតចិត្តយ៉ាងមាំទាំ ក្នុងធម៌ទាំងឡាយដែលសាងភាពជាព្រះពុទ្ធ ដែលទ្រង់សមាទានហើយនោះឯង ចាត់ជាអធិដ្ឋានបារមី ។ បទថា **តេសុ** ប្រែថា ក្នុងសត្វទាំងនោះ ។ ពាក្យថា ( **ដោយព្រះមេត្តា** ) **ដែលមិនមានការញាប់ញ័រ** គឺ ដែលធម៌ដែលជាបដិបក្ខ គប្បីធ្វើឲ្យញាប់ញ័រមិនបាន។ ពាក្យថា ( **ទ្រង់ធ្វើព្រះបារមីទាំងឡាយឲ្យពេញបរិបូណ៌ហើយ** ) **ដោយប្រការយ៉ាងនេះ** គឺ ដោយអាការមានភាពជាអ្នកមានអជ្ឈាស្រ័យ ឧបការៈក្នុងសត្វទាំងឡាយជាដើម តាមដែលពោលហើយ ។ ដូចជា បារមីទាំងឡាយជាគុណជាតិដែលមានព្រហ្មវិហារជាទីតាំងមាំ យ៉ាងណា , ក៏រមែងជាទីតាំងមាំនៃអធិដ្ឋានធម៌ទាំងឡាយក៏យ៉ាងនោះ ។

ពិតហើយ **សច្ចាធិដ្ឋាន** ( ទីតាំងមាំ គឺ សច្ចៈ ) រមែងមានបានដោយការដែលបារមីទាំងឡាយតាំងនៅបានរឿយៗ ដើម្បីការអនុគ្រោះអ្នកដទៃតាមដែលប្តេជ្ញាទុក , **ចាគាធិដ្ឋាន** ( ទីតាំងមាំ គឺ ចាគៈ ) រមែងមានបានដោយការលះបង់នូវធម៌ដែលជាបដិបក្ខចំពោះបារមីនោះ , **ឧបសមាធិដ្ឋាន** ( ទីតាំងមាំ គឺ ការចូលទៅស្ងប់ ) រមែងមានបានដោយការចូលទៅស្ងប់ចិត្តរបស់ខ្លួនដោយបារមីទាំងឡាយ , **បញ្ញាធិដ្ឋាន** ( ទីតាំងមាំ គឺ បញ្ញា ) រមែងមានបានដោយភាពជាបុគ្គលឆ្លាតឈ្លាសក្នុងឧបាយឧបការៈដល់អ្នកដទៃដោយបារមីទាំងឡាយនោះ ។ គប្បីនាំអធិដ្ឋានម្យ៉ាងៗទៅក្នុងបារមីទាំងឡាយតាមសមគួរយ៉ាងនេះចុះ ។ នេះជាការសង្ខេបក្នុងរឿងនេះ ,

ចំណែកពាក្យដែលគួរពោលដោយពិស្តារ ក្នុងបារមីទាំងឡាយណា បណ្ឌិតគប្បីជ្រាបពាក្យនោះ តាមន័យដែលខ្ញុំព្រះករុណាបានពោលទុកក្នុងអដ្ឋកថា បរមត្ថទីបនីដែលជាការពណ៌នាចរិយាបិដកនោះឯង ខ្ញុំព្រះករុណាមិនពង្រីកសេចក្តីឲ្យពិស្តារទេ ដោយខ្លាចសេចក្តីពិស្តារហួសពេក ។ ក្នុងពាក្យថា ដែលមានប្រភេទ ជាព្រះទសពលញ្ញាណ ១០ ជាដើមក៏យ៉ាងនោះ ដូច្នេះ ។ បទថា **ឯតាវ ហោន្តិ** ជាពាក្យប្រកបសេចក្តីថា **ឯតា ហោន្តិ ឯវ** ( បានដល់ អប្បមញ្ញា ទាំងនេះឯង ) ។

( ចប់ មហាដីកា )

បរិច្ឆេទទី ៩

ឈ្មោះ ព្រហ្មវិហារនិទ្ទេស

ក្នុងអធិការនៃសមាធិភាវនា ក្នុងបករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

ដែលខ្ញុំព្រះករុណាធ្វើដើម្បីប្រយោជន៍ដល់ភាពបាមោជ្ជនៃសាធុជន ដូច្នេះឯង ។

# អារុប្បនិទ្ទេស

-----◎-----

## អាកាសានញ្ចាយតនៈ

ក្នុងអរូបកម្មដ្ឋាន ៤ ដែលទ្រង់លើកឡើងសម្តែងទុកក្នុងលំដាប់នៃព្រហ្មវិហារ ព្រះយោគាវចរដែលប្រាថ្នានឹងចម្រើនអាកាសានញ្ចាយតនៈជាលំដាប់ដំបូង ( ពិចារណា ) ឃើញទោសក្នុងករជរូប គឺ រាងកាយស្រស់ៗ ឯទោស ( ខាងក្រៅ ) គឺ ការដែលត្រូវចាប់ដំបង ( ដើម្បីប្រហារគ្នា ) ជាដើមនោះ តាមបាលីថា ការកាន់ដំបង ឬចាប់សស្ត្រា និងការឈ្លោះទាស់ទែងគ្នាទាំងឡាយ មានប្រាកដក៏ព្រោះមានរូបជាហេតុ តែថា ទោសមានការកាន់ដំបងជាដើមនោះ មិនមានដោយប្រការទាំងពួងក្នុងអរូបភព លោកពិចារណាឃើញយ៉ាងនេះហើយ រមែងជាអ្នកបដិបត្តិដើម្បីការនឿយណាយក្នុងរូបទាំងឡាយ ដើម្បីការប្រាសចាកតម្រេកក្នុងរូបទាំងឡាយ ដើម្បីការរលត់ទៅនៃរូបទាំងឡាយដោយពិត ដូច្នេះក្តី ការឈឺចាប់ទាំងពាន់យ៉ាង មានរោគភ្នែក រោគត្រចៀកជាដើមក្តី ហើយទើបញុំាងចតុត្ថជ្ឈានឲ្យកើតឡើងក្នុងកសិណ ៩ មានបឋវីកសិណជាដើមយ៉ាងណាមួយ វៀរបរិច្ឆិន្នាកាសកសិណ ដើម្បីឈានកន្លងនូវករជរូបនោះ តាមការពិត ករជរូបជាអារម្មណ៍ដែលព្រះយោគាវចរនោះឈានកន្លងបង់បានហើយ ដោយអំណាចរូបាវចរចតុត្ថជ្ឈាន តែព្រោះថា សូម្បីកសិណរូប ( គឺ និមិត្តកសិណ ) ក៏មានចំណែកស្រដៀងករជរូបនោះឯង ព្រោះហេតុនោះ លោកទើបប្រាថ្នានឹងឈានកន្លងកសិណរូបនោះ ចេញទៀត សួរថា ឈានកន្លងដូចម្តេច ? ឆ្លើយថា ប្រៀបដូចបុរសដែលខ្លាចពស់ ត្រូវ

ពស់ក្នុងព្រៃជ្រៅ ក៏រត់គេចដោយរហ័ស រត់ទៅឃើញស្លឹកត្នោត មានឆ្នូតជាស្នាមគូស ( ខ្វាត់ខ្វែង ) ឬវល្លិ ឬខ្សែ ឬស្នាមដីបែកក្រហែងក្តី ( ប្រហែលៗ ស្រដៀងពស់ ) ក្នុងទីដែលគេចទៅហើយ ក៏ខ្លាច ក៏ស្រៀវ មិនចង់សម្លឹងមើលវាឡើយ យ៉ាងណា ។ ម្យ៉ាងទៀត ប្រៀបដូចបុរសដែលនៅក្នុងស្រុកជាមួយនឹងបុគ្គលដែលជាសត្រូវនឹងគ្នា ដែលធ្លាប់ធ្វើសេចក្តីវិនាសឲ្យ ត្រូវគេគំរាមកំហែងដោយអំពើផ្សេងៗ ដូចជាប្រទូស្ត ( នឹងឲ្យស្លាប់ ) ចាប់ចង ( ធ្វើទារុណកម្ម ) ឬ ដុតផ្ទះចោលជាដើម ( ទ្រាំមិនបាន ) ក៏ទៅនៅស្រុកដទៃទៅ ឃើញបុគ្គលដែលមានរូបរាងប៉ុន ឬ សំឡេងដូច ឬ អាកប្បកិរិយាស្រដៀងនឹងបុរសដែលជាសត្រូវក្នុងស្រុកនោះ គេក៏ខ្លាច ស្រៀវមិនចង់មើលគេឡើយ យ៉ាងណា ។

តទៅនេះជាការប្រៀបធៀបពាក្យឧបមា ក្នុងឧបមេយ្យដែលពោលនោះ គឺវេលាដែលភិក្ខុដល់ព្រមដោយករជរូប ដោយធ្វើវាឲ្យជាអារម្មណ៍ ដូចវេលាដែលបុរស ( ២ នាក់ ) នោះត្រូវពស់ ឬសត្រូវគំរាម វេលាដែលភិក្ខុឈានកន្លងករជរូប ចេញបានដោយអំណាចរូបាវចរចតុត្ថជ្ឈាន ដូចការដែលបុរស ( ២ នាក់ ) នោះរត់គេចទៅដោយរហ័ស ឬ ទៅនៅស្រុកដទៃ ការដែលភិក្ខុកំណត់ឃើញថា សូម្បីកសិណរូបនេះក៏មានចំណែកស្រដៀងករជរូបនោះឯង ដូច្នេះហើយប្រាថ្នានឹងឈានកន្លងកសិណរូបនោះទៀត ដូចការដែលបុរស ( ២ នាក់ ) នោះឃើញវត្ថុស្រដៀងពស់ ដូចជាស្លឹកត្នោតមានឆ្នូតជាស្នាម ( ខ្វាត់ខ្វែង ) ក្តី បុរសស្រដៀងសត្រូវក្តី ក្នុងទីដែលរត់គេចទៅក្តី ក្នុងភូមិដទៃក្តី ហើយស្រៀវខ្លាច និងមិនចង់មើល ដូច្នោះ ។

ម្យ៉ាងទៀត សូម្បីឧបមា ( ដទៃទៀត ) មានឧបមាដោយឆ្កែដែលត្រូវជ្រូក

ព្រៃខ្វះ និងបុគ្គលខ្វាចខ្មោចជាដើម ក៏គួរនាំមកពោលក្នុងប្រការនេះបាន ។

ព្រះយោគាវចរនោះ នឿយណាយអំពីកសិណរូប ដែលជាអារម្មណ៍របស់ចតុត្ថជ្ឈាននោះយ៉ាងនេះហើយ ជាអ្នកប្រាថ្នានឹងចៀសចេញទៅ ទើបបំពេញភាពជាវសីដោយអាការ ៥ បានហើយ ចេញចាករូបាវចរចតុត្ថជ្ឈានដែលស្ទាត់ជំនាញហើយ ឃើញទោសក្នុងឈាននោះថា ឈាននេះធ្វើកសិណរូបដែលយើងនឿយណាយហើយឲ្យជាអារម្មណ៍ខ្វះ ថាឈាននេះមានសត្រូវ គឺ សោមនស្សនៅជិតខ្វះ ថាឈាននេះគ្រោតគ្រាតជាងសន្តវិមោក្ខ ( វិមោក្ខដែលល្អិត គឺអរូបជ្ឈាន ) ខ្វះ ។

ការមានអង្គគ្រោតគ្រាត មានក្នុងអរូបជ្ឈាននោះក៏ទេ ព្រោះសូម្បីអរូបជ្ឈានទាំងឡាយ ក៏មានអង្គ ២ ដូចរូបាវចរចតុត្ថជ្ឈាននោះ ដែលមានអង្គ ២ នោះដែរ ( គឺ ឧបេក្ខា និង ឯកគ្គតា ) ។

## ការបើកកសិណ

ព្រះយោគាវចរនោះ កាលឃើញទោសក្នុងរូបាវចរចតុត្ថជ្ឈាននោះ យ៉ាងនេះហើយ កាត់ការជាប់ជំពាក់ក្នុងឈាននោះចេញ ធ្វើទុកក្នុងចិត្តនូវអាកាសានញ្ចាយតនៈថា ជាធម៌ល្អិត ពង្រីកកសិណទៅរហូតដល់មាត់កណ្ដាប់ចក្កវាឡ ឬរហូតប៉ុនដែលត្រូវការ ធ្វើទុកក្នុងចិត្តនូវឱកាសដែលកសិណរូបផ្សាយទៅដល់ថា **អាកាសោ អាកាសោ - អាកាស អាកាស** ឬថា **អនន្តោ អាកាសោ -** អាកាសជាអនន្តដូច្នេះ រមែងបើកកសិណបាន កាលបើកកសិណ មិនមែនមូរយកដូចមូរកន្ទេលនោះទេ មិនមែនលើកយក ដូចលើកនំចេញអំពីខ្ទះនោះទេ គ្រាន់តែមិនគិតដល់ មិនធ្វើទុកក្នុងចិត្តដល់ មិនពិចារណាដល់ ( កសិណនោះ ) ប៉ុណ្ណោះ ហើយ

កាលមិនគិតដល់ មិនធ្វើទុកក្នុងចិត្តដល់ មិនពិចារណាដល់ ( កសិណនោះ ) ធ្វើទុកក្នុងចិត្តត្រឹមតែឱកាសដែលកសិណរូបផ្សាយទៅប៉ុណ្ណោះថា **អាកាសោ អាកាសោ** - អាកាស អាកាស , ដូច្នេះ ឈ្មោះថា បើកកសិណ ឯកសិណកាលត្រូវបើកហើយ ក៏មិនមែនរបូតផុតឡើង មិនមែនខ្ចាត់ខ្ចាយទៅ តែអាស្រ័យការមិនធ្វើទុកក្នុងចិត្តដល់កសិណរូបនេះ និងធ្វើទុកក្នុងចិត្តថា **អាកាសោ អាកាសោ** - អាកាស អាកាស , ក៏បានឈ្មោះថា ត្រូវបើកហើយប៉ុណ្ណោះ កសិណុគ្ឃាដិមាកាសនិមិត្ត ( និមិត្ត គឺ អាកាសត្រង់ទីកសិណរូបបើកទៅ ) ក៏ ប្រាកដឡើង ។

ពាក្យថា **កសិណុគ្ឃាដិមាកាស** ( អាកាសត្រង់ទីកសិណរូបបើកទៅ ) ក្តី ពាក្យថា **កសិណផុដ្ឋាកាស** ( ឱកាសប៉ុនទីកសិណផ្សាយទៅ ) ក្តី ពាក្យថា **កសិណវិវិត្តាកាស** ( ឱកាសទទេចាកកសិណរូប ) ក្តី ទាំងអស់នេះក៏ដូចគ្នានោះឯង ។

## ឧបចារៈ និង អប្បនា

ព្រះយោគាវចរនោះនឹកយកកសិណុគ្ឃាដិមាកាសនោះហើយ នឹកទៀតថា **អាកាសោ អាកាសោ** - អាកាស អាកាស , ធ្វើទៅរហូតជានិមិត្តដែលនឹកភ្លាមប្រាកដភ្លាម( តក្កាហត ) ត្រិះរិះភ្លាមប្រាកដភ្លាម( វិតក្កាហត ) កាលលោកនឹកគិតនិមិត្តនោះរឿយៗ ធ្វើទៅរហូតឲ្យជានិមិត្តដែលនឹកភ្លាមប្រាកដភ្លាម ត្រិះរិះភ្លាមប្រាកដភ្លាម យ៉ាងនោះ នីវរណៈទាំងឡាយក៏រម្ងាប់ សតិតាំងមាំ ចិត្តជាសមាធិថ្នាក់ឧបចារៈ លោកសេពចម្រើនធ្វើឲ្យច្រើននូវនិមិត្តនោះឲ្យរឿយៗ កាលលោកសេព ចម្រើន ធ្វើឲ្យច្រើនរឿយ ៗ យ៉ាងនោះ អាកាសានញ្ចាយតនចិត្តរមែងតាំងមាំក្នុងអាកាស

ដូចដែលរូបាវចរចិត្តតាំងមាំក្នុងកសិណ មានបឋវីកសិណជាដើម ដូច្នោះ សូម្បីក្នុងអាកាសានញ្ចាយតនឈាននេះ ជវន ៣ - ៤ ខណៈ ក្នុងចំណែកខាងដើម នៅជាកាមាវចរសម្បយុត្តដោយឧបេក្ខាវេទនា ជវនដួងទី ៤ - ៥ ទើបជាអរូបាវចរ , ពាក្យពណ៌នាដ៏សេសមានន័យដូចពោលហើយ ក្នុងបឋវីកសិណនោះឯង ។

## ភាពប្លែកក្នុងអាកាសានញ្ចាយតនៈ

ចំណែកសេចក្តីតទៅនេះ ជាការប្លែកក្នុងអាកាសានញ្ចាយតនឈាន គឺកាលអរូបាវចរចិត្តកើតឡើងយ៉ាងនេះហើយ ភិក្ខុនោះធ្លាប់សម្លឹងដួងកសិណដោយឈានចក្ខុមកមុនហើយ កាលកសិណនិមិត្តប្រាកដ ត្រូវមនសិការ ដោយបរិកម្មថា “ **អាកាសោ អាកាសោ** ” នេះប្រាសចាកទៅដោយឆាប់រហ័សហើយ ក៏គង់សម្លឹងតែអាកាសប្រៀបដូចបុរសដែលចងតុបតែងប្រហោងផ្សេងៗ មានចន្លោះទ្វារតូចរបស់យាន ឬ ប្រហោងមាត់ថ្នាំងជាដើមឯណាមួយដោយក្រណាត់សំពត់ពណ៌ខៀវ ឬ ពណ៌ដទៃ មានពណ៌លឿង ក្រហម ស ជាដើមឯណាមួយ ហើយសម្លឹងមើលកាលក្រណាត់សំពត់នោះត្រូវកម្លាំងខ្យល់ ឬ កម្លាំងអ្វីៗ ដទៃផាត់យកចេញហើយក៏ គង់ឈរសម្លឹងតែអាកាស ដូច្នោះ ។

ដោយការនាទុក្រមត្រឹមប៉ុណ្ណេះ ភិក្ខុនោះ បានឈ្មោះថា ព្រោះឈានកន្លងរូបសញ្ញាដោយប្រការទាំងពួង ព្រោះកម្ចាត់បង់នូវបដិឃសញ្ញាដោយប្រការទាំងពួង ព្រោះមិនធ្វើទុកក្នុងចិត្តដល់នានត្តសញ្ញាដោយប្រការទាំងពួង ធ្វើទុកក្នុងចិត្តត្រឹមតែថា **អនន្តោ អាកាសោ** - អាកាសជាអនន្ត ហើយចូលដល់អាកាសានញ្ចាយតនៈ។

# អធិប្បាយ
# អត្ថបាឋៈក្នុងអាកាសានញ្ចាយតនៈ

## អធិប្បាយ សព្វសោ

ក្នុងបាឋៈទាំងនោះ បទថា **សព្វសោ** ដោយប្រការទាំងពួង គឺ **សព្វាការេន** ( ដោយអាការទាំងពួង ) សេចក្តីគឺថា ទាំងអស់ ឬថា មិនមានចំណែកសល់ ។

## អធិប្បាយ រូបសញ្ញានំ

បទថា **រូបសញ្ញា** បានដល់ រូបាវចរជ្ឈាន ដែលពោលដោយលើកសញ្ញាជាសំខាន់នោះឯង និង បានដល់ អារម្មណ៍របស់រូបាវចរជ្ឈាននោះផង ពិតណាស់ សូម្បីរូបាវចរជ្ឈាន ហៅថា រូប ក៏បាន ដូចក្នុងព្រះបាលីថា **រូបី រូបានិ បស្សតិ** ( អ្នកបានរូបជ្ឈាន រមែងឃើញកសិណរូបដោយឈានចក្ខុ ) ជាដើម សូម្បីអារម្មណ៍របស់រូបាវចរនោះក៏ហៅថា រូប បាន , ដូចក្នុងព្រះបាលីថា **ពហិទ្ធា រូបានិ បស្សតិ សុវណ្ណទុព្វណ្ណានិ** ( អ្នកបានរូបជ្ឈាន រមែងឃើញកសិណរូបទាំងឡាយខាងក្រៅដែលស្អាត និង អាក្រក់ ) ជាដើម ព្រោះហេតុនោះ ក្នុងទីនេះ ពាក្យថា **រូបសញ្ញា** ដែលមានសេចក្តីអធិប្បាយថា “ **រូបេ សញ្ញា រូបសញ្ញា** - សញ្ញាក្នុងរូប ( ឈាន ) ឈ្មោះថា រូបសញ្ញា ” ដូច្នេះនោះ គប្បីជ្រាបថា ជាឈ្មោះនៃរូបាវចរជ្ឈានដែលពោលដោយលើកសញ្ញាជាសំខាន់ និង ពាក្យនោះដែលមានសេចក្តីអធិប្បាយថា “ **រូបំ សញ្ញា អស្សាតិ រូបសញ្ញំ** រូបជាសញ្ញានៃអារម្មណ៍នោះ ព្រោះហេតុនោះ អារម្មណ៍នោះ ទើបឈ្មោះថា រូបសញ្ញា ( មាន

រូបជាសញ្ញា ) អធិប្បាយថា ឈាននោះមានរូបជាឈ្មោះ ” ដូច្នេះ គប្បីជ្រាបថា ជាពាក្យហៅអារម្មណ៍របស់រូបាវចរជ្ឈាននោះ ដែលផ្សេងដោយកសិណ ៩ មាន បឋវីកសិណ ជាដើម ។

## អធិប្បាយ សមតិក្កមា

បទថា **ព្រោះឈានកន្លង** គឺព្រោះឈប់ស្រឡាញ់ និងព្រោះរលត់ សួរថា ពាក្យអធិប្បាយមានដូចម្តេច ? ឆ្លើយថា “ ព្រោះឈប់ស្រឡាញ់ និងព្រោះរលត់ គឺ ហេតុដែលឈប់ស្រឡាញ់ និងហេតុដែលរលត់ទៅនៃរូបសញ្ញាទាំងឡាយ ដែលបានដល់ ឈាន ១៥ ដោយចាត់ជាកុសល វិបាក និង កិរិយា ( នីមួយៗ ៥ ) ទាំងនោះ និង រូបសញ្ញាទាំងឡាយដែលបានដល់អារម្មណ៍ ៩ តាមចំនួន កសិណ មានបឋវីកសិណជាដើមទាំងនោះគ្រប់ចំណែក ឬមិនមានចំណែកសល់ ទើបចូលដល់អាកាសានញ្ចាយតនៈបាន ព្រោះថា អ្នកមានរូបសញ្ញានៅមិនទាន់ កន្លងទៅដោយប្រការទាំងពួង មិនអាចចូលដល់អាកាសានញ្ចាយតនៈនោះបាន ឡើយ ” ព្រោះហេតុដែលការឈានកន្លងសញ្ញា រមែងមិនមានដល់បុគ្គលដែលមិន ទាន់ឈប់ស្រឡាញ់ក្នុងអារម្មណ៍ តែកាលសញ្ញាទាំងឡាយឈានកន្លងទៅហើយ អារម្មណ៍ក៏ត្រូវឈានកន្លងដូចគ្នា ព្រោះដូច្នោះ ព្រះមានព្រះភាគទើបមិនត្រាស់ការ ឈានកន្លងអារម្មណ៍ទុកក្នុងអាកាសានញ្ចាយតនៈនោះ ត្រាស់តែការឈានកន្លង សញ្ញាទុកក្នុងវិភង្គយ៉ាងនេះថា “ បណ្តាសញ្ញាទាំងនោះ រូបសញ្ញាទាំងឡាយ ដូចម្តេច ? សញ្ញា គឺ ការចាំបាន ការចំណាំឯណានៃភិក្ខុដែលដល់ព្រម ឬចូល ដល់រូបាវចរសមាបត្តិ ឬមានរូបាវចរសមាបត្តិជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម្មិក្តី សញ្ញា

ទាំងនេះ ហៅថា រូបសញ្ញា ភិក្ខុនោះជាអ្នកឈានកន្លង គឺ ឈានកន្លងទៅយ៉ាងល្អ ហើយនូវរូបសញ្ញាទាំងនេះ ព្រោះហេតុនោះ ទើបពោលថា ព្រោះឈានកន្លងរូបសញ្ញាដោយប្រការទាំងពួង " ដូច្នេះ ។

តែព្រោះ អរូបាវចរសមាបត្តិទាំងនោះ ព្រះយោគាវចរគប្បីសម្រេចបាន ដោយការឈានកន្លងអារម្មណ៍តាមលំដាប់ មិនដូចរូបាវចរជ្ឈាន មានបឋមជ្ឈានជាដើម ដែលគប្បីសម្រេចបានក្នុងអារម្មណ៍តែមួយប៉ុណ្ណោះ ព្រោះដូច្នោះ ការពណ៌នាសេចក្តីនេះ គប្បីជ្រាបថា ខ្ញុំព្រះករុណាធ្វើដោយសំដៅដល់ការកន្លងអារម្មណ៍ផង ។

## អធិប្បាយ បដិឃសញ្ញានំ អត្ថង្គមា

ពាក្យថា **បដិឃសញ្ញានំ អត្ថង្គមា** ព្រោះកម្ចាត់បង់បដិឃសញ្ញា មានពណ៌នាសេចក្តីថា សញ្ញាដែលកើតឡើងព្រម ព្រោះការប៉ះខ្ទប់គ្នានៃវត្ថុ មានចក្ខុជាដើម និងអារម្មណ៍ មានរូបជាដើម ឈ្មោះ **បដិឃសញ្ញា** ពាក្យនេះជាឈ្មោះនៃសញ្ញា ៥ មានរូបសញ្ញាជាដើម ដូចបាលីថា " ក្នុងសញ្ញាទាំងនោះ **បដិឃសញ្ញា** ដូចម្តេច ? គឺ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញា សញ្ញាទាំងនេះ ហៅថា **បដិឃសញ្ញា** " ដូច្នេះ ។ ព្រោះទម្លាក់ចុះ គឺ ព្រោះលះបង់ ព្រោះមិនកើតឡើង អធិប្បាយថា ព្រោះធ្វើមិនឲ្យប្រព្រឹត្តទៅនៃបដិឃ-សញ្ញាទាំង ១០ គឺ ចំណែកកុសលវិបាក ៥ ចំណែកអកុសលវិបាក ៥ ដោយប្រការទាំងពួង ។

សញ្ញាទាំងនោះរមែងមិនមានដល់ព្រះយោគាវចរ ដែលសម្រេចនូវរូបាវចរជ្ឈាន

មានបឋមជ្ឈានជាដើមឡើយ ព្រោះក្នុងសម័យ ( ដែលសម្រេចឈាន ) ចិត្តនោះ រមែងមិនប្រព្រឹត្តទៅក្នុងទ្វារទាំង ៥ ក៏ពិត សូម្បីយ៉ាងនោះ ការពោលដល់សញ្ញាទាំងនោះ ក្នុងអាកាសានញ្ចាយតនកថានេះទៀត បណ្ឌិតគប្បីជ្រាបថា ជាការពោលដោយការសរសើរឈាននេះ ដើម្បីញុំាងឧស្សាហ៍ ឲ្យកើតដល់អ្នកបដិបត្តិក្នុងឈាននេះ ដូចការពោលដល់សុខនិងទុក្ខ ដែលលះបានហើយក្នុងឈានដទៃក្នុងចតុត្ថជ្ឈានទៀត និង ដូចការពោលដល់សំយោជនៈខាងក្រោម ៣ មានសក្កាយទិដ្ឋិជាដើម ដែលលះបានក្នុងមគ្គដទៃហើយ ក្នុងតតិយមគ្គ ( ទៀត )នោះ ,ម្យ៉ាងទៀត សញ្ញាទាំងនោះ មិនមានដល់អ្នកចាក់ចុះរូបាវចរជ្ឈានហើយក៏ពិត សូម្បីដូច្នោះក៏មិនមែនមិនមាន ព្រោះលះបាន , ព្រោះរូបាវចរភាវនា ( ការចម្រើនរូបាវចរជ្ឈាន ) មិនបានប្រព្រឹត្តទៅដើម្បីលះបង់រូប ព្រោះការប្រព្រឹត្តទៅនៃសញ្ញាទាំងនោះ នៅទាក់ទងដោយរូបនៅឡើយ , ចំណែក ( អរូបាវចរ ) ភាវនា នេះប្រព្រឹត្តទៅដើម្បីខ្ចាក់ចោលនូវរូប ( ដោយត្រង់ ) ព្រោះហេតុនោះ ទើបគួរពោលទុកថា បដិឃសញ្ញាទាំងនោះ លះបានហើយក្នុងអរូបទី ១ នេះ និង មិនមែនត្រឹមតែពោលប៉ុណ្ណោះទេ សូម្បីកម្ចាត់នូវការចុះទៅយ៉ាងនោះចេញផងក៏គួរ ព្រោះបដិឃសញ្ញានោះ លះបង់មិនទាន់បានក្នុងឈានខាងដើមនោះឯង ព្រះមានព្រះភាគទើបត្រាស់ថា សំឡេងជាបន្លា ( ជាសត្រូវ ) សម្រាប់អ្នកចូលបឋមជ្ឈាន ចំណែកក្នុងអរូបជ្ឈាននេះទ្រង់ត្រាស់ដល់អរូបសមាបត្តិទាំងឡាយ ជាអនេញ្ជា ( មិនញាប់ញ័រ ) និងជា **សន្តវិមោក្ខ** ( វិមោក្ខយ៉ាងល្អិត ) ផង ក៏ព្រោះភាពដែលបដិឃសញ្ញាទាំងនោះលះបានហើយដោយពិត ពិតណាស់ អាឡារតាបសកាលាមគោត្រចូលអរូបសមាបត្តិមិនឃើញរទេះប្រមាណ ៥០០ ដែលឆ្លងកាត់ជិត ៗ លោកមិនបានឮសំឡេងរទេះ

ផងដែរ ។

# អធិប្បាយ
# នានត្តសញ្ញានំ អមនសិការា

សេចក្ដីថា **នានត្តសញ្ញានំ អមនសិការា** ( ព្រោះមិនធ្វើទុកក្នុងចិត្តដល់នានត្តសញ្ញា ) មានអធិប្បាយថា “ ពាក្យថា **នានត្តសញ្ញានំ** ” គឺ ដែលសញ្ញាទាំងឡាយប្រព្រឹត្តទៅក្នុងគោចរ ( គឺ អារម្មណ៍ ) ដែលកើតផ្សេងៗគ្នា ឬ ដែលសញ្ញាទាំងឡាយមានសភាវៈផ្សេងៗគ្នា ព្រោះសញ្ញាទាំងនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ចែកទុកក្នុងវិភង្គ យ៉ាងនេះថា “ ក្នុងសញ្ញាទាំងនោះ **នានត្តសញ្ញា** ដូចម្ដេច ? **សញ្ញា** គឺ ការចាំបាន ការសម្គាល់នៃព្រះយោគាវចរ ដែលប្រកបទៅដោយមនោធាតុ ឬ ព្រមទៅដោយមនោវិញ្ញាណធាតុ តែមិនបានចូលសមាបត្តិ សញ្ញាទាំងនេះ ហៅថា **នានត្តសញ្ញា** ” ដូច្នេះ សញ្ញាដែលបំណងយកក្នុងទីនេះ ទើបជាសញ្ញាដែលសង្គ្រោះ ដោយមនោធាតុ ឬ មនោវិញ្ញាណធាតុនៃព្រះយោគី ដែលមិនបានចូលសមាបត្តិ រមែងប្រព្រឹត្តទៅក្នុងគោចរ គឺ អារម្មណ៍ដែលប្រព្រឹត្តទៅផ្សេងៗ គឺ មានសភាវៈផ្សេងៗ ដែលផ្សេងគ្នាជាច្រើនយ៉ាង មានរូប និងសំឡេងជាដើម , ម្យ៉ាងទៀត ព្រោះសញ្ញាទាំង ៤៤ យ៉ាងនេះ គឺ សញ្ញាជាកាមាវចរកុសល ៨ សញ្ញាជាអកុសល ១២ សញ្ញាជាកាមាវចរកុសលវិបាក ១១ សញ្ញាជាអកុសលវិបាក ២ សញ្ញាជាកាមាវចរកិរិយា ១១ ទាំងនេះកើតផ្សេងៗគ្នា គឺ មានសភាវៈផ្សេងគ្នា មិនដូចគ្នានិងគ្នា ព្រោះហេតុនោះ ទើបហៅថា **នានត្តសញ្ញា** ( សេចក្ដីក្នុងមាតិកា **នានត្តសញ្ញានំ អមនសិការា** នេះថា ) ព្រោះមិន

ធ្វើទុកក្នុងចិត្ត គឺ មិននឹកនាដល់ **នានត្តសញ្ញា** ទាំងនោះដោយប្រការទាំងពួង មានពាក្យអធិប្បាយថា ព្រោះហេតុដែលព្រះយោគាវចរមិននឹកដល់ មិនដាក់ចិត្ត មិនពិចារណានូវនានត្តសញ្ញាទាំងនោះ ។

# អត្ថន័យផ្សេងនៃបាឋៈ

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបថា ព្រោះហេតុដែលក្នុងសញ្ញា ៣ នោះ រូបសញ្ញា និង បដិឃសញ្ញាខាងដើម រមែងមិនមានក្នុងភពដែលកើតដោយឈាននេះទេ នឹងពោលថ្វីដល់កាលដែលចូលឈាននេះក្នុងភពនោះ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ការមិនមានតែម្តងនៃសញ្ញាទាំងនោះ ទាំងពីរចំណែកដោយពាក្យថា " **ព្រោះឈានកន្លង និង ព្រោះកម្ចាត់បង់** " **ចំណែកក្នុងនានត្តសញ្ញា ព្រោះហេតុសញ្ញា ២៧** គឺសញ្ញាជាកាមាវចរកុសល ៨ សញ្ញាជាកិរិយា ៩ សញ្ញាជាអកុសល ១០ ទាំងនេះនៅមាននៅក្នុងភពដែលកើតដោយឈាននេះ ព្រោះដូច្នោះ គប្បីជ្រាបថា ត្រាស់ ( ប្រើពាក្យ ) ថា " ព្រោះមិនធ្វើទុកក្នុងចិត្តដល់នានត្តសញ្ញាទាំងនោះ " ពិតណាស់ សូម្បីក្នុងភពនោះៗ ព្រះយោគាវចរ កាលនឹងចូលដល់ឈាននេះ ក៏ចូលដល់បាន ព្រោះមិនធ្វើទុកក្នុងចិត្តដល់នានត្តសញ្ញាទាំងនោះ កាលនៅធ្វើទុកក្នុងចិត្តដល់នានត្តសញ្ញាទាំងនោះ ក៏ឈ្មោះថា ជាអ្នកនៅមិនទាន់ចូលឈាន ដូច្នេះ ។

# អត្ថន័យដោយសង្ខេប

តែពោលដោយសង្ខេបគប្បីជ្រាបថា ក្នុងបាឋៈទាំងនោះ ដោយបាឋៈថា " **រូបសញ្ញានំ សមតិក្កមា** – ព្រោះឈានកន្លងរូបសញ្ញាទាំងឡាយ " នេះជាការ

ត្រាស់ការលះរូបាវចរធម៌ទាំងអស់ ដោយបាឋៈថា " **បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា** - ព្រោះកម្ចាត់បង់នូវបដិសញ្ញាទាំងឡាយ ព្រោះមិនធ្វើទុកក្នុងចិត្តដល់នានត្តសញ្ញាទាំងឡាយ " នេះត្រាស់ការលះ និងការមិនធ្វើទុកក្នុងចិត្តនូវចិត្ត និង ចេតសិកដែលជាកាមាវចរៈទាំងអស់ ។

## អធិប្បាយ អនន្តោ អាកាសោ

ក្នុងបាឋៈថា " **អនន្តោ អាកាសោ** - អាកាសជាអនន្ត " នេះ មានវិនិច្ឆ័យថា ទីបំផុតនៃការកើតក្តី ទីបំផុតនៃការវិនាសក្តី របស់អាកាសនោះមិនប្រាកដ ព្រោះហេតុនោះ អាកាសនោះ ទើបឈ្មោះថា **អនន្ត** ( មានទីបំផុតមិនប្រាកដ ) កសិណុគ្ឃាដិមាកាស ( អាកាសត្រង់ទីកសិណរូបបើកទៅ ) ហៅថា **អាកាស** , ម្យ៉ាងទៀត ភាពជាអនន្តក្នុងអាកាសនោះ គប្បីជ្រាប ( ថាកើត ) ដោយអំណាចនៃមនសិការក៏បាន ព្រោះហេតុនោះឯង ក្នុងវិភង្គទើបពោលថា " ភិក្ខុតាំងចិត្តទុកមាំក្នុងអាកាសនោះ ផ្សាយទៅមិនមានទីបំផុត ព្រោះហេតុនោះ ទើបហៅថា **អនន្តោ អាកាសោ - អាកាសជា អនន្ត** " ដូច្នេះ ។

## អធិប្បាយ អាកាសានញ្ចាយតនំ

ចំណែកក្នុងបាឋៈថា " **អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ** - ចូលដល់ អាកាសានញ្ចាយតនៈនោះ " មានអត្ថវិគ្រោះថា វត្ថុដែលឈ្មោះថា **អនន្ត** ព្រោះមិនមានទីបំផុត អាកាសជាអនន្ត ទើបឈ្មោះថា **អាកាសានន្ត** អាកាសានន្តនោះឯងជា **អាកាសានញ្ច** , **អាកាសានញ្ច** នោះ ឈ្មោះថា ជាអាយតនៈ ដោយអត្ថថា ជាទីអាស្រ័យនៅនៃឈាននេះ ព្រមទាំងសម្បយុត្តធម៌ ដូចពាក្យថា

**ទេវាយតន** ( គឺ ទេវស្ថាន ) របស់ទេវតាទាំងឡាយ ព្រោះហេតុនោះ ឈាននោះ ទើបឈ្មោះថា អាកាសានញ្ចាយតនៈ ( ឈានមានអាកាសមិនមានទីបំផុត ជាទីអាស្រ័យ ) ។ ពាក្យថា “ **ចូលដល់... ហើយ** ” នោះ មានសេចក្តីថា សម្រេចអាកាសានញ្ចាយតនៈនោះហើយ គឺ ធ្វើអាកាសានញ្ចាយតនៈនោះ ឲ្យសម្រេចហើយ សម្រេចសម្រាន្តនៅដោយឥរិយាបថវិហារ ( ការផ្លាស់ប្តូរឥរិយាបថ ) ដែលសមគួរដល់ឈាននោះ ។ នេះជាពាក្យអធិប្បាយយ៉ាងពិស្តារ ក្នុងអាកាសានញ្ចាយតនកម្មដ្ឋាន ។

# មហាដីកា

# ពណ៌នា អារុប្បនិទ្ទេស

------◎------

## ពណ៌នា អរូបកម្មដ្ឋាន ទី ១

ពាក្យថា ***ដែលលោកលើកឡើងសម្តែងទុក*** គឺដែលលោកលើកឡើងសម្តែងទុកយ៉ាងនេះថា “ អរូប ៤ ” , ក៏ពាក្យនេះ ជាសត្តមីវិភត្តិក្នុងអត្ថថា ***និទ្ធារណៈ*** ។ ព្រោះហេតុនោះៗឯង លោកទើបពោលថា “ ក្នុងបណ្តាអរូបកម្មដ្ឋាន ៤ ” ដូច្នេះទុក ។ ក្នុងពាក្យថា ក្នុងបណ្តាអរូប ៤ នោះ ឈ្មោះថា ***អរូប*** ព្រោះជាការស្ងាត់ចាករូបនោះឯង , ***អរូប*** នោះឯងជា ***អារុប្ប*** បានដល់ ឈាន , តែក្នុងទីនេះ លោកបំណងយកកម្មដ្ឋាន ដែលមានអរូបជ្ឈាននោះ ជាផល ។ ភ្ជាប់សេចក្តីថា ព្រះយោគាវចរ ដែលប្រាថ្នាចម្រើនអាកាសានញ្ចាយតនៈនោះ ត្រូវធ្វើចតុត្ថជ្ឈានឲ្យកើត ។ បទថា ***រូបាធិករណំ*** ប្រែថា ព្រោះរូបជាហេតុ ។ ព្រោះស័ព្ទថា ***អធិករណ*** ក្នុងពាក្យថា ***រូបាធិករណំ*** នេះ មានអត្ថថា ***ហេតុ*** ដូចក្នុងពាក្យថា “ ***កាមាធិករណ*** ” ព្រោះកាមជាហេតុដូច្នេះ ។ ឧបករណ៍ មានដំបងជាដើម ឈ្មោះថា ***ទណ្ឌ*** ( ដំបង ) ក៏ដោយន័យថា ជាគ្រឿងដាក់ទោស ។ ការចាប់ដំបងនោះ ដោយការបំណងនឹងធ្វើអ្នកដទៃឲ្យឈឺចាប់ ឈ្មោះថា ***ទណ្ឌាទានំ*** ( ការចាប់ដំបង ) ។ ***អាវុធ*** ឈ្មោះថា សត្ថ ( សស្ត្រា ) ក៏ដោយន័យថា ជាគ្រឿងបៀតបៀនសត្វទាំងឡាយ ។ ការជជែកប្រកែកគ្នា ឈ្មោះថា ***កលហ*** ( ការឈ្លោះ ) ។ សេចក្តី

ក្រោធចោទប្រកាន់គ្នា ឈ្មោះថា **វិគ្គហ** ( ការចាប់កំហុស ) ។ ការៈដែលតវ៉ាគ្នាផ្សេងៗ ឈ្មោះថា **វិវាទ** ( ការវិវាទ ) ។ ពាក្យថា សេចក្តីនេះមិនមានក្នុងអរូប គឺ ទោសមានការចាប់ដំបងជាដើម តាមដែលពោលហើយ ។ ពាក្យថា **ដោយប្រការទាំងពួង** គឺ ដោយមិនមានសល់ ។ ឈ្មោះថា ( **មិនមាន** ) **ក្នុងអរូប** គឺ មិនមាន ព្រោះភពជាអរូប ឬ មិនមានក្នុងអរូបភព ។ ពាក្យថា **នូវរូបទាំងឡាយនោះឯង** គឺ ( ដើម្បីប្រយោជន៍ដល់ការនឿយណាយ ) ក្នុងរូបទាំងឡាយដែលបានឃើញទោសហើយនោះឯង អធិប្បាយថា មិនមែនដើម្បីប្រយោជន៍ដល់ការនឿយណាយក្នុងអរូបទាំងឡាយ ។ បទថា **និព្វិទាយ** ប្រែថា ដើម្បីប្រយោជន៍ដល់ការនឿយណាយ ដោយអំណាចការគ្រប់សង្កត់ ។ បទថា **វិរាគាយ** ប្រែថា ដើម្បីប្រយោជន៍ដល់ការប្រាសចាកតម្រេក ។ បទថា **និរោធាយ** ប្រែថា ដើម្បីប្រយោជន៍ដល់ការរលត់ ។ ពាក្យថា **និព្វិទាយ** ជាដើមទាំងអស់នេះ លោកពោលសំដៅយកការឈានកន្លងបាន ។ ពាក្យថា **ទោសទាំងឡាយ មានការចាប់ដំបងជាដើម** ដោយ **អាទិ** ស័ព្ទ ( ប្រែថា **ជាដើម** ) គប្បីឃើញថា លោករួមយកភាពវិនាសដែលមានរូបជាហេតុទាំងពួង មានអទិន្នាទានជាដើម ដែលមិនបានមកក្នុងព្រះបាលីក្នុងទីនេះ ។ ពាក្យថា **ក្នុងករជរូប លោកពោលទុក ដើម្បីសម្តែងដល់ការដែលរូបជារបស់គួរដល់ភាពជាហេតុនៃទោស តាមដែលពោលហើយ** មានសេចក្តីថា ក្នុងរូបគ្រោតគ្រាត ។ បទថា **អាទីនវំ** ប្រែថា ទោស ។ បទថា **តស្ស** ប្រែថា ( ដើម្បីឈានកន្លង ) នូវរូបនោះ ។ សូម្បីអាលោកកសិណ ក៏ជាវណ្ណកសិណពិសេសម្យ៉ាងនោះឯង ព្រោះហេតុនោះ ព្រះយោគី ក៏អាចបើកបដិភាគនិមិត្ត ដែលប្រព្រឹត្តទៅក្នុងអាលោកកសិណនោះបាន តែមិនអាចបើកបរិច្ឆិន្នាកាស

កសិណដើម្បីនឹងកាន់យកអាកាសនិមិត្ត ( ដែលជាអារម្មណ៍របស់អាកាសានញ្ចាយតនវិញ្ញាណ ) បានឡើយ ។ ព្រោះថា ឈ្មោះថា ការបើកកសិណនោះ គប្បីមានបានដោយ ( អាស្រ័យ ) រូបដែលជានិមិត្តប៉ុណ្ណោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ក្នុងបណ្តាកសិណ ៩ យ៉ាង វៀរបរិច្ឆិន្នាកាសដូច្នេះៗ ចំណែកអាចារ្យខ្លះពោលថា ក្នុងបណ្តាកសិណ ៨ យ៉ាង វៀរអាលោកកសិណផងដូច្នេះ , តែលោកមិនបានសម្តែងហេតុក្នុងការវៀរអាលោកកសិណនោះទេ ឈ្មោះថា **ករជរូប** ដែលព្រះយោគាវចរនោះ ឈានកន្លងបានហើយ ដោយការមិនធ្វើករជរូបនោះឲ្យជាអារម្មណ៍ ។

សួរថា ប្រសិនបើយ៉ាងនេះ ព្រោះហេតុអ្វី លោកទើបពោលថា ដោយអំណាចនៃចតុត្ថជ្ឈានដូច្នេះវិញ ។ សូម្បីឈានខាងដើម មានបឋមជ្ឈានជាដើម ក៏រមែងប្រព្រឹត្តទៅដោយទាក់ទងនឹងការមិនធ្វើករជរូបនោះ ឲ្យជាអារម្មណ៍ដូចគ្នា ព្រោះភាពជាឈានដែលមានបដិភាគនិមិត្តជាអារម្មណ៍ មិនមែនឬ ? ឆ្លើយថា ប្រការដែលពោលមកនេះ ក៏ជាសេចក្តីពិត តែថា ករជរូបដែលព្រះយោគាវចរឈានកន្លងបាន ដោយរូបាវចរចតុត្ថជ្ឈានដែលដល់នូវការមិនញាប់ញ័រ ព្រោះមានសភាវៈស្ងប់ហើយ ដោយការលះអង្គគ្រោតគ្រាតបាន ឈ្មោះថា ជាការដែលឈានកន្លងបានយ៉ាងល្អ ព្រោះហេតុនោះ លោកអាចារ្យ ទើបពោលថា ដោយអំណាចនៃរូបាវចរចតុត្ថជ្ឈាន ដូច្នេះ ។ អាចារ្យពួកខ្លះពោលថា លោកអាចារ្យពោលថា ដោយអំណាចនៃរូបាវចរចតុត្ថជ្ឈានដូច្នេះ ព្រោះរូបាវចរចតុត្ថជ្ឈាន ជាគ្រឿងរំលត់ខ្យល់ដង្ហើមចេញ-ចូលបាន និងជាគ្រឿងឈានកន្លងកាមធាតុបាន ដូច្នេះពាក្យពោលរបស់អាចារ្យពួកខ្លះនោះ មិនមែនជាហេតុឡើយ, ព្រោះរូបដែលមានចិត្តជាសមុដ្ឋាន

ក្រៅអំពីនេះ ក៏នៅកើតបាន និងព្រោះឈានជាន់ទាបៗ ក៏មិនមែនធម៌ដែលប្រព្រឹត្ត ទៅដើម្បីកាមធាតុ ។ បទថា **តប្បដិភាគមេវ** ប្រែថា មានចំណែកប្រៀបគ្នាបាននឹង ករជរូបនោះៗឯង ព្រោះមានការកាន់យកនិមិត្តជាសភាវៈ ។ តែប្រការដែលឈ្មោះ ថាដូចគ្នា គឺ ការដែលកាន់យកនិមិត្តនោះមាន ក៏ទេ ( ព្រោះថា កសិណរូប ប៉ុណ្ណោះ ដែលជាទីកាន់យកនិមិត្ត តែករជរូបមិនមែនជាទីកាន់យកនិមិត្តទេ ) ព្រោះ ដូច្នោះ លោកអាចារ្យសំដៅយកពាក្យដេញដោលដែលថា ប្រយោជន៍អ្វី ដោយការ ឈានកន្លងកសិណរូបនោះ ? ដូច្នេះ ទើបពោលថា **កថំ យថា** ( គឺ ហេតុអ្វី ប្រៀបដូច ។ ល ។ ) ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **កថំ** ( គឺ ដូច ម្តេច ) ជា **កថេតុកម្យតាបុច្ឆា** ( ពាក្យសួរដោយសេចក្តីត្រូវការឆ្លើយខ្លួនឯង ) ។ បទថា **យថា** ជានិបាតក្នុងអត្ថថា ឧបមា ។ ពាក្យថា **ដែលវិចិត្រដោយស្នាម គំនូសគូស** គឺ ដែលវិចិត្រដោយស្នាមគូស ដែលជាឆ្នូតតាក់តែង ដែលមនុស្ស ប្រើពណ៌ផ្សេងៗ មានពណ៌ខ្មៅជាដើមធ្វើឡើង ។ ពាក្យថា **ស្នាមប្រេះ** គឺជា ប្រហោង ។ ពាក្យថា **គេឃើញ** គឺ ឃើញអំពីចម្ងាយ ។ ពាក្យថា **មានរូបរាង មានសំឡេង មានអាការប្រព្រឹត្តទៅដូចគ្នា** គឺ មានរូបពណ៌សណ្ឋាន មានសំឡេង មានអាការកម្រើកដូចគ្នា ។

បទថា **អារម្មណាវសេន** គឺ ដោយទាក់ទងនឹងការធ្វើឲ្យជាអារម្មណ៍ យ៉ាង នេះថា ភ្នែករបស់យើងស្អាត រាងកាយរបស់យើងរឹងមាំ បរិក្ខាររបស់យើងជា បរិក្ខារលំដាប់ល្អ ដូច្នេះ ។ ពាក្យថា **កាលដែលភិក្ខុនៅជាអ្នកសេពគប់នឹងករជរូប** គឺ កាលដែលភិក្ខុនៅជាអ្នកប្រកបព្រមដោយរូបដែលជាអត្តភាពរបស់ខ្លួន និងដោយ រូបដែលជាអារម្មណ៍ ។ បទថា **តម្បិ** ប្រែថា សូម្បីកសិណរូបនោះ ។ ព្រោះថា

ពាក្យនេះជាទុតិយាវិភត្តិ ក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។ ប្រកបសេចក្តីថា ភាពដែលភិក្ខុជាអ្នកប្រាថ្នានឹងឈានកន្លង ប្រៀបដូចបុគ្គលទាំងនោះដែលមានការភ័យខ្លាច ការស្រៀវ ការមិនចង់ឃើញ ។ ព្រោះថា ពាក្យនេះជាពាក្យពោលទូទៅដល់ការនឿយណាយ ការប្រាសចាកសេចក្តីត្រេកអរ និងការរលត់តាមដែលពោលហើយ។ ពិតណាស់ លោកអាចារ្យសំដៅយកការៈទាំង ៣ នោះ ទើបបានពោលដល់ការខ្លាច ការស្រៀវ និងការមិនចង់ឃើញ ។ លោកអាចារ្យសំដៅយករឿងដែលមានមកក្នុងន័យថា ឆ្កែមួយក្បាលត្រូវជ្រូកព្រៃខ្វេះរហូតស្ទើរស្លាប់ ប្រញាប់គេចទៅ ឆ្កែព្រៃនោះ ឃើញឆ្នាំងដាំបាយអំពីចម្ងាយ ក្នុងវេលាដែលមើលទៅមិនទាន់ច្បាស់ មើលព្រាលៗ ហើយក៏មានសេចក្តីសម្គាល់ថាជាជ្រូក ទើបខ្លាច ញាប់ញ័រប្រញាប់គេចទៅ ។ បុគ្គលខ្លាចខ្មោច ឃើញដើមត្នោតកំបុតកនាកណ្តាលយប់ ក្នុងស្ថានទីដែលខ្លួនមិនស្និទ្ធស្នាល ឬ មិនសូវស្គាល់ ក៏មានសេចក្តីសម្គាល់ថា ជាខ្មោច ទើបស្រៀវខ្លាចរហូតសន្លប់ ( បាត់សតិ ) ដួលចុះទៅ ទើបពោលថា គួរពោលរឿងឧបមាទាំងឡាយ មានរឿងឆ្កែដែលត្រូវជ្រូកព្រៃខ្វេះ អ្នកខ្លាចខ្មោចជាដើម ទុកផង ដូច្នេះ ។

ពាក្យថា **តាមប្រការដែលពោលហើយនេះ** លោកអាចារ្យពោលបញ្ជាក់ដល់អត្ថន័យនៃឧបមាតាមដែលបានពោលហើយ ។ បទថា **សោ** ប្រែថា ព្រះយោគាវចរនោះ ។ ភ្ជាប់សេចក្តីថា សម្លឹងឃើញទោសក្នុងឈាននោះ ។ ពាក្យថា **រូប** គឺ ( ឈាននេះធ្វើ ) កសិណរូបដែលយើងនឿយណាយឲ្យជាអារម្មណ៍ ។ ពាក្យថា **ជាងសន្តវិមោក្ខ** គឺ គ្រោតគ្រាតជាងអរូបជ្ឈាន ។ ពិតណាស់ អរូបជ្ឈានទាំងនោះមកហើយថា ជាសន្តវិមោក្ខ ( វិមោក្ខដែលស្ងប់ ) ដូចក្នុងប្រយោគថា វិមោក្ខដែល

ស្ងប់ទាំងនោះ ឈានកន្ទងរូបទាំងឡាយ ជាអរូបជ្ឈានដូច្នេះជាដើម ។ ភាវៈដែលអរូបជ្ឈាននោះសម្រេចភាពជាវិមោក្ខដែលស្ងប់ ព្រះយោគីនឹងគប្បីជ្រាបបាន ក៏ដោយការរព្ញករឿយៗ ។ ដោយ **ឯវ** សព្ទ ក្នុងបទថា **យាថេវ** លោកអាចារ្យសម្តែងត្រឹមតែជាឈានមានអង្គ ២ គឺ ឧបេក្ខា និង ចិត្តេកគ្គតាទុក , រូបាវចរចតុត្ថជ្ឈាននេះជាឈានមានអង្គ ២ ដោយប្រការណា សូម្បីអរូបជ្ឈានទាំងឡាយ ក៏ជាឈានមានអង្គ ២ ដោយប្រការនោះដែរ , មិនមែនសម្តែងត្រឹមតែភាពជាឈានមានអង្គ ២ ដូចជាក្នុងតតិយជ្ឈាននោះទេ សួរថា សូម្បីក្នុងឈានទាំងនោះ ឈានដែលសូម្បីថាមានអង្គ ២ ដូចគ្នា ក៏គង់មានភាពផ្សេងគ្នា ដោយការផ្សេងគ្នានៃភូមិ មិនមែនឬ ? ឆ្លើយថា ប្រការនេះមិនបានខុសទេ ព្រោះជាឧបមា និង ឧបមេយ្យ មានការចាត់ចែងខដែលផ្សេងគ្នាទុកហើយ ។

បទថា **តត្ថ** ប្រែថា ក្នុងរូបាវចរចតុត្ថជ្ឈាននោះ ។ បទថា **និយន្តិ** ប្រែថា សេចក្តីអាល័យ ។ ពាក្យថា **ធ្វើឲ្យអស់ទៅ** គឺ ធ្វើសេចក្តីអាល័យក្នុងឈាននោះឲ្យអស់ទៅ ដោយការសម្លឹងឃើញទោស មានសេចក្តីថា ជាអ្នកមិនអាល័យ ។ ការធ្វើទុកក្នុងចិត្តថា ជាធម៌ប្រណីត និងថាជាធម៌ល្អិតសុខុម និងជាការសម្រេចបាន ក៏ដោយការធ្វើទុកក្នុងចិត្តថាជាធម៌ស្ងប់ប៉ុណ្ណោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ធ្វើទុកក្នុងចិត្តថាជាធម៌ស្ងប់ដូច្នេះ ។ ពាក្យថា **ផ្សាយ** គឺ ផ្សាយកសិណដែលបានពង្រីកទុកមុនហើយ ឬថា ផ្សាយដោយអំណាចការពង្រីក ក្នុងវេលានោះ ។ បទថា **តេន** គឺ កសិណរូប ។ ពាក្យថា ឈ្មោះថា **បើកកសិណ** គឺ ពង្រីកចេញនូវកសិណរូប មានបឋវីកសិណជាដើម ដែលជាអារម្មណ៍របស់រូបាវចរចតុត្ថជ្ឈាន ។ ក៏លោកអាចារ្យកាលនឹងសម្តែងវិធីបើក ទើបពោលថា កាលនឹង

បើកដូច្នេះជាដើមទុក ។ ក្នុងបទទាំងនោះ បទថា **សំវេល្លេតិ** ប្រែថា មូរ ។ បទថា **អញ្ឆេទដ្ឋ** ប្រែថា យ៉ាងមាំទាំ ។ បទថា **នេវ ឧព្វដ្ដតិ** ប្រែថា មិនមែននឹងរបូតទៅ ។ បទថា **នវិវដ្ដតិ** ប្រែថា មិនមែននឹងវិលវល់ទៅ ។ បទថា **ឥមស្ស** ប្រែថា នូវកសិណរូបនេះ ។ ពាក្យថា **ការមិនធ្វើទុកក្នុងចិត្ត** គឺ ការមិនធ្វើ បានដល់ មិនគិតទុកក្នុងចិត្ត ។ ពាក្យថា **និងព្រោះអាស្រ័យការធ្វើទុកក្នុងចិត្ត** គឺ និងព្រោះអាស្រ័យការធ្វើទុកក្នុងចិត្ត គឺ ការបម្រើនថា **អាកាស អាកាស** ដូច្នេះ ។ សេចក្ដីនេះត្រូវលោកអធិប្បាយថា ៖

កាលព្រះយោគាវចរមិនធ្វើទុកក្នុងចិត្តនូវកសិណរូបដែលជាអារម្មណ៍របស់រូបាវចរចតុត្ថជ្ឈានដោយអស់ជើង តែថា ធ្វើទុកក្នុងចិត្តនូវឱកាសដែលកសិណរូបនោះខ្ទប់ដល់ ដោយចម្រើនទៅថា **អាកាស អាកាស** ដូច្នេះ ក្នុងវេលាណាឱកាសដែលកសិណរូបប៉ះដល់នោះ ប្រាកដជាអាកាសឡើងមកដោយអានុភាពនៃភាវនា , ក្នុងពេលនោះ ព្រះយោគាវចរនោះ ឈ្មោះថា បើកកសិណបាន និងកសិណនោះក៏ឈ្មោះថា ត្រូវព្រះយោគាវចរនោះបើកបានហើយ ដូច្នេះឯង ។ ព្រោះហេតុនោះលោកអាចារ្យទើបពោលថា ត្រឹមតែអាកាសដែលជាទីកសិណត្រូវបើកទៅប៉ុណ្ណោះ ប្រាកដដូច្នេះ ។ ពាក្យថា **ទាំងអស់នេះ** មានសេចក្ដីថា ពាក្យពោលទាំង ៣ យ៉ាងនេះ តែមួយដូចគ្នានោះឯង ព្រោះភាពជាវេវចនៈគ្នា ។

ព្រោះហេតុអ្វី ព្រោះលោកអាចារ្យពោលថា នីវរណៈទាំងឡាយ រមែងស្ងប់ទៅដូច្នេះទៅវិញ នីវរណៈទាំងឡាយត្រូវគ្របសង្កត់នៅក្នុងឧបចារខណៈនៃរូបាវចរបឋមជ្ឈានហើយមិនមែនឬ និង រាប់តាំងអំពីនោះមក នីវរណៈទាំងនោះ ក៏មិនបានរួបរឹតព្រះយោគីឡើយ មិនមែនឬ ។ ប្រសិនបើ នីវរណៈទាំងនោះ គប្បី

រូបរឹតបានទៀត លោកនឹងវិនាសចាកឈាន ? ចំណែកពាក្យដែលអាចារ្យពួកមួយពោលទុកថា នីវរណៈល្អិត ដែលគប្បីគ្របសង្កត់ដោយអរូបជ្ឈានទៅមាន នៅឡើយ , ពាក្យថា **នីវរណៈទាំងឡាយរមែងស្ងប់ទៅ** នេះ លោកអាចារ្យសំដៅយកនីវរណៈល្អិតនោះ ដូច្នេះ ត្រឹមតែជាមតិរបស់អាចារ្យទាំងនោះប៉ុណ្ណោះ ។ ព្រោះថា ក្នុងមហគ្គតកុសលទាំងឡាយ ឈ្មោះថា មិនមានការលះតាមលំដាប់លំដោយ ( ថ្នាក់គ្រោតគ្រាត ថ្នាក់ល្អិត ) ដូចជាក្នុងលោកុត្តរកុសលនោះឡើយ។ ចំណែកភាពវិសេសជាងរូបាវចរជ្ឈានទាំងឡាយ មានភាពជាឈានដែលមានផលដ៏ឧឡារជាដើម នៃអរូបាវចរជ្ឈានទាំងឡាយណា បណ្ឌិតគប្បីជ្រាបថា ភាពពិសេសនោះ ដូចភាពពិសេសជាងឈានដើមៗ នៃឈានក្រោយៗ ក្នុងបណ្ដាឈានទាំងនោះឯង ដោយការៈដែលស្ងប់ក្រៃលែងឡើងទៅ ប្រណីតក្រៃលែងឡើងទៅតាមភាពពិសេសនៃភាវនា ។ ពាក្យថា **រមែងស្ងប់ទៅ** លោកពោលទុកដោយទាក់ទងនឹងពាក្យពោលសរសើរ ។ ពិតយ៉ាងនោះ សូម្បីទីដទៃលោកក៏នៅពោលដល់ការលះធម៌ដែលត្រូវលះទៅហើយ ក្នុងខាងដើមតទៅទៀត ។ ចំណែកអាចារ្យពួកណាពោលថា លោកអាចារ្យពោលទុកយ៉ាងនេះ ព្រោះធ្វើអធិប្បាយថា កុសលធម៌ទាំងឡាយទាំងពួងជាបដិបក្ខចំពោះអកុសលធម៌ទាំងឡាយទាំងពួង ដូច្នេះ អាចារ្យទាំងនោះ គប្បីពោលដល់ហេតុនៃការដែលលោក មិនពោលដល់ការគ្របសង្កត់នីវរណៈទុកក្នុងឧបចារៈនៃទុតិយជ្ឈានជាដើម ។ ពាក្យថា **សតិរមែងតាំងមាំ** គឺសតិដែលមានអាកាសនិមិត្តជាអារម្មណ៍ តាំងនៅជាធម្មជាតិ តាំងមាំដោយប្រពៃ ។ ក្នុងពាក្យនេះ លោកសម្ដែងដល់ការខ្នះខ្នែងក្នុងកិច្ចរបស់ខ្លួននៃធម៌ទាំងឡាយ មានសទ្ធាជាទី ៥ ដែលឧបការៈដល់ឧបចារជ្ឈាន ដោយមានសតិជាប្រធាន ។ បទថា

**ឧបចារេន** គឺដោយឧបចារជ្ឈាន ។ ពាក្យថា **ក្នុងអាកាសានញ្ចាយតនឈាន** នេះ ជាការពោលរួម សំដៅយករូបាវចរចតុត្ថជ្ឈាន ។ ព្រោះថា រូបាវចរចតុត្ថជ្ឈាននោះ ក៏សម្បយុត្តទឹងឧបេក្ខាវេទនា ។ ពាក្យថា **ពាក្យដ៏សេស** បានដល់ ពាក្យថា ជវនដួងដ៏សេសជាកាមាវចរជាដើម ។ ពាក្យណាគួរពោល ដែលនៅមិនបាន ពោលទុកក្នុងទីនេះ ពាក្យនោះបណ្ឌិតគប្បីជ្រាបតាមទំនងនៃន័យដែលលោកពោល ទុកក្នុងបឋវីកសិណនិទ្ទេសនោះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា មានន័យដូចខ្ញុំព្រះករុណាបានពោលហើយ ក្នុងបឋវីកសិណនោះឯង ដូច្នេះ ។

លោកអាចារ្យចង្អុលដល់ប្រការដែលមិនផ្សេងគ្នាទឹងឈានដទៃ ក្នុងអាកា-សានញ្ចាយតនឈាននោះ យ៉ាងនេះហើយ ឥឡូវនេះ បំណងសម្ដែងប្រការដែល ផ្សេងគ្នា ទើបពោលថា ចំណែកតទៅនេះជាប្រការដែលផ្សេងគ្នាដូច្នេះជាដើម ។ បទថា **យានប្បុតោឡិកុម្ភិមុក្ខាទីនំ** មានសេចក្ដីថា ចន្លោះនៃយានទាំងឡាយ មាន **រ** ( ឬគ្រែស្នែង ) ដែលមានដំបូលបិទជិតជាដើម ឈ្មោះថា **យានមុខ** , ប្រហោង នៃ **បុតោឡី** គឺ ទ្វារតូចៗ ឈ្មោះថា **បុតោឡិមុក្ខ** , គប្បីភ្ជាប់ស័ព្ទថា “ **មុខ** ” ចូលតែមួយបទថា **កុម្ភិមុក្ខ** ( មាត់ថ្នាំង ) ដូច្នេះជាដើម ។ ពាក្យថា **ឈរសម្លឹង នូវអាកាសប៉ុណ្ណោះ** បានដល់ ឈរសម្លឹងនូវទីកាត់ជុំវិញដោយប្រហោងយាន ជាដើមប៉ុណ្ណោះ ។ ពាក្យថា **ត្រូវមនសិការដែលជាការបរិកម្ម ( ប្រាសទៅ )** មានន័យថា ត្រូវមានមនសិការដែលជាការបរិកម្ម គឺ ឧបចារជ្ឈាន ( ប្រាសទៅ ) ។ ក៏ពាក្យថា បរិកម្ម អនុលោម និងថា ឧបចារៈនេះ មានអត្ថដទៃផ្សេងក៏ទេ ( គឺ មិនផ្សេងគ្នា ) ។ ឈ្មោះថា សម្លឹង ក៏ដោយចក្ខុ គឺ អរូបាវចរជ្ឈាន ។

ពាក្យថា **ដោយអាការទាំងពួង** គឺ ដោយអាការដែលសម្លឹងឃើញទោសក្នុង

រូបធម៌ទាំងឡាយ ក្នុងរូបនិមិត្តទាំងឡាយ មានបឋវីកសិណជាដើម និងក្នុងឈាន ទាំងឡាយ ដែលមានរូបនិមិត្តនោះជាអារម្មណ៍ទាំងពួង មានការសម្លឹងឃើញថាជា ហេតុឲ្យកើតនូវការចាប់ដំបងជាដើម ព្រោះមានរូបជាហេតុ ឬថា ដោយអាការ មានភាពជាអ្នកមិនត្រូវនឹងនឹកដល់ ព្រោះលះបង់សេចក្តីស្រឡាញ់ក្នុងរូបធម៌ជាដើម ទាំងនោះៗ ឯង ។ សូម្បីរូបជ្ឈានក៏ហៅថារូបបាន ដោយការលុបបទចុង ( គឺ បទថា **ឈាន** ) ដូចដែលហៅរូបកពថា **រូប** ក្នុងប្រយោគថា រមែងចម្រើនមគ្គ ដើម្បីការចូលដល់រូប ដូច្នេះជាដើម ។ ជាសេចក្តីពិតថា បទថា **រូបី** ( អ្នកមានរូប ) មានន័យថា អ្នកបានរូបជ្ឈាន ។ សូម្បីអារម្មណ៍ គឺ កសិណរូប ក៏ហៅថា រូប បាន ដោយការលប់បទដើម ( គឺ **បទថា កសិណ** ) **ដូចដែលពោលថា** " **ព្រះ ទេវទត្តថា ទត្តៈ** " ។ ពាក្យថា **រមែងឃើញរូបទាំងឡាយ** មានសេចក្តីថា រមែង ឃើញកសិណរូបទាំងឡាយដោយឈានចក្ខុ ។ ពាក្យថា **ព្រោះដូច្នោះ** មាន សេចក្តីថា ព្រោះហេតុដែលវោហារ ( បញ្ញត្តិ ) ថា **រូប** រមែងឃើញប្រើក្នុង រូបជ្ឈាន និងកសិណរូប ដោយការលុបបទចុង និងដោយការលុបបទដើម តាម លំដាប់ដូច្នោះ ។ សញ្ញាក្នុងរូប គឺ ក្នុងរូបជ្ឈាន បានដល់ សហគតៈដោយ រូបជ្ឈាននោះ ឈ្មោះថា រូបសញ្ញា ។ ដោយ **ច** ស័ព្ទ ( ប្រែថា និង ) ដោយ បទថា **តទារម្មណស្ស ច** ( និងអារម្មណ៍របស់រូបាវចរជ្ឈានទាំងនោះ ) លោក រួមយករូបាវចរជ្ឈានតាមដែលពោលហើយ ។ ដោយ **ច** ស័ព្ទនោះ លោកអាចារ្យ សម្តែងថា បទថា **រូបសញ្ញានំ** ក្នុងព្រះបាលីជានិទ្ទេសដែលព្រះមានព្រះភាគទ្រង់ ធ្វើទុកដោយជា **សរូបេកសេស** ( សល់បទដែលមានរូបដូចគ្នាទុកបទមួយ ) ។ បទថា **ព្រោះប្រាសចាកសេចក្តីត្រេកអរ** គឺ ព្រោះសេចក្តីវង្វៀស ។ ពាក្យថា **ព្រោះ**

**ការរំលត់បង់** គឺ ព្រោះការធ្វើឲ្យរលត់ទៅបាន ដោយការគ្របសង្កត់ឆន្ទរាគៈដែលទាក់ទងនឹងរូបសញ្ញានោះ ។ លោកអាចារ្យបំណងនឹងធ្វើអត្ថន័យដែលពោលហើយនោះឯង ឲ្យជាក់ច្បាស់ក្រៃលែងឡើង ទើបពោលថា មានអធិប្បាយដូចម្ដេចដូច្នេះជាដើម ។ម្យ៉ាងទៀត គប្បីធ្វើពាក្យប្រកបសេចក្ដីក្នុងបាឋៈនេះយ៉ាងនេះថា ព្រោះប្រាសចាកសេចក្ដីត្រេកអរក្នុងរូប ( រូបសញ្ញា ) នោះបានដោយអាការទាំងពួង ព្រោះការរំលត់បាននូវរូប ( រូបសញ្ញា ) មិនមានសល់ដូច្នេះ ។

ពាក្យថា **ការឈានកន្លងសញ្ញា រមែងមិនមានដល់បុគ្គលដែលនៅមិនទាន់ប្រាសចាកសេចក្ដីត្រេកអរក្នុងអារម្មណ៍** នេះ លោកអាចារ្យពោលទុក ព្រោះលោកធ្វើទុកក្នុងចិត្តថា ព្រោះហេតុដែលព្រះយោគីនឹងគប្បីសម្រេចឈានទាំងនេះបាន ក៏ដោយការឈានកន្លងអារម្មណ៍ , មិនមែននឹងសម្រេចបានដោយការឈានកន្លងអង្គដូច្នេះទេ ។ ព្រោះហេតុដែលក្នុងអាកាសានញ្ចាយតនជ្ឈាននេះ មានការឈានកន្លងសញ្ញាដោយវៀរការឈានកន្លងអារម្មណ៍ក៏ទេ ដូច្នោះ លោកអាចារ្យទើបពោលថា កាលសញ្ញាត្រូវឈានកន្លងទៅហើយ អារម្មណ៍ក៏ត្រូវឈានកន្លងទៅដូចគ្នាដូច្នេះ ។ ក្អាប់សេចក្ដីថា **អវត្វា វុត្តោ** ( ទើបមិនត្រាស់ដល់... ត្រាស់តែ... )។ ក្នុងពាក្យថា នៃបុគ្គលដែលចូល ( រូបាវចរសមាបត្តិ ) ជាដើម , ស័ព្ទថា **បុគ្គលដែលចូល** ទ្រង់ត្រាស់ទុកដោយទាក់ទងនឹងសញ្ញាដែលជាកុសល , ស័ព្ទថា **បុគ្គលដែលឧប្បត្តិ** ទ្រង់ត្រាស់ទុកដោយទាក់ទងនឹងសញ្ញាដែលជាវិបាក , ស័ព្ទថា **បុគ្គលដែលមានរូបាវចរសមាបត្តិជាគ្រឿងនៅជាសុខក្នុងអត្តភាពនេះ** ទ្រង់ត្រាស់ទុកដោយទាក់ទងនឹងសញ្ញាដែលជាកិរិយា ។ ពិតណាស់ ឈានទាំងឡាយរបស់ព្រះអរហន្តចាត់ជាទិដ្ឋធម្មសុខវិហារ ( គ្រឿងនៅជាសុខក្នុងអត្តភាពនេះ ) ដោយពិសេស ។

លោកអាចារ្យសំដៅយកពាក្យដេញដោលដែលថា ប្រសិនបើបុគ្គលដែលមានការឈានកន្លងសញ្ញា និងមានការឈានកន្លងអារម្មណ៍ដែលមិនទាន់បានធ្វើឲ្យសម្រេចនិង ការឈានកន្លងអារម្មណ៍ ក៏មិនបានត្រាស់ទុកក្នុងបករណ៍វិភង្គ កាលបើដូច្នោះព្រោះហេតុអ្វី ទ្រង់ទើបបានកាន់យកក្នុងទីនេះវិញ ដូច្នេះ ទើបពោលថា ម្យ៉ាងទៀតព្រោះហេតុដែល ដូច្នេះជាដើម ។ អធិប្បាយថា ការពណ៌នាសេចក្ដីនេះ គឺ ខ្ញុំព្រះករុណា បានធ្វើទុកដោយទាក់ទងនឹងការឈានកន្លងអារម្មណ៍ផង ក៏ពាក្យថារូបសញ្ញានេះ ជាឈ្មោះនៃអារម្មណ៍របស់រូបាវចរជ្ឈាននោះ ដូច្នេះជាដើម មិនបានពោលការឈានកន្លងសញ្ញាតែម្យ៉ាង ដូចជាក្នុងបករណ៍វិភង្គទេ ។

ពាក្យថា **ព្រោះការប៉ះខ្ទប់គ្នា** គឺព្រោះការប្រជុំគ្នានៃវត្ថុ មានចក្ខុជាដើមដែលជាវិសយី ( អ្នកទទួលខ្ទប់អារម្មណ៍ ) និងរូបជាដើម ដែលជាវិសយៈ ( អារម្មណ៍ ) ដោយការខ្ទប់គ្នា ។ ក្នុងពាក្យថា **ព្រោះការដល់នូវការតាំងនៅមិនបានជាដើម** ពាក្យដំបូងៗ ជាពាក្យពោលដល់អត្ថន័យរបស់ពាក្យក្រោយៗ , ព្រោះដូច្នោះ លោកអាចារ្យបំណងសម្ដែងហេតុក្នុងការកាន់យកការតាំងនៅមិនបាននោះ ក្នុងឈាននោះឯងថា ការដល់នូវការតាំងនៅមិនបាននៃបដិឃសញ្ញាទាំងឡាយ បានដល់ ការកើតឡើងមិនបានក្នុងវេលាដែលព្រមព្រៀងដោយឈាន ដូច្នេះ ដោយពាក្យដេញដោលជាមុខ ទើបពោលថា **កាមញ្ចតា** ( បដិឃសញ្ញាទាំងនេះ...ក៏ពិត ) ជាដើម ។ ឈ្មោះថា ដើម្បីនឹងទ្រង់ញ៉ាំងឧស្សាហៈឲ្យកើតដល់ព្រះយោគីអ្នកបដិបត្តិទាំងឡាយ ទើបបានត្រាស់ដល់សញ្ញាទាំងនេះ គឺ បដិឃសញ្ញាទាំងឡាយទុកក្នុងអាកាសានញ្ចាយ-តនឈាននេះ គឺ ក្នុងកថាពោលដោយអរូបជ្ឈានទី ១ ដោយទាក់ទងនឹងការដល់នូវការតាំងនៅមិនបាន ។

លោកអាចារ្យបំណាងសម្តែងថា ឬថាប្រយោជន៍អ្វីដោយពាក្យពោលសរសើរលើកតម្កើងឈានទេះទៅវិញ , ក៏ការដល់នូវការតាំងនៅមិនបាន នៃបដិឃសញ្ញាទាំងឡាយ គឺ ទ្រង់ត្រាស់ទុក ក៏ព្រោះជាប្រការដែលគួរពោលទុកក្នុងឈានទេះនោះឯង ដូច្នេះទើបពោលថា ន័យម្យ៉ាងទៀតដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ សម្រាប់សភាវធម៌ ឈ្មោះថា មិនមានក៏ដោយភាវៈដែលត្រូវធម៌ជាបដិបក្ខ លះបង់ទៅ ឬថា ដោយការមិនមាននៃបច្ច័យ ។ លោកអាចារ្យកាលនឹងសម្តែងថា ក្នុងបណ្តាបុគ្គលដែលដល់ព្រមដោយរូបជ្ឈាន និងដល់ព្រមដោយអរូបជ្ឈានទាំងនោះ សម្រាប់បុគ្គលដែលដល់ព្រមដោយរូបជ្ឈាន ឈ្មោះថា មិនមានបដិឃសញ្ញា ក៏ដោយគ្រាន់តែមិនមានបច្ច័យ , មិនមែនដោយការបានសម្រេចធម៌ដែលជាបដិបក្ខ ( រូបឈានមិនបានជាបដិបក្ខចំពោះបដិឃសញ្ញា ) ហេតុនោះ ទើបពោលថា **កិញ្ចាបិ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **តា** បានដល់ បដិឃសញ្ញា ។ បទថា **រូបាវចរំ** បានដល់ រូបាវចរជ្ឈាន ។ បទថា **សមាបន្នស្ស** បានដល់ បុគ្គលដែលកំពុងចូល ។ ប្រកបសេចក្តីថា មិនមានប្រាកដពិត ។ ពាក្យថា **មិនមែនថាមិនមានព្រោះលះបានហើយ** មានសេចក្តីថា ក្នុងវេលានោះ បដិឃសញ្ញា ឈ្មោះថា មិនមាន ព្រោះភាវៈដែលលះបានហើយក៏ទេ ។ លោកអាចារ្យពោលដល់ហេតុក្នុងពាក្យនោះទុកថា ព្រោះថា រូបាវចរភាវនា មិនបានប្រព្រឹត្តទៅដើម្បីខ្ចាក់ចោលនូវរូបឡើយ ។ លោកអាចារ្យសំដៅយកពាក្យចោទដែលថា សូម្បីបដិឃសញ្ញាក៏ជានាមធម៌ដូចគ្នា មិនមែនឬ ដូច្នេះទើបពោលថា និងសញ្ញាទាំងនេះ ក៏ឈ្មោះថាមានការប្រព្រឹត្តទៅទាក់ទងដោយរូប ដូច្នេះ ។ ដោយពាក្យថា ចំណែកភាវនានេះលោកពោលដល់ អរូបភាវនា ។ បទថា **ធារេតុំ** ប្រែថា ដើម្បីនឹងកំណត់ចុះទៅ ។

ពាក្យថា ( **តែព្រោះលះបានហើយ** ) **ក្នុងឈានទនេះ** គឺ ក្នុងអរូបជ្ឈាន ។ ឈ្មោះថា បានត្រាស់ដល់ភាពដែលអរូបសមាបត្តិទាំងឡាយជាអនេញ្ជធម៌ ក៏ដោយពាក្យថា អនេញ្ជាភិសង្ខារជាដើម ។ និងឈ្មោះថា បានត្រាស់ដល់ភាពជាសន្តវិមោក្ខទុក ក៏ដោយពាក្យថា វិមោក្ខដែលស្ងប់ទាំងនោះ ឈានកន្លងរូបទាំងឡាយជាអរូបជ្ឈានដូច្នេះ ជាដើម ។

បុគ្គលរមែងមិនចេញចាកអរូបសមាបត្តិ ព្រោះសំឡេងទេ ព្រោះការដែលលះបដិឃសញ្ញាបានយ៉ាងល្អហើយ ដោយអំណាចនៃការវនាដែលជាបដិបក្ខ ដែលមានការសម្លឹងឃើញទោស ( ក្នុងរូប ) ចេញមុខ ។ តែថា គប្បីមានការចេញចាករូបាវចរសមាបត្តិទាំងពួងបាន ព្រោះភាពដែលមិនបានលះបង់បដិឃសញ្ញាដោយល្អយ៉ាងនោះ , ឯបឋមជ្ឈានរមែងអត់ធន់ចំពោះសំឡេង សូម្បីដែលតិចៗ មិនបាន ព្រោះហេតុនោះ ទើបត្រាស់ថា សំឡេងជាបន្លារបស់ភិក្ខុដែលចូលបឋមជ្ឈាននោះដូច្នេះ ។ ការដែលលោកអាចារ្យពោលដល់ការឈានកន្លង និងការដល់នូវការតាំងនៅមិនបាននៃរូបសញ្ញា និង បដិឃសញ្ញាដែលគួរនឹងកើតឡើងក្រោយអំពីចុតិក្នុងកាលមិនមានអរូបភាវនា ដោយការធ្វើឲ្យដល់នូវការកើតឡើងមិនបានជាធម្មតារហូតទាល់តែវិបាករបស់ខ្លួន ( អរូបវិបាក ) នឹងប្រព្រឹត្តទៅ ។ ចំណែកក្នុងបណ្តានានត្តសញ្ញាទាំងឡាយ នានត្តសញ្ញាណាអាស្រ័យរូប ( ជាអារម្មណ៍ ឬវត្ថុ ) តែម្យ៉ាង ទើបកើតឡើងក្នុងភពនោះ ( ក្នុងអរូបជ្ឈាន ) មិនបាន នានត្តសញ្ញានោះកើតឡើងមិនបាន ក៏ព្រោះភពនោះមិនមែនឱកាស ដែលកើតឡើងមិនបានព្រោះត្រូវអរូបភាវនាហាមទុក , ចំណែកនានត្តសញ្ញាប្រភេទខ្លះ ព្រោះមិនទាន់ត្រូវអរូបភាវនាហាម ក៏រមែងកើតឡើងបាន ។ ព្រោះដូច្នោះ ទើបទ្រង់ត្រាស់ដល់

ការមិនដាក់ចិត្ត ការមិននឹកដល់ ការមិនពិចារណានូវនានត្តសញ្ញាទាំងនោះ ឬ ការមិនធ្វើកវត្តចិត្តឲ្យអស់ទៅដោយជវនបដិបាទកមនសិការ បានដល់ ការមិនធ្វើឲ្យចូលទៅ ( រកសញ្ញាទាំងនោះ ) ។

លោកអាចារ្យនោះបំណងសម្តែងការមាំទាំនៃសមាធិ ព្រោះការឈានកន្លងរូបទាំងឡាយ ដែលជាហេតុនៃការធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ទើបពោលថា **សង្ខេបតោ** ( ដោយសង្ខេប ) ដូច្នេះជាដើម ។ ន័យម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់សរសើរអាកាសានញ្ចាយតនសមាបត្តិទុកដោយបទទាំង ៣ នេះ ( មានបទថា ព្រោះការឈានកន្លងបាននូវរូបសញ្ញាជាដើម ) ក៏ដើម្បីទ្រង់ញ៉ាំងឧស្សាហៈឲ្យកើតដល់អ្នកស្តាប់ និងដើម្បីទ្រង់ប្រលោមចិត្ត ។ ពិតណាស់ ទ្រង់បំណងនឹងការពារបុគ្គលដែលមិនឆ្លាត បុគ្គលមានការប្រកាន់យ៉ាងនេះថា សម្រាប់សញ្ញាដែលធ្វើឲ្យប្រព្រឹត្តទៅក្នុងអាកាស ដែលប្រាសចាកភាពគួរត្រេកអរដោយប្រការទាំងពួង នឹងមានអានិសង្សដូចម្តេច ? ដូច្នេះ ឲ្យផុតពីការប្រកាន់ខុសនោះ ទើបបានត្រាស់អានិសង្សរបស់ឈានទុកដោយបទទាំង ៣ ។ គេទាំងនោះបានស្តាប់អានិសង្សទាំងនោះហើយ ក៏នឹងមានការគិតយ៉ាងនេះថា ន័យថា សមាបត្តិនេះស្ងប់យ៉ាងនេះ ប្រណីតយ៉ាងនេះ ណ្ហើយចុះ ពួកយើងនឹងធ្វើសេចក្តីឧស្សាហៈដើម្បីធ្វើសមាបត្តិនោះឲ្យកើតឡើង ដូច្នេះ ។

បទថា **អស្ស** បានដល់ អាកាស ។ ទីបំផុត គឺ ការកើតឡើង ឈ្មោះថា **ឧបាទន្ត** , ឈ្មោះថា **វយន្ត** ដោយប្រការនោះដូចគ្នា ( បានដល់ ទីបំផុត គឺការរលត់ទៅ ) ។ ពិតណាស់ សភាវធម៌ ឈ្មោះថា ត្រូវខណ្ឌដោយការកើតឡើង និង ការរលត់ទៅ ព្រោះមិនមាន ក៏ត្រឡប់ជាមានឡើង និងមានហើយ ក៏

ត្រឡប់ជាវិនាសទៅ ។ ចំណែកអាកាស ព្រោះមិនមានសភាវធម៌ ទើបត្រាស់ថា **អនន្ត** ( មិនមានទីបំផុត ) ព្រោះមិនមានទីបំផុតទាំងពីរយ៉ាងនោះ ។ ព្រោះក្នុងទីនេះ មិនបានបំណងយកអជដាកាស ( អាកាស គឺ ទីទទេ ជាទីសញ្ចរទៅមកនៃបក្សី ឬជាទីតាំងនៃលោកធាតុ ) និង បរិច្ឆិន្នាកាស ( អាកាសដែលជាចន្លោះទទេ ) មានចន្លោះបង្អួចជាដើម លោកអាចារ្យទើបពោលថា ទ្រង់ត្រាស់ហៅកសិណុគ្ឃាដិមាកាសថា **អាកាសោ** ដូច្នេះ ។ **អាកាស** ឈ្មោះថា កសិណុគ្ឃាដ ព្រោះអត្ថថា ជាហេតុដែលកសិណត្រូវបើកទៅ , **កសិណុគ្ឃាដ** នោះឯង ជា **កសិណុគ្ឃាដិម** ។ ពាក្យថា **សូម្បីដោយអំណាចនៃមនសិការ** គឺ សូម្បីដោយអំណាចនៃមនសិការ គឺ ការបរិកម្មដែលប្រព្រឹត្តទៅដោយអាការដែលផ្សាយទៅដ៏រកទីបំផុតមិនបាន ដោយការកាន់យកអាកាសត្រឹមតែថា ជាទីទទេវៀរចាករូប មិនកាន់យក **បរិច្ឆេទាកាស** ( ទីទទេដែលត្រូវខណ្ឌ ) ។ ពាក្យថា **រមែងផ្សាយទៅមិនមានទីបំផុត** គឺ រមែងប៉ះខ្ទប់ដោយឈានផស្សៈ ដែលមានបរិកម្មសម្ផស្សជាខាងដើម ធ្វើឲ្យមិនមានទីបំផុតដោយការៈដែលមិនកាន់យកបរិច្ឆេទាកាស ។ ប្រៀបដូច **ភិសជ្ជ** នោះឯងជា **ភេសជ្ជ** ( ប្រែថា ថ្នាំ ) យ៉ាងណា , **អាកាសានន្ត** នោះឯងជា **អាកាសានញ្ច** ក៏យ៉ាងនោះ ព្រោះធ្វើ " **ត** " អក្ខរៈដែលនៅក្រោយសំយោគ ( អក្សរតម្រួត គឺ **ន** ) ឲ្យជា **ច** អក្ខរៈ ។ លោកពោលដល់អារម្មណ៍ ( ដែលហៅថា **អាកាសានញ្ច** ថាជា **អាយតនៈ** ដោយន័យថា ជាទីអាស្រ័យនៃឈាននេះ ព្រោះភាពជាទីតាំង គឺ ទីប្រព្រឹត្តទៅនៃឈាន ព្រោះស័ព្ទថា អាយតនៈប្រាកដក្នុងន័យថា ជាទីតាំងទីអាស្រ័យ ។ ស័ព្ទថា **អាយតន** ក្នុងន័យថា ជាហេតុ ជាប្រភព ( អណ្តូង )កើត ស្ថានទីកើត និង ជាទីលំនៅ ក៏

ប្រើក្នុងឈាននេះបានដូចគ្នា ។

( ចប់ មហាដីកា )

( ការអធិប្បាយ អាកាសានញ្ចាយតនៈ ចប់ដោយប្រការដូច្នេះ )

# វិញ្ញាណញ្ចាយតនៈ

ចំណែកព្រះយោគាវចរដែលប្រាថ្នានឹងចម្រើនវិញ្ញាណញ្ចាយតនៈតទៅ គប្បីជាអ្នកប្រព្រឹត្តវសីការៈ ( ធ្វើឲ្យស្ទាត់ជំនាញ ) ក្នុងអាកាសានញ្ចាយតនសមាបត្តិដោយអាការ ៥ ហើយ ពិចារណាឲ្យឃើញទោសក្នុងអាកាសានញ្ចាយតនៈថា សមាបត្តិនេះមានសត្រូវ គឺ រូបាវចរជ្ឈានទៅជិត និងនៅមិនល្អិតដូចវិញ្ញាណ-ញ្ចាយតនៈ ដូច្នេះហើយ លះបង់ការពេញចិត្តក្នុងអាកាសានញ្ចាយតនៈនោះចេញ ដាក់ចិត្តដល់វិញ្ញាណញ្ចាយតនៈថា ជាធម៌ល្អិត ហើយនឹកយកការដឹងដែលប្រព្រឹត្តទៅ ផ្សាយទូទៅក្នុងអាកាសនិមិត្តនោះ មនសិការទៅ បច្ចវេក្ខណៈទៅរឿយៗ ថា **វិញ្ញាណំ វិញ្ញាណំ - វិញ្ញាណ វិញ្ញាណ** ធ្វើរហូតជា **តក្កាហត** ( នឹកភ្វាមប្រាកដភ្វាម ) ជា **វិតក្កាហត** ( ត្រិះរិះភ្វាមប្រាកដភ្វាម ) តែកុំមនសិការ ( ត្រឹមតែ ) ថា **អនន្តំ អនន្តំ -** មិនមានទីបំផុត មិនមានទីបំផុត ។ កាលលោកញ៉ាំងចិត្តឲ្យត្រាច់ទៅក្នុងនិមិត្តនោះរឿយៗ យ៉ាងនោះ នីវរណៈទាំងឡាយ នឹងរម្ងាប់ចុះ សតិនឹងតាំងមាំ ចិត្តនឹងជាសមាធិថ្នាក់ឧបចារៈ លោកសេព ចម្រើន ធ្វើឲ្យច្រើននូវនិមិត្តនោះរឿយៗទៅ កាលលោកធ្វើទៅយ៉ាងនោះ វិញ្ញាណញ្ចាយតនចិត្ត រមែងនឹងចុះស៊ប់ ( ជាអប្បនា ) នៅក្នុងវិញ្ញាណដែលផ្សាយទូទាំងអាកាសនិមិត្ត ដូចអាកាសា-នញ្ចាយតនចិត្ត ចុះស៊ប់នៅក្នុងអាកាសដូច្នោះ ។

ចំណែកន័យនៃអប្បនាក្នុងវិញ្ញាណញ្ចាយតនៈនេះ បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលហើយ ( ក្នុងអាកាសានញ្ចាយតនៈ ) ចុះ ។

ដោយការនៃនុក្រមត្រឹមប៉ុណ្ណេះ ព្រះយោគាវចរនោះ ហៅថា ឈានកន្លងអាកាសានញ្ចាយតនៈដោយប្រការទាំងពួង ហើយធ្វើទុកក្នុងចិត្តថា **អនន្តំ វិញ្ញាណំ**

វិញ្ញាណជា **អនន្ត** ចូលដល់វិញ្ញាណញ្ចាយតនៈហើយ ។

# អធិប្បាយ

## អត្ថបាឋៈ ក្នុងវិញ្ញាណញ្ចាយតនៈ

ក្នុងបាឋៈទាំងនោះ ពាក្យថា **ដោយប្រការទាំងពួងនេះ** មានន័យដូចពោលមកហើយ ចំណែកក្នុងពាក្យថា ឈានកន្លងអាកាសានញ្ចាយតនៈនោះ មានអធិប្បាយថា តាមន័យដែលពោលមកមុន សូម្បីឈានក៏ឈ្មោះថា អាកាសានញ្ចាយតនៈ សូម្បីអារម្មណ៍ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ , ពិតណាស់ សូម្បីអារម្មណ៍ ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ ព្រោះអត្ថវិគ្រោះថា **អាកាសានញ្ច** ( អាកាសមិនមានទីបំផុត ) ផង **អាកាសានញ្ច** នោះ ឈ្មោះថាជា **អាយតនៈ** ដោយអត្ថថា ជាទីអាស្រ័យ ដូចពាក្យថា **ទេវាយតន** ( គឺ ទេវស្ថាន ) របស់ទេវតាទាំងឡាយ ព្រោះអាកាសានញ្ចៈនោះជាអារម្មណ៍នៃអរូបជ្ឈានទី ១ ផង ដូច្នេះ តាមន័យដំបូង ន័យមួយទៀត អារម្មណ៍ឈ្មោះថា **អាកាសានញ្ចាយតនៈ** ព្រោះអត្ថវិគ្រោះថា **អាកាសានញ្ច** ផង , **អាកាសានញ្ច** នោះ ឈ្មោះថាជា **អាយតនៈ** ដោយអត្ថថា ជាទីកើត ដូចពាក្យថា ដែនកម្ពោជា ជា **អាយតនៈ** ( គឺ ទីកើត ) របស់សេះទាំងឡាយ ព្រោះអាកាសានញ្ចៈនោះជាហេតុកើតនៃឈាននោះផង ដូច្នេះក៏បាន ព្រោះហេតុដែលវិញ្ញាណញ្ចាយតនៈនេះ ព្រះយោគាវចរចាំបាច់ឈានកន្លងទាំង ២ យ៉ាងនោះ គឺ ទាំងឈាន ទាំងអារម្មណ៍យ៉ាងនោះ ដោយធ្វើមិនឲ្យ ( អាកាសានញ្ចាយតនៈនោះ ) ប្រព្រឹត្តទៅ និង ដោយមិនធ្វើទុកក្នុងចិត្ត ( ដល់អាកាសានញ្ចាយតនៈនោះ ) ប៉ុណ្ណោះ ទើបចូលដល់បាន ព្រោះហេតុនោះ ពាក្យថា

**ឈានកន្លងអាកាសានញ្ចាយតនៈនេះ** គប្បីជ្រាបថា លោកពោលរួមយកឈាន និង អារម្មណ៍ទាំង ២ នោះ ចូលជាមួយគ្នា ។

ពាក្យថា **អនន្តំ វិញ្ញាណំ** មានអធិប្បាយថា មនសិការយកការដឹងដែលប្រព្រឹត្តទៅ ផ្សាយទូទាំងអាកាសនិមិត្តនោះយ៉ាងនេះថា **អនន្តោ អាកាសោ** - អាកាសជាអនន្ត ដូច្នោះនោះឯងមកថា **អនន្តំ វិញ្ញាណំ**-វិញ្ញាណជាអនន្ត ដូច្នេះ , ន័យម្យ៉ាងទៀត វិញ្ញាណនោះជាអនន្តដោយអំណាចមនសិការ , ពិតណាស់ ព្រះយោគាវចរនោះ កាលមនសិការដល់វិញ្ញាណដែលមានអាកាសជាទីតាំងនោះ មិនមានចំណែកសល់ ក៏ប៉ុនគ្នានឹងមនសិការថា ( វិញ្ញាណ ) មិនមានទីបំផុត សូម្បីពាក្យណាដែលពោលក្នុងវិភង្គថា **អនន្តំ វិញ្ញាណន្តិ តញ្ញេវ អាកាសំ វិញ្ញាណេន ។បេ។ តេន វុច្ចតិ អនន្តំ វិញ្ញាណំ** ដូច្នេះ ។ បទថា **វិញ្ញាណេន** ក្នុងពាក្យនោះ បណ្ឌិតគប្បីជ្រាបថា ជាតតិយាវិភត្តិក្នុងអត្ថទុតិយាវិភត្តិ ព្រោះព្រះអដ្ឋកថាចារ្យទាំងឡាយពណ៌នាសេចក្ដីនៃបទនោះទៅន័យនោះ ទើបមានអធិប្បាយ ( ឲ្យប្រែ **វិញ្ញាណេន** ថា នូវវិញ្ញាណ ) ថាព្រះយោគាវចរផ្សាយ ( វិញ្ញាណ ) ទៅ គឺធ្វើទុកក្នុងចិត្តនូវវិញ្ញាណដែលសម្ផស្សនឹងអាកាសនិមិត្តនោះៗឯង មិនមានទីបំផុត ។

ចំណែកក្នុងពាក្យថា **ចូលដល់វិញ្ញាណញ្ចាយតនៈនោះ** មានអត្ថវិគ្រោះថា ទីបំផុតនៃវិញ្ញាណនោះមិនមាន ហេតុនោះ វិញ្ញាណនោះ ទើបឈ្មោះថា **អនន្ត អនន្ត** នោះឯងជា **អានញ្ច** លោកមិនបានពោលវិគ្រោះថាវិញ្ញាណជា **អានញ្ច** ឈ្មោះថា **វិញ្ញាណានញ្ច** តែពោលថា **វិញ្ញាណញ្ច** ទៅវិញ នេះឯងជា **រុឡ្ហិ** ស័ព្ទ ( ស័ព្ទចុះ ) ក្នុងអត្ថនេះ **វិញ្ញាណញ្ច** នោះ ឈ្មោះថា ជាអាយតនៈ ដោយអត្ថថា ជាទីអាស្រ័យនៅនៃឈាននោះ ព្រមទាំងសម្បយុត្តធម៌ ដូចពាក្យថា ទេវាយតនៈរបស់ទេវតា

*ទាំងឡាយ ព្រោះហេតុនោះ ឈាននោះ ទើបឈ្មោះថា វិញ្ញាណញ្ចាយតនៈ ( ឈានមានវិញ្ញាណមិនមានទីបំផុត ជាទីអាស្រ័យ ) ពាក្យដ៏សេស មានអត្ថដូចដែលពោលមកហើយនោះឯង ។ នេះជាពាក្យខែយ៉ាងពិស្តារ ក្នុងវិញ្ញាណញ្ចាយតនកម្មដ្ឋាន ។*

# មហាដីកា
# អធិប្បាយ វិញ្ញាណញ្ចាយតនៈ

*ព្រះយោគាវចរ ឈ្មោះថា **បានសន្សំវសីភាវៈ** ព្រោះអត្ថថា បានសន្សំ គឺប្រព្រឹត្តធ្វើឲ្យស្ទាត់ជំនាញនូវវសីភាវៈ ដែលមានការនឹកដល់ ( អង្គឈាន ) ជាដើមជាលក្ខណៈ , ដែលព្រះយោគាវចរបានសន្សំវសីភាវៈនោះ ។ ព្រោះមិនឈានកន្លងរូបាវចរសញ្ញាហើយ ក៏មិនអាចសម្រេចបាន , ព្រោះការប្រព្រឹត្តទៅក្នុងការធ្វើទុកក្នុងចិត្តនូវសញ្ញាដែលសហគតៈដោយរូបាវចរជ្ឈាននោះ ជាហេតុនាំមកនូវភាពជា ហាយនភាគិយសមាធិ ( សមាធិមានចំណែកនៃការវិនាស ) និងព្រោះការឈានកន្លងធម៌ដែលគួរឈានកន្លងយ៉ាងដទៃ អំពីរូបាវចរជ្ឈាននោះ នឹងមានការសម្រេចបាន ដោយការឈានកន្លងរូបាវចរជ្ឈាននោះៗ ឯង លោកទើបពោលថា ( សមាបត្តិនេះ ) មានសត្រូវ គឺ រូបាវចរជ្ឈាននៅជិត ដូច្នេះ ។ អរូបាវចរជ្ឈានទី ២ មានសភាពស្ងប់ក្រៃលែងជាងអរូបាវចរជ្ឈានទី ១ ព្រោះភាវៈដែលភាវនា ( ការចម្រើនដើម្បីធ្វើអរូបាវចរជ្ឈានទី ២ ឲ្យកើតឡើង ) ដែលដំណើរត្រង់វិថីហើយ ជា*

ហេតុនាំមកនូវភាពវិសេសក្រៃលែងឡើងទៅ និង ព្រោះជាហេតុឲ្យសម្រេចភាពប្រណីត ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា នឹងស្ងប់ដូចជាវិញ្ញាណញ្ចា-យតនៈក៏ទេ ដូច្នេះ ។ ពិតណាស់ លោកនឹងពោល ( តទៅខាងមុខ ) ថា ក្នុងអរូបសមាបត្តិទាំងនេះ អរូបសមាបត្តិក្រោយៗ ប្រណីតល្អជាង ដូច្នេះ ។ ពាក្យថា **មិនមានទីបំផុត មិនមានទីបំផុត** មានសេចក្តីថា មិនគប្បីមនសិការ គឺ មិនគប្បីចម្រើនទៅថា សេចក្តីថា មិនមានទីបំផុត មិនមានទីបំផុត តែម្យ៉ាង , តែគប្បីមនសិការទៅថា **វិញ្ញាណមិនមានទីបំផុត វិញ្ញាណមិនមានទីបំផុត** , ឬ គប្បីមនសិការទៅថា **វិញ្ញាណ វិញ្ញាណ** ដូច្នេះ ។

ពាក្យថា **ក្នុងនិមិត្តនោះ** គឺ ក្នុងវិញ្ញាណនិមិត្ត ពោលគឺ អរូបវិញ្ញាណដួងទី ១ នោះ ។ ពាក្យថា **ធ្វើចិត្តឲ្យត្រាច់ទៅ** គឺ ធ្វើភាវនាចិត្តឲ្យប្រព្រឹត្តទៅ ។ ពាក្យថា ក្នុងវិញ្ញាណដែលផ្សាយទៅកាន់អាកាស គឺ ក្នុងអរូបវិញ្ញាណទី ១ ដែលជាអារម្មណ៍ប្រព្រឹត្តទៅ ផ្សាយទៅកាន់កសិណុគ្ឃាដិមាកាស ។ ពាក្យថា **រមែងដល់អប្បនា** គឺ រមែងប្រព្រឹត្តទៅដោយអំណាចអប្បនា ។ អរូបវិញ្ញាណទី ២ នេះរមែងសម្រេចដល់អប្បនាបាន ក្នុងអារម្មណ៍សូម្បីជាសភាវធម៌ ដូចគ្នានឹងអរូប-វិញ្ញាណ ទី ៤ ព្រោះជាភាវនាឈានកន្លងអារម្មណ៍ ។ ក្នុងពាក្យថា **ចំណែកន័យនៃអប្បនាក្នុងវិញ្ញាណញ្ចាយតនៈនេះ** គប្បីជ្រាបតាមន័យដែលខ្ញុំព្រះករុណាបានពោលហើយនោះចុះ នេះមានសេចក្តីថា គប្បីជ្រាបតាមន័យដែលខ្ញុំព្រះករុណាបានពោលហើយក្នុងអរូបជ្ឈានទី ១ ថា ក្នុងអរូបជ្ឈានទី ២ ជវនចិត្ត ៣ ឬ ៤ ខណៈខាងដើមជាកាមាវចរចិត្តដែលសម្បយុត្តនឹងឧបេក្ខាវេទនាប៉ុណ្ណោះ ។ ជវនចិត្តខណៈទី ៤ ឬទី ៥ ជាអរូបាវចរចិត្ត ដូច្នេះជាដើម , ន័យម្យ៉ាងទៀត ពាក្យថា **ន័យនៃ**

**អប្បនា** បានដល់ ន័យអប្បនានៃឈានក្នុងអារម្មណ៍ សូម្បីជាសភាវធម៌ គឺថា អរូបជ្ឈាន រមែងដល់អប្បនាបាន ដោយទាក់ទងនឹងភាវនាឈានកទ្ធងអារម្មណ៍ សេចក្តីថា គប្បីជ្រាបតាមន័យដែលខ្ញុំព្រះករុណាបានពោលហើយ ក្នុងមរណា-នុស្សតិនិទ្ទេសថា ក្នុងអរូបជ្ឈាននោះ មានត្រឹមតែការឈានកទ្ធងអារម្មណ៍របស់ឈានដែលដល់អប្បនាហើយប៉ុណ្ណោះ ដូច្នេះ ។

បទថា **សព្វសោ** មានសេចក្តីថា ដោយអាការទាំងពួង គឺ ដោយអាការដែលសម្លឹងឃើញទោសទាំងអស់ក្នុងអរូបជ្ឈានទី ១ ក្នុងន័យមានអាទិ៍យ៉ាងនេះថា មានភាពជាឈានដែលមានសត្រូវ គឺ រូបជ្ឈាននៅជិត , មានភាពជាឈានដែលមានសភាវៈមិនស្ងប់ , ឬថា ដោយអាការ មានការលះបង់សេចក្តីអាល័យក្នុងអរូបជ្ឈាន ទី ១ នោះ ភាពជាអ្នកមិនត្រូវការនឹងនឹកដល់ជាដើម , ម្យ៉ាងទៀត ( ឈានកទ្ធងអាកាសានញ្ចាយតនៈ ) ទាំងពួង គឺ មិនមានសល់ដោយប្រភេទនៃឈានដែលជាកុសល វិបាក និង កិរិយា ។ ក៏អធិប្បាយនេះនោះ បណ្ឌិតអាចជ្រាបបានតាមន័យដែលលោកពោលទុកហើយក្នុងខាងដើម ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា បទថា **សព្វសោ** នេះ មានន័យដូចពោលហើយនោះឯងដូច្នេះ , ភាវៈដែលឈាន ឈ្មោះថា អាកាសានញ្ចាយតនៈ លោកបានពោលទុកហើយក្នុងខាងដើម ដោយទាក់ទងនឹងពាក្យដែលជា **ពាហិរត្ថសមាស** ព្រោះហេតុនោះ លោកទើបពោលថា សូម្បីឈានក៏ឈ្មោះថា អាកាសានញ្ចាយតនៈតាមន័យដែលបានពោលហើយខាងដើម ។ ដើម្បីសម្តែងមាតិកាដែលថា ចំណែកភាវៈដែលអារម្មណ៍ ឈ្មោះថា អាកាសានញ្ចាយតនៈបាន ក៏ដោយទាក់ទងនឹងពាក្យសមាស ដែលមានអធិករណ៍ស្មើគ្នាដូច្នោះ លោកអាចារ្យទើបពោលថា សូម្បី

អារម្មណ៍ ( ក៏ឈ្មោះថា អាកាសានញ្ចាយតនៈ ) ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **តាមន័យមុននោះឯង** នេះលោកពោលសំដៅយករូបសម្រេចនៃបទដែលបានពោលទុក ដោយពាក្យថា ឈ្មោះថា **អនន្ត** ព្រោះអត្ថថា ជាវត្ថុដែលមិនមានទីបំផុតជាដើម ។ លោកអាចារ្យបំណាងសម្ដែងថា អត្ថន័យក្នុងពាក្យថា អាកាសានញ្ចាយតនៈនេះ រមែងសមគួរដោយ " **អាយតន** " សព្ទ សូម្បីមានន័យថា ជាប្រទេសដែលកើត ដូចដែលសមគួរដោយ " **អាយតន** " សព្ទដែលមានន័យថា ជាទីតាំងទីអាស្រ័យ ដូច្នេះ ទើបពោលថា **តថា** ដូច្នេះជាដើម ។ ក្នុងពាក្យនោះ ឈ្មោះថា **សញ្ជាតិ** ព្រោះអត្ថថា ជាទីកើត សញ្ជាតិនោះឯងជា **ទេស** ទើបឈ្មោះថា **សញ្ជាតិទេស** ( ប្រែថា ប្រទេសទីកើត ) ។ គប្បីប្រកបឈានទុកដោយការធ្វើមិនឲ្យប្រព្រឹត្តទៅ ។ គប្បីប្រកបអារម្មណ៍ទុកដោយការមិនធ្វើទុកក្នុងចិត្ត ។ ឬថាប្រកបធម្មជាតិទាំងពីរទុកដោយប្រការទាំង ២ ។ ពិតណាស់ សូម្បីការមិននឹកដល់ឈាន , ឬ ការមិនធ្វើកវជ្ជចិត្តឲ្យមានការអស់ទៅ ដោយជវនបដិបាទកមនសិការ ក៏ឈ្មោះថា ជាការមិនធ្វើ ( ឈាននោះ ) ទុកក្នុងចិត្ត , និងការមិនធ្វើអារម្មណ៍ឲ្យប្រព្រឹត្តទៅ ដោយទាក់ទងនឹងការធ្វើឲ្យជាអារម្មណ៍ ឈ្មោះថា ជាការធ្វើ ( អារម្មណ៍ ) មិនឲ្យប្រព្រឹត្តទៅ ព្រោះមានអត្ថយ៉ាងនេះ ព្រះមានព្រះភាគទើបត្រាស់រួមយកធម្មជាតិ ទាំងពីរចូលគ្នា ( ដោយពាក្យថា អាកាសា-នញ្ចាយតនៈត្រឹមតែពាក្យមួយ ) ដោយជាពាក្យសម្ដែងខៃយ៉ាងសាមញ្ញ ឬ ដោយន័យដ៏សេសទុកបទមួយ ។

អរូបវិញ្ញាណដួងដំបូង ហៅថា **អនន្តំ វិញ្ញាណំ** ព្រោះព្រះយោគាវចរគប្បីមនសិការថា មិនមានទីបំផុត តាមអាការដែលផ្សាយទៅរបស់ខ្លួននោះឯង ដោយ

ទាក់ទងនឹងការធ្វើអាការដែលមិនមានទីបំផុត ឲ្យជាអារម្មណ៍ទុកខាងដើម , មួយាង ទៀត ហៅថា **អនន្តំ** ដោយទាក់ទងនឹងការធ្វើទុកក្នុងចិត្តដដែលៗ អធិប្បាយថា ដោយទាក់ទងនឹងការធ្វើទុកក្នុងចិត្តដោយអស់ជើង ។ ព្រោះហេតុនោះ លោក អាចារ្យទើបពោលថា កាលធ្វើទុកក្នុងចិត្ត ។ល។ ដោយមិនមានសល់ ក៏ឈ្មោះថា ធ្វើទុកក្នុងចិត្តថា មិនមានទីបំផុតដូច្នេះ ។ លោកអាចារ្យកាលនឹងសម្តែងថា សូម្បី ក្នុងឈានវិភង្គក៏ត្រាស់ន័យនេះឯងទុក ដូច្នេះទើបពោលថា សូម្បីពាក្យដែល ត្រាស់ទុកក្នុងគម្ពីរវិភង្គឯណា ដូច្នេះជាដើម ។ មួយាងទៀត គប្បីជ្រាបអត្ថន័យនៃ ព្រះបាលីនោះយ៉ាងនេះថា ៖

រមែងធ្វើទុកក្នុងចិត្តនូវវិញ្ញាណដែលផ្សាយទៅកាន់អាកាសនោះឯង ដោយ វិញ្ញាណញ្ចាយតនវិញ្ញាណ ដូច្នេះ ។ អត្ថន័យនេះប្រាកដថា គួរនឹងត្រឹមត្រូវហើយ មានសេចក្តីថា រមែងធ្វើទុកក្នុងចិត្តនូវវិញ្ញាណដែលផ្សាយទៅកាន់អាកាសនោះឯង មានអាការដែលវិញ្ញាណនោះកាន់យកបានហើយ ។ ឈ្មោះថា រមែងផ្សាយទៅនូវ វិញ្ញាណនោះ មិនមានទីបំផុត យ៉ាងនេះដូច្នោះឯង ។ ពិតណាស់ ព្រះយោគីដែល ដល់ព្រមដោយអរូបវិញ្ញាណទី ១ ផ្សាយអាកាសណាទៅ មិនមានទីបំផុតដោយ វិញ្ញាណ , ព្រះយោគីដែលដល់ព្រមដោយអរូបវិញ្ញាណទី ២ កាលធ្វើទុកក្នុងចិត្ត នូវវិញ្ញាណ ដែលប្រព្រឹត្តទៅរួមគ្នានឹងអាការដែលផ្សាយទៅកាន់អាកាសនោះឯង ហៅថា ផ្សាយទៅមិនមានទីបំផុត ។

ក្នុងអរូបជ្ឈានទី ១ នេះ មានភាពជាអនន្តៈ គឺ មិនមានទីបំផុតដោយអំណាច នៃការធ្វើទុកក្នុងចិត្ត ដោយអាការដែលផ្សាយទៅមិនមានទីបំផុត មិនមែនមាន ភាពជាអនន្តៈ ព្រោះភាពមិនមានទីបំផុត គឺ ការកើតឡើងជាដើម ដូចជាអាកាស

ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ឈ្មោះថា **អនន្ត** ព្រោះអត្ថថា ជាវត្ថុមិនមានទីបំផុតត្រឹមនេះប៉ុណ្ណោះ ។ ព្រោះពាក្យថា **រុឡ្ហិ** ស័ព្ទនេះ លោកសម្ដែងថា **វិញ្ញាណញ្ច** ក្នុងអត្ថនៃបទថា **វិញ្ញាណានញ្ច** នេះ ជាស័ព្ទដែលនិយមប្រើ , ម្យ៉ាងទៀត ក្នុងពាក្យថា **វិញ្ញាណញ្ច** នេះ បណ្ឌិតគប្បីឃើញន័យយ៉ាងនេះថា វិញ្ញាណតាមដែលពោលហើយ( គឺអរូបវិញ្ញាណទី ១ ) , ឈ្មោះថា **វិញ្ញាណញ្ច** ព្រោះអត្ថថា ត្រូវអរូបជ្ឈានទី ២ ទាញទុក គឺ ទាក់ទងនឹងអាការដែលពោលហើយ ។ ពាក្យដ៏សេសមានអត្ថដូចបានពោលហើយនោះឯង ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា ពាក្យដ៏សេស ក៏មានអត្ថដូចគ្នានឹងពាក្យដែលពោលទុកមុនៗ នោះឯង ដូច្នេះ ។

( ចប់ មហាដីកា )

( ការអធិប្បាយ វិញ្ញាណញ្ចាយតនៈ ចប់ដោយប្រការដូច្នេះ )

# អាកិញ្ចញ្ញាយតនៈ

ចំណែកព្រះយោគាវចរ ដែលមានបំណងនឹងចម្រើនអាកិញ្ចញ្ញាយតនៈ គប្បីជាអ្នកប្រព្រឹត្តវសីភាវៈ ( ធ្វើឲ្យជំនាញ ) ក្នុងវិញ្ញាណញ្ចាយតនសមាបត្តិ ដោយអាការ ៥ យ៉ាង ហើយ ( ពិចារណា ) ឲ្យឃើញទោសក្នុងវិញ្ញាណញ្ចាយតនៈ ថា " **សមាបត្តិនេះ មានសត្រូវ គឺ អាកាសានញ្ចាយតនៈនៅជិត និង មិនល្អិតដូចអាកិញ្ចញ្ញាយតនៈ** " ដូច្នេះហើយ លះបង់ការពេញចិត្តក្នុងវិញ្ញាណញ្ចាយតនៈនោះចេញ បង្អោនចិត្តទៅក្នុងអាកិញ្ចញ្ញាយតនៈ ថាជា ធម៌ល្អិតសុខុម ធ្វើទុកក្នុងចិត្តដល់ **ការមិនមាន ភាពសូន្យទទេ អាការដែលសោះសូន្យទៅ** នៃការដឹងក្នុងអាកាសានញ្ចាយតនៈ ដែលជាអារម្មណ៍នៃវិញ្ញាណញ្ចាយតនៈនុ៎ះ , សួរថា គប្បីធ្វើទុកក្នុងចិត្តដូចម្តេច ? ឆ្លើយថា កុំដាក់ចិត្តដល់ការដឹងនោះ រំពឹងធ្វើទុកក្នុងចិត្តដោយការកំណត់ថា **នត្ថិ នត្ថិ - មិនមាន មិនមាន** ឬថា **សុញ្ញំ សុញ្ញំ - សូន្យសូន្យ** ឬថា **វិវិត្តំ វិវិត្តំ - ទទេ ទទេ** ដូច្នេះ រឿយ ៗ ទៅ ធ្វើរហូតជា **តក្កាហតវិតក្កាហត** កាលលោកញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅក្នុងនិមិត្តនោះរឿយៗ យ៉ាងនោះនីវរណធម៌ទាំងឡាយនឹងស្ងប់ម្ងាប់ទៅ សតិនឹងតាំងមាំ ចិត្តនឹងជាសមាធិ ថ្នាក់ឧបចារៈ លោកសេពចម្រើន ធ្វើឲ្យច្រើននូវនិមិត្តនោះរឿយៗទៅ កាលធ្វើដូច្នោះអាកិញ្ចញ្ញាយតនចិត្តរមែងតាំងមាំ ( ជាអប្បនា ) នៅក្នុងភាពសោះសូន្យនោះ ឬការមិនមាននៃមហគ្គតវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងអាកាស ( និមិត្ត ) នោះឯងដូចវិញ្ញាណញ្ចាយតនចិត្ត ដែលតាំងមាំនៅក្នុងមហគ្គតវិញ្ញាណដែលផ្សាយទៅ ក្នុងអាកាស ( និមិត្ត ) ដូច្នោះ ។

## អាកិញ្ចញ្ញាយតនៈឃើញតែការមិនមាន

រីឯ ន័យនៃអប្បនា ក្នុងអាកិញ្ចញ្ញាយតនៈនេះ បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលហើយ ( ក្នុងអាកាសានញ្ចាយតនៈ ) ចុះ តែនេះជាសេចក្តីផ្សេងគ្នា គឺ កាលអប្បនាចិត្តនោះកើតឡើង ( យោគាវចរ ) ភិក្ខុនោះ ឃើញការដឹងដែលប្រព្រឹត្តទៅក្នុងអាកាសជាទស្សនវិស័យនៃវិញ្ញាណញ្ចាយតនឈានមុនហើយ កាលការដឹងនោះវិនាសទៅហើយ ព្រោះមនសិការដោយបរិកម្មថា “ **មិនមាន មិនមាន** ” ជាដើមហើយ ក៏ឃើញតែការមិនមាន ពោលគឺ ការប្រាសទៅនៃការដឹងនោះ ប្រៀបដូចបុរស ឃើញភិក្ខុសង្ឃប្រជុំគ្នា ដោយករណីយ៍ខ្វះ នៅក្នុងស្ថានទីប្រជុំមានរោងមូលជាដើម រួចហើយក៏ចេញទៅអស់ បន្ទាប់ពីសម្រេចកិច្ចប្រជុំហើយ ភិក្ខុទាំងឡាយក្រោកឡើងអស់ហើយ ក៏បានមកឈរនៅត្រង់ទ្វារមើលស្ថានទីនោះទៀត ក៏ឃើញតែភាពទទេប៉ុណ្ណោះ ឃើញតែភាពមិនមានប៉ុណ្ណោះ ការគិតទំនងនេះរមែងមិនមានដល់គេថា “ ស្លាប់ហើយ ភិក្ខុទាំងឡាយនោះស្លាប់អស់ ឬថា គ្រប់អន្តរធានអស់ ” ដែលពិត គេឃើញតែការមិនមាន ដោយភាពទទេប៉ុណ្ណោះ នោះឯង ។

ឯការវិនានុក្រមត្រឹមប៉ុណ្ណោះ ព្រះយោគាវចរនោះ ហៅថា “ ឈានកន្លងវិញ្ញាណញ្ចាយតនៈដោយប្រការទាំងពួងហើយ ធ្វើទុកក្នុងចិត្តថា **នត្ថិ កិញ្ចិ - អ្វីតិចតួចមិនមាន** ក៏ចូលដល់អាកិញ្ចញ្ញាយតនៈ ” ។

## អធិប្បាយ ចាប់ក្នុងអាកិញ្ចញ្ញាយតនៈ

សូម្បីក្នុងទីនេះ បទថា **សព្វសោ - ដោយប្រការទាំងពួង** នេះក៏មានន័យ

ដូចដែលពោលហើយនោះឯង ។ ម្យ៉ាងទៀត ក្នុងបទ “ វិញ្ញាណញ្ចាយតនៈ ” នេះ ក៏សំដៅយកទាំងឈានទាំងអារម្មណ៍ ជាវិញ្ញាណញ្ចាយតនៈ តាមន័យដែលពោលមកខាងដើមដូចគ្នា ពិតហើយសូម្បីអារម្មណ៍ ក៏ឈ្មោះថា វិញ្ញាណញ្ចាយតនៈ ព្រោះអត្ថវិគ្រោះថា “ **វិញ្ញាណញ្ចៈ** - វិញ្ញាណមិនមានទីបំផុតផង , **វិញ្ញាណញ្ចៈ** នោះ ឈ្មោះថាជា អាយតនៈផង ក្នុងអត្ថថា ជាទីអាស្រ័យ ដូច ( ពាក្យថា ) ទេវាយតនៈ របស់ទេវតាទាំងឡាយ , ព្រោះវិញ្ញាណញ្ចៈនោះ ជាអារម្មណ៍របស់អរូបឈានទី ២ ផង ” ដូច្នេះ តាមន័យខាងដើមនោះឯង , ម្យ៉ាងទៀត អារម្មណ៍ឈ្មោះថា វិញ្ញាណញ្ចាយតនៈ ព្រោះអត្ថវិគ្រោះថា “ វិញ្ញាណញ្ចៈផង , វិញ្ញាណញ្ចៈនោះ ឈ្មោះថាជា **អាយតនៈ** ដោយអត្ថថា ជាទីកើត , ដូចពាក្យថា ដែនកម្ពុជាជាអាយតនៈ ( ជាទីកំណើត ) នៃសេះទាំងឡាយជាដើម ព្រោះវិញ្ញាណញ្ចៈជាហេតុឲ្យកើតនៃឈាននោះ ដូចគ្នា ” ដូច្នេះក៏បាន ព្រោះហេតុដែលអាកិញ្ចញ្ញាយតនៈនេះ ព្រះយោគាវចរចាំបាច់ត្រូវឈានកន្លងទាំង ២ យ៉ាងនោះ គឺ ទាំងឈាន ទាំងអារម្មណ៍ ដោយធ្វើមិនឲ្យ ( វិញ្ញាណញ្ចាយតនៈនោះ ) ប្រព្រឹត្តទៅនិងដោយមិនធ្វើទុកក្នុងចិត្ត ( ដល់វិញ្ញាណញ្ចាយតនៈនោះប៉ុណ្ណោះ ) ទើបអាចចូលដល់បាន ព្រោះហេតុនោះ ពាក្យថា “ ឈានកន្លងវិញ្ញាណញ្ចាយតនៈ ” នេះគប្បីជ្រាបថា លោកពោលរួមយកឈាន និង អារម្មណ៍ទាំង ២ នោះ ចូលគ្នា ។

ពាក្យថា **នត្ថិ កិញ្ចិ** - អ្វីតិចតួចមិនមាន នោះ មានអធិប្បាយថា មនសិការយ៉ាងនេះថា **នត្ថិ នត្ថិ** - មិនមាន មិនមាន , **សុញ្ញំ សុញ្ញំ** - សូន្យ សូន្យ , **វិវិត្តំ វិវិត្តំ** - ទទេ ទទេ ដូច្នេះ , សូម្បីពាក្យបានពោលទុកក្នុងវិភង្គថា “ ពាក្យថា **នត្ថិ កិញ្ចិ** គឺ ធ្វើវិញ្ញាណនោះឯង មិនឲ្យមាន ឲ្យប្រាសទៅ ឲ្យអន្តរធានទៅ

( រហូត ) ដល់ឃើញថា **អ្វីតិចតួចមិនមាន** ព្រោះដូច្នោះ ទើបហៅថា **នត្ថិ កិញ្ចិ** ដូច្នេះ , ពាក្យនោះ ហាក់ដូចពោលដល់ការពិចារណាដោយការវិនាសទៅក៏ពិតតែដែលពិត សេចក្ដីនៃពាក្យនោះ គប្បីយល់ដូចដែលពោលនោះចុះ ព្រោះកាលព្រះយោគាវចរ មិននឹកដល់ មិនធ្វើទុកក្នុងចិត្តដល់ មិនកំណត់ចិត្តដល់វិញ្ញាណនោះទេ ដាក់ចិត្តតែក្នុងការមិនមាន ភាពសូន្យ ភាពទទេ របស់វាតែម្យ៉ាងប៉ុណ្ណោះ ទើបហៅបានថា ធ្វើមិនឲ្យមាន ឲ្យប្រាសទៅ ឲ្យអន្តរធានទៅ មិនមែនដោយយ៉ាងដទៃឡើយ ។

រីឯ ក្នុងពាក្យថា **ចូលដល់អាកិញ្ចញ្ញាយតនៈ** នោះ មានអត្ថវិគ្រោះថា **អ្វីតិចតួចនៃវិញ្ញាណនោះ មិនមាន** ព្រោះហេតុនោះ វិញ្ញាណនោះ ទើបឈ្មោះថា **អកិញ្ចនៈ** មានអធិប្បាយថា វត្ថុដ៏សេសនៃវិញ្ញាណនោះ ក្នុងទីបំផុត សូម្បីត្រឹមតែការរលត់ក៏មិនមាន , ភាពជា **អាកិញ្ចន** ឈ្មោះថា **អាកិញ្ចញ្ញ** ពាក្យនេះជាពាក្យហៅការប្រាសទៅនៃវិញ្ញាណ ( ការដឹងដែលមាន ) ក្នុងអាកាសានញ្ចាយតនៈ ( នោះឯង ) , **អាកិញ្ចញ្ញ** នោះ ឈ្មោះថា ជាអាយតនៈ ដោយអត្ថថា ជាទីអាស្រ័យនៃឈាននោះ ដូចពាក្យថា ទេវាយតនៈរបស់ទេវតាទាំងឡាយ ព្រោះហេតុនោះ ឈាននោះ ទើបឈ្មោះថា **អាកិញ្ចញ្ញាយតនៈ** ( ឈានមានការមិនមានវិញ្ញាណតិចតួច ជាទីអាស្រ័យ ) ពាក្យដ៏សេស មានអត្ថដូចដែលពោលមកខាងដើមនោះឯង ។

នេះជាពាក្យអធិប្បាយយ៉ាងពិស្ដារក្នុងអាកិញ្ចញ្ញាយតនកម្មដ្ឋាន ។

# មហាដីកា

# អធិប្បាយ អាកិញ្ចញ្ញាយតនៈ

ក្នុងអរូបកម្មដ្ឋាន ទី ៣ មានពាក្យណាដូចពាក្យដែលពោលទុកហើយពីខាងដើម គប្បីជ្រាបពាក្យនោះតាមទំនងនៃន័យដែលខ្ញុំម្ចាស់ពោលអធិប្បាយហើយចុះ ខ្ញុំម្ចាស់នឹងអធិប្បាយតែចំពោះពាក្យដែលមិនទាន់អធិប្បាយប៉ុណ្ណោះ ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **នៃអារម្មណ៍នោះឯង** គឺ នៃអារម្មណ៍ដែលវិញ្ញាណញ្ចាយតនៈប្រារព្ធកើតឡើង នោះឯង ។ សួរថា អារម្មណ៍នោះ គឺ អ្វី ? លោកអាចារ្យពោលថា គឺ **នៃអាកាសានញ្ចាយតនវិញ្ញាណ** ដូច្នេះ ។ ដោយពាក្យនេះ លោកសម្តែងថា អារម្មណ៍នៃអរូបជ្ឈាន ទី ៣ ដែលផ្សេងពីការមិនមាននៃអាកាសានញ្ចាយតនវិញ្ញាណនោះ ក៏មិនមែន ។ ដោយពាក្យថា ដែលជាអារម្មណ៍នេះ លោកបដិសេធអរូបវិញ្ញាណ ទី ២ ដែលមិនបានជាអារម្មណ៍នៃអាកិញ្ចញ្ញាយតនៈនោះ ។ បទថា **អភាវោ** ប្រែថា ការមិនមាន ។ បទថា **សុញ្ញតា** ប្រែថា សូន្យ ។ បទថា **វិវិត្តាការោ** - អាការដែលទទេ បានដល់ ភាពស្ងប់ស្ងាត់ ។ លោកពោលដល់ការប្រាសទៅនៃអរូបវិញ្ញាណដួងទី ១ ទុកដោយបទទាំង ៣ នោះឯង ។ លោកអាចារ្យកាលពោលថា " គប្បីធ្វើទុកក្នុងចិត្ត " ដូច្នេះហើយ ក៏បំណងសម្តែងវិធីធ្វើទុកក្នុងចិត្ត ទើបពោលថា " ( គឺ មិនធ្វើទុកក្នុងចិត្ត ) ដល់វិញ្ញាណនោះ " ដូច្នេះជាដើម ។ ក្នុងពាក្យទាំងឡាយនោះ ពាក្យថា **មិនធ្វើទុកក្នុងចិត្ត** គឺ មិនធ្វើទុកក្នុងចិត្ត បានដល់ មិនគិតដល់ដោយអស់ជើង ។ **វា** ស័ព្ទ មានអត្ថថា មិនកំណត់ពិតប្រាកដ , ដោយ **វា** ស័ព្ទ នោះ លោកសម្តែងថា ក្នុងប្រការទាំង

៣ យ៉ាង ( មានប្រការថា **នត្ថិ នត្ថិ** ជាដើម ) សូម្បីប្រការតែមួយ ក៏សម្រេចប្រយោជន៍បាន ។

ពាក្យថា **ក្នុងនិមិត្តនោះ** បានដល់ ក្នុងនិមិត្ត គឺ ហេតុកើតឡើងនៃឈានពោលគឺ ការមិនមាននៃអរូបទី ១ នោះ ។ ២ បទថា **អាកាសេ ផុដ្ឋេ** ប្រែថា ក្នុងការមិនមាននៃមហគ្គតវិញ្ញាណ ដែលប្រព្រឹត្តផ្សាយទៅកាន់អាកាស ។ ឬថា បាឋៈនឹងជា **អាកាសផុដ្ឋេ** ដូច្នេះ ។ បទថា **សុញ្ញវិវិត្តនត្ថិភាវេ** ប្រែថា ក្នុងភាពទទេ , ក្នុងភាពសោះសូន្យ , និងក្នុងការមិនមាន ដូច្នេះលោកពោលទុកដើម្បីកាន់យកបាន ( យល់ ) នូវអាការដែលជាហេតុធ្វើឲ្យកើតឡើង ។ ន័យម្យ៉ាងទៀត បទថា **សុញ្ញវិវិត្តនត្ថិភាវេ** ប្រែថា ក្នុងការមិនមាន ពោលគឺ ភាពសោះសូន្យ និងភាពទទេ , ដោយពាក្យនោះ លោកសំដែងដល់ការមិនមាន គឺ ការវិនាសទៅនោះឯង , មិនមែនសម្ដែងដល់ការមិនមាន មកក្នុងខាងដើមទេ ។

ពាក្យថា **គឺថា កាលបើអប្បនាចិត្តនោះកើតឡើងហើយ** គឺ កាលចិត្តដែលសម្បយុត្តជាមួយអាកិញ្ចញ្ញាយតនឈាន ដែលប្រព្រឹត្តទៅដោយអំណាចអប្បនាកើតឡើងហើយ , ឬថា កាលអប្បនាចិត្តតាមដែលពោលហើយនោះ កើតឡើងហើយ ក្នុងភាវៈមិនមាន ពោលគឺ ការប្រាសទៅនៃអរូបវិញ្ញាណជួងទី ១ ។ ភ្ជាប់សេចក្ដីថា ភិក្ខុនោះ ក៏រមែងសម្លឹងឃើញចំពោះភាវៈមិនមានប៉ុណ្ណោះឯង ។ ប្រែកបសេចក្ដីថា បុរសទៅក្នុងទីដទៃ កាលត្រឡប់មកវិញ ក៏ឃើញតែទីទទេប៉ុណ្ណោះ , គឺ ឃើញតែភាពមិនមានប៉ុណ្ណោះ ដូច្នេះ ។ ពាក្យថា **ស្ថានទីនោះ** គឺ ( ក្រឡេកមើល ) ស្ថានទីដែលប្រជុំនោះ ។ ដោយពាក្យថា **អន្តរធានទៅព្រោះការធ្វើទុកក្នុងចិត្ត គឺ ការបរិកម្ម** នេះ លោកអាចារ្យសម្ដែងថា វិញ្ញាណនោះ មានការអន្តរធាន

ទៅ ក៏ព្រោះមិនមានការធ្វើឲ្យជាអារម្មណ៍ មិនមែនព្រោះការវិនាសទៅឡើយ ។ តទៅនេះ ជាប្រការប្រៀបធៀបជាមួយឧបមា ក្នុងឧបមេយ្យនោះ ប្រៀបធៀបដូចជាបុរសម្នាក់នោះ ឃើញពួកភិក្ខុប្រជុំគ្នា នៅកន្លែងនោះហើយ ក៏ចេញទៅ , កាលភិក្ខុគ្រប់រូបចេញចាកទៅពីទីកន្លែងនោះ ព្រោះករណីយ៍កិច្ចខ្លះ គេត្រឡប់មក ក៏រមែងឃើញតែទីកន្លែង ដែលសូន្យទទេចាកភិក្ខុទាំងឡាយនោះប៉ុណ្ណោះ , រមែងមិនពិចារណាដល់ហេតុដែលភិក្ខុទាំងឡាយ ចេញចាកទៅពីកន្លែងនោះ យ៉ាងណា , ព្រះយោគាវចរនេះក្នុងកាលមុន ឃើញអរូបវិញ្ញាណដួងទី ១ ដោយចក្ខុ គឺ វិញ្ញាណញ្ចាយតនឈានហើយ ក្នុងខាងក្រោយ កាលវិញ្ញាណនោះ ប្រាសទៅហើយ ព្រោះការធ្វើទុកក្នុងចិត្ត គឺ ការបរិកម្មថា មិនមាន ក៏រមែងឃើញតែការមិនមាននៃវិញ្ញាណនោះ ដោយចក្ខុ គឺ អរូបជ្ឈានទី ៣ ប៉ុណ្ណោះ មិនពិចារណាដល់ហេតុដែលវិញ្ញាណនោះប្រាសទៅទេ ព្រោះឈាននោះ មិនមានការពិចារណាបែបនោះដូច្នេះឯង ។ ក្នុងបទថា **សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម** នេះ គួរនឹងពោលពាក្យអត្ថាធិប្បាយណាទុក ពាក្យអត្ថាធិប្បាយនោះ បណ្ឌិតគប្បីជ្រាបតាមទំនងនៃន័យដែលខ្ញុំម្ចាស់បានពោលហើយ ក្នុងខាងដើមចុះ ។

លោកអាចារ្យ កាលនឹងពោលដល់ន័យរបស់បទថា “ **នត្ថិ** ” ថា ឈ្មោះថា ការមិនមាន ដោយបរិយាយក៏បានដល់ ភាពសូន្យ និង ភាពទទេ ដូច្នេះ ទើបបានកាន់យកទាំងបទថា **សុញ្ញ** - សូន្យ និង បទថា **វិវិត្ត** - ទទេ ។ ក៏ពាក្យនិយាយដដែលៗ ( ថា **មិនមាន មិនមាន , សូន្យ សូន្យ , ទទេ ទទេ** ) ជាពាក្យសម្តែងអាការចម្រើន ។ ដើម្បីសម្តែងថា ន័យរបស់បទនេះដែលត្រាស់ទុកនៅក្នុងគម្ពីរព្រះវិភង្គ ក៏ដូចគ្នាដែរ ដូច្នេះ , លោកទើបពោលថា “ **យម្បិ វិភង្គេ** ”

ដូច្នេះជាដើម ។ ក្នុងបាឋៈព្រះបាលីនោះ ពាក្យថា **រមែងធ្វើវិញ្ញាណនោះឯង មិនឲ្យមាន** មានន័យថា អរូបវិញ្ញាណដួងទី ១ ដែលធ្វើទុកក្នុងចិត្តថា " **អនន្តំ វិញ្ញាណំ** " វិញ្ញាណមិនមានទីបំផុតខាងដើម បានដល់ ធ្វើអរូបជ្ឈានដួងទី ១ នោះឯង ។ អធិប្បាយ សេចក្តីថា ធ្វើអរូបវិញ្ញាណដួងទី ១ នោះឯង ដែលជាអារម្មណ៍ មិនឲ្យមានដោយអរូបវិញ្ញាណដួងទី ៣ ដូចធ្វើរូបនិមិត្តមិនឲ្យមាន ដោយអរូប-វិញ្ញាណដួងទី ១ ដូច្នោះ ។ ពាក្យថា **ប្រសិនបើទ្រង់ត្រាស់ដល់ការពិចារណាថា អស់ទៅ** លោកអាចារ្យពោលដល់ កង្ខានុបស្សនាញាណ ។ ពិតហើយ លោកអាចារ្យមានបំណងថា កង្ខានុបស្សនាញាណនោះ ឃើញចំពោះការមិនមាន គឺ ការបែកធ្លាយទៅនៃសង្ខតធម៌ទាំងឡាយប៉ុណ្ណោះ ក៏អាចនឹងពោលបានថា " សូម្បីវិញ្ញាណ ធ្វើមិនឲ្យមាន " ដូច្នេះជាដើម ទើបពោលថា " **ប្រសិនបើត្រាស់ដល់ការពិចារណាថា អស់ទៅ** " ដូច្នេះ ។ បទថា **អស្ស** ប្រែថា នៃឋានៈនោះ ។ បទថា **អស្ស** បទមួយទៀត ប្រែថា នៃវិញ្ញាណនោះ ។ បទថា **អភាវេតិ** ប្រែថា ធ្វើមិនឲ្យមាន , បានដល់ ធ្វើទុកដោយប្រការដែលមិនប្រាកដដល់ញាណ ដោយការមិនធ្វើទុកក្នុងចិត្ត ។ ព្រោះហេតុនោះ ទើបឈ្មោះថា **ធ្វើឲ្យប្រាសទៅ** គឺ ធ្វើឲ្យលត់ទៅ , ឬថា ធ្វើឲ្យវិនាសទៅ ដោយធ្វើតាមប្រការឲ្យប្រាកដមិនបាន ។ ព្រោះហេតុនោះឯង ធ្វើឲ្យ **អន្តរធានទៅ** គឺ ធ្វើឲ្យដល់នូវចំណែកខាងក្រៅ ។ ពាក្យថា **មិនមែនដោយប្រការដទៃ** អធិប្បាយថា ព្រះបាលីនេះ មានន័យដូចប្រការពោលហើយ , មិនមែនដោយប្រការដទៃក្រៅពីនេះទេ ព្រោះមិនត្រឹមត្រូវ ។

បទថា **អស្ស** បានដល់ ការមិនមាននៃអរូបវិញ្ញាណដួងទី ១ ។ បទថា **កិញ្ចនំ** ប្រែថា ត្រឹមតែតិចតួច ។ ឈ្មោះថា ការមានប្រាកដតិចតួចនៃសភាវធម៌

គប្បីបានដល់ ការរលត់នោះឯង ព្រោះហេតុនោះ ទើបលោកអាចារ្យពោលថា “ **វិញ្ញាណនេះ មិនមានវត្ថុដែលនៅសល់ ដោយទីបំផុតសូម្បីត្រឹមតែការរលត់ទៅ** ” ដូច្នេះ ។ ពិតហើយ សូម្បីត្រឹមតែការរលត់នៅប្រាកដ វិញ្ញាណនោះ នឹងជាវិញ្ញាណដែលនៅមានតិចតួច ។ម្យ៉ាងទៀត បទថា **អកិញ្ចនំ** លោកអាចារ្យពោលដល់ការប្រាសទៅដោយអស់ជើងនៃវិញ្ញាណ មិនកាន់យកប្រការណា ៗ ។ ពាក្យដ៏សេស មានន័យដូចខ្ញុំម្ចាស់បានពោលហើយ ។

( ចប់ មហាដីកា )

( ការអធិប្បាយ អាកិញ្ចញ្ញាយតនៈ ចប់ដោយប្រការដូច្នេះ )

# នេវសញ្ញានាសញ្ញាយតនៈ

ចំណែកព្រះយោគាវចរភិក្ខុ អ្នកប្រាថ្នានឹងចម្រើននេវសញ្ញានាសញ្ញាយតនៈ ( តទៅ ) គប្បីប្រព្រឹត្តវសីភាវៈ ( ធ្វើឲ្យជំនាញ ) ក្នុងអាកិញ្ចញ្ញាយតនសមាបត្តិ ដោយអាការ ៥ ហើយ ( ពិចារណាឲ្យ ) ឃើញទោសក្នុងអាកិញ្ចញ្ញាយតនៈ យ៉ាងនេះថា “ សមាបត្តិនេះមានសត្រូវ គឺ វិញ្ញាណញ្ចាយតនៈនៅជិត និង នៅមិនទាន់ល្អិតដូចនេវសញ្ញានាសញ្ញាយតនៈ ឬ ( ឃើញទោស ) ថា សញ្ញាដូចជារោគ សញ្ញាដូចជាបូស សញ្ញាដូចជាកូនសរ ធម្មជាតិនោះល្អិត ធម្មជាតិនោះប្រណីត ធម្មជាតិនោះ គឺអ្វី ធម្មជាតិនោះ គឺ នេវសញ្ញានាសញ្ញាយតនៈ ” និង ( ឃើញ ) អានិសង្ស ក្នុងគុណជាន់លើ ( គឺ អរូបទី ៤ ) ហើយ ដកសេចក្តីពេញចិត្តក្នុងអាកិញ្ចញ្ញាយតនៈ បង្អោនចិត្តទៅក្នុងនេវសញ្ញានាសញ្ញាយតនៈ ថា ជាធម៌ល្អិត ត្រិះរិះយកអាកិញ្ចញ្ញាយតនសមាបត្តិដែលមាន **នត្ថិភាវ** ជាអារម្មណ៍កើតឡើង មកមនសិការក្នុងបច្ចវេក្ខណៈរឿយៗថា “ **សន្តា សន្តា - ល្អិត ល្អិត** ” ធ្វើឲ្យជា **តក្កាហត**( នឹកភ្ជាមប្រាកដភ្ជាម ) **វិតក្កាហត**( ត្រិះរិះភ្ជាមប្រាកដភ្ជាម ) កាលបើលោកញុំាងចិត្តឲ្យត្រាច់ ទៅក្នុងនិមិត្តនោះរឿយៗ យ៉ាងនោះ នីវរណៈទាំងឡាយនឹងស្ងប់រម្ងាប់ សតិនឹងតាំងមាំ ចិត្តជាសមាធិថ្នាក់ឧបចារៈ លោកសេពចម្រើន ធ្វើឲ្យច្រើននូវនិមិត្តនោះរឿយ ៗ កាលលោកធ្វើយ៉ាងនោះ នេវសញ្ញានា-សញ្ញាយតនចិត្ត រមែងតាំងមាំ ( ជាអប្បនា ) នៅក្នុងខន្ធទាំង ៤ ពោលគឺ អាកិញ្ចញ្ញាយតនសមាបត្តិ ដូចនឹងអាកិញ្ចញ្ញាយតនៈ ( ចិត្ត ) តាំងមាំនៅក្នុងការប្រាសទៅនៃ វិញ្ញាណដូច្នោះ , រីឯន័យនៃអប្បនាក្នុងប្រការនេះ គប្បីជ្រាបតាមន័យដែលពោល ហើយនោះចុះ ។

ដោយការនានុក្រមត្រឹមប៉ុណ្ណេះ យោគាវចរភិក្ខុនោះ ហៅថា “ ឈានកន្លង អាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួងហើយ ចូលដល់នេវសញ្ញានាសញ្ញាយតនៈ ហើយ ” ។

# អធិប្បាយ

## អត្ថបាឋៈក្នុងនេវសញ្ញានាសញ្ញាយតនៈ

សូម្បីក្នុងទីនេះ បទថា “ **សព្វសោ - ដោយប្រការទាំងពួង** ” នេះ មាន ន័យដូចពោលហើយនោះឯង ក្នុងពាក្យថា “ ឈានកន្លងអាកិញ្ចញ្ញាយតនៈ ” នោះ ណា ក៏សំដៅយកទាំងឈានទាំងអារម្មណ៍ ជាអាកិញ្ចញ្ញាយតនៈ ដូចន័យដែល ពោលមកខាងដើមដែរ ។ ពិតហើយ សូម្បីអារម្មណ៍ ក៏ឈ្មោះថា អាកិញ្ចញ្ញាយ-តនៈ ព្រោះអត្ថវិគ្រោះថា “ **អាកិញ្ច** ( វិញ្ញាណតិចតួចមិនមាន ) ដោយ **អាកិញ្ច** នោះ ឈ្មោះថា ជាអាយតនៈ ដោយអត្ថថា ជាទីអាស្រ័យ ដូច( ពាក្យថា ) ទេវាយតនៈ របស់ទេវតាទាំងឡាយ ព្រោះ **អាកិញ្ច** នោះ ជាអារម្មណ៍របស់ អរូបជ្ឈានទី ៣ ផង ” ដូច្នេះ ដូចន័យខាងដើមនោះឯង , ម្យ៉ាងវិញទៀត អារម្មណ៍ ឈ្មោះថា **អាកិញ្ចញ្ញាយតនៈ** ព្រោះអត្ថវិគ្រោះថា “ **អាកិញ្ច** ផង **អាកិញ្ច** នោះ ឈ្មោះថា ជាអាយតនៈ ដោយអត្ថថា ជាទីកើត ដូចពាក្យថា ( ដែន កម្ពោជា ជាអាយតនៈ គឺ ភូមិកំណើតរបស់សេះទាំងឡាយ ) ជាដើម ព្រោះ **អាកិញ្ច** នោះ ជាហេតុកើតឡើងនៃឈាននោះ ដូចគ្នាផង ” ដូច្នេះក៏បាន ព្រោះ ហេតុ ដែលនេវសញ្ញានាសញ្ញាយតនៈនេះ ព្រះយោគាវចរចាំបាច់ត្រូវឈានកន្លង ចេញទាំង ២ យ៉ាងនោះ គឺ ទាំងឈានទាំងអារម្មណ៍នោះ ដោយធ្វើមិនឲ្យ ( អាកិ-

ញ្ចញ្ញាយតនៈនោះ ) ប្រព្រឹត្តទៅ និងដោយមិនធ្វើទុកក្នុងចិត្តដល់ ( អាកិញ្ច-ញ្ញាយតនៈ )ប៉ុណ្ណោះ ទើបអាចចូលដល់បាន ព្រោះហេតុនោះ ពាក្យថា " ឈានកន្លងអាកិញ្ចញ្ញាយតនៈ " នេះ គប្បីជ្រាបថា លោកពោលរួបរួមយកឈាន និងអារម្មណ៍ទាំង ២ នោះ ចូលគ្នា ។

ចំណែកក្នុងបទថា " នេវសញ្ញានាសញ្ញាយតនៈ " នោះ មានអត្ថាធិប្បាយថា ឈាននោះហៅថា នេវសញ្ញានាសញ្ញាយតនៈ ព្រោះការមាននៃសញ្ញាណាសញ្ញានោះ រមែងមានដល់ព្រះយោគាវចរ អ្នកបដិបត្តិយ៉ាងណា ក្នុងវិភង្គសម្តែងដល់ការបដិបត្តិរបស់ព្រះយោគាវចរនោះមុន ទើបលើកឡើង ( ជាបុគ្គលាធិដ្ឋាន ) ថា " **នេវសញ្ញីនាសញ្ញី** " ហើយពោលថា ព្រះយោគាវចរ ធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនៈនោះឯង ព្រោះថា ជាធម៌ល្អិត ធ្វើរហូតឲ្យជាសង្ខារដូចជាសេសសមាបត្តិ ( សមាបត្តិមានត្រឹមតែសេសសង្ខារជាអារម្មណ៍ ? ) ព្រោះហេតុនោះ ទើបហៅថា " នេវសញ្ញីនាសញ្ញី " ដូច្នេះ ក្នុងពាក្យទាំងនោះ ពាក្យថា " ធ្វើទុកក្នុងចិត្តថា ជាធម៌ល្អិត " នោះ គឺ ធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនៈនោះថាជាសមាបត្តិល្អិត ព្រោះមានអារម្មណ៍ល្អិត ( ដោយន័យ ) ដូច្នេះថា " សមាបត្តិនេះ ល្អិតពិតហ្ន៎ ! មើលចុះ សមាបត្តិឯណា នឹងធ្វើសូម្បីការមិនមាន ( នៃវិញ្ញាណ ) ឲ្យជាអារម្មណ៍ តែតាំងនៅបាន " ។

ប្រសិនបើមានពាក្យសួរថា ព្រះយោគាវចរធ្វើទុកក្នុងចិត្ត " នូវអាកិញ្ចញ្ញា-យតនៈ " ថា ជាធម៌ល្អិតយ៉ាងនោះ ការឈានកន្លង សម្រេចបានយ៉ាងណា គប្បីឆ្លើយថា ការឈានកន្លងសម្រេចបាន ព្រោះព្រះយោគាវចរ មិនបានប្រាថ្នានឹងចូល " អាកិញ្ចញ្ញាយតនៈនោះ " ពិតហើយ លោកធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនៈ

នោះថា ជាធម៌ល្អិត ដូច្នោះក៏ពិត សូម្បីដូច្នោះ ការរំពឹងគិត ការរួមចិត្ត ការធ្វើទុកក្នុងចិត្តថា យើងនឹងរំពឹងរក យើងនឹងចូល យើងនឹងអាស្រ័យនៅ យើងនឹងចេញ យើងនឹងពិចារណាដល់សមាបត្តិនោះ នេះក៏មិនមានដល់យើង ។ សួរថា ព្រោះហេតុដូចម្ដេច ? ឆ្លើយថា ព្រោះនេវសញ្ញានាសញ្ញាយតនៈ ល្អិតជាង ប្រណីតជាងអាកិញ្ចញ្ញាយតនៈ ដូចសេចក្ដីថា ព្រះរាជាប្រថាប់លើ-កដំរីដ៏ប្រសើរ ស្ដេចទៅតាមថ្នល់ក្នុងព្រះនគរដោយរាជានុភាពដ៏ធំក្រៃលែង ទតព្រះនេត្រឃើញពួកជាងមានថ្វីដៃ មានជាងក្លុកជាដើម ដែលស្លៀកសំពត់ ១ ផ្ទាំង ទុកជួតក្បាល ១ ផ្ទាំង មានខ្លួនប្រឡាក់ដោយកម្ទេចទាំងឡាយ មានកម្ទេចក្លុកជាដើម ធ្វើការផ្សេងៗ មានទន្តវិកតិ ( ឆ្លាក់ផ្លុងជារូបផ្សេងៗ ) ជាដើម ក៏ពេញព្រះហឫទ័យក្នុងភាពឆ្លាតរបស់ពួកគេដោយទទួលថា “ អើហ្ន៎ ! ពួកអ្នកនេះឆ្លាត មើលចុះ ធ្វើការមានថ្វីដៃ ” ដូច្នេះ បន្ទាប់មក ទ្រង់ត្រិះរិះថា “ អើ យើងនឹងលះបង់សម្បត្តិ ធ្វើជាអ្នកមានថ្វីដៃ ដូច្នោះដែរ ” យ៉ាងនេះ មិនមានដល់ព្រះអង្គទេ ព្រោះហេតុអ្វី ព្រោះសិរីរាជសម្បត្តិ មានគុណធំជាង ព្រះអង្គក៏ស្ដេចលះបង់ពួកជាងមានថ្វីដៃ ដោយព្រះអង្គឯង យ៉ាងណា ព្រះយោគាវចរ ក៏ដូច្នោះដូចគ្នា ធ្វើទុកក្នុងចិត្តដល់សមាបត្តិនោះថា ជាធម៌ល្អិតក៏ពិត តែថា ការពិចារណា ការរួមចិត្ត ការបង្អោនចិត្តថា “ យើងនឹងរំពឹងរក យើងនឹងចូល យើងនឹងនៅ យើងនឹងចេញ យើងនឹងពិចារណាដល់សមាបត្តិនោះ ” នេះ មិនមានដល់លោកឡើយ លោកកាលធ្វើទុកក្នុងចិត្តដល់សមាបត្តិនោះថា ជាធម្មជាតិល្អិត តាមន័យដែលពោលហើយនោះ ក៏នឹងសម្រេចដល់សញ្ញា ដែលដល់អប្បនាដ៏ល្អិតក្រៃលែងនោះ ដែលជាសញ្ញា ជាហេតុឲ្យបានឈ្មោះថា ជានេវសញ្ញីនាសញ្ញី ឈ្មោះថា ធ្វើរហូតឲ្យជាសង្ខារ ហាក់បីដូចជា

សេសសមាបត្តិ ។

ពាក្យថា **សង្ខារហាក់ដូចជាសេសសមាបត្តិ** គឺ អរូបសមាបត្តិទី ៤ ដែលមានសង្ខារដល់នូវភាពល្អិតដ៏ក្រៃលែង ។

## ពាក្យថា
## នេវសញ្ញានាសញ្ញាយតនៈសំដៅយកអ្វី

ឥឡូវនេះ ដើម្បីទឹងសម្តែងវត្ថុ ដែលហៅថា នេវសញ្ញានាសញ្ញាយតនៈ ដោយអំណាចនៃសញ្ញាដែលព្រះយោគាវចរ បានសម្រេចហើយ យ៉ាងនោះ ដោយសេចក្តីសម្គាល់ ( ក្នុងវិភង្គ ) ទើបពោលថា “ ពាក្យ នេវសញ្ញានាសញ្ញាយតនៈ សំដៅដល់ធម៌ គឺ ចិត្ត និង ចេតសិក របស់បុគ្គលដែលចូលដល់នេវសញ្ញានា-សញ្ញាយតនៈ ( ឈាន ) ឬ អ្នកចូលដល់ ( គឺ កើតក្នុង ) នេវសញ្ញានា-សញ្ញាយតនៈ ( ភព ) អ្នកមាននេវសញ្ញានាសញ្ញាយតនៈ ( ឈាន ) ជាធម៌នៅជាសុខ ក្នុងទិដ្ឋធម៌ ក៏បាន ” ដូច្នេះ បុគ្គលក្នុង ៣ ពួកនោះ ធម៌ គឺ ចិត្ត និង ចេតសិករបស់បុគ្គលអ្នកចូល ( នេវសញ្ញានាសញ្ញាយតនៈ ) ទ្រង់បំណងយកក្នុងទីនេះ ។

## ខ្លឹមសារនៃពាក្យ

រីឯខ្លឹមសារនៃពាក្យ ក្នុងពាក្យថា **នេវសញ្ញានាសញ្ញាយតនៈ** នោះ គប្បីជ្រាបថា ឈាននោះព្រមទាំងសម្បយុត្តធម៌ ឈ្មោះថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ដែលពិត ព្រោះមិនមានសញ្ញាគ្រោតគ្រាត តែថា មានសញ្ញា

ល្អិត ព្រោះហេតុនោះ ឈាននោះទើបឈ្មោះថា នេវសញ្ញានាសញ្ញៈ ( ឈានមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ) , នេវសញ្ញានាសញ្ញៈ ( ឈាន ) ផង , នេវសញ្ញានាសញ្ញៈ( ឈាន )នោះ ឈ្មោះថា ជាអាយតនៈ ព្រោះទាក់ទងក្នុងមនាយតនៈ និង ធម្មាយតនៈផង ព្រោះហេតុនោះ ទើបឈ្មោះថា នេវសញ្ញា-នាសញ្ញាយតនៈ ( អាយតនៈ គឺ ឈានមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ) អត្ថវិកប្បមួយទៀត សញ្ញាណាក្នុងអរូបទី ៤ នេះ សញ្ញានោះរាប់ថាជាសញ្ញាក៏មិនមែន ព្រោះមិនអាចនឹងធ្វើសញ្ញាកិច្ច ( នាទីនៃសញ្ញា ) ឲ្យប្រាកដច្បាស់បាន ចាត់ថាមិនមានសញ្ញាក៏មិនមែន ព្រោះជាវត្ថុដែលមានដោយភាពជាសេសសង្ខារដ៏ល្អិត ព្រោះហេតុនោះ សញ្ញានោះ ទើបឈ្មោះថា នេវសញ្ញានា-សញ្ញា ( សញ្ញាដែលរាប់ថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ) នេវសញ្ញានាសញ្ញាផង នេវសញ្ញានាសញ្ញានោះ ជាអាយតនៈ ដោយអត្ថថា ជាទីអាស្រ័យនៃធម៌ដ៏សេស ( គឺ សម្បយុត្តធម៌ ) ផង ព្រោះហេតុនោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញាយតនៈ ។

ឯក្នុងអរូបទី ៤ នេះ សញ្ញាមានត្រឹមតែម្យ៉ាងដូច្នោះ ក៏មិនបាន ដែលពិតសូម្បីវេទនាក៏ជា **នេវវេទនានាវេទនា** - មានវេទនាក៏មិនមែន មិនមានវេទនាក៏មិនមែន , សូម្បីចិត្តក៏ជា **នេវចិត្តំនាចិត្តំ** - មានចិត្តក៏មិនមែន មិនមានចិត្តក៏មិនមែន , សូម្បីផស្សៈក៏ជា **នេវផស្សោនាផស្សោ** - មានផស្សៈក៏មិនមែន មិនមានផស្សៈក៏មិនមែន ក្នុងសម្បយុត្តធម៌ដ៏សេសទាំងឡាយ ក៏មានន័យដូច្នេះ ព្រោះ ( ព្រះធម៌ ) ទេសនានេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់ធ្វើដោយ ( លើក ) សញ្ញាជាប្រធាន , ម្យ៉ាងទៀត សេចក្តីនេះ បណ្ឌិតគប្បីធ្វើឲ្យជាក់ច្បាស់ដោយ

ឧបមាទាំងឡាយ ផ្ដើមពីរឿងប្រេងលាបបាត្រទៅ ។

មានរឿងពោលថា សាមណេរលាបបាត្រដោយប្រេងហើយ រក្សាទុក រហូតដល់ពេលហុតយាគូ ព្រះថេរៈហៅលោកឲ្យយកបាត្រមក លោកប្រាប់ថា " ក្នុងបាត្រនេះមានប្រេង " បន្ទាប់មក កាលព្រះថេរៈប្រាប់ថា " នាំមកចុះ សាមណេរ យើងនឹងចាក់ទុកក្នុងត្រឡោក " ក៏ប្រាប់ថា " ប្រេងមិនមានទេ ទាន ! " ។

ក្នុងពាក្យរបស់សាមណេរនោះ ពាក្យថា " ប្រេងមាន " ក៏ត្រូវ ព្រោះសំដៅដល់ ( ប្រេងនោះ ) មិនគួរ ( លាយ ) ជាមួយយាគូ ព្រោះវា ( មានជាប់ ) នៅខាងក្នុង ( បាត្រ ) , ពាក្យថា " មិនមាន " ក៏ត្រូវ ព្រោះសំដៅយកប្រើធ្វើការងារផ្សេងៗ មានការចាក់បំពេញត្រឡោកប្រេងជាដើម មិនបានយ៉ាងណា សូម្បីសញ្ញានោះ ក៏ដូច្នោះ ចាត់ថា មានសញ្ញាក៏មិនមែន ព្រោះមិនអាចធ្វើសញ្ញាកិច្ចឲ្យប្រាកដច្បាស់ មិនមានសញ្ញាក៏មិនមែន ព្រោះជាវត្ថុដែលមានប្រាកដជាសេសសង្ខារដ៏ល្អិត ។

សួរថា សញ្ញាកិច្ចក្នុងពាក្យនោះ គឺអ្វី ? ឆ្លើយថា សញ្ញាកិច្ច គឺ ការចាំអារម្មណ៍បាន យ៉ាងណាមួយ ការចូលដល់ភាពជាវិស័យ ( គឺ អារម្មណ៍ ) នៃវិបស្សនា ហើយញ៉ាំងនិព្វិទាឲ្យកើតឡើងបាន ដែលសញ្ញានោះ ធ្វើកិច្ច គឺ ការចាំ ( អារម្មណ៍ ) មិនអាចធ្វើឲ្យច្បាស់បាន ដូចធាតុភ្លើងក្នុងទឹកក្ដៅ មិនអាចធ្វើកិច្ច គឺ ការដុតឈើបានដូច្នោះ សូម្បីការចូលដល់ភាពជាវិស័យនៃវិបស្សនា ហើយញ៉ាំងនិព្វិទាឲ្យកើត ដូចសញ្ញាក្នុងសមាបត្តិដ៏សេស ក៏មិនអាចធ្វើបាន ព្រោះថាភិក្ខុដែលមិនបានធ្វើអភិនិវេសៈ ( គឺ វិបស្សនា ) ក្នុងនាមក្ខន្ធដទៃមកហើយ ក៏មិនអាចនឹងពិចារណា នេវសញ្ញានាសញ្ញាយតនខន្ធ ហើយនឹងឲ្យសម្រេចដល់

និព្វិទាបានឡើយ , អាចនឹងសម្រេចបានចំពោះតែព្រះសារីបុត្ត ឬ លោកអ្នកមានបញ្ញាច្រើន ជាបកតិវិបស្សកៈ( ពិចារណាឃើញច្បាស់តាមប្រក្រតី ) ព្រះសារីបុត្តនោះឯង ទើបអាច ( ពិចារណានេវសញ្ញានាសញ្ញាយតនខន្ធ ធ្វើឲ្យដល់និព្វិទាបាន ) តែសូម្បី ព្រះសារីបុត្តនោះ ក៏អាចធ្វើបានត្រឹមតែការពិចារណាជាកលាបៈ ( ជាក្រុម ជាពួក ) ប៉ុណ្ណោះ មិនអាចពិចារណា ( បែកសម្បយុត្ត )ធម៌ ( មានផស្សៈជាដើម ) ចេញជាបទតូចៗបានឡើយ ដោយលោកឃើញថា ធម៌ទាំងឡាយនេះក៏ជាយ៉ាងនោះ គឺ មិនមាន ក៏មាន , មាន ក៏ប្រាប់មិនបាន ដូច្នេះ , សមាបត្តិនេះដល់នូវភាពល្អិត ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ប្រការនេះ បណ្ឌិតគប្បីធ្វើឲ្យច្បាស់ ដោយឧបមាដូចទឹកតាមផ្លូវដើរ ដូច្នោះ ដូចគ្នានឹងឧបមាជាមួយប្រេងលាបបាត្រ ក៏បាន ។

សាមណេរដែលដើរទៅខាងមុខព្រះថេរៈ កាលដើរទៅតាមផ្លូវឃើញទឹកដក់តាមផ្លូវបន្តិចបន្តួច ក៏ប្រាប់ថា “ ទឹក ទាន ! សូមពាក់ស្បែកជើង ” ពេលនោះព្រះថេរៈប្រាប់ថា “ សាមណេរ បើមានទឹក ចូរនាំយកសំពត់ងូតមក យើងនឹងងូតទឹក , សាមណេរក៏ប្រាប់ថា “ ទឹកមិនមានទេទាន ” ។

ក្នុងពាក្យរបស់សាមណេរនោះ ពាក្យថា “ ទឹកមាន ” ក៏ត្រូវ ព្រោះសំដៅយក វាមានល្មមឲ្យពាក់ស្បែកជើង , ពាក្យថា “ ទឹកមិនមាន ” ក៏ត្រូវ ព្រោះវាមិនអាចឲ្យងូតបាន យ៉ាងណា សូម្បីសញ្ញានោះ ក៏ដូចគ្នា ចាត់ថាមានសញ្ញាក៏មិនមែន ព្រោះមិនអាចធ្វើសញ្ញាកិច្ចឲ្យច្បាស់បាន ចាត់ថា មិនមានសញ្ញាក៏មិនមែន ព្រោះជាវត្ថុដែលមានដោយភាពជាសេសសង្ខារដ៏ល្អិត ។

សេចក្តីនេះ គួរធ្វើឲ្យជាក់ច្បាស់ដោយឧបមា ( ២ ប្រការដែលពោលហើយ )

នេះប៉ុណ្ណោះ ក៏មិនមែន បណ្ឌិតគប្បីធ្វើឲ្យជាក់ច្បាស់ សូម្បីដោយឧបមាដទៃ ៗ ដែលសមគ្នាទៀត ក៏បាន ។

ពាក្យថា **ឧបសម្បជ្ជ វិហរតិ - ចូលដល់...ហើយ** នេះ មានន័យដូចពោលមកហើយនោះឯង ។

( នេះជាកថា យ៉ាងពិស្តារក្នុងនេវសញ្ញានាសញ្ញាយតនកម្មដ្ឋាន )

# មហាដីកា

# អធិប្បាយ នេវសញ្ញានាសញ្ញាយតនៈ

ពាក្យថា **នឹងស្ងប់ក៏មិនមែន** មានន័យថា នេវសញ្ញានាសញ្ញាយតនសមាបត្តិ ឈ្មោះថា ជាធម្មជាតិដែលស្ងប់ យ៉ាងពិសេស ព្រោះសម្រេចភាពជាសេសសង្ខារដ៏ល្អិត យ៉ាងណា , អាកិញ្ចញ្ញាយតនសមាបត្តិនេះ នឹងឈ្មោះថា ជាធម្មជាតិ ដែលស្ងប់ដូចគ្នានោះដែរ ក៏មិនមែន ព្រោះមិនមានភាវៈនោះ ។ ភាពជាទុក្ខនេះ ឈ្មោះថា ដូចជារោគ ព្រោះជាទីត្រូវរក្សាដោយបច្ច័យក្នុងខន្ធទាំងឡាយ និងព្រោះជាមូលនៃរោគ , ឈ្មោះថា ដូចជាបូស ព្រោះប្រកបដោយការឈឺពឹត គឺភាពជាទុក្ខជាដើម , និងឈ្មោះថា ដូចជាកូនសរ ព្រោះធ្វើការចុកចាប់ឲ្យកើតឡើង , សេចក្ដីទុក្ខនោះ កាលសញ្ញាមាន ទើបកើតឡើងបាន កាលសញ្ញាមិនមាន ក៏កើតឡើងមិនបាន ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា “ **សញ្ញាដូចជារោគ សញ្ញាដូចជាបូស សញ្ញាដូចជាកូនសរ** ” ។ ក្នុងបណ្ដាសញ្ញាទាំងឡាយនេះ គប្បីជ្រាបថា សញ្ញាដែលមានកិច្ចប្រាកដច្បាស់នោះ ជាសញ្ញាគ្រោតគ្រាតប្រព្រឹត្ត

ទៅក្នុងបញ្ចវោការភព ។ មិនមែនសញ្ញាតែម្យ៉ាងប៉ុណ្ណោះទេ តែគប្បីជ្រាបដល់ការសង្គ្រោះយកទាំងសម្បយុត្តធម៌ទាំងឡាយ មានវេទនា ចេតនា ជាដើម ។ តែលោកអាចារ្យធ្វើនិទ្ទេសទុកដោយ មានសញ្ញាជាប្រធាន ។ ពាក្យថា **ធម្មជាតិនេះស្ងប់** មានន័យថា ធម្មជាតិនេះ ឈ្មោះថា ស្ងប់ ព្រោះវៀរចាកសញ្ញាដែលដូចជារោគជាដើម ដែលបង្កើតឡើងនូវសេចក្ដីមិនស្ងប់ ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា ប្រណីត ។ ធម្មជាតិនោះ គឺអ្វី ? ព្រោះហេតុនោះ លោកអាចារ្យទើបឆ្លើយថា គឺ **នេវសញ្ញានាសញ្ញា** ដូច្នេះ ។ ដោយការបញ្ជាក់ដល់នេវសញ្ញានាសញ្ញាយតនៈនោះ ឈានដែលសម្បយុត្តជាមួយនេវសញ្ញានាសញ្ញានោះ លោកពោលថា **ទោស** , ក្នុងពាក្យថា **ទោស** នេះ គប្បីឃើញថា សូម្បីការមានប្រាកដនៃសញ្ញាជាដើម ដែលដូចជារោគជាដើម ក៏ឈ្មោះថា **ទោស** , មិនមែនចំពោះភាវៈដែលមានសត្រូវ គឺ វិញ្ញាណញ្ចាយតនៈនៅជិតប៉ុណ្ណោះទេ ។ ពាក្យថា **ក្នុងគុណវិសេសជាន់លើ** គឺ ក្នុងអរូបទី ៤ ។ បទថា **សាវ** កាត់ជា **សា ឯវ** ។ ពាក្យថា **ដែលធ្វើឲ្យប្រព្រឹត្តទៅ** ( ធ្វើការមិនមានឲ្យជាអារម្មណ៍ ) បានដល់ ធ្វើឲ្យប្រព្រឹត្តទៅ គឺ ធ្វើឲ្យកើតឡើង ដែលប្រើសិទ្ធិ ។

ពាក្យថា **ក្នុងនិមិត្តនោះ** បានដល់ ក្នុងនិមិត្ត គឺ ឈាន ដែលហៅថា អរូបសមាបត្តិទី ៣ នោះ ។ បទថា **មានសំ** - ចិត្ត ក្នុងពាក្យថា ធ្វើចិត្តឲ្យត្រាច់ទៅ បានដល់ ចិត្ត ព្រោះធ្វើអធិប្បាយថា ចិត្តនោះឯង ឈ្មោះថា **មានស** , ឬថា បានដល់ ភាវនាមនសិការ ។ ព្រោះថា ភាវនាមនសិការនោះ មានក្នុងចិត្ត ទើបហៅថា មានសៈ ។ សូម្បីធម៌ទាំងឡាយដែលសម្បយុត្តជាមួយឈាន ក៏បានដោយបរិយាយ ( ឈ្មោះអម ) ថា សមាបត្តិ ព្រោះការទំនុកបម្រុងដល់ឈាន ព្រោះ

ហេតុនោះ លោកអាចារ្យទើបពោលថា ក្នុងខន្ធ ៤ ដែលហៅថា អាកិញ្ចញ្ញាយតន-សមាបត្តិ ដូច្នេះ អធិប្បាយថា ក្នុងខន្ធ ៤ ដែលហៅថា អាកិញ្ចញ្ញាយតនសមាបត្តិ ដែលជាអារម្មណ៍ ។

**ឈាន** ឈ្មោះថា **អាកិញ្ចញ្ញាយតនៈ** ព្រោះអត្ថថា មានអាកិញ្ចញ្ញ ( ភាវៈដែលអ្វីតិចតួចមិនមាន ) តាមដែលពោលហើយជាអាយតនៈ គឺ ជាហេតុ ដោយភាពជាអារម្មណប្បច្ច័យ , ន័យម្យ៉ាងទៀត គប្បីឃើញអត្ថយ៉ាងនេះថា អារម្មណ៍ គឺ អាកិញ្ចញ្ញ ឈ្មោះថា អាកិញ្ចញ្ញាយតនៈ ព្រោះអត្ថថា ជាអារម្មណប្បច្ច័យ គឺ ជាហេតុនៃឈាន ។ ពាក្យអត្ថាធិប្បាយដ៏សេស ក្នុងពាក្យពោលទាំងឡាយនេះ បណ្ឌិតគប្បីជ្រាបតាមទំនងនៃន័យ ដែលបានពោលហើយក្នុងបទដើមចុះ ។

ពាក្យថា **ព្រោះមានសញ្ញាណា** បានដល់ ព្រោះមានសញ្ញាបែបណា , គឺសញ្ញាដែលមិនគួរ ហៅថា សញ្ញា ព្រោះមិនមានកិច្ចនៃសញ្ញាឲ្យប្រាកដច្បាស់ , មិនគួរហៅថា **អសញ្ញា** ( មិនមែនសញ្ញា ) ព្រោះមិនផុតសភាវៈនៃសញ្ញាផង , មានសេចក្តីថា ព្រោះសញ្ញានោះ នៅប្រាកដ ។ បទថា **តំ** ប្រែថា ឈាននោះ ។ ក្នុង ២ បទថា **តំ តាវ ទស្សេតុំ** នេះ មានសេចក្តីថា បទថា **តំ** ទ្រង់បំណងសម្តែងសញ្ញា និងការបដិបត្តិនោះ , គឺ ទ្រង់បំណងសម្តែងសញ្ញាតាមដែលពោលហើយ , និងឧបាយឲ្យសម្រេចសញ្ញានោះ ។ ក៏ព្រះមានព្រះភាគ កាលនឹងទ្រង់លើកធម៌ឡើង ដែលជាបុគ្គលាធិដ្ឋាន ទើបទ្រង់លើកសញ្ញាឡើងដែលអាស្រ័យបុគ្គលអ្នកមានសញ្ញាជាប្រកដូវថា នេវសញ្ញីនាសញ្ញី ( អ្នកមានសញ្ញាក៏មិនមែនមិនមានសញ្ញាក៏មិនមែន ) , ដោយប្រការផ្សេងទៀត ព្រះអង្គក៏ទ្រង់លើកឡើងថា នេវសញ្ញានាសញ្ញាយតនៈ ។ រីឯការបដិបត្តិនោះ ប្រព្រឹត្តទៅក្នុងបុគ្គលណា និង

ប្រព្រឹត្តទៅដោយប្រការណា ទ្រង់បំណងសម្ដែងដល់ការបដិបត្តិនោះ ទើបត្រាស់ថា " រមែងធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនៈថា ជាធម៌ស្ងប់ ទើបធ្វើសង្ខារាវសេស-សមាបត្តិឲ្យកើតឡើងបាន " ដូច្នេះ ។ ពិតណាស់ អាកិញ្ចញ្ញាយតនៈ ជាស្ថានទីប្រព្រឹត្តទៅនៃការចម្រើនអរូបជ្ឈានទី ៤ , ទើបឈ្មោះថា ជាអាការដែលប្រព្រឹត្តទៅនៃសង្ខារាវសេសសមាបត្តិ ។ បទថា **យត្រ ហិ នាម** កែជា **យា នាម** ។ ពាក្យថា **សូម្បីត្រឹមតែការមិនមាន** គឺសូម្បីត្រឹមតែភាពសូន្យនៃវិញ្ញាណ អធិប្បាយថា សូម្បីជាវិញ្ញាណដែលល្អិតយ៉ាងនេះ ។ ពាក្យថា **ព្រោះជាសមាបត្តិ ដែលមានអារម្មណ៍ស្ងប់** មានសេចក្ដីថា សមាបត្តិនេះមានអារម្មណ៍ស្ងប់ ព្រោះហេតុនោះទើបឈ្មោះថា **សន្តារម្មណា** , ភាពជាសមាបត្តិដែលមានអារម្មណ៍ស្ងប់នោះ ទើបឈ្មោះថា **សន្តារម្មណតា** , បានដល់ ព្រោះជាសមាបត្តិដែលមានអារម្មណ៍ស្ងប់នោះ មិនមែនព្រោះភាពជាឈានដែលស្ងប់ទេ , ព្រោះថា អរូបសមាបត្តិ ទី ៣ មិនស្ងប់ជាងអរូបសមាបត្តិទី ៤ ទេ ។

អាចារ្យអ្នកសួរ កាលនឹងពោលថា ព្រះយោគាវចរ ធ្វើទុកក្នុងចិត្តនូវឈានណាថា ជាធម៌ស្ងប់ , ក៏មិនគួរមានការសម្លឹងឃើញទោសក្នុងឈាននោះ ។ កាលមិនមានការសម្លឹងឃើញទោស ក៏មិនអាចនឹងមានការឈានកន្លងបានឡើយ ។ ដូច្នេះ ទើបពោលថា ប្រសិនបើ ធ្វើទុកក្នុងចិត្តថា ជាសមាបត្តិដែលស្ងប់ហើយសោត នឹងមានការឈានកន្លងបានដូចម្ដេច ? ដូច្នេះ អាចារ្យក្រៅពីនេះ ( ព្រះអដ្ឋកថាចារ្យ ) ទើបពោលឆ្លើយថា " នឹងមានការឈានកន្លងដោយការៈ ដែលព្រះយោគាវចរ មិនមែនជាអ្នកត្រូវការនឹងចូលដូច្នេះ , ដោយពាក្យនោះ លោកសម្ដែងថា សូម្បីការសម្លឹងឃើញទោស ក៏មានប្រាកដដូចគ្នា ។ ពិតណាស់ ព្រះ

យោគីនោះជាដើម លោកធ្វើសេចក្តីដែលពោលហើយនោះឯង ឲ្យច្បាស់ឡើង ។ ក្នុងពាក្យទាំងនោះ ព្រះយោគី មានសេចក្តីត្រេកអរក្នុងឈានណា ក៏នឹងគប្បីមានការបដិបត្តិ គឺ ការនឹក ការចូលជាដើម ក្នុងឈាននោះ ។ លោកអាចារ្យកាលនឹងសម្តែងថា ការបដិបត្តិក្នុងអរូបជ្ឈានទី ៣ នោះ មិនមានដល់លោកដោយប្រការទាំងពួង ( មិនមែននឹកដល់ ឬ ចូលជាដើម ) , មានត្រឹមតែការធ្វើឲ្យជាអារម្មណ៍តែមួយសុទ្ធ ព្រោះនៅមានសញ្ញាប្រាកដ ដូច្នេះ ទើបពោលថា **កិញ្ចាបិ** ដូច្នេះជាដើម ។

ពាក្យថា **ស្តេចលះបង់បានហើយ** មានសេចក្តីថា កាលស្តេចមិនហួងហែងជីវិតរបស់ពួកជាងសិល្បៈទាំងឡាយនោះ សូម្បីត្រឹមតែប៉ុនចុងស្មៅ ក៏ស្តេចលះបង់ពួក ទាំងនោះចោលហើយ ។ បទថា **សោ** បានដល់ ព្រះយោគាវចរ ។ បទថា **តំ** បានដល់ អរូបសមាបត្តិទី ៣ ។ ពាក្យថា **តាមន័យដែលពោលហើយខាងដើមនោះឯង** គឺ កាលមនសិការថា ជាសមាបត្តិដែលស្ងប់តាមន័យដែលពោលហើយក្នុងពាក្យថា សមាបត្តិនេះស្ងប់ហ្ន៎ ! ដូច្នេះជាដើម ។ បទថា **តំ** ប្រកបសេចក្តីថា រមែងសម្រេចសញ្ញា គឺ សញ្ញាដែលជាហេតុ ឲ្យពោលដល់លោកបានថា ឈ្មោះថាជា នេវសញ្ញីនាសញ្ញី ធ្វើសង្ខារាវសេសសមាបត្តិឲ្យកើតឡើង ។ ព្រោះថាជាទេសនាដែលលោកពោលទុក ដោយមានសញ្ញាជាប្រធាន ។ ពាក្យថា **ដែលល្អិតក្រៃលែង** គឺ ដែលមានភាវៈដល់នូវភាពឧត្តម ។ ពាក្យថា **សង្ខារាវសេស-សមាបត្តិ** គឺ សមាបត្តិដែលត្រឹមជាសេសសង្ខារ ព្រោះល្អិតដ៏ក្រៃលែង ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា មានតែសង្ខារដែលដល់នូវភាពល្អិតក្រៃ-លែង ។ ឈ្មោះថា **អច្ចន្តំ** ( ក្រៃលែង ) ព្រោះអត្ថថា លើសលប់ ។ សេចក្តីថា

ជាសង្ខារល្អិតដែលដល់នូវភាពខ្ពង់ខ្ពស់ក្រៃលែង ដោយប្រការដែលមិនមានវត្ថុដែលល្អិតក្រៃលែងជាង ។ ពិតហើយ សង្ខារទាំងឡាយដែលដល់នូវភាពកំពូលបំផុតក្នុងអរូបសមាបត្តិ ៤ តាមលំដាប់នៃភាវនាដែលប្រព្រឹត្តទៅ ផ្ដើមតាំងពីឧបចារៈនៃបឋមជ្ឈាន ប្រសិនបើដំណើរទៅយ៉ាងនោះ ផុតចាកសង្ខារនោះទៅ នឹងមានតែការរលត់ប៉ុណ្ណោះ , មិនមានការប្រព្រឹត្តទៅរបស់សង្ខារ ( តទៅទៀត ) ដូច្នេះ ។ ព្រោះហេតុនោះ ទើបលោកហៅថា **សង្ខារាវសេសសមាបត្តិ** ។

ពាក្យថា **វត្ថុនោះ** បានដល់ ខន្ធ ៤ ។ ពាក្យថា **ដោយសភាវៈ** គឺ ជាបរមត្ថធម៌ដែលផ្សេងៗគ្នា ព្រោះសេចក្ដីផ្សេងគ្នា មានកុសលជាដើម ។ ដោយពិសេស ក្នុងទីនេះបំណងយកខន្ធ ៤ ជាទីតាំងទីអាស្រ័យនៃអធិប្បញ្ញាសិក្ខា ព្រោះហេតុនោះ ទើបលោកពោលថា ក្នុងទីនេះសង្គ្រោះយកធម៌ទាំងឡាយ គឺ ចិត្តនិង ចេតសិករបស់បុគ្គល ដែលចូលនេវសញ្ញានាសញ្ញាយតនសមាបត្តិ ដូច្នេះ ។ ពាក្យថា **ព្រោះមិនមានសញ្ញាគ្រោតគ្រាត** គឺ ព្រោះមិនមានសញ្ញាគ្រោតគ្រាតដូចសញ្ញា ដែលទាក់ទងក្នុងបញ្ចវោការភព ដូចសញ្ញាក្នុងភូមិ ៣ ខាងក្រោមសូម្បីក្នុងចតុវោការភព ព្រោះអត្ថថា សញ្ញាក្នុងអរូបកុសលទី ៤ គ្រោតគ្រាតជាងសញ្ញាក្នុងអរូបវិបាកទី ៤ ក៏ពិត សូម្បីដូច្នោះ ដែលឈ្មោះថា គ្រោតគ្រាតល្អិត បណ្ឌិតគប្បីកាន់យកបានដោយការប្រៀបធៀបគ្នាជាថ្នាក់ៗ ដូចជាសញ្ញាក្នុងវិបស្សនា គ្រោតគ្រាតជាងសញ្ញាក្នុងមគ្គ សញ្ញាក្នុងមគ្គគ្រោតគ្រាតជាងសញ្ញាក្នុងផលដូច្នោះ ។ ពាក្យថា **ព្រោះនៅមានសញ្ញាល្អិត** មានន័យថា ព្រោះនៅមាន គឺព្រោះភាវៈដែលសញ្ញាល្អិត ដោយការចូលដល់ភាពជាសេសសង្ខារល្អិតនៅមានៗ **ន** អក្សរ ក្នុងបទថា **នេវស្ស** នេះ មានអត្ថថា មិនមាន ។ **ន** អក្សរ ក្នុងបទថា

**នាសញ្ញា** នេះ មានអត្ថថា ដទៃ , **អ** អក្សរ មានអត្ថថា មិនមាន , មានន័យថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។ ពាក្យថា **ព្រោះការដែលទាក់ទង** គឺ ព្រោះការរួមខាងក្នុង ជាចំណែកមួយ ។ បទថា **ឯត្ថ** បានដល់ ក្នុងអរូបជ្ឈាន ទី ៤ ។ ក្នុងអត្ថវិកប្បទី ២ **ន** អក្សរ ក្នុងបទថា **នេវសញ្ញា** នេះ មានអត្ថថា ដទៃ ។ យ៉ាងនោះដូចគ្នា **ន** អក្សរ និង **អ** អក្សរ ក្នុងបទថា **នាសញ្ញា** នេះ ក៏មានអត្ថថា ដទៃដែរ , ដោយបទទាំង ២ នេះ លោកអាចារ្យសម្តែងការមានប្រាកដនៃសញ្ញានោះឯង , ព្រោះហេតុនោះ លោកពោលដល់ភាពជាអាយតនៈ ព្រោះទាក់ទងក្នុងធម្មាយតនៈនោះឯង លោកពោលថា ដោយសេចក្តីថា ជាទីតាំង ទីអាស្រ័យ ដូច្នេះ ក៏ព្រោះជានិស្សយប្បច្ច័យ ។

លោកអាចារ្យសំដៅយកពាក្យសម្តែងដែលប្រើថា ក្នុងអរូបសមាបត្តិទី ៤ នេះ អ្វីជាហេតុដែលធ្វើឲ្យសញ្ញាតែមួយកើតដូច្នេះ ដូច្នោះ ទើបពោលថា មិនមែនសញ្ញាតែម្យ៉ាង ដូច្នេះជាដើម ។ គប្បីឃើញថា ទេសនានេះ ទ្រង់ត្រាស់ទុកដោយមានសញ្ញាជាប្រធាន ដូចគ្នាក្នុងពាក្យថា **នានត្តកាយា នានត្តសញ្ញិនោ** - មានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ជាដើម ។ ពាក្យថា **ប្រការនេះដូច្នេះ** បានដល់ ប្រការដែលពោលហើយដល់ធម៌ ដែលអាស្រ័យអាការពិសេសខ្លះហើយ ក៏គួរពោលដល់បានថា មានដោយសភាវៈនោះឯង តែអាស្រ័យអាការពិសេសខ្លះ ( ន័យម្យ៉ាងទៀត ) ក៏ត្រឡប់ពោលថា មិនមាន ដូច្នេះ ។

សាមណេរសំដៅយកបាត្រដែលមិនគួរប្រើ ទើបពោលដល់ប្រេង សូម្បីមានតិចតួចបំផុតថា មានប្រេង ដូច្នេះ , សំដៅយកការចាក់ឲ្យពេញត្រឡោក ទើបពោលដល់ប្រេងនោះថា មិនមានប្រេងទេ ទាន ! ព្រោះហេតុនោះ លោក

អាចារ្យទើបពោលថា **តត្ថ យថា** - ក្នុងពាក្យរបស់សាមណេរនោះ ដូច្នេះ ជាដើម ។

សួរថា ប្រសិនបើ ការចាំអារម្មណ៍ជាកិច្ចរបស់សញ្ញាសោត សញ្ញាក៏កំពុងមាន , សញ្ញានេះ មិនអាចធ្វើកិច្ចបាន ហេតុអ្វី ? លោកអាចារ្យឆ្លើយថា **ទហនកិច្ចមិវ** ដូច្នេះជាដើម ។ ពិតហើយ សញ្ញានេះមិនអាចធ្វើកិច្ចរបស់សញ្ញាឲ្យច្បាស់បាន ព្រោះការដល់នូវភាពជាសេសសង្ខារដ៏ល្អិតនោះឯង , ព្រោះហេតុនោះឯង ទើបមិនជាធម្មជាតិដែលមានញាណគប្បីកាន់យកបានដោយងាយ ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា មិនអាចនឹងធ្វើនិព្វិទាឲ្យកើតឡើងបាន ដូច្នេះ ។ ពាក្យថា **មិនបានធ្វើអភិនិវេសៈ** គឺ មិនបានធ្វើការសន្សំវិបស្សនាទុកបានដល់ មិនបានធ្វើសមសនចារៈ ( ការពិចារណា ) ឲ្យប្រព្រឹត្តទៅ ។ បទថា **បកតិវិបស្សកោ** ប្រែថា អ្នកចម្រើនវិបស្សនាជាប្រក្រតី បានដល់ អ្នកសន្សំវិបស្សនាដោយសក្ការៈ មានខន្ធជាដើមជាគន្លងផ្លូវ ហើយឃើញច្បាស់នូវធម៌ទាំងឡាយដែលប្រព្រឹត្តទៅតាមទ្វារ ព្រមទាំងទ្វារ និង អារម្មណ៍ , កិក្ខុដែលមានបញ្ញាច្រើន រមែងអាចធ្វើឧទយព្វយញ្ញាណដែលមានធម៌ទាំងឡាយ ក្នុងនេវសញ្ញា-នាសញ្ញាយតនៈនោះ ជាអារម្មណ៍ឲ្យកើតឡើងដោយប្រការណា , លោកអាចារ្យបំណងសម្តែងប្រការនោះ ទើបពោលថា **សោបិ** ដូច្នេះជាដើម ។ ពាក្យថា ទាក់ទងដល់ការពិចារណាជាពួកៗប៉ុណ្ណោះ គឺ ដោយទាក់ទងការមិនចែកធម៌ទាំង-ឡាយ មានផស្សៈជាដើម ទាក់ទងក្នុងអរូបចិត្តុប្បាទដួងទី ៤ តែពិចារណាដោយការរួមគ្នាជាពួក ៗ គឺ ជាសំណុំ ៗ បានដល់ ទាក់ទងនឹងការពិចារណាជាពួក ៗ ដែល ( អ្នកស្រុកសីហឡៈ ) ហៅថា វិបស្សនាន័យ ។ ការចែកធម៌ទាំងឡាយ

មានផស្សៈជាដើម កាន់យកតាមសភាវៈ ដែលមានផ្សេងៗ ពិចារណាថា ជារបស់មិនទៀងជាដើម ឈ្មោះថា **អនុបទធម្មវិបស្សនា** - ការពិចារណាឃើញធម៌ទៅតាមលំដាប់បទ ។ សេចក្ដីថា សមាបត្តិ នេះដល់នូវភាពល្អិត ដោយប្រការដែលឈ្មោះថា សូម្បីតែព្រះសារីបុត្ត ក៏ពិចារណាមិនឃើញតាមលំដាប់បទបាន ។

ពាក្យថា **ព្រះថេរៈ** បានដល់ ព្រះថេរៈរូបណាមួយ ។ ក្នុងពាក្យថា ដោយឧបមាដែលសមគួរផ្សេងៗទៀត តទៅនេះ ជាឧបមារឿងមួយ គឺ ៖

មានរឿងថា ព្រាហ្មណ៍ម្នាក់ ឃើញបុរសម្នាក់កាន់ភាជនៈដីដ៏ស្អាត ក៏សុំគេថា ចូរឲ្យភាជនៈនេះដល់យើងបានទេដូច្នេះ ។ បុរសនោះ សំដៅយកភាជនៈដែលសើមដោយស្រា ទើបពោលថា “ ខ្ញុំមិនអាចឲ្យបានទេ ” លោកម្ចាស់ , មានស្រានៅក្នុងភាជន៍នេះ ដូច្នេះ ។ ព្រាហ្មណ៍ទើបអាងបុរសម្នាក់ទៀត ដែលឈរនៅជិតខ្លួន ទើបពោលថា “ បើដូច្នោះ ឲ្យគេនេះផឹកស្រាចុះ ” , គេក៏ឆ្លើយថា “ មិនមានស្រាទេ លោកម្ចាស់ ” ដូច្នេះ ។ ក្នុងពាក្យរបស់បុរសនោះ ដែលគេនិយាយថា “ មានស្រា ” ក៏ព្រោះសំដៅយកភាជនៈដែលមិនសមគួរប្រើ សម្រាប់អ្នកជាព្រាហ្មណ៍ , កាលនិយាយថា “ មិនមានស្រា ” ព្រោះមិនមានស្រានៅក្នុងភាជនៈ ដែលជារបស់ល្មមនឹងផឹកបាន យ៉ាងណា , សូម្បីក្នុងអត្ថនេះ បណ្ឌិត ក៏គប្បីឃើញដូច្នោះ ។

សួរថា ព្រោះហេតុអ្វីក្នុងខាងដើម ព្រះយោគីកាន់យកអាការនៃភាវនា ក្នុងអរូបភាវនានោះ ៗ ថា “ អាកាសមិនមានទីបំផុត វិញ្ញាណមិនមានទីបំផុត អ្វីតិចតួចមិនមាន ” ដូច្នេះយ៉ាងណា ក្នុងអរូបភាវនាទី ៤ នេះ , មិនបានកាន់យកអាការនៃភាវនាណាៗ ដែលដូចគ្នានោះទៅ ? ឆ្លើយថា អាចារ្យពួកខ្លះពោលទុកមុនថា

" ឈ្មោះថា អាការនៃភាវនា បានដល់ អាការដែលឈានព្រមទាំងឧបចារៈប្រព្រឹត្ត ទៅក្នុងអារម្មណ៍រៀងៗខ្លួន , អារម្មណ៍ក្នុងអរូបទី ៤ នេះ បានដល់ ធម៌ទាំងឡាយ ក្នុងអាកិញ្ចញ្ញាយតនៈ ( គឺ អាកិញ្ចញ្ញាយតនវិញ្ញាណ ព្រមទាំងចេតសិក ) ។ ព្រះយោគី កាលនឹងកាន់យកធម៌ទាំងឡាយនោះ គប្បីកាន់យកដោយទាក់ទងនឹង ធម៌ទាំងឡាយនោះជាប្រធាន ណាមួយក៏បាន , ទាំងអស់ក៏បាន ។ ក្នុងបណ្ដា ព្រះយោគី ២ ផ្នែកនោះ ក្នុងផ្នែកដំបូង ( កាន់យកធម៌ដែលជាប្រធានតែម្យ៉ាង ) រមែងគួរដល់ការកាន់យកវិញ្ញាណ ( គឺ អាកិញ្ចញ្ញាយតនវិញ្ញាណ , មិនកាន់ យកចេតសិក ) ព្រោះហេតុនោះ ព្រោះការធ្វើទុកក្នុងចិត្តថា " វិញ្ញាណ វិញ្ញាណ " អរូបជ្ឈានទី ៤ ក៏ដល់នូវភាពជាវិញ្ញាណញ្ចាយតនៈទៅ ។ រីឯ ក្នុងផ្នែកទី ២ ព្រោះការធ្វើទុកក្នុងចិត្តនូវឈាន ( គឺ ទាំងវិញ្ញាណ ទាំងចេតសិក ) ថា " អ្វី តិចតួចមិនមាន អ្វីតិចតួចមិនមាន " ដូច្នេះ ដោយភាវៈដែលធម៌ទាំងឡាយក្នុង អាកិញ្ចញ្ញាយតនៈជាអារម្មណ៍ អរូបជ្ឈានទី ៤ ក៏នឹងដល់ភាពជាអាកិញ្ចញ្ញាយតនៈ ( ព្រោះកាន់យកអាកិញ្ចញ្ញាយតនៈ ជាអារម្មណ៍ ) ឬ ជាឈានដែលមាន នត្ថិភាវៈជាអារម្មណ៍ ។ រមែងមិនបានជានេវសញ្ញានាសញ្ញាយតនៈដោយប្រការ ទាំងពួង ។ ឆ្លើយថា ប្រការដែលពោលមកនោះ រកហេតុផលមិនបាន ព្រោះមិន មានការធ្វើឈានឲ្យប្រព្រឹត្តទៅយ៉ាងនោះ ។ ពិតហើយ អរូបភាវនាទី ៤ មិនបាន ប្រព្រឹត្តទៅដោយការកាន់យកវិញ្ញាណ ឬ អាកិញ្ចញ្ញៈទេ , ក្នុងកាលណាៗ ក៏កាន់ យកត្រឹមតែអរូបជ្ឈានទី ៣ ។

សួរទៀតថា បើយ៉ាងនេះ ព្រោះហេតុអ្វី ទើបទ្រង់មិនកាន់យកពាក្យថា **ស្ងប់** ទៅ ? ឆ្លើយថា ក្នុងព្រះសូត្រទ្រង់មិនបានកាន់យកពាក្យថា **ស្ងប់** ក៏ពិត ,

តែទ្រង់កាន់យកក្នុងវិភង្គរួចហើយ ។ ដូចដែលទ្រង់ត្រាស់ទុកថា **ភិក្ខុរមែងធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនៈនោះថា ជាធម៌ស្ងប់ , ទើបធ្វើសង្ខារាវសេសសមាបត្តិនោះឲ្យកើតឡើងបាន** ។ សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ក្នុងព្រះសូត្រ ទ្រង់មិនកាន់យកអាការនៃការនា ដូចដែលទ្រង់កាន់យកក្នុងព្រះវិភង្គ ? ឆ្លើយថា ដែលទ្រង់មិនកាន់យកដូចដែលទ្រង់កាន់យកក្នុងព្រះវិភង្គ ព្រោះហេតុ គឺ អធ្យាស្រ័យនៃវេនេយ្យសត្វ និងព្រោះហេតុ គឺ ជាទេសនាវិលាស ( លម្អនៃទេសនា ) ។ ពិតហើយ អាការនៃការនាក្នុងអរូបកម្មដ្ឋាន ៣ ខាងក្រោម ដែលថា " អាកាសមិនមានទីបំផុត វិញ្ញាណមិនមានទីបំផុត អ្វីតិចតួចមិនមាន " ដូច្នេះ ទ្រង់កាន់យកហើយ យ៉ាងណា , វេនេយ្យសត្វទាំងឡាយណា រមែងចាក់ធ្លុះសភាវៈនោះបានកាលមិនកាន់យកអាការនៃការនានោះ ដូច្នោះ , ទ្រង់ធ្វើទេសនាក្នុងព្រះសូត្រទុកយ៉ាងនោះ ក៏ដោយអំណាចនៃវេនេយ្យសត្វទាំងឡាយនោះ , សូម្បីក្នុងព្រះអភិធម្មមាតិកាទេសនា ដែលមានគតិជាព្រះសូត្រ ក៏មាននៅក្នុងសុត្តន្តភាជនីបទ ។ រីឯវេនេយ្យសត្វទាំងឡាយណាដែលចាក់ធ្លុះសភាវៈនោះបាន ក្នុងកាលទ្រង់ត្រាស់ចែកអាការនៃការនានោះប៉ុណ្ណោះ , ព្រះមានព្រះភាគ ត្រាស់នូវអាការនៃការនា ទុកក្នុងបករណ៍វិភង្គ ដោយអំណាចនៃវេនេយ្យសត្វទាំងឡាយនោះ ។ ព្រះមានព្រះភាគសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ជាឥស្សរៈក្នុងធម៌ កាលទ្រង់ជ្រាបប្រការដែលគប្បីសម្តែងនៃធម៌ទាំងឡាយ ក៏ទ្រង់កាន់យកអាការនៃការនាក្នុងទីកន្លែងខ្លះ , ទ្រង់មិនកាន់យកអាការនៃការនាទុកក្នុងទីខ្លះ ។ ទេសនានោះ រមែងប្រព្រឹត្តទៅត្រឹមតែដើម្បីប្រយោជន៍ គឺ ន័យវិចិត្រដែលគប្បីណែនាំបានដូច្នេះ សេចក្តីដែលពោលមកនេះចាត់ជាទេសនាវិលាស ។ ន័យម្យ៉ាងទៀត គប្បីឃើញហេតុក្នុងការដែលទ្រង់កាន់យក

និងទ្រង់មិនកាន់យកនៃការនាក្នុងទីនេះ សូម្បីដូច្នេះថា ទេសនាក្នុងព្រះសូត្រជាពាក្យពោលដោយបរិយាយ ព្រោះហេតុនោះ ក្នុងព្រះសូត្រនោះ ទើបទ្រង់មិនកាន់យកអាការនៃការនា រីឯទេសនាព្រះអភិធម្ម ជាពាក្យពោលដោយនិប្បរិយាយ ព្រោះហេតុនោះ ក្នុងព្រះអភិធម្មនោះ ទើបទ្រង់កាន់យកអាការនៃការនា ។

រីឯ អាចារ្យមួយពួកទៀត ពោលថា ការដែលព្រះសូត្រទ្រង់មិនកាន់យកអាការនៃការនា ក៏ដើម្បីសម្តែងសេចក្តីផ្សេងគ្នា ក្នុងអរូបជ្ឈានទី ៤ , សេចក្តីផ្សេងគ្នានោះ ជាការនាដែលប្រពឹត្តទៅតាមលំដាប់ធ្វើឲ្យកើតឡើង ។ និងការនាដែលប្រព្រឹត្តទៅតាមលំដាប់នោះ ជាលំដាប់នៃការលះដែលធ្វើឲ្យកើតឡើង ព្រោះព្រះយោគីសម្រេចឈានទាំងឡាយបាន ក៏ដោយការឈានកន្លងធម៌ដែលគប្បីលះ ។ ពិតហើយ ទ្រង់សម្តែងរូបាវចរជ្ឈានទាំងឡាយ ដោយវិធី មានការស្ងាត់ចាកកាមទាំងឡាយជាដើម ស្ងប់វិតក្កៈ វិចារៈ លះបង់បីតិ និងរំលត់សោមនស្ស ជាប្រការសំខាន់ ( សុទ្ធតែជាការឈានកន្លងធម៌ដែលគប្បីលះ ) , អរូបជ្ឈានទាំងឡាយទ្រង់សម្តែងទុកដោយវិធី មានការឈានកន្លងរូបសញ្ញាជាដើមជាសំខាន់ ។ ម្យ៉ាងទៀត មិនមែនចំពោះតែឈានតែម្យ៉ាងប៉ុណ្ណោះទេ , តែថា សីល សូម្បីទាំងអស់ , បញ្ញា សូម្បីទាំងអស់ ក៏ឡើងកាន់ទេសនា ដោយទ្រង់សម្តែងការឈានកន្លងធម៌ដែលគប្បីលះ ជាការសំខាន់ដូចគ្នា ព្រោះព្រះយោគីអាចធ្វើឲ្យសម្រេចបាន ដោយទាក់ទងនឹងការលះបង់ធម៌ដែលជាបដិបក្ខ ដោយពាក្យថា " **ភិក្ខុជាអ្នកលះបង់បាណាតិបាត វៀរចាកបាណាតិបាត** " ជាដើម ។ ឥន្ទ្រិយសំវរៈ ក៏ទ្រង់សម្តែងទុកដោយទាក់ទងនឹងការលះបង់ធម៌ដែលជាបដិបក្ខប៉ុណ្ណោះ ។ ពិតហើយ សីលសំវរៈ ទ្រង់សម្តែងទុកដោយទាក់ទងនឹងការលះធម៌ជាបដិបក្ខ ដោយពាក្យថា " **ឃើញរូប**

**ដោយចក្ខុហើយ មិនជាអ្នកកាន់យកនិមិត្ត មិនជាអ្នកកាន់យកនូវអនុព្យញ្ជនៈ** ” ជាដើម , ភាពជាអ្នកដឹងប្រមាណក្នុងភោជន ក៏ទ្រង់កាន់យកដោយទាក់ទងនឹងការលះបង់ធម៌ដែលជាបដិបក្ខ ដោយពាក្យថា “ **មិនមែនដើម្បីលេង មិនមែនដើម្បីស្រវឹង** ” ជាដើម , ភាពបរិសុទ្ធនៃអាជីវៈ ក៏ទ្រង់សម្ដែងទុកទាក់ទងនឹងការលះបង់ធម៌ដែលជាបដិបក្ខ ដោយពាក្យថា “ **ភិក្ខុក្នុងព្រះសាសនានេះ លះបង់មិច្ឆាអាជីវៈ ចិញ្ចឹមជីវិតដោយសម្មាអាជីវៈ** ” ជាដើម , ការប្រកបរឿយៗ នូវជាគរិយធម៌ ( ធម៌របស់បុគ្គលអ្នកភ្ញាក់ គឺ ការមិនល្ងោកក្នុងការដេកលក់ ) ក៏ទ្រង់សម្ដែងទុក ដោយទាក់ទងនឹងការលះបង់ធម៌ដែលជាបដិបក្ខ ដោយពាក្យថា “ លះបង់អភិជ្ឈាក្នុងលោកហើយ ជាអ្នកមានចិត្តប្រាសចាកអភិជ្ឈា ” ជាដើម , បញ្ញាដែលទ្រង់សម្ដែងទុក ទាក់ទងនឹងការលះបង់ធម៌ដែលជាបដិបក្ខនោះ ដោយពាក្យថា “ គប្បីចម្រើនអនិច្ចសញ្ញា ដើម្បីដកនូវអស្មិមានះ ម្នាលមេឃិយៈ **អនត្តសញ្ញា** រមែងតាំងឡើងដល់បុគ្គលដែលមានអនិច្ចសញ្ញា , អស្មិមានះរបស់បុគ្គលដែលមានអនត្តសញ្ញា រមែងដកចេញបាន ព្រោះអាសវៈទាំងឡាយអស់ទៅ ភិក្ខុទើបដឹងថា ធ្វើឲ្យជាក់ច្បាស់នូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ បានចូលដល់ក្នុងអត្តភាពនេះ ” ជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគកាលទ្រង់សម្ដែងនូវឈានទាំងឡាយ ទើបទ្រង់សម្ដែងហើយដោយការសម្ដែងនូវការឈានកន្ទង់ធម៌ ដែលគប្បីលះជាសំខាន់នោះឯង ដោយពាក្យថា **វិវិច្ចេវ កាមេហិ** ជាដើម ។ ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបពោលថា “ ទ្រង់សម្ដែងរូបាវចរជ្ឈានទាំងឡាយ ដោយវិធី មានការស្ងាត់ចាកកាមជាដើម ស្ងាត់ចាកវិតក្កនិងវិចារៈ លះបង់បីតិ និងរំលត់សោមនស្សជាសំខាន់ , អរូបាវចរជ្ឈានទាំងឡាយ

ទ្រង់សម្តែងទុកដោយវិធី ឈានកន្ទងរូបសញ្ញាជាដើមជាសំខាន់ ” ដូច្នេះ ។ ក្នុងបណ្តាឈានទាំងឡាយនោះ រូបាវចរបឋមជ្ឈានដែលដល់ភាពជាឧត្តរិមនុស្សធម៌ ដោយការគ្របសង្កត់នីវរណធម៌ទាំងឡាយ មានកាមច្ឆន្ទៈជាដើម , និងបាបធម៌ទាំងឡាយដែលតាំងនៅក្នុងចិត្តប្បាទជាមួយនីវរណៈនោះ គឺជាធម្មជាតិដែលល្អិតសុខុម ស្ងប់និងប្រណីត ព្រោះព្រះយោគីជាអ្នកប្រកបព្រមដោយធម៌ទាំងឡាយមានសទ្ធាជាដើម ដែលមានសភាវៈក្លាហាន ផូរផង់ និងក្លៀវក្លាជាងកាមាវចរធម៌ទាំងឡាយ ដូចជាធម៌ទាំងឡាយ មានវិតក្កជាដើម ដែលសម្រេចភាពជាភាវនាពិសេស បានយ៉ាងនោះឯង , រីឯ ទុតិយជ្ឈានជាដើម រមែងជាធម្មជាតិដែលដល់នូវភាវៈល្អិតសុខុម និងល្អិតសុខុមក្រៃលែងឡើងជាដើម ប្រសើរក្រៃលែងជាងបឋមជ្ឈាននោះ ដោយការលះអង្គគ្រោតគ្រាតបាន ដោយភាពពិសេសនៃភាវនាយ៉ាងណា , អរូបាវចរជ្ឈានទី ១ ក៏ដូច្នោះ កាលប្រព្រឹត្តទៅដោយភាពជាភាវនាលះបង់នូវរូប ក៏ជាធម្មជាតិដែលដល់នូវសេចក្តីស្ងប់សុខុម ជាងរូបាវចរធម៌ទាំងពួង ដូចជាការដល់នូវសេចក្តីស្ងប់ សុខុមជាងកាមាវចរធម៌តាមប្រក្រតីទាំងឡាយដូច្នោះ ព្រោះការមានអារម្មណ៍ស្ងប់ ព្រោះការមានអង្គស្ងប់ ។ ព្រោះការមានអារម្មណ៍ស្ងប់ ធម៌ទាំងឡាយ ( ដែលទាក់ទងនៅក្នុងអរូបាវចរជ្ឈាន ទី ១ ) ដែលមានអារម្មណ៍ស្ងប់នោះ ជាអារម្មណ៍ រមែងជាធម្មជាតិដែលមានសភាវៈស្ងប់ , ដូចធម៌ទាំងឡាយ មានលោកុត្តរធម៌ជាអារម្មណ៍ដូច្នោះ។ ម្យ៉ាងទៀត អរូបាវចរជ្ឈានសូម្បីមិនមានភាពផ្សេងគ្នាពីរូបាវចរជ្ឈានទី ៤ ដោយធម៌ ព្រោះជាមហគ្គតធម៌ដូចគ្នា ក៏ឈ្មោះថា ស្ងប់ជាង ទោះបីដោយអង្គ , គឺជាអង្គស្ងប់ ដែលជាហេតុឲ្យទ្រង់ត្រាស់ដល់ភាពជាសន្តវិមោក្ខ ។ ចំណែករូបាវចរជ្ឈានទី ២ ជាដើម ឈ្មោះ

ថា ដល់នូវភាពស្ងប់ក្រៃលែង ស្ងប់ជាទីបំផុត ជាងអរូបជ្ឈានទី ១ ជាដើម ដោយអង្គ និងដោយអារម្មណ៍ ព្រោះប្រកបព្រមដោយភាពវិសេសនៃភាវនា តាមប្រការដែលពោលហើយនោះឯង ភាពពិសេសនៃភាវនានោះ កាលនឹងធ្វើឈាននោះៗ ឲ្យដល់នូវភាពស្ងប់សុខុម ដោយអំណាចការឈានកន្លងធម៌ ដែលគប្បីលះបង់នោះៗ ចាប់តាំងពីឧបចារៈនៃបឋមជ្ឈានទៅ ក៏ធ្វើឲ្យសម្រេចនូវភាពជាសេស-សង្ខារដ៏ល្អិតក្នុងអរូបទី ៤ ។ ហេតុដែលឲ្យអរូបទី ៤ ប្រព្រឹត្តទៅដោយខ្លួនឯងក្នុងអរូបធម៌ទី ៣ ទាំងឡាយ ( ដោយការធ្វើឲ្យជាអារម្មណ៍ ) រមែងមិនអាចធ្វើឲ្យធម៌ទាំងឡាយនោះ ជាក់ច្បាស់តាមសេចក្តីពិត ដូចជាឈានដទៃក្រៅពីឈានទី ៤ នោះ ដែលអាចធ្វើអារម្មណ៍របស់ខ្លួនឲ្យប្រាកដច្បាស់តាមសេចក្តីពិតបាន ដូចភាពដែលមិនជាបច្ច័យ ដើម្បីការចូលដល់ភាពជាអារម្មណ៍របស់វិបស្សនា ដោយទាក់ទងនឹងការពិចារណាឃើញធម៌ ទៅតាមលំដាប់បទហើយ ទើបកើតនិព្វិទាញាណរបស់ព្រះយោគាវចរ ដែលជាអ្នកចម្រើនវិបស្សនា តាមប្រក្រតី ព្រោះការដល់នូវភាពជាសេសសង្ខារដ៏សុខុមនោះ ។ អរូបជ្ឈានទី ៤ នោះ មានត្រឹមតែជាការប្រារព្ធប្រព្រឹត្តទៅក្នុងអរូបទី ៣ នោះ តែម្យ៉ាងប៉ុណ្ណោះ , អរូបជ្ឈានទី ៤ នោះ ឈ្មោះថា មិនល្មមដើម្បីធ្វើជាទីតាំង ដោយអាការប្រាកដច្បាស់ សូម្បីជាអារម្មណ៍នឹងល្មមដើម្បីធ្វើឲ្យជាអារម្មណ៍បានដូចម្តេច ? ។ ព្រោះដូច្នោះ ព្រះសាស្តាទ្រង់សម្លឹងឃើញកិច្ច ដែលមិនប្រាកដច្បាស់នៃអរូបជ្ឈានទី ៤ នោះ , កាលទ្រង់ធ្វើអាការនៃភាវនាទុកក្នុងឋានៈ ៣ ខាងក្រោមហើយ ទ្រង់បំណងសម្តែងថា អាការនៃភាវនាដែលដូច្នោះ រមែងមិនមានក្នុងអរូបជ្ឈានទី ៤ នេះ ទើបទ្រង់មិនត្រាស់អាការនៃភាវនាទុកក្នុងព្រះសូត្រ ក្នុងទេសនាក្នុងអរូបជ្ឈានទី ៤ ព្រោះ ជាទេសនា

ដោយបរិយាយ ។

តែព្រោះហេតុដែលអាការប្រព្រឹត្តទៅក្នុងអារម្មណ៍ រមែងមានចំពោះធម៌ដែលមានអារម្មណ៍នោះឯង ព្រោះហេតុនោះ ទ្រង់បំណងសម្ដែងការៈដែលអរូបជ្ឈានទី ៤ ដល់នូវភាពជាធម្មជាតិសុខុមយ៉ាងក្រៃលែងនោះ ទើបត្រាស់ទុកក្នុងបករណ៍វិភង្គថា “ រមែងធ្វើទុកក្នុងចិត្ត នូវអាកិញ្ចញ្ញាយតនៈនោះឯងថា ជាធម្មជាតិស្ងប់ ” , ក្នុងវេលាដែលទ្រង់ត្រាស់ទុកក្នុងព្រះវិភង្គថា “ រមែងធ្វើទុកក្នុងចិត្ត ជាធម៌ដែលស្ងប់ ” ដោយជាពាក្យប្រៀនប្រដៅតាមសមគួរដល់ធម៌ , ឬ ទាក់ទងដល់ការចម្រើនជាខាងដើម , គប្បីឃើញថា ក្នុងពេលនោះ ទ្រង់ត្រាស់ពាក្យនោះទុក ក៏ព្រោះ អរូបជ្ឈានទី ៤ នោះ ប្រាកដច្បាស់ដល់ព្រះយោគី ។ ឯក្នុងព្រះសូត្រទ្រង់មិនត្រាស់យកអាការនៃភាវនា ដោយទាក់ទងនឹងអប្បនា ក៏ព្រោះការដែលមិនប្រាកដច្បាស់ ។ ពិតហើយ កម្មដ្ឋានខ្លះ ជាធម្មជាតិមិនប្រាកដច្បាស់ក្នុងខាងដើម ដូចជាពុទ្ធានុស្សតិជាដើម ។ ខ្លះជាធម្មជាតិមិនប្រាកដច្បាស់ត្រង់កណ្ដាល ដូចជាអានាបានស្សតិ ។ ខ្លះជាធម្មជាតិមិនប្រាកដច្បាស់ក្នុងវារៈទាំង ២ ដូចជាឧបសមានុស្សតិ ជាដើម ។ ចំណែកអរូបកម្មដ្ឋានទី ៤ ជាធម្មជាតិមិនប្រាកដច្បាស់ក្នុងទីបំផុត ព្រោះក្នុងកាលដែលភាវនាដល់កំពូល អារម្មណ៍មិនជាធម្មជាតិដែលប្រាកដច្បាស់ ។ ព្រោះដូច្នោះ បណ្ឌិតគប្បីសម្រេចចិត្តក្នុងរឿងនេះបានថា ព្រះសាស្ដាទ្រង់បំណងសម្ដែងប្រការដទៃ ក្នុងអរូបជ្ឈានទី ៤ , សេចក្ដីនេះ ទើបទ្រង់មិនកាន់យកអាការនៃភាវនាទុកក្នុងព្រះសូត្រ , មិនមែនទ្រង់មិនកាន់យក ព្រោះមិនមានដោយអាការទាំងពួងនោះទេ ។

( ចប់ មហាដីកា )

( ការអធិប្បាយ នេវសញ្ញានាសញ្ញាយតនៈ ចប់ដោយប្រការដូច្នេះ )

( អារុប្បនិទ្ទេស ៤ ចប់ដោយបរិបូរណ៍ )

# បកិណ្ណកកថា

ព្រោះលោកនាថ ដ៏មានព្រះរូបមិនមាននរណាប្រៀបផ្ទឹមដល់ ទ្រង់ត្រាស់អរូប ៤ ប្រការ ណាទុក បណ្ឌិតបានជ្រាបអរូប ៤ នោះ យ៉ាងនេះហើយ គប្បីយល់បកិណ្ណកកថា ក្នុងអរូបនោះទៀតខ្លះ ។

## អរូបកើតលំដាប់ ដោយកន្លងអារម្មណ៍ មិនមែនដោយកន្លងអង្គ

អរូបសមាបត្តិទាំងឡាយនេះ សូម្បីមាន ៤ ដោយការឈានកន្លងអារម្មណ៍ អ្នកប្រាជ្ញទាំងឡាយ មិនបានត្រូវការដោយការឈានកន្លងអង្គនៃសមាបត្តិនោះទេ ។

ពិតហើយ អរូបសមាបត្តិទាំងឡាយនេះ គប្បីជ្រាបថា សូម្បីមាន ៤ ដោយការកន្លងអារម្មណ៍គ្រប់ប្រការ គឺ ក្នុងសមាបត្តិ ៤ នោះ សមាបត្តិទី ១ មានដោយការកន្លងរូបនិមិត្ត , ទី ២ ដោយការឈានកន្លងអាកាស , ទី ៣ ដោយការឈានកន្លងវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាស , ទី ៤ ដោយការឈានកន្លងការប្រាសទៅនៃវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាស តែបណ្ឌិតទាំងឡាយមិនត្រូវការ ការឈានកន្លងអង្គនៃសមាបត្តិទាំងឡាយនោះ ព្រោះការឈានកន្លងអង្គក្នុងសមាបត្តិទាំងឡាយនោះ មិនមានដូចក្នុងរូបាវចរសមាបត្តិទាំងឡាយទេ ព្រោះក្នុងសមាបត្តិទាំងឡាយនោះ គ្រប់ប្រការ មានអង្គឈានត្រឹមតែ ២ ប៉ុណ្ណោះ គឺ ឧបេក្ខា ចិត្តេកគ្គតា ។

# អរូបប្រណីតជាងគ្នា
# ព្រោះអង្គប្រណីតចូលដល់តាមលំដាប់

កាលបើដូច្នេះ ក្នុងអរូបសមាបត្តិនេះ សមាបត្តិបទក្រោយៗ ប្រណីតជាងសមាបត្តិបទមុនៗ បណ្ឌិតគប្បីជ្រាបរឿងផ្ទៃប្រាសាទ និងសំពត់ ជាឧបមាក្នុងការប្រណីតជាងគ្នានោះ ៖

ដូចជា ក្នុងផ្ទៃក្រោមនៃប្រាសាទ ៤ ជាន់ បញ្ចកាមគុណប្រណីតដោយអំណាចគ្រឿងបម្រើ មានការរាំ ច្រៀង និង ប្រគុំដន្ត្រី គ្រឿងក្រអូប និង ក្បួនផ្កា ឈើក្រអូប ភោជន ទីដេក និង គ្រឿងស្លៀកដណ្តប់ ( ដូចជា ) របស់ទិព្វជាដើម ម្នាក់ៗថា ជាវត្ថុបាត់ទុកថាគ្រប់ , តែនៅជានទី ២ បញ្ចកាមគុណប្រណីតជាងជាន់ក្រោមនោះ , ក្នុងជាន់ទី ៣ ប្រណីតជាងនោះ , ក្នុងជាន់ទី ៤ ប្រណីតជាងគេទាំងអស់ , ក្នុងការឧបមានោះ ជាន់ទាំង ៤ នោះ ជាផ្ទៃប្រាសាទដូចគ្នា ការផ្សេងគ្នានៃផ្ទៃប្រាសាទទាំង ៤ ជាន់នោះ មិនមានក៏ពិត សូម្បីដូច្នោះ ផ្ទៃជាន់លើ ក៏ប្រណីតជាងជាន់ក្រោម ដោយមានការសម្បូរណ៍នៃបញ្ចកាមគុណផ្សេងគ្នាយ៉ាងណា , ម្យ៉ាងទៀត សំពត់ ( សាច់ខ្វះទម្ងន់ស្រាល ) ប្រភេទចតុបលៈ (ទម្ងន់ ៤ បលៈ ) និង ប្រភេទតិបលៈ ( ទម្ងន់ ៣ បលៈ ) , ទ្វិបលៈ ( ទម្ងន់ ២ បលៈ ) , ឯកបលៈ ( ទម្ងន់ ១ បលៈ ) ដែលប្រណីតជាងគ្នាដោយអំណាចនៃ ( ប្រភេទទាំង ៤ គឺ ) គ្រោតគ្រាត ល្អិត ល្អិតជាង និង ល្អិតបំផុត ដែលស្ត្រីម្នាក់ត្បាញទុក ម្នាក់ៗថា ជាសំពត់មានខ្នាតប៉ុនគ្នា ទាំងបណ្តោយ និង ទទឹងក្នុងការឧបមានោះ សំពត់ ៤ ប្រភេទ នោះ មានខ្នាតប៉ុនគ្នា ទាំងដោយទទឹង និង

ដោយបណ្តាយ ភាពផ្សេងគ្នានៃឋានរបស់សំពត់នោះ មិនមានក៏ពិត តែថា សំពត់ក្រោយៗ ប្រណីតជាងសំពត់មុនៗ ដោយមានសម្ផស្សទន់ល្មើយ សាច់ល្អិត និងការមានតម្លៃខ្ពស់ យ៉ាងណា សូម្បីក្នុងអរូបសមាបត្តិទាំង ៤ ក៏មានអង្គ ២ គឺ **ឧបេក្ខា ចិត្តេកគ្គតា** នេះដោយពិត សូម្បីដូច្នោះ បណ្ឌិតគប្បីជ្រាបចុះថា ក្នុងសមាបត្តិនេះ សមាបត្តិក្រោយៗ រមែងប្រណីតជាង ដោយការប្រណីត និងប្រណីតជាងគ្នានៃអង្គទាំងឡាយនោះ ដោយភាពពិសេស ( ជាងគ្នា ) នៃភាវនាដូច្នោះដូចគ្នា , អរូបសមាបត្តិទាំងឡាយនោះ ប្រណីត និងប្រណីតជាងទៅតាមលំដាប់ ដោយប្រការដូច្នេះ ។

## អរូប ៤ ឧបមាដូចបុរស ៤ នាក់

បុរសម្នាក់មកតោងមណ្ឌបត្រង់ទីដែលមិនស្អាត បុរសម្នាក់ទៀត មកតោងបុរសនោះ បុរសម្នាក់ទៀត មកមិនតោងទេ តែឈរនៅខាងក្រៅ និង បុរសម្នាក់ទៀត មកឋិតនៅអាស្រ័យនឹងបុរសដែលនៅខាងក្រៅនោះ អរូបសមាបត្តិទាំង ៤ អ្នកប្រាជ្ញគប្បីជ្រាបដោយភាពជាធម្មជាតិ ដូចបុរស ៤ នាក់ នោះតាមលំដាប់ចុះ ។

តទៅនេះ ជាពាក្យប្រកបសេចក្តីក្នុងឧបមានោះ រឿងមានមកថា មានមណ្ឌប ១ ខ្នង នៅក្នុងទីដែលមិនស្អាត កាលនោះ បុរសម្នាក់មកក្នុងទីនោះ ខ្ពើមទីដែលមិនស្អាតនោះ ទើបតោងមណ្ឌបនោះដោយដៃទាំង២ តោងមណ្ឌបនោះ ដូចព្យួរទុកក្រោយមក មានបុរសម្នាក់ទៀត មកអាស្រ័យ ( តោង ) បុរសដែលតោងមណ្ឌបនោះ , បុរសម្នាក់ទៀត មកដល់ គិតថា “ បុរសនេះតោងមណ្ឌប ហើយអ្នកដែលអាស្រ័យនឹងបុរសនេះក្តី ទាំងពីរនាក់នេះនៅដោយលំបាក ហើយការធ្លាក់ចុះទៅ

ក្នុងមណ្ឌប នឹងមានដល់គេទាំងពីរនោះជាប្រាកដ ណ្ហើយចុះ យើងនឹងនៅខាងក្រៅល្អ ដូច្នេះហើយ គេមិនតោងបុរស ដែលតោងបុរសជំបូងនោះទេ ក៏ឈរនៅខាងក្រៅនោះទៅ ឯបុរសម្នាក់ទៀតមក សម្គាល់ឃើញបុរសនោះថា ការមិនរួចភ័យនៃបុរសដែលតោងមណ្ឌប និង បុរសដែលតោងបុរសតោងមណ្ឌបនោះផង , បុរសដែលឈរនៅខាងក្រៅនោះល្អ ទើបអាស្រ័យនឹងបុរសដែលនៅខាងក្រៅនោះឯង ។

កសិណុគ្ឃាដិមាកាស ( អាកាសត្រង់បើកកសិណ ) បណ្ឌិតគប្បីឃើញដូចមណ្ឌប នៅត្រង់ទីមិនស្អាត ក្នុងពាក្យឧបមានោះ , អាកាសានញ្ចាយតនៈដែលមានអាកាសជាអារម្មណ៍ ព្រោះខ្ពើមនូវរូបនិមិត្ត គប្បីឃើញដូចបុរសដែលតោងមណ្ឌប ព្រោះខ្ពើមទីមិនស្អាត , វិញ្ញាណញ្ចាយតនៈ ដែលប្រារព្ធអាកាសានញ្ចាយតនៈ ដែលមានអាកាសជាអារម្មណ៍ប្រព្រឹត្តទៅ គប្បីឃើញដូចបុរសដែលតោងបុរសអ្នកតោងមណ្ឌបនោះ , អាកិញ្ចញ្ញាយតនៈ ដែលមិនធ្វើអាកាសានញ្ចាយតនៈឲ្យជាអារម្មណ៍ មានការមិនមានវិញ្ញាណនោះ ជាអារម្មណ៍ គប្បីឃើញដូចបុគ្គលដែលគិត ( ឃើញ ) ការមិនរួចភ័យនៃបុរសទាំង ២ នោះ ទើបមិនតោងបុរសដែលតោងមណ្ឌបនោះ ក៏ឈរនៅខាងក្រៅ , នេវសញ្ញានាសញ្ញាយតនៈដែលប្រារព្ធអាកិញ្ចញ្ញាយតនៈ ដែលតាំងនៅខាងក្រៅ បានដល់ ការមិនមាននៃវិញ្ញាណដែលប្រព្រឹត្តទៅ គប្បីឃើញដូចអ្នកសម្គាល់ ដល់មនុស្សដែលគិតឃើញការមិនរួចភ័យ នៃបុរសដែលតោងមណ្ឌប និងបុគ្គលដែលអាស្រ័យ , បុរសនោះដែលឈរនៅខាងក្រៅនោះឯងថា ជាវិធីល្អ ទើបអាស្រ័យនឹងបុរសនោះទៅ , នេវសញ្ញានាសញ្ញាយតនៈនេះ កាលប្រព្រឹត្តទៅយ៉ាងនោះ **ចាំបាច់ត្រូវធ្វើអាកិញ្ច-**

**ញ្ញាយតនៈនោះ ឲ្យជាអារម្មណ៍ ព្រោះមិនមានអារម្មណ៍ដទៃ ដូច ( ប្រជាជន ) ចាំបាច់ត្រូវអាស្រ័យព្រះរាជា សូម្បីមានការមិនល្អប្រាកដ ប្រព្រឹត្តទៅ ព្រោះការចិញ្ចឹមជីវិត ជាហេតុដូច្នោះ** , អធិប្បាយសេចក្តីថា នេវសញ្ញានាសញ្ញានេះ ចាំបាច់ត្រូវធ្វើអាកិញ្ចញ្ញាយតនៈ ដែលមានទោសឃើញហើយ “ សមាបត្តិនោះ មានសត្រូវគឺ វិញ្ញាណញ្ចាយតនៈនៅជិត ” ដូច្នេះ ឲ្យជាអារម្មណ៍ ព្រោះមិនមានអារម្មណ៍ដទៃ ប្រៀបដូចអ្វី ? ប្រៀបដូចប្រជាជនចាំបាច់ត្រូវអាស្រ័យព្រះរាជា សូម្បីមានការមិនល្អប្រាកដ ព្រោះការចិញ្ចឹមជីវិតជាហេតុដូច្នោះ , អធិប្បាយថា ប្រជាជនកាល មិនបានការចិញ្ចឹមជីវិតក្នុងប្រទេសដទៃ ក៏ចាំបាច់ត្រូវអាស្រ័យព្រះរាជា ១ អង្គ ដែលទ្រង់មិនសង្រួម ( ក្នុងសីល ) មានការប្រព្រឹត្តតាមផ្លូវកាយផ្លូវចិត្តគ្រោតគ្រាត សូម្បីឃើញការមិនល្អដែលនរណាៗ ឃើញថា ព្រះរាជានេះ ជាអ្នកមានការប្រព្រឹត្តគ្រោតគ្រាត ដូច្នេះ មានប្រាកដ ព្រោះការចិញ្ចឹមជីវិតជាហេតុយ៉ាងណា នេវសញ្ញានាសញ្ញាយតនៈ កាលមិនបានអារម្មណ៍ដទៃ ក៏ចាំបាច់ត្រូវធ្វើអាកិញ្ចញ្ញាយតនៈ ទោះឃើញទោសមានប្រាកដហើយ ឲ្យជាអារម្មណ៍ក៏ដូច្នោះដូចគ្នា ឯនេវសញ្ញានាសញ្ញាយតនៈ កាលធ្វើយ៉ាងនោះ ៖

ក៏រមែងអាស្រ័យ ( អាកិញ្ចញ្ញាយតនៈ ) ឈាននោះ ប្រព្រឹត្តទៅ ( ព្រោះមិនមានអ្វីត្រូវអាស្រ័យ ) ដូចជាបុគ្គលឡើងលើជណ្តើរវែង ( ឡើងដល់លើហើយ ) ក៏រមែងកាន់ក្បាលជណ្តើរ ( ព្រោះមិនមានអ្វីកាន់ ) និងដូចបុគ្គលឡើងភ្នំ ហើយក៏ឈរនៅលើកំពូល ( ព្រោះមិនមានអ្វីកាន់ ) ឬ ដូចបុគ្គលឡើងភ្នំ ( ថ្មប៉ប្រះទឹក ) ដល់កំពូលហើយ ក៏ជ្រែងជង្គង់ទប់ខ្លួន ( ព្រោះមិនមានអ្វីកាន់ ) ដូច្នោះឯង ។

# មហាដីកា

ពាក្យថា **មានព្រះរូបកាយរកអ្នកប្រៀបមិនបាន** គឺ មានព្រះរូបកាយដែលមិនសាធារណៈដល់បុគ្គលដទៃ ដោយគុណនៃរូបទាំងឡាយ មានព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ ព្រះអនុព្យញ្ជនៈ ៨០ ប្រការ ព្រះកេតុមាលាដែលមានព្រះរស្មីផ្សាយទៅប្រមាណ ១ ព្យាម ជាដើម , ន័យម្យ៉ាងទៀត ស័ព្ទថា **រូប** មានអត្ថថា សភាវៈ ដូចក្នុងប្រយោគថា “ សភាវៈដែលគួរស្រឡាញ់ សភាវៈដែលគួរគ្រេកអរ ក្នុងលោក ” ដូច្នេះជាដើម ។ ព្រោះដូច្នោះ បទថា **អសទិសរូបោ** ប្រែថា ដែលមានសភាវៈរកអ្នកស្មើមិនបាន , ដោយពាក្យនោះ លោកអាចារ្យសម្ដែងដល់ទ្រង់ជាបុគ្គលរកអ្នកស្មើមិនបាន សូម្បីដោយព្រះធម្មកាយសម្បត្តិដោយការសម្ដែងការប្រកបត្រូវ ក្នុងគុណវិសេសទាំងឡាយ មានព្រះទសពលញ្ញាណ ព្រះចតុវេសារជ្ជញ្ញាណជាដើមនៃព្រះសាស្ដា ។ ស័ព្ទថា **ឥតិ** ប្រែថា យ៉ាងនេះ ដូចប្រការដែលពោលហើយ ។ បទថា **តស្មិំ** បានដល់ ក្នុងអរូប ។ ពាក្យថា **គប្បីជ្រាបបកិណ្ណកកថាខ្លះ** គឺ កុំកាន់យកអត្ថដែលមិនសាធារណៈ គឺ ប្រចាំដោយចំពោះក្នុងឈាននោះៗ ដូចក្នុងខាងដើមប៉ុណ្ណោះ គប្បីជ្រាបបកិណ្ណកកថាដែលប្រព្រឹត្តទៅ កាន់យកអត្ថ ដែលជាបកិណ្ណកៈ គឺ រាយរង នៅក្នុងឈាននោះៗ ឯងចុះ ដោយអត្ថសាធារណៈខ្លះ ។

ពាក្យថា **ដោយការឈានកន្លងរូបនិមិត្ត** គឺ ដោយការឈានកន្លងបដិភាគនិមិត្ត ដែលហៅថា កសិណរូប ។ ពាក្យថា **ដោយការឈានកន្លងអាកាស** គឺ ដោយការឈានកន្លងកសិណុគ្ឃាដិមាកាស ( អាកាសបានពីការបើកកសិណ ) ។

ពាក្យថា **ដោយការឈានកន្លងវិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាស** គឺ ដោយការឈានកន្លងអរូបវិញ្ញាណទី ១ , មិនមែនដោយការឈានកន្លងអរូបវិញ្ញាណទី ២ ទេ , ព្រោះថា ការធ្វើអរូបវិញ្ញាណទី ៣ នោះឯង ឲ្យប្រាកដ រមែងសម្រេចបានដោយការឈានកន្លងអរូបវិញ្ញាណទី ១ នោះ ។ ឯក្នុងការធ្វើអរូបវិញ្ញាណទី ២ ឲ្យប្រាកដ អរូបវិញ្ញាណទី ១ នោះឯង គប្បីឈានកន្លងទៅ មិនមែនអារម្មណ៍របស់អរូបទី ១ នោះទេ , តែថា ការឃើញទោសក្នុងអារម្មណ៍ហើយ ឈានកន្លងវត្ថុដែលមិនមែនអារម្មណ៍ ដើម្បីការធ្វើឲ្យប្រាកដរមែងមិនត្រឹមត្រូវ ។ ក្នុងព្រះបាលីបានត្រាស់ទុកថា “ ភិក្ខុជាអ្នកមានសតិ ចូលវិញ្ញាណញ្ចាយតនសមាបត្តិ ។ ល ។ ជាអ្នកមានសតិ ចេញហើយ ធ្វើវិញ្ញាណនោះឯង មិនឲ្យមាន ” ដូច្នេះ , មិនបានត្រាស់ទុកថា “ ធ្វើវិញ្ញាណញ្ចាយតនសមាបត្តិនោះឯង មិនឲ្យមាន ” ឬថា “ ធ្វើសមាបត្តិនោះឯង មិនឲ្យមាន ” ដូច្នេះទេ ។ ចំណែកពាក្យថា កាលធ្វើទុកក្នុងចិត្តយ៉ាងនេះថា “ វិញ្ញាណមិនមានទីបំផុត ដូច្នេះ ក៏ចូលដល់វិញ្ញាណញ្ចាយតនៈ ” គឺ ទ្រង់ត្រាស់ដល់ធម្មជាតិ ២ យ៉ាង គឺ វិញ្ញាណដែលជាអារម្មណ៍ និងវិញ្ញាណញ្ចាយតនជ្ឈាន ។ ភិក្ខុដែលចេញចាក ( សមាបត្តិ ) ដោយធម្មជាតិទាំង ២ នោះណាមួយ ឬចាកធម្មជាតិទាំង ២ នោះ ណាមួយ , ព្រោះហេតុនោះ ដោយព្រះតម្រាស់សម្តែងអធិប្បាយទុកក្នុងបករណ៍បដ្ឋាន ពាក្យថា **វិញ្ញាណំ** នៅក្នុងទីនេះនៅជិតគ្នានឹងសម្ពន្ធស័ព្ទថា **តំ** ( **តំ យេវ វិញ្ញាណំ អភាវេតិ** ) ត្រាស់ទុកដើម្បីបដិសេធវិញ្ញាណញ្ចាយតនៈថា “ ក៏សមាបត្តិនេះ ជាភាវនាឈានកន្លងអារម្មណ៍ ) ដូច្នេះ ។ ព្រោះដូច្នោះ គឺជាការត្រាស់ដល់ការឈានកន្លង គឺ ការធ្វើអរូបវិញ្ញាណទី ១ មិនឲ្យមាននោះឯង ។

ពាក្យថា **សូម្បីជាយ៉ាងនេះ** គឺ សូម្បីមិនមានការឈានកន្លងអង្គ ។ បទថា **សុប្បណីតតរា** គឺ ជាធម្មជាតិដែលប្រណីតជាង មានន័យថា ជាធម្មជាតិដែលល្អ និង ប្រណីតជាង ។ ដោយពាក្យថា “ ដូចជា ” ជាដើម លោកអាចារ្យសម្តែងសេចក្តីប្រការនេះថា សូម្បីកាលសមាបត្តិ ៤ ទាំងនេះ មានការស្មើគ្នាដោយភាពជាអរូប និង ដោយអង្គ សូម្បីដូច្នោះ ក៏នៅមានការប្រណីតជាងគ្នាឡើងតាមលំដាប់ ដែលសម្រេចហើយតាមភាពវិសេសនៃភាវនា ដូចកាលផ្ទៃប្រាសាទទាំង ៤ និង សំពត់ ៤ ផ្ទាំង មានការស្មើគ្នា ដោយភាពជាផ្ទៃប្រាសាទ ( ដូច )គ្នា , និង ជាសំពត់មានខ្នាតប៉ុនគ្នា សូម្បីដូច្នោះ ក៏នៅមានការប្រណីតជាងគ្នាជាដើម ដែលទាក់ទងជាមួយកាមគុណ និងសម្ផស្សដែលទន់ល្មើយជាដើមក្រៃលែងឡើងទៅ ដូច្នេះឯង ។

ពាក្យថា **អាស្រ័យ ( បុរសដែលតោងមណ្ឌប )** គឺ ទីអាស្រ័យហើយស្ថិតនៅ ។ ពាក្យថា **តាំងនៅមិនបានល្អ** គឺ មិនតាំងនៅបានដោយប្រពៃ , ឬថាលំបាកឈរ ។ បទថា **តំនិស្សិតំ** មានន័យថា ស្ថានទីដែលបុរសនោះតោង ។ម្យ៉ាងទៀត បទថា **តំនិស្សិតំ** មានន័យថា ( គេមិនអាស្រ័យ ) បុរសដែលអាស្រ័យនឹងបុរសដែលតោងមណ្ឌបនោះ ។ ពិតណាស់ ការដែលអរូបវិញ្ញាណទី ៣ តាំងនៅក្នុងភាពទទេ ប្រាសចាកវិញ្ញាណដែលអាស្រ័យអាកាស គឺ ក្នុងការប្រាសទៅនៃវិញ្ញាណនោះ ក៏ប្រៀបដូចបុរសទី ៣ ឈរនៅក្នុងឱកាសខាងក្រៅដែលជាទីប្រាសចាកបុរសដែលតោងមណ្ឌបនោះ មិនអាស្រ័យបុរសអ្នកតោងមណ្ឌបដូច្នោះ នោះឯង ។

ពាក្យថា **នេវសញ្ញានាសញ្ញាយតនៈនេះ ព្រោះមិនមានអារម្មណ៍ដទៃ ទើប**

**ចាំបាច់ធ្វើអាកិញ្ចញ្ញាយតនៈនោះឲ្យជាអារម្មណ៍** មានន័យថា នេវសញ្ញានាសញ្ញា-យតនៈនេះ ព្រោះមិនមាន គឺ ព្រោះមិនបានវត្ថុដែលសមគួរដល់ភាពជាអារម្មណ៍យ៉ាងដទៃ ដូច្នេះ ទើបធ្វើអាកិញ្ចញ្ញាយតនៈនោះ សូម្បីបានឃើញទោសហើយ ថា “ ជាវិញ្ញាណដែលមានសត្រូវ គឺ វិញ្ញាណញ្ចាយតនៈនៅជិត និង មានការប្រាសទៅនៃវិញ្ញាណដួងទី ១ ដែលធ្វើអាកាស ដែលនៅជិតចំពោះរូប ឲ្យជាអារម្មណ៍ , និងស្ងប់ដូចនេវសញ្ញានាសញ្ញាយតនៈ ក៏ទេ ” ដូច្នេះ ឲ្យជាអារម្មណ៍នោះឯង ។ ពាក្យថា **អ្នកជាធំក្នុងទ្វីបទាំងពួងនេះ** លោកពោលទុកដើម្បីសម្តែងភាពដែលពួកជន ( អ្នកបំណងដើម្បីចិញ្ចឹមជីវិត ) ជាអ្នកដែលមិនមានទីដទៃត្រូវទៅ ។ បទថា **វុត្តិ** ប្រែថា ការចិញ្ចឹមជីវិត ។ ពាក្យថា **ប្រព្រឹត្តទៅ** គឺ មានជីវិតរស់នៅ ។

ក្នុងបាទព្រះគាថា មានបទថា **អារុឡ្ហា** ជាដើម មានសេចក្តីសង្ខេបដូចតទៅនេះ ប្រៀបដូចថា បុរសខ្វះឡើងលើជណ្តើរវែង គឺ ខ្ពស់ច្រើនជួរបុរសឈរនៅលើជណ្តើរនោះហើយ ក៏រមែងតោងក្បាលជណ្តើរនោះ ប៉ុណ្ណោះឯង ព្រោះមិនមានអ្វីតោង យ៉ាងណា និងប្រៀបដូចជាបុគ្គលដែលឡើងលើកំពូលភ្នំដីសុទ្ធ ឬថាភ្នំដីលាយដោយថ្ម ក៏រមែងតោងតែកំពូលនោះប៉ុណ្ណោះ យ៉ាងណា និងប្រៀបដូចថា មនុស្សដែលឡើងភ្នំថ្មសុទ្ធ អង្គុញខ្លួន ព្រោះមិនមានវត្ថុដទៃ ( ដែលអាចតោងបាន ) ក៏រមែងជ្រែងជើងរបស់ខ្លួនទប់ប៉ុណ្ណោះ យ៉ាងណា អរូបជ្ឈានទី ៤ នេះ ក៏រមែងតោងយកអរូបជ្ឈានទី ៣ នោះ ប្រព្រឹត្តទៅ ដូច្នោះ ដូចគ្នានោះឯង ។ ក្នុងអធិការនេះ នៅមានពាក្យណាដែលខ្ញុំម្ចាស់ចែកទុកដោយអត្ថ ពាក្យនោះងាយទាំងអស់ហើយ ។

# បរិច្ឆេទទី ១០

## ឈ្មោះ អារុប្បនិទ្ទេស ក្នុង

## អធិការនៃសមាធិការនានៃបករណ៍វិសេស ឈ្មោះ វិសុទ្ធិមគ្គ

## ដែលខ្ញុំម្ចាស់ធ្វើដើម្បីប្រយោជន៍ដល់សេចក្តីបាមោជ្ជនៃសាធុជន ដូច្នេះឯង ។